# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ភាគ ២១

## តិកនិបាត

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងតិកនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ

ព្រះអដ្ឋកថាកែសេចក្តី ១៦២ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ភាគ ៤១

## តិកនិបាត

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងតិកនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ

ព្រះអដ្ឋកថាកែសេចក្តី ១៤២ សូត្រ

# អង្គុត្តរនិកាយ តិកនិបាត
## រួមមាន
## ៣ បណ្ណាសកៈ និង ១៥ វគ្គ
## ព្រះអដ្ឋកថាកែសេចក្ដី ១៤២ សូត្រ

### បឋមបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ | ពាលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៧ សូត្រ |
| ២ | រថការវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៣ | បុគ្គលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៤ | ទេវទូតវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៩ សូត្រ |
| ៥ | ចូឡវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្ដី ១១ សូត្រ |

### ទុតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ | ព្រាហ្មណវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ២ | មហាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៣ | អានន្ទវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៤ | សមណវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្ដី ១១ សូត្រ |
| ៥ | លោណផលវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្ដី ១១ សូត្រ |

### តតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ | សម្ពោធិវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៩ សូត្រ |
| ២ | អាបាយិកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៩ សូត្រ |
| ៣ | កុសិនារវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៩ សូត្រ |
| ៤ | យោធាជីវវគ្គ | មាន ១៣ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៥ | មង្គលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៥ សូត្រ |

និងអដ្ឋកថាដែលមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

# ស្រៈនិងសញ្ញា

## *Signes et accents:*



# ស្រៈពេញតួ
# Voyelles.



# ព្យញ្ជនៈ

# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្ក Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ក Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | c | ch | j | jh | ñ |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម<br>Romain | c | ch | j | jh | ñ |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ហ<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡូម Romain | c | ch | j | jh | ñ |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ဉ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី*

រិកកាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ **ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុញ្ញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដកពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្ញាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសជ្រាវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋៈ ) ខ្វះ ( សិរិក្កូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទួន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម វ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ដុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ឡូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក ណាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ធិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ិត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីថាន

ឧបាសិកា ហាយ សា៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៉ូវ | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ-

ឧទ្ទិសថ្វាយ និងគោរពជូនៈ

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## តិកនិបាត បឋមបណ្ណាសកៈ


### ពាលវគ្គ ទី ១

| | | |
|---|---|---|
| អដ្ឋកថា ភយសូត្រ | ទី ១ | ១ |
| អដ្ឋកថា លក្ខណសូត្រ | ទី ២ | ៦ |
| អដ្ឋកថា ចិន្តិសូត្រ | ទី ៣ | ៨ |
| អដ្ឋកថា អច្ចយសូត្រ | ទី ៤ | ១០ |
| អដ្ឋកថា អយោនិសោសូត្រ | ទី ៥ | ១១ |
| អដ្ឋកថា ខតសូត្រ | ទី ៩ | ១៥ |
| អដ្ឋកថា មលសូត្រ | ទី ១០ | ១៦ |

### រថការវគ្គ ទី ២

| | | |
|---|---|---|
| អដ្ឋកថា ញាតកសូត្រ | ទី ១ | ១៨ |
| អដ្ឋកថា សារណីយសូត្រ | ទី ២ | ២២ |
| អដ្ឋកថា ភិក្ខុសូត្រ | ទី ៣ | ២៦ |
| អដ្ឋកថា ចក្កវត្តិសូត្រ | ទី ៤ | ៣៣ |
| អដ្ឋកថា បចេតនសូត្រ | ទី ៥ | ៤១ |
| អដ្ឋកថា អបណ្ណកសូត្រ | ទី ៦ | ៤៤ |
| អដ្ឋកថា អត្តសូត្រ | ទី ៧ | ៥៥ |
| អដ្ឋកថា ទេវសូត្រ | ទី ៨ | ៥៦ |
| អដ្ឋកថា បឋមចាបណិកសូត្រ | ទី ៩ | ៥៧ |
| អដ្ឋកថា ទុតិយចាបណិកសូត្រ | ទី ១០ | ៦១ |

### បុគ្គលវគ្គ ទី ៣

| | | |
|---|---|---|
| អដ្ឋកថា សមិទ្ធសូត្រ | ទី ១ | ៦៥ |
| អដ្ឋកថា គិលានសូត្រ | ទី ២ | ៦៧ |

| | | |
|---|---|---|
| អដ្ឋកថា សង្ខារសូត្រ | ទី ៣ | ៧១ |
| អដ្ឋកថា ពហុការសូត្រ | ទី ៤ | ៧៤ |
| អដ្ឋកថា វជិរូបមសូត្រ | ទី ៥ | ៧៧ |
| អដ្ឋកថា សេវិតព្វសូត្រ | ទី ៦ | ៨១ |
| អដ្ឋកថា ជិគុច្ឆិតព្វសូត្រ | ទី ៧ | ៨៤ |
| អដ្ឋកថា កូដភាណីសូត្រ | ទី ៨ | ៨៧ |
| អដ្ឋកថា អន្ធសូត្រ | ទី ៩ | ៩០ |
| អដ្ឋកថា អវកុជ្ជសូត្រ | ទី ១០ | ៩៣ |

**ទេវទូតវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា សព្រហ្មកសូត្រ | ទី ១ | ៩៨ |
| អដ្ឋកថា អានន្ទសូត្រ | ទី ២ | ១០៤ |
| អដ្ឋកថា សារីបុត្តសូត្រ | ទី ៣ | ១០៨ |
| អដ្ឋកថា និទានសូត្រ | ទី ៤ | ១១៣ |
| អដ្ឋកថា ហត្ថកសូត្រ | ទី ៥ | ១៤៥ |
| អដ្ឋកថា ទេវទូតសូត្រ | ទី ៦ | ១៥១ |
| អដ្ឋកថា បឋមរាជសូត្រ | ទី ៧ | ១៦៥ |
| អដ្ឋកថា សុខុមាលសូត្រ | ទី ៩ | ១៧៤ |
| អដ្ឋកថា អធិបតីសូត្រ | ទី ១០ | ១៩២ |

**ចូឡវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា សម្មុខីភាវសូត្រ | ទី ១ | ១៩៧ |
| អដ្ឋកថា តិដ្ឋានសូត្រ | ទី ២ | ១៩៩ |
| អដ្ឋកថា បច្ចយវត្តសូត្រ | ទី ៣ | ២០៩ |
| អដ្ឋកថា បរេសសូត្រ | ទី ៤ | ២១០ |
| អដ្ឋកថា បណ្ឌិតសូត្រ | ទី ៥ | ២១១ |
| អដ្ឋកថា សីលវន្តសូត្រ | ទី ៦ | ២១៤ |
| អដ្ឋកថា សង្ខតសូត្រ | ទី ៧ | ២១៦ |
| អដ្ឋកថា អសង្ខតសូត្រ | ទី ៨ | ២១៨ |

អដ្ឋកថា បត្តរាជសូត្រ ទី ៩ ២១៩
អដ្ឋកថា អាតប្បសូត្រ ទី ១០ ២២០
អដ្ឋកថា មហាចោរសូត្រ ទី ១១ ២២២

# ទុតិយបណ្ណាសកៈ

## ព្រាហ្មណវគ្គ ទី ១

អដ្ឋកថា បឋមជនសូត្រ ទី ១ ២២៥
អដ្ឋកថា ទុតិយជនសូត្រ ទី ២ ២២៨
អដ្ឋកថា ព្រាហ្មណសូត្រ ទី ៣ ២២៩
អដ្ឋកថា បរិព្វាជកសូត្រ ទី ៤ ២៣១
អដ្ឋកថា និព្វុតសូត្រ ទី ៥ ២៣២
អដ្ឋកថា បលោភសូត្រ ទី ៦ ២៣៣
អដ្ឋកថា វច្ឆគោត្តសូត្រ ទី ៧ ២៣៦
អដ្ឋកថា តិកណ្ណសូត្រ ទី ៨ ២៤១
អដ្ឋកថា ជាណុស្សោណិសូត្រ ទី ៩ ២៥៧
អដ្ឋកថា សង្គារវសូត្រ ទី ១០ ២៥៨

## មហាវគ្គ ទី ២

អដ្ឋកថា តិត្ថាយតនសូត្រទី ១ ២៧២
អដ្ឋកថា ភយសូត្រ ទី ២ ៣០១
អដ្ឋកថា វេនាគបុរសូត្រ ទី ៣ ៣០៤
អដ្ឋកថា សរភសូត្រ ទី ៤ ៣២៦
អដ្ឋកថា កាលាមសូត្រ ទី ៥ ៣៤៧
អដ្ឋកថា សាឡ្ហសូត្រ ទី ៦ ៣៥២
អដ្ឋកថា កថាវត្ថុសូត្រ ទី ៧ ៣៥៦
អដ្ឋកថា តិត្ថិយសូត្រ ទី ៨ ៣៦៩
អដ្ឋកថា មូលសូត្រ ទី ៩ ៣៧៧
អដ្ឋកថា ឧបោសថសូត្រ ទី ១០ ៣៨៣

## អានន្ទវគ្គ ទី ៣


| | | |
|---|---|---|
| អដ្ឋកថា ឆន្នសូត្រ | ទី ១ | ៤០៤ |
| អដ្ឋកថា អាជីវកសូត្រ | ទី ២ | ៤០៧ |
| អដ្ឋកថា សក្យមហានាមសូត្រ | ទី ៣ | ៤០៩ |
| អដ្ឋកថា និគណ្ឋសូត្រ | ទី ៤ | ៤១១ |
| អដ្ឋកថា និវេសកសូត្រ | ទី ៥ | ៤១៦ |
| អដ្ឋកថា បឋមភវសូត្រ | ទី ៦ | ៤១៨ |
| អដ្ឋកថា ទុតិយភវសូត្រ | ទី ៧ | ៤២០ |
| អដ្ឋកថា សីលព្វតសូត្រ | ទី ៨ | ៤២១ |
| អដ្ឋកថា គន្ធជាតសូត្រ | ទី ៩ | ៤២៣ |
| អដ្ឋកថា ចូឡនីសូត្រ | ទី ១០ | ៤២៦ |


## សមណវគ្គ ទី ៤


| | | |
|---|---|---|
| អដ្ឋកថា សមណសូត្រ | ទី ១ | ៤៤៥ |
| អដ្ឋកថា គទ្រភសូត្រ | ទី ២ | ៤៤៧ |
| អដ្ឋកថា ខេត្តសូត្រ | ទី ៣ | ៤៤៨ |
| អដ្ឋកថា វជ្ជីបុត្តសូត្រ | ទី ៤ | ៤៤៩ |
| អដ្ឋកថា បឋមសេក្ខសូត្រ | ទី ៥ | ៤៥១ |
| អដ្ឋកថា បឋមសិក្ខាសូត្រ | ទី ៦ | ៤៥២ |
| អដ្ឋកថា ទុតិយសិក្ខាសូត្រ | ទី ៧ | ៤៥៧ |
| អដ្ឋកថា តតិយសិក្ខាសូត្រ | ទី ៨ | ៤៦៣ |
| អដ្ឋកថា បឋមសិក្ខត្តយសូត្រ | ទី ៩ | ៤៦៤ |
| អដ្ឋកថា ទុតិយសិក្ខត្តយសូត្រ | ទី ១០ | ៤៦៥ |
| អដ្ឋកថា បង្កធាសូត្រ | ទី ១១ | ៤៦៨ |


## លោណផលវគ្គ ទី ៥


| | | |
|---|---|---|
| អដ្ឋកថា អច្ចាយិកសូត្រ | ទី ១ | ៤៧១ |
| អដ្ឋកថា បវិវេកសូត្រ | ទី ២ | ៤៧៣ |
| អដ្ឋកថា សរទសូត្រ | ទី ៣ | ៤៧៧ |

អដ្ឋកថា បរិសាសូត្រ ទី ៤ ៤៧៨

អដ្ឋកថា បឋមអាជានេយ្យសូត្រ ទី ៥ ៤៨២

អដ្ឋកថា ទុតិយអាជានេយ្យសូត្រ ទី ៦ ៤៨៤

អដ្ឋកថា តតិយអាជានេយ្យសូត្រ ទី ៧ ៤៨៥

អដ្ឋកថា ពោត្ថកសូត្រ ទី ៨ ៤៨៦

អដ្ឋកថា លោណផលសូត្រ ទី ៩ ៤៨៨

អដ្ឋកថា សង្ឃសូត្រ ទី ១០ ៤៩៤

អដ្ឋកថា និមិត្តសូត្រ ទី ១១ ៤៩៨


# តតិយបណ្ណាសកៈ

## សម្ពោធិវគ្គ ទី ១


អដ្ឋកថា បុព្វេសម្ពោធសូត្រ ទី ១ ៥០១

អដ្ឋកថា បឋមអស្សាទសូត្រ ទី ២ ៥០៣

អដ្ឋកថា សមណព្រាហ្មណ៍សូត្រ ទី ៤ ៥០៥

អដ្ឋកថា រុណ្ណសូត្រ ទី ៥ ៥០៦

អដ្ឋកថា អតិត្តិសូត្រ ទី ៦ ៥០៨

អដ្ឋកថា បឋមកូដសូត្រ ទី ៧ ៥០៩

អដ្ឋកថា ទុតិយកូដសូត្រ ទី ៨ ៥១០

អដ្ឋកថា បឋមនិទានសូត្រ ទី ៩ ៥១១

អដ្ឋកថា ទុតិយនិទានសូត្រ ទី ១០ ៥១២


## អាបាយិកវគ្គ ទី ២


អដ្ឋកថា អាបាយិកសូត្រ ទី ១ ៥១៤

អដ្ឋកថា ទុល្លភសូត្រ ទី ២ ៥១៦

អដ្ឋកថា អប្បមេយ្យសូត្រ ទី ៣ ៥១៧

អដ្ឋកថា អានេញ្ជសូត្រ ទី ៤ ៥១៨

អដ្ឋកថា អយសូត្រ ទី ៥ ៥២០

អដ្ឋកថា អបណ្ណកសូត្រ ទី ៦ ៥២២

អដ្ឋកថា បឋមសោចេយ្យសូត្រ ទី ៨ ៥២៤
អដ្ឋកថា ទុតិយសោចេយ្យសូត្រ ទី ៩ ៥២៥
អដ្ឋកថា មោនេយ្យសូត្រ ទី ១០ ៥២៦

**កុសិនារវគ្គ ទី ៣**

អដ្ឋកថា កុសិនារសូត្រ ទី ១ ៥២៨
អដ្ឋកថា ភណ្ឌនសូត្រ ទី ២ ៥៣០
អដ្ឋកថា គោតមសូត្រ ទី ៣ ៥៣១
អដ្ឋកថា ភរណ្ឌុសូត្រ ទី ៤ ៥៣៥
អដ្ឋកថា ហត្ថកសូត្រ ទី ៥ ៥៣៧
អដ្ឋកថា កដុវិយសូត្រ ទី ៦ ៥៤៣
អដ្ឋកថា បឋមអនុរុទ្ធសូត្រ ទី ៧ ៥៤៥
អដ្ឋកថា ទុតិយអនុរុទ្ធសូត្រ ទី ៨ ៥៤៦
អដ្ឋកថា បដិច្ឆន្នសូត្រ ទី ៩ ៥៤៧
អដ្ឋកថា លេខសូត្រ ទី ១០ ៥៤៨

**យោធាជីវវគ្គ ទី ៤**

អដ្ឋកថា យោធាជីវសូត្រ ទី ១ ៥៤៩
អដ្ឋកថា បរិសាសូត្រ ទី ២ ៥៥១
អដ្ឋកថា ឧប្បាទសូត្រ ទី ៤ ៥៥៣
អដ្ឋកថា កេសកម្ពលសូត្រ ទី ៥ ៥៥៤
អដ្ឋកថា បឋមអស្សសូត្រ ទី ៨ ៥៥៧
អដ្ឋកថា ទុតិយអស្សសូត្រ ទី ៩ ៥៥៨
អដ្ឋកថា តតិយអស្សសូត្រ ទី ១០ ៥៥៩
អដ្ឋកថា បឋមមោរនិវាបសូត្រ ទី ១១ ៥៦០
អដ្ឋកថា ទុតិយមោរនិវាបសូត្រ ទី ១២ ៥៦១
អដ្ឋកថា តតិយមោរនិវាបសូត្រ ទី ១៣ ៥៦២

**មង្គលវគ្គ ទី ៥**

អដ្ឋកថា អកុសលសូត្រ ទី ១ ៥៦៣

| | | |
|---|---|---|
| អដ្ឋកថា សារជ្ជសូត្រ | ទី ២ | ៥៦៤ |
| អដ្ឋកថា វិសមសូត្រ | ទី ៣ | ៥៦៥ |
| អដ្ឋកថា អសុចិសូត្រ | ទី ៤ | ៥៦៦ |
| អដ្ឋកថា សុបុព្វណ្ហសូត្រ | ទី ១០ | ៥៧២ |
| អដ្ឋកថា មិនសង្គ្រោះចូលក្នុងបណ្ណាសកៈ | | ៥៧៤ |

# អង្គុត្តរនិកាយ តិកនិបាត

## បឋមបណ្ណាសកៈ

## ពាលវគ្គវណ្ណនាទី ១

## អដ្ឋកថា ភយសូត្រទី ១

### *“បុគ្គលមានភ័យ និងមិនមានភ័យ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភយសូត្រទី ១ នៃតិកនិបាត ដូចតទៅនេះ ៖-*

[១] *ក្នុងបទថា **ភយានិ** (ភ័យ) ជាដើម ភាពនៃចិត្តតក់ស្លុត ឈ្មោះថា **ភ័យ** ។ អាការដែលចិត្តមិនជាសមាធិ ឈ្មោះថា **ឧបទ្វវៈ** (ចង្រៃ) ។ អាការដែលទើសទាក់នៃចិត្ត គឺ អាការដែលចិត្តជាប់នៅក្នុងអារម្មណ៍នោះៗ ឈ្មោះថា **ឧបសគ្គ** ។*

*គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃភ័យ ឧបទ្វវៈ និងឧបស័គ្គទាំងនោះ ដូចតទៅនេះ ។*

*ពួកចោរដែលអាស្រ័យនៅតាមភ្នំ និងកន្លែងឆ្ងាយដាច់ស្រយ៉ាល ឲ្យដំណឹងទៅដល់អ្នកជនបទថា ពួកយើងនឹងចូលប្លន់ស្រុករបស់ពួកលោកក្នុងថ្ងៃឯណោះ តាំងពីវេលាដែលបានស្ដាប់ដំណឹងនោះ អ្នកជនបទទាំងនោះ ក៏*

នាំគ្នាភ័យខ្លាច ។ អាការយ៉ាងនេះ ឈ្មោះថា អាការដែលចិត្តតក់ស្លុត ។

អ្នកជនបទក៏នាំគ្នាគិតថា ធ្វើយ៉ាងណាល្អហ្ន៎ កាលបើពួកចោរក្រោធនឹងពួកយើងហើយ គប្បីនាំសេចក្តីវិនាសឲ្យដល់ពួកយើងដោយពិត ដូច្នេះហើយ ប្រមូលទ្រព្យសម្បត្តិដែលល្មមកាន់ជាប់ដៃទៅបាន ចូលក្នុងព្រៃព្រមទាំងហ្វូងសត្វទ្វេបាទ ចតុបាទ ដេកលើផែនដីនៅក្នុងព្រៃនោះ ត្រូវសត្វល្អិតមានរបោម និងមូសជាដើមខាំ ក៏នាំគ្នាគេចចូលទៅកាន់ចន្លោះគុម្ពឈើ ជាន់ជន្ទាត់ឈើ និងបន្លា ។ សេចក្តីពាយមាយរបស់អ្នកជនបទទាំងនោះ ដែលត្រាច់ទៅហើយយ៉ាងនោះ ឈ្មោះថា អាការដែលចិត្តមិនស្ងប់ ។

បន្ទាប់អំពីនោះ កាលពួកចោរមិនមកតាមថ្ងៃដែលបានប្រាប់ អ្នកស្រុកក៏គិតគ្នាថា ប្រហែលជាដំណឹងកុហក ពួកយើងនឹងត្រឡប់ចូលក្នុងស្រុកវិញដូច្នេះ ហើយនាំគ្នាប្រមូលរបស់របរត្រឡប់ចូលកាន់ស្រុក ។ គ្រានោះ ពួកចោរជ្រាបថា អ្នកស្រុកទាំងនោះនាំគ្នាត្រឡប់ចូលស្រុកហើយ ទើបនាំគ្នាមកឡោមព័ទ្ធស្រុក ដុតភ្លើងត្រង់ទ្វារ សម្លាប់មនុស្សដ៏ច្រើន ប្លន់យកទ្រព្យសម្បត្តិទាំងអស់ទៅ ។ បណ្តាអ្នកជនបទទាំងនោះ ពួកដែលនៅសល់ពីត្រូវចោរសម្លាប់ ក៏នាំគ្នាលត់ភ្លើង ហើយអង្គុយសោកសៅនៅក្នុងទីនោះៗ ត្រង់ម្លប់ស្រមោលទ្វារ និងស្រមោលផ្ទះជាដើម ខ្សឹកខ្សួលដល់របស់របរដែលវិនាស

ទៅ ។ អាការដែលទើសទាក់ចិត្តយ៉ាងនេះ ឈ្មោះថា អាការដែលទាស់ចិត្ត នៅក្នុងអារម្មណ៍នោះ ។

បទថា **នឡាគារា** (ចេញពីផ្ទះដែលប្រក់ដោយដើមបបុស) បានដល់ ផ្ទះដែលបិទបាំងដោយដើមបបុស ចំណែកគ្រឿងផ្ទះដ៏សេសក្នុងផ្ទះដែលប្រក់ដោយដើមបបុសនេះ ធ្វើពីឈើ ។ សូម្បីក្នុងផ្ទះស្មៅ ក៏មានន័យនេះឯង ។ បទថា **កូដាគារានិ** (ផ្ទះកំពូល) បានដល់ ផ្ទះដែលលើកកំពូល ។ បទថា **ឧល្លិត្តាវលិត្តានិ** (ដែលបូកលាបទាំងខាងក្នុងខាងក្រៅ) បានដល់ បូកលាបទាំងខាងក្នុង និងខាងក្រៅ ។ បទថា **និវាតានិ**បានដល់ ខ្យល់ចូលទៅមិនបាន ។ បទថា **ផុសិតគ្គឡានិ** (មានសន្ទះទ្វារដ៏ជិតស្និទ្ធ) បានដល់ មានសន្ទះទ្វារដ៏ជិតចូលយ៉ាងស្និទ្ធត្រង់ក្របទ្វារ ព្រោះជារបស់ដែលជាងដ៏ឆ្លាតធ្វើទុក ។ បទថា **បិហិតកវាដានិ** (មានបង្អួចបិទជិត) បានដល់ មានសន្ទះបង្អួចប្រកបទុក ។ ដោយពីរបទនេះ ព្រះមានព្រះភាគ មិនបានត្រាស់សំដៅដល់សន្ទះទ្វារ និងបង្អួចដែលបិទទុកប្រចាំ តែត្រាស់ពីគុណសម្បត្តិប៉ុណ្ណោះ ។ ក៏សន្ទះទ្វារ និងបង្អួចទាំងនោះ រមែងបិទ និងបើកបានគ្រប់ខណៈដែលត្រូវការ ។

បទថា **ពាលតោ ឧប្បជ្ជន្តិ** (រមែងកើតពីបុគ្គលពាល) សេចក្តីថា ឧបស័គ្គទាំងឡាយ រមែងកើតឡើងព្រោះអាស្រ័យជនពាលទាំងនោះ ។ ពិត

ណាស់ បុគ្គលពាល គឺ បុគ្គលមិនមែនជាបណ្ឌិត កាលបើប្រាថ្នាជាព្រះរាជា ជាឧបរាជ ឬប្រាថ្នាតំណែងធំយ៉ាងដទៃ ក៏នឹងបបួលកូនស្ទ្រីមេម៉ាយ បុគ្គលដែលល្ងង់ដូចខ្លួន ចំនួនតិចតួចហើយបញ្ចុះបញ្ចូលថា មកចុះលោកទាំងឡាយនឹងធ្វើពួកលោកឲ្យជាធំ លាក់ខ្លួននៅតាមភ្នំ និងព្រៃក្រាស់ជាដើម ហើយចោមវាយអ្នកស្រុកតាមជាយដែន ធ្វើអ្នកស្រុកឲ្យវិនាសអស់ ហើយក៏ចោមនិគមខ្លះ ជនបទខ្លះ តាមលំដាប់ ។

បុគ្គលដែលប្រាថ្នាទីផុតពីភ័យ ទើបនាំគ្នាចោលផ្ទះសំបែងគេចចេញទៅ ។ ទាំងភិក្ខុ ភិក្ខុនី ដែលអាស្រ័យអ្នកស្រុក អ្នកនិគម និងអ្នកជនបទទាំងនោះ បាននាំគ្នាលះបង់ចោលទីនៅរៀងៗ ខ្លួន គេចចេញទៅ ។ ក្នុងទីដែលលោកទាំងនោះទៅហើយ ភិក្ខុក្តី សេនាសនៈក្តី ក៏រកបានលំបាក ។ ភ័យរមែងមកដល់បរិស័ទទាំង ៤ យ៉ាងនេះឯង ។

សូម្បីក្នុងបព្វជិតទាំងឡាយ ភិក្ខុដែលជាពាល ២ រូប វិវាទគ្នាហើយក៏ផ្តើមចោទគ្នានិងគ្នា ទើបកើតសេចក្តីវល់ធំដល់ព្រះរាជា ដូចពួកភិក្ខុនៅក្រុងកោសម្ពី ដូច្នោះ ។ ភ័យរមែងមកដល់បរិស័ទ ៤ ក៏ដូចគ្នា ភ័យពួកណាកើតឡើងដូចពោលមកនេះ ភ័យទាំងអស់នោះ រមែងកើតឡើងមកអំពីជនពាល ព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យចប់ស្រេច តាមអនុសន្ធិ ដូចពោលមក

ដូច្នេះឯង ។

ចប់អដ្ឋកថា ភយសូត្រទី ១

# អដ្ឋកថា លក្ខណសូត្រទី ២

## *"លក្ខណៈរបស់បុគ្គលពាល និងបណ្ឌិត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង លក្ខណសូត្រទី ២ ដូចតទៅនេះ ៖-*

[២] *កម្មដែលប្រព្រឹត្តទៅផ្លូវកាយទ្វារជាដើម ជាលក្ខណៈ គឺ ជាហេតុឲ្យដឹងចំពោះបុគ្គលនោះ ហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា* ***មានកម្មជាលក្ខណៈ*** *។*

*បញ្ញាដែលស្អាតដោយការប្រព្រឹត្ត (ចរិត) ឈ្មោះថា* ***អបទានសោភនីបញ្ញា*** *។ អធិប្បាយថា ពាល និងបណ្ឌិត រមែងប្រាកដដោយកម្មដែលខ្លួនប្រព្រឹត្តមកហើយនុ៎ះឯង ។*

*ពិតណាស់ វិថីជីវិតជនពាលប្រព្រឹត្តទៅ រមែងដូចជាផ្លូវរបស់ភ្លើងព្រៃ ដែលដុតដើមឈើ គំនរឈើ គាមនិគមជាដើម ដូច្នោះ ។ ប្រាកដសល់ត្រឹមតែបង្គោលសសរប៉ុណ្ណោះ និងពេញទៅដោយរងើក ធ្យូង និងផេះ ។ ចំណែក វិថីជីវិតបណ្ឌិតប្រព្រឹត្តទៅ ដូចផ្ទៃមេឃដែលតាំងឡើងទាំង ៤ ទិស ហើយបណ្តាលភ្លៀងចុះមក ពេញបឹងបួរ និងអណ្តូងជាដើម នាំសេចក្តីសម្បូរស្រូវអង្ករផ្សេងៗ មក ដូច្នោះ ។ ទីកន្លែងដែលបរិបូរដោយទឹក និងមានផលាផលប្រភេទផ្សេងៗ ដុះលូតលាស់ ប្រាកដក្នុងទីដែលមានភ្លៀងបង្អុរចុះមក*

*ពេញបរិបូរ និងអណ្ដូង យ៉ាងណា ក្នុងវិថីជីវិតបណ្ឌិតប្រព្រឹត្តទៅ ក៏ប្រាកដមាន តែសម្បត្តិតែម្យ៉ាងប៉ុណ្ណោះ មិនមានវិបត្តិឡើយ ដូច្នោះ ។ បទដ៏សេសក្នុង សូត្រនេះ មានអត្ថងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា លក្ខណសូត្រទី ២

# អដ្ឋកថា ចិន្តសូត្រទី ៣

## *“លក្ខណៈផ្សេងគ្នារវាងបណ្ឌិត និងពាល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចិន្តសូត្រទី ៣ ដូចតទៅនេះ ៖-*

[៣] *បទថា* ***ពាលក្ខណានិ*** *(ពាលលក្ខណៈ) ដែលឈ្មោះថា ពាល-លក្ខណៈ (លក្ខណៈរបស់បុគ្គលពាល) ព្រោះជាគ្រឿងឲ្យមនុស្សទាំងឡាយកំណត់ គឺ ដឹងបានថា បុគ្គលនេះជាពាល ។ លក្ខណៈទាំងនោះឯង ជាហេតុឲ្យដឹងច្បាស់បុគ្គលពាល ព្រោះហេតុនោះ ទើបឈ្មោះថា* ***ពាលនិមិត្ត*** *(គ្រឿងសម្គាល់ជនពាល) ។ បទថា* ***ពាលាបទានានិ*** *(ពាលបទាន) បានដល់ ការប្រព្រឹត្តរបស់បុគ្គលពាល ។ បទថា* ***ទុច្ចិន្តិតចិន្តី*** *(ជាអ្នកគិតអាក្រក់ជាប្រក្រតី) សេចក្តីថា បុគ្គលពាលកាលគិត រមែងគិតតែរឿងដែលមិនល្អ ដោយអំណាចអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ ។ បទថា* ***ទុព្ភាសិតភាសី*** *(និយាយអាក្រក់ជាប្រក្រតី) សេចក្តីថា សូម្បីកាលនឹងនិយាយ ក៏រមែងនិយាយតែពាក្យដែលមិនល្អ មានប្រភេទជាមុសាវាទជាដើម ។ បទថា* ***ទុក្កដកម្មការី*** *(ធ្វើកម្មអាក្រក់ជាប្រក្រតី) សេចក្តីថា សូម្បីកាលធ្វើ រមែងធ្វើតែវត្ថុដែលមិនល្អ ដោយអំណាចបាណាតិបាតជាដើម ។ បទមានជាដើមថា* ***បណ្ឌិតលក្ខណានិ*** *(បណ្ឌិតលក្ខណៈ) គប្បីជ្រាបតាមទំនងលក្ខណៈដែលពោលហើយនុ៎ះឯង ។*

*ចំណែកបទទាំងឡាយ មានបទថា* ***សុចិន្តិតចិន្តី*** *(ជាអ្នកគិតល្អជាប្រក្រតី) ជាដើម ក្នុងសូត្រនេះ គប្បីប្រកបដោយអំណាចនៃសុចរិតទាំងឡាយ មានមនោសុចរិតជាដើម ។*

ចប់អដ្ឋកថា ចិន្តសូត្រទី ៣

# អដ្ឋកថា អច្ចយសូត្រទី ៤

## "ធម៌ដែលសម្ដែងថាជាពាល ឬបណ្ឌិត"

*គប្បីជ្រាបវិនិច្ឆ័យក្នុង អច្ចយសូត្រទី ៤ ដូចតទៅនេះ ៖-*

*[៤] បទថា **អច្ចយំ អច្ចយតោ ន បស្សតិ** (មិនឃើញទោសថាជាទោស) សេចក្ដីថា បុគ្គលពាល រមែងមិនឃើញកំហុសរបស់ខ្លួនថាជាទោស ។ បទថា **អច្ចយតោ ទិស្វា យថាធម្មំ ន បដិករោតិ** (លុះឃើញថាជាទោសហើយ មិនសម្ដែងទោសឲ្យសមគួរតាមធម៌) សេចក្ដីថា បុគ្គលពាល សូម្បីជ្រាបថា យើងធ្វើខុស ក៏មិនព្រមធ្វើតាមធម៌ គឺ ទទួលទណ្ឌកម្ម ក៏មិនព្រមសារភាពទោស ។ បទថា **អច្ចយំ ទេសេន្តស្ស យថាធម្មំ ន បដិគ្គណ្ហាតិ** (ទុកជាបុគ្គលដទៃសារភាពទោស ក៏មិនទទួលទោសឲ្យសមគួរតាមធម៌) សេចក្ដីថា កាលបុគ្គលដទៃដឹងថា យើងធ្វើខុស ទទួលទណ្ឌកម្ម ហើយសូមខមាទោស បុគ្គលពាលក៏មិនលើកលែងទោសឲ្យ ។*

*ធម៌ចំណែកស (របស់បណ្ឌិត) គប្បីជ្រាបដោយន័យដែលផ្ទុយគ្នាតាមដែលពោលហើយចុះ ។*

ចប់អដ្ឋកថា អច្ចយសូត្រទី ៤

# អដ្ឋកថា អយោនិសោសូត្រទី ៥

## *"ធម៌ដែលសម្តែងថាជាពាល ឬបណ្ឌិត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អយោនិសោសូត្រទី ៥ ដូចតទៅនេះ ៖-*

[៥] *បទថា* ***អយោនិសោ បញ្ហំ កត្តា ហោតិ*** *(តែងបញ្ហាមិនត្រូវទំនង) សេចក្តីថា បុគ្គលពាល រមែងធ្វើវត្ថុដែលមិនមែនជាបញ្ហានុ៎ះឯង ឲ្យជាបញ្ហា ព្រោះគិតមិនត្រូវវិធី ដូចព្រះលោឡុទាយី កាលត្រូវសួរថា ឧទាយី ទីតាំងរបស់អនុស្សតិមានប៉ុន្មានហ្ន៎ ក៏គិតថាខន្ធដែលធ្លាប់អាស្រ័យនៅក្នុងភពមុន ជាទីតាំងរបស់អនុស្សតិ ដូច្នេះហើយ ធ្វើវត្ថុដែលមិនជាបញ្ហា ឲ្យជាបញ្ហាដូច្នោះ ។*

*បទថា* ***អយោនិសោ បញ្ហំ វិសជ្ជេតា ហោតិ*** *(ដោះស្រាយបញ្ហាមិនត្រូវទំនង) សេចក្តីថា ក៏បុគ្គលពាល សូម្បីកាលនឹងវិសជ្ជនាបញ្ហាដែលគិតទៀត ក៏វិសជ្ជនាដោយមិនត្រូវទំនង ដូចជាព្រះថេរៈនោះឯង ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងធម្មវិន័យនេះ រមែងរលឹកដល់ខន្ធដែលអាស្រ័យនៅក្នុងភពមុនបានច្រើន គឺ រលឹកបានមួយជាតិខ្លះ គឺ រមែងពោលវត្ថុដែលមិនជាបញ្ហានុ៎ះឯង ថាជាបញ្ហា ។*

*ក្នុងបទថា* ***បរិមណ្ឌលេហិ បទព្យញ្ជនេហិ*** *(ដោយបទ និងព្យញ្ជនៈ*

ជាបរិមណ្ឌល) នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បទនោះឯង ឈ្មោះថា បទ និងព្យញ្ជនៈ ព្រោះធ្វើអត្ថឲ្យប្រាកដ ។ បទ និងព្យញ្ជនៈនោះ ដែលលោកពោលធ្វើអក្សរឲ្យបរិបូរ មិនឲ្យវិនាសអត្ថរបស់ព្យញ្ជនៈ ១០ យ៉ាង ឈ្មោះថា ជាបរិមណ្ឌល ។ អធិប្បាយថា ដោយបទ និងព្យញ្ជនៈបែបនេះ ។

បទថា **សិលិដ្ឋេហិ** (រៀបរយល្អ) បានដល់ ដែលឈ្មោះថា រៀបរយ ព្រោះមានបទស្រួលបរិបូរណ៍ ។

បទថា **ឧបគតេហិ** (ចូលដល់) បានដល់ ចូលដល់ផល និងហេតុ ។

បទថា **នាភិនុមោទិត** (មិនរីករាយ) សេចក្តីថា បុគ្គលពាលរមែងមិនអនុមោទនា គឺ មិនត្រេកអរបញ្ហារបស់បុគ្គលដទៃដែលវិសជ្ជនាដោយត្រូវទំនងយ៉ាងនេះ គឺ ដែលវិសជ្ជនាធ្វើឲ្យសម្បូរដោយអាការគ្រប់យ៉ាង ។ ដូចព្រះលោឡុទាយី មិនអនុមោទនាបញ្ហារបស់ព្រះសារីបុត្រ ដូច្នោះ ។ ដូចលោកពោលទុកថា

អាវុសោសារីបុត្រ មិនមែនឋានៈ មិនមែនឱកាសឡើយ ដែលព្រះអនាគាមីនោះ កន្លងកាពជាបុគ្គលនៅរួមជាមួយពួកទេពដែលមានកវឡិង្ការាហារជាភក្សា ចូលដល់ពួកទេពដែលជាមនោមយៈពួកណាមួយហើយ នឹងគប្បី

ចូលសញ្ញាវេទយិតនិរោធក៏បាន នឹងគប្បីចេញចាកសញ្ញាវេទយិតនិរោធក៏បាន ឋានៈនេះមិនមានឡើយ ។

ក្នុងបទថា **យោនិសោ បញ្ហំ កត្តា** (តែងបញ្ហាត្រូវទំនង) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បណ្ឌិតគិតបញ្ហាដោយត្រូវទំនងហើយ រមែងវិសជ្ជនាបញ្ហាដោយត្រូវទំនង ដូចព្រះអានន្ទត្ថេរៈ ដូច្នោះ ។ ពិតណាស់ ព្រះថេរៈត្រូវព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ ទីតាំងរបស់អនុស្សតិមានប៉ុន្មានហ្ន៎ ក៏គិតដោយឧបាយជាមុនថា នេះនឹងជាបញ្ហា កាលនឹងវិសជ្ជនាដោយឧបាយ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ស្ងាត់ហើយ ចេញចាកកាមទាំងឡាយ ។ល។ ហើយចូលចតុត្ថជ្ឈាន បពិត្រព្រះអង្គដ៏ចម្រើន ទីតាំងរបស់អនុស្សតិនេះ ដែលចម្រើនហើយយ៉ាងនេះ ធ្វើឲ្យច្រើនហើយយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។

បទថា **អព្ភានុមោទិតា ហោតិ** (រមែងរីករាយ) សេចក្តីថា បណ្ឌិតរមែងអនុមោទនាដោយត្រូវទំនង ដូចព្រះតថាគតអនុមោទនា ដូច្នោះ ។ ពិតហើយ ព្រះតថាគតកាលព្រះអានន្ទវិសជ្ជនាបញ្ហាហើយ ក៏ត្រាស់ព្រះតម្រាស់ជាដើមថា សាធុ សាធុ អានន្ទ ហេតុដូច្នោះ អានន្ទ អ្នកចូរចាំ ទីតាំងនៃ

*អនុស្សតិទី ៦ នេះ ទុកបុះ អានន្ទ ភិក្ខុក្នុងធម្មវិន័យនេះ មានសតិឈានទៅខាងមុខ មានសតិឈានថយក្រោយ ។*

ចប់អដ្ឋកថា អយោនិសោសូត្រទី ៥

# អដ្ឋកថា ខតសូត្រទី ៩

## *"ការរក្សាខ្លួនបែបបុគ្គលពាល និងបណ្ឌិត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខតសូត្រទី ៩ ដូចតទៅនេះ ៖-*

[៦] *ធម៌ចំណែកស ក្នុងចំណែកខាងដើម កំណត់ដោយកុសលកម្មបថ ១០ ក្នុងចំណែកជាខាងក្រោយ រមែងប្រព្រឹត្តទៅរហូតដល់អរហត្តមគ្គ ។*

*ក្នុងបទថា* ***ពហុញ្ច បញ្ញំ បសវតិ*** *(និងបានបុណ្យដ៏ច្រើន) នេះ ព្រះមានព្រះភាគត្រាស់ដល់បុណ្យដែលលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។*

ចប់អដ្ឋកថា ខតសូត្រទី ៩

# អដ្ឋកថា មលសូត្រទី ១០

## *"ពោលពីមន្ទិល ៣ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មលសូត្រទី ១០ ដូចតទៅនេះ ៈ-*

[១០] *ភាវៈរបស់បុគ្គលទ្រុស្តសីល ឈ្មោះថា **ទុស្សីល្យ** ។ ទុស្សីល្យៈនោះឯង ជាមន្ទិល ទើបឈ្មោះថា **ទុស្សីល្យមល** ។*

### *អត្ថរបស់មន្ទិល*

*សួរថា ឈ្មោះថា **មន្ទិល** ព្រោះអត្ថដូចម្តេច ។*

*ឆ្លើយថា ព្រោះអត្ថថា តាមដុត ១ ព្រោះអត្ថថា មានក្លិនស្អុយ ១ ព្រោះអត្ថថា ធ្វើឲ្យសៅហ្មង ១ ។*

*អធិប្បាយថា មន្ទិលនោះ រមែងតាមដុតសត្វ ក្នុងអបាយទាំងឡាយមាននរកជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា ជាមន្ទិល ព្រោះអត្ថថា តាមដុតខ្លះ ។*

*បុគ្គលប្រកបដោយមន្ទិលនោះ រមែងជាទីគួរវៀរស ទាំងក្នុងសម្នាក់មាតាបិតា ទាំងខាងក្នុងភិក្ខុសង្ឃ ទាំងក្នុងពោធិស្ថាន និងចេតិយស្ថាន និងក្លិនដែលកើតពីសេចក្តីមិនល្អរបស់គេ រមែងផ្សាយទៅក្នុងគ្រប់ទិសថា បុគ្គលនោះធ្វើបាបកម្មបែបនេះ ព្រោះហេតុនោះ ទើបឈ្មោះថា ជាមន្ទិល ព្រោះអត្ថ*

ថា មានក្លិនស្អុយខ្លះ ។

បុគ្គលដែលប្រកបដោយមន្ទិលនោះ រមែងទទួលសេចក្តីក្តៅក្រហាយក្នុងទីដែលទៅដល់ និងកាយកម្មជាដើមរបស់គេ ក៏មិនស្អាត មិនថ្លាផូរផង់ព្រោះហេតុនោះ ទើបឈ្មោះថា ជាមន្ទិល ព្រោះអត្ថថា ធ្វើឲ្យសៅហ្មងខ្លះ ។

ម្យ៉ាងទៀត មន្ទិលនោះ រមែងធ្វើទេវសម្បត្តិ មនុស្សសម្បត្តិ និងនិព្វានសម្បត្តិឲ្យវិនស្សូតទៅ ព្រោះហេតុនោះ គប្បីជ្រាបថា ជាមន្ទិល ព្រោះអត្ថថា ធ្វើឲ្យវិនស្សូតខ្លះ ។

សូម្បីក្នុងមន្ទិល គឺ ឥស្សា និងមន្ទិល គឺ សេចក្តីកំណាញ់ ក៏មានន័យនេះដូចគ្នា ។

ចប់អដ្ឋកថា មលសូត្រទី ១០

## ចប់ពាលវគ្គវណ្ណនាទី ១

### ក្នុងវគ្គនេះមាន ១០ សូត្រ

### ព្រះអដ្ឋកថាកែសេចក្តី ៧ សូត្រ

# វគ្គទី ២ រថការវគ្គ

## អដ្ឋកថា ញាតកសូត្រទី ១

### *"បដិបទាដើម្បីប្រយោជន៍ និងមិនមែនប្រយោជន៍"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ញាតកសូត្រទី ១ ដូចតទៅនេះ ៖-*

*កាយកម្ម វចីកម្ម មនោកម្ម*

[១១] *បទថា **ញាតកោ** (អ្នកមានកេរ្តិ៍ឈ្មោះ) បានដល់ ភិក្ខុដែលមានកេរ្តិ៍ឈ្មោះ គឺ ប្រជាជនស្គាល់គ្រប់គ្នាហើយ បានដល់ ប្រាកដហើយ ។ បទថា **អននុលោមិកេ** (មិនសមគួរ) សេចក្តីថា កាយកម្ម ឈ្មោះថា អននុលោមិកៈ ព្រោះអត្ថថា មិនសមគួរដល់សាសនា ។ ក្នុងកាយកម្មដែលមិនសមគួរនោះ ។ បទថា **កាយកម្មេ** (ក្នុងកាយកម្ម) បានដល់ ក្នុងកាយទុច្ចរិត មានបាណាតិបាតជាដើម ។*

*ម្យ៉ាងទៀត កាយទុច្ចរិតនោះជាកម្មគ្រោតគ្រាត តែភិក្ខុអាចនឹងបបួលក្នុងកាយទុច្ចរិតជាដើមនេះបាន គឺ ដឹកនាំ បានដល់ ឲ្យកាន់យកក្នុងកម្មបែបនេះថា ការនមស្ការទិសទាំងឡាយគួរ ការធ្វើពលីកម្មឲ្យភូតវមែងគួរ សូម្បីក្នុងវចីកម្ម (ក៏ដូចគ្នាគឺ) មុសាវាទជាដើមជាកម្មគ្រោតគ្រាត តែភិក្ខុនោះ នឹង*

បបួលក្នុងវចីកម្មបែបនេះថា ដែលឈ្មោះថា ការនិយាយកុហកដល់បុគ្គល ល្ងង់នេះថា មិនមាន ព្រោះមិនបំណងនឹងឲ្យរបស់របរខ្លួនដល់អ្នកដទៃ ក៏គួរនិយាយបាន ។ សូម្បីក្នុងមនោកម្ម (ក៏ដូចគ្នាគឺ) អភិជ្ឈាជាដើម ក៏ជាកម្មគ្រោតគ្រាត តែភិក្ខុកាលប្រាប់កម្មដ្ឋានឃ្មៀងឃ្លាតទៅ ក៏មិនឈ្មោះថា ដឹកនាំក្នុងមនោកម្មដែលគួរ ដូចព្រះថេរៈអ្នកស្រុកទក្ខិណវិហារ ដូច្នោះ ។

## ព្រះថេរៈអ្នកស្រុកទក្ខិណវិហារ

បានឮមកថា បុត្រនាងម្នាក់ចូលទៅរកព្រះថេរៈនោះ ហើយសួរថា បុគ្គលកាលចម្រើនមេត្តា គួរចម្រើនមេត្តាក្នុងបុគ្គលណាមុន ។ ព្រះថេរៈមិនព្រមប្រាប់ដល់បុគ្គលដែលជាសភាគ និងវិសភាគគ្នា តែប្រាប់ថា ក្នុងបុគ្គលដែលជាទីស្រឡាញ់ ។ បុត្រនាងនោះ មានភរិយាជាទីស្រឡាញ់ ។ គេទើបផ្សាយមេត្តាទៅរកនាង រហូតដល់ឆ្កួត ។

សួរថា ក៏ភិក្ខុអ្នកប្រាប់កម្មដ្ឋាននេះ ជាអ្នកបដិបត្តិដើម្បីមិនជាប្រយោជន៍ដ៏ចម្រើនដល់ជនច្រើនដូចម្តេច ។

ឆ្លើយថា ក៏ព្រោះបរិវារជនរបស់ភិក្ខុបែបនេះ មានសទ្ធិវិហារិកជាដើម និងមានឧបដ្ឋាកជាដើម រួមទាំងទេវតាដ៏សេស ដែលជាមិត្តរបស់ទេវតាទាំងនោះ តាំងពីអារក្ខទេវតារបស់បរិវារជនទាំងនោះ រហូតដល់ព្រហ្មលោក ក៏

នាំគ្នាធ្វើតាមដែលភិក្ខុនោះធ្វើហើយ ដោយគិតថា ភិក្ខុនេះនឹងធ្វើអ្វី ព្រោះមិនដឹងក៏មិនមែន ភិក្ខុនេះឈ្មោះថា ជាអ្នកបដិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនដ៏ច្រើន ដោយប្រការដូចពណ៌នាមក ដូច្នេះ ។

ក្នុងធម៌ចំណែកស គប្បីជ្រាបកាយកម្ម និងវចីកម្ម ដោយអំណាចនៃចេតនាទាំងឡាយ មានចេតនាជាគ្រឿងវៀរចាកបាណាតិបាតជាដើមនុ៎ះឯង ។ ចំណែកភិក្ខុដែលប្រាប់កម្មដ្ឋានមិនឃ្លៀងឃ្លាត ឈ្មោះថា ដឹកនាំក្នុងធម៌ដែលសមគួរ ដូចព្រះតិស្សត្ថេរៈអ្នកជំនាញក្នុង ៤ និកាយ អ្នកស្រុកកោលិតវិហារ ដូច្នោះ ។

## ព្រះតិស្សត្ថេរៈ

បានឮមកថា ព្រះទត្តាភយត្ថេរៈ ជាបងប្រុសរបស់ព្រះតិស្សត្ថេរៈនោះ នៅក្នុងចេតិយវិហារ កាលរោគមួយប្រភេទកើតឡើង ឲ្យហៅភិក្ខុជាប្អូនប្រុសមក ហើយប្រាប់ថា លោកម្ចាស់ ជួយប្រាប់កម្មដ្ឋានប្រការណាមួយដែលស្រោលដល់ខ្ញុំផងចុះ ។ ភិក្ខុជាប្អូនប្រុសឆ្លើយប្រាប់ថា លោកបង ប្រយោជន៍អ្វីដោយកម្មដ្ឋានប្រការដទៃ លោកបងគួរកំណត់កវឡិង្ការាហារ ។

ភិក្ខុជាបងប្រុសសួរថា លោកម្ចាស់ កវឡិង្ការាហារនេះ មានប្រយោជន៍យ៉ាងណា ។ ភិក្ខុប្អូនប្រុសប្រាប់ថា លោកបង កវឡិង្ការាហារ ជាឧបាទាយរូប

និងកាលឃើញឧបាទាយរូបណាមួយហើយ ឧបាទាយរូប ២៣ ក៏រមែងប្រាកដច្បាស់ផង ។

ភិក្ខុបងប្រុសនោះ បានស្តាប់ដូច្នោះហើយ ឆ្លើយថា លោកម្ចាស់ កម្មដ្ឋានប៉ុណ្ណោះក៏ល្មមសមគួរហើយ ដូច្នេះហើយ ប្រាប់ភិក្ខុប្អូនប្រុសនោះត្រឡប់ទៅ កំណត់កវឡិង្ការាហារ ហើយកំណត់ឧបាទាយរូប ត្រឡប់ទៅត្រឡប់មកក៏បានសម្រេចជាព្រះអរហន្ត ។ រំពេចនោះ ភិក្ខុបងប្រុសក៏ហៅព្រះថេរៈប្អូនប្រុសនោះ អ្នកដែលមិនទាន់ចេញផុតក្រៅវិហារផង មកប្រាប់ថា លោកម្ចាស់លោកជាទីពឹងដ៏ធំរបស់ខ្ញុំ ដូច្នេះហើយ ប្រាប់គុណដែលខ្លួនបានហើយដល់ព្រះថេរៈប្អូនប្រុស ។ បទថា **ពហុជនហិតាយ** (ដើម្បីសេចក្តីចម្រើនដល់ជនច្រើន) សេចក្តីថា ក៏បរិវារជនរបស់ភិក្ខុសូម្បីនេះ មានសទ្ធិវិហារិកជាដើមក៏នាំគ្នាធ្វើតាមវត្តដែលភិក្ខុនោះធ្វើហើយ ដោយគិតថា ភិក្ខុនេះនឹងធ្វើអ្វីព្រោះមិនដឹងហើយក៏មិនមែន ឧបដ្ឋាកជាដើមក៏ដូចគ្នា ទេវតាទាំងឡាយ គឺ អារក្ខទេវតារបស់បរិវារជនទាំងនោះ ភុម្មទេវតាដែលជាមិត្តរបស់អារក្ខទេវតាទាំងនោះ និងអាកាសទេវតាដែលជាមិត្តរបស់ភុម្មទេវតាទាំងនោះ រួមទាំងទេវតាដែលកើតក្នុងព្រហ្មលោក ក៏នាំគ្នាធ្វើតាមវត្តដែលភិក្ខុនោះធ្វើហើយដូចគ្នា ភិក្ខុឈ្មោះថា ជាអ្នកបដិបត្តិដើម្បីសេចក្តីចម្រើនដល់ជនដ៏ច្រើន ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ញាតកសូត្រទី ១

# អដ្ឋកថា សារណីយសូត្រទី ២

## *“ទីដែលក្សត្រិយ៍ និងភិក្ខុគប្បីរឭកដល់”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារណីយសូត្រទី ២ ដូចតទៅនេះ ៖-*

### *វត្ថុដែលប្រជាប់ចិត្ត ៣ ប្រការ*

[១២] *បទថា* ***ខត្តិយស្ស*** *បានដល់ ជាក្សត្រិយ៍ដោយកំណើត ។ បទថា* ***មុទ្ធាភិសិត្តស្ស*** *(បានទទួលមុទ្ធាភិសេក) បានដល់ ទ្រង់បានទទួលមុទ្ធាភិសេកហើយ ដោយការអភិសេកជាព្រះរាជា ។ បទថា* ***សារណីយានិ ហោន្តិ*** *(ជាទីរឭក) សេចក្តីថា ជាទីមិនត្រូវភ្លេច ។ បទថា* ***ជាតោ*** *(ប្រសូតិ) បានដល់ កើតហើយ ។ បទថា* ***យាវជីវំ សារណីយំ*** *(ជាទីរឭកអស់ជីវិត) សេចក្តីថា ក្នុងវេលាដែលទ្រង់នៅក្មេង ព្រះមហាក្សត្រិយ៍ទ្រង់មិនអាចជ្រាបអ្វីៗ ដែលជាប់ទាក់ទងនឹងព្រះអង្គបានឡើយ (ក៏ពិត) ប៉ុន្តែថា ក្នុងវេលាតមកទ្រង់ស្តាប់រឿងរ៉ាវដែលពួកព្រះញាតិ មានព្រះជនកជននីជាដើម ឬអ្នកដែលនៅជាមួយគ្នាទូលថា ព្រះអង្គទ្រង់ព្រះរាជសម្ភពក្នុងជនបទឯណោះ ក្នុងនគរឯណោះ ក្នុងថ្ងៃឯណោះ ក្នុងនក្សត្រឯណោះ តាំងពីថ្ងៃនោះមក (រឿងរ៉ាវដែលព្រះញាតិត្រាស់ឲ្យស្តាប់) ជារឿងរ៉ាវដែលព្រះអង្គនឹងត្រូវរលឹកទុក គឺទ្រង់មិនភ្លេចរហូតដល់អស់ព្រះជន្មនោះឯង ។*

ពិតហើយ ព្រះបាទបាតកិនទ្ធៈ មិនមានកិច្ចដែលនឹងត្រូវធ្វើដោយជាតិនិងឋានៈជាដើមឡើយ ។ ប៉ុន្តែថា ព្រះមានព្រះភាគទ្រង់នាំហេតុការណ៍នេះមកក៏ដើម្បីទ្រង់សម្តែងបុគ្គល ៣ ពួក ដែលប្រៀបដូចជាព្រះរាជានោះ ព្រោះដូច្នោះព្រះមានព្រះភាគ កាលទ្រង់នឹងសម្តែងបុគ្គលទាំងនោះ ទើបទ្រង់ត្រាស់បទថា **ឯវមេវខោ ភិក្ខវេ** ជាដើម ។

បណ្តាបទទាំងនោះ ក្នុងបទថា **អនាគារិយំ បព្វជិតោ ហោតិ** (បួសជាបព្វជិត) នេះ គប្បីជ្រាបថា ចតុប្បារិសុទ្ធិសីល អាស្រ័យបព្វជ្ជានុ៎ះឯង ។ បទថា **សរណីយំ ហោតិ** (ជាទីរលឹក) សេចក្តីថា (ទីដែលភិក្ខុកោរសក់ និងពុកមាត់ហើយ គ្រងសំពត់កាសាវព័ត្រ ចេញចាកផ្ទះបួសជាអ្នកមិនមានផ្ទះនេះ) ជាទីដែលភិក្ខុត្រូវរលឹក គឺ មិនភ្លេចរហូតអស់មួយជីវិតឡើយ យ៉ាងនេះថា យើងបួសហើយគ្រង់គល់ឈើឯណោះ ក្នុងទីចង្ក្រមឯណោះ ក្នុងរោងឧបសម្បទាឯណោះ ក្នុងវិហារឯណោះ ក្នុងជនបទឯណោះ ក្នុងរដ្ឋឯណោះ ។

បទថា **ឥទំ ទុក្ខំ** (នេះទុក្ខ) សេចក្តីថា ទុក្ខមានត្រឹមប៉ុណ្ណោះ មិនមានទុក្ខក្រៅអំពីនេះ ។ បទថា **អយំ ទុក្ខសមុទយោ** (នេះហេតុកើតឡើងនៃទុក្ខ) សេចក្តីថា ហេតុកើតឡើងនៃទុក្ខមានត្រឹមតែប៉ុណ្ណោះ មិនមានហេតុកើតឡើងនៃទុក្ខដទៃពីនេះ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះឯង ។

ព្រះមានព្រះភាគត្រាស់សោតាបត្តិមគ្គទុកដោយសច្ចៈ ៤ ក្នុងសូត្រនេះ ដូចពណ៌នាមកដូច្នេះ ។ ចំណែកកសិណបរិកម្ម និងវិបស្សនាញាណ អាស្រ័យមគ្គទាំងនោះ ។

បទថា **សរណីយំ ហោតិ** (ជាទីរឭក) សេចក្តីថា (ស្ថានទីដែលភិក្ខុបានសម្រេចជាព្រះសោតាបន្ន) ជាស្ថានទីដែលភិក្ខុត្រូវរលឹក គឺ មិនភ្លេចរហូតអស់មួយជីវិតថា យើងសម្រេចជាព្រះសោតាបន្ន ត្រង់គល់ឈើឯណោះ ។ល។ ក្នុងវង្គឯណោះ ។ បទថា **អាសវានំ ខយា** (ព្រោះអស់អាសវៈទាំងឡាយ) បានដល់ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ។ បទថា **អនាសវំ ចេតោវិមុត្តឹ** (ចេតោវិមុត្តិដែលរកអាសវៈមិនបាន) បានដល់ ផលសមាធិ ។ បទថា **បញ្ញាវិមុត្តឹ** បានដល់ ផលប្បញ្ញា ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** (ធ្វើឲ្យជាក់ច្បាស់ ... ដោយការដឹងដ៏ក្រៃលែងដោយខ្លួនឯង) សេចក្តីថា ការធ្វើឲ្យប្រចក្សដោយបញ្ញាដ៏វិសេសក្រៃលែង ដោយខ្លួនឯង ។ បទថា **ឧបសម្បជ្ជ វិហរតិ** (ចូលដល់ហើយ) បានដល់ បានហើយ ។ បទថា **សរណីយំ** (ជាទីរឭក) សេចក្តីថា ធម្មតាថា ស្ថានទីដែលខ្លួនឯងបានសម្រេចជាព្រះអរហន្តជាស្ថានទីដែលភិក្ខុត្រូវរលឹក គឺ មិនភ្លេចរហូតអស់ជីវិតថា យើងបានសម្រេចជាព្រះអរហន្តត្រង់គល់ឈើឯណោះ ។ល។ ក្នុងវង្គឯណោះ ។

ព្រះមានព្រះភាគទ្រង់បញ្ចប់ព្រះធម៌ទេសនាតាមអនុសន្ធិ ដូចពោលមក នេះឯង ។

ចប់អដ្ឋកថា សារណីយសូត្រទី ២

# អដ្ឋកថា ភិក្ខុសូត្រ ៣

## “បុគ្គល ៣ ពួកក្នុងផ្លូវលោក និងផ្លូវធម៌”

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភិក្ខុសូត្រទី ៣ ដូចតទៅនេះ ៖-*

[១៣] *បទថា* ***សន្តា*** *(មាន) បានដល់ មានហើយ គឺ រកបានហើយ ។ បទថា* ***សំវិជ្ជមានា*** *(ប្រាកដហើយ) ជាវេវចនៈរបស់បទថា* ***សន្តា*** *នោះឯង ។ បទថា* ***លោកស្មឹ*** *(ក្នុងលោក) បានដល់ ក្នុងសត្វលោក ។ បទថា* ***និរាសោ*** *(បុគ្គលគ្មានសង្ឃឹម) បានដល់ បុគ្គលដែលមិនមានសេចក្ដីសង្ឃឹម គឺ មិនមានសេចក្ដីប្រាថ្នា ។*

### អធិប្បាយបទថា អាសំសោ-វិគតាសោ

*បទថា* ***អាសំសោ*** *(បុគ្គលមានសេចក្ដីប្រាថ្នា) បានដល់ បុគ្គលនៅប្រាថ្នា គឺ នៅមានសេចក្ដីប្រាថ្នា ។ បទថា* ***វិគតាសោ*** *(បុគ្គលអស់សេចក្ដីប្រាថ្នា) បានដល់ បុគ្គលដែលដកសេចក្ដីប្រាថ្នាហើយ ។ បទថា* ***ចណ្ឌាកុលេ*** *(ត្រកូលចណ្ឌាល) បានដល់ ក្នុងត្រកូលរបស់មនុស្សចណ្ឌាលទាំងឡាយ ។ បទថា* ***វេណកុលេ*** *(ត្រកូលអ្នកតម្បាញ) បានដល់ ក្នុងត្រកូលរបស់ជាងត្បាញផែង ។ បទថា* ***នេសាទកុលេ*** *(ត្រកូលព្រាន) បានដល់ ក្នុងត្រកូលរបស់ព្រាន មានព្រានម្រឹគជាដើម ។ បទថា* ***រថការកុលេ*** *(ត្រកូលជាងរថ)*

បានដល់ ក្នុងត្រកូលជាងស្បែក ។ បទថា **បុក្កុសកុលេ** (ត្រកូលអ្នកចោលសម្រាម) បានដល់ ក្នុងត្រកូលអ្នកចោលផ្កាឈើ[១] ។

លុះទ្រង់សម្តែងសេចក្តីវិបត្តិរបស់ត្រកូល ដោយហេតុត្រឹមតែប៉ុណ្ណោះហើយ ឥឡូវនេះ ព្រោះហេតុដែលបុគ្គលខ្លះ សូម្បីកើតក្នុងត្រកូលទាប ក៏ញុំាំងធនជាន មានទ្រព្យច្រើន តែបុគ្គលដែលមិនមានប្រាថ្នានេះ មិនដូច្នោះទេ ដូច្នោះ កាលទ្រង់សម្តែងដល់សេចក្តីវិបត្តិនៃភោគៈរបស់គេ ទើបត្រាស់បទថា **ទលិទ្ទេ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ទលិទ្ទេ** (ក្រលំបាក) បានដល់ បុគ្គលប្រកបដោយភាពជាអ្នកក្រលំបាក ។ បទថា **អប្បន្នបានភោជនេ** (ខ្វះខាតបាយទឹកភោជន) បានដល់ ត្រកូលដែលមានបាយទឹក និងរបស់បរិភោគតិច ។ បទថា **កសិរវុត្តិកេ** (រស់នៅលំបាក) បានដល់ ត្រកូលដែលមានការចិញ្ចឹមជីវិតលំបាក អធិប្បាយថា ក្នុងត្រកូលដែលគេទាំងឡាយប្រើសេចក្តីព្យាយាមប្រារព្ធព្យាយាមយ៉ាងខ្លាំងក្លា ទើបសម្រេចការចិញ្ចឹមជីវិត ។ បទថា **យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ** (រកអាហារ និងគ្រឿងស្លៀកដណ្តប់បានដោយលំបាក) សេចក្តីថា បុគ្គលក្នុងត្រកូលណា ធ្វើការរកស៊ី បានរបស់បរិភោគ

---

១-អ្នកចោលឧច្ចារៈរបស់នាយចៅហ្វាយ ។

គឺ បាយយាគូ និងភត្ត និងគ្រឿងស្លៀកដណ្តប់ដែលល្មមបិទបាំងអវយវៈដែល គួរខ្មាស បានដោយលំបាក ។

ឥឡូវនេះ ព្រោះហេតុដែលបុគ្គលខ្លះ សូម្បីកើតក្នុងត្រកូលទាប មាន ឧបធិសម្បត្តិ គឺ តាំងនៅក្នុងការដែលមានរាងកាយសមប្រកប ប៉ុន្តែថា បុគ្គល នេះមិនដូច្នោះ ដូច្នោះ ដើម្បីទ្រង់សម្តែងសេចក្តីវិបត្តិនៃរាងកាយរបស់គេ ព្រះ មានព្រះភាគ ទើបត្រាស់បទថា **ជាបុគ្គលមានសម្បុរអាក្រក់** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ទព្វណ្ណោ** (ជាបុគ្គលមានសម្បុរអាក្រក់) សេចក្តីថា មានពណ៌សម្បុរដូចត្រូវភ្លើងឆេះ ស្រដៀងបិសាចធូលី ។

បទថា **ទុទ្ទសិកោ** (អ្នកផងមិនចង់មើល) បានដល់ មិនជាទីចម្រើន ភ្នែកសូម្បីមាតាបង្កើតគេ ។ បទថា **ឱកោដិមកោ** បានដល់ មនុស្សតឿ ។ បទថា **កាណោ** (ភ្នែកខ្វាក់) បានដល់ បុគ្គលខ្វាក់ភ្នែកម្ខាងខ្លះ បុគ្គលខ្វាក់ភ្នែក ទាំងពីរខាងខ្លះ ។ បទថា **កុណិ** (ក្ញែង) បានដល់ បុគ្គលមានដៃក្ញែងម្ខាងខ្លះ ទាំងពីរខាងខ្លះ ។ បទថា **ខញ្ជ** (ខ្វក) បានដល់ បុគ្គលខ្វកជើងម្ខាងខ្លះ ខ្វកទាំងពីរខាងខ្លះ ។ បទថា **បក្ខហតោ** បានដល់ មនុស្សពិការ ។

បទថា **បទីបេយ្យស្ស** (គ្រឿងប្រទីប) បានដល់ ឧបករណ៍បំភ្លឺ មាន ប្រេង និងក្បៀងជាដើម ។ បទថា **តស្ស ន ឯវំ ហោតិ** (សេចក្តីប្រាថ្នា

យ៉ាងនេះ មិនមានដល់បុគ្គលនោះ) សេចក្តីថា បុគ្គលនោះ រមែងមិនមានការគិតយ៉ាងនេះ ។

សួរថា ព្រោះអ្វី ទើបមិនមាន ។

ឆ្លើយថា ព្រោះគេកើតក្នុងត្រកូលទាប ។

បទថា **ជេដ្ឋោ** (អង្គធំ) សេចក្តីថា កាលព្រះរាជឱរសមួយអង្គទៀតជាអង្គធំនៅមាន ព្រះរាជឱរសអង្គតូច ក៏ទ្រង់មិនធ្វើសេចក្តីប្រាថ្នា ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **អង្គធំ** ដូច្នេះ ។ បទថា **អភិសេកោ** (ទឹកអភិសេក) សេចក្តីថា សូម្បីមានព្រះរាជឱរសពីរអង្គធំ ក៏មិនគួរអភិសេក ទើបទ្រង់មិនធ្វើសេចក្តីប្រាថ្នា ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ទឹកអភិសេក** ដូច្នេះ ។ បទថា **អនភិសិត្តោ** (មិនទាន់បានទទួលអភិសេក) សេចក្តីថា សូម្បីព្រះរាជឱរសដែលគួរដល់ការអភិសេក ដែលវៀរចាកទោស មានព្រះនេត្រខ្វាក់ និងព្រះហស្តក្ញែងជាដើម បានទទួលអភិសេកម្តងហើយ ក៏ទ្រង់មិនធ្វើសេចក្តីប្រាថ្នាក្នុងការអភិសេកម្តងទៀត ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **មិនទាន់បានទទួលអភិសេក** ដូច្នេះ ។ បទថា **មចលបត្តោ** (ជាបុគ្គលមិនញាប់ញ័រ) សេចក្តីថា ចំណែកព្រះឱរសអង្គធំ កាលនៅជាព្រះរាជកុមារ មិនទាន់បានទទួលការអភិសេក ព្រះរាជឱរសនោះ មិន

បានធ្វើសេចក្ដីប្រាថ្នាក្នុងការអភិសេក តែតមក ទ្រង់មានព្រះជន្មាយុបាន ១៦ វស្សា ផ្ដើមមានព្រះមស្សុប្រាកដ ឈ្មោះថា ទ្រង់សម្រេចនិតិការៈ អាចនឹងកាន់រាជការធំបាន ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ជាបុគ្គលមាំទាំ** ដូច្នេះ ។ បទថា **តស្ស ឯវំ ហោតិ** (សេចក្ដីប្រាថ្នាយ៉ាងនេះ រមែងមានដល់ព្រះឱរសនោះ) បានដល់ សួរថា ព្រោះហេតុអ្វី ព្រះរាជឱរសនោះ ទើបមានព្រះតម្រិះយ៉ាងនេះ ។ ឆ្លើយថា ព្រោះព្រះអង្គមានព្រះជាតិខ្ពង់ខ្ពស់ ។

បទថា **ទុស្សីលោ** (ជាអ្នកទ្រុស្តសីល) បានដល់ អ្នកមិនមានសីល ។ បទថា **បាបធម្មោ** (មានធម៌ដ៏លាមក) បានដល់ បុគ្គលមានធម៌ដ៏អាក្រក់ ។ បទថា **អសុចិ** (មិនស្អាត) បានដល់ អ្នកប្រកបដោយកម្មទាំងឡាយ មានកាយ-កម្មជាដើមដែលមិនស្អាត ។ បទថា **សង្កស្សរសមាចារោ** (មានការប្រព្រឹត្តគួរខ្ពើម) សេចក្ដីថា បុគ្គលមានសមាចារដែលបុគ្គលដទៃគប្បីរលឹកដល់ ដោយការខ្ពើមរអើម គឺ មានសមាចារជាទីតាំងនៃការខ្ពើមរអើមរបស់អ្នកដទៃយ៉ាងនេះថា បុគ្គលនេះប្រហែលជាធ្វើបាបកម្មនេះ ព្រោះគេបានឃើញបាបកម្មខ្លះដែលមិនសមគួរ ។ម្យ៉ាងទៀត អធិប្បាយថា មានសមាចារដែលខ្លួននោះឯងគប្បីរលឹកដល់ដោយចិត្ត ឈ្មោះថា មានការប្រព្រឹត្តគួររង្កៀស ។ ពិតហើយ ភិក្ខុនោះ ឃើញភិក្ខុទាំងឡាយប្រជុំគ្នា ប្រឹក្សាគ្នាដល់រឿងខ្លះក្នុងទីទាំងឡាយ

មានទិសច្រោកពេលថ្ងៃជាដើម ហើយក៏មានការគិតយ៉ាងនេះថា ភិក្ខុទាំងនេះ ប្រជុំប្រឹក្សាគ្នា ពួកលោកដឹងកម្មដែលយើងធ្វើហើយទើបប្រឹក្សាគ្នាហ្ន៎ យ៉ាងនេះ គេឈ្មោះថា មានសមាចារដែលខ្លួនឯងគប្បីរលឹកដល់ដោយការរង្កៀស ។ បទថា **បដិច្ឆន្នកម្មន្តោ** (មានការងារដែលបិទបាំង) សេចក្តីថា បុគ្គលប្រកបដោយបាបកម្មដែលត្រូវបិទបាំង ។ បទថា **អស្សមណោ សមណបដិញ្ញោ** (មិនមែនជាសមណៈ តែប្តេជ្ញាថាជាសមណៈ) សេចក្តីថា បុគ្គលមិនមែនជាសមណៈ តែក៏ប្តេជ្ញាយ៉ាងនេះថា យើងជាសមណៈ ព្រោះគេជាសមណៈផ្ទុម ។

បទថា **អព្រហ្មចារី ព្រហ្មចារីបដិញ្ញោ** (មិនមែនជាសព្រហ្មចារី តែប្តេជ្ញាថា ជាព្រហ្មចារី) សេចក្តីថា បុគ្គលមិនជាព្រហ្មចារី តែឃើញអ្នកដទៃដែលជាព្រហ្មចារីស្លៀកដណ្តប់រៀបរយ គ្រងសំពត់ពណ៌ណផ្កាកុសមៈ ត្រាច់បិណ្ឌបាតចិញ្ចឹមជីវិតនៅក្នុងគាម និគម រាជធានី ក៏ធ្វើដូចជាប្តេជ្ញាថា យើងជាព្រហ្មចារី ព្រោះសូម្បីខ្លួនឯងក៏បដិបត្តិដោយអាការដូច្នោះ គឺ យ៉ាងនោះ ។ តែកាលពោលថា យើងជាភិក្ខុ ហើយចូលទៅកាន់រោងឧបោសថជាដើម ឈ្មោះថា បដិប្តេជ្ញាថាជាព្រហ្មចារីដោយពិត ។ កាលទទួលលាភរបស់សង្ឃ ក៏ទំនងដូចគ្នា ។

*បទថា **អន្តោបូតិ** (ជាបុគ្គលស្អុយក្នុង) បានដល់ មានខាងក្នុងប្រឡាក់ប្រឡូសដោយកម្មអាក្រក់ ។ បទថា **អវស្សុតោ** (ទទឹក) បានដល់ បុគ្គលទទឹកដោយកិលេសទាំងឡាយ មានរាគៈជាដើមដែលកើតរឿយៗ ។ បទថា **តស្ស ន ឯវំ ហោតិ** (ការប្រាថ្នាយ៉ាងនេះ មិនមានដល់បុគ្គលនោះ) សេចក្តីថា បុគ្គលនោះ មិនមានការគិតយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះគេមិនមានឧបនិស្ស័យនៃលោកុត្តរធម៌ ។ បទថា **តស្ស ឯវំ ហោតិ** (សេចក្តីប្រាថ្នាយ៉ាងនេះ រមែងមានដល់ភិក្ខុនោះ) សេចក្តីថា ព្រោះហេតុអ្វី លោកទើបមានការគិតយ៉ាងនេះ ព្រោះលោកជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូរណ៍ក្នុងមហាសីល ។*

ចប់អដ្ឋកថា ភិក្ខុសូត្រទី ៣

# អដ្ឋកថា ចក្កវត្តិសូត្រទី ៤

## *“រាជារបស់ស្តេចចក្រពត្តិ និងរបស់ព្រះពុទ្ធ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចក្កវត្តិសូត្រទី ៤ ដូចតទៅនេះ ៖-*

### *អត្ថនៃបទថា រាជា*

[១៤] *ឈ្មោះថា **រាជា** ព្រោះមានន័យថា ធ្វើឲ្យប្រជាជនស្រឡាញ់ដោយសង្គហវត្ថុ ៤ ។ ឈ្មោះថា **ចក្រពត្តិ** ព្រោះអត្ថថា ធ្វើចក្កឲ្យវិលទៅ ។ ឈ្មោះថា **ធម្មិកៈ** ព្រោះអត្ថថា មានធម៌ ។ ឈ្មោះថា **ធម្មរាជា** ព្រោះអត្ថថា ទ្រង់ជាព្រះរាជាដោយធម៌នោះឯង គឺ ដោយវត្តនៃចក្រពត្តិ ១០ ប្រការ ។ បទថា **សោបិ ន អរាជកំ** (ស្តេចចក្រពត្តិនោះ “រមែងមិនញ៉ាំងចក្ក” ដែលមិនមានព្រះរាជា “ឲ្យវិលទៅ”) សេចក្តីថា ស្តេចចក្រពត្តិនោះ កាលមិនបានព្រះរាជាដទៃជាទីអាស្រ័យ ក៏ទ្រង់មិនអាចព្រលែងចក្រទៅបាន ។*

*ព្រះសាស្តាទ្រង់ផ្តើមទេសនាទុកយ៉ាងនេះហើយ ក៏ទ្រង់ស្ងៀម ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះព្រះអង្គទ្រង់ព្រះតម្រិះថា ភិក្ខុទាំងឡាយអ្នកឆ្លាតក្នុងអនុសន្ធិ នឹងក្រោកឡើងសួរអនុសន្ធិ ព្រោះថា ក្នុងទីនេះមានភិក្ខុទំនងនោះច្រើន លុះតថាគតដែលភិក្ខុទាំងនោះសួរហើយ ទើបនឹងពង្រីកទេសនា ។ ក្នុងនោះ ភិក្ខុអ្នកឆ្លាតក្នុងអនុសន្ធិមួយរូប កាលនឹងទូលសួរព្រះ-*

មានព្រះភាគ ទើបក្រាបទូលពាក្យថា **បពិត្រព្រះអង្គដ៏ចម្រើន ក៏នរណា** ដូច្នេះជាដើម ។ ចំណែកព្រះមានព្រះភាគ កាលទ្រង់នឹងព្យាករណ៍ដល់ភិក្ខុនោះ ទើបត្រាស់ពាក្យថា **ភិក្ខុ ធម៌** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ធម្មោ** បានដល់ ធម្ម គឺ កុសលកម្មបថ ១០ ប្រការ ។ បទថា **ធម្មំ** បានដល់ ធម៌មានប្រការដូចពោលហើយនោះឯង ។ បទថា **និស្សាយ** (ទ្រង់អាស្រ័យ) បានដល់ ធ្វើធម៌នោះឯង ឲ្យជាទីអាស្រ័យផ្លូវចិត្ត ដែលតម្កល់ធម៌នោះទុកក្នុងចិត្ត ។ បទថា **ធម្មំ សក្ករោន្តោ** (ទើបទ្រង់សក្ការៈធម៌) សេចក្ដីថា ធម៌ដែលខ្លួនសក្ការៈហើយនុ៎ះឯង រមែងធ្វើដោយល្អដោយប្រការណា ក៏ធ្វើដោយប្រការនោះឯង ។ បទថា **ធម្មំ គរុករោន្តោ** (គោរពធម៌) សេចក្ដីថា គោរពធម៌នោះ ដោយការកើតសេចក្ដីគោរពក្នុងធម៌នោះ ។ បទថា **ធម្មំ អបចាមានោ** (លំឱនគោរពធម៌) សេចក្ដីថា ធ្វើសេចក្ដីឱនលំទោនបន្ទាបខ្លួនដោយសាមីចិកម្ម មានការផ្គងអញ្ជលីជាដើម ដល់ធម៌នោះឯង ។

បទថា **ធម្មទ្ធជោ ធម្មកេតុ** (មានធម៌ជាទង់ មានធម៌ជាសញ្ញា) សេចក្ដីថា ឈ្មោះថា ជាអ្នកមានធម៌ជាទង់ជ័យ និងឈ្មោះថា ជាអ្នកមានធម៌ជាសញ្ញា ព្រោះធ្វើធម៌នោះទុកខាងមុខ ដូចអ្នកចម្បាំងលើកទង់ទុកខាងមុខ និងលើកធម៌

នោះឡើង ដូចអ្នកចម្បាំងលើកលំពែងឡើងប្រព្រឹត្តទៅ ។ បទថា **ធម្មាធិប-តេយ្យោ** (មានធម៌ជាអធិបតី) សេចក្តីថា ឈ្មោះថា ជាអ្នកមានធម៌ជាធំ ព្រោះជាអ្នកមានធម៌ជាអធិបតី និងព្រោះធ្វើកិរិយាទាំងពួង (រាជកិច្ចគ្រប់យ៉ាង) ដោយអំណាចធម៌នោះឯង ។ ក្នុងបទថា **ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហាតិ** (ចាត់ការរក្សាឃុំគ្រងធម៌) គប្បីជ្រាបអធិប្បាយថា ការរក្សាជាដើម ឈ្មោះថា ប្រកបដោយធម៌ ព្រោះអត្ថថា មានធម៌ ។ ការរក្សា ការការពារ និងការឃុំគ្រងឈ្មោះថា ការរក្សា ការការពារ ការឃុំគ្រង ។ បណ្តាការរក្សា ការការពារនិងការឃុំគ្រងនោះ គុណធម៌ មានខន្តិជាដើម ឈ្មោះថា ការរក្សា ដូចព្រះ-ពុទ្ធវចនៈថា **បុគ្គលកាលរក្សាអ្នកដទៃ ឈ្មោះថា រក្សាខ្លួន** ។ សមដូចព្រះពុទ្ធតម្រាស់ដែលទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក៏បុគ្គលរក្សាអ្នកដទៃដោយវិធីយ៉ាងណា ទើបឈ្មោះថា រក្សាខ្លួន បុគ្គលរក្សាអ្នកដទៃដោយខន្តិដោយអវិហិង្សា ដោយមេត្តាចិត្ត (និង) ដោយសេចក្តីអាណិត ទើបឈ្មោះថា រក្សាខ្លួន ដូច្នេះ ។ ការការពារសម្បត្តិ មានសំពត់ស្លៀក សំពត់ដណ្តប់និងផ្ទះជាដើម ឈ្មោះថា ការការពារ ។ ការឃុំគ្រងដើម្បីការពារឧបទ្រវន្តរាយពីចោរជាដើម ឈ្មោះថា ការឃុំគ្រង ។ អធិប្បាយថា ស្តេចចក្រពត្តិ ទ្រង់ចាត់គឺ ទ្រង់ដាក់ការរក្សា ការការពារ និងការឃុំគ្រង ដែលត្រូវតាមធម៌នោះដោយ

ល្អ ។

## បុគ្គលដែលត្រូវទទួលការរក្សា

ឥឡូវនេះ កាលទ្រង់សម្ដែងបុគ្គលដែលនឹងត្រូវចាត់ការរក្សា ការពារ និងឃុំគ្រង ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **អន្តោជន** ដូច្នេះជាដើម ។ ក្នុងបទថា **អន្តោជន** (បុគ្គលខាងក្នុង) ជាដើមនោះ មានសេចក្ដីសង្ខេបដូចតទៅនេះ

ស្ដេចចក្រពត្តិ កាលទ្រង់ឲ្យព្រះរាជឱរស និងព្រះមហេសី ដែលហៅថា អ្នកខាងក្នុង តាំងនៅក្នុងសីលសំវរៈ ព្រះរាជទានសំពត់ គ្រឿងក្រអូប និងកម្រងផ្កាជាដើម ដល់ព្រះរាជឱរស និងព្រះមហេសីនោះ ព្រមទាំងការពារឧបទ្រវន្តរាយទាំងពួង ដល់ព្រះរាជឱរស និងព្រះមហេសីនោះ ឈ្មោះថា ចាត់ចែងការរក្សា ការពារ និងការឃុំគ្រងដែលជាធម៌ ។ សូម្បីក្នុងក្សត្រិយ៍ជាដើម ក៏មានន័យដូចគ្នានេះឯង ។ ចំណែកសេចក្ដីប្លែកគ្នាមានដូចតទៅនេះ ។

ក្សត្រិយ៍ដែលបានទទួលអភិសេកហើយ ស្ដេចចក្រពត្តិ ក៏ត្រូវទ្រង់អនុគ្រោះសូម្បីដោយការព្រះរាជទានរតនៈ មានសេះអាជានេយ្យ ដែលមានលក្ខណៈល្អជាដើមឲ្យ ។ ក្សត្រិយ៍ដែលជារាជបរិវារ ស្ដេចចក្រពត្តិ ក៏ទ្រង់ធ្វើឲ្យពេញព្រះទ័យ សូម្បីដោយការព្រះរាជទានយានពាហនៈដែលគួរឲ្យ ។

ពលទាហាន ស្តេចចក្រពត្តិ ក៏អនុគ្រោះសូម្បីដោយការព្រះរាជទានអាហារ តម្លៃឈ្នួល ដោយមិនឲ្យកន្លងវេលា ។

ព្រាហ្មណ៍ទាំងឡាយ ស្តេចចក្រពត្តិ ទ្រង់ក៏អនុគ្រោះដោយទេយ្យធម៌ មានបាយ ទឹក និងសំពត់ជាដើម ។ គហបតីទាំងឡាយ ស្តេចចក្រពត្តិ ទ្រង់ក៏អនុគ្រោះដោយព្រះរាជទានកត្ត ពូជ នង្គ័ល និងគោជាដើម ។ ប្រជាជនអ្នកនៅក្នុងនិគម ឈ្មោះថា អ្នកនិគម ប្រជាជនដែលនៅក្នុងជនបទ ឈ្មោះថា អ្នកជនបទ ប្រជាជនទាំងអស់នោះ ក៏ដូចគ្នា គឺ ស្តេចចក្រពត្តិទ្រង់ក៏អនុគ្រោះផងដែរ ។

ចំណែកសមណព្រាហ្មណ៍ទាំងឡាយ អ្នកមានបាបដែលស្ងប់ហើយ បណ្តេតបាបបានហើយ ស្តេចចក្រពត្តិទ្រង់ក៏សក្ការៈ ដោយព្រះរាជទានសមណ-បរិក្ខារ ។ ម្រឹគ និងបក្សីទាំងឡាយ ស្តេចចក្រពត្តិ ទ្រង់ក៏ធ្វើឲ្យរួចផុតភ័យ ដោយព្រះរាជទានអភ័យ ។

### ស្តេចចក្រពត្តិបុគ្គលណាជំទាស់មិនបាន

បទថា **ធម្មេនេវ ចក្កំ វត្តេតិ** ទ្រង់ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅដោយធម៌ នោះឯង) សេចក្តីថា ស្តេចចក្រពត្តិទ្រង់ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅដោយធម៌ គឺ កុសលកម្មបថ ១០ នុ៎ះឯង ។ បទថា **តំ ហោតិ ចក្កំ អប្បដិវត្តិយំ** (ចក្រនោះ

សេចក្តីថា ចក្រ គឺ អាជ្ញាសិទ្ធិនោះ គឺ ដែលស្តេចចក្រពត្តិនោះឲ្យវិលទៅហើយយ៉ាងនោះ ជារបស់ដែលមនុស្សណាឲ្យវិលត្រឡប់មិនបាន ។ បទថា **កេនចិ មនុស្សភូតេន** (ដែលសត្រូវណាៗ ជាមនុស្ស) សេចក្តីថា ធម្មតាទេវតាទាំងឡាយ រមែងធ្វើវត្ថុដែលខ្លួនប្រាថ្នា បានសម្រេចសមតាមប្រាថ្នា ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ដែលជាមនុស្ស ដូច្នេះ ដោយទ្រង់មិនរួមដល់ទេវតាទាំងនោះផង ។ បទថា **បច្ចត្ថិកេន** (ដែលសត្រូវ) បានដល់ សត្រូវ អធិប្បាយថា ជាសត្រូវគូបដិបក្ខ ។

បទថា **ធម្មិកោ** (ជាអ្នកទ្រទ្រង់ធម៌) សេចក្តីថា ស្តេចចក្រពត្តិទ្រង់ជាអ្នកទ្រទ្រង់ធម៌ដោយអំណាចកុសលធម្មបថ ១០ ចំណែកព្រះតថាគតទ្រង់ជាអ្នកទ្រទ្រង់ធម៌ ដោយអំណាចលោកុត្តរធម៌ ៩ ។ បទថា **ធម្មរាជា** (ជាព្រះធម្មរាជា) សេចក្តីថា ព្រះតថាគត ឈ្មោះថា ទ្រង់ជាព្រះធម្មរាជា ព្រោះអត្ថថា ធ្វើមហាជនឲ្យត្រេកអរ ដោយលោកុត្តរធម្ម ៩ ។ បទថា **ធម្មំយេវ** (ធម៌ប៉ុណ្ណោះ) សេចក្តីថា ព្រះតថាគតទ្រង់អាស្រ័យលោកុត្តរធម្ម ៩ នុ៎ះឯង ទើបសក្ការៈធម៌នោះ គោរពធម៌នោះ នមស្ការធម៌នោះ ។ ធម៌របស់ព្រះ-តថាគតនោះឯង ឈ្មោះថា ជាទង់ ព្រោះអត្ថថា ខ្ពស់ ព្រោះហេតុនោះ ព្រះតថាគតនោះ ទើបឈ្មោះថា មានធម៌ជាទង់ ។ ធម៌នោះឯង របស់ព្រះតថាគត

នោះ ជាសញ្ញា ព្រោះហេតុនោះ ព្រះតថាគតនោះ ទើបឈ្មោះថា មានធម៌ជាសញ្ញា ។ ព្រះតថាគតឈ្មោះថា ធម្មាធិបតេយ្យ ព្រោះអត្ថថា ទ្រង់ធ្វើធម៌ឲ្យជាអធិបតី គឺ ឲ្យជាធំ ។ បទថា **ធម្មិកំ រក្ខាវរណគុត្តឹ** (ការរក្សា ការពារឃុំគ្រងដែលជាធម៌) សេចក្តីថា ការរក្សា ការការពារ និងការឃុំគ្រង ដែលឲ្យលោកិយធម៌ និងលោកុត្តរធម៌ ។ បទថា **សំវិទហតិ** (ចាត់ចែង) បានដល់ទ្រង់ដាក់ គឺ ទ្រង់បញ្ញត្តិ ។ បទថា **ឯវរូបំ** (យ៉ាងនេះ) សេចក្តីថា បុគ្គលមិនគួរសេពទុច្ចរិត ៣ យ៉ាង មិនគួរសេពវត្ថុថោកទាប ។ ក្នុងគ្រប់បទ គប្បីជ្រាបអត្ថាធិប្បាយយ៉ាងនេះ ។

បទថា **សំវិទហិត្វា** (ចាត់ចែង) បានដល់ ទ្រង់ដាក់ទុក គឺ ត្រាស់ប្រាប់ ។ បទថា **ធម្មេនេវ អនុត្តរំ ធម្មចក្កំ បវត្តេតិ** (ញ៉ាំងព្រះធម្មចក្កដ៏កំពូលឲ្យប្រព្រឹត្តទៅដោយធម៌នោះឯង) សេចក្តីថា ព្រះតថាគតទ្រង់បន្លិលធម្មចក្ក ដែលមិនមាននរណាស្មើដូច ឲ្យប្រព្រឹត្តទៅដោយលោកុត្តរធម៌ ៩ នោះឯង ។ បទថា **តំ ហោតិ ចក្កំ អប្បដិវត្តិយំ** (ធម្មចក្រនោះ ជាចក្រដែល... ជំទាស់មិនបាន) សេចក្តីថា ចក្រ គឺ ធម្មនោះ ដែលព្រះតថាគតឲ្យវិលទៅហើយយ៉ាងនោះ ដែលនរណាៗ សូម្បីត្រឹមតែម្នាក់ ក្នុងបណ្តាបុគ្គលទាំងនេះ មានសមណៈជាដើម មិនអាចនឹងឲ្យវិលត្រឡប់ គឺ ជំទាស់បាន ។ បទដ៏សេស

*ក្នុងទីគ្រប់កន្លែង ឆ្ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ចក្កវត្តិសូត្រទី ៤

# អដ្ឋកថា បចេតនសូត្រទី ៥

## *“ការរៀបនៃឈើ និងមនុស្ស”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បចេតនសូត្រទី ៥ ដូចតទៅនេះ ៈ-*

[១៥] *អត្ថរបស់បទថា* ***ឥសិបតនេ*** *(នៅឥសិបតនៈ) សេចក្តីថា ដែលជាទីនៅនៃពួកឥសី ពោលគឺ ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធមកសម្រាក ដើម្បីប្រកាសធម្មចក្រ និងដើម្បីត្រូវការធ្វើឧបោសថ អធិប្បាយថា ទីប្រជុំ ។ បាឋៈថា* ***បទនេ*** *ដូច្នេះ ក៏មាន ។ អត្ថក៏យ៉ាងនេះដូចគ្នា ។ បទថា* ***មិគទាយេ*** *(មិគទាយវ័ន) សេចក្តីថា ក្នុងព្រៃដែលព្រះរាជទានដល់ម្រឹគទាំងឡាយ ដើម្បីត្រូវការឲ្យជាទីដែលមិនមានភ័យ ។*

*បទថា* ***ឆហិ មាសេហិ ឆារត្តូនេហិ*** *(អស់វេលា ៦ ខែ នៅខ្វះ ៦ ថ្ងៃ) សេចក្តីថា បានឮថា ជាងរថនោះចាត់ចែងឧបករណ៍គ្រប់ប្រភេទ ហើយចូលព្រៃព្រមជាមួយកូនសិស្សច្រើននាក់ ក្នុងថ្ងៃដែលបានទទួលព្រះបរមរាជឱង្ការ ហើយ រៀរដើមឈើដែលដុះនៅតាមទ្វារស្រុក កណ្តាលស្រុក ទេវស្ថាន និងព្រៃស្មសានជាដើម និងដើមឈើដែលត្រូវភ្លើងឆេះ ដើមឈើដែលរលំ និងដើមឈើងាប់ ជ្រើសរើសយកដើមឈើដែលដុះនៅក្នុងភូមិប្រទេសដែលល្អប្រាសចាកទោសទាំងអស់ សមគួរប្រើធ្វើដុំ កាំ និងកង់ បានយកមកធ្វើជាកង់*

រថនោះ ។ កាលជាងឈើជ្រើសរើសយកដើមឈើមកធ្វើជាកង់រថនៅហើយ វេលា ៦ ខែខ្វះ ៦ រាត្រី ក៏កន្លងទៅ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា **អស់វេលា ៦ ខែ ខ្វះ ៦ ថ្ងៃ** ដូច្នេះ ។

បទថា **នានាករណំ** (ផ្សេងគ្នា) បានដល់ សេចក្តីផ្សេងគ្នា ។ បទថា **នេសំ** កាត់បទជា **ន ឯសំ** បានដល់ យើងមិនឃើញសេចក្តីផ្សេងគ្នានៃកង់ទាំងនោះ ។ បទថា **អត្ថេសំ** កាត់បទជា **អត្ថិ ឯសំ** បានដល់ សេចក្តីផ្សេងគ្នានៃកង់ទាំង ២ នោះ មានហើយព្រះអង្គ ។ បទថា **អភិសង្ខារស្ស គតិ** (ទៅក្នុងទីបំផុតនៃកម្លាំង) បានដល់ វិលទៅកាន់ទីអស់កម្លាំង ។ បទថា **ចិង្គុ-លាយិត្វា** បានដល់ ដួលទៅ ។ បទថា **អក្ខាហតំ មញ្ញេ** (ហាក់ដូចជាជាប់នឹងភ្លៅ) សេចក្តីថា ដូចជាខ្ចាស់ត្រង់ភ្លៅ ។ បទថា **សទោសា** (មានទោស) សេចក្តីថា មានពក គឺ ប្រកបដោយពករដិបរដុប ។ បទថា **សកសាវា** (មានស្រាយ) សេចក្តីថា ជាប់ខ្លឹមដែលស្អុយ និងស្រាយ ។

បទថា **កាយវង្កា** (វៀចផ្លូវកាយ) ជាដើម ជាឈ្មោះនៃទុច្ចរិតទាំងឡាយមានកាយទុច្ចរិតជាដើម ។ បទថា **ឯវំ បបតិតា** (ធ្លាក់ទៅ...យ៉ាងនេះ) សេចក្តីថា ធ្លាក់ទៅដោយខុសចាកគុណសេចក្តីល្អយ៉ាងនេះ ។ បទថា **ឯវំ បតិដ្ឋិតា** (តាំងមាំ...យ៉ាងនេះ) សេចក្តីថា តាំងនៅដោយគុណធម៌ទាំងឡាយ

យ៉ាងនេះ ។ ក្នុងបុគ្គល ៦ ប្រភេទនោះ លោកិយមហាជន ឈ្មោះថា ធ្លាក់ទៅហើយចាកគុណសេចក្ដីល្អ ។ ចំណែកព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ឈ្មោះថា តាំងមាំហើយក្នុងគុណសេចក្ដីល្អ ។ សូម្បីក្នុងបណ្ដាព្រះអរិយបុគ្គលទាំង ៤ ប្រភេទនោះ ព្រះអរិយបុគ្គល ៣ ប្រភេទខាងដើម ឈ្មោះថា ធ្លាក់ទៅហើយចាកគុណសេចក្ដីល្អ ក្នុងខណៈដែលកិលេសទាំងឡាយកើតឡើង ។ ចំណែកព្រះខីណាស្រព ឈ្មោះថា តាំងមាំហើយដោយចំណែកតែម្យ៉ាងដោយពិត ។ បទថា **តស្មា** (ព្រោះហេតុនោះ) សេចក្ដីថា ព្រោះហេតុដែលព្រះអរិយៈ ៣ ប្រភេទខាងដើម នៅលះសេចក្ដីវៀចវេរកាយមិនបានជាដើមទើបធ្លាក់ទៅ ចំណែកព្រះខីណាស្រពទាំងឡាយ លះសេចក្ដីវៀចវេរកាយជាដើមបានហើយ រមែងតាំងមាំនៅក្នុងគុណសេចក្ដីល្អ ។

មួយទៀត គប្បីជ្រាបការលះសេចក្ដីវៀចវេរកាយជាដើម ដូចតទៅនេះ អកុសលកម្មបថ ៦ ប្រការទាំងនេះ គឺ **បាណាតិបាត អទិន្នាទាន មិច្ឆាចារៈ មុសាវាទ បិសុណាវាចា មិច្ឆាទិដ្ឋិ** ព្រះអរិយបុគ្គល រមែងលះបានដោយសោតាបត្តិមគ្គ ។ ពីរយ៉ាង គឺ **ផរុសវាចា ព្យាបាទ** លះបានដោយអនាគាមិមគ្គ ។ ពីរយ៉ាងគឺ **អភិជ្ឈា សម្ផប្បលាបៈ** លះបានដោយអរហត្តមគ្គ ។

ចប់អដ្ឋកថា បចេតនសូត្រទី ៨

# អដ្ឋកថា អបណ្ណកសូត្រទី ៦

## *"ការបដិបត្តិមិនខុស"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អបណ្ណកសូត្រទី ៦ ដូចតទៅនេះ ៖-*

[១៦] *បទថា* ***អបណ្ណកប្បដិបទំ*** *(អបណ្ណកប្បដិបទា) សេចក្តីថា ព្រះអរិយបុគ្គលជាអ្នកបដិបត្តិវត្តបដិបត្តិដែលមិនខុស គឺ វត្តបដិបត្តិដែលល្អ ដោយចំណែកមួយ វត្តបដិបត្តិដែលនាំសត្វចេញចាកកាម វត្តបដិបត្តិដែលប្រកប ដោយហេតុ វត្តបដិបត្តិដែលមានសារៈ វត្តបដិបត្តិដែលជាគោល (មណ្ឌបដិ-បទា) វត្តបដិបត្តិដែលមិនជាសត្រូវ វត្តបដិបត្តិដែលសមគួរ វត្តបដិបត្តិធម៌ សមគួរដល់ធម៌ មិនមែនបដិបត្តិដោយការប៉ាន់ស្មាន (តក្កវិជ្ជា) ឬដោយកាន់ យកតាមន័យ ។ ព្រោះថា ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលបដិបត្តិដូច្នេះ (កាន់យកដោយតក្កៈ កាន់យកដោយន័យ) នឹងវិនាសចាកមនុស្សសម្បត្តិ ទេវ-សម្បត្តិ និងនិព្វានសម្បត្តិ ។ ចំណែកអ្នកបដិបត្តិអបណ្ណកប្បដិបទា នឹងមិន វិនាសចាកសម្បត្តិទាំងនោះ ។*

### *នាយកឯរទេះ ២ ពួក*

*ដូចក្នុងអតីតសម័យ កាលនាយកឯរទេះ ២ ពួក ធ្វើដំណើរទៅកាន់ ទីកន្តារ នាយកឯរទេះល្ងង់ខ្លៅ ជឿពាក្យរបស់យក្ខ ដល់នូវសេចក្តីវិនាសព្រម*

ទាំងពួកឈ្មួញ (ចំណែក) នាយកងរទេះដែលឆ្លាត មិនជឿស្តាប់ពាក្យរបស់យក្ខ គិតថា យើងនឹងលះបង់ទឹកក្នុងទីដែលយើងបានជួបទឹក ដូច្នេះហើយ ឲ្យសញ្ញាទឹងពួកឈ្មួញ ហើយទើបធ្វើដំណើរទៅ ដែលលោកសំដៅយក ពោល គាថានេះថា

បុគ្គលពួកមួយ បានពោលឋានៈដែលមិនខុស អ្នកប៉ិនស្មាន
ពោលឋានៈទីពីរ (ខុស) អ្នកប្រាជ្ញដឹងឋានៈត្រូវខុសហើយ
គួរកាន់យកតែឋានៈដែលមិនខុស ។

បទថា **យោនិ** ក្នុងបទថា **យោនិ ចស្ស អារទ្ធា ហោតិ** នេះ ជាឈ្មោះចំណែកនៃខន្ធខ្លះ ហេតុខ្លះ បស្សាវមគ្គខ្លះ ។ ពិតហើយ ចំណែកនៃខន្ធ ឈ្មោះថា **យោនិ** មានមកក្នុងបទមានអាទិ៍ថា **ចតស្សោ ខោ សារិបុត្ត យោនិយោ** ប្រែថា ម្នាលសារីបុត្រ កំណើតទាំងនេះមាន ៤ យ៉ាង ។ ហេតុ ឈ្មោះថា **យោនិ** ក្នុងបទជាដើមថា **យោនិ ហេសា ភូមិជ ផលស្ស អធិគ-មាយ** ប្រែថា ម្នាលភូមិជៈ ក៏នោះជាហេតុ ដើម្បីសម្រេចផល ។ បស្សាវមគ្គ ឈ្មោះថា **យោនិ** មានមកក្នុងបទមានជាអាទិ៍ថា **ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិសម្ភវំ** ប្រែថា តថាគតមិនពោលអ្នកដែលកើតពីទ្វារប្រសូតិ គឺកើតពីមាតា ថាជាព្រាហ្មណ៍ឡើយ ។ ក្នុងបទមានជាអាទិ៍ថា **តមេនំ កម្មជា**

វាតា និវត្តិត្វា ឧទ្ធំបាទំ អធោសិរំ សម្បរិវត្តេត្វា មាតុយោនិមុខេ សម្បដិ-បាទេន្តិ ប្រែថា ខ្យល់កម្មជវាត បក់សត្វនោះ ឲ្យមានជើងឡើងខាងលើ សិរសៈត្រឡប់ចុះខាងក្រោម ហើយទៅឈប់នៅត្រង់មាត់ទ្វារប្រសូតិរបស់មាតា ។ តែក្នុងទីនេះ ទ្រង់បំណងយក **ហេតុ** ថាជា **យោនិ** ។ បទថា **អារទ្ធា** (បានផ្តើមហើយ) បានដល់ ផ្គងទុក គឺ ធ្វើឲ្យបរិបូរណ៍ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **អាសវានំ ខយាយ** (នៃការអស់អាសវៈ) ដូចតទៅនេះ ។ កិលេស ឈ្មោះថា អាសវៈ ព្រោះអត្ថថា ហូរមក ។ មានអធិប្បាយថា ហូរមកផ្លូវភ្នែកខ្លះ ។ល។ ផ្លូវចិត្តខ្លះ ។ម្យ៉ាងទៀត ឈ្មោះថា អាសវៈ ព្រោះហូរចាកធម៌ ដរាបដល់គោត្រភូ ចាកឱកាសលោក ដរាបដល់ភវគ្គព្រហ្ម ។ អធិប្បាយថា ធ្វើធម៌ទាំងនេះ និងឱកាសលោកនោះ ទុកក្នុងខាងក្នុងប្រព្រឹត្តទៅ ។ ពិតហើយ ន័យថា ធ្វើទុកក្នុងខាងក្នុងនេះ ជាអាការរបស់អាសវៈ ។ ឈ្មោះថា អាសវៈ ព្រោះដូចជាគ្រឿងត្រាំទាំងឡាយ មានគ្រឿងត្រាំជាដើម ដោយន័យថា ច្រើនត្រាំទុកយូរ ។ ពិតហើយ សូម្បីក្នុងផ្លូវលោក គេក៏ហៅរបស់ដែលត្រាំទុកយូរ មានស្រាជាដើមថា អាសវៈ ។ ក៏បើគ្រឿងត្រាំទាំងឡាយ មានស្រាជាដើម ឈ្មោះថា អាសវៈ ព្រោះអត្ថថាត្រាំទុកយូរហើយសោត កិលេសទាំងនោះ ក៏គួរជាអាសវៈដូចគ្នា ។ សមដូច

ព្រះពុទ្ធតម្រាស់ ដែលត្រាស់ទុកមានជាអាទិថា **បុរិមា ភិក្ខវេ កោដិ ន បញ្ញាយតិ អវិជ្ជាយ ឥតោ បុព្វេ អវិជ្ជា នាហោតិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ខាងដើមរបស់អវិជ្ជា មិនប្រាកដ មុនអំពីនេះ អវិជ្ជាមិនមាន ។ ម្យ៉ាងទៀត កិលេស ឈ្មោះថា អាសវៈ ព្រោះហូរទៅ គឺ ប្រសព្វសង្សារទុក្ខតទៅ ដូច្នេះខ្លះ ។ ក៏ក្នុងចំនួនវិគ្រោះទាំង ៤ នេះ វិគ្រោះដើមៗ (វិគ្រោះ ៣ យ៉ាង) ប្រើបានក្នុងទីដែលកិលេសទាំងឡាយមក (ដោយឈ្មោះថា) អាសវៈ តែវិគ្រោះក្រោយប្រើបានចំពោះក្នុងកម្ម ។ ក៏កម្មកិលេសតែម្យ៉ាងប៉ុណ្ណោះ ជាអាសវៈ ក៏មិនមែន ដោយពិត សូម្បីឧបទ្រវនានប្បការ ក៏ជាអាសវៈ ។ ព្រោះក្នុងព្រះសូត្រទាំងឡាយ កិលេសដែលមានការវិវាទជាមូល មកហើយ (ដោយឈ្មោះថា) អាសវៈ ដូចក្នុងប្រយោគនេះថា **នាហំ ចុន្ទ ទិដ្ឋធម្មិកានំយេវ អាសវានំ សំវរាយ ធម្មំ ទេសេមិ** ប្រែថា នែចុន្ទៈ តថាគតនឹងមិនសម្តែងធម៌ដើម្បីបិទអាសវៈទាំងឡាយក្នុងបច្ចុប្បន្នប៉ុណ្ណោះ ។

ធម៌ដែលជាហេតុឲ្យកើតក្នុងភូមិ ៣ និងអកុសលធម៌ដ៏សេស មកហើយ (ដោយឈ្មោះថា) អាសវៈ ដូចក្នុងប្រយោគនេះថា

*អាសវៈទាំងឡាយរបស់តថាគត ដែលជាហេតុឲ្យចូលដល់ភាពជាទេវតា ឬជាហេតុឲ្យជាគន្ធព្វ ហោះទៅក្នុងអាកាស ជាហេតុ*

ឲ្យដល់ភាពជាយក្ខ ជាមនុស្ស និងជាសត្វកើតក្នុងទឹក អស់ហើយ អាសវៈទាំងនោះតថាគតកម្ចាត់ហើយ ធ្វើឲ្យដាច់ឫសហើយ ។

ឧបទ្រវនានប្បការ មានការពោលប្រទូស្តអ្នកដទៃ បន្តរការក្តៅក្រហាយ ការសម្លាប់ ការឃុំឃាំងជាដើមក្តី ជាហេតុឲ្យបានទទួលទុក្ខក្នុងអបាយក្តី មកហើយដោយឈ្មោះថា អាសវៈ ដូចក្នុងប្រយោគនេះថា **ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ** ប្រែថា តថាគតសម្តែងធម៌ដើម្បីបិទអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ដើម្បីកម្ចាត់អាសវៈទាំងឡាយ ក្នុងខាងមុខ ។

ក៏អាសវៈទាំងឡាយនោះ ក្នុងទីណា មកហើយយ៉ាងណា ក្នុងទីនោះគប្បីជ្រាបយ៉ាងនោះ ។ ព្រោះថា អាសវៈទាំងនេះ ក្នុងព្រះវិន័យ មានមក ២ យ៉ាងថា ដើម្បីបិទអាសវៈក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់អាសវៈក្នុងខាងមុខ ១ ។ ក្នុងសឡាយតនវគ្គ មានមក ៣ យ៉ាងថា ម្នាលលោកដ៏មានអាយុ អាសវៈមាន ៣ យ៉ាងទាំងនេះ គឺ កាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាៈ ១ តែក្នុងព្រះសូត្រដទៃៗ និងក្នុងអភិធម្ម មានមក ៤ យ៉ាង ព្រមទាំងទិដ្ឋាសវៈ ។ ក្នុងនិព្វេធិកបរិយាយសូត្រ អាសវៈទាំងឡាយមាន ៥ យ៉ាង ដូច្នេះថា មាន

ហើយ ម្នាលភិក្ខុទាំងឡាយ អាសវៈជាហេតុឲ្យទៅកាន់នរក ១ អាសវៈជាហេតុឲ្យទៅកាន់កំណើតតិរច្ឆាន ១ អាសវៈជាហេតុឲ្យទៅកាន់បិត្តិវិស័យ ១ អាសវៈជាហេតុឲ្យទៅកាន់មនុស្សលោក ១ អាសវៈជាហេតុឲ្យទៅកាន់ទេវលោក ១ ។ តែក្នុងទីនេះ កម្មនុ៎ះឯង ត្រាស់ថាជា អាសវៈ ។ ក្នុងឆក្កនិបាត អាសវៈទាំងឡាយមកហើយ ៦ យ៉ាង ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ អាសវៈដែលគប្បីលះដោយសំវរៈ ក៏មាន ។ ក្នុងសព្វាសវបរិយាយសូត្រ អាសវៈ ៦ យ៉ាង ទាំងនោះឯង មានមកជា ៧ យ៉ាង ព្រមដោយអាសវៈទាំងឡាយ ដែលគប្បីលះដោយទស្សនៈ ។ តែក្នុងទីនេះ គប្បីជ្រាបថា ទ្រង់បំណងយកអាសវៈទាំង ៤ តាមន័យនៃព្រះអភិធម្ម ។

ការទម្លាយអាសវៈបានដោយខណៈក្តី អាការដែលអាសវៈអស់ទៅដោយមិនមានសល់ក្តី មគ្គផល ព្រះនិព្វានក្តី ត្រាស់ហៅថា **អាសវក្ខយ** (ការអស់អាសវៈ) ក្នុងបទថា **ខយាយ** (នៃការអស់) នេះ ។ ពិតណាស់ ការទម្លាយអាសវៈបានដោយខណៈ ត្រាស់ហៅថា **អាសវក្ខយ** ដូចក្នុងប្រយោគនេះថា **យោ អាសវានំ ខយោ វយោ ភេទោ អនិច្ចតា អន្តរធានំ** ប្រែថា ការអស់ទៅ ការវិនាសទៅ ការទម្លាយ សេចក្តីមិនទៀង សេចក្តីអន្តរធាននៃអាសវៈទាំងឡាយ ។

ការលះអាសវៈ ការអស់ទៅនៃអាសវៈដោយចំណែកមួយ ការមិនកើតឡើងនៃអាសវៈ អាការដែលអាសវៈអស់ទៅ ការមិនមាននៃអាសវៈទាំងឡាយ ត្រាស់ហៅថា **អាសវក្ខយ** ដូចក្នុងប្រយោគនេះថា **ជានតោ អហំ ភិក្ខវេ បស្សតោ អាសវានំ ខយំ វទាមិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលការអស់ទៅនៃអាសវៈទាំងឡាយ សម្រាប់ភិក្ខុដែលដឹងហើយឃើញនៅ ។

មគ្គ ត្រាស់ហៅថា **អាសវក្ខយ** ដូចក្នុងគាថានេះថា

**សេក្ខស្ស សិក្ខមានស្ស ឧជុមគ្គានុសារិនោ**
**ខយស្មឹ បឋមំ ញាណំ តតោ អញ្ញា អនន្តរា**

កាលបុគ្គលសិក្សារៀនសូត្រហើយ ប្រព្រឹត្តទៅតាមផ្លូវដែលត្រង់ ក្នុងខណៈអស់អាសវៈ ញាណទឹងកើតឡើងមុន តពីនោះ អរហត្តផលទើបកើតឡើង ។

ផល ត្រាស់ហៅថា **អាសវក្ខយ** ដូចក្នុងប្រយោគនេះថា ឈ្មោះថាសមណៈ ព្រោះអស់អាសវៈទាំងឡាយ ។

និព្វាន ហៅថា **អាសវក្ខយ** ក្នុងគាថានេះថា

**បរវជ្ជានុបស្សិស្ស និច្ចំ ឧជ្ឈានសញ្ញិនោ**

អាសវា តស្ស វឌ្ឍន្តិ អារា សោ អាសវក្ខយា ។
អាសវៈទាំងឡាយ រមែងចម្រើនដល់អ្នកសម្លឹងរំពៃទោស
អ្នកដទៃ ត្រូវលើកទោសហើយជានិច្ច គេរមែងនៅឆ្ងាយពី
ព្រះនិព្វាន ។

តែក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ថា **អាសវានំ ខយាយ** ដោយទ្រង់សំដៅដល់ផល អធិប្បាយថា ដើម្បីប្រយោជន៍ដល់អរហត្តផល ។

បទថា **ឥន្ទ្រិយេសុ គុត្តទ្វារោ** (បុគ្គលមានទ្វារឃុំគ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ) សេចក្ដីថា មានទ្វារដែលបិទហើយក្នុងឥន្ទ្រិយទាំងឡាយ មានចិត្តជាទី ៦ ។ បទថា **ភោជនេ មត្តញ្ញូ** (ជាបុគ្គលស្គាល់ប្រមាណក្នុងភោជន) សេចក្ដីថា ដឹងប្រមាណក្នុងភោជន អធិប្បាយថា ដឹងប្រមាណក្នុងការទទួល ការឆាន់ និងការពិចារណា ។ បទថា **ជាគរិយំ អនុយុត្តោ** (ជាបុគ្គលឧស្សាហ៍ប្រកបដោយភាពជាអ្នកមិនឃើញដល់ការដេក) សេចក្ដីថា ជាអ្នកបែងចែកពេលយប់ពេលថ្ងៃចេញជា ៦ ចំណែក ហើយប្រកបរឿយៗ នូវភាពជាអ្នកភ្ញាក់ក្នុង ៥ ចំណែក អធិប្បាយថា ច្រើនក្នុងការភ្ញាក់នុ៎ះឯង ។

ព្រះមានព្រះភាគ លុះទ្រង់សម្ដែងមាតិកាទុកយ៉ាងនេះហើយ កាលនឹងចែកមាតិកានុ៎ះឯង តាមលំដាប់ដែលទ្រង់សម្ដែងទុក ទើបត្រាស់បទមានជា

អាទិ៍ថា **តថញ្ច ភិក្ខវេ ភិក្ខុ** ដូច្នេះ ។ បណ្ដាបទទាំងនោះ អត្ថរបស់បទថា **ចក្ខុនា រូបំ ទិស្វា** (ឃើញរូបដោយភ្នែក) ជាដើម បានពោលពិស្ដារហើយក្នុងបករណ៍ពិសេស ឈ្មោះថា វិសុទ្ធិមគ្គ ។ អត្ថនៃបទទាំងឡាយមានជាអាទិ៍ថា **បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ** (ភិក្ខុពិចារណាដោយឧបាយហើយ ទើបឆាន់អាហារ មិនមែនដើម្បីលេង) បានពោលពិស្ដារហើយក្នុងបករណ៍ពិសេស ឈ្មោះថា វិសុទ្ធិមគ្គនោះដូចគ្នា ។

បទថា **អាវរណិយេហិ ធម្មេហិ** សេចក្ដីថា ចាកពីនីវរណធម៌ ៥ ប្រការ ព្រោះនីវរណៈជាគ្រឿងរាំងចិត្ត ព្រោះដូច្នោះ នីវរណៈទាំងនោះទើបត្រាស់ហៅថា អាវរណិយធម៌ ។ បទថា **សីហសេយ្យំ កប្បេតិ** (សម្រេចសីហសេយ្យា) សេចក្ដីថា សម្រេចការដេកដូចរាជសីហ៍ ។ បទថា **បាទេ បាទំ អច្ចាធាយ** (ត្រួតជើងលើគ្នា) បានដល់ ដាក់ជើងឆ្វេងលើជើងស្ដាំ ។ ព្រោះថា កាលដាក់ជើងទុកស្មើគ្នា ជង្គង់នឹងប៉ះខ្ទប់ជង្គង់ កជើងក៏នឹងប៉ះខ្ទប់កជើង ទុក្ខវេទនានឹងកើតព្រោះការប៉ះខ្ទប់គ្នានោះ ព្រោះដូច្នោះ ដើម្បីនឹងវៀរទោសនោះ លោកគប្បីដាក់ជើងលើគ្នាបន្តិច ។ ដោយហេតុនោះ ទើបត្រាស់ថា **ដាក់ជើងលើគ្នា** ដូច្នេះ ។

បទថា **សតោ សម្បជានោ** (មានសតិសម្បជញ្ញៈ) សេចក្ដីថា ប្រកប

ដោយសតិ និងសម្បជញ្ញៈ ។ សួរថា ភិក្ខុនោះ កាលដេកលក់ទីងឈ្មោះថា មានសតិសម្បជញ្ញៈបានដូចម្តេច ។ ឆ្លើយថា ដោយអំណាចនៃការប្រព្រឹត្តទៅ (នៃកម្មដ្ឋានមុនពេលលក់) ។ ព្រោះថា ភិក្ខុនេះ កាលចង្ក្រមក្នុងទីចង្ក្រម ដឹងខ្លួនងងុយដេក ទើបផ្អាកកម្មដ្ឋានដែលកំពុងបំពេញ ហើយអង្គុយលើគ្រែ ឬលើបន្ទះក្តារដេកលក់ទៅ កាលភ្ញាក់ ក៏មកបំពេញកម្មដ្ឋានក្នុងទីដែលសម្រាកនុ៎ះឯងទៀត ព្រោះដូច្នោះ សូម្បីលោកដេកលក់ ក៏នៅឈ្មោះថា មានសតិសម្បជញ្ញៈ ។ នេះជាន័យក្នុងមូលកម្មដ្ឋាន ។ ចំណែកភិក្ខុនេះ ឈ្មោះថា មានសតិសម្បជញ្ញៈ សូម្បីដោយកម្មដ្ឋានតាមដែលកំណត់ ។ ប្រការនេះមានដូចម្តេច ។ អធិប្បាយថា ភិក្ខុនេះកាលចង្ក្រម ដឹងខ្លួនថា ងងុយដេក ក៏ដេកផ្អៀងខាងស្តាំលើផ្ទាំងថ្ម ឬលើគ្រែ ពិចារណាថា កាយមិនមានចិត្ត ដេកនៅលើគ្រែដែលមិនមានចិត្ត គ្រែដែលមិនមានចិត្ត ក៏ដាក់នៅលើបថវីដែលមិនមានចិត្ត បថវីដែលមិនមានចិត្ត ក៏នៅលើទឹកដែលមិនមានចិត្ត ទឹកដែលមិនមានចិត្ត ក៏នៅលើខ្យល់ដែលមិនមានចិត្ត ខ្យល់ដែលមិនមានចិត្ត ក៏នៅលើអាកាសដែលមិនមានចិត្ត បណ្តាវត្ថុទាំងនោះ សូម្បីអាកាសក៏មិនដឹងថា យើងទ្រខ្យល់ទុក សូម្បីខ្យល់ក៏មិនដឹងថា យើងស្ថិតនៅលើអាកាស សូម្បីខ្យល់ក៏ដូច្នោះ មិនដឹងថា យើងទ្រទឹក ។ល។ គ្រែក៏មិនដឹងថា យើងលើកកាយទុក

កាយក៏មិនដឹងថា យើងនៅលើគ្រែ ព្រោះថា វត្ថុទាំងនោះផ្សេងគ្នា មិនមានដឹងដល់គ្នា មិនមានការយល់គ្នា មិនមានការធ្វើទុកក្នុងចិត្តគ្នា មិនមានចេតនាឬមិនមានសេចក្តីប្រាថ្នាដល់គ្នានិងគ្នាឡើយ ដូច្នេះ កាលភិក្ខុនោះពិចារណាយ៉ាងនេះ បច្ចវេក្ខណចិត្តនោះ រមែងធ្លាក់ចុះកាន់ភវង្គ ។ លោកសូម្បីកាលលក់ហើយ ក៏រមែងឈ្មោះថា មានសតិសម្បជញ្ញៈ ។

បទថា **ឧដ្ឋានសញ្ញំ មនសិករិត្វា** (ធ្វើឧដ្ឋានសញ្ញាទុកក្នុងចិត្ត) សេចក្តីថា ដាក់ចិត្តដល់សញ្ញាដែលកំណត់វេលាក្រោកឡើងថា កាលព្រះច័ន្ទ ឬផ្កាយរះដល់ត្រង់នេះ យើងនឹងក្រោកឡើង អធិប្បាយថា ដាក់សញ្ញាទុកក្នុងចិត្ត ។ ព្រោះថា កាលភិក្ខុនោះបដិបត្តិយ៉ាងនេះ ហើយដេក ក៏នឹងក្រោកឡើងបានត្រង់ក្នុងវេលាតាមដែលកំណត់ទុកហើយនុ៎ះឯង ។

ចប់អដ្ឋកថា អបណ្ណកសូត្រទី ៦

# អដ្ឋកថា អត្តសូត្រទី ៧

*"ធម៌ដែលនាំឲ្យបៀតបៀន និងមិនបៀតបៀនខ្លួន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អត្តសូត្រទី ៧ ដូចតទៅនេះ ៖-*

[១៧] *បទថា* ***អត្តព្យាពាធាយ*** *(ដើម្បីបៀតបៀនខ្លួន) បានដល់ ដើម្បីឲ្យខ្លួនឯងលំបាក ។ បទថា* ***បរព្យាពាធាយ*** *(ដើម្បីបៀតបៀនបុគ្គលដទៃ) បានដល់ ដើម្បីឲ្យបុគ្គលដទៃលំបាក ។ បទថា* ***កាយសុចរិតំ*** *(កាយសុចរិត) ជាដើម មកក្នុងខាងដើម ដោយអំណាចកុសលកម្មបថ ១០ ។ ប៉ុន្តែថា ក្នុងថ្នាក់ខ្ពស់ឡើងទៅ រហូតដល់អរហត្តផល លោកក៏មិនបានហាមទុកឡើយ ។*

ចប់អដ្ឋកថា អត្តសូត្រទី ៧

# អដ្ឋកថា ទេវលោកសូត្រទី ៨

## *"ធម៌ដែលគួរខ្ពើមរអើម"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទេវលោកសូត្រទី ៨ ដូចតទៅនេះ ៖*

[១៨] *បទថា* ***អដ្ដិយេយ្យាថ*** *(ពួកអ្នកជិនធុន់) សេចក្ដីថា ពួកអ្នកគប្បីជាអ្នកត្រូវសេចក្ដីជិនធុន់បៀតបៀន ។ បទថា* ***ហរាយេយ្យាថ*** *(ធុញទ្រាន់) សេចក្ដីថា គប្បីធុញទ្រាន់ ។ បទថា* ***ជិគុច្ឆេយ្យាថ*** *(ខ្ពើមរអើម) សេចក្ដីថា គប្បីកើតសេចក្ដីខ្ពើមរអើម ក្នុងពាក្យនិយាយនោះ ដូចកើតសេចក្ដីខ្ពើមរអើមក្នុងលាមក ដូច្នោះ ។ បទថា* ***ឥតិ*** *ក្នុងបទថា* ***ឥតិ កិរ*** *នេះ គប្បីឃើញថា ជាសេចក្ដីរៀបរយនៃព្យញ្ជនៈដោយការភ្ជាប់បទ ។ បទថា* ***កិរ*** *ជានិបាត ប្រើក្នុងអត្ថថា បានស្ដាប់តៗ គ្នាមក ។ បទថា* ***កិរ*** *នោះ គប្បីជ្រាបការភ្ជាប់សេចក្ដីយ៉ាងនេះថា បានឮថា អ្នកទាំងឡាយគប្បីជិនធុន់ដោយអាយុទិព្វ ។ បទថា* ***បគេវ ខោ បន*** *(នឹងចាំបាច់ពោលថ្វី) មានអត្ថស្មើនឹង* ***បឋមតរំ*** *(មុនដំបូង ឬលំដាប់ដំបូង) ។*

ចប់អដ្ឋកថា ទេវលោកសូត្រទី ៨

# អដ្ឋកថា បឋមបាបណិកសូត្រទី ៩

## *“អង្គគុណរបស់ឈ្មួញ និងរបស់ភិក្ខុ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបាបណិកសូត្រទី ៩ ដូចតទៅនេះ ៈ-*

### *ឈ្មួញដែលមិនតាំងចិត្តធ្វើការងារ*

[១៩] *បទថា* **បាបិណិកោ** *(ឈ្មួញ)*[១] *បានដល់ ម្ចាស់របស់រាន លក់ដូរ ។ ពាក្យថា* **បាបិកោ** *នោះ ជាឈ្មោះរបស់ឈ្មួញ អ្នកបើកលក់ របស់របរ ។ បទថា* **អភព្វោ** *(មិនគួរ) ប្រែថា ជាបុគ្គលមិនសមគួរ ។*

*បទថា* **ន សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ** *(មិនប្រកបការតាំងចិត្តធ្វើការងារ) សេចក្តីថា ការងារទីតាំងចិត្តធ្វើយ៉ាងណា ទើបទីងរាប់ថា ជាការធ្វើឲ្យសម្រេច ល្អបាន គេមិនតាំងចិត្តធ្វើឲ្យសម្រេចដោយខ្លួនឯងយ៉ាងនោះ ។ ក្នុងបទថា* **ន សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ** *មិនប្រកកការងារដោយតាំងចិត្តនោះ គប្បីជ្រាបអធិប្បាយ ដូចតទៅនេះ*

*វេលាជិតភ្លឺ ឈ្មួញក្រោកឡើងដោយសំឡេងជើង តាំងប្រទីប តែ មិនអង្គុយចាត់ចែងទំនិញ ឈ្មោះថា មិនប្រកបធ្វើការងារដោយត្រឹមត្រូវក្នុង វេលាព្រឹក ព្រោះថា ឈ្មួញដែលជាអ្នកលក់ទំនិញនេះ មិនបានជាម្ចាស់របស់*

---

*១-បាលិ ប្រែថា អ្នកផ្សារ ។*

សម្បត្តិ ដែលមានឱកាសទាំង ៣ ជាបច្ច័យ គឺ របស់របរដែលពួកចោរលួច ក្នុងពេលយប់ ប្រញាប់មកផ្សារដោយគិតថា យើងនឹងលែងរបស់នេះឲ្យផុត ពីដៃរបស់យើងហើយលក់ឲ្យ ដោយតម្លៃថោក ១ របស់របរដែលមនុស្សចំនួន ច្រើនជាគូប្រជែង ដណ្តើមទិញដណ្តើមលក់ វេលាពេលយប់នៅក្នុងក្រុង ជិត ភ្លឺទៅផ្សារទិញយក ១ ឬរបស់របរដែលមនុស្សបំណាំងនឹងទៅកាន់ជនបទ ប្រញាប់ ទៅផ្សារអំពីព្រឹកហើយទិញយក ១ ។

ក្នុងវេលាដែលបុគ្គលដទៃសម្រាកទទួលទានអាហារ គេក៏ត្រឡប់មក ទទួលទានអាហារខ្លះ គឺ រក្សាទំនិញពីព្រឹកព្រលឹម ហើយត្រឡប់ទៅផ្ទះ ទទួល ទានអាហារហើយក៏ដេកលក់ទៅ ពេលល្ងាចទើបត្រឡប់មកកាន់ផ្សារម្តងទៀត យ៉ាងនេះ ឈ្មោះថា មិនប្រកបការងារដោយល្អ ក្នុងវេលាថ្ងៃ ។

ដោយឈ្មួញនោះជាអ្នកលក់របស់របរ ដែលមិនបានជាម្ចាស់របស់ សម្បត្តិ ដែលមានឱកាសទាំង ២ ជាបច្ច័យ គឺ របស់របរដែលពួកចោរមក បញ្ចេញមិនទាន់ក្នុងពេលព្រឹក តែពេលថ្ងៃ ខណៈដែលមនុស្សដទៃៗ មិនទាន់ សញ្ចរទៅមក ពួកចោរក៏នឹងទៅកាន់រានផ្សារ ហើយលក់ឲ្យដោយតម្លៃថោក ១ របស់របរដែលពួកឥស្សរជនអ្នកមានបុណ្យ ប្រើមនុស្សទៅនាំមកក្នុងវេលា ទទួលទានអាហារ ដោយបង្គាប់ថា គួរនឹងបានវត្ថុនេះៗ មកអំពីផ្សារ ១ ។

ចំណែកវេលាល្ងាច រហូតដល់វេលាដែលគេប្រាប់យាម គេក៏មិនតាំងប្រទីប ហើយអង្គុយខាងក្នុងរានផ្សារ យ៉ាងនេះ ឈ្មោះថា មិនប្រកបការងារដោយសមគួរ ក្នុងវេលាល្ងាច ។

ព្រោះថា ឈ្មួញនោះ នឹងមិនបានជាម្ចាស់របស់សម្បត្តិ ដែលមានឱកាសនោះជាបច្ច័យ គឺ របស់របរដែលពួកចោរមក បញ្ចេញមិនទាន់ ទាំងវេលាព្រឹក និងវេលាថ្ងៃ តែត្រឡប់ទៅកាន់ផ្សារក្នុងវេលាល្ងាច ហើយលក់ឲ្យដោយតម្លៃថោក ។

## ភិក្ខុមិនតាំងចិត្តហ្វឹកហាត់សមាធិ

បទថា **ន សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ** (មិនបដិបត្តិសមាធិនិមិត្តដោយគោរព) សេចក្ដីថា ភិក្ខុមិនចូលសមាធិដោយកិរិយាដែលគោរព ។

ក៏ក្នុងបទថា **មិនបដិបត្តិសមាធិនិមិត្តដោយគោរព** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

ភិក្ខុធ្វើវត្តត្រង់លានចេតិយ និងលានពោធិ៍ហើយ ចូលទៅកាន់សេនាសនៈ ប៉ុន្តែថា មិនព្រមអង្គុយចូលសមាបត្តិរហូតដល់វេលាភិក្ខាចារ ឈ្មោះថា មិនបដិបត្តិសមាធិនិមិត្តដោយគោរព ។ ចំណែកវេលាខាងក្រោយបាន់ភត្តាហារ លោកត្រឡប់ពីបិណ្ឌបាត ហើយចូលទៅកាន់ទីសម្រាកពេលយប់ និង

ទីសម្រាកពេលថ្ងៃ ប៉ុន្តែថា មិនអង្គុយចូលសមាបត្តិរហូតដល់វេលាល្ងាច ឈ្មោះថា មិនបដិបត្តិសមាធិនិមិត្តដោយគោរព ក្នុងវេលាថ្ងៃ ។

មួយទៀត វេលាល្ងាច លោកថ្វាយបង្គំចេតិយ ធ្វើការទំនុកបម្រុងព្រះថេរៈ ហើយចូលទៅកាន់សេនាសនៈ ប៉ុន្តែថា មិនព្រមអង្គុយចូលសមាបត្តិរហូតដល់អស់បឋមយាម ឈ្មោះថា មិនបដិបត្តិសមាធិនិមិត្តដោយគោរព ក្នុងវេលាល្ងាច ។

អាការខាងល្អ គប្បីជ្រាបតាមន័យផ្ទុយគ្នាតាមដែលពោលហើយ ក្នុងចំណែកមិនល្អ ។

មួយទៀត ក្នុងបទនេះ ក្នុងទីដែលលោកពោលទុកថា **ចូលសមាបត្តិ** កាលមិនមានសមាបត្តិ សូម្បីវិបស្សនាក៏គួរ ។ និងក្នុងបទថា **សមាធិនិមិត្ត** សូម្បីអារម្មណ៍របស់សមាធិក៏គួរដូចគ្នា ។ សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា **សូម្បីសមាធិ ក៏ឈ្មោះថា សមាធិនិមិត្ត សូម្បីអារម្មណ៍របស់សមាធិ ក៏ឈ្មោះថា សមាធិនិមិត្ត** ។

ចប់អដ្ឋកថា បឋមចាបណិកសូត្រទី ៩

# អដ្ឋកថា ទុតិយបាបណិកសូត្រទី ១០

## "គុណសម្បត្តិរបស់ឈ្មួញ និងរបស់ភិក្ខុ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយបាបណិកសូត្រទី ១០ ដូចតទៅនេះ ៖-*

### អ្នកផ្សារមានបញ្ញា

*[២០] បទថា **ចក្ខុមា** (អ្នកមានទស្សនវិស័យ) សេចក្តីថា ឈ្មួញជាអ្នកមានបញ្ញាចក្ខុ ។ បទថា **វិធុរោ** (ឆ្លាត) សេចក្តីថា ជាអ្នកមានធុរៈដ៏សំខាន់ គឺ មានធុរៈដែលខ្ពង់ខ្ពស់ បានដល់ ការប្រកបដោយវីរិយៈដែលសម្បយុត្តដោយញាណ ។ បទថា **និស្សយសម្បន្នោ** (បានកម្លាំងជួយឧបត្ថម្ភ) គឺ ដល់ព្រមដោយទីពឹង បានដល់ ដល់ព្រមដោយទីពំនាក់ ។*

*បទថា **បណិយំ** (ទំនិញ) បានដល់ ទំនិញដែលត្រូវលក់ ។ ក្នុងបទនោះថា **ឯត្តកំ មូលំ ភវិស្សតិ ឯត្តកោ ឧទ្រយោ** (ជាដើមទុនប៉ុណ្ណេះ ចំណេញប៉ុណ្ណេះ) មានអធិប្បាយថា ទំនិញដែលទិញមកនោះ ដោយការទិញមានបរិយាយដូចដែលត្រាស់ទុកថា ទិញយ៉ាងនេះ លក់យ៉ាងនេះ ។ ទំនិញនោះ ចាត់ជាដើមទុន គឺ ចំនួនដែលទិញមកប៉ុណ្ណេះ ដូច្នោះ កាលចំណាយទំនិញនោះទៅ ក្នុងការចំណាយទំនិញ នឹងចំណេញប៉ុណ្ណេះ គឺ បានកើនឡើងប៉ុណ្ណេះ ។*

បទថា **កុសលោ ហោតិ បណិយំ កេតុញ្ច វិកេតុញ្ច** (ជាអ្នកឆ្លាត ដែលទិញ និងលក់ទំនិញ) សេចក្តីថា ឈ្មួញដែលឆ្លាត ទៅរកទិញក្នុងទីដែលរកទំនិញបានងាយ និងទៅលក់ក្នុងទីដែលរកទំនិញបានលំបាក ឈ្មោះថា ជាអ្នកឆ្លាតក្នុងទីនេះ គេរមែងបានលាភកើនឡើង ១០ ដងខ្លះ ២០ ដងខ្លះ ។

បទថា **អឌ្ឍា** (បាលិ **អឌ្ឍោ**) (អ្នកស្តុកស្តម្ភ) បានដល់ ឥស្សរជន គឺអ្នកដល់ព្រមដោយទ្រព្យដែលរក្សាទុកចំនួនច្រើន ។ បទថា **មហទ្ធនា** (មានទ្រព្យច្រើន) បានដល់ អ្នកមានទ្រព្យច្រើន ដោយអំណាចគ្រឿងប្រើប្រាស់ ។ បទថា **មហាភោគា** (មានភោគៈច្រើន) បានដល់ អ្នកមានភោគៈច្រើន ដោយវត្ថុដែលជាគ្រឿងឧបភោគ និងបរិភោគ ។ បទថា **បដិពលោ** (មានកម្លាំង) បានដល់ ឈ្មោះថា ជាអ្នកអាច ព្រោះដល់ព្រមដោយកម្លាំងកាយ និងកម្លាំងបញ្ញា ។ បទថា **អម្ហាកញ្ច កាលេន កាលំ អនុប្បទាតុំ** (និងផ្តល់ទ្រព្យឲ្យយើងខ្លះ តាមកាលដ៏សមគួរ) សេចក្តីថា ដើម្បីបន្ថែមឲ្យការប្រាក់ឲ្យដែលកើតពីទ្រព្យដែលគេខ្ចីទៅធ្វើជាដើមទុន ដល់យើងទាំងឡាយតាមកាលដ៏សមគួរ ។ បទថា **និបតន្តិ** (រមែងទទួល) បានដល់ គោរពអញ្ជើញ ។ បាលីជា **និបទន្តិ** ក៏មាន ន័យក៏ទំនងនេះឯង ។

បទថា **កុសលានំ ធម្មានំ ឧបសម្បទា** (ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយ

ឲ្យដល់ព្រម) សេចក្តីថា ដើម្បីសេចក្តីដល់ព្រម គឺ ដើម្បីបានចំពោះនូវ កុសលធម៌ទាំងឡាយ ។ បទថា **ថាមវា** (កម្លាំង) សេចក្តីថា ប្រកបដោយ កម្លាំងបញ្ញា ។ បទថា **ទឡ្ហបរក្កមោ** (ប្រឹងប្រែងដ៏មុតមាំ) សេចក្តីថា ប្រកប ដោយសេចក្តីប្រឹងប្រែង ដោយបញ្ញាដ៏មុតមាំ ។ បទថា **អនិក្ខិត្តធុរោ** (មិនលះ បង់ធុរៈ) សេចក្តីថា មិនលះបង់ធុរៈ យ៉ាងនេះថា យើងមិនទាន់ដល់ទីបំផុត ផុវ នឹងមិនដាក់ធុរៈ គឺ សេចក្តីព្យាយាមនេះ ។

បទថា **ពហុស្សុតា** (ជាពហុស្សូត) សេចក្តីថា ឈ្មោះថា ជាពហុស្សូត ព្រោះមានព្រះពុទ្ធវចនៈដែលបានស្តាប់មកច្រើន ដោយចេះចាំក្នុង ១ និកាយ ឬ ២ និកាយជាដើម ។ បទថា **អាគតាមា** (ចេះចាំស្ទាត់) សេចក្តីថា និកាយ ១ ឈ្មោះថា អាគម ១ ។ និកាយ ២ ឈ្មោះថា ២ អាគម ។ និកាយ ៥ ឈ្មោះថា ៥ អាគម ។ ក្នុងអាគមទាំង ៥ នេះ បុគ្គលណាចេះចាំ គឺ ស្ទាត់ ជំនាញ បានដល់ លើកឡើងបានសូម្បីត្រឹមតែមួយអាគម លោកនោះ ឈ្មោះថា ចេះចាំស្ទាត់ព្រះពុទ្ធវចនៈ ។

បទថា **ធម្មធរា** (ទ្រទ្រង់ធម៌) បានដល់ អ្នកទ្រទ្រង់ទុកនូវព្រះសុត្តន្ត- បិដក ។ បទថា **វិនយធរា** (ទ្រទ្រង់វិន័យ) បានដល់ អ្នកទ្រទ្រង់ទុកនូវព្រះ វិន័យបិដក ។ បទថា **មាតិកាធរា** (ទ្រទ្រង់មាតិកា) បានដល់ អ្នកទ្រទ្រង់ទុក

នូវមាតិកាទាំងពីរ ។ បទថា **បរិបុច្ឆតិ** (សាកសួរ) បានដល់ សាកសួរដល់ប្រយោជន៍ និងវត្ថុដែលមិនមែនប្រយោជន៍ ដល់ហេតុ និងវត្ថុដែលមែនជាហេតុ ។ បទថា **បរិបញ្ហតិ** (ដណ្ដឹងសួរ) បានដល់ បានទទួលឱកាសដែលដឹង គឺ កំណត់ថា យើងនឹងសួរធម៌វិន័យឈ្មោះនេះ ។ ប្រការដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងនោះឯង ។

ក៏ក្នុងព្រះសូត្រនេះ បញ្ញាកើតមុន សេចក្ដីព្យាយាម និងការសេពគប់កល្យាណមិត្តកើតខាងក្រោយ ។ ក្នុងប្រការនោះ មិនគប្បីយល់សេចក្ដីយ៉ាងនេះថា សម្រេចព្រះអរហត្តមុនហើយ ទើបបំពេញព្យាយាម ហើយសេពគប់កល្យាណមិត្តខាងក្រោយ ។ ធម្មតាព្រះធម្មទេសនា នឹងមានការកំណត់ដោយបរិយាយទាប បរិយាយខ្ពស់ ឬដោយចំណែកទាំង ២ ខ្លះ ។ តែក្នុងព្រះសូត្រនេះ គប្បីជ្រាបការកំណត់ដោយបរិយាយខ្ពស់ប៉ុណ្ណោះ ។ ព្រោះដូច្នោះ កាលនឹងត្រាស់ ក៏ទ្រង់សម្ដែងការអាស្រ័យការសេពគប់កល្យាណមិត្តទុកមុន ហើយទ្រង់សម្ដែងសេចក្ដីព្យាយាមទុកជាកណ្ដាល ហើយទើបត្រាស់ប្រាប់ព្រះអរហត្តក្នុងខាងក្រោយ ។

ចប់ទុតិយបាបណិកសូត្រទី ១០

## ចប់រថការវគ្គវណ្ណនាទី ២

## ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្ដី ១០ សូត្រ

# បុគ្គលវគ្គទី ៣

## អដ្ឋកថា សមិទ្ធសូត្រទី ១

*"បុគ្គល ៣ ពួក ដែលព្យាករណ៍លំបាក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមិទ្ធសូត្រទី ១ ដូចតទៅនេះ ៖-*

[២១] *ព្រះអរិយបុគ្គល ឈ្មោះថា* **កាយសក្ខី** *ព្រោះសម្ផស្សឈានផស្សៈមកពីមុន ក្រោយមកទើបធ្វើឲ្យច្បាស់នូវនិរោធ គឺ ព្រះនិព្វាន ។*

*ឈ្មោះថា* **ទិដ្ឋិប្បត្តោ** *ព្រោះសម្រេចធម៌នោះដែលខ្លួនឃើញហើយ ។*

*ឈ្មោះថា* **សទ្ធាវិមុត្តោ** *ព្រោះជឿ (មានសទ្ធា) ទើបបានរួចផុត ។*

*បទថា* **ខមតិ** *បានដល់ ពេញចិត្ត ។ បទថា* **អភិក្កន្តតរោ** *(ប្រសើរជាង) បានដល់ ប្រសើរបំផុត ។ បទថា* **បណីតតរោ** *ប្រែថា ប្រណីតជាង ។*

*បទថា* **សទ្ធិន្ទ្រិយំ អធិមត្តំ ហោតិ** *(ព្រោះសទ្ធិន្ទ្រិយរបស់បុគ្គលនេះមានប្រមាណក្រៃលែង) សេចក្ដីថា ព្រះសមិទ្ធត្ថេរៈក្នុងខណៈនៃអរហត្តមគ្គមានសទ្ធិន្ទ្រិយជាធុរៈ (ជាធំ) មានឥន្ទ្រិយដែលជាសហជាតិគ្នា ៤ ឥន្ទ្រិយដ៏សេសជាបរិវាររបស់សទ្ធិន្ទ្រិយនោះ ។ ដូច្នោះ ព្រះថេរៈកាលនឹងពោលដល់មគ្គដែលខ្លួនបានសម្រេចហើយ ទើបបានពោលយ៉ាងនេះ ។ ចំណែកព្រះ*

ព្រះមហាកោដ្ឋិតត្ថេរៈ ក្នុងខណៈនៃអរហត្តមគ្គ មានសមាធិន្ទ្រិយជាធុរៈ (ជាធំ) ឥន្ទ្រិយ ៤ យ៉ាងដ៏សេស ជាបរិវាររបស់សមាធិនោះឯង ។ ព្រោះដូច្នោះ ព្រះមហាកោដ្ឋិតត្ថេរៈនោះ កាលនឹងប្រាប់ថា សមាធិន្ទ្រិយ មានប្រមាណក្រៃលែង (ជាធំ) ទើបបានពោលដល់មគ្គដែលខ្លួនបានសម្រេចនោះឯង ។ ចំណែកព្រះសារីបុត្តត្ថេរៈ ក្នុងខណៈនៃអរហត្តមគ្គ មានបញ្ញិន្ទ្រិយជាធុរៈ (ជាធំ) មានឥន្ទ្រិយ ៤ យ៉ាងដ៏សេស ជាបរិវាររបស់បញ្ញិន្ទ្រិយនោះឯង ។ ព្រោះដូច្នោះ ព្រះសារីបុត្តត្ថេរៈ កាលនឹងប្រាប់ថា បញ្ញិន្ទ្រិយមានប្រមាណក្រៃលែង (ជាធំ) ទើបបានប្រាប់មគ្គដែលខ្លួនបានសម្រេចហើយនោះឯង ។

បទថា **ន ខ្វេត្ថ** កាត់បទជា **ន ខោ ឯត្ថ** ។ បទថា **ឯកំសេន ព្យាកាតុំ** សេចក្តីថា ដើម្បីព្យាករណ៍ដោយចំណែកតែមួយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីព្រមព្រៀងនៃអរហត្តមគ្គ ដោយបទថា **ជាអ្នកបដិបត្តិដើម្បីព្រះអរហត្ត** ។ ក្នុងព្រះសូត្រនេះ សូម្បីព្រះថេរៈទាំង ៣ បានពោលចំពោះមគ្គដែលខ្លួនសម្រេចហើយ ដោយប្រការដូចពណ៌នាដូច្នេះ ។ តែសម្មាទិដ្ឋិ ត្រាស់ចំពោះបុគ្គលតាំងនៅក្នុងភូមិធម៌ដទៃ ។

ចប់អដ្ឋកថា សមិទ្ធសូត្រទី ១

# អដ្ឋកថា គិលានសូត្រទី ២

## *“បុគ្គលឈឺ និងបុគ្គលប្រៀបដូចអ្នកឈឺ ៣ ពួក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង គិលានសូត្រទី ២ ដូចតទៅនេះ ៈ-*

[២២] *បទថា* ***សប្បាយានិ*** *(ដែលសមគួរ) បានដល់ ជាប្រយោជន៍ ជំទូលាយ គឺ ធ្វើសេចក្ដីចម្រើនឲ្យក្រៃលែងឡើង ។ បទថា* ***បដិរូប*** *គឺ* ***អនុច្ឆវិកំ*** *(សមគួរ) ។ ដោយបទថា* ***នេវ វុដ្ឋាតិ តម្ហា អាពាធា*** *(មិនវិនាសចាកអាពាធនោះ) នេះ ព្រះមានព្រះភាគត្រាស់ដល់អ្នកជំងឺ ដែលជិតស្លាប់ ហើយប្រកបដោយរោគខ្យល់ និងរោគធ្លុតជ្រូកជាដើម ដែលរក្សាមិនបាន ។ ដោយបទថា* ***វុដ្ឋាតិ តម្ហា អាពាធា*** *(វិនាសចាកអាពាធនោះ) នេះ ព្រះមាន-ព្រះភាគត្រាស់ដល់អាពាធតិចតួច បែកប្រភេទ មានរោគក្អក កមរមាស់ និងជំងឺប្រែប្រួលរដូវជាដើម ។*

*ក៏ដោយបទថា* ***លភន្តោ សប្បាយានិ ភោជនានិ នោ អលភន្តោ*** *(កាលបានអាហារដែលសមគួរ ទើបសះស្បើយពីអាពាធនោះ កាលមិនបានអាហារដែលសមគួរ រមែងមិនសប្បាយ) នេះ ព្រះមានព្រះភាគ ត្រាស់ដល់អាពាធគ្រប់ប្រភេទដែលនឹងសះស្បើយបានដោយការរក្សា ។ ក៏ក្នុងសូត្រនេះ ដែលឈ្មោះថា ឧបដ្ឋាកដែលសមគួរនោះ គប្បីជ្រាបថា បានដល់ អ្នកដែល*

ច្លាត ឧស្សាហ៍ មិនខ្ជិលច្រអូស ប្រកបដោយគុណរបស់អ្នកព្យាបាលជំងឺ ។

បទថា **គិលានុបដ្ឋាកោ អនុញ្ញាតោ** (អនុញ្ញាតគិលានុបដ្ឋាក) បានដល់គិលានុបដ្ឋាកដែលទ្រង់អនុញ្ញាតទុកថា ភិក្ខុសង្ឃគប្បីឲ្យ ។ អធិប្បាយថា កាលភិក្ខុឈឺនោះមិនអាចនឹងព្យាបាលតាមធម្មតារបស់ខ្លួនបាន ភិក្ខុសង្ឃត្រូវប្រគល់ភិក្ខុមួយរូប និងសាមណេរមួយរូប ឲ្យដល់លោកថា លោកទាំងពីរចូរបដិបត្តិភិក្ខុនេះ ។ ក៏រហូតអស់វេលាដែលភិក្ខុ និងសាមណេរដែលជាឧបដ្ឋាកទាំងពីរនោះ បដិបត្តិភិក្ខុឈឺនោះហើយ ភិក្ខុឈឺក្តី អ្នកបដិបត្តិទាំងពីរនោះក្តី មានសេចក្តីត្រូវការវត្ថុណា វត្ថុទាំងអស់នោះ ជាភារៈរបស់ភិក្ខុសង្ឃទាំងនោះ ។

បទថា **អញ្ញេបិ គិលានា ឧបដ្ឋាតព្វា** (អ្នកជំងឺសូម្បីដទៃ ក៏គួរបានការព្យាបាលផង) សេចក្តីថា អ្នកជំងឺសូម្បីក្រៅពីនេះ សង្ឃក៏គួរឲ្យការរក្សាផង ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះអ្នកដែលមានអាពាធដល់ក្តួតកាលសង្ឃមិនរក្សាព្យាបាល នឹងធ្វើសេចក្តីទោមនស្សក្នុងចិត្តថា ប្រសិនបើភិក្ខុទាំងឡាយព្យាបាលយើង យើងក៏នឹងសះស្បើយ តែភិក្ខុទាំងឡាយមិនព្យាបាលយើងឡើយ ដូច្នេះ ហើយនឹងគប្បីទៅកើតក្នុងអបាយ ។ តែកាលបើសង្ឃព្យាបាល លោកនឹងមានសេចក្តីគិតយ៉ាងនេះថា ភិក្ខុសង្ឃបានធ្វើកម្មដែល

គួរធ្វើហើយ តែអាពាធនេះ ជាវិបាកកម្មរបស់យើង លោកនឹងចម្រើនមេត្តាទៅក្នុងភិក្ខុសង្ឃ ហើយនឹងកើតក្នុងសួគ៌ ។ ចំណែកភិក្ខុណាប្រកបដោយអាពាធតិចតួច សូម្បីបានឧបដ្ឋាកក៏សះស្បើយ មិនបានក៏សះស្បើយនោះ អាពាធរបស់ភិក្ខុនោះ សូម្បីវៀរចាកថ្នាំក៏សះស្បើយបាន តែកាលផ្សំថ្នាំថ្វាយនឹងសះស្បើយបានរហ័សជាង ។ តពីនោះ លោកក៏អាចនឹងរៀនព្រះពុទ្ធវចនៈ ឬបំពេញសមណធម៌បាន ដោយហេតុនេះ ព្រះមានព្រះភាគទ្រង់ទើបត្រាស់ថា សូម្បីភិក្ខុដែលអាពាធពួកដទៃ សង្ឃក៏គួរឧបដ្ឋាក ។

បទថា **នេវ ឱក្កមតិ** (មិនឈានកន្លង) បានដល់ មិនប្រព្រឹត្តទៅ ។ បទថា **និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ** (ផ្លូវដែលត្រូវក្នុងកុសលទាំងឡាយ) បានដល់ ផ្លូវដែលត្រូវ ពោលគឺ មគ្គវិធីក្នុងកុសលធម៌ទាំងឡាយ ។ បទនេះ ជាការត្រាស់សំដៅដល់បុគ្គលដែលជា **បទបរមៈ** ។ វារៈទី ២ ទ្រង់សំដៅយក **ឧគ្ឃដិតញ្ញូបុគ្គល** ដូចព្រះនាលកត្ថេរៈក្នុងព្រះសាសនា បានទទួលឱវាទក្នុងសំណាក់របស់ព្រះបច្ចេកពុទ្ធទាំងឡាយត្រឹមតែម្តង ក៏បានត្រាស់ដឹងនូវបច្ចេកពោធិញ្ញាណក្នុងមក្នុងពុទ្ធន្តរ ។ វារៈទី ៣ ត្រាស់សំដៅដល់ **វិបចិត្តញ្ញូបុគ្គល** ។ ចំណែក **នេយ្យបុគ្គល** ក៏ត្រូវអាស្រ័យន័យនុ៎ះឯង (ទើបនឹងត្រាស់ដឹងបាន) ។

បទថា **ធម្មទេសនា អនុញ្ញាតា** (តថាគតទើបអនុញ្ញាតការសម្តែងធម៌) បានដល់ ធម្មកថាដែលទ្រង់អនុញ្ញាតទុកមួយខែ ៨ ដង ។ បទថា **អញ្ញេសំបិ ធម្មោ ទេសេតព្វោ** (តថាគតសម្តែងធម៌ដល់ជនដទៃផង) សេចក្តីថា គប្បីសម្តែងធម៌ដល់បុគ្គលទាំងឡាយសូម្បីក្រៅអំពីនេះ ។ ព្រោះហេតុអ្វី ។ ព្រោះថា **បទបរមបុគ្គល** សូម្បីមិនអាចសម្រេចធម៌ក្នុងអត្តភាពនេះបាន តែក៏នឹងបានជាបច្ច័យក្នុងអនាគត ។ ចំណែកបុគ្គលណា កាលបានឃើញព្រះរូបកាយរបស់ព្រះតថាគត ទើបបានសម្រេចក្តី កាលមិនបានឃើញក៏បានសម្រេចក្តីមួយទៀត កាលបានស្តាប់ព្រះធម្មវិន័យទើបបានសម្រេចក្តី មិនបានស្តាប់ក៏បានសម្រេចក្តី បុគ្គលនោះនឹងបានសម្រេចទាំងដែលមិនបានឃើញ មិនបានស្តាប់ ។ តែកាលបានឃើញ បានស្តាប់ ក៏នឹងបានសម្រេចរហ័ស ព្រោះហេតុដូចពោលមកនេះ ទើបគួរសម្តែងធម៌ដល់បុគ្គលទាំងនោះ ។ ចំណែកបុគ្គលពួកទី ៣ (**បទបរមៈ**) ចាំបាច់ត្រូវសម្តែងធម៌ដដែលៗ ។

ចប់អដ្ឋកថា គិលានសូត្រទី ២

# អដ្ឋកថា សង្ខារសូត្រទី ៣

## *“កម្ម និងផលរបស់កម្ម”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ខារសូត្រទី ៣ ដូចតទៅនេះ ៖-*

[២៣] *បទថា* ***សព្យាបជ្ឈំ*** *(ដែលប្រកបដោយសេចក្តីបៀតបៀន) បានដល់ មានទុក្ខ ។ បទថា* ***កាយសង្ខារំ*** *(កាយសង្ខារ) បានដល់ ចេតនាក្នុងកាយទ្វារ ។ បទថា* ***អភិសង្ខរោតិ*** *(តាក់តែង) សេចក្តីថា ប្រមូលមក គឺធ្វើឲ្យជាគំនរ បានដល់ ធ្វើឲ្យជាដុំ ។ សូម្បីក្នុងវចីទ្វារ និងមនោទ្វារ ក៏មានន័យនេះដូចគ្នា ។ បទថា* ***សព្យាបជ្ឈំ លោកំ*** *(លោកដែលប្រកបដោយសេចក្តីបៀតបៀន) បានដល់ សត្វលោកអ្នកមានទុក្ខ ។ បទថា* ***សព្យាបជ្ឈា ផស្សា ផុសន្តិ*** *(ផស្សៈទាំងឡាយដែលប្រកបដោយសេចក្តីបៀតបៀន រមែងពាល់ត្រូវ) សេចក្តីថា ផស្សៈដែលមានផលជាទុក្ខ រមែងត្រឹមត្រូវ ។ បទថា* ***សព្យាបជ្ឈំ វេទនំ វេទិយតិ*** *(រមែងសោយវេទនា ដែលប្រកបដោយសេចក្តីបៀតបៀន) សេចក្តីថា សោយវេទនាដែលមានផលជាទុក្ខ អធិប្បាយថា សោយសេចក្តីឈឺចាប់ និងអាពាធ គឺ អស់នូវភាពស្រស់ស្រាយ ។*

*បទថា* ***សេយ្យថាបិ សត្តា នេរយិកា*** *(ដូចជាពួកសត្វនរក) មានអធិប្បាយថា គេរមែងសោយវេទនាដូចសត្វទាំងឡាយដែលកើតក្នុងនរក សោយ*

តែវេទនាដែលជាទុក្ខតែម្យ៉ាង ដូច្នោះ ។ សួរថា នរកនោះ មិនមានឧបេក្ខា-វេទនាឬ ។ ឆ្លើយថា មាន តែវេទនានោះនៅក្នុងឋានៈជាអព្វោហារិកៈ ព្រោះទុក្ខវេទនាមានកម្លាំងខ្លាំង ។ ហេតុដូចពណ៌នាមកនេះ ព្រះអង្គទ្រង់នាំនរកនុ៎ះឯង មកប្រៀបធៀបនឹងនរក ។ បានឮថា នេះឈ្មោះថា បដិភាគឧបមា ក្នុងសេចក្តីនោះ ។

សូម្បីក្នុងបទថា *សេយ្យថាបិ ទេវា សុភកិណ្ហា* (ដូចទេវតាសុភកិណ្ហា) នេះ ព្រះមានព្រះភាគទ្រង់នាំយកទេវលោកនោះឯង មកប្រៀបធៀបជាមួយទេវលោក ។ ក៏ព្រោះវិបាករបស់ឈានដែលមានបីតិ រមែងប្រព្រឹត្តទៅក្នុងព្រហ្មលោកជាន់ក្រោម ចំណែកវិបាករបស់ឈានដែលមិនមានបីតិ មានតែសុខតែម្យ៉ាង នឹងប្រព្រឹត្តទៅក្នុងព្រហ្មជាន់សុភកិណ្ហា ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់សុភកិណ្ហព្រហ្ម ទ្រង់មិនកាន់ព្រហ្មជាន់ក្រោមទាំងនោះ ។ ដោយប្រការដូចពណ៌នាមកនេះ សូម្បីឧបមានេះក្នុងសេចក្តីនោះ ក៏គប្បីជ្រាបថាជាបដិភាគឧបមា ។

បទថា *វោកិណ្ណសុខទុក្ខំ* (ជាសុខខ្លះជាទុក្ខខ្លះលាយគ្នា) បានដល់វេទនាដែលមានសុខ និងទុក្ខលាយឡំគ្នា ។ បទថា *សេយ្យថាបិ មនុស្សា* (ដូចពួកមនុស្ស) សេចក្តីថា ពិតណាស់ មនុស្សទាំងឡាយ រមែងមានសុខ

មានទុក្ខតាមកាលវេលា ។ បទថា **ឯកច្ចេ ច ទេវា** (ទេវតាពួកខ្លះ) បានដល់ទេវតាជាន់កាមាវចរៈ ។ ទេវតាជាន់កាមាវចរៈទាំងនោះ ក៏មានសុខមានទុក្ខតាមកាលវេលា ។ ព្រោះទេវតាជាន់កាមាវចរៈ ដែលមានសក្តិតូចជាងនោះ នឹងត្រូវក្រោកចាកអាសនៈ នឹងត្រូវជៀសចេញចាកផ្លូវ នឹងត្រូវដោះសំពត់ដណ្តប់ចេញ នឹងត្រូវធ្វើអញ្ជលីកម្ម ព្រោះឃើញទេវតាដែលមានសក្តិធំជាងកិច្ចកម្មសូម្បីទាំងអស់នោះ រមែងឈ្មោះថា ជាទុក្ខ ។ បទថា **ឯកច្ចេ ច វិនិបាតិកា** (និងពួកវិនិបាតប្រភេទខ្លះ) បានដល់ វេមានិកប្រេត ។ ក៏ប្រេតទាំងនោះ រមែងសោយសម្បត្តិតាមកាលវេលា សោយកម្មតាមកាលវេលា ព្រោះដូច្នោះ ទើបឈ្មោះថា មានសុខមានទុក្ខលាយគ្នានោះឯង ។ ដោយប្រការដូចពណ៌នាមកនេះ សុចរិត ៣ យ៉ាងក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះអង្គត្រាស់លាយគ្នាទាំងជាលោកិយៈ និងលោកុត្តរៈ ។

ចប់អដ្ឋកថា សង្ខារសូត្រទី ៣

# អដ្ឋកថា ពហុការសូត្រទី ៤

## *"បុគ្គលមានឧបការៈច្រើន ៣ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពហុការសូត្រទី ៤ ដូចតទៅនេះ ៈ-*

[២៤] *បទថា* ***តយោមេ ភិក្ខវេ បុគ្គលា*** *(ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ) បានដល់ បុគ្គលដែលជាអាចារ្យ ៣ ពួក ។ បទថា* ***បុគ្គលស្ស ពហុការា*** *(ជាអ្នកមានឧបការៈច្រើនដល់បុគ្គល) បានដល់ អ្នកមានឧបការៈច្រើនដល់បុគ្គលជាអន្តេវាសិក ។ បទថា* ***ពុទ្ធំ*** *បានដល់ ព្រះសព្វញ្ញុពុទ្ធ ។ បទថា* ***សរណំ គតោ ហោតិ*** *(ដល់ព្រះពុទ្ធជាសរណៈ) បានដល់ព្រះពុទ្ធជាទីពឹង ។ បទថា* ***ធម្មំ*** *(ព្រះធម៌) បានដល់ នវលោកុត្តរធម៌ ព្រមទាំងបែបផែន (ព្រះបរិយត្តិធម៌) ។ បទថា* ***សង្ឃំ*** *បានដល់ ពួកព្រះអរិយបុគ្គល ៨ ពួក ។*

*ក៏ការដល់សរណៈនេះ ព្រះមានព្រះភាគត្រាស់ទុក ដោយអំណាចនៃបុគ្គលដែលមិនធ្លាប់ដល់សរណៈ គឺ បុគ្គលមិនធ្លាប់ធ្វើសេចក្ដីជឿនោះ ។ ព្រោះថា អាចារ្យ ៣ ពួក គឺ អ្នកឲ្យសរណៈ ១ អ្នកឲ្យដល់សោតាបត្តិមគ្គ ១ អ្នកឲ្យដល់ព្រះអរហត្តមគ្គ ១ មកហើយក្នុងព្រះសូត្រនេះថា មានឧបការៈច្រើន ។ អាចារ្យ ៥ ពួក គឺ អាចារ្យអ្នកឲ្យបព្វជ្ជា ១ អាចារ្យអ្នកប្រាប់ពុទ្ធវចនៈ ១ អាចារ្យអ្នកឲ្យកម្មវាចា ១ អាចារ្យអ្នកឲ្យសម្រេចសកទាគាមិមគ្គ ១*

អាចារ្យអ្នកឲ្យសម្រេចអនាគាមិមគ្គ ១ មិនបានមកហើយក្នុងសូត្រនេះ ។

សួរថា អាចារ្យទាំងនេះមិនមានឧបការៈច្រើនឬ ។

ឆ្លើយថា មិនមែនមិនមានឧបការៈច្រើននោះទេ តែព្រះធម្មទេសនានេះកំណត់ទុក ២ ចំណែក ព្រោះដូច្នោះ អាចារ្យសូម្បីទាំងអស់នេះ ឈ្មោះថាមានឧបការៈច្រើន ។ ក្នុងបណ្តាគុណធម៌ទាំងនោះ អ្នកមិនបានធ្វើអភិនិវេសៈ (បុញ្ញាធិការ) ទុក រមែងសមគួរក្នុងការដល់សរណគមន៍ប៉ុណ្ណោះ ។ ចំណែកចតុប្បារិសុទ្ធិសីល កសិណបរិកម្ម និងវិបស្សនាញាណ ជាគុណធម៌ដែលអាស្រ័យបឋមមគ្គ ។ (ចំណែក) មគ្គ និងផល ២ ខាងលើ គប្បីជ្រាបថាអាស្រ័យអរហត្តមគ្គ ។

បទថា **ឥមិនា បុគ្គលេ** (បុគ្គលនេះ) បានដល់ បុគ្គលដែលជាអន្តេវាសិកនេះ ។ បទថា **សុប្បដិការំ វទាមិ** (តថាគតពោល...និងធ្វើការតបគុណមិនបានឡើយ) សេចក្តីថា តថាគតពោលថា ការតបគុណ មិនមែនជារបស់ដែលធ្វើបានងាយ ។ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា ពិតហើយ បណ្តាអភិវាទនកម្មជាដើម អន្តេវាសិកកាលក្រាបចុះថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានច្រើនរយដង ច្រើនពាន់ដង ក្រោកចាកអាសនៈទៅទទួល (អាចារ្យ) ក្នុងខណៈដែលឃើញគ្រប់គ្រា លើកដៃប្រណម ធ្វើសាមីចិកម្មដ៏សមគួរ ថ្វាយចីវរ

១០០ ផ្ទាំង ១.០០០ ផ្ទាំង ថ្វាយបិណ្ឌបាត ១០០ ជង ១.០០០ ជង រាល់ថ្ងៃ សានទីនៅដែលសុទ្ធទៅដោយកែវ ៧ ប្រការ ដោយមានចក្រវាឡជាព្រំដែន (និង) ថ្វាយភេសជ្ជៈច្រើនប្រការ មានទឹកដោះថ្លា ទឹកដោះខាប់ជាដើម ជាប្រចាំ ឈ្មោះថា មិនទាន់អាចធ្វើការតបនូវឧបការៈដែលអាចារ្យធ្វើហើយ ឲ្យអស់បាន ។

ចប់អដ្ឋកថា ពហុការសូត្រទី ៤

# អដ្ឋកថា វជិរូបមសូត្រទី ៥

*“បុគ្គលមានចិត្តដូចដំបៅចាស់ ដូចផ្លេកបន្ទោរ ដូចពេជ្រ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វជិរូបមសូត្រទី ៥ ដូចតទៅនេះ ៈ-*

*[២៥] បទថា **អរុក្ខូបមចិត្តោ** (មានចិត្តដូចដំបៅ) បានដល់ មានចិត្តដូចជាដំបៅក្លាយ ។ បទថា **វិជ្ជូបមចិត្តោ** (មានចិត្តដូចផ្លេកបន្ទោរ) បានដល់ មានចិត្តដូចនឹងផ្លេកបន្ទោរ ព្រោះមានពន្លឺដោយជួរខណៈតិចតួច ។ បទថា **វជិរូបមចិត្តោ** (មានចិត្តដូចពេជ្រ) បានដល់ មានចិត្តដូចជាពេជ្រ ព្រោះអាចធ្វើការសម្លាប់ឫសគល់របស់កិលេសទាំងឡាយបាន ។ បទថា **អភិសជ្ជតិ** (តានតឹង) គឺ ជាប់ជំពាក់ (ប្រកាន់ក្នុងរឿង) ។ បទថា **កុប្បតិ** (ក្រោធ) សេចក្តីថា រមែងប្របូកប្របល់ ដោយអំណាចនៃសេចក្តីក្រោធ ។ បទថា **ព្យាបជ្ជតិ** (ទាស់ចិត្ត) សេចក្តីថា លះសភាពប្រក្រតី ជារបស់ស្អុយ ។ បទថា **បតិត្ថីយតិ** (ក្រេវក្រោធ) បានដល់ រមែងដល់នូវសេចក្តីរឹងត្អឹង គឺ សេចក្តីរឹងរូស ។ បទថា **កោបំ** បានដល់ សេចក្តីក្រោធមានកំលាំងខ្សោយ ។ បទថា **ទោសំ** បានដល់ ទោសៈដែលមានកម្លាំងច្រើនជាងសេចក្តីក្រោធនោះ ដោយអំណាចនៃការប្រទូសរ៉ាយ ។ បទថា **អប្បច្ចយំ** (ការមិនពេញចិត្ត) បានដល់ ទោមនស្ស ដែលជាអាការនៃសេចក្តីមិនពេញចិត្ត ។*

បទថា **ទុដ្ឋារុកោ** (ដំបៅកាច) បានដល់ ដំបៅក្លាយ ។ បទថា **កដ្ឋេន** (ឈើ) បានដល់ ចុងឈើច្រត់ ។ បទថា **កឋលេន** បានដល់ អំបែងក្បឿង ។ បទថា **អាសវំ ទេតិ** (មានខ្ទុះហូរ) បានដល់ ហូរជាប់តគ្នាទៅ ។ អធិប្បាយថា ដំបៅក្លាយនឹងហូរចេញនូវរបស់ ៣ យ៉ាងនេះ គឺខ្ទុះ ឈាម និងទឹករងៃតាមធម្មតារបស់ខ្លួន តែកាលប៉ះត្រូវ នឹងហូរវត្ថុទាំងនោះចេញមកដ៏ច្រើន ។

ក្នុងបទថា **ឯវមេវ ខោ** នេះ មានការប្រៀបធៀបដូចតទៅនេះ បុគ្គលក្រោធ គប្បីឃើញដូចដំបៅកាច ។ ចរណៈ (ព្រឹត្តិកម្ម) របស់បុគ្គលក្រោធគប្បីឃើញដូចការហូរ (របស់មិនស្អាត) របស់ដំបៅកាចនោះ ចេញទៅតាមធម្មតារបស់ខ្លួនខ្លះ ចរណៈ (ព្រឹត្តិកម្ម) របស់គេដែលប្រទុសរ៉ាយ គប្បីឃើញដូចការហូរ (របស់មិនស្អាត) របស់សាកសពដែលហើមប៉ោងចេញទៅតាមធម្មតារបស់ខ្លួនខ្លះ ពាក្យនិយាយបន្តិចបន្តួច ក៏គប្បីឃើញដូចត្រូវប៉ះខ្ទប់ដោយឈើ ឬក្បឿង ភាវៈដែលគេប្រកាន់ដ៏ខ្លាំក្លាដោយទិដ្ឋិថា បុគ្គលនេះ (ព្រហើន) និយាយដូច្នេះ ជាមួយបុគ្គលដូចយើង គប្បីឃើញដូចការហូរចេញដ៏ច្រើននៃដំបៅក្លាយ ។

បទថា **រត្តន្ធការតិមិសាយ** (ក្នុងពេលយប់ងងឹត) សេចក្តីថា ក្នុងយាមរាត្រី គឺ ក្នុងវេលាដែលងងឹតស្និទ្ធ ព្រោះធ្វើសេចក្តីងងឹត ដោយបិទបាំង

ការកើតឡើងនៃចក្ខុវិញ្ញាណ ។ បទថា **វិជ្ជន្តរិកាយ** (ក្នុងវាងផ្លេកបន្ទោរ) បានដល់ ក្នុងខណៈនៃផ្លេកបន្ទោរ ។ សូម្បីក្នុងសេចក្តីនេះ ក៏មានការប្រៀបធៀបដូចតទៅនេះ ក៏ព្រះយោគាវចរ គប្បីឃើញដូចបុរសអ្នកមានភ្នែកល្អ ។ កិលេសដែលសោតាបត្តិមគ្គសម្លាប់ គប្បីឃើញដូចសេចក្តីងងឹត វេលាដែលសោតាបត្តិមគ្គកើតឡើង គប្បីឃើញដូចពន្លឺរបស់ផ្លេកបន្ទោរ ការឃើញព្រះនិព្វានក្នុងខណៈនៃសោតាបត្តិមគ្គ គប្បីឃើញដូចការឃើញរូបបានដោយជុំវិញរបស់បុរសអ្នកមានចក្ខុក្នុងខណៈនៃផ្លេកបន្ទោរ កិលេសដែលសកទាគាមិមគ្គសម្លាប់ គប្បីឃើញដូចការកម្ចាត់សេចក្តីងងឹតបានម្តងទៀត ការកើតឡើងនៃសកទាគាមិមគ្គញាណ គប្បីឃើញដូចជាការលេចឡើងនៃផ្លេកបន្ទោរម្តងទៀត ការឃើញព្រះនិព្វានក្នុងខណៈនៃសកទាគាមិមគ្គ គប្បីឃើញដូចជាការឃើញរូបបានដោយជុំវិញនៃបុរសអ្នកមានភ្នែកល្អ ក្នុងខណៈផ្លេកបន្ទោរ កិលេសដែលអនាគាមិមគ្គសម្លាប់ ដូចការកម្ចាត់សេចក្តីងងឹតអន្ធការម្តងទៀត ការកើតឡើងនៃអនាគាមិមគ្គញាណ គប្បីឃើញដូចការបំភ្លឺនៃផ្លេកបន្ទោរម្តងទៀត ការឃើញព្រះនិព្វានក្នុងខណៈនៃអនាគាមិមគ្គ គប្បីឃើញដូចជាការឃើញរូបដោយជុំវិញនៃបុរសអ្នកមានភ្នែកល្អ ក្នុងវាងផ្លេកបន្ទោរ ។

សូម្បីក្នុងភាវៈនៃបុគ្គលមានចិត្តប្រៀបដូចជាពេជ្រ ក៏មានការប្រៀប-

ធៀបដូចតទៅនេះ ពិតហើយ អរហត្តមគ្គញ្ញាណ គប្បីឃើញដូចពេជ្រ ។ កិលេសទាំងឡាយដែលព្រះអរហត្តមគ្គញ្ញាណកម្ចាត់ហើយ គប្បីឃើញដូចដុំកែវមណី ឬដុំថ្ម កិលេសទាំងឡាយដែលព្រះអរហត្តមគ្គញ្ញាណកម្ចាត់មិនបានមិនមាន កិលេសដែលព្រះអរហត្តមគ្គញ្ញាណកម្ចាត់បានហើយ មិនត្រឡប់កើតទៀតឡើយ គប្បីឃើញដុំកែវមណី ឬដុំថ្ម ដែលត្រូវពេជ្រកាត់ហើយ នឹងមិនត្រឡប់ជាប់គ្នាវិញឡើយ ដូច្នេះឯង ។

ចប់អដ្ឋកថា វជិរូបមសូត្រទី ៩

# អដ្ឋកថា សេវិតព្វសូត្រទី ៦

*"បុគ្គលដែលគួរសេពគប់ និងមិនគួរសេពគប់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សេវិតព្វសូត្រទី ៦ ដូចតទៅនេះ ៈ-*

*[២៦] បទថា **សេវិតព្វោ** (គួរសមាគម) បានដល់ គប្បីចូលទៅរក ។ បទថា **ភជិតព្វោ** (គួរគប់រក) បានដល់ គប្បីស្និទ្ធស្នាល ។ បទថា **បយិរុបាសិតព្វោ** (គួរចូលជិត) បានដល់ គប្បីចូលទៅរឿយៗ ដោយការអង្គុយក្នុងទីជិត ។ បទថា **សក្កត្វា គរុកត្វា** (សក្ការៈគោរព) សេចក្តីថា ធ្វើទាំងសក្ការៈ និងសេចក្តីគោរព ។*

*ក្នុងបទថា **ហីនោ ហោតិ សីលេន** (ជាបុគ្គលតូចទាប ដោយសីល) ជាដើម គប្បីជ្រាបសេចក្តីទាប (ជាងគ្នា) ដោយការប្រៀបធៀបគ្នា ។ អធិប្បាយថា ក្នុងបណ្តាបុគ្គលទាំងនោះ បុគ្គលរក្សាសីល ១០ មិនគួរសេពគប់បុគ្គលរក្សាសីល ៥ ។ បុគ្គលរក្សាចតុប្បារិសុទ្ធិសីល មិនគួរសេពគប់បុគ្គលរក្សាសីល ១០ ។ បទថា **អញ្ញត្រ អនុទយា អញ្ញត្រ អនុកម្បា** (វៀរតែការអាណិត វៀរតែការអនុគ្រោះ) សេចក្តីថា ក្រៅពីការអាណិត និងអនុគ្រោះ ។ ព្រោះថា ដើម្បីប្រយោជន៍ខ្លួនហើយ ក៏មិនគួរសេពគប់បុគ្គលដូច្នេះ ។ តែនឹងចូលទៅរកគេ ដោយសេចក្តីអាណិត ដោយអនុគ្រោះក៏គួរ ។*

បទថា **សីលសាមញ្ញគតានំ សតំ** (បើយើងទាំងឡាយមានសីលស្មើគ្នា) សេចក្តីថា បើយើងទាំងឡាយដល់ភាពជាអ្នកស្មើគ្នាដោយសីល ។ បទថា **សីលកថា ច នោ ភវិស្សតិ** (ពួកយើងក៏នឹងនិយាយគ្នាក្នុងរឿងសីលបាន) សេចក្តីថា កថាប្រារព្ធសីលនុ៎ះឯង នឹងមានដល់យើងទាំងឡាយ ដែលមានសីលស្មើគ្នាយ៉ាងនេះ ។ បទថា **សា ច នោ បវត្តនី ភវិស្សតិ** (ការនិយាយគ្នារបស់ពួកយើងនោះ ក៏នឹងប្រព្រឹត្តទៅ) សេចក្តីថា កថារបស់ពួកយើង ដែលនិយាយគ្នាសូម្បីរហូតអស់ទាំងថ្ងៃ នឹងប្រព្រឹត្តទៅ គឺ មិនដាច់រយៈ ។ បទថា **សា ច នោ ផាសុ ភវិស្សតិ** (ការនិយាយគ្នាក្នុងរឿងសីលនោះ ក៏ជាសេចក្តីសុខរបស់ពួកយើង) សេចក្តីថា សីលកថាដែលប្រព្រឹត្តទៅរហូតអស់ទាំងថ្ងៃនោះ នឹងនៅយ៉ាងសប្បាយរបស់យើងទាំងឡាយ ។ សូម្បីក្នុងសមាធិកថា និងបញ្ញាកថា ក៏មានន័យដូចគ្នានេះឯង ។

បទថា **សីលក្ខន្ធំ** គឺ **សីលរាសិ** គំនរសីល ។ បុគ្គលវៀរធម៌ដែលមិនជាទីសប្បាយដល់សីល គឺ មិនជាឧបការៈដល់សីល បដិបត្តិធម៌ដែលសប្បាយ គឺ ធម៌ដែលជាឧបការៈដល់សីល ឈ្មោះថា អនុគ្រោះសីលក្ខន្ធដោយបញ្ញា ក្នុងទីនោះៗ ក្នុងបទថា **តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ** ( នឹងរក្សាគំនរសីលដោយបញ្ញាក្នុងធម៌នោះៗ ) នេះ ។ សូម្បីក្នុងសមាធិខន្ធ

និងបញ្ញាខន្ធ ក៏មានន័យនេះដូចគ្នា ។

បទថា **និហីយតិ** (រមែងសាបសូន្យ) សេចក្តីថា បុគ្គលកាលគប់រក អ្នកដែលទាបជាងខ្លួន រមែងសាបសូន្យ គឺ រមែងវិនាស ជាប់តគ្នារឿយៗ ទៅ ដូចទឹកដែលហូរចេញពីធម្មក្រក ។ បទថា **តុល្យសេវី** (គប់រកបុគ្គលស្មើគ្នា) បានដល់ គប់រកបុគ្គលដែលស្មើនឹងខ្លួន ។ បទថា **សេដ្ឋមុបនមំ** (គប់រកបុគ្គលដែលប្រសើរជាង) បានដល់ បង្អោនចូលទៅរកបុគ្គលដែលប្រសើរ ។ បទថា **ឧទេតិ ខិប្បំ** (រមែងចម្រើនរហ័ស) សេចក្តីថា រមែងចម្រើនរហ័សតែម្យ៉ាង ។ បទថា **តស្មា អត្តនោ ឧត្តរឹ ភជេថ** (ព្រោះដូច្នោះ គួរគប់រកបុគ្គលដែលក្រៃលែងជាងខ្លួន) សេចក្តីថា ព្រោះហេតុដែលបុគ្គលបង្អោនខ្លួនចូលទៅរកបុគ្គលដែលប្រសើរ រមែងចម្រើនរហ័ស ដូច្នោះ ទើបគួរគប់រកបុគ្គលដែលខ្ពស់ជាង បានដល់ បុគ្គលដែលប្រសើរជាងខ្លួន ។

ចប់អដ្ឋកថា សេវិតព្វសូត្រទី ៦

# អដ្ឋកថា ជិគុច្ឆិតព្វសូត្រទី ៧

## *"បុគ្គលដែលគួរសេពគប់ និងមិនគួរសេពគប់"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ជិគុច្ឆិតព្វសូត្រទី ៧ ដូចតទៅនេះ ៈ-*

[២៧] *បទថា* ***ជិគុច្ឆិតព្វោ*** *(គួរខ្ពើម) សេចក្តីថា បុគ្គលដែលនរណាៗ គប្បីរង្កៀសដូចលាមក ដូច្នោះ ។ បទថា* ***អថខោ នំ*** *គឺ* ***អថខោ អស្ស*** *។ បទថា* ***កិត្តិសទ្ទោ*** *(កិត្តិសព្ទ) គឺ សំឡេងដែលពោលតគ្នា ។ ក្នុងបទថា* ***ឯវមេវ ខោ*** *(ដូច្នោះដូចគ្នា) នេះ គប្បីជ្រាបការប្រៀបធៀបដូចតទៅនេះ ៈ-*

*ភាពជាអ្នកទ្រុស្តសីល គប្បីឃើញដូចរណ្តៅលាមក ។ បុគ្គលដែលទ្រុស្តសីល គប្បីឃើញដូចពស់តុកកែធ្លាក់ចុះទៅក្នុងរណ្តៅលាមក ដូច្នោះ ការៈដែលបុគ្គលដែលគប់រកបុគ្គលទ្រុស្តសីល (តែ) មិនធ្វើតាមបុគ្គលដែលទ្រុស្តសីលនោះ គប្បីឃើញដូចការៈដែលបុគ្គលត្រូវពស់ដែលគេលើកឡើងពីរណ្តៅលាមកពាក់លើរាងកាយ តែមិនខាំ ដូច្នោះ វេលាដែលបុគ្គលគប់រកបុគ្គលទ្រុស្តសីល រហូតមានឈ្មោះមិនល្អទូទៅ គប្បីជ្រាបដូចវេលាដែលគេត្រូវពស់ប្រលាក់លាមករឹតសរីរៈ ដូច្នោះ ។ បទថា* ***តិណ្ឌុកាលតំ*** *បានដល់ អង្កត់ភ្លើងឧសជង្ហ្គោ ។ បទថា* ***ភិយ្យោសោ មត្តាយ ចិចិដាយតិ*** *(រមែងធ្វើសំឡេងឮចិចិដៈក្រៃលែងឡើង) សេចក្តីថា ក៏អង្កត់ឧសជង្ហ្គោនោះ កាលត្រូវ*

ដុតតាមប្រក្រតី កំទេចនឹងផ្ទុះចេញមានសំឡេងចិចិដៈៗ អធិប្បាយថា កាល កៀសដោយកំណាត់ឈើ នឹងបញ្ចេញសំឡេងខ្លាំងឡើង ។

បទថា **ឯវមេវ ខោ** (ដូច្នោះដូចគ្នា) សេចក្តីថា បុគ្គលក្រោធក៏ដូច្នោះដែរ គឺ សូម្បីតាមធម្មតារបស់ខ្លួន ក៏ជាអ្នកមិនស្ងប់ មានការប្រទូសត្រាប់ទៅ ។ ក្នុងវេលាដែលបានស្តាប់ពាក្យនិយាយ (ពោលថា) សូម្បីតិចតួច ក៏ក្រេវក្រោធប្រទូសរ៉ាយក្រៃលែងឡើងថា បុគ្គលនេះនិយាយយ៉ាងនេះៗ នឹងមនុស្សដូចជាយើងបាន ។ បទថា **គូថកូបោ** (រណ្តៅលាមក) បានដល់ រណ្តៅដែលពេញទៅដោយលាមក ឬគំនរលាមកនោះឯង ។ ក៏ក្នុងទីនេះ គប្បីជ្រាបការប្រៀបធៀប ដូចន័យមុននោះឯង ។

បទថា **តស្មា ឯវរូបោ បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ** (ព្រោះដូច្នោះ បុគ្គលដែលក្រោធនេះ គួរសម្លឹងជាព្រងើយ មិនគួរសមាគម) សេចក្តីថា ព្រោះហេតុដែលបុគ្គលអ្នកក្រោធ កាលនរណាគប់រក នៅកៀកជិតក៏ក្រោធ ដូចគ្នា រមែងក្រោធសូម្បីចំពោះបុគ្គលដែលជេរថា បុគ្គលនេះមានប្រយោជន៍អ្វី ដូច្នោះ គេទើបដូចជាភ្លើងឆេះចំបើង ដែលគ្រប់បុគ្គលគួរសម្លឹងជាព្រងើយ មិនគួរចូលទៅគប់រក ។ លោកអធិប្បាយទុកដូចម្តេច ។ លោកអធិប្បាយទុកថា បុគ្គលដែលចូលទៅជិតភ្លើងចំបើងជិតពេក នឹងក្តៅ រាងកាយ

របស់គេនឹងត្រូវឆេះផងដែរ បុគ្គលដែលថយចេញឆ្ងាយពេក នឹងមិនក្ដៅ ភាពត្រជាក់របស់គេក៏មិនបាត់ ចំណែកបុគ្គលដែលអាំងភ្លើងនៅក្នុងចម្ងាយល្មម មិនចូលជិតពេក និងមិនថយឆ្ងាយពេក ភាពត្រជាក់ក៏នឹងបាត់ទៅ ព្រោះដូច្នោះ បុគ្គលដែលក្រោធដូចជាភ្លើងចំបើង ទើបគួរត្រូវព្រងើយ ដោយការដាក់ខ្លួនជាកណ្ដាល មិនគួរនរណាៗ នឹងសមាគម មិនគួរនរណាៗ នឹងគប់រក មិនគួរដល់នរណាៗ នឹងចូលទៅអង្គុយជិត ។

បទថា **កល្យាណមិត្តោ** (មានមិត្តល្អ) បានដល់ មានមិត្តដែលស្អាត ។ បទថា **កល្យាណសហាយោ** (មានសាហាយល្អ) បានដល់ សាហាយដែលស្អាត ។ ដែលឈ្មោះថា សាហាយ បានដល់ អ្នកមានប្រក្រតីទៅរួមគ្នា និងប្រព្រឹត្តរួមគ្នា ។ បទថា **កល្យាណសម្បវង្កោ** (មានសម្លាញ់ល្អ) បានដល់ អ្នកបង្អោនទៅក្នុងកល្យាណមិត្តទាំងឡាយ គឺ ក្នុងបុគ្គលដែលស្អាត អធិប្បាយថា មានចិត្តបង្អោនទៅក្នុងកល្យាណមិត្តនោះ ។

ចប់អដ្ឋកថា ជិគុច្ឆិតព្វសូត្រទី ៧

# អដ្ឋកថា គូថភាណីសូត្រទី ៨

## *"បុគ្គលអ្នកពោល ៣ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង គូថភាណីសូត្រទី ៨ ដូចតទៅនេះ ៖-*

*[២៨] បុគ្គលណា ពោលពាក្យប្រកបដោយក្លិនស្អុយដូចលាមក បុគ្គលនោះឈ្មោះថា **គូថភាណី** ។ បុគ្គលណាពោលពាក្យប្រកបដោយក្លិនក្រអូបដូចផ្កាឈើ បុគ្គលនោះឈ្មោះថា **បុប្ផភាណី** ។ បុគ្គលណា ពោលពាក្យផ្អែមល្ហែមដូចទឹកឃ្មុំ បុគ្គលនោះឈ្មោះថា **មធុភាណី** ។*

*បទថា **សភាគតោ** (ចូលសភា) បានដល់ នៅក្នុងសភា ។ បទថា **បរិសគតោ** (ចូលជំនុំជន) បានដល់ នៅក្នុងបរិស័ទ ។ បទថា **ញាតិមជ្ឈគតោ** (ក្នុងពពួកញាតិ) បានដល់ នៅក្នុងកណ្តាលទាយាទទាំងឡាយ ។ បទថា **បូគមជ្ឈគតោ** (ក្នុងពពួកករជការ) បានដល់ នៅក្នុងកណ្តាលសេនាទាំងឡាយ ។ បទថា **រាជកុលមជ្ឈគតោ** (ក្នុងរាជត្រកូល) បានដល់ នៅក្នុងកណ្តាលរាជត្រកូល គឺ ក្នុងផ្ទៃព្រះរោងសម្រាប់វិនិច្ឆ័យរបស់ព្រះរាជា ។ បទថា **អភិនីតោ** (ត្រូវនាំខ្លួនទៅ) បានដល់ ត្រូវនាំទៅដើម្បីត្រូវការសាកសួរ ។ បទថា **សក្ខិបុដ្ឋោ** (ត្រូវសាកសួរជាសាក្សី) បានដល់ ត្រូវគេអាងជាសាក្សី ហើយសួរ ។ បទថា **ឯវំ ភោ បុរិស** នេះ ជាអាលបនៈ ។ បទថា **អត្តហេតុ វា បរហេតុ***

វា (ព្រោះឃើញដល់ខ្លួនខ្លះ ព្រោះឃើញដល់អ្នកដទៃខ្លះ) បានដល់ ព្រោះហេតុនៃអវយវៈ មានដៃ និងជើងជាដើមរបស់ខ្លួន ឬរបស់បុគ្គលដទៃ ។ **លោក** លោកបំណងយកថា **អាមិស** ក្នុងបទថា **អាមិសកិញ្ចិក្ខហេតុ វា** នេះ ។ បទថា **កិញ្ចិក្ខំ** បានដល់ វត្ថុបន្តិចបន្តួច គឺ របស់តិចតួច អធិប្បាយថា ហេតុនៃអាមិស ដោយទីបំផុតសូម្បីត្រឹមតែសត្វទទា សត្វក្រួច ដុំទឹកដោះថ្លា និងដុំទឹកដោះខាប់ ជាដើម ។ បទថា **សម្បជានមុសា ភាសិតា ហោតិ** សេចក្តីថា ពោលមុសាវាទទាំងដឹងខ្លួន ។

ទោស ហៅថា **ឯលៈ** ក្នុងបទថា **នេលា** ។ វាចា ឈ្មោះថា **មិនមានទោស** ព្រោះអត្ថថា ទោសនៃវាចានោះមិនមាន អធិប្បាយថា ប្រាសចាកទោស ។ វាចាមិនមានទោស ដូចសីលដែលព្រះមានព្រះភាគត្រាស់ទុកក្នុងគាថានេះថា **នេលង្គោ សេតបច្ឆាទោ** ។

វាចា ឈ្មោះថា **សប្បាយត្រចៀក** បានដល់ វាចាដែលសុខត្រចៀក ព្រោះមានព្យញ្ជនៈពីរោះ ។ វាចានោះ មិនឲ្យកើតការចាក់ដោតត្រចៀក ដូចប្រើម្ជុលចាក់ដូច្នោះ ។

វាចា ឈ្មោះថា **គួរស្រឡាញ់** ព្រោះអត្ថថា មិនឲ្យកើតសេចក្តីក្រោធ ឲ្យកើតសេចក្តីស្រឡាញ់ ទូទៅទាំងរាងកាយ ព្រោះមានអត្ថពីរោះ ។

វាចា ឈ្មោះថា **ជាប់ចិត្ត** ព្រោះអត្ថថា ពេញចិត្ត គឺ មិនខ្វាំងខ្ទប់ចូលទៅកាន់ចិត្តដោយស្រួល ។

វាចា ឈ្មោះថា **ជាសំដីអ្នកក្រុង** ព្រោះអត្ថថា មានក្នុងក្រុង ព្រោះបរិបូរណ៍ដោយគុណ ។ មួយទៀត វាចា ឈ្មោះថា ជាសំដីអ្នកក្រុង ព្រោះអត្ថថា ល្អិតល្អន់ល្អ ដូចនារីដែលចម្រើនធំធាត់ក្នុងក្រុង ដូច្នោះ ។ មួយទៀត វាចា ឈ្មោះថា ជាសំដីអ្នកក្រុង ព្រោះអត្ថថា ជាវាចារបស់អ្នកក្រុង អធិប្បាយថា ជាវាចារបស់អ្នកដែលនៅក្នុងក្រុង ។ ពិតហើយ អ្នកក្រុងរមែងមានពាក្យសំដីគួរសម គឺ ហៅបុគ្គលវ័យចំណាស់ឪពុកថា លោកឪពុក ហៅបុគ្គលវ័យចំណាស់បងប្រុសប្អូនប្រុសថា បងប្រុស ប្អូនប្រុស ។

ព្រោះថា ពាក្យសំដីនេះ ឈ្មោះថា **ជាទីស្រឡាញ់នៃជនច្រើន** ព្រោះអត្ថថា ជាវាចាដែលជនច្រើនស្រឡាញ់ ។

វាចា ឈ្មោះថា **ជាទីពេញចិត្តនៃជនច្រើន** ព្រោះអត្ថថា ជាទីពេញចិត្ត គឺ ធ្វើសេចក្ដីចម្រើនចិត្តដល់ជនច្រើន ព្រោះជាវាចាដែលជនច្រើនស្រឡាញ់នោះឯង ។

ចប់អដ្ឋកថា កូដភាណិសូត្រទី ៨

# អដ្ឋកថា អន្ធសូត្រទី ៩

## "បុគ្គលខ្វាក់ មានភ្នែកម្ខាង និងមានភ្នែកទាំងពីរខាង"

គប្បីជ្រាបវិនិច្ឆ័យក្នុង អន្ធសូត្រទី ៩ ដូចតទៅនេះ ៖-

[២៩] បទថា **ចក្ខុ ន ហោតិ** (មិនមានភ្នែក) បានដល់ មិនមានបញ្ញា-ចក្ខុ ។ បទថា **ផាតឹ ករេយ្យ** (ធ្វើឲ្យចម្រើន) សេចក្តីថា គប្បីធ្វើភោគៈដែលបានមកហើយ ឲ្យគង់នៅ គឺ ឲ្យចម្រើន ។ បទថា **សាវជ្ជានវជ្ជេ** (ដែលមានទោស និងមិនមានទោស) បានដល់ ធម៌ដែលមានទោស និងមិនមានទោស ។ បទថា **ហីនប្បណីតេ** (ដែលគ្រោតគ្រាត និងល្អិត) បានដល់ ធម៌ទាប និងខ្ពស់ ។ បទថា **កណ្ហសុក្កសប្បដិភាគេ** (ជាចំណែកខ្មៅ និងស) សេចក្តីថា ធម៌ខ្មៅ និងធម្មសនុ៎ះឯង ព្រះមានព្រះភាគត្រាស់ថា ជាបដិភាគនឹងគ្នា ព្រោះជាបដិបក្ខដល់គ្នា ព្រោះជាសត្រូវដល់គ្នានិងគ្នា ។ ក៏ក្នុងបទនេះ មានសេចក្តីសង្ខេបដូចតទៅនេះ បុគ្គលគប្បីស្គាល់កុសលធម៌ ថាជាកុសលធម៌ ។ គប្បីស្គាល់អកុសលធម៌ ថាជាអកុសលធម៌ ។ សូម្បីក្នុងបទមានជាអាទិ៍ថា ធម៌ដែលមានទោសជាដើម ក៏មានន័យនេះឯង ។ ចំណែកក្នុងធម៌ដែលជាបដិ-ភាគគ្នា ទាំងធម៌ខ្មៅ និងធម៌ស ធម៌ខ្មៅបុគ្គលគប្បីដឹងថា ជាបដិភាគនឹងធម៌ស ធម៌សបុគ្គលគប្បីដឹងថា ជាបដិភាគនឹងធម៌ខ្មៅ ដោយបញ្ញាចក្ខុណា ចក្ខុបែប

នោះ របស់បុគ្គលនោះមិនមាន អ្នកសិក្សាគប្បីជ្រាបន័យ សូម្បីក្នុងវារៈដ៏សេស ក៏មានន័យដូចពោលមកនេះឯង ។

បទថា **ន ចេវ ភោគា តថារូបា** (ភោគៈដូចពោលមកក៏មិនមាន) សេចក្តីថា សូម្បីភោគៈប្រភេទនោះ រមែងមិនមានដល់បុគ្គលនោះ ។ បទថា **ន ច បុញ្ញានិ កុព្វតិ** (សេចក្តីល្អក៏មិនធ្វើ) សេចក្តីថា ហើយគេរមែងមិនធ្វើបុណ្យ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ គឺ ទ្រង់ត្រាស់ដល់ការមិនមាននៃចក្ខុដែលជាហេតុឲ្យភោគៈកើតឡើង និងចក្ខុដែលធ្វើឲ្យកើតញាណ (បញ្ញា-ចក្ខុ) ។ បទថា **ឧភយត្ថ កលិគ្គហោ** (គ្រោះកាចទាំងពីរ) បានដល់ ចាប់ខុស អធិប្បាយថា ចាប់យកឃ្មៀងឃ្មាតក្នុងលោកទាំង ២ គឺ ក្នុងលោកនេះ និងក្នុងលោកខាងមុខ ។ម្យ៉ាងទៀត បទថា **គ្រោះកាចទាំងពីរផ្លូវ** គឺ ចាប់យកប្រយោជន៍ទាំង ២ គឺ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយកពថា ជាទោស អធិប្បាយថា ប្រកាន់យកខុស ។ បទថា **ធម្មាធម្មេន** (ដោយរឿងធម៌ និងអធម៌) បានដល់ ដោយធម៌ គឺ កុសលកម្មបថ ១០ ខ្វះ ដោយធម៌ គឺ អកុសលកម្មបថ ១០ ខ្វះ ។ បទថា **សំសដ្ឋោ** (ប្រឡូកប្រឡំ) បានដល់ អំពើកោង ។ បទថា **ភោគានិ បរិយេសតិ** (ស្វែងរកតែភោគទ្រព្យ) គឺ ស្វែងរកភោគៈទាំងឡាយ ។

បទថា **ថេយ្យេន កូដកម្មេន មុសាវាទេន ចូភយំ** (ដោយការលួចការកោង និងក្រឡិចក្រឡុច) សេចក្តីថា ស្វែងរកភោគៈទាំងឡាយដោយកម្មទាំងពីរ ក្នុងបណ្តាកម្មមានថេយ្យកម្មជាដើម ។ សួរថា ស្វែងរកដោយកម្មទាំងពីរដូចម្តេច ។ ឆ្លើយថា យ៉ាងនេះគឺ ស្វែងរកភោគៈទាំងឡាយដោយថេយ្យកម្ម (ការលួច) និងកូដកម្ម (ការគៀចក្រាញ ឬអំពើកោង) បានដល់ស្វែងរកដោយថេយ្យកម្ម និងមុសាវាទ និងស្វែងរកដោយកូដកម្ម និងមុសាវាទ ។ បទថា **សំហាតុំ** (ដើម្បីរួបរួម) បានដល់ ដើម្បីប្រមូល ។ បទថា **ធម្មលទ្ធេហិ** (ដែលខ្លួនរកបានដោយល្អ) បានដល់ ដែលបានមកដោយធម៌ គឺកុសលកម្មបថ ១០ ។ បទថា **ឧដ្ឋានាធិគតំ** គឺ ដែលបានដោយសេចក្តីព្យាយាម ។ បទថា **អព្យគ្គមនសោ** គឺ មានចិត្តប្រាសចាកវិចិកិច្ឆា ។ បទថា **ភទ្ទកណ្ឋានំ** (ឋានៈដ៏ប្រសើរ) គឺ ឋានៈរបស់ទេពដ៏ប្រសើរ ។ បទថា **ន សោចតិ** (មិនសោកសៅ) គឺ មិនសោកសៅ ដោយសេចក្តីសោកសៅខាងក្នុង សូម្បីក្នុងទីណា ។

ចប់អដ្ឋកថា អន្ធសូត្រទី ៩

# អដ្ឋកថា អវកុជ្ជិតសូត្រទី ១០

## *"បុគ្គលមានបញ្ញា ៣ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អវកុជ្ជិតសូត្រទី ១០ ដូចតទៅនេះ ៖-*

[៣០] *បទថា **អវកុជ្ជបញ្ញោ** (មានបញ្ញាដូចក្អមផ្កាប់) បានដល់ មានបញ្ញាដូចគ្នានឹងក្អមផ្កាប់មាត់ចុះ ។ បទថា **ឧច្ឆង្គបញ្ញោ** (មានបញ្ញាដូចថ្នក់លេច) បានដល់ មានបញ្ញាដូចគ្នានឹងថ្នក់លេច ។ បទថា **បុថុបញ្ញោ** (មានបញ្ញាច្រើន) បានដល់ មានបញ្ញាធំទូលាយ ។*

*ក្នុងបទថា **អាទិកល្យាណំ** (ល្អខាងដើម) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ការផ្ដើម (ទេសនា) ឈ្មោះថា ខាងដើម , កណ្ដាលនៃកថាឈ្មោះថា កណ្ដាល , ផ្នែកបញ្ចប់ ឈ្មោះថា ខាងចុង ។ ភិក្ខុទាំងនោះ កាលពោលធម៌ដល់បុគ្គលនោះ យ៉ាងនេះ ឈ្មោះថា ពោលធ្វើឲ្យល្អ គឺ ឲ្យចម្រើនបានដល់ មិនមានទោស ទាំងក្នុងភាវៈចាប់ផ្ដើម ទាំងក្នុងភាវៈកណ្ដាល ទាំងក្នុងភាវៈខាងចុង ។ មួយទៀត ក្នុងសូត្រនេះ មានខាងដើម កណ្ដាល និងខាងចុងនៃទេសនា និងមានខាងដើម កណ្ដាល និងខាងចុងនៃសាសនធម៌ ។*

*បណ្ដាទេសនា និងសាសនធម្មទាំងពីរនោះ (នឹងពោល) ទេសនាមុនគាថា ៤ បទ បទដំបូងជាខាងដើម ពីរបទជាកណ្ដាល (និង) បទខាងក្រោយ*

ជាបទខាងចុង ។

ចំពោះព្រះសូត្រដែលមានអនុសន្ធិតែមួយ និទានជាខាងដើម អនុសន្ធិជាកណ្តាល ផ្នែកចប់ព្រះសូត្រដែលមានបទថា **ឥទមវោច** ជាខាងចុង ។

ចំពោះព្រះសូត្រដែលមានអនុសន្ធិច្រើន អនុសន្ធិទី ១ ជាខាងដើម អនុសន្ធិមួយ ឬច្រើនអនុសន្ធិ ជាកណ្តាល អនុសន្ធិចុងក្រោយ ជាខាងចុង ។ នេះជាន័យនៃទេសនា ។

ចំណែកសាសនធម៌ សីលជាខាងដើម សមាធិជាកណ្តាល វិបស្សនាជាខាងចុង ។ម្យ៉ាងទៀត សមាធិជាខាងដើម វិបស្សនាជាកណ្តាល មគ្គជាខាងចុង ។ ម្យ៉ាងទៀត វិបស្សនាជាខាងដើម មគ្គជាកណ្តាល ផលជាខាងចុង ។ ម្យ៉ាងទៀត មគ្គជាខាងដើម ផលជាកណ្តាល និព្វានជាខាងចុង ។ ម្យ៉ាងទៀត កាលធ្វើធម៌ឲ្យជាគូៗ គ្នា សីល និងសមាធិជាខាងដើម វិបស្សនានិងមគ្គជាកណ្តាល ផល និងនិព្វានជាខាងចុង ។

បទថា **សាត្ថំ** (ព្រមទាំងអត្ថ) សេចក្តីថា ភិក្ខុទាំងឡាយសម្តែងធម៌ឲ្យមានប្រយោជន៍ ។ បទថា **សព្យញ្ជនំ** សេចក្តីថា សម្តែងធម៌ឲ្យអក្សរបរិបូរណ៍ ។ បទថា **កេវលបរិបុណ្ណំ** (បរិបូរគ្រប់សព្វ) សេចក្តីថា សម្តែងធម៌ឲ្យបរិបូរណ៍គ្រប់សព្វ គឺ មិនខ្វះខាត ។ បទថា **បរិសុទ្ធំ** (បរិសុទ្ធិ) សេចក្តី

ថា សម្តែងធម៌ឲ្យបរិសុទ្ធិ គឺ មិនឲ្យប្រឡូកប្រឡល់ មិនមានទីបញ្ចប់ ។ បទថា **ព្រហ្មចរិយំ បកាសេន្តិ** (ប្រកាសព្រហ្មចរិយៈ) សេចក្តីថា កាលសម្តែងដូច្នោះ ឈ្មោះថា ប្រកាសអរិយមគ្គមានអង្គ ៨ ដែលសង្គ្រោះដោយត្រៃសិក្ខា ដែលជាចរិយាដ៏ប្រសើរបំផុត ។ បទថា **នេវាទិ មនសិករោតិ** (មិនធ្វើទុកក្នុងចិត្តទាំងជាខាងដើម) សេចក្តីថា តាំងពីផ្តើមទេសនាក៏មិនធ្វើទុកក្នុងចិត្ត ។

បទថា **កុម្ភោ** គឺ **ឃដោ** (ឆ្នាំង) ។ បទថា **និកុជ្ជោ** (ផ្កាប់) គឺ ផ្កាប់មាត់ចុះ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បុគ្គលដែលមានបញ្ញាទន់ទាប គប្បីឃើញដូចក្អមផ្កាប់មាត់ចុះ ។ វេលាដែលបាន (ស្តាប់) ព្រះធម៌ទេសនា គប្បីឃើញដូចវេលាដែលចាក់ទឹក (លើក្អម) ។ វេលាដែលបុគ្គលអង្គុយនៅលើអាសនៈនោះ មិនទាន់អាចរៀនបាន គប្បីឃើញដូចវេលាដែលទឹកហូរចេញទៅអស់ ។ វេលាដែលបុគ្គលនោះក្រោកឡើង ហើយចាំមិនបាន គប្បីឃើញដូចវេលាដែលទឹកមិនដក់នៅ (ក្នុងក្អម) ។ បទថា **អាកិណ្ណានិ** ប្រែថា ដែលរក្សាទុក ។ បទថា **សតិសម្មោសា បកិរេយ្យ** (ភ្លេចខ្លួន ក្រោកឡើង ក៏ជ្រុះអស់ទៅ) សេចក្តីថា (របស់គួរទំពារនោះ) គប្បីជ្រុះទៅ ព្រោះជាអ្នកភ្លេចខ្លួន ។

ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖-

បុគ្គលដែលមានបញ្ញាដូចថ្នក់លេច គប្បីឃើញដូចជាថ្នក់លេច ។ ព្រះពុទ្ធវចនៈមានប្រការផ្សេងៗ គប្បីឃើញដូចរបស់ទំពារស៊ីប្រភេទផ្សេងៗ ។ វេលាដែលបុគ្គលអង្គុយរៀននៅលើអាសនៈនោះ គប្បីឃើញដូចវេលាដែលបុគ្គលអង្គុយទំពាររបស់ទំពារប្រភេទផ្សេងៗ (ដែលនៅ) លើភ្លៅ ។ វេលាដែលបុគ្គលក្រោកចាកអាសនៈនោះ ហើយចាំមិនបាន គប្បីឃើញដូចវេលាដែលបុគ្គលក្រោកឡើងធ្វើរបស់ឲ្យជ្រុះរាត់រាយ ព្រោះភ្លេចខ្លួន ។

បទថា **ឧក្កុជ្ជោ** (ផ្ងារ) បានដល់ (ក្អម) ដាក់ផ្ងារមាត់ឡើង ។ បទថា **សណ្ឋាតិ** (រមែងដក់) គឺ ទឹករមែងដក់នៅ ។

ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បុគ្គលដែលមានបញ្ញាទូលាយ គប្បីឃើញដូចក្អមដែលដាក់មាត់ផ្ងារឡើង ។ វេលាដែលបានស្តាប់ទេសនា គប្បីឃើញដូចវេលាដែលចាក់ទឹកចុះ ។ វេលាដែលបុគ្គលអង្គុយស្តាប់នៅលើអាសនៈនោះ គប្បីឃើញដូចវេលាដែលទឹកដក់នៅ ។ វេលាដែលបុគ្គលក្រោកឡើងដើរទៅ នៅចាំបាន គប្បីឃើញដូចវេលាដែលទឹកមិនហូរចេញទៅ ។

បទថា **ទុម្មេធោ** (ល្ងង់ខ្លៅ) បានដល់ មិនមានបញ្ញា ។ បទថា **អវិចិក្ខណោ** (មិនមានបញ្ញាជាគ្រឿងពិចារណា) បានដល់ មិនមានបញ្ញាជា

គ្រឿងចាត់ការ ។ បទថា គន្តា (ទៅ) បានដល់ មានការទៅជាប្រក្រតី ។ បទថា សេយ្យោ ឯតេន វុច្ចតិ (តថាគតពោលថា ប្រសើរជាងបុគ្គលមានបញ្ញាដូចជាភ្លូមផ្កាប់) សេចក្តីថា (បុគ្គលដែលមានបញ្ញាដូចថ្នក់លេច) ព្រះពុទ្ធជាម្ចាស់ត្រាស់ថា ប្រសើរជាងបុគ្គលនោះ (គឺបុគ្គលមានបញ្ញាដូចជាភ្លូមផ្កាប់) ។

បទថា ធម្មានុធម្មាបដិបន្នោ (បដិបត្តិធម៌សមគួរដល់ធម៌) សេចក្តីថា បដិបត្តិធម៌សមគួរដល់លោកុត្តរធម៌ ៩ គឺ បដិបត្តិវត្តបដិបត្តិខាងដើម ព្រមទាំងសីល ។ បទថា ទុក្ខស្ស បានដល់ វដ្តទុក្ខ ។ បទថា អន្តករោ សិយា (គប្បីធ្វើទីបំផុត) សេចក្តីថា បុគ្គលគប្បីជាអ្នកធ្វើទីបំផុត គឺ គប្បីជាអ្នកធ្វើឲ្យអស់ឫសគល់ បានដល់ គប្បីជាអ្នកធ្វើឲ្យដល់ទីបំផុតផ្លូវ (ទុក្ខ) ។

ចប់អដ្ឋកថា អវកុជ្ជសូត្រទី ១០

## ចប់បុគ្គលវគ្គវណ្ណនាទី ៣

## ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ១០ សូត្រ

# ទេវទូតវគ្គទី ៤

## អដ្ឋកថា ព្រហ្មកសូត្រទី ១

*"ពោលដោយព្រហ្មបុគ្គ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រហ្មកសូត្រទី ១ ដូចតទៅនេះ ៖-*

[៣១] *បទថា* ***អជ្ឈាគារេ*** *(ក្នុងផ្ទះខ្លួន) បានដល់ ក្នុងផ្ទះរបស់ខ្លួន ។ បទថា* ***បូជិតា ហោន្តិ*** *(ដែលបុត្តទាំងឡាយបូជាហើយ) សេចក្តីថា មាតាបិតាជាអ្នកដែលបុត្របដិបត្តិទំនុកបម្រុង ដោយវត្ថុដែលមាននៅក្នុងផ្ទះ ។*

*ព្រះមានព្រះភាគ លុះទ្រង់ប្រកាសត្រកូលដែលបូជាមាតាបិតា ថាជាត្រកូលមានព្រហ្ម (ប្រចាំផ្ទះ) ដោយមានមាតាបិតា (ជាព្រហ្ម) យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងដល់វត្ថុដែលមាតាបិតាទាំងនោះ ជាបុព្វាចារ្យជាដើម ទើបត្រាស់ពាក្យមានជាអាទិ៍ថា* ***មានបុព្វាចារ្យ*** *ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា* ***ព្រហ្មា*** *(ព្រហ្ម) ជាដើម ព្រះមានព្រះភាគត្រាស់ទុក ដើម្បីឲ្យសម្រេចភាពជាព្រហ្មជាដើម ដល់ត្រកូលទាំងនោះ ។ បទថា* ***ពហុការា*** *(មានឧបការៈច្រើន) បានដល់ មានឧបការៈច្រើនដល់បុត្រទាំងឡាយ ។ បទថា* ***អាបាទកា*** *(ថ្នាក់ថ្នម) បានដល់ ថ្នមជីវិតទុក ។ អធិប្បាយថា មាតាបិតា*

ចួមជីវិតបុត្រ គឺ ចិញ្ចឹមបីបាច់រក្សា បានដល់ ឲ្យប្រព្រឹត្តទៅបាន ។ បទថា **បោសកា** (ចិញ្ចឹម) សេចក្តីថា ចិញ្ចឹមឲ្យដៃជើងធំធាត់ ឲ្យផឹកឈាមក្នុងដោះ ។ បទថា **ឥមស្ស លោកស្ស ទស្សេតារោ** (សម្តែងលោកនេះ) សេចក្តីថា ព្រោះឈ្មោះថា ការដែលបុត្រទាំងឡាយបានឃើញឥដ្ឋារម្មណ៍ និងអនិដ្ឋា-រម្មណ៍ក្នុងលោកនេះបាន ព្រោះអាស្រ័យមាតាបិតា ព្រោះដូច្នោះ មាតាបិតា ទើបឈ្មោះថា ជាអ្នកសម្តែងលោកនេះ ។

បទថា **ព្រហ្មា** (ព្រហ្ម) ក្នុងបទថា **ព្រហ្មាតិ មាតាបិតរោ** (មាតាបិតាទាំងឡាយ...ហៅថា ព្រហ្ម) នេះ ជាឈ្មោះរបស់លោកដ៏ប្រសើរបំផុត ។ ព្រហ្មនឹងមិនលះភាវនា ៤ យ៉ាង គឺ មេត្តា ករុណា មុទិតា ឧបេក្ខា យ៉ាងណា មាតាបិតាទាំងឡាយ ក៏ដូច្នោះ នឹងមិនលះភាវនា ៤ ក្នុងបុត្រទាំងឡាយ ភាវនាទាំង ៤ នោះ គប្បីជ្រាបតាមរយៈកាលដូចតទៅនេះ ។

ពិតណាស់ ក្នុងវេលាដែលបុត្រនៅក្នុងផ្ទៃ មាតាបិតាកើតមេត្តាចិត្តយ៉ាងនេះថា កាលណាហ្ន៎ យើងនឹងបានឃើញបុត្រតូច រួចផុតភ័យ មិនមានរោគ មានអវយវៈតូចធំគ្រប់បរិបូរណ៍ ។ តែកាលណា បុត្រតូចនោះនៅក្មេង ដេកលើកម្រាល មានសង្អើច ឬស្រមើលវារលើ ឬដេកនៀលចុះឡើង មានសំឡេងស្រែកយំ កាលមាតាបិតាបានឮសំឡេងបុត្រនោះ ក៏កើតសេចក្តីករុណា

តែក្នុងវេលាដែលបុត្រវត់លេងទៅមក ឬក្នុងវេលាដែលបុត្រតាំងនៅក្នុងវ័យកម្លោះក្រមុំ មាតាបិតារមែងតាមសម្លឹងមើល នឹងមានចិត្តជូរស្រោល រីករាយសប្បាយ ដូចជាសំឡីគដែលថ្ពិច ១០០ ដង ត្រាំចុះក្នុងទឹកដោះថ្លា កាលនោះមាតាបិតានឹងមានមុទិតា ។ តែកាលណា បុត្រផ្តើមមានភរិយាស្វាមី បែកផ្ទះចេញទៅ កាលនោះ មាតាបិតានឹងមានការកំណត់ក្នុងចិត្តថា ឥឡូវនេះ បុត្ររបស់យើងនឹងអាចរស់នៅបានដោយខ្លួនឯង ដូច្នោះហើយ វេលានោះ មាតា-បិតានឹងមានឧបេក្ខា ។ ដោយហេតុដូចពោលមកនេះ ព្រះមានព្រះភាគត្រាស់ថា **មាតាបិតាទាំងឡាយ** (ជាអ្នកមានសេចក្តីអាណិតអាសូរដល់កូន) **ហៅថាជាព្រហ្ម** ដូច្នេះ ។

បទថា **បុព្វាចរិយាតិ វុច្ចរេ** (ហៅថាជាបុព្វាចារ្យ) សេចក្តីថា ការពិត មាតាបិតាទាំងឡាយចាប់ផ្តើមតាំងពីបុត្រកើតហើយ រមែងឲ្យបុត្ររៀនឲ្យបុត្រចេះគិតថា ចូរអង្គុយយ៉ាងនេះ ចូរឈរយ៉ាងនេះ ចូរដើរយ៉ាងនេះ ចូរដេកយ៉ាងនេះ ចូរទំពារយ៉ាងនេះ ចូរស៊ីយ៉ាងនេះ អ្នកនេះបុត្រគួរហៅពុក អ្នកនេះគួរហៅបង អ្នកនេះគួរហៅប្អូន បុត្រគួរធ្វើវត្ថុនេះ មិនគួរធ្វើវត្ថុនេះ គួរចូលទៅរកអ្នកឈ្មោះឯណោះ អ្នកឈ្មោះឯណោះមិនគួរចូលទៅរក ។ ក្នុងវេលាតមក អាចារ្យដទៃទើបឲ្យសិក្សាសិល្បៈដំរី សិល្បៈសេះ សិល្បៈរថ

សិល្បៈផ្សេង និងការចំនួនជាដើម ។ អាចារ្យដទៃឲ្យសរណៈ អាចារ្យដទៃឲ្យតាំងនៅក្នុងសីល អាចារ្យដទៃឲ្យបព្វជ្ជា អាចារ្យដទៃឲ្យរៀនពុទ្ធវចនៈ អាចារ្យដទៃឲ្យឧបសម្បទា អាចារ្យដទៃឲ្យសម្រេចសោតាបត្តិមគ្គជាដើម ។ ដូច្នោះ អាចារ្យសូម្បីទាំងអស់នោះ ទើបឈ្មោះថា **ជាបច្ឆាចារ្យ** ចំណែកមាតាបិតាជាអាចារ្យមុនគ្រប់អាចារ្យ (បុព្វាចារ្យ) ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ហៅថាជាបុព្វាចារ្យ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វុច្ចរេ** បានដល់ ហៅ គឺ ពោល ។

បទថា **អាហុនេយ្យា ច បុត្តានំ** (ជាអាហុនេយ្យរបស់បុត្រទាំងឡាយ) សេចក្តីថា រមែងគួរបានទទួលបាយ ទឹកជាដើម ដែលបុត្រចាត់ចែងមកដើម្បីបូជា ដើម្បីទទួល គឺ ជាអ្នកសមគួរដើម្បីនឹងទទួលបាយ និងទឹកជាដើមនោះ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **ជាអាហុនេយ្យរបស់បុត្រទាំងឡាយ** ដូច្នេះ ។ បទថា **បជាយ អនុកម្បកា** (មានសេចក្តីអាណិតអាសូរដល់កូន) សេចក្តីថា មាតាបិតា រមែងថ្នាក់ថ្នមរក្សាបុត្ររបស់ខ្លួន សូម្បីដោយការសម្លាប់ជីវិតរបស់សត្វដទៃ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **មានសេចក្តីអាណិតអាសូរដល់កូន** ដូច្នេះ ។ បទថា **នមស្សេយ្យ** (គប្បីឱនគោរព) បានដល់ ធ្វើការនមស្ការ ។ បទថា **សក្ករេយ្យ** (សក្ការៈ) សេចក្តីថា គប្បីរាប់

អានដោយសក្ការៈ ។ ឥឡូវនេះ កាលទ្រង់នឹងសម្តែងសក្ការៈនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ដោយបាយ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អន្នេន** (ដោយបាយ) បានដល់ បបរ បាយ កត្ត និងរបស់គួរទំពារ ។ បទថា **បានេន** (ដោយ ទឹក) បានដល់ ទឹក ៨ យ៉ាង ។ បទថា **វត្ថេន** (ដោយសំពត់) បានដល់ សំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្តប់ ។ បទថា **សយនេន** (ដោយទីដេក) បានដល់ គ្រឿងទ្រទ្រង់ គឺ គ្រែ និងតាំង ។ បទថា **ឧច្ឆាទនេន** (ដោយគ្រឿងអប់) បានដល់ គ្រឿងលាបសម្រាប់កម្ចាត់ក្លិនស្អុយ ធ្វើឲ្យមានក្លិនក្រអូប ។ បទថា **ន្ហាបនេន** (ដោយការជម្រះកាយ) សេចក្តីថា ដោយការឲ្យងូតដោយទឹកក្តៅក្នុងវេលាត្រជាក់ ដោយងូតទឹកត្រជាក់ក្នុងវេលាក្តៅ ។ បទថា **បាទានំ ធោវនេ** (ដោយការលាងជើង) សេចក្តីថា ដោយការលាងជើងដោយទឹកក្តៅ និងទឹកត្រជាក់ និងដោយការលាបដោយប្រេង ។ បទថា **បេច្ច** (ខាងក្រោយពីស្លាប់ទៅ) គឺ ទៅកាន់បរលោក ។ បទថា **សគ្គេ បមោទតិ** (រមែងរីករាយក្នុងស្ថានសួគ៌) សេចក្តីថា ក្នុងលោកនេះ មនុស្សជាបណ្ឌិត ឃើញការប្រណិបត្តិក្នុងមាតាបិតា (របស់គេ) ហើយ ក៏សរសើរគេក្នុងលោកនេះឯង ព្រោះមានការប្រណិបត្តិជាហេតុ ។

ក៏បុគ្គលដែលទំនុកបម្រុងមាតាបិតានោះ ទៅកាន់បរលោកហើយ ស្ថិត

*នៅក្នុងសួគ៌ រមែងរីករាយដោយទិព្វសម្បត្តិ ដូច្នេះ ។*

ចប់អដ្ឋកថា ព្រហ្មកសូត្រទី ១

# អដ្ឋកថា អានន្ទសូត្រទី ២

## *"ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសូត្រទី ២ ដូចតទៅនេះ ៈ-*

[៣២] *បទថា* ***តថារូបោ*** *គឺ* ***តថាជាតិកោ*** *(ដូច្នោះ) ។ បទថា* ***សមាធិបដិលាភោ*** *(ការបានសមាធិ) បានដល់ ការបានឯកគ្គតានៃចិត្ត ។ ក្នុងបទថា* ***ឥមស្មឹ ច វិញ្ញាណកេ*** *(ដែលមានវិញ្ញាណនេះ) នេះ គប្បីជ្រាបអធិប្បាយថា ក្នុងរាងកាយទាំងពីរចំណែក គឺ ទាំងរបស់ខ្លួន និងរបស់អ្នកដទៃ ដែលព្រះអានន្ទពោលទុកថា* ***នេះ*** *ដោយរួម (រាងកាយទាំងពីរ) ចូលជាមួយគ្នា ព្រោះមានអត្ថយក ជាសវិញ្ញាណកៈ (មានវិញ្ញាណ) ដូចគ្នា ។ បទថា* ***អហំការមមំការមានានុសយា*** *(អហំការ មមំការ និងមានានុស័យ) បានដល់ កិលេសទាំងនេះ គឺ ទិដ្ឋិ គឺ អហង្ការ ១ តណ្ហា គឺ មមង្ការ ១ អនុស័យ គឺ មានះ ១ ។ បទថា* ***នាស្សុ*** *គឺ* ***ន ភវេយ្យុំ*** *(មិនគប្បីមាន) ។ បទថា* ***ពហិទ្ធា ច សព្វនិមិត្តេសុ*** *(ក្នុងសព្វនិមិត្តខាងក្រៅ) បានដល់ ក្នុងនិមិត្តទាំងអស់ ក្នុងចំណែកខាងក្រៅនេះ គឺ រូបនិមិត្ត ១ សទ្ទនិមិត្ត ១ គន្ធនិមិត្ត ១ រសនិមិត្ត ១ ផោដ្ឋព្វនិមិត្ត ១ សស្សតទិនិមិត្ត (និមិត្តជាទៀងជាដើម) ១ បុគ្គលនិមិត្ត ១ ធម្មនិមិត្ត ១ ។*

បទថា **ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ** (ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ) បាន ដល់ ផលសមាធិ និងផលញ្ញាណ ។ បទថា **សិយា** គឺ **ភវេយ្យ** (គប្បីមាន) ។ បទថា **ឥធានន្ទ ភិក្ខុនោ** (អានន្ទ ភិក្ខុក្នុងធម្មវិន័យនេះ) សេចក្តីថា ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ។

## លក្ខណៈរបស់និព្វាន

ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះនិព្វាន ទើបត្រាស់ថា **ឯតំ សន្តំ ឯតំ បណីតំ** (ធម្មជាតិនោះស្ងប់ ធម្មជាតិនោះប្រណីត) ដូច្នេះ ។ ក៏និព្វាន ឈ្មោះថា **សន្តៈ** (ស្ងប់) ព្រោះកិលេសទាំងឡាយស្ងប់ ។ និព្វាន ឈ្មោះថា **ស្ងប់** ព្រោះចិត្តុប្បាទរបស់អ្នកចូលសមាបត្តិ ដោយរលឹកថា ព្រះនិព្វាន ជាដែនស្ងប់ ហើយអង្គុយរហូតអស់ថ្ងៃ ប្រព្រឹត្តទៅថា ស្ងប់ពិតនោះឯង ដូច្នេះខ្លះ ។

បទថា **បណីតំ** (ប្រណីត) សេចក្តីថា និព្វាន ឈ្មោះថា **ប្រណីត** ព្រោះចិត្តុប្បាទរបស់បុគ្គលដែលអង្គុយចូលសមាបត្តិ ប្រព្រឹត្តទៅថា ប្រណីតពិតនោះឯង ។ សូម្បីបទថា **សព្វសង្ខារសមថោ** (ការស្ងប់រម្ងាប់សង្ខារទាំងពួង) ជាដើម ក៏ជាវេវចនៈរបស់និព្វាននោះដូចគ្នា ។

ក៏ចិត្តុប្បាទរបស់បុគ្គលដែលអង្គុយចូលសមាបត្តិទាំងថ្ងៃ ដោយព្រេក

ថា សេចក្តីស្ងប់នៃសង្ខារទាំងអស់ ដូច្នេះ រមែងប្រព្រឹត្តទៅថា ស្ងប់រម្ងាប់សង្ខារទាំងពួង ។ល។ មួយទៀត ព្រោះការមិនមាននៃតណ្ហា ពោលគឺ គ្រឿងរួបរឹតទុកក្នុងភព ៣ ដែលបាននាមថា និព្វាន ចិត្តុប្បាទរបស់បុគ្គលដែលអង្គុយចូលសមាបត្តិក្នុងនិព្វាននោះ រមែងប្រព្រឹត្តទៅថា និព្វាន ព្រោះហេតុនោះ និព្វាន ទើបបាននាមថា **សេចក្តីស្ងប់រម្ងាប់សង្ខារទាំងពួង** ជាដើម ។ ក៏ក្នុងការរឭក និងការសង្រួមការគិតទាំង ៨ យ៉ាងនេះ ក្នុងទីនេះ នឹងរឭក និងសង្រួមការគិតតែម្យ៉ាងក៏បាន ២ យ៉ាងក៏បាន ទាំងអស់ក៏បានដូចគ្នា ។

បទថា **សង្ខាយ** (ព្រោះដឹង) គឺ ដឹងដោយញាណ ។ បទថា **បរោ-បរានិ** កាត់បទជា **បរានិ ច ឱបរានិ ច** អធិប្បាយថា អត្តភាពរបស់បុគ្គលដទៃ និងអត្តភាពរបស់ខ្លួនជាដើម ឈ្មោះថា **បរៈ** (គឺអត្តភាពរបស់បុគ្គលដទៃ) និងឈ្មោះថា **បរៈ** (គឺអត្តភាពរបស់ខ្លួន) ។ បទថា **យស្ស** (បុគ្គលណា) គឺ របស់ព្រះអរហន្តណា ។ បទថា **ឥញ្ជិតំ** (កិលេសជាហេតុឲ្យញាប់ញ័រ) គឺ សេចក្តីញាប់ញ័រ បានដល់ សេចក្តីវក់វី គឺ សេចក្តីក្តៅក្រហាយ ៧ យ៉ាងទាំងនេះ ~សេចក្តីញាប់ញ័រ ៧ យ៉ាង គឺ សេចក្តីញាប់ញ័រព្រោះរាគៈ សេចក្តីញាប់ញ័រព្រោះទោសៈ សេចក្តីញាប់ញ័រព្រោះមោហៈ សេចក្តីញាប់ញ័រព្រោះមានៈ សេចក្តីញាប់ញ័រព្រោះទិដ្ឋិ សេចក្តីញាប់ញ័រព្រោះកិលេស និង

សេចក្តីញាប់ញ័រព្រោះទុច្ចរិត ។ បទថា **នត្ថិ កុហិញ្ចិ** (មិនមាន...ក្នុងលោកណាៗ គឺ សូម្បីក្នុងអារម្មណ៍ណានីមួយ ។

បទថា **សន្តោ** (ស្ងប់) បានដល់ (បុគ្គលនោះ) ឈ្មោះថា អ្នកស្ងប់ព្រោះកិលេសដែលជាសត្រូវស្ងប់ ។ បទថា **វិធូមោ** (ប្រាសចាកផ្សែងភ្លើង) បានដល់ វៀរផ្សែង គឺ ទុច្ចរិត មានកាយទុច្ចរិតជាដើម ។ បទថា **អនីឃោ** (មិនចង្អៀតចង្អល់) បានដល់ ប្រាសចាកគ្រឿងចង្អៀតចង្អល់ មានរាគៈជាដើម ។ បទថា **និរាសោ** (មិនមានសេចក្តីប្រាថ្នា) បានដល់ មិនមានតណ្ហា ។ បទថា **អតារិ** (បានឆ្លងផុត) បានដល់ គឺ ឆ្លងផុត បានដល់ កន្លងហើយ ។ បទថា **សោ** (បុគ្គលនោះ) បានដល់ ព្រះអរហន្តខីណាស្រពនោះ ។ ក្នុងបទថា **ជាតិជរំ** (ជាតិ និងជរា) នេះ សូម្បីព្យាធិ និងមរណៈ ក៏គប្បីជ្រាបថា ទ្រង់សំដៅយកដូចគ្នា ដោយសព្ទថា ជាតិ ជរាទុះឯង ។ អរហត្តផលសមាបត្តិទុះឯង ព្រះមានព្រះភាគត្រាស់ទុកហើយ ទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថា ដោយប្រការដូចពណ៌នាមកដូច្នេះឯង ។

ចប់អដ្ឋកថា អានន្ទសូត្រទី ២

# អដ្ឋកថា សារីបុត្តសូត្រទី ៣

## *"បុគ្គលកម្ចាត់តណ្ហាបាន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារីបុត្តសូត្រទី ៣ ដូចតទៅនេះ ៈ-*

*[៣៣] បទថា **សង្ខិត្តេន** (ដោយសង្ខេប) បានដល់ ដោយការតាំងជាបទមាតិកាទុក ។ បទថា **វិត្ថារេន** (ដោយពិស្តារ) បានដល់ ការចែកមាតិកាដែលតាំងទុកហើយចេញទៅ ។ បទថា **សង្ខិត្តវិត្ថារេន** (ទាំងដោយសង្ខេបនិងពិស្តារ) បានដល់ គ្រាខ្លះក៏សង្ខេប គ្រាខ្លះក៏ពិស្តារ ។ បទថា **អញ្ញាតារោ ច ទល្លភា** (តែបុគ្គលដឹងទូទៅដល់ (ធម៌) រកបានលំបាក) សេចក្ដីថា ក៏បុគ្គលដែលត្រាស់ដឹង រកបានលំបាក ។*

*ព្រះមានព្រះភាគត្រាស់ពាក្យនេះ ចំពោះព្រះសារីបុត្ត ដោយមានព្រះពុទ្ធបំណងថា តថាគតនឹងបន្តញាណឲ្យព្រះសារីបុត្រ ។ ព្រះថេរៈលុះបានស្ដាប់ព្រះពុទ្ធតម្រាស់នោះហើយ សូម្បីមិនក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនព្រះអង្គនឹងយល់ឯងក៏ពិត តែដោយមានបំណងថា បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះអង្គទ្រង់ដាក់ព្រះទ័យសម្ដែង (ធម៌) ខ្ញុំព្រះអង្គនឹងយល់ធម៌ ដែលព្រះអង្គទ្រង់សម្ដែងហើយបានដោយរយន័យ ពាន់ន័យ ប្រការនោះសូមឲ្យជាការៈរបស់ខ្ញុំព្រះអង្គចុះ ដូច្នេះ កាលនឹងញ៉ាំងព្រះសាស្ដាឲ្យឧស្សាហ៍ ក្នុងការ*

សម្តែងធម៌ ទើបបានទូលពាក្យមានជាអាទិ៍ថា បពិត្រព្រះមានព្រះភាគ នេះជាវេលាដែលព្រះអង្គទ្រង់សម្តែងធម៌ហើយ ។ លំដាប់នោះ ព្រះសាស្តាទើបទ្រង់ផ្តើមទេសនាដល់ព្រះសារីបុត្រថា **តស្មាតិហ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឥមស្មិញ្ច សវិញ្ញាណកេ** (ក្នុងកាយ ដែលមានវិញ្ញាណនេះ) ជាដើម មានន័យដូចពោលហើយនុ៎ះឯង ។

បទថា **អច្ឆេជ្ជិ តណ្ហំ** (កាត់តណ្ហាហើយ) បានដល់ កាត់តណ្ហាដោយសស្ត្រា គឺ មគ្គញាណ ។ បទថា **វិវត្តយិ សំយោជនំ** (គាស់រំលើងនូវសំយោជនៈ) បានដល់ ដកសំយោជនៈទាំង ១០ យ៉ាង ព្រមទាំងឫសចោលទៅ ។ បទថា **សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្ស** (ធ្វើទីបំផុតទុក្ខបានដោយការត្រាស់ដឹង ព្រោះលះមានះបានដោយល្អហើយ) សេចក្តីថា បានធ្វើទីបំផុតនៃវដ្តទុក្ខ ដោយការត្រាស់ដឹង ព្រោះលះមានះ ៩ យ៉ាង បានដោយឧបាយត្រូវទំនង ដោយវត្តបដិបត្តិប្រពៃ ។ បទថា **ឥទញ្ច បន មេតំ សារីបុត្ត សន្ធាយ ភាសិតំ** (សារីបុត្ត ក៏តថាគតសំដៅយកប្រការនេះ ទើបបានពោល) សេចក្តីថា ម្នាលសារីបុត្រ តថាគតពោលពាក្យនោះ សំដៅយកផលសមាបត្តិនេះឯង ក្នុងឧទយប្បញ្ហា ក្នុងបារាយនវគ្គ ។

ឥឡូវនេះ កាលទ្រង់សម្តែងព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគត្រាស់

ទុកហើយ ទើបប្រារព្ធពាក្យមានជាអាទិ៍ថា **បហានំ កាមសញ្ញានំ** (ការលះកាមសញ្ញា) ដូច្នេះ ៗ ក៏បទថា **បហានំ កាមច្ឆន្ទានំ** (ការលះកាមច្ឆន្ទៈ) នេះ មានមកហើយក្នុងឧទយបញ្ហា ៗ តែក្នុងព្រះសូត្រនេះ លោកអាចារ្យអ្នករចនាអង្គុត្តរនិកាយ លើកឡើងតាំងទុកថា **កាមសញ្ញានំ** ដូច្នេះ ៗ ក្នុងពីរបទនោះ ផ្សេងគ្នាតែព្យញ្ជនៈ ចំណែកអត្ថក៏ដូចគ្នាទាំងឯង ៗ បទថា **កាមសញ្ញានំ** (កាមសញ្ញា) បានដល់ សញ្ញាដែលកើតឡើងប្រារព្ធកាម ឬបានដល់ សញ្ញាដែលកើតជាមួយចិត្តសហគតដោយលោភៈ ៨ ដួង ៗ បទថា **ទោមនស្សាន ចូភយំ** (និងទោមនស្សទាំង ២) សេចក្តីថា តថាគតពោលការលះអកុសលចេតសិកសូម្បីទាំងពីរ គឺ កាមសញ្ញាទាំងនេះ ១ ទោមនស្សចេតសិក ១ គឺ អរហត្តផល ពោលគឺ ការលះដោយបដិបស្សទ្ធិ (វិមុត្តិ) ថាជាអញ្ញាវិមោក្ខ ៗ

ចំណែកក្នុងនិទ្ទេស ព្រះអង្គត្រាស់ទុកថា (តថាគតពោល) ការលះបាន សេចក្តីស្ងប់ ការលះបង់ សេចក្តីស្ងប់រម្ងាប់ អកុសលចេតសិកទាំងពីរយ៉ាង គឺ កាមច្ឆន្ទៈ និងទោមនស្ស ថាជា **អមតមហានិព្វាន** ៗ ពាក្យនោះព្រះអង្គត្រាស់ទុកដោយអំណាចសរុបសេចក្តី ព្រោះថា សេចក្តីស្ងប់រម្ងាប់ពោលគឺ **អាការដែលកិលេសអស់ទៅ** ហៅថា បហានៈខ្វះ **មគ្គ** ដែលលះបង់

កិលេសហើយ ក៏ហៅថា បហានៈខ្ទះ ផល ពោលគឺ សេចក្តីស្ងប់កិលេស បាន ក៏ហៅថា បហានៈខ្ទះ ។ កិលេសទាំងឡាយដែលព្រះយោគាវចរលះបាន ព្រោះមកដល់ព្រះនិព្វានណា ព្រះនិព្វាននោះ ឈ្មោះថា អមតនិព្វាន ។ ព្រោះ ដូច្នោះ បទទាំងនេះ ទើបមកហើយក្នុងនិទ្ទេសនោះ ។

ក៏ព្រោះព្រះពុទ្ធវចនៈថា **តថាគតពោល...ថាជាអញ្ញាវិមោក្ខ** ទើបទ្រង់ បំណាងយកចំពោះព្រះអរហត្តផល និងព្រោះព្រះពុទ្ធវចនៈថា **ការបន្ទោបង់ ថីនៈ** គឺ ព្រះអង្គទ្រង់បំណាងយកចំពោះព្រះអរហត្តផល ព្រោះថីនៈ (នីវរណៈ) កើតឡើងក្នុងទីបំផុតនៃការបន្ទោបង់ ព្រោះព្រះពុទ្ធវចនៈថា **ការរារាំងកុក្កុច្ចៈ** គឺ ទ្រង់បំណាងយកផលប៉ុណ្ណោះ ព្រោះផលកើតឡើងក្នុងលំដាប់នៃមគ្គ ដែល ជាហេតុហាមកុក្កុច្ចៈនីវរណៈ ។ បទថា **ឧបេក្ខាសតិសំសុទ្ធំ** (សេចក្តីបរិសុទ្ធ ល្អដោយឧបេក្ខា និងសតិ) សេចក្តីថា បរិសុទ្ធល្អដោយឧបេក្ខា និងសតិ ដែល កើតឡើងក្នុងផលដែលប្រព្រឹត្តទៅក្នុងញាណទី ៤ ។ សម្មាសង្កប្បៈ លោក ហៅថា សេចក្តីត្រិះរិះក្នុងធម៌ ក្នុងបទថា **មានសេចក្តីត្រិះរិះក្នុងធម៌នាំមុខ** ។

សម្មាសង្កប្បៈនោះ ឈ្មោះថា **មានសេចក្តីត្រិះរិះក្នុងធម៌នាំមុខ** ព្រោះ មានមកអំពីដើម គឺ មានមកអំពីមុន បានដល់ ដល់មុន នៃអញ្ញាវិមោក្ខ ។ តថាគតពោល... មានសេចក្តីត្រិះរិះក្នុងធម៌នាំមុខនោះថា ជាអញ្ញាវិមោក្ខ ។

វិមោក្ខដែលកើតឡើងក្នុងទីបំផុតនៃអញ្ញិន្ទ្រិយ ឈ្មោះថា **អញ្ញាវិមោក្ខ** ឬវិមោក្ខដែលកើតឡើងដល់ព្រះអរហត្តផល ឈ្មោះថា **អញ្ញាវិមោក្ខ** អធិប្បាយថា បានដល់ **អញ្ញាវិមុត្តិ** ។ បទថា **អវិជ្ជាយ បភេទនំ** (ជាគ្រឿងទម្លាយអវិជ្ជា) សេចក្តីថា ជាគ្រឿងទម្លាយអវិជ្ជា ព្រោះកើតឡើងក្នុងទីបំផុតនៃការទម្លាយអវិជ្ជា ។ មួយវិញទៀត អរហត្តផលនុ៎ះឯង ដែលបាននាមយ៉ាងនេះ ព្រោះប្រារព្ធព្រះនិព្វានដែលស្ងប់ ហើយកើតឡើង ។ ព្រះអរហត្តផលនុ៎ះឯង គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ប្រកាសហើយដោយបទទាំងឡាយនេះ សូម្បីទាំងអស់ មានបទថា **កាលៈ** ជាដើម ដោយប្រការដូចពណ៌នាមកដូច្នេះ ។

ចប់អដ្ឋកថា សារីបុត្តសូត្រទី ៣

# អដ្ឋកថា និទានសូត្រទី ៤

## *"ហេតុកើតឡើងនៃកម្ម"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និទានសូត្រទី ៤ ដូចតទៅនេះ ៖-*

[៣៤] *បទថា* ***និទានានិ*** *គឺ* ***ការណានិ*** *(ហេតុទាំងឡាយ) ។ បទថា* ***កម្មានំ*** *(កម្ម) បានដល់ កម្មដែលឲ្យសត្វដល់វដ្ដៈ ។ បទថា* ***លោភោ និទានំ កម្មានំ សមុទយាយ*** *(លោភៈជាហេតុកើតឡើងនៃកម្មទាំងឡាយ) សេចក្ដីថា សេចក្ដីលោភ ដែលមានសេចក្ដីចង់បាន និងសេចក្ដីល្មោភជាសភាវៈ ជាឫស គល់ គឺ ជាហេតុ អធិប្បាយថា ជាបច្ច័យ ដើម្បីការកើតឡើងនៃកម្ម ដែលធ្វើឲ្យដល់វដ្ដៈ គឺ ធ្វើការប្រមូលមកនូវកម្មដែលនឹងឲ្យដល់វដ្ដៈ ។ ទោសៈដែលមានការកាច និងសេចក្ដីប្រទូសរ៉ាយជាសភាវៈ ឈ្មោះថា* ***ទោសៈ*** *។ មោហៈដែលមានសេចក្ដីវង្វេង និងសេចក្ដីល្ងង់ជាសភាវៈ ឈ្មោះថា* ***មោហៈ*** *។*

*បទថា* ***លោភបកតំ*** *(ដែលបុគ្គលធ្វើចំពោះលោភៈ) សេចក្ដីថា កម្មដែលបុគ្គលធ្វើហើយព្រោះលោភចិត្ត អធិប្បាយថា បានដល់ កម្មដែលបុគ្គលត្រូវសេចក្ដីលោភគ្របសង្កត់ កើតការលោភហើយធ្វើ ។ កម្ម ឈ្មោះថា* ***លោភជំ*** *ព្រោះកើតពីសេចក្ដីលោភ ។ កម្ម ឈ្មោះថា* ***លោភនិទានំ*** *ព្រោះមានសេចក្ដីលោភជាដើមហេតុ ។ កម្ម ឈ្មោះថា* ***លោភសមុទយំ*** *ព្រោះមាន*

សេចក្តីលោភជាដែនកើត ។ បច្ច័យ ឈ្មោះថា សមុទ័យ អធិប្បាយថា មានលោភៈជាបច្ច័យ ។ បទថា **យត្ថស្ស អត្តភាវោ និព្វត្តតិ** (ក្នុងភព ក្នុងជាតិដែលអត្តភាពរបស់គេទៅកើត) សេចក្តីថា ក្នុងទីណា អត្តភាពរបស់បុគ្គលនោះ ដែលមានកម្មកើតពីសេចក្តីលោភបង្កើតហើយ គឺ ខន្ធទាំងឡាយរមែងប្រាកដ ។

បទថា **តត្ថ តំ កម្មំ វិបច្ចតិ** (កម្មនោះរមែងឲ្យផល...នោះ) សេចក្តីថា កម្មនោះ រមែងបង្កើតផលក្នុងខន្ធទាំងឡាយនោះ ។ បទថា **ទិដ្ឋេ វា ធម្មេ** (ក្នុងបច្ចុប្បន្នជាតិនេះខ្វះ) ជាដើម ព្រះមានព្រះភាគត្រាស់ទុក ដើម្បីទ្រង់សម្តែងដល់ប្រភេទនៃកម្មនោះ ព្រោះកម្មនោះជាទិដ្ឋធម្មវេទនីយកម្ម (ឲ្យផលក្នុងជាតិនេះ) ក៏មាន ជាឧបបជ្ជវេទនីយកម្ម (ឲ្យផលក្នុងជាតិមុខ) ក៏មាន ជាអបរាបរិយាយវេទនីយកម្ម (ឲ្យផលក្នុងភពតៗ ទៅ) ក៏មាន ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **អខណ្ឌានិ** (មិនបែក) ប្រែថា មិនបែកបាក់វិនាស ។ បទថា **អបូតីនិ** (មិនស្អុយ) សេចក្តីថា មិនដល់ភាពជាពូជដែលខូច ព្រោះជាពូជដែលមិនស្អុយ ។ បទថា **អវាតាតបហតានិ** (មិនត្រូវខ្យល់កំដៅថ្ងៃ) សេចក្តីថា ទាំងមិនខូចដោយខ្យល់ និងកំដៅថ្ងៃ ។ បទថា **សារាទានិ** (ប្រកបដោយខ្លឹម)

សេចក្តីថា រាប់ថាជាពូជល្អ គឺ មានគុណតម្លៃ ប្រកបដោយខ្លឹម ។ បទថា **សុខសយិតានិ** (រក្សាទុកយ៉ាងល្អ) ដោយប្រមូលទុកដាក់ល្អ ។

បទថា **សុក្ខេត្តេ** (ក្នុងស្រែល្អ) បានដល់ ក្នុងស្រែដែលភ្ជួររាស់ល្អ ។ បទថា **សុបរិកម្មកតាយ ភូមិយា** (ក្នុងដីដែលត្រៀមទុកល្អហើយ) បានដល់ ដីស្រែដែលចាត់ចែងទុកដោយល្អ ដោយការភ្ជួរដោយនង្គ័ល និងរាស់ ។ បទថា **និក្ខិត្តានិ** (សាបព្រោះ) បានដល់ ដាំទុកហើយ ។ បទថា **អនុប្បវេច្ឆេយ្យ** (ស្រោច) បានដល់ ធ្លាក់រឿយៗ ។ ក្នុងបទថា **វុឌ្ឍឹ** (ចម្រើន) ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា ចម្រើន ព្រោះលូតលាស់ឡើង ។ ឈ្មោះថា ដុះល្អ ព្រោះមានឫសរឹងមាំដុះចាក់ទៅខាងក្រោម ។ ឈ្មោះថា **សម្បូរ** ព្រោះផ្សាយចេញទៅដោយជុំវិញ ។

ក៏ក្នុងសូត្រនេះ ពាក្យណាដែលព្រះមានព្រះភាគត្រាស់ទុក មានជាអាទិ៍ថា **ទិដ្ឋេ វា ធម្មេ** ដើម្បីមិនឲ្យច្រឡំក្នុងពាក្យនោះ ក្នុងទីនេះ គួរពោលចែកនូវកម្មតទៅ ។ អធិប្បាយថា ដោយបរិយាយនៃព្រះសូត្រ ព្រះមាន-ព្រះភាគទ្រង់ចែកកម្មទុក ១១ យ៉ាង ។ គឺ **ទិដ្ឋធម្មវេទនីយកម្ម ១ ឧបបជ្ជវេទនីយកម្ម ១ អបរបរិយាយវេទនីយកម្ម ១ គរុកម្ម ១ ពហុលកកម្ម ១ យទាសន្នកម្ម ១ កដត្តាកម្ម ១ ជនកកម្ម ១ ឧបត្ថម្ភកកម្ម ១ ឧបបីឡកកម្ម ១**

ឧបឃាតកម្ម ១ ។

## អធិប្បាយ ទិដ្ឋធម្មវេទនីយកម្ម

បណ្តាកម្ម ១១ យ៉ាងនោះ ក្នុងបណ្តា (ជវនៈ) ចិត្ត ៧ ដួង ជវនចេតនាដួងដំបូង ដែលជាកុសល ឬអកុសល ក្នុងជវនវិធីដំបូង ឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ។

ទិដ្ឋធម្មវេទនីយកម្មនោះ ឲ្យវិបាកក្នុងអត្តភាពនេះប៉ុណ្ណោះ ដែលជាកុសល (ឲ្យវិបាកក្នុងអត្តភាពនេះ) ដូចកម្មរបស់កាកវលិយសេដ្ឋី និងបុណ្ណកសេដ្ឋីជាដើម , ចំណែកអកុសល (ឲ្យផលក្នុងអត្តភាពនេះ) ដូចកម្មរបស់ នន្ទយក្ខ នន្ទមាណព នន្ទគោឃាត ភិក្ខុកោកាលិកៈ ព្រះបាទសុប្បពុទ្ធ ព្រះទេវទត្ត និងនាងចិញ្ចាមាណវិកាជាដើម ។ តែកាលមិនអាចឲ្យផល នឹងជាអហោសិកម្មទៅ គឺ ដល់ភាពជាកម្មដែលមិនមានផល កម្មនោះ គប្បីសាធកៈដោយប្រការប្រៀបធៀបនឹងព្រានម្រឹគ ។

## ឧបមាដូចព្រានម្រឹគ

ប្រៀបដូចកូនសរដែលព្រានម្រឹគ ឃើញម្រឹគហើយ ទាញធ្នូបាញ់ទៅ បើមិនខុស ក៏នឹងធ្វើឲ្យម្រឹគនោះដួលចុះក្នុងទីនោះឯង លំដាប់នោះ ព្រានម្រឹគក៏បកស្បែកម្រឹគនោះចេញ កាត់ឲ្យជាចំណែកតូចៗ កាន់យកសាច់ម្រឹគនោះ

ទៅចិញ្ចឹមកូនប្រពន្ធ ប្រសិនបើបាញ់ខុស ម្រឹគគេចផុត មិនបែរត្រឡប់មក កាន់ទិសនោះទៀត យ៉ាងណា ការឧបមេយ្យនេះ ក៏គប្បីជ្រាបដូច្នោះ ។ អធិប្បាយថា ការត្រឡប់បានវារៈនៃវិបាករបស់ទិដ្ឋធម្មវេទនីយកម្ម ដូចគ្នានឹងកូនសរដែលបាញ់ត្រូវម្រឹគមិនខុស ការក្លាយជាកម្មដែលមិនមានផល ដូចកូនសរដែលបាញ់ម្រឹគខុសដូច្នោះ ដូច្នេះឯង ។

## អធិប្បាយ ឧបបជ្ជវេទនីយកម្ម

ចំណែកជវនចេតនាដួងទី ៧ ដែលញ៉ាំងប្រយោជន៍ឲ្យសម្រេច ឈ្មោះថា **ឧបបជ្ជវេទនីយកម្ម** ។ ឧបបជ្ជវេទនីយកម្មនោះ ឲ្យផលក្នុងអត្តភាពតទៅ (បន្ទាប់ពីស្លាប់) តែក្នុងបណ្តាកុសលាកុសលទាំងពីរចំណែកនេះ ឧបបជ្ជវេទនីយកម្មក្នុងចំណែកជាកុសល គប្បីជ្រាបដោយអំណាចនៃសមាបត្តិ ៨ ចំណែកអកុសល គប្បីជ្រាបដោយអំណាចនៃអនន្តរិយកម្ម ៥ ។ បណ្តាកម្មទាំងពីរចំណែកនោះ បុគ្គលដែលបានសមាបត្តិ ៨ នឹងកើតក្នុងព្រហ្មលោក ដោយសមាបត្តិណាមួយ ។ ចំណែកបុគ្គលធ្វើអនន្តរិយកម្ម ៥ នឹងកើតក្នុងនរកដោយកម្មណាមួយ ។ សមាបត្តិដ៏សេស និងកម្ម (ដ៏សេស) នឹងជាអហោសិកម្មទាំងអស់ គឺ ជាកម្មដែលមិនមានវិបាក ។ សេចក្តីនេះ គប្បីជ្រាបតាមការប្រៀបធៀបដូចប្រការដំបូងចុះ ។

## អធិប្បាយ អបរបរិយាយវេទនីយកម្ម

ក៏ជវនចេតនា ៥ ដួង ដែលកើតឡើងក្នុងចន្លោះនៃជវនៈ ២ ដួង (ជវនចេតនាដួងទី ១ និងជវនចេតនាដួងទី ៧) ឈ្មោះថា **អបរបរិយាយវេទនីយកម្ម** ។ អបរបរិយាយវេទនីយកម្មនោះ បានឱកាសកាលណាក្នុងអនាគតកាល កាលនោះ នឹងឲ្យផល កាលការប្រព្រឹត្តទៅនៃសង្សារវដ្ដៈនៅមាន កម្មនោះនឹងឈ្មោះថា ជាអហោសិកម្ម រមែងមិនមាន ។ កម្មទាំងអស់នោះ គួរសម្ដែងដោយ (រឿង) ព្រានសុនខ ។ ប្រៀបដូច សុនខដែលនាយព្រានម្រឹគព្រលែងទៅ ព្រោះឃើញម្រឹគ ទើបរត់ដេញតាមម្រឹគទៅ ពេលទាន់ក្នុងទីណា ក៏ខាំយកក្នុងទីនោះឯង យ៉ាងណា កម្មនេះក៏ដូច្នោះ បានឱកាសក្នុងពេលណា ក៏នឹងឲ្យផលក្នុងទីនោះភ្លាម ។ ដែលឈ្មោះថា សត្វ រួចផុតពីកម្មនោះមិនមាន ។

## អធិប្បាយគរុកម្ម

ចំណែកក្នុងបណ្ដាកម្មធ្ងន់ និងកម្មស្រាល ទាំងដែលជាកុសល និងអកុសល កម្មណាធ្ងន់ កម្មនោះឈ្មោះថា **គរុកម្ម** ។ គរុកម្មនេះ ក្នុងចំណែកកុសល គប្បីជ្រាបថា បានដល់ មហគ្គតកម្ម , ក្នុងចំណែកអកុសល គប្បីជ្រាបថា បានដល់ អនន្តរិយកម្ម ៥ ។ កាលគរុកម្មនោះមានហើយ កុសលកម្ម

ឬអកុសលកម្មដ៏សេស មិនអាចឲ្យផលបាន ។ គរុកម្មសូម្បីទាំងពីរយ៉ាងនោះឯង នឹងឲ្យបដិសន្ធិ ។ ឧបមាដូចជាដុំគ្រួស ឬដុំដែក សូម្បីប្រមាណប៉ុនគ្រាប់ស្ពៃ ដែលបោះចុះក្នុងទឹក មិនអាចនឹងអណ្តែតឡើងលើទឹកបាន នឹងលិចចុះតែម្យ៉ាង យ៉ាងណា ក្នុងកុសលកម្មក្តី អកុសលកម្មក្តី ក៏ដូច្នោះ កម្មចំណែកណាធ្ងន់ គេនឹងកាន់យកកម្មចំណែកនោះឯងទៅ ។

## អធិប្បាយ ពហុលកកម្ម

ចំណែកក្នុងកុសលកម្ម និងអកុសលកម្មទាំងឡាយ កម្មណាច្រើន កម្មនោះឈ្មោះថា **ពហុលកកម្ម** ។ ពហុលកកម្មនោះ គប្បីជ្រាបដោយអំណាចអាសេវនៈដែលបានហើយ រហូតអស់កាលយូរ ។ ម្យ៉ាងទៀត ក្នុងចំណែកកុសលកម្ម កម្មណាដែលមានកម្លាំងក៏សាងសោមនស្សឲ្យ ក្នុងចំណែកអកុសលកម្ម សាងសេចក្តីក្តៅក្រហាយឲ្យ កម្មនោះឈ្មោះថា **ពហុលកកម្ម** ។ ឧបមាដូចជា កាលអ្នកបោកចំបាប់ ២ នាក់ ឡើងវេទិកា អ្នកណាមានកំលាំងច្រើន អ្នកនោះនឹងធ្វើឲ្យម្នាក់ទៀត (បរាជ័យ) យ៉ាងណា ពហុលកកម្មនោះក៏ដូច្នោះដូចគ្នា នឹងរាំងកម្មក្រៅអំពីនេះដែលមានកម្លាំងតិច (ឈ្នះ) ទៅ ។ កម្មណាច្រើនដោយការសេពរហូតជាប់ ឬមានកម្លាំងដោយអំណាចធ្វើឲ្យក្តៅក្រហាយ កម្មនោះនឹងឥតផល ដូចកម្មរបស់ព្រះបាទទុដ្ឋគាមណីអភ័យ ដូច្នោះ ។

## រឿងព្រះបាទទុដ្ឋគាមណីអភ័យ

បានឮមកថា ព្រះបាទទុដ្ឋគាមណីអភ័យនោះ ច្បាំងចាញ់ក្នុងចុល្ល-ង្គណិយយុទ្ធ ទ្រង់ជិះសេះគេចចេញទៅ ។ មហាតឹកឈ្មោះថា តិស្សអាមាត្យរបស់ព្រះអង្គ តាមស្តេចទៅតែម្នាក់ឯងប៉ុណ្ណោះ ។ ស្តេចចូលកាន់ព្រៃមួយក៏ប្រថាប់អង្គុយ កាលត្រូវសេចក្តីស្រេកឃ្លានបៀតបៀន ទើបទទួលត្រាស់បង្គាប់ថា ម្នាលតិស្សៈ យើងទាំងពីរនាក់ស្រេកឃ្លានខ្លាំងណាស់ នឹងធ្វើយ៉ាងណា ។ មានអាហារដែរព្រះអង្គ ខ្ញុំព្រះអង្គបាននាំព្រះក្រយាហារដាក់ក្នុងថាសមាស ១ វេចទុកក្នុងសំពត់សាដកឯណោះ ។ បើយ៉ាងនោះ ចូរនាំមក ។ គេទើបនាំព្រះក្រយាហារចេញមក ដាក់ត្រង់ព្រះភ័ក្ត្រព្រះរាជា ។ ស្តេចទ្រង់ឃើញហើយ ត្រាស់បង្គាប់ថា ចូរបែងចេញជា ៤ ចំណែកចុះសំឡាញ់ ។ គេទូលសួរថា ពួកយើងមាន ៣ នាក់ ហេតុដូចម្តេច ព្រះអង្គទើបឲ្យបែងជា ៤ ចំណែក ។ តិស្សៈ វេលាដែលយើងនឹករលឹកដល់ខ្លួន យើងមិនធ្លាប់បរិភោគអាហារដែលនៅមិនទាន់បានប្រគេនដល់ភិក្ខុជាមុនឡើយ សូម្បីថ្ងៃនេះ យើងក៏មិនព្រមបរិភោគ ដោយមិនទាន់បានប្រគេនអាហារដល់ភិក្ខុ ។ គេទើបបែងចែកអាហារចេញជា ៤ ចំណែក ។ ព្រះរាជាទ្រង់ត្រាស់ថា អ្នកចូរប្រកាសវេលា ។ ក្នុងព្រៃ យើងនឹងបានព្រះភិក្ខុអំពីណា ព្រះអង្គ ។ ប្រការនេះមិន

មែនជានាទីរបស់អ្នកទេ បើសទ្វារបស់យើងនៅមាន យើងនឹងបានព្រះភិក្ខុឯង អ្នកចូរដាក់ចិត្ត ហើយប្រកាសវេលាចុះ ។ គេទើបប្រកាសដល់ ៣ ដងថា ដល់វេលាអាហារហើយ ករុណាលោកម្ចាស់ ដល់វេលាអាហារហើយ ករុណាលោកម្ចាស់ ។

លំដាប់នោះ ព្រះពោធិយមាលកមហាតិស្សត្ថេរៈ បានឮសំឡេងនោះដោយទិព្វសោតធាតុ រំពឹងថា សំឡេងនេះនៅទីណា ។ ទើបដឹងថា ថ្ងៃនេះព្រះបាទទុដ្ឋគាមណីអភ័យចាញ់សង្គ្រាម ស្តេចចូលកាន់ដងព្រៃ ប្រថាប់អង្គុយ ហើយឲ្យបែងចែកបាយមួយចំណែកចេញជា ៤ ចំណែក ទ្រង់រំពឹងថា យើងនឹងបរិភោគត្រឹមតែមួយចំណែក ទើបប្រកាសវេលា (ភត្ត) លោកគិតថា ថ្ងៃនេះ យើងគួរធ្វើការសង្គ្រោះព្រះរាជា ហើយមកដោយមនោគតិ បានឈរត្រង់ព្រះភក្ត្រព្រះរាជា ។ ព្រះរាជាទតព្រះនេត្រឃើញហើយ ទ្រង់មានព្រះទ័យជ្រះថ្លា ត្រាស់ថា ឃើញទេតិស្សៈ ដូច្នេះ ថ្វាយបង្គំព្រះថេរៈហើយ ត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឲ្យបាត្រ ។ ព្រះថេរៈនាំបាត្រចេញហើយ ព្រះរាជាទ្រង់ផ្ទេរអាហារចំណែករបស់ព្រះថេរៈ ព្រមទាំងចំណែករបស់ព្រះអង្គចុះក្នុងបាត្រ ហើយត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ដែលឈ្មោះថា សេចក្តីលំបាកដោយអាហារ ចូរកុំមានក្នុងកាលណាៗ ទ្រង់ថ្វាយបង្គំ

ហើយប្រថាប់ឈរ ។ ចំណែកតិស្សអាមាត្យ គិតថា កាលព្រះរាជារបស់យើង ទតព្រះនេត្រហើយ យើងមិនអាចបរិភោគបាន ទើបបានផ្ទេរចំណែករបស់ខ្លួន ដាក់ទៅក្នុងបាត្រព្រះថេរៈដូចគ្នា ។ សូម្បីសេះក៏គិតថា សូម្បីយើងក៏គួរថ្វាយ ចំណែករបស់យើងដល់ព្រះថេរៈ ។ ព្រះរាជទតព្រះនេត្រមើលសេះ ទ្រង់ ជ្រាបថា សូម្បីសេះនេះ ក៏មានបំណងនឹងដាក់ចំណែករបស់ខ្លួនក្នុងបាត្ររបស់ ព្រះថេរៈដូចគ្នា ទើបបានដាក់ចំណែកនោះទៅក្នុងបាត្រនោះដូចគ្នា ថ្វាយបង្គំ ហើយ បញ្ជូនព្រះថេរៈទៅ ព្រះថេរៈកាន់យកភត្តនោះទៅ ហើយបានថ្វាយ ចំពោះភិក្ខុសង្ឃតាំងពីដើម ដោយបែងជាដុំៗ ។

លំដាប់នោះ ព្រះរាជាទ្រង់បានត្រិះរិះថា ពួកយើងស្រេកឃ្លានខ្លាំង យ៉ាងនេះ ជាការល្អណាស់ ប្រសិនបើព្រះថេរៈនឹងបញ្ជូនអាហារដែលសេស សល់មកឲ្យ ។ ព្រះថេរៈជ្រាបព្រះរាជតម្រិះរបស់ព្រះរាជាហើយ ទើបធ្វើភត្ត ដែលនៅសល់ឲ្យល្មមដល់អ្នកទាំងនោះនឹងបរិភោគរស់បាន ទើបបោះបាត្រទៅ ក្នុងអាកាស ។ បាត្រក៏មកធ្លាក់នៅលើព្រះហស្តរបស់ព្រះរាជា ។ សូម្បី អាហារក៏ល្មមដល់អ្នកទាំង ៣ នឹងបរិភោគរស់នៅបាន ។ លំដាប់នោះ ព្រះ រាជាទ្រង់លាងបាត្រហើយ ទ្រង់ត្រិះរិះថា យើងនឹងមិនបញ្ជូនបាត្រទទេទៅទេ ទើបទ្រង់ដោះព្រះភូសាសាច់ល្អ ជូតទឹក ហើយដាក់សំពត់ទុកក្នុងបាត្រ ទ្រង់អធិដ្ឋាន

ថា សូមបាត្រចូរប្រតិស្ឋាននៅក្នុងដៃរបស់លោកម្ចាស់របស់យើង ហើយទ្រង់បោះបាត្រទៅក្នុងអាកាស ។ បាត្រក៏ទៅប្រតិស្ឋាននៅក្នុងដៃរបស់ព្រះថេរៈ ។

ក្នុងវេលាតមក កាលព្រះរាជាទ្រង់ឲ្យសាងមហាចេតិយកម្ពស់ ១២០ ហត្ថ បញ្ចុះព្រះបរមសារីរិកធាតុចំណែកទី ៨ នៃព្រះតថាគតទុក កាលព្រះចេតិយមិនទាន់សម្រេច ក៏បានវេលាជិតសុគត ។ លំដាប់នោះ កាលព្រះភិក្ខុសង្ឃស្វាធ្យាយដោយនិកាយទាំង ៥ ថ្វាយព្រះអង្គដែលផ្ទំនៅផ្នែកទិសខាងត្បូងនៃមហាចេតិយ រថ ៦ គ្រឿង មកពីទេវលោក ៦ ជាន់ ឈប់នៅរៀងគ្នាក្នុងអាកាស ត្រង់ព្រះភ័ក្ត្ររបស់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរនាំសៀវភៅបញ្ជីកត់ត្រាការធ្វើបុណ្យមក ហើយត្រាស់ឲ្យអានបញ្ជីនោះតាំងពីដើម ។ មិនមានកម្មអ្វីដែលនឹងឲ្យព្រះអង្គពេញព្រះទ័យ ទើបត្រាស់ថា ចូរអានតទៅទៀត ។ អ្នកអាន អានតទៅថា បពិត្រសម្មតិទេព កាលព្រះអង្គចាញ់សង្គ្រាមក្នុងចុល្លង្គណិយយុទ្ធ ស្តេចចូលព្រៃ ប្រថាប់អង្គុយថ្វាយភិក្ខាដល់ព្រះពោធិយមាលកមហាតិស្សត្ថេរៈ ដោយទ្រង់បែងចែកព្រះក្រយាហារតែមួយចេញជា ៤ ចំណែក ។ ព្រះរាជាត្រាស់បង្គាប់ឲ្យឈប់អានហើយសាកសួរភិក្ខុសង្ឃថា លោកម្ចាស់ ទេវលោកជាន់ណាជារមណីយដ្ឋាន ។ ភិក្ខុសង្ឃថ្វាយព្រះពរថា សូមថ្វាយព្រះពរមហាបពិត្រ តុសិតពិភពជាទីប្រថាប់

របស់ព្រះពោធិសត្វគ្រប់ព្រះអង្គ ។ ព្រះរាជាសុគតហើយ ប្រថាប់អង្គុយលើ រាជរថដែលមកពីតុសិតពិភពនុ៎ះឯង ស្តេចបានដល់តុសិតពិភពហើយ ។ នេះ ជារឿងក្នុងការឲ្យវិបាករបស់កម្មដែលមានកម្លាំង ។

## អធិប្បាយ យទាសន្នកម្ម

ក្នុងបណ្តាកុសលកម្ម និងអកុសលកម្មទាំងឡាយ កម្មណាអាចនឹង ឲ្យនឹករលឹកដល់បានក្នុងវេលាជិតស្លាប់ កម្មនោះឈ្មោះថា **យទាសន្នកម្ម** ។ យទាសន្នកម្មនោះឯង កាលកុសលកម្ម និងអកុសលកម្មដទៃសូម្បីមានហើយ ក៏ឲ្យផល (មុន) ព្រោះនៅជិតមរណកាល ដូចកាលបើកទ្វារក្រោលគោ ដែល មានហ្វូងគោពេញក្រោល បណ្តាគោដែលហ្វឹកហើយ និងគោមានកម្លាំង សូម្បី មាននៅក្នុងចំណែកដទៃៗ (ឆ្ងាយពីទ្វារក្រោល) គោណាមួយនៅជិតទ្វារក្រោល ដោយទីបំផុតសូម្បីជាគោថយកម្លាំងក៏ដោយ គោនោះក៏រមែងចេញបានមុននុ៎ះ ឯង ដូច្នោះ ។ ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះជាគ្រឿងឧបមា ។

## រឿងអ្នករក្សាទ្វារអ្នកស្រុកទមិឡ

បានឮមកថា ក្នុងស្រុកមធុគណៈ មាននាយទ្វារអ្នកស្រុកទមិឡម្នាក់ កាន់យកសន្ទូចទៅពីព្រឹក ស្ទូចត្រីបានហើយបែងចេញជា ៣ ចំណែក មួយ ចំណែកដូរអង្ករ មួយចំណែកដូរទឹកដោះ មួយចំណែកធ្វើជាសម្ភារបរិភោគ ។

ដោយទំនងនេះ គេធ្វើបាណាតិបាតអស់ ៥០ ឆ្នាំ តមកដល់ខ្លួនចាស់ ដួលដេកលើកន្ទេល ក្នុងខណៈនោះ ព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរៈ អ្នកស្រុកគិរីវិហារ រំពឹងថា បុគ្គលម្នាក់នេះ កាលបើយើងឃើញហើយ កុំវិនាសឡើយ ហើយទៅឈរត្រង់ទ្វារផ្ទះរបស់គេ ។ ខណៈនោះ ភរិយារបស់គេប្រាប់ថា នុ៎ះព្រះថេរៈមកប្រោសហើយ គេឆ្លើយថា អស់វេលា ៥០ ឆ្នាំ យើងមិនធ្លាប់ទៅសំណាក់របស់ព្រះថេរៈឡើយ ព្រោះគុណសេចក្តីល្អអ្វីរបស់យើង លោកទើបត្រូវមក នាងចូរទៅនិមន្តឲ្យលោកចេញទៅចុះ ។ នាងប្រាប់ព្រះថេរៈថា និមន្តទៅប្រោសសត្វខាងមុខចុះលោកម្ចាស់ ព្រះថេរៈសួរថា ឧបាសកមានវិបត្តិផ្លូវកាយដូចម្តេច ។ នាងឆ្លើយថា ខ្សោយកម្លាំងហើយ លោកម្ចាស់ ។ ព្រះថេរៈចូលទៅកាន់ផ្ទះ ឲ្យមានសតិ ហើយពោលថា ញោមទទួលសីល (ទេ) ។ គេឆ្លើយថា ទទួល លោកម្ចាស់ និមន្តឲ្យសីលចុះ ។ ព្រះថេរៈឲ្យសរណៈ ៣ ហើយ ផ្តើមនឹងឲ្យសីល ៥ ។ ក្នុងខណៈដែលឧបាសកនោះថា បញ្ចសីលានិ នុ៎ះឯង អណ្តាតក៏រឹង ។ ព្រះថេរៈគិតថា ប៉ុណ្ណេះក៏សមគួរ ហើយនិមន្តចេញទៅ ។ ចំណែកគេស្លាប់ហើយ ទៅកើតក្នុងភពចាតុម្មហារាជិកៈ ។ ក៏ក្នុងខណៈដែលគេកើតនោះឯង រលឹកថា យើងធ្វើកម្មអ្វីហ្ន៎ ទើបបានសម្បត្តិនេះ ដឹងថា បានព្រោះអាស្រ័យព្រះថេរៈ ទើបមកពីទេវលោក ថ្វាយបង្គំព្រះថេរៈ ហើយ

ឈរក្នុងទីដ៏សមគួរម្ខាង កាលព្រះថេរៈសួរថា នោះជានរណា ឆ្លើយថា ខ្ញុំ (គឺ) អ្នករក្សាទ្វារអ្នកស្រុកទមិឡ លោកម្ចាស់ ។ ព្រះថេរៈសួរថា លោកទៅកើតទីណា ។ ឆ្លើយថា ខ្ញុំកើតនៅជាន់ចាតុម្មហារាជិកៈ លោកម្ចាស់ ប្រសិនបើលោកម្ចាស់បានឲ្យសីល ៥ ចប់ហើយសោត ខ្ញុំគង់បានកើតក្នុងជាន់ខ្ពស់ជាងនេះ ខ្ញុំនឹងធ្វើដូចម្ដេច ។ ព្រះថេរៈឆ្លើយថា ទេវបុត្រ លោកមិនអាចទទួលយកបានឯង ទេវបុត្រថ្វាយបង្គំព្រះថេរៈហើយ ត្រឡប់ទៅកាន់ទេវលោក ។ នេះជារឿងឧបមា ក្នុងកុសលកម្ម ។

## រឿងមហាវាតកាលឧបាសក

ក៏ក្នុងចន្លោះទន្លេគង្គា បានឧបាសកឈ្មោះថា មហាវាតកាលៈ ។ គេស្វាធ្យាយអាការ ៣២ ដើម្បីប្រាថ្នាសោតាបត្តិមគ្គរហូតអស់ ៣០ ឆ្នាំ ដល់ទិដ្ឋិវិបល្លាសថា យើងស្វាធ្យាយអាការ ៣២ យ៉ាងនេះ ក៏មិនអាចឲ្យកើតសូម្បីត្រឹមតែឱកាសបាន ប្រហែលជាព្រះពុទ្ធសាសនា មិនមែនជាសាសនាដែលជាគ្រឿងនាំសត្វចេញចាកភព (ពិតទេ) គេធ្វើកាលកិរិយាហើយ បានទៅកើតជាកូនក្រពើប្រវែង ៩ ឧសភៈ នៅនឹងមហាទន្លេគង្គា ។ សម័យមួយ រទេះបន្ទុកសសរថ្ម ៦០០ រទេះ ធ្វើដំណើរទៅតាមកំពង់កច្ឆបៈ ។ ក្រពើនោះ ត្របាក់ទាំងមនុស្សទាំងថ្មនោះសូម្បីទាំងអស់ ។ នេះជារឿងឧបមាក្នុងអកុសលកម្ម ។

## អធិប្បាយ កដត្តាវាបនកម្ម

ចំណែកកម្មក្រៅពីកម្ម ៣ ដូចពោលមកហើយនេះ ធ្វើទៅដោយមិនដឹង ឈ្មោះថា **កដត្តាវាបនកម្ម** ។ កដត្តាវាបនកម្មនោះ ឲ្យវិបាកបានក្នុងកាលខ្លះ ព្រោះមិនមានកម្មទាំង ៣ យ៉ាងនោះ ដូចកំណាត់ឈើ ដែលបុគ្គលបោះទៅ នឹងធ្លាក់ទៅក្នុងទីដែលមិនមានគោលដៅ ដូច្នោះ ។

## អធិប្បាយ ជនកកម្ម

កម្មដែលឲ្យបដិសន្ធិតែម្យ៉ាង មិនឲ្យក្នុងបវត្តិកាល កម្មដទៃរមែងឲ្យវិបាកក្នុងបវត្តិកាល ឈ្មោះថា **ជនកកម្ម** ។ ឧបមាថា មាតាឲ្យកំណើតតែម្យ៉ាង ចំណែកមេដោះ ចិញ្ចឹមបីបាច់ យ៉ាងណា ជនកកម្មក៏ដូច្នោះ ឲ្យបដិសន្ធិដូចមាតា (ចំណែក) កម្មដែលមកឧបតម្ភក្នុងបវត្តិកាល ដូចជាមេដោះ ។

## អធិប្បាយ ឧបត្ថម្ភកម្ម

ធម្មតាឧបត្ថម្ភកម្ម មានទាំងក្នុងកុសល ទាំងក្នុងអកុសល ព្រោះថាបុគ្គលខ្លះធ្វើកុសលកម្មហើយកើតក្នុងសុគតិភព ។ គេតាំងនៅក្នុងសុគតិភពនោះហើយ បំពេញកុសលរឿយៗ គាំទ្រកម្មនោះ រមែងអន្ទោលទៅក្នុងសុគតិ-ភពនោះឯង រហូតអស់វេលាច្រើនពាន់ឆ្នាំ ។ បុគ្គលខ្លះធ្វើអកុសលកម្មហើយកើតក្នុងទុគ្គតិភព គេតាំងនៅក្នុងទុគ្គតិនោះ ធ្វើអកុសលកម្មរឿយៗ គាំទ្រកម្ម

នោះ នឹងអន្ទោលទៅក្នុងទុគ្គតិកពនោះឯង អស់វេលាច្រើនពាន់ឆ្នាំ ។

ន័យម្យ៉ាងទៀត គួរជ្រាបដូច្នេះ ទាំងកុសលកម្ម ទាំងអកុសលកម្ម ឈ្មោះថា ជនកកម្ម ។ ជនកកម្មនោះ ឲ្យកើតវិបាកក្ខន្ធទាំងដែលជារូប និង អរូប ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ។ ចំណែកឧបត្ថម្ភកកម្ម មិន អាចឲ្យកើតវិបាកបាន តែនឹងឧបត្ថម្ភសុខទុក្ខដែលកើតឡើងព្រោះវិបាក ដែល បដិសន្ធិរបស់កម្មដទៃឲ្យកើតហើយ រមែងប្រព្រឹត្តទៅអស់កាលយូរ ។

## អធិប្បាយ ឧបបីឡកកម្ម

កម្មដែលបៀតបៀន បៀតបៀនសុខទុក្ខ ដែលកើតឡើងព្រោះវិបាក ដែលបដិសន្ធិរបស់កម្មដទៃឲ្យកើតហើយ នឹងមិនឲ្យ (សុខ ឬទុក្ខនោះ) ប្រព្រឹត្ត ទៅអស់កាលយូរ ឈ្មោះថា **ឧបបីឡកកម្ម** ។

ក្នុងឧបបីឡកកម្មនោះ មានន័យដូចតទៅនេះ ។ កាលកុសលកម្មកំពុង ឲ្យផល អកុសលកម្មជាឧបបីឡកកម្មមិនឲ្យ (ឱកាស) កុសលកម្មនោះឲ្យផល ។ សូម្បីកាលអកុសលកម្មនោះកំពុងឲ្យផល កុសលកម្មជាឧបបីឡកកម្មមិនឲ្យ (ឱកាស) អកុសលកម្មនោះឲ្យផល ។ ដើមឈើ គុម្ពឈើ វល្លិ៍ ដែលកំពុង ចម្រើនលូតលាស់ បុគ្គលណាមួយយកឈើមកដំ ឬយកសស្ត្រាមកកាត់ កាល នោះ ដើមឈើ គុម្ពឈើ ឬវល្លិ៍នោះ នឹងមិនចម្រើនលូតលាស់ឡើង យ៉ាង

ណា កុសលកម្មក៏ដូច្នោះ កាលកំពុងឲ្យផល (តែត្រូវ) អកុសលកម្មបៀតបៀន ឬថា អកុសលកម្មកំពុងឲ្យផល (តែត្រូវ) កុសលកម្មបៀតបៀន នឹងមិនអាចឲ្យផលបាន ។ ក្នុងពីរយ៉ាងនោះ ចំពោះនាយសុនក្ខត្ត: អកុសលកម្ម (ឈ្មោះថា) បៀតបៀនកុសលកម្ម , ចំពោះនាយចោរឃាតក: កុសលកម្ម (ឈ្មោះថា) បៀតបៀនអកុសលកម្ម ។

## រឿងពេជ្ឈឃាត ឈ្មោះតាវកាឡក:

បានឮមកថា ក្នុងក្រុងរាជគ្រឹះ នាយតាវកាឡក: ធ្វើចោរឃាតកម្ម (ប្រហារជីវិតចោរ) មកអស់វេលា ៥០ ឆ្នាំ ។ លំដាប់នោះ រាជបុរសទាំងឡាយបានក្រាបទូលចំពោះព្រះរាជាអំពីគេថា បពិត្រព្រះសម្មតិទេព នាយតាវកាឡក: ចាស់ហើយ មិនអាចនឹងប្រហារជីវិតចោរបាន ព្រះរាជាត្រាស់បង្គាប់ថា អ្នកទាំងឡាយចូរដោះគេចេញពីតំណែងនោះ ។ អាមាត្រទាំងឡាយដោះគេចេញហើយ តែងតាំងអ្នកដទៃជំនួស ។ ចំណែកនាយតាវកាឡក: ឈប់ពីធ្វើការងារនោះ (ជាពេជ្ឈឃាដ) មិនធ្លាប់ស្លៀកសំពត់ថ្មី មិនដែលបានទ្រទ្រង់របស់ក្រអូប និងផ្កាឈើ មិនបានបរិភោគបាយបាយាស មិនបានលាបរាងកាយដោយទឹកក្រអូប និងការងូតទឹក ។ គេគិតថា យើងនៅដោយភេទជាមនុស្សសៅហ្មងមកយូរហើយ ទើបប្រាប់ភរិយាឲ្យដាំបាយបាយាស ឲ្យនាំគ្រឿងសំភារ:

សម្រាប់ងូតទៅកាន់កំពង់ទឹក ងូតទឹកហើយ ស្លៀកសំពត់ថ្មី លាបគ្រឿងក្រអូប ប្រដាប់ផ្កាឈើ ហើយដើរមកកាន់ផ្ទះ ឃើញព្រះសារីបុត្តត្ថេរៈ សប្បាយចិត្តថា យើងនឹងបានផុតពីកម្មដែលសៅហ្មងផង និងបានជួបលោកម្ចាស់របស់យើងផង ទើបនាំព្រះថេរៈទៅកាន់ផ្ទះ ហើយអង្គាសដោយបាយបាយាសដែលផ្សំដោយទឹកដោះថ្លា ទឹកដោះខាប់ និងកម្មេចស្ករត្នោត ។ ព្រះថេរៈបានអនុមោទនាទានរបស់គេ ។ គេបានស្តាប់អនុមោទនាកថាហើយ ក៏បានអនុលោមិកខន្តិ តាមជូនព្រះថេរៈហើយ ដើរត្រឡប់ ក្នុងចន្លោះផ្លូវត្រូវមេគោការកូនជល់ឲ្យអស់ជីវិតទៅ បានទៅកើតក្នុងតាវតឹង្សពិភព ។ ភិក្ខុទាំងឡាយក្រាបទូលសួរព្រះតថាគតថា បពិត្រព្រះអង្គ ថ្ងៃនេះឯង នាយចោរឃាតដែលព្រះសារីបុត្តត្ថេរៈជួយនាំចេញចាកកម្មដែលសៅហ្មង ក៏ដល់កម្មហើយក្នុងថ្ងៃនេះដូចគ្នា គេកើតក្នុងទីណាហ្ន៎ ។

ព្រះមានព្រះភាគ : ក្នុងតាវតឹង្សពិភព ភិក្ខុទាំងឡាយ ។

ភិក្ខុទាំងឡាយ : បពិត្រព្រះអង្គ នាយចោរឃាត សម្លាប់មនុស្សមកអស់វេលាជាយូរ ឯព្រះអង្គក៏ត្រាស់ទូន្មានទុកយ៉ាងនេះ ដូច្នេះ បាបកម្មមិនមានផលទេឬ ។

ព្រះមានព្រះភាគ : ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំពោលដូច្នោះ នាយ

ចោរឃាត បានកល្យាណមិត្តដែលមានកម្លាំងជាឧបនិស្សយប្បច្ច័យ ថ្វាយបិណ្ឌបាតដល់ព្រះធម្មសេនាបតី ស្ដាប់អនុមោទនាកថាហើយ ក៏បានអនុលោមិកខន្តិ ទើបបានទៅកើតក្នុងទីនោះ ។

នាយចោរឃាត បានស្ដាប់ពាក្យជាសុភាសិត
ក្នុងក្រុងហើយ បានអនុលោមិកខន្តិ រីករាយ
ចិត្ត ទៅកើតក្នុងត្រៃទេព ។

## អធិប្បាយ ឧបឃាតកម្ម

ចំណែកឧបឃាតកម្ម ជាកុសលខ្លះ ជាអកុសលខ្លះ មានហើយ នឹងកាត់បង់នូវកម្មដទៃ ដែលមានកម្លាំងខ្សោយជាង ហាមវិបាករបស់កម្មនោះទុកហើយធ្វើឱកាសដល់វិបាករបស់ខ្លួន ។ ក៏កាលកម្មធ្វើ (ឲ្យ) ឱកាសយ៉ាងនេះហើយ កម្មនោះហៅថា បញ្ចេញផលហើយ ។ ឧបឃាតកម្មនេះទុំះឯង មានឈ្មោះថា ឧបច្ឆេទកកម្ម ។

## អធិប្បាយ ឧបច្ឆេទកកម្ម

ក្នុងឧបច្ឆេទកកម្មនោះ មានន័យដូចតទៅនេះ ក្នុងវេលាដែលកុសលកម្មឲ្យផល អកុសលកម្មណាមួយនឹងកើតឡើងកាត់ផ្ដាច់នូវកម្មនោះឲ្យអស់ទៅ សូម្បីក្នុងវេលាដែលអកុសលកម្មឲ្យផល កុសលកម្មណាមួយក៏នឹងកើត

ឡើង កាត់ផ្តាច់នូវកម្មនោះហើយឲ្យអស់ទៅ ។ នេះឈ្មោះថា **ឧបច្ឆេទកកម្ម** ។ បណ្តាឧបច្ឆេទកកម្មដែលជាកុសល និងអកុសល ទាំងពីរយ៉ាងនោះ កម្មរបស់ព្រះបាទអជាតសត្រូវ ជាកម្មដែលកាត់ផ្តាច់នូវកុសល ចំណែកកម្មរបស់ព្រះអង្គុលិមាលត្ថេរៈ ជាកម្មកាត់ផ្តាច់នូវអកុសល ។ ដោយប្រការដូចពោលមកនេះ គឺ លោកចែកកម្ម ១១ យ៉ាង តាមសុត្តន្តិកបរិយាយ ។

## កម្ម ១៦ យ៉ាង តាមព្រះអភិធម្ម

ចំណែកព្រះអភិធម្មបរិយាយ លោកចែកកម្មទុក ១៦ យ៉ាង ។ គឺ ៈ-

កម្មសមាទានអាក្រក់ខ្លះ ជំទាស់នឹងគតិសម្បត្តិ មិនឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ ជំទាស់ឧបធិសម្បត្តិ មិនឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ ជំទាស់កាលសម្បត្តិ មិនឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ ជំទាស់បយោគសម្បត្តិ មិនឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ អាស្រ័យគតិវិបត្តិ ឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ អាស្រ័យឧបធិវិបត្តិ ឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ អាស្រ័យកាលវិបត្តិ ឲ្យផល ១

កម្មសមាទានអាក្រក់ខ្លះ អាស្រ័យបយោគវិបត្តិ ឲ្យផល ១

កម្មសមាទានល្អខ្លះ ជំទាស់គតិវិបត្តិ មិនឲ្យផល ១

កម្មសមាទានល្អខ្លះ ជំទាស់ឧបធិវិបត្តិ មិនឲ្យផល ១
កម្មសមាទានល្អខ្លះ ជំទាស់កាលវិបត្តិ មិនឲ្យផល ១
កម្មសមាទានល្អខ្លះ ជំទាស់បយោគវិបត្តិ មិនឲ្យផល ១
កម្មសមាទានល្អខ្លះ អាស្រ័យគតិសម្បត្តិ ឲ្យផល ១
កម្មសមាទានល្អខ្លះ អាស្រ័យឧបធិសម្បត្តិ ឲ្យផល ១
កម្មសមាទានល្អខ្លះ អាស្រ័យកាលសម្បត្តិ ឲ្យផល ១
កម្មសមាទានល្អខ្លះ អាស្រ័យបយោគសម្បត្តិ ឲ្យផល ១

### អធិប្បាយ កម្ម ១៦ យ៉ាង តាមព្រះអភិធម្ម

បណ្ដាបទទាំងនោះ បទថា **អាក្រក់** បានដល់ លាមក ។ បទថា **កម្មសមាទាន** បានដល់ ការកាន់យកនូវកម្ម ។ ពាក្យថា **កម្មសមាទាន** នេះ ជាឈ្មោះនៃកម្មទាំងឡាយ ដែលបុគ្គលសមាទានហើយ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **ជំទាស់នឹងគតិសម្បត្តិ មិនឲ្យផល** ជាដើម ដូចតទៅនេះ

កាលកម្ម ដែលមានការសោយអនិដ្ឋារម្មណ៍ជាកិច្ច មានហើយនុ៎ះឯង កម្មនោះ របស់សត្វអ្នកកើតក្នុងសុគតិភព ឈ្មោះថា ជំទាស់គតិសម្បត្តិ មិនឲ្យផល អធិប្បាយថា ជាកម្មត្រូវគតិសម្បត្តិហាម មិនឲ្យផល ។

ក៏បុគ្គលណា កើតក្នុងផ្ទៃរបស់ស្រីទាសី ឬស្រីកម្មករ ព្រោះបាបកម្ម

(តែ) ជាអ្នកមានឧបធិសម្បត្តិ តាំងនៅក្នុងសេចក្ដីសម្រេច (គឺភាពស្រស់ស្អាត) នៃអត្តភាព ។ កាលចៅហ្វាយនាយរបស់គេឃើញរូបសម្បត្តិរបស់គេហើយ កើតសេចក្ដីគិតថា បុគ្គលនេះ មិនសមគួរធ្វើការងារដែលថោកទាប តែងតាំងគេទុកក្នុងតំណែងភណ្ឌាគារិកជាដើម ប្រគល់សម្បត្តិឲ្យហើយ ចិញ្ចឹមទុកដូចជាកូនរបស់ខ្លួន ។ កម្មរបស់បុគ្គលបែបនេះ ជាកម្មដែលជំទាស់ឧបធិសម្បត្តិ ឈ្មោះថា មិនឲ្យផល ។

ចំណែកបុគ្គលណា កើតក្នុងវេលាដែលមានភោជនាហាររកបានងាយ និងមានរសឆ្ងាញ់ ដូចជាកាលបុគ្គលដែលកើតក្នុងបឋមកប្ប បាបកម្មរបស់គេសូម្បីមានហើយ (តែ) ជាកម្មជំទាស់នឹងកាលសម្បត្តិ ឈ្មោះថា មិនឲ្យផល ។

ចំណែកបុគ្គលណា អាស្រ័យសេចក្ដីព្យាយាមតាមសមគួរចិញ្ចឹមជីវិត តែគេស្វែងរកក្នុងវេលាដែលគួរនឹងត្រូវការ ត្រឡប់ក្នុងវេលាដែលគួរនឹងត្រូវត្រឡប់ ឈប់ក្នុងវេលាដែលគួរនឹងត្រូវការឈប់ ឲ្យសំណូកក្នុងវេលាដែលគួរសំណូក ធ្វើចោរកម្មក្នុងវេលាដែលគួរធ្វើចោរកម្ម បាបកម្មរបស់បុគ្គលនេះ ជាកម្មដែលជំទាស់បយោគសម្បត្តិ ឈ្មោះថា មិនឲ្យផល ។

ចំណែកបាបកម្មរបស់បុគ្គលដែលកើតក្នុងទុគ្គតិភព ឈ្មោះថា អាស្រ័យគតិវិបត្តិឲ្យផល ។

ចំណែកបុគ្គលណា កើតក្នុងផ្ទៃរបស់ស្រីទាសី ឬស្រីកម្មករ មានពណ៌សម្បុរមិនល្អ រូបរាងមិនស្អាត ធ្វើឲ្យកើតសង្ស័យថា ជាយក្ខ ឬជាមនុស្ស បើគេជាប្រុស មនុស្សទាំងឡាយនឹងគិតថា បុគ្គលនេះមិនសមគួរដល់ការងារយ៉ាងដទៃ ហើយឲ្យគេចិញ្ចឹមដំរី ចិញ្ចឹមសេះ ចិញ្ចឹមគោ ឬឲ្យរកស្មៅ រកឧសឲ្យចាក់កន្ទេល បើជាស្រី មនុស្សទាំងឡាយនឹងប្រើឲ្យដាំបាយរបស់ណ្តែកឲ្យដំរីឲ្យសេះជាដើម ឲ្យចាក់សម្រាម ឬប្រើឲ្យធ្វើការងារដែលគួររង្កៀសដទៃៗ ។ បាបកម្មរបស់បុគ្គលបែបនេះ ឈ្មោះថា អាស្រ័យឧបធិវិបត្តិឲ្យផល ។

ចំណែកបុគ្គលណា កើតក្នុងវេលារកបាយលំបាក ក្នុងវេលាត្រកូលវិនាសទ្រព្យសម្បត្តិ ឬក្នុងកាលអន្តរកប្ប បាបកម្មរបស់បុគ្គលនោះ ឈ្មោះថា អាស្រ័យកាលវិបត្តិឲ្យផល ។

មួយយ៉ាងទៀត បុគ្គលណាមិនចេះដឹង ប្រកបសេចក្តីព្យាយាមដោយមិនដឹងកាលដើម្បីចូលទៅរកក្នុងវេលាដែលគួរចូលទៅរក ។ល។ មិនដឹងកាលនឹងធ្វើចោរកម្ម ក្នុងវេលាដែលគួរធ្វើចោរកម្ម បាបកម្មរបស់បុគ្គលនោះ ឈ្មោះថា អាស្រ័យបយោគវិបត្តិឲ្យផល ។

ក៏បុគ្គលណា កាលកម្មដែលសមគួរដល់ការសោយឥដ្ឋារម្មណ៍ជាកិច្ចមានហើយទុះឯង ទៅកើតក្នុងទុគ្គតិភព កម្មរបស់បុគ្គលនោះ ជំទាស់នឹងគតិ-

វិបត្តិ ឈ្មោះថា មិនឲ្យផល ។

ចំណែកបុគ្គលណា កើតក្នុងព្រះរាជវាំង ឬក្នុងផ្ទះរបស់រាជមហាមាត្រជាដើម ដោយអនុភាពនៃបុព្វកម្ម ជាមនុស្សខ្វាក់ ជាមនុស្សគម ជាមនុស្សខ្វក ឬថា ជាមនុស្សទន់ខ្សោយ មនុស្សទាំងឡាយមិនព្រមឲ្យតំណែងដល់គេព្រោះឃើញថា គេមិនសមគួរដល់តំណែងឧបរាជ សេនាបតី និងនាយឃ្លាំងជាដើម បុណ្យរបស់គេតាមដែលពោលមកនេះ ជំទាស់នឹងឧបធិវិបត្តិ ឈ្មោះថា មិនឲ្យផល ។

ចំណែកបុគ្គលណា កើតក្នុងពួកមនុស្ស ក្នុងវេលារកបាយលំបាក ក្នុងវេលាដែល (ត្រកូល) វិនាសទ្រព្យសម្បត្តិ ឬក្នុងអន្តរកប្ប កម្មល្អរបស់គេនោះ ជំទាស់នឹងកាលវិបត្តិ ឈ្មោះថា មិនឲ្យផល ។

បុគ្គលណា មិនចេះដឹងក៏ប្រកបសេចក្តីព្យាយាម តាមន័យដូចបានពោលហើយក្នុងខាងក្រោយនុ៎ះឯង កម្មល្អរបស់គេនោះ ជំទាស់នឹងបយោគវិបត្តិ ឈ្មោះថា មិនឲ្យផល ។

តែកម្មរបស់បុគ្គលកើតក្នុងសុគតិភព ដោយកល្យាណកម្មនោះ ឈ្មោះថា អាស្រ័យគតិសម្បត្តិឲ្យផល ។

បុគ្គលទាំងឡាយឃើញអត្តភាពរបស់អ្នកដែលកើតក្នុងរាជត្រកូល ឬ

ត្រកូលរបស់រាជមហាមាត្រជាដើម ដល់ឧបធិសម្បត្តិ គឺ តាំងនៅក្នុងការដល់ព្រមនៃអត្តភាព ដូចជារតនតោរណៈ (សសរខឿនកែវ) ដែលគេតាំងទុកត្រង់ទេវនគរ ឃើញថា បុគ្គលនេះសមគួរទឹងតំណែងឧបរាជ សេនាបតី ឬតំណែងនាយឃ្លាំងជាដើម ដល់គេដែលនៅកំឡោះ ក៏រមែងឲ្យតំណែងទាំងនោះ ។ កល្យាណធម៌របស់បុគ្គលបែបនេះ ឈ្មោះថា អាស្រ័យឧបធិសម្បត្តិឲ្យផល ។

បុគ្គលណាកើតក្នុងបឋមកប្បក្តី ក្នុងវេលាដែលបាយទឹករកបានងាយក្តី កល្យាណកម្មរបស់គេ ឈ្មោះថា អាស្រ័យកាលសម្បត្តិឲ្យផល ។

បុគ្គលណាចេះដឹង ប្រកបសេចក្តីព្យាយាម ដោយន័យដូចពោលហើយនោះ និងកម្មរបស់បុគ្គលនោះ ឈ្មោះថា អាស្រ័យបយោគសម្បត្តិឲ្យផល ។

លោកចែកកម្ម ១៦ យ៉ាង តាមបរិយាយនៃព្រះអភិធម្ម ដោយប្រការដូចពណ៌នាមកដូច្នេះ ។

## កម្ម ១២ យ៉ាង តាមបដិសម្ភិទាមគ្គ

ដោយបរិយាយនៃបដិសម្ភិទាមគ្គ លោកចែកកម្ម ១២ យ៉ាងទុកម្យ៉ាងទៀត គឺ ៖-

កម្មបានមានហើយ កម្មវិបាកបានមានហើយ ១

កម្មបានមានហើយ កម្មវិបាកមិនបានមានហើយ ១

| | | |
|---|---|---|
| កម្មបានមានហើយ | កម្មវិបាកបានមានហើយ | ១ |
| កម្មបានមានហើយ | កម្មវិបាកមិនបានមានហើយ | ១ |
| កម្មបានមានហើយ | កម្មវិបាកមានហើយ | ១ |
| កម្មបានមានហើយ | កម្មវិបាករមែងមិនមាន | ១ |
| កម្មបានមានហើយ | កម្មវិបាកនឹងមាន | ១ |
| កម្មបានមានហើយ | កម្មវិបាកនឹងមិនមាន | ១ |
| កម្មមានហើយ | កម្មវិបាកមានហើយ | ១ |
| កម្មមានហើយ | កម្មវិបាកមិនមាន | ១ |
| កម្មនឹងមាន | កម្មវិបាកនឹងមាន | ១ |
| កម្មនឹងមាន | កម្មវិបាកនឹងមិនមាន | ១ |

## អធិប្បាយកម្ម ១២ យ៉ាង តាមបដិសម្ភិទាមគ្គ

បណ្ដាកម្ម ១២ យ៉ាងនោះ កម្មណាដែលបានធ្វើហើយក្នុងអតីត ក៏បានវារៈនៃផលក្នុងអតីតនុ៎ះឯង ដែលនឹងឲ្យបដិសន្ធិ ក៏ឲ្យបដិសន្ធិបាន ចំណែកដែលនឹងឲ្យកើតរូប ក៏អាចឲ្យកើតរូបបាន កម្មនោះ លោកពោលថា **កម្ម** (ការធ្វើ) **បានមានហើយ កម្មវិបាក** (ផលនៃការធ្វើ) **ក៏បានមានហើយ** ។

ចំណែកកម្មណាដែលមិនបានវារៈឲ្យផល ដែលនឹងឲ្យបដិសន្ធិ ក៏មិន

អាចនឹងឲ្យបដិសន្ធិបាន ឬដែលនឹងឲ្យកើតរូបបាន ក៏មិនអាចឲ្យកើតរូបបាន កម្មនោះ លោកពោលថា **កម្មបានមានហើយ (តែ) កម្មវិបាកមិនបានមានហើយ** ។

ចំណែកកម្មណាដែលបានធ្វើហើយក្នុងអតីត បានវារៈនៃផលក្នុងបច្ចុប្បន្ន ដែលនឹងឲ្យបដិសន្ធិ ក៏ឲ្យបដិសន្ធិហើយ ឬដែលនឹងឲ្យកើតរូប ក៏ឲ្យកើតរូបហើយតាំងនៅ កម្មនោះ លោកពោលថា **កម្មបានមានហើយ កម្មវិបាកមានហើយ** ។

ចំណែកកម្មណាដែលមិនបានវារៈឲ្យផល ដែលនឹងឲ្យបដិសន្ធិ ក៏មិនអាចឲ្យបដិសន្ធិបាន ឬដែលនឹងឲ្យកើតរូប ក៏មិនអាចឲ្យកើតរូបបាន កម្មនោះ លោកពោលថា **កម្មបានមានហើយ កម្មវិបាករមែងមិនមាន** ។

ចំណែកកម្មណាដែលបានធ្វើក្នុងអតីត នឹងបានវារៈឲ្យផលក្នុងអនាគត ដែលឲ្យបដិសន្ធិ ក៏នឹងអាចឲ្យបដិសន្ធិបាន ឬដែលឲ្យកើតរូប ក៏អាចឲ្យកើតរូបបាន កម្មនោះ លោកពោលថា **កម្មបានមានហើយ កម្មវិបាកនឹងមាន** ។

ចំណែកកម្មណាមិនបានវារៈឲ្យផលក្នុងអនាគត ដែលឲ្យបដិសន្ធិ ក៏មិនអាចឲ្យបដិសន្ធិ ឬដែលឲ្យកើតរូប ក៏មិនអាចឲ្យកើតរូប កម្មនោះ លោកពោលថា **កម្មបានមានហើយ កម្មវិបាកនឹងមិនមាន** ។

ចំណែកកម្មណាដែលបានធ្វើក្នុងបច្ចុប្បន្ន នឹងបានវារៈឲ្យផលក្នុងបច្ចុ-

ប្បន្នដូចគ្នា កម្មនោះ លោកពោលថា **កម្មមានហើយ កម្មវិបាកក៏មានហើយ** ។

ចំណែកកម្មណាមិនបានវារៈឲ្យផលក្នុងបច្ចុប្បន្ន កម្មនោះ លោកពោលថា **កម្មមានហើយ តែកម្មវិបាកមិនមាន** ។

ចំណែកកម្មដែលបានធ្វើក្នុងបច្ចុប្បន្ន តែបានវារៈឲ្យផលក្នុងអនាគត ដែលនឹងឲ្យបដិសន្ធិ ក៏នឹងឲ្យបដិសន្ធិបាន ឬនឹងឲ្យកើតរូប ក៏នឹងឲ្យកើតរូប (ក្នុងអនាគត) បាន កម្មនោះ លោកពោលថា **កម្មមានហើយ កម្មវិបាកក៏នឹងមាន** ។

ចំណែកកម្មដែលមិនបានវារៈឲ្យផល ដែលឲ្យបដិសន្ធិ ក៏មិនអាចឲ្យបដិសន្ធិបាន ឬដែលនឹងឲ្យកើតរូប ក៏មិនអាចឲ្យកើតរូប (ក្នុងអនាគត) បាន កម្មនោះ លោកពោលថា **កម្មមានហើយ តែកម្មវិបាកនឹងមិនមាន** ។

ចំណែកកម្មណាដែលនឹងធ្វើក្នុងអនាគត ក៏បានវារៈឲ្យផលក្នុងអនាគតដូចគ្នា ដែលនឹងឲ្យបដិសន្ធិ ក៏ឲ្យបដិសន្ធិ ឬដែលនឹងឲ្យកើតរូប ក៏ឲ្យកើតរូបបាន កម្មនោះ លោកពោលថា **កម្មក៏នឹងមាន កម្មវិបាកក៏នឹងមាន** ។

ចំណែកកម្មណាដែលនឹងមិនបានឲ្យផល នឹងឲ្យបដិសន្ធិ ក៏មិនអាចឲ្យបដិសន្ធិ ឬដែលនឹងឲ្យកើតរូប ក៏មិនអាចឲ្យកើតរូបបាន កម្មនោះ លោកពោលថា **កម្មនឹងមាន តែកម្មវិបាកនឹងមិនមាន** ។

តាមបរិយាយនៃបដិសម្ភិទាមគ្គ លោកចែកកម្មទុក ១២ យ៉ាង ដោយប្រការដូចពណ៌នាមកដូច្នេះ ។

កម្មទាំង ១២ យ៉ាងនេះក្តី កម្ម ១៦ យ៉ាងខាងដើមក្តី ដែលចែកទុកហើយ សង្ខេបពីឋានៈរបស់ខ្លួនចុះមក ពោលដោយបរិយាយនៃសុត្តន្ត ក៏មាន ១១ យ៉ាងប៉ុណ្ណោះ ។ សូម្បីកម្មទាំងនោះ សង្ខេបអំពីកម្ម ១១ យ៉ាងនោះហើយ នឹងនៅសល់ត្រឹមតែ ៣ យ៉ាងប៉ុណ្ណោះ គឺ **ទិដ្ឋធម្មវេទនីយកម្ម ១ ឧបបជ្ជវេទនីយកម្ម ១ អបរាបរិយាយវេទនីយកម្ម ១** ។ កម្មទាំងនោះ មិនមានការឈានកន្លងគ្នា រមែងតាំងនៅក្នុងឋានៈរបស់ខ្លួនតែម្យ៉ាង ។

ព្រោះថា ប្រសិនបើទិដ្ឋធម្មវេទនីយកម្ម ក្លាយជាឧបបជ្ជវេទនីយកម្ម ឬក្លាយជាអបរាបរិយាយវេទនីយកម្មសោត ព្រះសាស្តាគង់មិនត្រាស់ថា **ទិដ្ឋេវ ធម្មេ** (ក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះ) ។ សូម្បីបើ ឧបបជ្ជវេទនីយកម្ម នឹងក្លាយជាទិដ្ឋធម្មវេទនីយកម្ម ឬជាអបរាបរិយាយវេទនីយកម្មសោត ព្រះសាស្តាគង់មិនត្រាស់ថា **ឧបបជ្ជេ វា** (ក្នុងភពដែលនឹងកើតឡើង) ។ មួយទៀត បើអបរាបរិយាយវេទនីយកម្ម នឹងក្លាយជាទិដ្ឋធម្មវេទនីយកម្ម ឬជាឧបបជ្ជវេទ-នីយកម្មសោត ព្រះសាស្តាក៏គង់មិនត្រាស់ថា **អបរេ វា បរិយាយេ** (ឬក្នុងបរិយាយកពតទៅ) ។ សូម្បីក្នុងសុកបក្ខ (កុសលកម្ម) គប្បីជ្រាបអត្ថដោយ

ន័យនេះដូចគ្នា ។

[៣៥] គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ដែលជាសុកបក្ខ ដូចតទៅនេះ បទថា **លោកេ វិគតេ** (កាលលោកៈអស់ទៅ) សេចក្តីថា កាលលោកៈប្រាសទៅហើយ គឺ រលត់ហើយ ។ បទថា **តាលវត្ថុកតំ** (ដូចជាត្នោតកំបុតក) សេចក្តីថា ធ្វើឲ្យមានត្រឹមតែវត្ថុនៃដើមត្នោត អធិប្បាយថា ធ្វើឲ្យមិនដុះឡើងទៀតដូចដើមត្នោតដែលកំបុតកហើយ ។ បទថា **អនភាវំ កតំ** គឺ **អនុអភាវំ កតំ** (ធ្វើមិនឲ្យមានក្នុងខាងក្រោយ) អធិប្បាយថា ធ្វើដោយប្រការដែលនឹងមិនឲ្យកើតឡើងទៀត ។ បទថា **ឯវស្សុ** គឺ **ឯវំ ភវេយ្យុំ** (គប្បីយ៉ាងនោះ) ។

គប្បីជ្រាបប្រការប្រៀបធៀប ក្នុងបទថា **ឯវមេវ ខោ** ដូចតទៅនេះ **កុសលកម្ម និងអកុសលកម្ម** គប្បីឃើញដូចជាពូជ ។ **ព្រះយោគាវចរ** គប្បីឃើញដូចជាបុរសយកភ្លើងដុតពូជទាំងនោះ ។ **មគ្គញ្ញាណ** គប្បីឃើញដូចជាភ្លើង ។ **វេលាដែលកិលេសត្រូវមគ្គញ្ញាណដុត** គប្បីឃើញដូចជាវេលាដែលដុតពូជនោះ ។ **វេលាដែលព្រះយោគាវចរធ្វើឫសគល់របស់ខន្ធ ៥ ឲ្យអស់ហើយតាំងនៅ** គប្បីឃើញដូចវេលាដែលបុរសដុតពូជឲ្យជាផេះ ។ វេលាដែលព្រះខីណាស្រពមិនបដិសន្ធិក្នុងភពថ្មី ព្រោះរលត់ខន្ធ ព្រោះខន្ធ ៥ មានឫសអស់ហើយ មិនបដិសន្ធិតទៅ ព្រោះរំលត់ការបន្តនៃឧបាទិន្នកសង្ខារបានហើយ

គប្បីប្រាបដូចវេលាដែលពូជត្រូវគេរោយទៅក្នុងខ្យល់ខ្លាំង ឬរោយទៅក្នុងទន្លេ ធ្វើមិនឲ្យវិលត្រឡប់មកទៀតបាន ។

បទថា **មោហជំ វាបិវិទ្ទសុ** (ក្នុងបិដក **មោហជញ្ចាបវិទ្ទសុ**) (បុគ្គលល្ងង់ "ធ្វើកម្ម" ដែលកើតពីមោហៈ) សេចក្តីថា អ្នកមិនដឹង (ធ្វើកម្ម) សូម្បីដែលកើតពីមោហៈ មានពាក្យអធិប្បាយដែលលោកពោលទុកដូច្នេះថា គេមិនដឹង គឺ ជាអន្ធពាល ធ្វើកម្មដែលកើតពីលោភៈខ្លះ កើតពីទោសៈខ្លះ កើតពីមោហៈខ្លះ កម្មណាដែលគេធ្វើហើយដូច្នេះ ឈ្មោះថា ធ្វើហើយ តិចក្តី ច្រើនក្តី ។ បទថា **ឥធេវ តំ វេទនីយំ** (កម្មនោះឲ្យផលក្នុងអត្តភាពនេះឯង) សេចក្តីថា កម្មនោះ ជាកម្មដែលបុគ្គលពាលនោះ នឹងគប្បីបានសោយក្នុងលោកនេះ គឺក្នុងអត្តភាពរបស់ខ្លួននេះឯង អធិប្បាយថា កម្មនោះ នឹងឲ្យផលក្នុងអត្តភាពរបស់គេនោះឯង ។

បទថា **វត្ថុំ អញ្ញំ ន វិជ្ជតិ** (វត្ថុដទៃ "ដែលជាទីទទួលផលរបស់កម្មនោះ" មិនមាន) សេចក្តីថា មិនមានវត្ថុដទៃដើម្បីប្រយោជន៍ដល់ការទទួលផលរបស់កម្មនោះ ព្រោះកម្មដែលបុគ្គលម្នាក់ធ្វើទុក នឹងឲ្យផលក្នុងអត្តភាពបុគ្គលដទៃមិនបាន ។

បទថា **តស្មា លោភញ្ច ទោសញ្ច មោហញ្ចាបិ វិទ្ទសុ** (ព្រោះហេតុ

នោះ ភិក្ខុជាអ្នកដឹង រមែងមិនធ្វើកម្មដែលកើតពីលោភៈ ទោសៈ មោហៈ) ព្រោះដូច្នោះ ភិក្ខុណាជាអ្នកដឹង គឺ ជាអ្នកមានបញ្ញា បានដល់ ជាបណ្ឌិត រមែងមិនធ្វើកម្មនោះ មានប្រភេទ មានកម្មដែលកើតពីសេចក្តីលោភជាដើម ភិក្ខុនោះញុំាងវិជ្ជាឲ្យកើតឡើងហើយ គប្បីលះទុគ្គតិគ្រប់យ៉ាងបាន គឺ កាលធ្វើវិជ្ជា គឺ ព្រះអរហត្តមគ្គឲ្យកើតឡើង នឹងលះទុគ្គតិគ្រប់យ៉ាងបាន ។ នេះជាមាតិក (ឧបមា) នៃទេសនាប៉ុណ្ណោះ ។ ចំណែកព្រះខីណាស្រពនោះ សូម្បីសុគតិក៏លះបានដោយពិត ។ សូម្បីក្នុងពាក្យដែលត្រាស់ទុកថា **តស្មា លោភញ្ច ទោសញ្ច មោហញ្ច** ដូច្នេះ គប្បីជ្រាបថា ទ្រង់សម្តែងដល់កម្មដែលកើតពីលោភៈ និងកើតពីទោសៈដូចគ្នា ដោយមាតិកា គឺ លោភៈ និងទោសៈ ។ ទាំងក្នុងព្រះសូត្រ ទាំងក្នុងព្រះគាថា ព្រះមានព្រះភាគបានត្រាស់ទាំងវដ្តៈ និងវិវដ្តៈទុក ដោយប្រការដូចពោលមកហើយនេះឯង ។

ចប់អដ្ឋកថា និទានសូត្រទី ៨

# អដ្ឋកថា ហត្ថកសូត្រទី ៥

## “បុគ្គលមានសេចក្ដីសុខពិត”

*គប្បីជ្រាបវិនិច្ឆ័យក្នុង និទានសូត្រទី ៤ ដូចតទៅនេះ ៈ-*

### ហត្ថករាជបុត្ត

[៣៦] *បទថា* ***អាឡវិយំ*** *(ក្នុងដែនអាឡវី) បានដល់ ក្នុងអាឡវីរដ្ឋ ។ បទថា* ***គោមគ្គេ*** *(ជិតផ្លូវគោ) បានដល់ ផ្លូវទៅរបស់ហ្វូងគោ ។ បទថា* ***បណ្ណសន្ថរេ*** *(លើកម្រាលស្លឹកឈើ) បានដល់ លើកម្រាលស្លឹកឈើដែលជ្រុះឯង ។ សួម្បីគ្រានោះ ព្រះតថាគតទ្រង់ក្រាលចីវរផ្ទាំងធំរបស់ព្រះសុគតចុះលើកម្រាលដែលបោសយកស្លឹកឈើដែលជ្រុះឯងមកគរទុក ក្នុងព្រៃជ្ជង់ ជិតផ្លូវហ្វូងមួយ ដែលជាផ្លូវគោដើរ (បែកទៅ) យ៉ាងនេះ ហើយក៏ប្រថាប់គង់ពត់ភ្នែន ។*

*បទថា* ***ហត្ថកោ អាឡវកោ*** *(ហត្ថកអាឡវករាជកុមារ) បានដល់ រាជ-កុមារក្រុងអាឡវី ទ្រង់បានព្រះនាមថា (ហត្ថកៈ) យ៉ាងនោះ ព្រោះស្ដេចចាកអំពីដៃ (របស់អាឡវកយក្ខ) ទៅកាន់ព្រះហស្ថ (របស់ព្រះសម្មាសម្ពុទ្ធ) ។*

### ហេតុកើតទេសនា

*បទថា* ***ឯតទវោច*** *(បានក្រាបទូលពាក្យនេះ) សេចក្ដីថា ហត្ថករាជបុត្រ*

បានក្រាបទូលពាក្យនេះ គឺ ពាក្យមានជាអាទិ៍ថា ព្រះមានព្រះភាគ (ទ្រង់ផ្ទំជាសុខ) ទេឬព្រះអង្គ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះសម្មាសម្ពុទ្ធស្ដេចទើបទៅប្រថាប់គង់នៅទីនោះហ្ន៎ (និង) ព្រោះហេតុអ្វី ព្រះរាជកុមារទើបស្ដេចទៅក្នុងទីនោះ ។

ឆ្លើយថា ជាដំបូង ព្រះសម្មាសម្ពុទ្ធទ្រង់ឃើញហេតុកើតព្រះធម៌ទេសនាដែលជាដើមហេតុឲ្យកើតរឿង ទើប (ស្ដេចទៅ) ប្រថាប់គង់ក្នុងទីនោះ ចំណែកព្រះរាជកុមារស្ដេចក្រោកឡើងពីព្រឹកព្រលឹម មានឧបាសក ៥០០ នាក់ហែហមស្ដេចដំណើរទៅកាន់កន្លែងដែលព្រះពុទ្ធ (ប្រថាប់នៅ) បែកចេញពីផ្លូវធំ ជាផ្លូវគោដើរ ស្ដេចទៅដោយព្រះបំណងថា យើងនឹងជ្រើសរើសផ្កាឈើលាយគ្នា ដើម្បីជាប្រយោជន៍ជាគ្រឿងបូជាព្រះពុទ្ធ ដូច្នេះហើយ ទតឃើញព្រះសាស្ដាទើបចូលទៅគាល់ ថ្វាយបង្គំហើយប្រថាប់អង្គុយក្នុងដ៏សមគួរម្ខាង ព្រះរាជ-កុមារនោះ ស្ដេចទៅទីនោះ ដោយហេតុដូចពណ៌នាមកនេះ ។

### ហត្ថកកុមារទូលសួរព្រះពុទ្ធ

បទថា **សុខមសយិត្ថ** (ផ្ទំជាសុខ) សេចក្ដីថា (ហត្ថកុមារទូលសួរព្រះពុទ្ធថា) ព្រះមានព្រះភាគ ទ្រង់ផ្ទំជាសុខស្រួលឬ ។ បទថា **អន្តរដ្ឋកោ** (នៅក្នុងចន្លោះ) សេចក្ដីថា ក្នុងចន្លោះខែ ៣ នឹងខែ ៤ ជាកាលវេលា (ដែល

សន្សើមធ្លាក់) នៅ ៨ ថ្ងៃ អធិប្បាយថា កាលវេលាដែលសន្សើមធ្លាក់ ហៅថា អន្តរដ្ឋកៈ (នៅក្នុងចន្លោះ) ព្រោះក្នុងចុងខែ ៣ មាន ៤ ថ្ងៃ (និង) ក្នុងដើមខែ ៤ មាន ៤ ថ្ងៃ ។

បទថា **ហិមបាតសមយោ** (ជាកាលសន្សើមធ្លាក់) បានដល់ ជាសម័យដែលទឹកសន្សើមធ្លាក់ ។ បទថា **ខរា** (រដិបរដុប) បានដល់ គ្រោតគ្រាត រឹង ។ បទថា **គោកណ្ដកហតា** (មានស្នាមជើងគោ) សេចក្ដីថា ត្រង់ទីដែលគោជាន់ដែលមានភក់ធ្លាក់ថ្មីៗ ភក់ផុលឡើងតាមប្រហោងក្រចកជើងគោ តាំងនៅ ។ ភក់នោះស្ងួត ព្រោះខ្យល់ និងកំដៅថ្ងៃ ដូចជាធ្មេញរណា ប៉ះត្រូវហើយរមែងឈឺ ។ ហត្ថកកុមារសំដៅយកភក់នោះ ទើបពោលថា ផ្ទៃដីក៏មានស្នាមក្រចកជើងគោ ។ មួយទៀត មានន័យថា ផ្ទៃដីដែលបែកព្រោះប្រហោងក្រចកជើងគោ ។

បទថា **វេរម្ភោ វាតោ វាយតិ** (ខ្យល់វេរម្ភៈក៏បក់មក) សេចក្ដីថា ខ្យល់រមែងបក់មកពីទិសទាំង ៤ ។ ក៏ខ្យល់ដែលបក់មកពីទិសមួយ ទិសពីរ ឬទិសបី មិនហៅថា ខ្យល់វេរម្ភៈ ។

ព្រះសាស្ដាទ្រង់ត្រិះរិះថា ព្រះរាជកុមារនេះមិនស្គាល់បុគ្គលដែលនៅជាសុខ មិនស្គាល់បុគ្គលដែលនៅជាទុក្ខក្នុងលោក តថាគតនឹងធ្វើឲ្យព្រះរាជ-

កុមារនេះស្គាល់ កាលទ្រង់នឹងអធិប្បាយព្រះធម៌ទេសនាឲ្យខ្ពស់ឡើង ទើបត្រាស់ពាក្យនេះថា **រាជកុមារ បើដូច្នោះ** ។ បណ្តាបទទាំងនោះ បទថា **យថា តេ ខមេយ្យ** (ទ្រង់ពេញព្រះទ័យយ៉ាងណា) សេចក្តីថា (ព្រះមានព្រះភាគត្រាស់សួរព្រះរាជកុមារថា) គប្បីពេញចិត្តដល់ព្រះអង្គដោយប្រការណា ។ បទថា **ឥធស្ស គឺ ឥមស្មឹ លោកេ អស្ស** (គប្បីមានលោកនេះ) ។

បទថា **គោណកត្ថតោ** (ក្រាលដោយសំពត់គោណកៈ) សេចក្តីថា គ្រែ (បល្ល័ង្ក) ដែលក្រាលដោយសំពត់កោជៅរ៍ពណ៌ខ្មៅ ដែលមានរោមប្រវែង ៤ ធ្នាប់ ។ បទថា **បដិកត្ថតោ** (ក្រាលដោយសំពត់បដិកៈ) សេចក្តីថា ក្រាលដោយកម្រាលពណ៌សធ្វើដោយរោមកែះ ។ បទថា **បដលិកត្ថតោ** (ក្រាលដោយកម្រាលដែលធ្វើដោយរោមកេះមានលាយផ្កា) ។ បទថា **កទលិមិគ-បវរបច្ចត្ថរណោ** (មានកម្រាលដ៏ប្រសើរជាវិការៈនៃស្បែកឈ្លូស) សេចក្តីថា ក្រាលដោយកម្រាលប្រភេទល្អធ្វើដោយស្បែកឈ្លូស ។ បានឮមកថា កម្រាលប្រភេទនោះ គេធ្វើដោយក្រាលស្បែកឈ្លូសលើសំពត់ស ហើយដេរភ្ជាប់ ។ បទថា **សឧត្តរច្ឆទោ** (មានសំពត់ក្រាលខាងលើ) បានដល់ (គ្រែ) ព្រមទាំងគ្រឿងប្រក់បាំងខាងលើ អធិប្បាយថា ព្រមទាំងពិតានក្រហមដែលចងទុកខាងលើ ។ បទថា **ឧភតោ លោហិតកូបធានោ** (មានខ្នើយពណ៌ក្រហមពីរ) បាន

ដល់ ខ្នើយពណ៌ក្រហមទាំងពីរដែលដាក់ទុកលើគ្រែ គឺ ខ្នើយកល់ក្បាល និង ខ្នើយកល់ជើង ។

បទថា **បជាបតិយោ** (ពួកបជាបតី) បានដល់ ភរិយាទាំងឡាយ ។ បទថា **មនាបេន បច្ចុបដ្ឋិតា អស្ស** (ចាំបម្រើដោយអាការជាទីពេញចិត្ត) សេចក្ដីថា គប្បីបានទទួលការប្រណិបត្តិ ដោយវិធីប្រណិបត្តិដែលគួរពេញចិត្ត ។ បទថា **កាយិកា វា** (ផ្លូវកាយក្ដី) សេចក្ដីថា សេចក្ដីក្ដៅដែលញុំាងកាយដែលប្រព្រឹត្តទៅដោយទ្វារ ៥ ឲ្យកំរើក ។ បទថា **ចេតសិកា វា** (ផ្លូវចិត្តក្ដី) បានដល់ ធ្វើមនោទ្វារឲ្យកម្រើក ។

បទថា **សោ រាគោ តថាគតស្ស បហីនោ** (រាគៈនោះ លះបង់ហើយ) សេចក្ដីថា រាគៈបែបនោះ ព្រះតថាគតលះបានហើយ ។ ចំណែករាគៈរបស់បុរសនោះ មិនឈ្មោះថា លះហើយទេ សូម្បីក្នុងទោសៈ និងមោហៈ ក៏មានន័យដូចគ្នានេះឯង ។

បទថា **ព្រាហ្មណោ** (ព្រាហ្មណ៍) គឺ បុគ្គលដែលបណ្ដែតបាបបានហើយ បានដល់ ព្រាហ្មណ៍ គឺ ព្រះខីណាស្រព ។ បទថា **បរិនិព្វុតោ** (រលត់ស្និទ្ធ) សេចក្ដីថា ឈ្មោះថា រលត់ស្និទ្ធ ព្រោះរលត់កិលេសមិនមានសល់ ។ បទថា **ន លិប្បតិ កាមេសុ** (មិនជាប់ក្នុងកាមទាំងឡាយ) សេចក្ដីថា មិនជាប់នៅក្នុង

វត្ថុកាម និងកិលេសកាម ដោយគ្រឿងលាប គឺ តណ្ហា និងទិដ្ឋិ ។ បទថា **សីតិភូតោ** (ជាបុគ្គលត្រជាក់) សេចក្តីថា ឈ្មោះថា ជាបុគ្គលត្រជាក់ ព្រោះមិនមានកិលេសជាហេតុឲ្យក្តៅផ្សាក្នុងខាងក្នុង ។ បទថា **និរូបធិ** (មិនមានឧបធិ) សេចក្តីថា ឈ្មោះថា មិនមានឧបធិ ព្រោះមិនមានឧបធិ គឺ កិលេស ។

បទថា **សព្វា អាសត្តិយោ ឆេត្វា** (កាត់ចំណងទាំងពួង) សេចក្តីថា កិលេសទាំងឡាយ មានតណ្ហាជាដើម ហៅថា ចំណង ។ (ព្រាហ្មណ៍) កាត់កិលេសជាគ្រឿងចងទាំងនោះអស់ហើយ ដែលផ្សាយជ្រួតជ្រាបទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។ បទថា **វិនេយ្យ ហទយេ ទរំ** (កម្ចាត់សេចក្តីខ្វល់ខ្វាយក្នុងហទយៈ) សេចក្តីថា កម្ចាត់ គឺ រម្ងាប់សេចក្តីខ្វល់ខ្វាយដែលនៅក្នុងចិត្ត ។ បទថា **សន្តិំ បប្បុយ្យ ចេតសោ** (ដល់សេចក្តីស្ងប់នៃចិត្ត) សេចក្តីថា ដល់ការរលត់កិលេសនៃចិត្ត ។ ម្យ៉ាងទៀត បទថា **ចេតសោ** នោះជាករណៈ (តតិយាវិភត្តិ) អធិប្បាយថា ត្រាស់ដឹងនិព្វានដោយចិត្ត ដូចក្នុងប្រយោគជាដើមថា **សព្វំ ចេតសា សមន្នាហរិត្វា** (ប្រមូលគ្រប់វត្ថុមកដោយចិត្ត) ។

ចប់អដ្ឋកថា ហត្ថកសូត្រទី ៥

# អដ្ឋកថា ទេវទូតសូត្រទី ៦(១)

## *“ទេវទូត ៣ ពួក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទេវទូតសូត្រទី ៦ ដូចតទៅនេះ ៈ-*

### *ទេវទូត*

[៣៧] *បទថា* ***ទេវទូតានិ*** *គឺ* ***ទេវទូតា*** *(ទេវទូតទាំងឡាយ) ។ ក៏ក្នុងបទថា* ***ទេវទូតានិ*** *នេះ មានអត្ថរបស់ពាក្យដូចតទៅនេះ មច្ចុ ឈ្មោះថា* ***ទេវៈ*** *ទូតរបស់ទេវៈនោះ ឈ្មោះថា* ***ទេវទូត*** *អធិប្បាយថា មនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ ហៅថា ទេវទូត ព្រោះដូចជាដាស់តឿនថា ឥឡូវនេះ លោកកំពុងចូលទៅជិតសេចក្តីស្លាប់ ដោយបំណងនឹងឲ្យកើតសេចក្តីសង្វេគ ។*

*មួយទៀត ឈ្មោះថា ទេវទូត ព្រោះអត្ថថា ជាទូតដូចទេវតាខ្លះ ។ អធិប្បាយថា កាលទេវតាតាក់តែងប្រដាប់ប្រដា ហើយឈរនិយាយនៅក្នុងអាកាសថា លោកនឹងស្លាប់ក្នុងថ្ងៃឯណោះ ពាក្យនិយាយរបស់ទេវតានោះជាគួរជឿ យ៉ាងណា សូម្បីមនុស្សចាស់ មនុស្សឈឺ និងអ្នកស្លាប់ ក៏ដូច្នោះដែរ កាលប្រាកដ ក៏ដូចជាដាស់តឿនថា សូម្បីលោកក៏មានសភាពយ៉ាងនេះ ជាធម្មតា និងពាក្យនិយាយនោះ របស់មនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់*

---

*(១) បិដក ជាទូតសូត្រ ។*

ទាំងនោះ ក៏ដូចជាពាក្យព្យាករណ៍របស់ទេវតា ព្រោះមិនប្រែប្រួលទៅជាយ៉ាង ដទៃឡើយព្រោះហេតុនោះ ទើបឈ្មោះថា ទេវទូត ព្រោះជាទូតដូចទេវតា ។

ម្យ៉ាងទៀត ឈ្មោះថា ទេវទូត ព្រោះជាទូតរបស់វិសុទ្ធិទេពក៏បាន ។ អធិប្បាយថា ព្រះពោធិសត្វគ្រប់អង្គ ឃើញមនុស្សចាស់ មនុស្សឈឺ មនុស្ស ស្លាប់ និងអ្នកបួសប៉ុណ្ណោះ ក៏ដល់សេចក្ដីសង្វេគ ហើយចេញបួស ។ មនុស្ស ចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួស ឈ្មោះថា ទេវទូត ព្រោះជា ទូតរបស់វិសុទ្ធិទេពទាំងឡាយខ្លះ ដូចពណ៌នាមកនេះ ។

តែក្នុងសូត្រនេះ លោកពោលថា **ទេវទូតានិ** ព្រោះលិង្គវិបល្លាស ។

## យមរាជសួរទេវទូត

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ផ្ដើមពាក្យថា (ប្រព្រឹត្ត) **ទុច្ចរិតដោយកាយ** ជាដើម ។

ឆ្លើយថា ដើម្បីទ្រង់សម្ដែងដល់កម្មរបស់បុគ្គលចូលដល់ឋានៈដែល ជាហេតុ (ឲ្យយមរាជ) សួរដល់ឋានៈរបស់ទេវទូតទាំងឡាយ ។

ពិតហើយ សត្វនេះ រមែងកើតក្នុងនរកដោយកម្មនេះ ។ យមរាជ រមែងសាកសួរដល់ទេវទូតទាំងឡាយ ។ បណ្ដាបទទាំងនោះ បទថា **កាយេន ទុច្ចរិតំ ចរតិ** (ប្រព្រឹត្តទុច្ចរិតដោយកាយ) សេចក្ដីថា ប្រព្រឹត្តទុច្ចរិត ៣ យ៉ាង

តាមផ្លូវកាយទ្វារ ។ បទថា **វាចាយ** (ដោយវាចា) សេចក្តីថា ប្រព្រឹត្តទុច្ចរិត ៤ យ៉ាង តាមផ្លូវវចីទ្វារ ។ បទថា **មនសា** (ដោយចិត្ត) សេចក្តីថា ប្រព្រឹត្តទុច្ចរិត ៣ យ៉ាង តាមផ្លូវមនោទ្វារ ។

## នាយនិរយបាល មានពិតឬទេ

ក្នុងបទថា **តមេនំ ភិក្ខវេ និរយបាលា** (ម្នាលភិក្ខុទាំងឡាយ នាយនិរយបាល...បុគ្គលនោះ) នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ព្រះថេរៈពួកខ្លះពោលថា នាយនិរយបាលមិនមានទេ កម្មនោះឯង រមែងដាក់ទោស ដូចជាភាពយន្ត ដូច្នោះ ។ ពាក្យនោះ ត្រូវជំទាស់ទុកក្នុងគម្ពីរអភិធម្មហើយ ដោយន័យមានជាដើមថា ក្នុងនរក មាននាយនិរយបាល និងថា អ្នកដាក់ទោសក៏មានហើយ ។ ប្រៀបដូចក្នុងមនុស្សលោក អ្នកដាក់ទោសមាន យ៉ាងណា ក្នុងនរក នាយនិរយបាលក៏មាន ដូច្នោះដែរ ។

## យមរាជ គឺ វេមានិកប្រេត

បទថា **យមស្ស រញ្ញោ** (ដល់យមរាជ) សេចក្តីថា ស្តេចវេមានិកប្រេត ឈ្មោះថា យមរាជ វេលាមួយ សោយសម្បត្តិ មានដើមកល្បព្រឹក្សទិព្វ ឧទ្យានទិព្វ និងពួកនាងទេពអប្សរជាដើម ក្នុងវិមានទិព្វ ។ វេលាមួយ សោយផលរបស់កម្ម ។ យមរាជអ្នកតាំងនៅក្នុងធម៌ជាធម្មរាជា មានហើយ ។

និងយមរាជនោះ ក៏មិនមែនមានតែមួយព្រះអង្គឯង ប៉ុន្តែថា មានដល់ ៤ អង្គ ត្រង់ ៤ ទ្វារ ។

## អធិប្បាយសព្ទ អមេត្តេយ្យៈ[១] អព្រហ្មញ្ញៈ

បទថា **អមេត្តេយ្យា** (បុគ្គលមិនចម្រើនដល់មាតា) សេចក្តីថា បុគ្គលដែលចម្រើនដល់មាតា ឈ្មោះថា មត្តេយ្យៈ អធិប្បាយថា ជាអ្នកបដិបត្តិត្រូវក្នុងមាតា បុគ្គលមិនចម្រើនដល់មាតា ឈ្មោះថា អមេត្តេយ្យៈ អធិប្បាយថា អ្នកបដិបត្តិខុសក្នុងមាតា ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។

ក្នុងបទថា **អព្រហ្មញ្ញា** (អ្នកបដិបត្តិខុសក្នុងព្រាហ្មណ៍) នេះ មានអធិប្បាយថា ព្រះខីណាស្រព ឈ្មោះថា ព្រាហ្មណ៍ បុគ្គលដែលបដិបត្តិខុសក្នុងព្រាហ្មណ៍ទាំងនោះ ឈ្មោះថា អព្រហ្មញ្ញៈ ។

បទថា **សមនុយុញ្ជតិ** (សាកសួរ) សេចក្តីថា យមរាជឲ្យនាំរបៀបក្នុងការសាកសួរ មកសាកសួរ ។ តែកាលឲ្យបញ្ជាក់ដល់លទ្ធិ ឈ្មោះថា សាកសួរ ។ កាលសួរដល់ហេតុ ឈ្មោះថា សួរតាមលំដាប់ ។ ដោយបទថា **នាទ្ទសំ** (ខ្ញុំមិនបានឃើញ) សត្វនរកពោលយ៉ាងនោះ សំដៅដល់ថា មិនមានទេវទូតអ្វីៗ ដែលត្រូវបញ្ជូនទៅក្នុងសំណាក់របស់ខ្លួន ។

---

(១) អដ្ឋកថា អមត្តេយ្យៈ , បិដក អមេត្តេយ្យៈ យកតាមបិដក ។

## យមរាជជាស់តឿន

គ្រានោះ យមរាជជ្រាបថា បុគ្គលនេះនៅកំណត់អត្ថរបស់ពាក្យនិយាយមិនបាន ត្រូវការនឹងឲ្យគេកំណត់បាន ទើបពោលពាក្យជាដើមថា **អម្ភោ បុរិស** ដូច្នេះចំពោះគេ ។ បណ្តាបទទាំងនោះ បទថា **ជិណ្ណំ** (ចាស់ហើយ) បានដល់ទ្រុឌទ្រោមព្រោះជរា ។ បទថា **គោបានសិវង្កំ** (ខ្នងកោង) បានដល់ កោងដូចបង្កង់ផ្ទះ ។ បទថា **ភោគ្គំ** (គម) បានដល់ ទោរចុះ ។ យមរាជសម្តែងដល់ភាវៈដែលបុគ្គលនោះ (មានខ្នង) កោងទ្រុះឯង ដោយបទថា **គម** សូម្បីនេះ ។

បទថា **ទណ្ឌបរាយនំ** (មានឈើច្រត់នាំមុខ) គឺ មានឈើច្រត់ជាទីពឹងបានដល់ មានឈើច្រត់ជាសម្លាញ់ ។ បទថា **បវេធមានំ** (ញើរញ័រ) បានដល់ញ័រហើយ ។ បទថា **អាតុរំ** (រសាប់រសល់) បានដល់ ឈឺព្រោះជរា ។ បទថា **ខណ្ឌទន្តំ** (ធ្មេញបាក់) បានដល់ ឈ្មោះថា មានធ្មេញបាក់ ព្រោះឈឺដោយហេតុនៃជរា ។ បទថា **បលិតកេសំ** (សក់ស្កូវ) បានដល់ មានសក់ស ។ បទថា **វិលូនំ** បានដល់ ក្បាលធក ដូចត្រូវនរណាដកយកសក់ទៅ ។ បទថា **ខលិតសិរំ** បានដល់ ក្បាលទំពែក ។ បទថា **វលិតំ** បានដល់ ស្បែកជ្រីវជ្រួញ ។ បទថា **តិលកាហតគត្តំ** បានដល់ មានខ្លួនជាស់ដោយប្រជ្រុយ ។ បទថា **ជរាធម្មោ** (មានការចាស់ជាធម្មតា) សេចក្តីថា មានជរាជាសភាព គឺ

មិនផុតពីជរាទៅបាន ធម្មតាថា ជរា រមែងប្រព្រឹត្តទៅខាងក្នុងខ្លួនយើងនេះឯង ។ សូម្បីក្នុងពីរបទតមកថា **ព្យាធិធម្មោ** (មានការឈឺជាធម្មតា) **មរណធម្មោ** (មានសេចក្តីស្លាប់ជាធម្មតា) ក៏មានន័យតែម្យ៉ាងដូចគ្នានេះឯង ។

## ទេវទូតទី ១

ក្នុងបទថា **បឋមំ ទេវទូតំ សមនុយុញ្ជិត្វា** (លុះសាកសួរដល់ទេវទូតទី ១ ហើយ) នេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ធម្មតាថា សត្វអ្នកទ្រុឌទ្រោម ព្រោះជរា រមែងពោលយ៉ាងនេះថា មើលចុះ លោកដ៏ចម្រើនទាំងឡាយ សូម្បីខ្ញុំក៏បានជាកម្លោះ សម្បូរណ៍ដោយកម្លាំងដៃ កម្លាំងដៃ និងការរហ័សរហួនដូចលោកទាំងឡាយមកហើយ (ប៉ុន្តែថា) សេចក្តីសម្បូរណ៍ដោយកម្លាំង និងការរហ័សរហួនទាំងនោះរបស់ខ្ញុំ វិនាសទៅអស់ហើយ សូម្បីដៃ និងជើងរបស់ខ្ញុំ ក៏មិនធ្វើនាទីរបស់ដៃ និងជើង ខ្ញុំក្លាយមកជាមនុស្សយ៉ាងនេះ ក៏ព្រោះមិនផុតពីជរា ហើយមិនមែនតែចំពោះខ្ញុំប៉ុណ្ណោះ សូម្បីពួកលោក ក៏មិនផុតពីជរាទៅបានដូចគ្នា ដូចជរាមកដល់ខ្ញុំយ៉ាងណា ជរាក៏នឹងមកសូម្បីដល់ពួកលោកដូច្នោះ ព្រោះជរានោះមកដូចដែលពោលមកនេះ ក្នុងថ្ងៃខាងមុខទុំះឯង សូមឲ្យលោកទាំងឡាយចូរធ្វើតែសេចក្តីល្អចុះ ។ ដោយហេតុនោះ សត្វដែលទ្រុឌទ្រោមព្រោះជរានោះ ទើបឈ្មោះថា **ទេវទូត** ។

## ទេវទូតទី ២

បទថា **អាពាធិកំ** បានដល់ ឈឺ ។ បទថា **ទុក្ខិតំ** បានដល់ មានទុក្ខ ។ បទថា **ពាឡ្ហគិលានំ** (ឈឺធ្ងន់) ប្រែថា ជាជំងឺធ្ងន់ហួសប្រមាណ ។ សូម្បីក្នុងទីនេះ ធម្មតាថា សត្វដែលឈឺ រមែងពោលដោយសេចក្ដីយ៉ាងនេះថា មើលចុះលោកដ៏ចម្រើនទាំងឡាយ សូម្បីខ្ញុំក៏ជាអ្នកមិនមានរោគដូចពួកលោកមកហើយ ប៉ុន្តែថា ឥឡូវនេះ ខ្ញុំត្រូវជំងឺគ្របសង្កត់ លិចនៅក្នុងបស្សាវៈឧច្ចារៈរបស់ខ្លួន សូម្បីតែនឹង (ញាំងកាយ) ឲ្យក្រោកឡើងក៏មិនអាច ដៃជើងរបស់ខ្ញុំសូម្បីនឹងមាននៅ ក៏ធ្វើនាទីរបស់ដៃជើងមិនបាន ខ្ញុំក្លាយជាមនុស្សដូច្នេះ ក៏ព្រោះមិនរួចផុតចាកព្យាធិ (សេចក្ដីឈឺ) ហើយក៏មិនមែនតែចំពោះខ្ញុំប៉ុណ្ណោះ សូម្បីពួកលោក ក៏មិនផុតពីព្យាធិដូចគ្នា ដូចព្យាធិមកដល់ខ្ញុំ យ៉ាងណា ព្យាធិក៏នឹងមកសូម្បីដល់ពួកលោក ដូច្នោះ ព្រោះព្យាធិនោះមក ដូចដែលពោលមកនេះក្នុងថ្ងៃខាងមុខពិត សូមឲ្យលោកទាំងឡាយចូរធ្វើតែសេចក្ដីល្អចុះ ។ ព្រោះហេតុនោះ សត្វដែលឈឺនោះ ទើបឈ្មោះថា **ទេវទូត** ។

## ទេវទូតទី ៣

ក្នុងបទថា **ឯកាហមតំ** (ដែលស្លាប់ហើយមួយថ្ងៃ) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ សត្វនោះស្លាប់បានមួយថ្ងៃ ព្រោះហេតុនោះ ទើបឈ្មោះ

ថា **ឯកាហមតៈ** ។ (លោកមិនឃើញ) សត្វស្លាប់ក្នុងមួយថ្ងៃនោះ (ឬ) ។ សូម្បីក្នុងពីរបទតមក (ស្លាប់ហើយពីរថ្ងៃខ្លះ បីថ្ងៃខ្លះ) ក៏មានន័យនេះឯង ។ សាកសព ឈ្មោះថា **ឧទ្ធុមាតកៈ** ព្រោះឡើងប៉ោងដោយការៈដែលហើមប៉ោង ប៉ោងឡើងតាមលំដាប់ រាប់តាំងពីអស់ជីវិតទៅ ដូចជាស្នប់ដែលពេញដោយខ្យល់ដូច្នោះ ។

សាកសពដែលមានពណ៌ (ខៀវ) ប្រេះទូទៅ ហៅថា វិនីលៈ ។ វិនីលៈនោះឯង ឈ្មោះថា វិនីលកៈ ។ (លោកមិនឃើញ) សាកសពពណ៌ខៀវនោះ (ទេឬ) ។ម្យ៉ាងទៀត សាកសពដែលមានពណ៌ខៀវនោះ រាប់ថា គួរស្អៀសព្រោះជារបស់គួរខ្ពើម ។ បទថា **វិបុព្វកំ** (មានខ្ទុះហូរ) បានដល់ សាកសពដែលមានខ្ទុះហូរចេញ អធិប្បាយថា សាកសពដែលប្រឡាក់ប្រឡូសទៅដោយខ្ទុះដែលហូរចេញអំពីទីដែលប្រេះ ។

ក្នុងបទថា **តតិយំ ទេវទូតំ** (ទេវទូតទី ៣) នេះ មានអធិប្បាយថា ធម្មតាថា សត្វស្លាប់ រមែងប្រាប់នូវអត្ថយ៉ាងនេះថា មើលចុះ លោកដ៏ចម្រើនទាំងឡាយ លោកទាំងឡាយ (ចូរមើល) ខ្ញុំត្រូវលះបង់ចោលទុកក្នុងព្រៃខ្មោចស្រស់ ដល់នូវសភាពដែលហើមប៉ោងជាដើម ក៏ខ្ញុំក្លាយជាដូច្នេះ ក៏ព្រោះមិនផុតពីសេចក្តីស្លាប់ ក៏មិនមែនចំពោះខ្ញុំប៉ុណ្ណោះ សូម្បីពួកលោកក៏មិនផុតអំពី

សេចក្ដីស្លាប់ដូចគ្នា ដូចសេចក្ដីស្លាប់មកដល់ខ្ញុំ យ៉ាងណា ក៏នឹងមកដល់ពួកលោកដូច្នោះ ព្រោះសេចក្ដីស្លាប់នោះ រមែងមកដល់ក្នុងថ្ងៃខាងមុខពិត សូមលោកទាំងឡាយចូរធ្វើតែសេចក្ដីល្អចុះ ។ ព្រោះហេតុនោះ សត្វស្លាប់នោះទើបចាត់ជា **ទេវទូត** ។

## នរណាត្រូវសួរដល់ទេវទូត នរណាមិនត្រូវសួរ

សួរថា នរណាទទួលបានការសាកសួរដល់ទេវទូត ។ ឆ្លើយថា បុគ្គលណាធ្វើបាបទុកច្រើន បុគ្គលនោះ (ស្លាប់ហើយ) ទៅកើតក្នុងនរកភ្លាម ។ តែបុគ្គលណាធ្វើបាបបន្តិចបន្តួច បុគ្គលនោះរមែងបានការសាកសួរដល់ទេវទូត ។

ឧបមា ដូចរាជបុរសចាប់ចោរបានព្រមទាំងភស្តុតាង រមែងធ្វើទោសដែលគួរធ្វើភ្លាម មិនចាំបាច់វិនិច្ឆ័យ តែអ្នកដែលគេសង្ស័យចាប់បាន គេនឹងនាំទៅកាន់ទីសម្រាប់វិនិច្ឆ័យ បុគ្គលនោះ រមែងបានទទួលការវិនិច្ឆ័យ យ៉ាងណា ការឧបមេយ្យនេះ ក៏ដូច្នោះ ។ ព្រោះអ្នកដែលមានបាបកម្មតិចតួច រលឹកបានតាមធម្មតារបស់ខ្លួនឯងខ្លះ ត្រូវជាស់តឿនឲ្យរលឹក ទើបរលឹកបានខ្លះ ។

## ឧបមាអ្នករលឹកបានតាមធម្មតារបស់ខ្លួន

ក្នុងការរលឹកបានឯង និងត្រូវជាស់តឿនឲ្យរលឹកនោះ មានឧបមាដូចតទៅនេះ ។

ទមិឡឈ្មោះទីឃជយន្តៈ រលឹកបានឯងតាមធម្មតារបស់ខ្លួន ។ បានឮមកថា ទមិឡនោះ យកសំពត់ក្រហមបូជាអាកាសចេតិយ នៅឯសុមនគិរិ-មហាវិហារ តមក (ស្លាប់ទៅ) កើតក្នុងទីជិតឧស្សទនរក បានឮសំឡេងអណ្ដាតភ្លើង ទើបរលឹកដល់សំពត់ (ក្រហម) ដែលខ្លួនយកបូជា (អាកាសចេតិយ) គេក៏ (ចុតិ) ទៅកើតក្នុងសួគ៌ ។

មានម្នាក់ទៀត ថ្វាយសំពត់សាដកសាច់រលោងដល់ភិក្ខុកម្លោះ ដែលជាបុត្រ វេលាដែលដាក់សំពត់ទុកទៀបជើង (លោកកូន) ក៏កាន់យកនិមិត្តក្នុងសំឡេងថា (ផ្ទាំងសំពត់) ។ តមក បុរសនោះ (ក៏ស្លាប់ទៅ) កើតក្នុងទីជិតឧស្សទនរក រលឹកដល់សំពត់សាដកនោះបាន ព្រោះ (បានឮ) សំឡេងអណ្ដាតភ្លើង ទើប (ចុតិ) ទៅកើតក្នុងសួគ៌ ។

ជនទាំងឡាយដែលកើតក្នុងនរក រលឹកដល់កុសលកម្មបានតាមធម្មតារបស់ខ្លួនហើយ (ចុតិទៅ) កើតក្នុងសួគ៌ ដូចពណ៌នាមកនេះឯង ។

ចំណែកសត្វអ្នករលឹកមិនបានតាមធម្មតារបស់ខ្លួន យមរាជរមែងសួរដល់ទេវទូត ៣ ។ បណ្ដាសត្វទាំងនោះ ខ្លះរលឹកបានត្រឹមតែទេវទូតទី ១ ប៉ុណ្ណោះ (តែ) ខ្លះរលឹកបានដល់ទេវទូតទី ២ និងទី ៣ ។ សត្វណារលឹកមិនបានសូម្បីទេវទូតទាំង ៣ យមរាជនឹងជាស់តឿនសត្វនោះឲ្យរលឹកបានឯង ។

## ឧបមាអ្នកដែលត្រូវជាស់តឿន

បានឮថា អាមាត្រម្នាក់បូជាព្រះមហាចេតិយ ដោយផ្កាម្លិះ ១ ផ្ទាំង ហើយបានចែកចំណែកបុណ្យឲ្យដល់យមរាជ ។ នាយនិរយបាលទាំងឡាយ បាននាំគេដែលកើតក្នុងនរកដោយអកុសលកម្ម ទៅកាន់សំណាក់យមរាជ ។ កាលគេរលឹកដល់កុសលមិនបានដោយទេវទូតទាំង ៣ យមរាជទើបពិចារណាឯង បានជាស់តឿនគេឲ្យរលឹកថា លោកបានបូជាព្រះមហាចេតិយដោយផ្កាម្លិះ ១ ផ្ទាំង ហើយបានចែកចំណែកបុណ្យឲ្យយើងមិនមែនឬ ។

វេលានោះ គេក៏រលឹកបាន ទើបទៅកើតក្នុងទេវលោក ចំណែកយមរាជសូម្បីត្រួតមើលដោយព្រះអង្គឯងហើយ កាលមិនឃើញ ក៏នឹងទ្រង់ស្ងៀមដោយទ្រង់ត្រិះរិះថា សត្វនេះនឹងសោយទុក្ខធំ ។

## ការដាក់ទោសក្នុងនរក

បទថា **តត្តំ អយោខីលំ** (ដែកគោលដ៏ក្តៅ) សេចក្តីថា នាយនិរយបាលទាំងឡាយ ចាប់អត្តភាព (ធំ) ប្រមាណ ៣ គាវុត ឲ្យដេកផ្ងារលើផែនដីលោហៈដែលភ្លើងឆេះ ហើយយកដែកគោលប៉ុនដើមត្នោត បោះចុះទៅត្រង់ដៃខាងស្តាំ ត្រង់ដៃខាងឆ្វេងជាដើម ក៏ដូចគ្នា ។ នាយនិរយបាលចាប់សត្វនរកនោះ ឲ្យដេកផ្កាប់មុខខ្លះ ផ្អៀងទៅឆ្វេងខ្លះ ផ្អៀងទៅស្តាំខ្លះ ឲ្យដេកផ្ងារ ហើយដាក់ទោស

សត្វនរកនោះ ដូច្នោះ ។

បទថា **សំវេសេត្វា** (ចាប់ឲ្យដេក) សេចក្តីថា (នាយនិរយបាល) ចាប់អត្តភាពប្រមាណ ៣ គាវុត ឲ្យដេកលើផែនដីលោហៈដែលភ្លើងឆេះ ។ បទថា **កុឋារីហិ** (ដោយដឹង) សេចក្តីថា ចាំងដោយដឹងធំប៉ុនផ្ទះកំពូល ។ ឈាមហូរដូចជាទន្លេ ។ អណ្តាតភ្លើងឆេះពីផែនដីលោហៈជាប់ ត្រង់កន្លែងចាំងនោះ ។ ទុក្ខធំកើតឡើង (ដល់សត្វនរក) ។ ចំណែកនាយនិរយបាលទាំងឡាយកាលចាំង ក៏ចាំងឲ្យជា ៨ ជ្រុងខ្លះ ៦ ជ្រុងខ្លះ ដូចវាយខ្សែបន្ទាត់ចាំងឈើ ។ បទថា **វាសីហិ** (ដោយកាំបិតព្រា) គឺ ដោយកាំបិតទាំងឡាយមានទំហំប៉ុនចង្អេរធំ ។

បទថា **រថេ យោជេត្វា** (ទឹមរថ) សេចក្តីថា (នាយនិរយបាលទាំងឡាយ) ទឹមសត្វនរកនោះ ឲ្យទាញរថព្រមទាំងនឹម ខ្សែ ប្រែក កង់រថ ទូករទេះ និងជន្ទួញ ដែលមានភ្លើងឆេះសព្វ ។ បទថា **មហន្តំ** (ធំ) គឺ មានប្រមាណប៉ុនផ្ទះកំពូលខ្នាតធំ ។ បទថា **អារោបេន្តិ** (ឲ្យឡើង) សេចក្តីថា វាយដោយញញួរដែកដែលភ្លើងឆេះសន្ធោសន្ធៅ ហើយបង្គាប់ឲ្យឡើង (ភ្នំភ្លើង) ។ បទថា **សកឹបិ ឧទ្ធំ** (គ្រាខ្លះក៏ផុលឡើង) សេចក្តីថា សត្វនរកនោះ (ត្រូវភ្លើងឆេះ) ផុលឡើងខាងលើ លិចចុះខាងក្រោម និងអណ្តែតទៅខាងទទឹង ដូចបាយដែល

ដាំពុះក្នុងឆ្នាំងក្តៅផុលឡើង ដូច្នោះ ។ បទថា **មហានិរយេ** (ក្នុងមហានរក) គឺ ក្នុងអវិចីមហានរក ។

បទថា **ភាគសោ មិតោ** (បែងចេញជាចំណែក ៗ) គឺ (មហានរក) បែងចែកទុកជាចំណែកៗ ។ បទថា **បរិយន្តោ** (ព័ទ្ធជុំវិញ) គឺ ត្រូវព័ទ្ធទុក ។ បទថា **អយសា** (ដោយផែនដែក) គឺ ត្រូវប្រក់ខាងលើដោយផែនដែក ។ បទថា **សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ** (ផ្សាយកំដៅ) សេចក្តីថា អណ្តាតភ្លើង តាំងនៅហើយយ៉ាងនោះ ។ កាលសត្វនរកនោះឈរមើលនៅក្នុងទី ១០០ យោជន៍ ដោយជុំវិញ ភ្នែកក៏នឹងផ្ទុះចេញមកដូចដុំសាច់ ២ ដុំ ដូច្នោះ ។

បទថា **ហីនកាយូបគា** (ចូលដល់កាយថោកទាប) សេចក្តីថា ជាអ្នកចូលដល់កំណើតដែលថោកទាប ។ បទថា **ឧបាទានេ** (ក្នុងសេចក្តីប្រកាន់មាំ) បានដល់ ក្នុងសេចក្តីប្រកាន់មាំដោយតណ្ហា និងទិដ្ឋិ ។ បទថា **ជាតិមរណសម្ភវេ** (ដែលជាដែនកើតនៃជរា និងមរណៈ) បានដល់ ជាហេតុនៃជាតិ និងមរណៈ ។ បទថា **អនុបាទា** (ដកសេចក្តីប្រកាន់) បានដល់ ព្រោះមិនប្រកាន់ដោយឧបាទាន ៤ ។ បទថា **ជាតិមរណសង្ខយេ** (ដែលជាទីអស់នៃជាតិ និងមរណៈ) សេចក្តីថា រួចផុតព្រោះនិព្វាន ដែលជាដែនអស់ទៅនៃជាតិ និង

*មរណៈ ។*

*បទថា* ***ទិដ្ឋធម្មាភិនិព្វុតា*** *(រលត់ទុក្ខបានក្នុងបច្ចុប្បន្នជាតិ) សេចក្ដីថា រលត់ស្និទ្ធហើយ ក្នុងព្រោះរលត់កិលេសទាំងអស់ក្នុងទិដ្ឋធម្ម គឺ ក្នុងអត្តភាពនេះ ទុំះឯង ។ បទថា* ***សព្វំ ទុក្ខំ ឧបច្ចគុំ*** *(កន្លងទុក្ខទាំងអស់បាន) សេចក្ដីថា កន្លងវដ្ដទុក្ខទាំងអស់ ។*

ចប់អដ្ឋកថា ទូតសូត្រទី ៦

# អដ្ឋកថា បឋមរាជសូត្រទី ៧

## *“ស្តេចលោកបាលត្រួតមនុស្សលោក”*

*គប្បីជ្រាបវិនិច្ឆ័យ បឋមរាជសូត្រទី ៧ ដូចតទៅនេះ ៖-*

### *ទេវតាត្រួតពិនិត្យមើលមនុស្សលោក*

*[៣៨] បទថា **អមច្ចា បារិសជ្ជា** (អាមាត្យជាបរិស័ទ) បានដល់បារិចារិកទេវតា (ទេវតាអ្នកបម្រើ) ។ បទថា **ឥមំ លោកំ អនុវិចរន្តិ** (ត្រួតមើលលោកនេះ) សេចក្តីថា បានឮថា ក្នុងថ្ងៃទី ៨ នៃបក្ខ ស្តេចសក្កទេវរាជទ្រង់បញ្ជាស្តេចមហារាជទាំង ៤ ថា លោកទាំងឡាយ ថ្ងៃនេះជាថ្ងៃ ៨ នៃបក្ខ លោកទាំងឡាយចូរទៅកាន់មនុស្សលោក ហើយចូរយកឈ្មោះ និងគោត្ររបស់មនុស្សដែលធ្វើបុណ្យមក ។ ស្តេចមហារាជទាំង ៤ នោះ ក៏ត្រឡប់ទៅបញ្ជាបរិវាររបស់ខ្លួនថា ទៅចុះលោកទាំងឡាយ លោកចូរទៅកាន់មនុស្សលោក សរសេរឈ្មោះ និងគោត្រមនុស្សដែលធ្វើបុណ្យក្នុងក្រាំងមាស ហើយនាំមកចុះ ។ បរិវារទាំងនោះធ្វើតាមពាក្យបញ្ជានោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ត្រួតមើលលោកនេះ** ដូច្នេះ ។ បទថា **កច្ចិ ពហូ** (មនុស្សចំណែកច្រើន...ខ្លះ ឬ) ជាដើម ព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្តែងអាការត្រួតមើលរបស់ទេវតាទាំងនោះ ។ ពិតហើយ ទេវតាទាំងឡាយកាល*

ទៅត្រួតមើលហើយយ៉ាងនេះ ឈ្មោះថា ត្រួតមើល (លោកនេះ) ។

## ការរក្សាឧបោសថ

បណ្ដាបទទាំងនោះ បទថា **ឧបោសថំ ឧបវសន្តិ** (បកតិឧបោសថ) សេចក្ដីថា មនុស្សទាំងឡាយអធិដ្ឋានអដ្ឋឧបោសថមួយខែ ៨ ដង ។ បទថា **បដិជាគរោន្តិ** (បដិជាគរឧបោសថ) សេចក្ដីថា ការបដិបត្តិឧបោសថសីលអមថ្ងៃបកតិឧបោសថនោះ ។ ជនទាំងឡាយ កាលបដិបត្តិបដិជាគរឧបោសថ-សីលនោះ រមែងរក្សាដោយការទទួល និងការជូនថ្ងៃឧបោសថ ៤ ថ្ងៃ ក្នុងកន្លះខែ (គឺ) កាលនឹងទទួលឧបោសថថ្ងៃ ៥ នៃបក្ខ ក៏ត្រូវរក្សាឧបោសថក្នុងថ្ងៃ ៤ និងជូនឧបោសថក្នុងថ្ងៃ ៦ នៃបក្ខ ។ កាលនឹងទទួលឧបោសថថ្ងៃ ៨ នៃបក្ខ ក៏ត្រូវរក្សាឧបោសថក្នុងថ្ងៃ ៧ និងជូនឧបោសថក្នុងថ្ងៃ ៩ នៃបក្ខ ។ កាលនឹងរក្សាឧបោសថថ្ងៃ ១៤ នៃបក្ខ ។ ក៏ត្រូវរក្សាឧបោសថក្នុងថ្ងៃ ១៣ និងជូនឧបោសថក្នុងថ្ងៃ ១៥ នៃបក្ខ ។ កាលនឹងទទួលឧបោសថថ្ងៃ ១៥ ក្នុងបក្ខ ក៏ត្រូវរក្សាឧបោសថក្នុងថ្ងៃ ១៤ និងជូនឧបោសថក្នុងថ្ងៃ ១ រោច ។

បទថា **បុញ្ញានិ ករោន្តិ** (ធ្វើបុណ្យទាំងឡាយ) សេចក្ដីថា មនុស្សទាំងឡាយ ធ្វើបុណ្យមានប្រការផ្សេងៗ មានការដល់សរណៈ ទទួលនិច្ចសីល បូជាដោយផ្កាឈើ ស្ដាប់ធម៌ តាំងប្រទីបពាន់ដួង និងសាងវិហារជាដើម ។

ទេវតាទាំងនោះ ទៅយ៉ាងនេះហើយ សរសេរឈ្មោះ និងគោត្ររបស់មនុស្ស អ្នកធ្វើបុណ្យចុះក្នុងក្រាំងមាស ហើយនាំមកថ្វាយស្តេចមហារាជទាំង ៤ ។ បទថា **បុត្តា ឥមំ លោកំ អនុវិចរន្តិ** (ពួកបុត្ត...ត្រួតមើលលោកនេះ) សេចក្តីថា (ឱរសរបស់ស្តេចមហារាជទាំង ៤) ត្រួតមើល ព្រោះត្រូវស្តេចមហារាជទាំង ៤ បញ្ជូនទៅ តាមន័យមុនទុំះឯង ។ បទថា **តទហុ** គឺ **តំ ទិវសំ** (ក្នុងថ្ងៃនោះ) ។ បទថា **ឧបោសថេ** បានដល់ ក្នុងថ្ងៃឧបោសថ ។

បទថា **សចេ ភិក្ខវេ អប្បកា ហោន្តិ** (ម្នាលភិក្ខុទាំងឡាយ បើមនុស្សចំនួនតិច) សេចក្តីថា បរិស័ទអាមាត្ររបស់ស្តេចមហារាជទាំង ៤ ចូលទៅកាន់គាម និគម និងរាជធានីនោះៗ ។ ក៏ទេវតាដែលអាស្រ័យនៅតាមគាម និគម និងរាជធានីនោះៗ ជ្រាបថា អាមាត្ររបស់ស្តេចមហារាជទាំងឡាយមកហើយ ក៏នាំគ្នាកាន់គ្រឿងបណ្ណាការទៅកាន់សំណាក់របស់ទេវតាទាំងនោះ ។

ទេវតាអាមាត្រជាបរិស័ទរបស់ស្តេចមហារាជទាំង ៤ នោះ ទទួលគ្រឿងបណ្ណាការហើយ ក៏សួរដល់ការធ្វើបុណ្យរបស់មនុស្សទាំងឡាយ តាមន័យដែលពោលទុកថា លោកអ្នកនិរទុក្ខទាំងឡាយ មនុស្សចំនួនច្រើនទំនុកបម្រុងមាតាឬទេ ។ កាលទេវតាប្រចាំគាម និគម និងរាជធានីរាយការថា មែនហើយលោកអ្នកនិរទុក្ខ ក្នុងស្រុកនេះ បុគ្គលឯណោះ និងបុគ្គលឯណោះបានធ្វើបុណ្យ

ហើយ ក៏ចុះឈ្មោះ និងគោត្ររបស់មនុស្សទាំងនោះទុក ហើយទៅក្នុងទីដទៃ ។

តមកក្នុងថ្ងៃ ១៤ នៃបក្ខ សូម្បីបុត្ររបស់ស្តេចមហារាជទាំង ៤ ក៏កាន់យកក្រាំងមាសនោះ ហើយត្រួតមើលដោយន័យនោះឯង កត់ឈ្មោះ និងគោត្រទុក ។ ក្នុងថ្ងៃ ១៥ នៃបក្ខ ដែលជាថ្ងៃឧបោសថនោះ ស្តេចមហារាជទាំង ៤ ក៏កត់ឈ្មោះ និងគោត្រក្នុងក្រាំងមាសនោះ តាមន័យនោះ ។ ស្តេចមហារាជទាំង ៤ នោះ ជ្រាបថា វេលានេះមានមនុស្សចំនួនតិច វេលានេះមានមនុស្សចំនួនច្រើន តាមចំនួនក្នុងក្រាំងមាស ។ ព្រះមានព្រះភាគទ្រង់សំដៅយកប្រការនោះ ទើបត្រាស់ពាក្យជាដើមថា **ម្នាលភិក្ខុទាំងឡាយ បើ...មនុស្សចំនួនតិចជាអ្នកទំនុកបម្រុងមាតា** ។ ដូច្នេះ ។

## ទេវតាជាន់តាវត្តិង្ស

បទថា **ទេវានំ តាវត្តឹសានំ** (ពួកទេវតាជាន់តាវត្តឹង្ស) សេចក្តីថា ទេវតាទាំងឡាយបាននាមយ៉ាងនេះថា (តាវត្តឹង្ស) ព្រោះអាស្រ័យទេវបុត្រ ៣៣ អង្គដែលកើតគ្រាដំបូង ។ ចំណែកកថាពោលដោយការឧប្បត្តិរបស់ទេវតាទាំងនោះ បានអធិប្បាយទុកហើយយ៉ាងពិស្តារក្នុងអដ្ឋកថា សក្កបញ្ហសូត្រក្នុងទីឃ-និកាយ ។ បទថា **តេន** (ព្រោះហេតុនោះ) គឺ ព្រោះការប្រាប់នោះ ឬព្រោះមនុស្សអ្នកធ្វើបុណ្យមានតិចនោះ ។ បទថា **ទិព្វា វត ភោ កាយា បរិហាយិ-**

**សុរន្តិ** (លោកដ៏ចម្រើនទាំងឡាយ ពួកទេវតានឹងវិនាស) សេចក្តីថា ព្រោះទេវបុត្រថ្មីៗ មិនប្រាកដ ពួកទេវតាក៏នឹងវិនាសទៅ ទេវនគរទំហំប្រមាណមួយម៉ឺនយោជន៍ ដែលគួររីករាយក៏នឹងសូន្យទទេ ។ បទថា **បរិបូរិស្សន្តិ អសុរកាយា** (ពួកអសុរនឹងបរិបូរ) សេចក្តីថា អបាយ ៤ នឹងពេញប្រៀប ។ ដោយហេតុនេះ ទេវតាជាន់តាវត្តិង្សទើបទាស់ចិត្តថា ពួកយើងនឹងមិនបានលេងនក្សត្រក្នុងកណ្តាលពួកទេវតាក្នុងទេវនគរដែលធ្លាប់កុះករ ។ សូម្បីក្នុងសុក្កបក្ខ ក៏គប្បីជ្រាបអត្ថដោយឧបាយនេះឯង ។

## អធិប្បាយ ទុតិយរាជសូត្រ

ព្រះមានព្រះភាគត្រាស់ថា **ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ** (ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ ស្តេចសក្កៈ) ដូច្នេះ ទ្រង់សំដៅដល់វេលាដែលព្រះអង្គជាស្តេចសក្កទេវរាជ ។ម្យ៉ាងទៀត លោកពោលថា ព្រះមានព្រះភាគ ត្រាស់សំដៅដល់អធ្យាស្រ័យរបស់ស្តេចសក្កៈមួយព្រះអង្គ ។ បទថា **អនុនយមានោ** (កាលនឹងត្រូវរំលឹក) បានដល់ ដាស់តឿនឲ្យរលឹកដឹង ។ បទថា **តាយំ វេលាយំ** (ក្នុងវេលានោះ) គឺ ក្នុងកាលនោះ ។

## និព្វានឧបោសថ

ក្នុងបទថា **បាដិហារិយបក្ខញ្ច** (និងអស់បាដិហារិយបក្ខ) នេះ គប្បីជ្រាប

វិនិច្ឆ័យដូចតទៅនេះ ។ ឧបោសថដែលរក្សាជាប់តគ្នារហូតអស់ត្រៃមាស ខាងក្នុងវស្សា ឈ្មោះថា **បាដិហារិយបក្ខឧបោសថ** ។ កាលមិនអាច (នឹងរក្សា) បាដិហារិយឧបោសថរហូតអស់ត្រៃមាសនោះបាន ក៏រក្សាបាដិហារិយឧបោសថមួយខែ ក្នុងរវាងថ្ងៃបវារណាទាំង ២ ខ្ទះ , បើមិនអាច (នឹងរក្សា) បាដិហារិយឧបោសថអស់មួយខែនោះបាន , (ក៏រក្សា) (បាដិហារិយឧបោសថ) កន្លះខែ តាំងពីថ្ងៃបវារណាដំបូងខ្ទះ ក៏ឈ្មោះថា បាដិហារិយបក្ខឧបោសថដូចគ្នា ។ បទថា **អដ្ឋង្គសុសមាគតំ** (ប្រកបដោយអង្គ ៨) បានដល់ ប្រកបដោយអង្គគុណ ៨ ។ បទថា **យោបស្ស មាទិសោ នរោ** (នរៈណាដូចជាយើង) សេចក្ដីថា សត្វពួកណាគប្បីដូចជាយើង ។ បានឮមកថា ស្ដេចសក្កៈជ្រាបគុណរបស់ឧបោសថមានប្រការដូចពោលហើយ ទើបលះបង់សម្បត្តិក្នុងទេវលោក ទៅរក្សាឧបោសថមួយខែ ៨ ថ្ងៃ ។

ន័យមួយទៀត បទថា **យោបស្ស មាទិសោ នរោ** សេចក្ដីថា សត្វពួកណាគប្បីដូចយើង អធិប្បាយថា គប្បីប្រាថ្នាដើម្បីបានទទួលមហាសម្បត្តិ ។ ក្នុងប្រការនេះ មានអធិប្បាយថា ក៏បុគ្គលអាចនឹងទទួលសក្កសម្បត្តិបាន ដោយឧបោសថកម្មបែបនេះ ។

អធិប្បាយ បទថា វុសិត្វា ជាដើម

បទថា **វុសិត្វា** (សម្រេចស្រេចហើយ) បានដល់ មានជីវិតព្រហ្មចារ្យនៅចប់ហើយ ។ បទថា **កតករណីយោ** (ធ្វើកិច្ចដែលគួរធ្វើហើយ) បានដល់ អ្នកធ្វើកិច្ចដែលគួរធ្វើដោយមគ្គ ៤ ។ បទថា **ឱហិតភារោ** (ដាក់ភារៈហើយ) បានដល់ ដាក់ចុះខន្ធភារៈ កិលេសភារៈ និងអភិសង្ខារភារៈហើយ ។ បទថា **អនុប្បត្តទត្ថោ** (សម្រេចប្រយោជន៍ខ្លួនហើយ) សេចក្តីថា អរហត្តផល ហៅថា ប្រយោជន៍របស់ខ្លួន អ្នកសម្រេចប្រយោជន៍របស់ខ្លួននោះ ។ បទថា **បរិ-ក្ខីកវសំយោជនោ** (អស់គ្រឿងដោតក្រងទុកក្នុងភពហើយ) សេចក្តីថា ឈ្មោះថា មានសញ្ញោជនៈជាគ្រឿងចងសត្វទុកក្នុងភពអស់ហើយ ព្រោះសញ្ញោជនៈដែលជាហេតុចងសត្វ ហើយអូសទាញទៅក្នុងភពទាំងឡាយអស់ហើយ ។ បទថា **សម្មទញ្ញាវិមុត្តោ** (រួចផុតដោយបញ្ញាដ៏ប្រពៃហើយ) សេចក្តីថា ឈ្មោះថា រួចផុតព្រោះដឹងដោយហេតុ ដោយន័យ ដោយការណៈ ។

បទថា **កល្លំ វចនាយ** (គួរពោល) បានដល់ គួរដើម្បីនឹងពោល ។ បទថា **យោបស្ស មាទិសោ នរោ** (នរៈណាដូចជាយើង) សេចក្តីថា សូម្បីបុគ្គលណាគប្បីជាព្រះខីណាស្រពដូចជាយើង បុគ្គលនោះ គប្បីរក្សាឧបោសថបែបនេះ គឺ កាលដឹងគុណរបស់ឧបោសថកម្ម គប្បីនៅយ៉ាងនេះ ។ ន័យមួយទៀត បទថា **យោបស្ស មាទិសោ នរោ** សេចក្តីថា សត្វពួកណាគប្បីដូចជា

យើង អធិប្បាយថា គប្បីប្រាថ្នាដើម្បីបានទទួលមហាសម្បត្តិ ។ ក្នុងបទនេះ មានអធិប្បាយដូច្នេះថា ក៏បុគ្គលអាចនឹងទទួលសម្បត្តិរបស់ព្រះឥណ្ឌាស្រេចបាន ដោយឧបោសថកម្មបែបនេះ ។

ចប់អដ្ឋកថា រាជសូត្រទី ៧

# អដ្ឋកថា ទុតិយរាជសូត្រទី ៨

[៣៩] *ទុតិយរាជសូត្រទី ៨ ព្រះអដ្ឋកថាអធិប្បាយរួមក្នុងសូត្រទី ៧ នោះឯង ។*

# អដ្ឋកថា សុខមាលសូត្រទី ៩

## *"សុខមាលជាតិ និងសេចក្ដីស្រវឹង ៣ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យ សុខមាលសូត្រទី ៩ ដូចតទៅនេះ ៖-*

### *សុខមាលជាតិ*

[៤០] *បទថា **សុខមាលោ** គឺ (យើងតថាគត) ជាអ្នកមិនមានទុក្ខ ។ បទថា **បរមសុខុមាលោ** គឺ ជាអ្នកមិនមានទុក្ខយ៉ាងក្រៃលែង ។ បទថា **អច្ចន្តសុខុមាលោ** គឺ ជាអ្នកមិនមានទុក្ខរហូតអស់កាល ។ ព្រះមានព្រះភាគត្រាស់ពាក្យនេះ ព្រោះទ្រង់សំដៅដល់ ព្រះអង្គមិនមានទុក្ខ រាប់តាំងពីស្ដេចឧប្បត្តិក្នុងក្រុងកបិលភស្ដុ ។ តែក្នុងវេលាដែលទ្រង់បំពេញទុក្ករកិរិយា ទុក្ខដែលព្រះអង្គសោយ មិនមានទីបំផុត ។*

*បទថា **ឯកត្ថា** គឺ ក្នុងស្រះបោក្ខរណីមួយកន្លែង ។ បទថា **ឧប្បលំ វប្បតិ** (ដាំឧប្បល) សេចក្ដីថា គេដាំឧប្បលខៀវទុក ។ ស្រះបោក្ខរណីនោះដេរដាស់ដោយផ្កាឧប្បលខៀវ ។ បទថា **បទុមំ** បានដល់ ឈូកស ។ បទថា **បុណ្ឌរិកំ**[១] បានដល់ ឈូកក្រហម ។ ក្រៅពីស្រះបោក្ខរណីទាំងពីរនេះ ដេរ-ដាស់ទៅដោយឈូកស និងឈូកក្រហម ដូចពណ៌នាមកនេះ ។*

---

*(១) ទីដទៃៗ បទុម បានដល់ ឈូកក្រហម , បុណ្ឌរិក បានដល់ ឈូកស ។*

## វិស្សុកម្មទេវបុត្រសាងស្រះបោក្ខរណី

ដូចបានស្តាប់មក ក្នុងវេលាដែលព្រះពោធិសត្វ មានព្រះជន្មាយុបាន ៧-៨ វស្សា ព្រះរាជា (សុទ្ធោទនៈ) ត្រាស់សួរអាមាត្រទាំងឡាយថា ពួកកុមារតូចៗ ពេញចិត្តលេងកីឡាប្រភេទណា ។ អាមាត្រទាំងឡាយក្រាបទូលថា ពេញចិត្តលេងទឹក ព្រះអង្គ ។ តពីនោះ ព្រះរាជាទ្រង់ត្រាស់ឲ្យប្រជុំកម្មករជីកដី ហើយឲ្យជ្រើសរើសយកទីសម្រាប់សាងស្រះបោក្ខរណី ។

វេលានោះ ស្តេចសក្កទេវរាជទ្រង់ពិចារណាមើល ទ្រង់បានជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់ត្រិះរិះថា គ្រឿងប្រើរបស់មនុស្សមិនសមគួរដល់ព្រះពោធិសត្វឡើយ គ្រឿងប្រើជាទិព្វទើបសមគួរ ដូច្នេះ ហើយត្រាស់ហៅវិស្សុកម្មទេវបុត្រមក ត្រាស់ថា បាទៅចុះ បាចូរសាងស្រះបោក្ខរណីក្នុងកន្លែងលេងរបស់ព្រះមហាសត្វ ។ វិស្សុកម្មទេវបុត្រទូលសួរថា ឲ្យមានលក្ខណៈដូចម្តេច ព្រះអង្គ ។

ស្តេចសក្កៈត្រាស់បង្គាប់ថា ស្រះបោក្ខរណីត្រូវមិនមានភក់ ពាសពេញដោយកែវមណី កែវមុក្តា និងកែវប្រវាឡ លោមព័ទ្ធជុំវិញដោយកំពែងកែវ ៧ ប្រការ ព្រមដោយជណ្តើរដែលមានកាំធ្វើដោយមាស ប្រាក់ និងកែវមណី មានបង្កាន់ដៃធ្វើដោយកែវមណី មានមេជណ្តើរធ្វើដោយកែវប្រវាឡ ក្នុងស្រះ

នេះត្រូវមានទូកធ្វើដោយមាស ប្រាក់ កែវមណី និងកែវប្រវាឡ ក្នុងទូកមាសត្រូវមានបល្ល័ង្កប្រាក់ ក្នុងទូកប្រាក់ត្រូវមានបល្ល័ង្កមាស ក្នុងទូកកែវមណីត្រូវមានបល្ល័ង្កកែវប្រវាឡ ក្នុងទូកកែវប្រវាឡត្រូវមានបល្ល័ង្កកែវមណី ត្រូវមាននាឡិជងទឹកធ្វើដោយមាស ប្រាក់ កែវមណី និងកែវប្រវាឡ និងស្រះបោក្ខរណីត្រូវដេរដាស់ដោយបទុម ៥ ប្រភេទ ។ វិស្សុកម្មទេវបុត្រទទួលបញ្ជាអំពីស្តេចសក្កទេវរាជថា ករុណាថ្លៃវិសេស ដូច្នេះហើយ ចុះមកកណ្តាលយប់ សាងស្រះបោក្ខរណីដោយទំនងនោះឯង ក្នុងទីដែលព្រះរាជាត្រាស់បង្គាប់ឲ្យជ្រើសរើសយក ។

សួរថា ក៏ស្រះបោក្ខរណីទាំងនេះ មិនមានភក់មែនឬ ។ ហើយបទុមទាំងឡាយរីកក្នុងស្រះនេះបានដូចម្តេច ។ ឆ្លើយថា បានឮថា វិស្សុកម្មទេវបុត្រនោះ សាងទូកតូចៗ ដែលធ្វើដោយមាស ប្រាក់ កែវមណី និងកែវប្រវាឡទុកតាមដែលផ្សេងៗ ក្នុងស្រះបោក្ខរណីទាំងនោះ ហើយអធិដ្ឋានថា ទូកទាំងនេះ ចូរពេញដោយភក់ចុះ និងសូមឲ្យឈូក ៥ ប្រភេទ ចូររីកក្នុងទូកនេះ ។ ឈូក ៥ ប្រភេទ ក៏រីកហើយ ដោយប្រការដូចពណ៌នាមកដូច្នេះ ។ លម្អងកេសរក៏ហុយឡើងបិទបាំងផ្ទៃទឹក ។ ពួកភមរសត្វ ៥ ប្រភេទ ក៏នាំគ្នាហើររោំ ។ វិស្សុកម្មទេវបុត្រសាងស្រះបោក្ខរណីទាំងនោះស្រេចហើយ ក៏ត្រឡប់

ទៅកាន់ទេវបុរីដូចដើម ។

គ្រាភ្ញីឡើង មហាជនឃើញហើយក៏គិតគ្នាថា ស្រះបោក្ខរណីគង់នឹងមាននរណានិម្មិតថ្វាយព្រះមហាបុរសដោយពិត ទើបនាំគ្នាទៅក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាមានមហាជនហែហម ស្តេចទៅទតមើលស្រះបោក្ខរណី ក៏ទ្រង់សោមនស្សថា ស្រះបោក្ខរណីទាំងនេះ ប្រាកដជាទេវតានិម្មិតឡើង ដោយបុញ្ញឫទ្ធិនៃឱរសរបស់យើង ។ តាំងពីនោះមក ព្រះមហាបុរសក៏ស្តេចទ្រង់ទៅលេងទឹក ។

បទថា **យាវទេវ** ក្នុងបទថា **យាវទេវ មមត្ថាយ** នេះ ជាបទកំណត់ដល់ខេត្តនៃការប្រកប អធិប្បាយថា ត្រឹមតែដើម្បីប្រយោជន៍ដល់តថាគតប៉ុណ្ណោះ មិនមានហេតុយ៉ាងដទៃក្នុងរឿងនេះ ។ បទថា **ន ខោ បនស្សាហំ** កាត់បទជា **ន ខោបនស្ស អហំ** ។ បទថា **កាសិកំ ចន្ទនំ** (ចន្ទន៍ក្នុងដែនកាសី) បានដល់ ឈើចន្ទន៍ដែនកាសី មានសាច់ល្អិតទន់ ។ បទថា **កាសិកំ សុ មេ តំ ភិក្ខវេ វេឋនំ** (ម្នាលភិក្ខុទាំងឡាយ សំពត់ឈ្នួតរបស់យើង ក៏ធ្វើក្នុងដែនកាសី) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សូម្បីសំពត់ជួតសីរសៈរបស់យើងក៏ជាសំពត់ធ្វើនៅដែនកាសី ។ ក៏បទថា **សុ** និង **តំ** ក្នុងបទថា **កាសិកំ សុ មេ តំ វេឋនំ** នេះ ត្រឹមតែនិបាត ។ បទថា **មេ** ជាឆដ្ឋីវិភត្តិ ។ ព្រះមានព្រះ-

ភាគទ្រង់សម្តែងថា សំពត់ជូតសីសៈរបស់តថាគត ជាសាច់ល្អិតល្អដោយពិត ។ បទថា **កាសិកា កញ្ចុកា** (អាវក៏ធ្វើក្នុងដែនកាសី) បានដល់ អាវនិងសំពត់ទទូរ ។ បទថា **សេតច្ឆត្តំ ធារិយតិ** (គេបាំងស្វេតឆត្រ) សេចក្តីថា តាំងស្វេតឆត្ររបស់មនុស្ស ទាំងស្វេតឆត្រជាទិព្វ ក៏ការពារនៅលើសីសៈដូចគ្នា ។ បទថា **មា នំ សិតំ វា** (មិនឲ្យសេចក្តីត្រជាក់...ពាល់ត្រូវព្រះពោ-ធិសត្វ) សេចក្តីថា សូមសេចក្តីត្រជាក់ ឬក្តៅជាដើមណាទីមួយ កុំបានសម្ផស្សព្រះពោធិសត្វនោះឡើយ ។

## ការសាងប្រាសាទ ៣ រដូវ

បទថា **តយោ បាសទា អហេសុំ** (មានប្រាសាទ ៣ ខ្នង) សេចក្តីថា បានឮថា កាលព្រះពោធិសត្វប្រសូតិហើយ មានព្រះជន្មាយុបាន ១៦ វស្សា ព្រះបាទសុទ្ធោទនៈ ទ្រង់ត្រិះរិះថា នឹងឲ្យសាងប្រាសាទសម្រាប់ព្រះរាជឱរសប្រថាប់នៅ ទើបត្រាស់បង្គាប់ឲ្យជាងឈើមកប្រជុំព្រមគ្នា ហើយបង្គាប់ឲ្យធ្វើគម្រោងរាងប្រាសាទ ៩ ជាន់ តាមឫក្សយាមល្អ ហើយឲ្យសាងប្រាសាទ ៣ ខ្នង ព្រះមានព្រះភាគទ្រង់សំដៅយកប្រាសាទទាំង ៣ ខ្នងនោះ ទើបត្រាស់បទនេះថា **មានប្រាសាទ ៣ ខ្នង** ។

ក្នុងបទថា **ហេមន្តិកោ** (សម្រាប់នៅក្នុងរដូវរងា) ជាដើម មានអធិប្បាយ

ថា ប្រាសាទមួយខ្នងដែលទ្រង់ប្រថាប់នៅយ៉ាងសប្បាយក្នុងរដូវហេមន្តៈ ឈ្មោះ ថា **ហេមន្តិកប្រាសាទ** (ប្រាសាទដែលប្រថាប់នៅក្នុងរដូវហេមន្តៈ) ។ សូម្បីក្នុងពីរបទក្រៅពីនេះ ក៏មានន័យនេះឯង ។ ក៏ក្នុងពាក្យទាំងនេះ មានអត្ថនៃពាក្យដូច្នេះ ការនៅក្នុងហេមន្តរដូវ ឈ្មោះថា **ហេមន្តៈ** ប្រាសាទ ឈ្មោះថា **ហេមន្តិកៈ** ព្រោះសមគួរនឹងហេមន្តរដូវ ។ សូម្បីក្នុងពីរបទក្រៅពីនេះ ក៏មានន័យនេះឯង ។

## ប្រាសាទរដូវរងា

បណ្តាប្រាសាទទាំង ៣ ខ្នងនោះ ប្រាសាទក្នុងហេមន្តរដូវមាន ៩ ជាន់ ក៏ឯជាន់ទីមួយៗ របស់ប្រាសាទនោះ ជាជាន់ទាបៗ ក៏ដើម្បីឲ្យទទួលកំដៅ ទ្វារ និងបង្អួចរបស់ប្រាសាទនោះ ក៏មានត្រចៀកជាប់ស្និទ្ធល្អមិនមានប្រហោងជាងទាំងឡាយសូម្បីកាលធ្វើចិត្រកម្ម ក៏គួរជាគំនរភ្លើងនៅក្នុងជាន់នោះៗ ។ ឯកម្រាលក្នុងផ្ទៃប្រាសាទនេះ ធ្វើអំពីសំពត់កម្ពល ។ សំពត់វាំងនន ពិតាន សំពត់ស្មៀក សំពត់ដណ្តប់ និងសំពត់ជូតសីរសៈក៏ដូចគ្នា (គឺ ធ្វើពីសំពត់កម្ពល) ។ បង្អួចបើកក្នុងពេលថ្ងៃដើម្បីឲ្យទទួលកំដៅ ហើយបិទក្នុងពេលយប់ ។

## ប្រាសាទរដូវក្តៅ

ប្រាសាទរដូវក្តៅមាន ៥ ជាន់ ។ ក៏ជាន់នីមួយៗ ក្នុងប្រាសាទនេះខ្ពស់ មិនចង្អៀត ដើម្បីឲ្យទទួលភាពត្រជាក់ ។ ទ្វារ និងបង្អួចបិទមិនស្និទ្ធពេក មានប្រហោង និងជាប់ដោយក្រឡាសំណាញ់ ។ ក្នុងការងាររចិត្រកម្ម គេបានគូរជាផ្កាឧប្បល ផ្កាបទុម និងផ្កាបុណ្ឌរិកទុក ។ ក៏កម្រាលផ្ទៃក្នុងប្រាសាទនេះធ្វើអំពីសំពត់សំបកឈើ សំពត់វាំងនន ពិតាន សំពត់ស្បៀក សំពត់ជណ្តប់ និងសំពត់ជួតសីសៈ (ក៏ធ្វើពីសំបកឈើ) ដូចគ្នា ។ ម្យ៉ាងទៀត ត្រង់ទីជិតបង្អួចក្នុងប្រាសាទនេះ ពួកជាងក៏តាំងពាងទឹកទុក ៩ ពាង ដាក់ទឹកជរាបពេញ ហើយយកផ្កាឈូកខៀវជាដើមបណ្តែតអំពីខាងលើ ។ គេធ្វើយន្តបង្ហូរទឹកជាច្រើនទុកតាមទីទាំងនោះ ជាហេតុឲ្យខ្សែទឹកហូរចេញមក ដូចកាលភ្លៀងធ្លាក់ ។ ខាងក្នុងប្រាសាទ គេដាក់ទនៃទឹកដែលមានភក់ពេញទុកក្នុងទីនោះៗ ហើយដាំឈូកបញ្ចវណ្ណទុក ។ លើកំពូលប្រាសាទ ក៏ចងខ្សែព្រ័ត្រស្បែកក្របីទុក ប្រើយន្តជាច្រើន (បង្ហូរទឹកឡើង) តម្កល់ជុំថ្ម (ឡើងខ្ពស់) រហូតដល់ជំបូល ជាហេតុឲ្យទឹកហូរមក ដូចក្នុងកាលភ្លៀងធ្លាក់ ។ សំឡេងទឹកហូរ ដូចជាសំឡេងផ្គរលាន់ ។ ឯទ្វារ និងបង្អួចក្នុងប្រាសាទនេះ បិទក្នុងវេលាពេលថ្ងៃ ហើយបើកក្នុងវេលាពេលយប់ ។

## ប្រាសាទរដូវភ្លៀង

ប្រាសាទរដូវភ្លៀង មាន ៧ ជាន់ ។ ក៏ជាន់នីមួយៗ ក្នុងប្រាសាទនេះ មិនខ្ពស់ពេក ដើម្បីត្រូវការឲ្យបានទទួលអាកាសទាំង ២ រដូវ (ត្រជាក់ និង ក្តៅ) ។ ទ្វារ និងបង្អួចពេលខ្លះក៏បិទជិតល្អ ពេលខ្លះក៏ចំហ ។ សូម្បីចិត្រ-កម្មក្នុងប្រាសាទនោះ ក្នុងកន្លែងខ្លះក៏គូរជាគំនរភ្លើង ក្នុងកន្លែងខ្លះក៏គូរជាស្រះធម្មជាតិ ។ ក៏សំពត់ មានសំពត់ក្រាលផ្ទៃជាដើមក្នុងប្រាសាទនេះ ក៏លាយគ្នាទាំងពីរប្រភេទ គឺ ទាំងសំពត់កម្ពល និងសំពត់សំបកឈើ ។ ទ្វារ និងបង្អួច ពេលខ្លះក៏បើកពេលយប់ហើយបិទពេលថ្ងៃ ពេលខ្លះក៏បើកពេលថ្ងៃហើយបិទពេលយប់ ។ ប្រាសាទទាំង ៣ ខ្នង ចំណែកកម្ពស់ខ្ពស់ស្មើគ្នា ។ តែមានសេចក្តីផ្សេងគ្នាក្នុងរឿងជាន់ ។

## ព្រះពោធិសត្វសម្តែងសិល្បៈ

កាលសាងប្រាសាទស្រេចយ៉ាងនេះហើយ ព្រះរាជាទ្រង់ត្រិះរិះថា ឱរសរបស់យើងចម្រើនវ័យហើយ យើងនឹងឲ្យលើកស្វេតឆត្រឡើងដើម្បីគេ ហើយរង់ចាំមើលសិរីរាជសម្បត្តិ ។ ព្រះអង្គទើបទ្រង់បញ្ជូនព្រះរាជសាសន៍ ទៅដល់សក្យរាជទាំងឡាយថា ឱរសរបស់ខ្ញុំចម្រើនវ័យហើយ ខ្ញុំនឹងស្ថាបនាគេទុកក្នុងរាជសម្បត្តិ សូមសក្យរាជទាំងឡាយចូរបញ្ជូនស្ត្រីដែលចម្រើនវ័យរៀងៗ ខ្លួនទៅកាន់រាជមណ្ឌបនេះចុះ ។

សក្យត្រកូលទាំងនោះ បានស្តាប់ព្រះរាជសាសន៍ហើយ អង្គផ្សេងៗ ទ្រង់ត្រិះរិះថា ព្រះកុមារសម្បូរណ៍ដោយព្រះរូបគួរទស្សនាប៉ុណ្ណោះ (ប៉ុន្តែថា) ទ្រង់មិនចេះសិល្បៈអ្វីៗ ឡើយ នឹងមិនអាចរក្សាព្រះវរជាយាបានឡើយ ពួកយើងមិនព្រមលើកកូនក្រមុំឲ្យ ។ ព្រះរាជាទ្រង់ស្តាប់ដំណឹងនោះហើយ ស្តេចបានទៅកាន់សំណាក់ព្រះរាជឱរស ហើយត្រាស់ប្រាប់ ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះបិតា ខ្ញុំគួរនឹងសម្តែងសិល្បៈអ្វី ។

ព្រះរាជាត្រាស់ថា កូនគួរលើកធ្នូសហស្សឡើងណាកូន ។ បើដូច្នោះ សូមព្រះបិតាឲ្យនាំមកចុះ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យនាំធ្នូមកឲ្យព្រះរាជឱរស ។ ធ្នូនោះប្រើមនុស្ស ១.០០០ នាក់ លើកឡើង ប្រើមនុស្ស ១.០០០ នាក់ ដាក់ចុះ ។ ព្រះមហាបុរសឲ្យនាំធ្នូមកហើយ ប្រថាប់អង្គុយលើបល្ល័ង្ក ទ្រង់ចាប់ខ្សែទុកត្រង់ព្រះបាទង្គុដ្ឋៈ (ម្រាមមេដៃ) ហើយទាញមក ទ្រង់យកព្រះបាទង្គុដ្ឋៈ ទ្រុះឯងនាំធ្នូមកហើយ ចាប់ដងធ្នូដោយព្រះហស្តឆ្វេង ទ្រង់យឹតខ្សែធ្នូដោយព្រះហស្តស្តាំ ហើយព្រលែង ទូទាំងព្រះនគរដល់នូវអាការស្រឡាំងកាំង ។ កាលមាននរណាសួរថា សំឡេងអ្វី ។ សក្យត្រកូលទាំងឡាយ ក៏ឆ្លើយព្រមគ្នាថា រន្ទះគម្រាម ។ ពេលនោះ បុគ្គលមួយពួកទៀតក៏ឆ្លើយថា ពួកលោកមិនដឹងទេឬ មិនមែនរន្ទះគម្រាមទេ នោះជាសំឡេងខ្សែធ្នូរបស់ព្រះអង្គីរសកុមារដែល

ទ្រង់លើកធ្នូ ដែលត្រូវប្រើកម្លាំងមនុស្សរហូត ១.០០០ នាក់ ហើយព្រលែងខ្សែ ។ សក្យរាជទាំងឡាយ ក៏មានព្រះទ័យសរសើរព្រោះការសម្តែងសិល្បៈរបស់ព្រះមហាសត្វត្រឹមតែប៉ុណ្ណោះ ។

ព្រះមហាបុរសក្រាបទូលព្រះរាជបិតាថា ខ្ញុំគប្បីធ្វើអ្វីដទៃទៀត ។

ព្រះរាជាត្រាស់ថា កូនគប្បីយកកូនសរបាញ់ផ្ទាំងដែកកម្រាស់ប្រមាណ ៨ ធ្នាប់ឲ្យធ្លុះ ។

ព្រះមហាបុរសបាញ់ទម្លុះផ្ទាំងដែកនោះ ហើយក្រាបទូលថា ខ្ញុំគប្បីធ្វើអ្វីយ៉ាងដទៃទៀតទេ ។

ព្រះរាជាត្រាស់ថា កូនគប្បីបាញ់សន្ទឹកទ្វារឈើកម្រាស់ ៤ ធ្នាប់ឲ្យធ្លុះ ។ ព្រះមហាបុរសបាញ់ទម្លុះបន្ទះក្តារនោះ ហើយក្រាបទូលថា ខ្ញុំគប្បីធ្វើអ្វីដទៃទៀតទេ ។

ព្រះរាជាត្រាស់ឆ្លើយថា កូនគប្បីបាញ់បន្ទះក្តាឈើល្វាកម្រាស់ ១ ចង្អាមឲ្យធ្លុះ ។

ព្រះមហាបុរសបាញ់ទម្លុះបន្ទះក្តាឈើល្វានោះហើយ ក្រាបទូលថា ខ្ញុំគប្បីនឹងធ្វើអ្វីដទៃទៀតទេ ។

ព្រះរាជាត្រាស់ឆ្លើយថា កូនគប្បីបាញ់បន្ទះក្តាដែលចងទុកត្រង់គ្រឿង

យន្ត ១០០ បន្ទះឲ្យធ្លុះ ។

ព្រះមហាបុរសបាញ់ទម្លុះបន្ទះក្តា ១០០ បន្ទះនោះហើយ ក្រាបទូលថា ខ្ញុំគប្បីធ្វើអ្វីយ៉ាងដទៃទៀតទេ ។

ព្រះរាជាត្រាស់ឆ្លើយថា កូនគប្បីបាញ់ស្បែកក្របីស្ងួតកម្រាស់ ៦០ ជាន់ឲ្យធ្លុះ ។

ព្រះមហាបុរសបាញ់ទម្លុះស្បែកក្របីស្ងួតសូម្បីនោះ ហើយក្រាបទូលថា ខ្ញុំគប្បីធ្វើអ្វីយ៉ាងដទៃទៀតទេ ។

លំដាប់នោះ សក្យត្រកូលទាំងឡាយក៏ប្រាប់ (ឲ្យបាញ់) រទេះដែលផ្ទុកដីខ្សាច់ជាដើម ។

ព្រះមហាសត្វបាញ់ទម្លុះទាំងរទេះផ្ទុកដីខ្សាច់ ទាំងរទេះផ្ទុកចំបើង ហើយបាញ់កូនសរចុះទៅក្នុងទឹកជម្រៅប្រមាណ ១ ឧសភៈ (និង) បាញ់ឡើងទៅលើគោកបានចម្ងាយប្រមាណ ៨ ឧសភៈ ។ ពេលនោះ សក្យត្រកូលទាំងឡាយក៏ក្រាបទូលព្រះមហាសត្វថា ឥឡូវនេះ ព្រះអង្គគប្បីបាញ់រោមទ្រាយឲ្យដាច់ដោយមានផ្លែត្រប់ជាគ្រឿងសម្គាល់ ។

ព្រះមហាសត្វត្រាស់ថា បើដូច្នោះ លោកទាំងឡាយចូរចង (រោមទ្រាយ) ។

សក្យត្រកូលទាំងឡាយក៏បង្គាប់ថា បាទាំងឡាយ ពួកបាចូរមកជួយគ្នា

ចង គឺ ព្រះអង្គីរសកុមារបាញ់ ក្នុងរយៈបានឮសំឡេង ពួកបាចូរធ្វើដំណើរទៅខាងមុខទៅ ព្រះអង្គីរសកុមារបាញ់ក្នុងរយៈផ្លូវមួយគាវុត ពួកបាចូរធ្វើដំណើរទៅខាងមុខ ព្រះអង្គីរសកុមារបាញ់ក្នុងរយៈផ្លូវកន្លះប្រយោជន៍ ពួកបាចូរធ្វើដំណើរទៅខាងមុខ ព្រះអង្គីរសកុមារបាញ់ក្នុងរយៈផ្លូវ ១ យោជន៍ ។

ព្រះមហាសត្វឲ្យចងរោមទ្រាយក្នុងរយៈផ្លូវចម្ងាយប្រមាណ ១ យោជន៍ ដោយមានផ្ទៃត្រប់ជាគ្រឿងសម្គាល់ ហើយបាញ់កូនសរទៅក្នុងទិសទាំងឡាយដែលក្រាស់ដោយអ័ព្ទ ក្នុងយាមរាត្រីដែលងងឹតស្និទ្ធ ។ កូនសរស្ទុះទៅផ្តាច់រោមទ្រាយក្នុងរយៈផ្លូវចម្ងាយប្រមាណ ១ យោជន៍ ហើយ (ធ្លាក់ចុះ) ចូលក្នុងផែនដីទៅ ម្យ៉ាងទៀត មិនមែនមានតែបាញ់កូនសរតែម្យ៉ាងប៉ុណ្ណោះទេ ។

ក៏ថ្ងៃនោះ ព្រះមហាសត្វ ទ្រង់សម្តែងសិល្បៈដែលមាននៅក្នុងលោកគ្រប់ប្រភេទ ។ សក្យត្រកូលទាំងឡាយ តុបតែងព្រះធីតារៀងៗ ខ្លួន ហើយបញ្ជូនមកថ្វាយ ។ ស្រីរបាំមានចំនួនរហូតដល់ ៤០.០០០ នាក់ ។ ព្រះ-មហាបុរសប្រថាប់នៅក្នុងប្រាសាទទាំង ៣ ខ្នង ប្រៀបដូចទេវបុត្រ ។

## ក្នុងប្រាសាទមិនមានមនុស្សប្រុសឡើយ

បទថា **និប្បុរិសេហិ តុរយេហិ** សេចក្តីថា តន្ត្រីដែលប្រាសចាកបុរស ។ មួយទៀត ក្នុងប្រាសាទនេះ មិនមែនការប្រគុំតន្ត្រីប៉ុណ្ណោះដែលមិនមានបុរស

(លេង) សូម្បីស្ថានទីគ្រប់កន្លែង ក៏មិនមានបុរសប្រចាំដូចគ្នា សូម្បីអ្នកយាមទ្វារក៏ជាស្ត្រីដូចគ្នា ។ ពួកអ្នកធ្វើការងារក្នុងពេលថ្វាយការស្រង់ទឹកជាដើម ក៏ជាស្ត្រីដូចគ្នា ។

បានឮមកថា ព្រះរាជាទ្រង់ត្រិះរិះថា សេចក្ដីរង្កៀសនឹងកើតឡើងដល់កូនប្រុសរបស់យើង ដែលសោយសុខសម្បត្តិដោយឥស្សរិយយសបែបនោះ ហើយព្រោះបានឃើញបុរស សូមសេចក្ដីរង្កៀសនោះកុំមានដល់កូនរបស់យើងឡើយ ដូច្នេះហើយ ទើបទ្រង់តែងតាំងស្ត្រីទុកក្នុងគ្រប់មុខនាទី ។ បទថា **បរិចារិយមានោ** (រីករាយហើយ) សេចក្ដីថា រីករាយពេញចិត្តហើយ ។

## ព្រះពោធិសត្វស្ដេចមិនចុះមកជាន់ក្រោមឡើយ

បទថា **ន ហេដ្ឋាបាសាទំ ឱរោហាមិ** (មិនបានចុះទៅកាន់ប្រាសាទជាន់ក្រោមឡើយ) សេចក្ដីថា យើងមិនបានចុះពីប្រាសាទទៅខាងក្រោមឡើយ ព្រោះហេតុនោះ បុរសត្រឹមតែម្នាក់ ក៏មិនបានឃើញយើងរហូតអស់ ៤ ខែ ។ បទថា **យថា** គឺ ដោយនិយាមណា ។ បទថា **ទាសកម្មករបោរិសស្ស** (ទាសៈ កម្មករ និងបុគ្គលអាស្រ័យ) បានដល់ ទាសៈ កម្មករ ដែលបានទទួលការរក្សាដោយតម្លៃអាហារប្រចាំថ្ងៃ និងអ្នកដែលអាស្រ័យនៅទើបបានបរិភោគ (រហូតទៅ) ។ បទថា **កណាជកំ** បានដល់ បាយចុងអង្ករ ។ បទថា **ពិលង្គទុតិយំ**

(មានទឹកជ្រក់ប្រកប) បានដល់ មានទឹកជ្រក់ជាគម្រប់ ២ ។ បទថា **ឯវរូបាយ ឥទ្ធិយា** (ដោយឫទ្ធិបែបនេះ) បានដល់ អ្នកប្រកបដោយឫទ្ធិ មានកំណើតយ៉ាងនេះ ។ បទថា **អច្ចន្តសុខុមាលេន**[១] (និងដោយសេចក្ដីសុខដ៏ក្រៃលែងយ៉ាងនេះ) បានដល់ និងជាអ្នកប្រកបដោយភាពជាអ្នកមិនមានទុក្ខ មានកំណើតយ៉ាងនេះ ។ បាឋៈជា **សុខមាលេន** ដូច្នេះក៏មាន ។

## ហេតុផលដែលត្រាស់សុខសម្បត្តិរបស់ព្រះអង្គ

ព្រះតថាគត ត្រាស់និទានដល់សិរីសម្បត្តិរបស់ព្រះអង្គ ដោយឋានៈត្រឹមប៉ុណ្ណេះ ដូចពណ៌នាមកនេះ និងកាលត្រាស់និទាននោះ ក៏មិនបានត្រាស់និទានដើម្បីសេចក្ដីលើកតម្កើងខ្លួនព្រះអង្គឡើយ ។ តែត្រាស់និទាននេះដើម្បីសម្ដែងដល់លក្ខណៈនៃសេចក្ដីមិនប្រមាទទុំះឯងថា តថាគតស្ថិតនៅក្នុងសម្បត្តិសូម្បីបែបនេះ ក៏មិនប្រមាទឡើយ ។ ដោយហេតុនោះឯង ព្រះអង្គទើបត្រាស់បទថា **បុថុជ្ជនអ្នកមិនបានស្ដាប់** ជាដើម ។ បណ្ដាបទទាំងនោះ បទា **បរំ** បានដល់ បុគ្គលដទៃ ។ បទថា **ជិណ្ណំ** (ចាស់) បានដល់ ទ្រុឌទ្រោមព្រោះជរា ។ បទថា **អដ្ដិយតិ** (នឿយណាយ) បានដល់ ជិនឆ្អន់ ធុញទ្រាន់ ។ បទថា **ហរាយតិ** បានដល់ ខ្មើមអៀម ។ បទថា **ជិគុច្ឆតិ** បានដល់ កើតសេចក្ដីរង្កៀស

---

(១) បាលីបិដក អច្ចន្តសុខុមាលេន , បាលីអដ្ឋកថា ឯវរូបេន ច សុខមាលេន ។

ឡើងដូចបានឃើញរបស់មិនស្អាត ។ បទថា **អត្តានំយេវ អតិសិត្វា** (ក្លួចខ្លួន) សេចក្តីថា នៀយណាយ ខ្ពើមរអើម ក្លួចខ្លួនថា មានជរាជាធម្មតា ។ បទថា **ជរាធម្មោ** (មានសេចក្តីចាស់ជាធម្មតា) បានដល់ មានជរាជាសភាព ។ បទថា **ជរំ អនតីតោ** (មិនកន្លងសេចក្តីចាស់) សេចក្តីថា យើងមិនកន្លងជរាទៅបាន គង់ប្រព្រឹត្តទៅក្នុងជរា ។ បទថា **ឥតិ បដិសញ្ចិក្ខតោ** (ពិចារណាឃើញហើយ យ៉ាងនេះ) បានដល់ ជាអ្នកពិចារណាឃើញយ៉ាងនេះ ។

## សេចក្តីស្រវឹង ៣ យ៉ាង

សេចក្តីស្រវឹងព្រោះមានះ ដែលអាស្រ័យភាពជាកំឡោះកើតឡើង ឈ្មោះថា **សេចក្តីស្រវឹងក្នុងភាពជាកំឡោះ** ។ បទថា **សព្វសោ បហីយិ** (បានវិនាសទៅ) សេចក្តីថា ព្រះមានព្រះភាគទ្រង់សំដែងសេចក្តីស្រវឹង ដែលលះបានហើយដោយអាការទាំងពួង ឲ្យដូចជាការលះបានហើយដោយមគ្គ ។ តែអ្នកសិក្សាគប្បីជ្រាបថា សេចក្តីស្រវឹងនេះមិនមែនលះបានដោយមគ្គ ព្រះមាន-ព្រះភាគត្រាស់ថា លះបានដោយការពិចារណា (វិបស្សនា) ។ ព្រោះថា ទេវតាទាំងឡាយសំដែងបុគ្គលដែលដល់ជរា ដល់ព្រះពោធិសត្វ ។ តាំងពីនោះមកជរាបដល់បានជាព្រះអរហន្ត ឈ្មោះថា សេចក្តីស្រវឹងក្នុងភាពជាកម្លោះ មិនកើតឡើងដល់ព្រះមហាសត្វឡើយ ។ សូម្បីជាតីរបទដ៏សេស ក៏មានន័យនេះ

ឯង ។ មួយទៀត ក្នុងពីរបទដ៏សេសនេះ មានអធិប្បាយដូចតទៅនេះ សេចក្តីស្រវឹងដោយអំណាចមានះ ដែលកើតឡើងព្រោះអាស្រ័យការមិនមានរោគថា យើងជាអ្នកមិនមានរោគ ឈ្មោះថា **សេចក្តីស្រវឹងព្រោះការមិនមានរោគ** ។ សេចក្តីស្រវឹងដោយអំណាចមានះ ដែលកើតឡើងព្រោះអាស្រ័យជីវិតថា យើងរស់នៅមកបានយូរ ឈ្មោះថា **សេចក្តីស្រវឹងក្នុងជីវិត** ។ បទថា **សិក្ខំ បច្ចក្ខាយ** បានដល់ ពោលលានូវសិក្ខា ។ បទថា **ហីនាយវត្តតិ** (ត្រឡប់មកជាគ្រហស្ថ) បានដល់ វិលមកដើម្បីភាពថោកទាប គឺ ដើម្បីជាគ្រហស្ថដែលជាភាវៈថោក-ទាប ។

បទថា **យថាធម្មា** (តាមធម្មតា) បានដល់ មានសភាវៈ ដោយសភាវៈទាំងឡាយ មានព្យាធិជាដើម ។ បទថា **តថាសន្តា** (មានហើយ) មានអធិប្បាយថា ជាអ្នកមានព្យាធិជាដើមជាសភាវៈដែលមិនប្រែប្រួល ដូចដែលមានហើយនុ៎ះឯង ។ បទថា **ជិគុច្ឆន្តិ** បានដល់ ជិនឆ្អន់ក្នុងបុគ្គលដទៃ ។ បទថា **មម ឯវំវិហារិនោ** (ដល់យើងដែលមានប្រក្រតីនៅយ៉ាងនោះ) សេចក្តីថា កាលតថាគតនៅដោយអាការយ៉ាងនោះ គឺ នៅដោយអាការជិនឆ្អន់ ធុញទ្រាន់យ៉ាងនេះ គប្បីជារបស់មិនសម គឺ មិនសមគួរ ។

បទថា **សោហំ ឯវំ វិហរន្តោ** (តថាគតកាលនៅយ៉ាងនេះ) សេចក្តីថា

តថាគតនោះ មិនធុញទ្រាន់ក្នុងបុគ្គលដទៃយ៉ាងនេះ ។ម្យ៉ាងទៀត (តថាគតនោះ) នៅយ៉ាងនេះ គឺ នៅដោយមានការពិចារណាជាធម៌ជាគ្រឿងនៅដូច្នេះ ។ បទថា **ញត្វា ធម្មំ និរូបធឹ** (បានដឹងធម៌ដែលមិនមានឧបធិ) សេចក្តីថា ទ្រង់ជ្រាបធម៌ គឺ ព្រះនិព្វានដែលមិនមានឧបធិទាំងពួង ។ បទថា **សព្វេ មទេ អភិភោស្មិ** (គ្របសង្កត់សេចក្តីស្រវឹងទាំងពួង) សេចក្តីថា តថាគតគ្របសង្កត់ គឺ ឈានកន្លងសេចក្តីស្រវឹងអស់ទាំង ៣ យ៉ាង ។

បទថា **នេក្ខម្មេ ទដ្ឋុ ខេមតំ** (បានឃើញនេក្ខមៈថាក្សេម) សេចក្តីថា ឃើញភាវៈដែលក្សេមក្នុងព្រះនិព្វាន ។ បាឋៈជា **នេក្ខម្មំ ទដ្ឋុ ខេមតោ** ក៏មាន ។ អត្ថ ក៏គឺ ឃើញនេក្ខម្មៈដោយសភាវៈដែលក្សេម ។

បទថា **តស្ស មេ អហុ ឧស្សាហោ** (សេចក្តីឧស្សាហ៍មានដល់តថាគតនោះ) សេចក្តីថា កាលតថាគតឃើញព្រះនិព្វាន ពោលគឺ នេក្ខម្មៈនោះជាក់ច្បាស់ ទើបមានសេចក្តីឧស្សាហ៍ មានន័យថា បានមានសេចក្តីព្យាយាម ។

បទថា **នាហំ ភព្វោ ឯតរហិ កាមានិ បដិសេវិតុំ** (ឥឡូវនេះ តថាគតជាអ្នកមិនគួរសេពកាមទាំងឡាយ) សេចក្តីថា ឥឡូវនេះ តថាគតមិនគួរនឹងសេពកាមទាំងពីរយ៉ាង ។ បទថា **អនិវត្តិ ភវិស្សាមិ** (តថាគតជាអ្នកមិនវិលត្រឡប់) សេចក្តីថា តថាគតនឹងមិនវិលត្រឡប់ គឺ នឹងមិនត្រឡប់ពីបព្វជ្ជា និង

*ពីសព្វញ្ញុតញ្ញាណ ។ បទថា* ***ព្រហ្មចរិយបរាយនោ*** *(ទីងមានព្រហ្មចារ្យជាគោលដៅ) សេចក្តីថា តថាគតជាអ្នកមានមគ្គព្រហ្មចរិយៈជាទីទៅក្នុងខាងមុខហើយ ។*

*ព្រះមានព្រះភាគ ត្រាស់ដល់សេចក្តីព្យាយាមដែលជាហេតុឲ្យព្រះអង្គបានត្រាស់ដឹង ត្រង់បល្ល័ង្កក្រោមដើមមហាពោធិ ដោយគាថាទាំងនេះ ដូចពោលមកនេះ ។*

ចប់អដ្ឋកថា សុខមាលសូត្រទី ៩

# អដ្ឋកថា អធិបតេយ្យសូត្រទី ១០

## *“អធិបតេយ្យ ៣”*

*គប្បីជ្រាបវិនិច្ឆ័យ អធិបតេយ្យសូត្រទី ១០ ដូចតទៅនេះ ៈ-*

*[៤១] គុណជាតិដែលកើតអំពីហេតុដ៏សំខាន់បំផុត ឈ្មោះថា* ***អធិ-បតេយ្យ*** *។ ក្នុងបទថា* ***អត្តាធិបតេយ្យំ*** *ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ គុណជាតដែលកើតដោយធ្វើខ្លួនឲ្យជាធំ ឈ្មោះថា* ***អត្តាធិបតេយ្យ*** *។ គុណជាតដែលកើតដោយធ្វើលោកឲ្យជាធំ ឈ្មោះថា* ***លោកាធិបតេយ្យ*** *។ គុណជាតដែលកើតដោយធ្វើលោកុត្តរធម៌ ៩ ឲ្យជាធំ ឈ្មោះថា* ***ធម្មាធិបតេយ្យ*** *។*

*បទថា* ***ឥតិភវាភវោ*** *ក្នុងបទថា* ***ន ឥតិភវាភវហេតុ*** *បានដល់ ភពសម្បត្តិក្នុងអនាគតយ៉ាងនោះ (តែ) មិនមែនព្រោះហេតុនៃភពសម្បត្តិនោះ ។ បទថា* ***ឱតិណ្ណោ*** *(ត្រូវ...គ្របសង្កត់) គឺ គ្រប់គ្រង ។ ក៏ជាតិគ្រប់គ្រងខាងក្នុងនៃបុគ្គលណា បុគ្គលនោះឈ្មោះថា ត្រូវជាតិគ្របសង្កត់ ។ សូម្បីក្នុងជរាជាដើម ក៏មានន័យនេះឯង ។ បទថា* ***កេវលស្ស ទុក្ខក្ខន្ធស្ស*** *(កងទុក្ខទាំងមូល) បានដល់ កងវដ្តទុក្ខទាំងអស់ ។ បទថា* ***អន្តកិរិយា បញ្ញាយេថ*** *(ការធ្វើទីបំផុត...នឹងគប្បីប្រាកដបាន) សេចក្តីថា ការធ្វើទីបំផុត គឺ ធ្វើការកំណត់ និងប្រុងស្មារតីគប្បីប្រាកដ ។ បទថា* ***ឱហាយ*** *គឺ* ***បហាយ*** *(លះបង់) ។ បទថា* ***បាបិដ្ឋតរេ***

(ដែលអាក្រក់ក្រៃលែង) បានដល់ ថោកទាបក្រៃលែង ។

បទថា **អារទ្ធំ** (ប្រារព្ធ) សេចក្តីថា (សេចក្តីព្យាយាម) ដែលផ្គងឡើងហើយ គឺ ឲ្យបរិបូរណ៍ហើយ និងឈ្មោះថា មិនធូរថយ ព្រោះផ្តើមហើយ ។ បទថា **ឧបដ្ឋិតា** (តាំងមាំ) សេចក្តីថា សតិ ឈ្មោះថា តាំងមាំ និងមិនវង្វេង ព្រោះតាំងមាំដោយអំណាចសតិប្បដ្ឋាន ៤ ។ បទថា **បស្សទ្ធោ កាយោ** (ស្ងប់កាយ) សេចក្តីថា នាមកាយ និងករជកាយស្ងប់ គឺ មានសេចក្តីខ្វល់ខ្វាយស្ងប់ហើយ និងព្រោះរម្ងាប់ហើយ ទើបឈ្មោះថា មិនរសាប់រសល់ ។ បទថា **សមាហិតំ ចិត្តំ** (ចិត្តតាំងមាំ) សេចក្តីថា ចិត្តដែលតាំងមាំដោយល្អ គឺ តាំងទុកដោយល្អក្នុងអារម្មណ៍ (និង) ព្រោះតាំងទុកដោយប្រពៃទុំះឯង ទើបឈ្មោះថា មានអារម្មណ៍តែមួយដ៏ប្រសើរ ។

បទថា **អធិបតី ករិត្វា** (ធ្វើ...ឲ្យជាអធិបតេយ្យ) បានដល់ ធ្វើធម៌ឲ្យជាធំ (សំខាន់) ។ បទថា **សុទ្ធមត្តានំ បរិហរតិ** (រក្សាខ្លួនឲ្យបរិសុទ្ធ) សេចក្តីថា រក្សា គឺ បដិបត្តិ បានដល់ ឃុំគ្រងខ្លួនឲ្យបរិសុទ្ធិ គឺ ឲ្យអស់មន្ទិល ។ មួយទៀត ភិក្ខុនេះឈ្មោះថា រក្សាខ្លួនឲ្យបរិសុទ្ធិដោយអម រហូតដល់អរហត្តមគ្គ ។ ចំណែកភិក្ខុសម្រេចផលហើយ ឈ្មោះថា រក្សាខ្លួនឲ្យបរិសុទ្ធិដោយត្រង់ ។ បទទាំងឡាយ មានបទថា **ស្វាក្ខាតោ** (ធម៌ដែលព្រះមានព្រះភាគត្រាស់

ល្អហើយ) ជាដើម បានអធិប្បាយទុកពិស្ដារហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **ជានំ បស្សំ វិហរន្តំ** (ដែលបណ្ឌិតឃើញហើយ) សេចក្ដីថា សព្រហ្មចារីទាំងឡាយឃើញធម៌នោះនៅ ។ ក៏ក្នុងបទថា **ឥមានិ ខោ ភិក្ខវេ តីណិ អធិបតេយ្យានិ** (ម្នាលភិក្ខុទាំងឡាយ អធិបតេយ្យ ៣ នេះឯង) នេះ មានសេចក្ដីថា អធិបតីទាំង ៣ យ៉ាងនោះ ព្រះមានព្រះភាគត្រាស់ទុកលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

បទថា **បកុព្វតោ** គឺ ករោន្តស្ស (សម្រាប់អ្នកធ្វើ) ។ បទថា **អត្តា តេ បុរិស ជានាតិ សច្ចំ វា យទិ វា មុសា** (ខ្លួនរបស់លោករមែងដឹងថាពិត ឬកុហក) សេចក្ដីថា លោកធ្វើវត្ថុណាទុក វត្ថុនោះនឹងមានពិត ឬមិនពិតក៏ដោយ ខ្លួនរបស់លោករមែងដឹងវត្ថុនោះ អ្នកសិក្សាគប្បីជ្រាបតាមហេតុនេះ ។ ឈ្មោះថា ទីបិទបាំងសម្រាប់អ្នកធ្វើបាបកម្ម មិនមានក្នុងលោក ។ បទថា **កល្យាណំ** គឺ **សុន្ទរំ** (សេចក្ដីល្អ) ។ បទថា **អតិមញ្ញសិ** (លោកប្រមាថ) គឺលោកសម្គាល់ហួស ។ បទថា **អថ នំ បរិគូហសិ**[១] (ដូចម្ដេចលោកបិទបាំងបាបនោះបាន) សេចក្ដីថា លោកព្យាយាមថា យើងនឹងបិទបាំងបាបទុកដោយប្រការដែលសូម្បីខ្លួនយើងក៏មិនដឹង ។

---

(១) ក្នុងអដ្ឋកថា គឺ អថ នំ បរិគុយ្ហសិ ។

បទថា **អត្តាធិបតោ** (មានខ្លួនជាធំ) បានដល់ មានខ្លួនជាអធិបតី គឺមានខ្លួនជាធំ ។ បទថា **លោកាធិបោ** (មានលោកជាធំ) បានដល់ មានលោកជាវត្ថុខ្ពង់ខ្ពស់ ។ បទថា **និបកោ** ប្រែថា មានបញ្ញា ។ បទថា **ឈាយី** (មានការសម្លឹង) ប្រែថា សម្លឹងហើយ ។ បទថា **ធម្មាធិបោ** (មានធម៌ជាធំ) បានដល់ មានធម៌ជាវត្ថុខ្ពង់ខ្ពស់ ។ បទថា **សច្ចប្បរក្កមោ** (មានសេចក្តីព្យាយាមដែលពិត) បានដល់ មានសេចក្តីពុះពារយ៉ាងមុតមាំ គឺ មានសេចក្តីប្រឹងប្រែងដោយពិត ។ បទថា **បសយ្ហ មារំ** (បង្ក្រាបមារ) បានដល់ គ្របសង្កត់មារ ។ បទថា **អភិភុយ្យ អន្តកំ** (គ្របសង្កត់មច្ចុ) នេះ ជាវេវចនៈរបស់បទថា **បសយ្ហ មារំ** (បង្ក្រាបមារ) នោះឯង ។

បទថា **យោ ច ផុសី ជាតិក្ខយំ បធានវា** (បុគ្គលណាមានសេចក្តីព្យាយាម...សម្រេចធម៌ដែលជាទីអស់នូវជាតិហើយ) សេចក្តីថា បុគ្គលណាមានប្រក្រតីសម្លឹង មានសេចក្តីព្យាយាមគ្របសង្កត់មារ ហើយសម្រេចអរហត្តផលដែលជាសភាវៈអស់ទៅនៃជាតិ ។ បទថា **សោ តាទិសោ** (បុគ្គលនោះដែលដូច្នោះ) បានដល់ បុគ្គលនោះ ប្រភេទនោះ គឺ តាំងនៅដោយអាការយ៉ាងនោះ ។ បទថា **លោកវិទូ** (អ្នកត្រាស់ដឹងលោក) គឺ ធ្វើលោកទាំង ៣ ឲ្យដឹងច្បាស់ គឺ ឲ្យប្រាកដតាំងនៅហើយ ។ បទថា **សុមេធោ** (អ្នកមានបញ្ញាល្អ)

*បានដល់ អ្នកមានបញ្ញាស្អាត ។ បទថា **សព្វេសុ ធម្មេសុ អតម្មយោ មុនិ** (ជាព្រះមុនី មិនមានចំណង់ក្នុងធម៌ទាំងពួង) សេចក្តីថា មុនី គឺ ព្រះខីណាស្រព ឈ្មោះថា អតម្មយៈ ព្រោះមិនមានតម្មយៈ ពោលគឺ តណ្ហាក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មានពាក្យអធិប្បាយថា លោកមិនវិនាស មិនសូន្យទៅ ក្នុងកាលណាៗ ក្នុងទីណាៗ ។*

ចប់អដ្ឋកថា អធិបតេយ្យសូត្រទី ១០

## ចប់ទេវទូតវគ្គវណ្ណនាទី ៤

## ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ០៩ សូត្រ

# ចុល្លវគ្គទី ៥

## អដ្ឋកថា សម្មុខីសូត្រទី ១

*"ហេតុឲ្យបានបុណ្យច្រើន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សម្មុខីសូត្រទី ១ ដូចតទៅនេះ ៈ-*

[៤២] *បទថា* ***សម្មុខីភាវា*** *គឺ* ***សម្មុខីភាវេន*** *(ព្រោះការព្រមព្រៀង) អធិប្បាយថា ព្រោះការមានហើយ ។ បទថា* ***បសវតិ*** *(រមែងបាន) បានដល់ បានចំពោះ ។ បទថា* ***សទ្ធាយ សម្មុខីភាវា*** *(ព្រោះការព្រមព្រៀងនៃសទ្ធា) សេចក្តីថា ព្រោះបើមិនមានសទ្ធា មិនមានទេយ្យធម៌ (និង) មិនមានបុគ្គលដែលជាបដិគ្គាហកៈ ពោលគឺ ព្រះទក្ខិណេយ្យបុគ្គលទេ នឹងគប្បីធ្វើបុញ្ញកម្មបានដូចម្តេច ។ តែព្រោះការព្រមព្រៀងនៃធម៌ ៣ នោះ ទើបអាចធ្វើបុញ្ញកម្មបាន ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យមានជាអាទិ៍ថា* ***ព្រោះការព្រមព្រៀងនៃសទ្ធា*** *ដូច្នេះ ។ ក្នុងធម៌ ៣ យ៉ាងនេះ ធម៌ ២ យ៉ាង គឺ ទេយ្យធម៌ ១ ទក្ខិណេយ្យបុគ្គល ១ រកបានងាយ តែសទ្ធារកបានលំបាក ។ ព្រោះបុថុជ្ជន មានសទ្ធាមិនមុតមាំ មានសភាពផ្សេងៗ ទៅតាមជំហានជើង ព្រោះហេតុនោះឯង សូម្បីព្រះអគ្គសាវក ដូចជាព្រះមហាមោគ្គល្លាន ក៏មិនអាច*

ជានាសទ្ធានោះបាន ទើបពោលថា ម្នាលអាវុសោ យើងជានាធម៌របស់លោក បាន ២ យ៉ាង គឺ ភោគៈ ១ ជីវិត ១ តែខ្លួនលោកត្រូវជានាសទ្ធា ដូច្នេះ ។

ចប់អដ្ឋកថា សម្មុខីសូត្រទី ១

# អដ្ឋកថា ឋានៈសូត្រទី ២

## *"លក្ខណៈបុគ្គលមានសទ្ធា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានៈសូត្រទី ២ ដូចតទៅនេះ ៖-*

*[៤៣] បទថា **វិគតមលមច្ឆេរេន** (ប្រាសចាកសេចក្តីកំណាញ់ដែលជាមន្ទិល) បានដល់ ប្រាសចាកមន្ទិល គឺ សេចក្តីកំណាញ់ ។ បទថា **មុត្តចាគោ** (មានការបរិច្ចាគរួចហើយ) សេចក្តីថា មានការលះបង់ស្រឡះហើយ ។ បទថា **បយតបាណិ** បានដល់ មានដៃដែលលាងហើយ (ធោតហត្ថោ) អធិប្បាយថា បុគ្គលមិនមានសទ្ធា សូម្បីលាងដៃដល់ ៧ ដង ក៏រាប់ថា នៅមានដៃប្រឡាក់ នុ៎ះឯង តែបុគ្គលមានសទ្ធា ឈ្មោះថា មានដៃដែលលាងស្អាតហើយនោះឯង ព្រោះជាអ្នកត្រេកអរក្រៃលែងហើយក្នុងទាន ។ បទថា **វោស្សគ្គរតោ** (ត្រេកអរក្នុងការលះបង់) សេចក្តីថា ត្រេកអរហើយក្នុងទាន ពោលគឺ ការលះបង់ ។ បទថា **យាចយោគោ** (គួរដល់ការសូម) សេចក្តីថា សមគួរឲ្យសូម ។ ម្យ៉ាងទៀត ឈ្មោះថា **យាចយោគោ** ព្រោះមានសេចក្តីសមគួរនឹងយាចកទាំងឡាយខ្វះ ។ បទថា **ទានសំវិភាគរតោ** (ពេញចិត្តក្នុងការឲ្យ និងការចែករំលែក) សេចក្តីថា កាលឲ្យទានក្តី កាលធ្វើការចែករំលែកក្តី រមែងឈ្មោះថា ត្រេកអរក្នុងទាន និងការចែករំលែក ។*

បទថា ទស្សនកាមោ សីលវតំ (ប្រាថ្នាក្នុងការឃើញអ្នកមានសីល) សេចក្តីថា មានសេចក្តីប្រាថ្នានឹងជួបអ្នកមានសីល ១០ យោជន៍ក៏ទៅ ២០ យោជន៍ក៏ទៅ ៣០ យោជន៍ក៏ទៅ ១០០ យោជន៍ក៏ទៅ ដូចបាដលីបុត្តកព្រាហ្មណ៍ និងព្រះបាទសទ្ធាតិស្សមហារាជ ។

## រឿងបាដលីបុត្តកព្រាហ្មណ៍

ដំណាលមកថា ជិតទ្វារព្រះនគរបាដលីបុត្រ មានព្រាហ្មណ៍ ២ នាក់ បានជ្រាបកិត្តិគុណរបស់ព្រះមហានាគត្ថេរៈ អ្នកនៅក្នុងកាឡវល្លិមណ្ឌប គិតគ្នាថា យើងទាំង ២ នាក់ គួរនឹងទៅរកភិក្ខុនោះ ដូច្នេះ ទាំងពីរនាក់ទើបចេញចាកព្រះនគរ ។ ម្នាក់ក៏ធ្វើមរណៈក្នុងរវាងផ្លូវ ។ ម្នាក់ទៅដល់ត្រើយសមុទ្រ ចុះទូកត្រង់កំពង់មហាជិត្តមកដល់អនុរាធបុរី សួរថា កាឡវល្លិមណ្ឌបនៅទីណា បានទទួលពាក្យឆ្លើយថា នៅរោហណជនបទ គេទៅដល់ទីនៅរបស់ព្រះថេរៈ តាមលំដាប់ កាន់យកទីស្នាក់ក្នុងផ្ទះដែលនៅឆ្ងាយ ជិតចុល្លគាមនគរ បានចាត់ចែងអាហារថ្វាយព្រះថេរៈ សួរដល់ទីនៅរបស់ព្រះថេរៈ ដើម្បីនឹងចូលជួបពីព្រឹក លុះព្រឹកឡើង ទៅឈរនៅក្រោយប្រជាជន ឃើញព្រះថេរៈដើរមកពីចម្ងាយ ក៏ឈរត្រង់ទីនោះឯងមួយស្របក់ ថ្វាយបង្គំហើយ ទើបចូលទៅរកចាប់កជើង (របស់ព្រះថេរៈ) ទុកយ៉ាងណែន ហើយប្រាប់ថា លោកម្ចាស់ខ្ពស់

ណាស់ ។ ក៏ព្រះថេរៈមិនខ្ពស់ពេក មិនទាបពេក មានខ្នាតល្មមប៉ុណ្ណោះ ព្រោះហេតុនោះ គេទើបប្រាប់លោកទៀតថា លោកម្ចាស់ មិនបានខ្ពស់ពេកទេ តែគុណរបស់លោកម្ចាស់ ផ្សាយទៅតាមទឹកសមុទ្រ ជោរជន់ដល់ផែនដីជម្ពូទ្វីបទាំងអស់ ។ សុមនីខ្ញុំអង្គុយនៅជិតទ្វារព្រះនគរបាដលីបុត្រ ក៏បានឮកិត្តិគុណរបស់លោកម្ចាស់ ។ គេបានថ្វាយភិក្ខាហារចំពោះព្រះថេរៈ ចាត់ចែងត្រៃចីវររបស់ខ្លួន ហើយបានបួសក្នុងសំណាក់របស់ព្រះថេរៈ តាំងនៅក្នុងឱវាទរបស់លោកហើយ បានសម្រេចអរហត្តផលត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ ។

## រឿងព្រះបាទសទ្ធាតិស្សមហារាជ

សុមនីព្រះបាទសទ្ធាតិស្សមហារាជ ត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ចូរប្រាប់ភិក្ខុមួយរូប ដែលសមគួរញ៉ោមនឹងថ្វាយបង្គំ ។ ភិក្ខុទាំងឡាយថ្វាយព្រះពរថា លោកម្ចាស់កុដ្ឋតិស្សត្ថេរៈ អ្នកនៅក្នុងមង្គលារាម ។ ព្រះរាជាព្រមដោយបរិវារជាច្រើន ស្ដេចបានទៅអស់រយៈផ្លូវ ៥ យោជន៍ ។ ព្រះថេរៈសួរភិក្ខុសង្ឃថា នោះសំឡេងអ្វី ។ ភិក្ខុសង្ឃប្រាប់ថាព្រះរាជាស្ដេចមកដើម្បីនឹងនមស្ការលោកម្ចាស់ ។ ព្រះថេរៈគិតថា នឹងមានការងារអ្វីក្នុងព្រះរាជវាំង ក្នុងវេលាដែលយើងចាស់ ទើបដេកលើគ្រែក្នុងទីសម្រាកពេលថ្ងៃ បានគូសស្នាម (គូសទៅមក) លើផែនដី ។ ព្រះរាជាត្រាស់

សួរថាភិក្ខុសង្ឃ ព្រះថេរៈទៅណា ។ ទ្រង់ស្តាប់ថា ព្រះថេរៈធ្វើវត្តនៅក្នុងទីសម្រាកពេលថ្ងៃ ទើបស្តេចទៅទីនោះ ឃើញព្រះថេរៈកំពុងគូសស្នាមលើផែនដី ទ្រង់ព្រះត្រិះរិះថា ធម្មតាព្រះខីណាស្រពមិនមានការឃ្មើសឃ្មងដៃ ភិក្ខុអង្គនេះមិនមែនជាព្រះខីណាស្រព ទើបទ្រង់មិនថ្វាយបង្គំ ហើយស្តេចត្រឡប់ទៅ ។ ភិក្ខុសង្ឃប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុអ្វី លោកម្ចាស់ទើបបង្កើតសេចក្តីក្តៅក្រហាយព្រះទ័យដល់ព្រះរាជា ដែលទ្រង់មានសទ្ធាជ្រះថ្លាដូច្នេះ ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ការរក្សាព្រះរាជសទ្ធា មិនមែននាទីរបស់លោកទាំងឡាយ (តែ) ជានាទីរបស់ព្រះថេរៈចាស់ ហើយកាលនឹងបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលតមក ទើបពោលនឹងភិក្ខុសង្ឃថា លោកទាំងឡាយចូរក្រាលបល្ល័ង្កសូម្បីដទៃទុកលើកូដាគារសម្រាប់យើង កាលភិក្ខុសង្ឃក្រាលបល្ល័ង្កហើយ ព្រះថេរៈអធិដ្ឋានថា ក្នុងវាងនេះសូមឲ្យកូដាគារនេះកុំអាលប្រតិស្ឋាន ក្នុងវេលាដែលព្រះរាជាទ្រង់ឃើញហើយទើបប្រតិស្ឋាននៅត្រង់ផែនដី ហើយបរិនិព្វាន ។ កូដាគារបានអណ្តែតទៅកាន់អាកាសអស់ចម្ងាយផ្លូវ ៥ យោជន៍ ។ ដើមឈើដែលល្មមនឹងដោតទង់បាន ក៏បានដោតទង់ទុក រហូតអស់ចម្ងាយផ្លូវ ៥ យោជន៍ ឈើទាំងគុម្ពៗក៏បានទោរទៅរកកូដាគារទាំងអស់ ។

ភិក្ខុទាំងឡាយបញ្ជូនដំណឹងទៅទូលព្រះរាជាថា ព្រះថេរៈបរិនិព្វានហើយ កូដាគារកំពុងអណ្តែតមកតាមអាកាស ។ ព្រះរាជាទ្រង់មិនជឿ ។ កូដាគារអណ្តែតមកតាមអាកាស ធ្វើប្រទក្សិណថូបារាម ហើយបានទៅសិលាចេតិយ-ស្ថាន ។ ព្រះចេតិយព្រមទាំងរបស់របរ បានអណ្តែតឡើង ទៅប្រតិស្ថាននៅលើកំពូលកូដាគារ ។ សំឡេងសាធុការទាំងពាន់ ក៏ដូចគ្រហឹមឡើង ។ ក្នុងខណៈនោះ ព្រះមហាព្យគ្ឃត្ថេរអង្គុយនៅលើកូដាគារជាន់ទី ៧ ជិតលោហ-ប្រាសាទ កំពុងធ្វើវិន័យកម្មដល់ភិក្ខុទាំងឡាយ បានឮសំឡេង (សាធុការ) នោះហើយ សាកសួរថា នោះសំឡេងអ្វី ។ ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះកុដ្ឋតិស្សត្ថេរ អ្នកនៅក្នុងមង្គលារាមបរិនិព្វានហើយ ។ កូដាគារអណ្តែតមកផ្លូវអាកាសអស់ចម្ងាយផ្លូវ ៥ យោជន៍ នោះជាសំឡេងសាធុការ ព្រោះកូដាគារ (ដែលអណ្តែតមក) នោះ ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ យើងនឹងអាស្រ័យលោកអ្នកមានបុណ្យហើយ បានសក្ការៈហោះមកតាមអាកាសនោះឯង អង្គុយលើគ្រែទីពីរ ហើយបរិនិព្វានដោយអនុ-បាទិសេសនិព្វានធាតុ ។ ព្រះរាជាទ្រង់កាន់យករបស់ក្រអូប ផ្កាឈើ និងលំអិតចន្ទន៍ ហើយស្តេចទៅបូជាកូដាគារដែលស្ថិតនៅក្នុងអាកាស ។ ក្នុងខណៈនោះ កូដាគារបានអណ្តែតមកប្រតិស្ឋានលើផែនដី ។ ព្រះរាជាបានត្រាស់បង្គាប់ឲ្យ

ធ្វើសរីរកិច្ចដោយសក្ការៈដ៏ធំ ហើយទ្រង់ទទួលយកព្រះធាតុទៅសាងចេតិយ ។ លោកដែលទ្រទ្រង់សីលបែបនេះ មានអ្នកប្រាថ្នានឹងឃើញជាធម្មតា ។ ព្រះបាទសទ្ធាតិស្សមហារាជនឹងជាអគ្គសាវកទី ២ របស់ព្រះស្រីអរិយមេត្តេយ្យ (ក្នុងអនាគត) ។

បទថា **សទ្ធម្មំ សោតុមិច្ឆតិ** (ប្រាថ្នាស្តាប់ព្រះធម៌) សេចក្តីថា ជាអ្នកប្រាថ្នានឹងស្តាប់ព្រះសទ្ធម្ម ដែលព្រះតថាគតទ្រង់ប្រកាសហើយ ដូចព្រះបិណ្ឌ-បាតិកត្ថេរជាដើម ។

## រឿងព្រះបិណ្ឌបាតិកត្ថេរ

បានឮមកថា ភិក្ខុ ៣០ រូប ចូលចាំវស្សាលើទីទួល ឈ្មោះថា គវវាឡៈ រាល់កន្លះខែ ក្នុងថ្ងៃឧបោសថ បាននិយាយគ្នាដល់មហាអរិយវង្ស ដែលពណ៌នាដល់ការសន្តោសដោយបច្ច័យ ៤ និងការត្រេកអរក្នុងភាវនា ។ ព្រះថេរៈអ្នកសមាទានបិណ្ឌបាតជាវត្តមួយរូប មកក្រោយអង្គុយក្នុងទីកំបាំង លំដាប់នោះពស់មួយក្បាលបានខាំលោក ដូចជាយកដង្កាប់ចាប់ទាញសាច់កំភួនជើងចេញអំពីជើង ។ ព្រះថេរៈសម្លឹងមើលឃើញពស់នោះ គិតថា ថ្ងៃនេះ យើងនឹងមិនធ្វើអន្តរាយដល់ការស្តាប់ធម៌ ចាប់ពស់ដាក់ចូលក្នុងថង់យាមចងមាត់ទុក ហើយដាក់ទុកក្នុងទីមិនឆ្ងាយ អង្គុយស្តាប់ធម៌បន្ត ។ អរុណរះឡើង ១ ពិស

ពស់ស្ងប់ ព្រះថេរៈបានសម្រេចផលទាំង បី ១ ពិសពស់ហូរចេញពីមាត់របួស ចូលទៅក្នុងដី ១ ព្រះថេរៈអ្នកសម្តែងធម៌ ចប់ធម្មកថា ១ (យ៉ាងនេះ) មានក្នុងខណៈតែមួយទុះឯង ។ តពីនោះ ព្រះថេរៈបាននិយាយថា អាវុសោទាំងឡាយ យើងចាប់ចោរបានមួយ ហើយស្រាយថង់យាមចេញ ព្រលែងពស់ឲ្យចេញទៅ ។ ភិក្ខុទាំងឡាយឃើញហើយ ទើបសួរថា វាខាំលោកម្ចាស់វេលាណា ។

ព្រះថេរៈ : អាវុសោទាំងឡាយ ខ្ញុំត្រូវវាខាំពេលល្ងាចម្សិលមិញ ។

ភិក្ខុ : លោកម្ចាស់ ហេតុអ្វី លោកដល់ធ្វើកម្មធ្ងន់យ៉ាងនេះ ។

ព្រះថេរៈ : អាវុសោទាំងឡាយ បើខ្ញុំប្រាប់ថា ខ្ញុំត្រូវពស់ខាំសោត ខ្ញុំនឹងមិនបានអានិសង្សមានប្រមាណប៉ុណ្ណេះ ។ នេះជារឿង (ឧបមា) របស់ព្រះបិណ្ឌបាតិកត្ថេរៈ ។

## រឿងភិក្ខុកំលោះអ្នកស្រុកតិស្សមហាវិហារ

ភិក្ខុកំលោះមួយរូប នៅប្រចាំនឹងតិស្សមហាវិហារ ជិតស្រុកធំមួយ បានជ្រាបថា ព្រះថេរៈអ្នកទេសនាមហាជាតក នឹងទេសន៍មហាវេស្សន្តរពាន់គាថា ក្នុងក្រុងទីឃវាបិ ទើបចេញចាកវត្តមកអស់ចម្ងាយផ្លូវ ១ យោជន៍ ដោយ (ដើរ) ក្នុងមួយថ្ងៃប៉ុណ្ណោះ ។ ក្នុងខណៈនោះឯង ព្រះថេរៈផ្តើមសម្តែងធម៌ ។

ភិក្ខុកម្លោះកំណត់បានចំពោះគាថាចុងក្រោយ និងគាថាដើម ព្រោះកើតសេចក្តីកន្ទល់ផ្លូវកាយ ដោយការដើរផ្លូវឆ្ងាយ ។ តពីនោះ ក្នុងវេលាដែលព្រះថេរៈពោលពាក្យថា **ឥទមវោច** (ចប់) ហើយក្រោកចេញទៅ ភិក្ខុកម្លោះបានឈរស្រែកយំដោយទាស់ចិត្តថា ការធ្វើដំណើរមករបស់យើងក្លាយជាគ្មានប្រយោជន៍ទៅហើយ ។ បុរសម្នាក់ បានឮពាក្យនោះហើយ បានទៅប្រាប់ព្រះថេរៈថា លោកម្ចាស់ ភិក្ខុកម្លោះមួយរូបមកពីតិស្សមហាវិហារ ដោយប្រាថ្នាថា នឹងស្តាប់ធម្មកថារបស់លោកម្ចាស់ លោកបានឈរយំហើយពោលថា ការមករបស់យើងក្លាយជាគ្មានប្រយោជន៍ ព្រោះមានសេចក្តីកន្ទល់ផ្លូវកាយ ។ ព្រះថេរៈឆ្លើយថា ទៅចុះ ទៅឲ្យសញ្ញាដល់លោកថា ថ្ងៃស្អែកនេះ យើងនឹងសម្តែងធម៌នោះដដែលទៀត ។ ស្អែកឡើង លោកបានស្តាប់ធម្មកថារបស់ព្រះថេរៈហើយ ក៏បានសម្រេចសោតាបត្តិផល ។

## រឿងស្ត្រីអ្នកក្រុងឧលុម្ពកោលិកណ្ណិ

នៅមានរឿងមួយទៀត ស្ត្រីអ្នកឧលុម្ពកោលិកណ្ណិជនបទម្នាក់ កំពុងឲ្យកូនបៅដោះ បានឮដំណឹងថា ព្រះមហាអភ័យត្ថេរអ្នកពោលគម្ពីរទីឃនិកាយ នឹងសម្តែងអរិយវង្សប្បដិបទាសូត្រ ទើបបានធ្វើដំណើរទៅអស់ចម្ងាយផ្លូវ ៥ យោជន៍ ចូលទៅកាន់វិហារ ក្នុងវេលាដែលព្រះថេរៈអ្នកទេសនាពេលថ្ងៃ គង់

ទេសន៍ ក៏ឲ្យកូនដេកលើផែនដី ឈរស្តាប់ធម៌របស់ព្រះថេរៈដែលទេសន៍ក្នុងពេលថ្ងៃ ។ សូម្បីព្រះថេរៈសម្តែងបទភាណ ក៏ឈរស្តាប់ដូចគ្នា ។ កាលព្រះថេរៈអ្នកទេសន៍បទភាណក្រោកឡើងហើយ ព្រះមហាថេរៈអ្នកពោលទីឃនិកាយក៏ផ្តើមសម្តែងមហាអរិយវង្ស ពណ៌នាដល់ការសន្តោសដោយបច្ច័យ ៤ និងការត្រេកអរដោយភាវនា ។ នាងឈរលើកដៃប្រណមស្តាប់ ។ ព្រះថេរៈសម្តែងបច្ច័យ ៣ ហើយ ធ្វើអាការនឹងក្រោកឡើង ។ នាងទើបប្រាប់ថា លោកម្ចាស់គិតថា នឹងទេសន៍អរិយវង្ស ហើយ (ត្រឡប់ទៅ) ឆាន់កោជនដែលឆ្ងាញ់ផឹកទឹកដែលមានរសផ្អែម ផ្សំថ្នាំដោយឈើឯម និងប្រេងជាដើម ទើបក្រោកឡើងក្នុងឋានៈដែលគួរនឹងសម្តែង (ធម៌) ។ ព្រះថេរៈពោលថា ប្រពៃហើយប្អូនស្រី ហើយផ្តើមធម៌ដែលជាទីត្រេកអរក្នុងភាវនាតទៅ ។ អរុណារះឡើង ១ ព្រះថេរៈពោលពាក្យថា **ឥទមវោច** ១ ឧបាសិកាបានសម្រេចសោតាបត្តិផល ១ (៣ យ៉ាងនេះ) ក៏មានក្នុងខណៈតែមួយនោះឯង ។

## រឿងស្ត្រីអ្នកស្រុកកាឡុមពរៈ

ស្ត្រីម្នាក់ទៀត ជាអ្នកស្រុកកាឡុពរៈ ពកូនទៅកាន់ចិត្តបព្វត ដោយគិតថា នឹងស្តាប់ធម៌ ឲ្យកូនដេកផ្អែកដើមឈើមួយដើម ខ្លួនឯងឈរស្តាប់ធម៌ក្នុងចន្លោះរត្តិភាគ ពស់មួយក្បាលខាំកូនដែលដេកនៅទីជិតនាង ទាំងដែលមើល

ឃើញស្នាមដាំខៀវរបស់ចន្លុមទាំង ៤ ហើយក៏លូនចេញទៅ ។ នាងគិតថា បើយើងនឹងប្រាប់ថា កូនរបស់យើងត្រូវពស់ខាំ នឹងជាអន្តរាយដល់ការស្តាប់ធម៌ កាលដែលយើងនៅវិលវល់ក្នុងសង្សារវដ្ត កូននេះ បានជាកូនរបស់យើងមកច្រើនជងហើយ យើងនឹងប្រព្រឹត្តធម៌ប៉ុណ្ណោះ ហើយឈររហូតអស់ទាំង ៣ យាម ផ្គងធម៌ទុក ក៏បានសម្រេចសោតាបត្តិផល ។ កាលអរុណរះហើយ ក៏ទម្លាយពិស (ពស់) ក្នុងបុត្រដោយការធ្វើសច្ចកិរិយា ហើយពបុត្រទៅ បុគ្គលបែបនេះ រមែងឈ្មោះថា ជាអ្នកប្រាថ្នាការស្តាប់ធម៌ ។

ចប់អដ្ឋកថា ឋានៈសូត្រទី ២

# អដ្ឋកថា បច្ចយវត្ថុសូត្រទី ៣

*“ប្រយោជន៍ ៣ ដែលអ្នកសម្តែងធម៌គួរពិចារណា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បច្ចយវត្ថុសូត្រទី ៣ ដូចតទៅនេះ ៖-*

[៤៤] *បទថា* ***តយោ ភិក្ខវេ អត្ថវសេ សម្បស្សន្តេន*** *(ម្នាលភិក្ខុទាំងឡាយ កាលឃើញប្រយោជន៍ ៣) សេចក្តីថា ឃើញប្រយោជន៍ ៣ យ៉ាង គឺ ហេតុ ៣ យ៉ាង ។ បទថា* ***អលមេវ*** *(គួរ) បានដល់ គួរហើយនោះឯង ។ បទថា* ***យោ ធម្មំ ទេសេតិ*** *(បុគ្គលណាសម្តែងធម៌) សេចក្តីថា បុគ្គលណាប្រកាសសច្ចធម៌ទាំង ៤ ។ បទថា* ***អត្ថប្បដិសំវេទី*** *(បានរសនៃអត្ថ) សេចក្តីថា បែកធ្លាយអដ្ឋកថាដោយញាណ ។ បទថា* ***ធម្មប្បដិសំវេទី*** *(បានរសនៃធម៌) សេចក្តីថា បែកធ្លាយក្នុងធម៌ដែលជាព្រះបាលី ។*

ចប់អដ្ឋកថា បច្ចយវត្ថុសូត្រទី ៣

# អដ្ឋកថា បរេសសូត្រទី ៤

## *"ហេតុឲ្យកើតការសន្ទនាធម៌"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរេសសូត្រទី ៤ ដូចតទៅនេះ ៈ-*

[៤៥] *បទថា* ***ឋានេហិ*** *(ដោយឋានៈ) បានដល់ ដោយហេតុទាំងឡាយ ។*

*បទថា* ***បវត្តនី*** *(ប្រព្រឹត្តទៅ) សេចក្តីថា មិនត្រូវជំទាស់ គឺ នាំទៅបាន ។*

ចប់អដ្ឋកថា បរេសសូត្រទី៤

# អដ្ឋកថា បណ្ឌិតសូត្រទី ៥

## *“ឋានៈ ៣ ដែលបណ្ឌិតបញ្ញត្តិទុក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បណ្ឌិតសូត្រទី ៥ ដូចតទៅនេះ ៈ-*

*[៤៦] បទថា **បណ្ឌិតបញ្ញត្តានិ** (បណ្ឌិតបានបញ្ញត្តិទុក) សេចក្តីថា ដែលបណ្ឌិតទាំងឡាយបញ្ញត្តិទុក គឺ ពោលទុក បានដល់ សរសើរហើយ ។ បទថា **សប្បុរិសបញ្ញត្តានិ** (សប្បុរសបានបញ្ញត្តិទុក) សេចក្តីថា ដែលសប្បុរសទាំងឡាយ គឺ មហាបុរសទាំងឡាយ បញ្ញត្តិទុកហើយ គឺ ពោលទុកហើយ បានដល់ សរសើរហើយ ។*

*ទាំងករុណា ទាំងធម៌ជាខាងដើមរបស់ករុណា ឈ្មោះថា **អវិហិង្សា** ។ ការសង្រួមក្នុងសីល ឈ្មោះថា **សញ្ញមៈ** ។ ការសង្រួមឥន្ទ្រិយ ឬការទូន្មានខ្លួនដោយឧបោសថ ឈ្មោះថា **ទមៈ** ។ ចំណែកក្នុងបុណ្ណោវាទសូត្រ ព្រះអង្គត្រាស់ហៅថា **ទមៈ** ។ សូម្បីបញ្ញាដែលត្រាស់ទុកក្នុងអឡវកសូត្រ ក៏សមគួរក្នុងព្រះសូត្រនេះដូចគ្នា ។*

*ការរក្សា ឃុំគ្រង ប្រណិបត្តិមាតាបិតា ឈ្មោះថា **មាតាបិតាឧបដ្ឋាន** ។ បទថា **សន្តានំ** (អ្នកស្ងប់) សេចក្តីថា ក្នុងសូត្រដទៃ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវកទាំងឡាយ ឈ្មោះថា **សប្បុរស** តែក្នុងព្រះសូត្រនេះ ទ្រង់*

បំណាច់យកបុគ្គលដែលទំនុកបម្រុងមាតាបិតា ។ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបឈ្មោះថា សប្បុរស ព្រោះអត្ថថា ខ្ពង់ខ្ពស់ ឈ្មោះថា ព្រហ្មចារី ព្រោះអត្ថថា ប្រព្រឹត្តប្រសើរទីបំផុត ។ ការទំនុកបម្រុងមាតាបិតានេះ សប្បុរសទាំងឡាយបញ្ញត្តិទុកហើយ គប្បីជ្រាបសេចក្តីក្នុងរឿងនេះ ដូចពណ៌នាមកនេះឯង ។

បទថា ***សតំ ឯតានិ ឋានានិ*** (គុណធម៌ទាំងនេះ ជាឋានៈនៃសប្បុរស) សេចក្តីថា ប្រការទាំងនេះជាឋានៈ គឺ ជាហេតុរបស់សប្បុរសទាំងឡាយ ។ បុគ្គលដែលទាំងប្រសើរ និងដល់ព្រមដោយទស្សនៈ (ការឃើញ) ព្រោះហេតុនៃឋានៈទាំង ៣ នេះឯង គប្បីជ្រាបថា **ជាបុគ្គលប្រសើរ និងដល់ព្រមដោយទស្សនៈ** ក្នុងព្រះសូត្រនេះ មិនមែនព្រះពុទ្ធជាដើម និងក៏មិនមែនជាព្រះសោតាបន្ន (ជាបុថុជ្ជន) ។

ន័យមួយទៀត គប្បីជ្រាបអត្ថាធិប្បាយនៃព្រះគាថានេះ ដោយអំណាចនៃការទំនុកបម្រុងមាតាបិតា យ៉ាងនេះថា ហេតុរបស់សប្បុរសទាំងឡាយ បានដល់ ឧត្តមបុរសទាំងឡាយនេះ គឺ ការទំនុកបម្រុងមាតា ១ ការបម្រុងបិតា ១ ឈ្មោះថា ឋានៈទាំងនេះ ជាឋានៈរបស់សប្បុរសទាំងឡាយ ។ ពិតហើយ បុគ្គលទំនុកបម្រុងមាតាបិតាប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ហៅថា **ជាបុគ្គល**

*ប្រសើរ និងជល់ព្រមដោយទស្សនះ ក្នុងព្រះសូត្រនេះ ។ បទថា ស លោកំ ភជតេ សិវំ (បុគ្គលនោះ រមែងចូលជល់លោកដ៏ក្សេម) សេចក្តីថា បុគ្គលនោះ រមែងទៅកាន់ទេវលោកដែលជាដែនក្សេម ។*

ចប់អដ្ឋកថា បណ្ឌិតសូត្រទី ៤

# អដ្ឋកថា សីលសូត្រទី ៦

## *"អ្នកដែលបង្កើតបុណ្យ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ៦ ដូចតទៅនេះ ៈ-*

*[៤៧] បទថា **តីហិ ឋានេហិ** (ដោយឋានៈ ៣) សេចក្តីថា ដោយហេតុ ៣ យ៉ាង ។ ក្នុងបទថា **កាយេន** (ដោយកាយ) ជាដើម មានអធិប្បាយថា មនុស្សទាំងឡាយ ឃើញភិក្ខុទាំងឡាយនិមន្តមក នឹងធ្វើការក្រោកទទួល ឃើញនិមន្តទៅក៏តាមជូនទៅ ធ្វើការប្រាប់ និងលាប (ជើងដោយប្រេង) ជាដើម ក្រាលអាសនៈទុកលើអាសនៈសាលា តាំងទឹកផឹកទុក ឈ្មោះថា **រមែងបានបុណ្យដោយកាយ** ។*

*មនុស្សទាំងឡាយឃើញភិក្ខុសង្ឃកំពុងនិមន្តបិណ្ឌបាត កាលពោលពាក្យជាដើមថា លោកទាំងឡាយចូរប្រគេនយាគូ ចូរប្រគេនបាយ ទឹកដោះថ្លា និងទឹកដោះខាប់ជាដើម ចូរបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម ចូររក្សាឧបោសថ ចូរស្តាប់ធម៌ និងចូរថ្វាយបង្គំព្រះចេតិយចុះ ដូច្នេះ ឈ្មោះថា **រមែងបានបុណ្យដោយវាចា** ។*

*អ្នកទាំងឡាយឃើញភិក្ខុទាំងឡាយកំពុងនិមន្តបិណ្ឌបាត កាលគិតថា សូមឲ្យអ្នកស្រុកបានថ្វាយទានចុះ ដូច្នេះ ឈ្មោះថា **រមែងបានបុណ្យដោយចិត្ត** ។*

*បទថា **បសវន្តិ** (រមែងបាន) បានដល់ បានចំពោះ ។ ក៏ក្នុងព្រះសូត្រនេះ ព្រះអង្គត្រាស់បុណ្យដែលលាយដោយលោកិយៈ និងលោកុត្តរៈ ។*

ចប់អដ្ឋកថា សីលសូត្រទី ៦

# អដ្ឋកថា សង្ខតសូត្រទី ៧

## *“លក្ខណៈ ៣ នៃសង្ខតធម៌”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ខតសូត្រទី ៧ ដូចតទៅនេះ ៖-*

*[៤៨] បទថា **សង្ខតស្ស** (សង្ខតធម៌) សេចក្ដីថា ដែលបច្ច័យទាំងឡាយមកប្រមូលគ្នាសាង (តាក់តែង) ។ គ្រឿងសម្គាល់ ដែលជាហេតុឲ្យសម្គាល់ដឹងថា វត្ថុនេះ ដែលបច្ច័យតាក់តែងហើយ ឈ្មោះថា **សង្ខតលក្ខណៈ** ។ បទថា **ឧប្បាទោ** បានដល់ ការកើត (ជាតិ) ។ បទថា **វយោ** (ការវិនាស) បានដល់ ការបែកធ្លាយ ។ សេចក្ដីទ្រុឌទ្រោម ឈ្មោះថា កាប្រែប្រួលនៃសង្ខតធម៌ដែលតាំងនៅហើយ ។*

*ក្នុងបទថា **សង្ខតលក្ខណៈ** នោះ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **សង្ខតៈ** ។ តែមគ្គ ផល ព្រះនិព្វាន ព្រះមានព្រះភាគមិនត្រាស់ទុកក្នុងព្រះសូត្រនេះ ព្រោះមិនចូលដល់ការពិចារណា ។ ការកើតឡើងជាដើម ឈ្មោះថា សង្ខតលក្ខណៈ ។ បណ្ដាលក្ខណៈទាំង ៣ នោះ ការកើតឡើង មានក្នុងឧប្បាទខណៈ ។ ការចាស់ មានក្នុងខណៈដែលតាំងនៅ (ឋិតិខណៈ) ។ ការវិនាស មានក្នុងភង្គខណៈ ។ លក្ខណៈ (គ្រឿងសម្គាល់) មិនមែនសង្ខតៈ (វត្ថុដែលត្រូវតាក់តែង) , សង្ខតៈ (វត្ថុដែលត្រូវតាក់តែង) ក៏មិនមែនលក្ខណៈ*

*(គ្រឿងសម្គាល់) ។ តែវត្ថុដែលជាសង្ខតៈ ត្រូវកំណត់ដោយលក្ខណៈ ។ ដូចលក្ខណៈរបស់ដំរី សេះ គោ និងក្របីជាដើម ដែលជាហេតុឲ្យចាំបាន ស្គាល់បាន ដូចជាស្នូរ លំពែងជាដើម មិនមែន (ខ្ទន) ដំរីជាដើម សូម្បី (ខ្ទន) ដំរីជាដើម ក៏មិនមែនលក្ខណៈដូចគ្នា តែដំរី សេះ គោ និងក្របីជាដើមនោះ (យើង) ដឹងបានថា ជាដំរីរបស់អ្នកឯណោះ សេះរបស់អ្នកឯណោះ ឬដំរីឈ្មោះឯណោះ សេះឈ្មោះឯណោះ ក៏ដោយលក្ខណៈទាំងឡាយ យ៉ាងណាការឧបមេយ្យនេះ ក៏គប្បីជ្រាបដូច្នោះ ។*

ចប់អដ្ឋកថា សង្ខតសូត្រទី ៧

# អដ្ឋកថា អសង្ខតសូត្រទី ៨

## *“លក្ខណៈ ៣ នៃអសង្ខតធម៌”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសង្ខតសូត្រទី ៨ ដូចតទៅនេះ ៈ-*

*[៤៩] បទថា **អសង្ខតស្ស** (អសង្ខតធម៌) បានដល់ ដែលបច្ច័យទាំងឡាយមិនបានប្រមូលសាងឲ្យកើត (មិនបានតាក់តែង) ។ គ្រឿងសម្គាល់ដែលជាហេតុឲ្យដឹងបានថា វត្ថុនេះមិនមានបច្ច័យតាក់តែង ឈ្មោះថា **អសង្ខតលក្ខណៈ** ។ ដោយបទថា **ន ឧប្បាទោ បញ្ញាយតិ** (ការកើតឡើងមិនប្រាកដ) ជាដើម ព្រះមានព្រះភាគត្រាស់ដល់ការមិនមាននៃការកើតឡើង ទាំងការចាស់ និងការរលត់ ។ ក៏ព្រោះមិនមានលក្ខណៈ មានការកើតឡើងជាដើម ទើបប្រាកដជាអសង្ខតៈ ។*

ចប់អដ្ឋកថា អសង្ខតសូត្រទី ៨

# អដ្ឋកថា បព្វតរាជសូត្រទី ៩

## *"ការពឹងអាស្រ័យជាហេតុឲ្យចម្រើន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បព្វតរាជសូត្រទី ៩ ដូចតទៅនេះ ៖-*

[៥០] *ដើមឈើធំ ឈ្មោះថា* **មហាសាលា** *។ បុគ្គលចម្រើនបំផុតក្នុងត្រកូល ឈ្មោះថា* **កុលបតិបុគ្គល** *។ បទថា* **សេលោ** *(ថ្មសុទ្ធ) បានដល់ (ភ្នំ) ថ្មសុទ្ធ ។ បទថា* **អរញ្ញស្មឹ** *(ក្នុងព្រៃ) បានដល់ ក្នុងទីមិនមែនស្រុក ។ បទថា* **ព្រហា** *គឺ* **មហន្តោ** *(ធំ) ។ បទថា* **វនេ** *គឺ* **អដវិយំ** *(ព្រៃ) ។ ដើមឈើដែលធំទីបំផុតក្នុងព្រៃ ឈ្មោះថា* **មេព្រៃ** *។ បទថា* **ឥធ ធម្មំ ចរិត្វាន មគ្គំ សុគតិគាមិនំ** *(ប្រព្រឹត្តធម៌ដែលជាផ្លូវឲ្យដល់សុគតិ ក្នុងលោក) សេចក្តីថា ប្រព្រឹត្តធម៌ ពោលគឺ ផ្លូវដែលឲ្យដំណើរទៅកាន់សុគតិ ។*

ចប់អដ្ឋកថា បព្វតសូត្រទី ៩

# អដ្ឋកថា អាតប្បសូត្រទី ១០

## *"សេចក្តីព្យាយាម ៣"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាតប្បសូត្រទី ១០ ដូចតទៅនេះ ៈ-*

*[៥១] បទថា **អាតប្បំ ករណីយំ** (សេចក្តីព្យាយាម គប្បីធ្វើ) សេចក្តីថា គួរប្រកបសេចក្តីព្យាយាម ។ បទថា **អនុប្បាទាយ** (ដើម្បី...មិនឲ្យកើតឡើង) សេចក្តីថា ដើម្បីត្រូវការមិនឲ្យកើតឡើង អធិប្បាយថា ត្រូវធ្វើដោយហេតុនេះ គឺ ដោយគិតថា យើងនឹងពិចារណាមិនឲ្យកិលេសកើតឡើង ។ សូម្បីតពីនេះទៅ ក៏មានន័យនេះដូចគ្នា ។*

*បទថា **សារីរិកានំ** (វេទនាដែលប្រព្រឹត្តផ្លូវកាយ) ដែលកើតក្នុងសរីរៈ ។ បទថា **ទុក្ខានំ** (ជាទុក្ខ) សេចក្តីថា (វេទនាទាំងឡាយ) ដែលជាទុក្ខ ។ បទថា **តិព្វានំ** (ខ្លាំងក្លា) បានដល់ ធ្ងន់ ឬខ្លាំងក្លាដោយអំណាចនៃការដុតពោល ។ បទថា **ខរានំ** (រឹង) បានដល់ គ្រោតគ្រាត ។ បទថា **កដុកានំ** (ដុតពោល) បានដល់ ក្តៅពោលពល ។ បទថា **អសាតានំ** (មិនគាប់ចិត្ត) បានដល់ មិនឆ្ងាញ់ពិសា ។ បទថា **អមនាបានំ** (មិនគួរត្រេកអរ) បានដល់ មិនអាចឲ្យចម្រើនចិត្តបាន ។ បទថា **បាណហរានំ** បានដល់ ផ្តាច់ផ្តិលជីវិត ។ បទថា **អធិវាសនាយ** (ដើម្បីអត់ទ្រាំ) បានដល់ ដើម្បីត្រូវការរពាំង គឺ ដើម្បីត្រូវការ*

អត់ទ្រាំ បានដល់ ដើម្បីត្រូវការអត់ធន់ ។

ព្រះសាស្តាត្រាទ្រង់បង្គាប់ គឺ ទ្រង់ញុំាងអាណត្តិសង្ឃឲ្យប្រព្រឹត្តទៅក្នុងឋានៈមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលនឹងទ្រង់ដឹកនាំ (ភិក្ខុទាំងឡាយ) ទើបត្រាស់ពាក្យមានជាអាទិ៍ថា **យតោ ខោ ភិក្ខវេ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យតោ** គឺ **យទា** (កាលណា) ។ បទថា **អាតាបី** (មានសេចក្តីព្យាយាម) បានដល់ មានវីរិយៈ ។ បទថា **និបកោ** បានដល់ មានបញ្ញា ។ បទថា **សតោ** (មានសតិ) បានដល់ ប្រកបដោយសតិ ។ បទថា **ទុក្ខស្ស អន្តកិរិយាយ** (ដើម្បីធ្វើនូវទីបំផុតទុក្ខ) បានដល់ ដើម្បីធ្វើការកាត់ផ្តាច់ និងអស់ទៅដោយជុំវិញនៃវដ្តទុក្ខ ។ គុណធម៌ ៣ យ៉ាង មានសេចក្តីព្យាយាមជាដើមនេះ ព្រះមានព្រះភាគ ត្រាស់លាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

ចប់អដ្ឋកថា អាតប្បសូត្រទី ១០

# អដ្ឋកថា មហាចោរសូត្រទី ១១

## *"អង្គរបស់ចោរ និងអង្គរបស់ភិក្ខុអលជ្ជី"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មហាចារសូត្រទី ១១ ដូចតទៅនេះ ៈ-*

[៥២] *ចោរដែលមានកម្លាំង មានពួកច្រើន ឈ្មោះថា* **មហាចោរ** *។ បទថា* **សន្ធឹ** *(ចន្លោះ) បានដល់ ទីតនៃផ្ទះ ។ បទថា* **និល្លោបំ** *(ប្លន់) បានដល់ ប្លន់បែបមហាវិនាស ។ បទថា* **ឯកាគារិកំ** *(ប្លន់ផ្ទះមួយខ្នង) បានដល់ បិទឡោមប្លន់ផ្ទះមួយខ្នងប៉ុណ្ណោះ ។ បទថា* **បរិបន្ថេបិ តិដ្ឋតិ** *(ចាំស្កាត់ផ្លូវ) បានដល់ ចាំស្កាត់តាមផ្លូវ ។*

*បទថា* **នទីវិទុគ្គំ** *(កោះនៃទន្លេ) បានដល់ ស្ថានទីដែលទន្លេហូរទៅមិនស្រួល គឺ ទីកោះ ដែលពួកចោរអាចនឹងលាក់ខ្លួននៅបានព្រមទាំងបរិវារ ២.០០០ នាក់ខ្លះ ៣.០០០ នាក់ខ្លះ ។ បទថា* **បព្វតវិសមំ** *(ញកភ្នំ) បានដល់ ទីភ្នំមិនស្មើគ្នា គឺ រូងភ្នំ ដែលពួកចោរអាចនឹងលាក់ខ្លួននៅបានព្រមទាំងបរិវារ ៧.០០០ ឬ ៨.០០០ នាក់ ។*

*បទថា* **តិណគហនំ** *(ព្រៃស្បាតស្មៅ) បានដល់ ស្ថានទីប្រមាណ ១ យោជន៍ ដែលស្មៅដុះឡើង ។ បទថា* **គេហាំ** *បានដល់ ផ្ទះ ។ ព្រៃស្រោងដែលមែកឈើដុះប្រទាក់គ្នា ជាប់ជំពាក់គ្នា ឈ្មោះថា ព្រៃស្រោងធំ ។*

បទថា **បរិយោធាយ អត្ថំ ភណិស្សន្តិ** (នឹងអធិប្បាយហេតុដើម្បីការពារ) សេចក្តីថា ព្រះរាជា ឬមហាមាត្រ នឹងពោលធ្វើឲ្យបរិសុទ្ធ គឺ បង្វែហេតុនោះៗ ចេញ ។ បទថា **ត្យាស្ស** កាត់បទជា **តេ អស្ស** ។ បទថា **បរិយោធាយ អត្ថំ ភណន្តិ** (អធិប្បាយហេតុដើម្បីការពារ) សេចក្តីថា បើនរណាៗ ផ្តើមពោលតិះដៀល (គេ) ព្រះរាជា ឬមហាមាត្រ នឹងបង្វែហេតុនោះៗ ចេញការពារសូម្បីទោសធ្ងន់ ហើយពោលយ៉ាងនេះថា ពួកអ្នកទាំងឡាយកុំនិយាយយ៉ាងនេះ ពួកយើងស្គាល់បុគ្គលនេះមកច្រើនជួរត្រកូល បុគ្គលនេះ នឹងមិនធ្វើយ៉ាងនេះ ។ ម្យ៉ាងទៀត អធិប្បាយថា បទថា **បរិយោធាយ** បានដល់ បិទបាំង ព្រោះព្រះរាជា ឬមហាមាត្រទាំងនោះ ពោលពាក្យបិទបាំងទោសឲ្យគេ ។

បទថា **ខតំ ឧបហតំ** (ត្រូវគាស់រំលើង ត្រូវបំផ្លាញ) សេចក្តីថា ឈ្មោះថាត្រូវគាស់រំលើង ព្រោះត្រូវជីកនូវគុណចោល ឈ្មោះថា ត្រូវបំផ្លាញ ព្រោះចូលទៅទម្លាយគុណ គឺ សេចក្តីល្អចេញ ។ បទថា **វិសមេន កាយកម្មេន** (ដោយកាយកម្មមិនស្មើ) សេចក្តីថា ដោយកម្មដែលធ្វើតាមកាយទ្វារ ដែលឈ្មោះថាជាកម្មអាក្រក់ ព្រោះអត្ថថា ឃៀងឃ្លាត ។ សូម្បីក្នុងវចីកម្ម និងមនោកម្ម ក៏មានន័យនេះដូចគ្នា ។ បទថា **អន្តគាហិកាយ** (ដោយអន្តគាហិកទិដ្ឋិ) សេចក្តីថា ដោយទិដ្ឋិដែលប្រកាន់យកទីបំផុត មានវត្ថុ ១០ ។ ពាក្យដ៏សេសក្នុងបទ

*ទាំងពួង មានសេចក្ដីងាយទាំងនោះឯង ។*

ចប់អដ្ឋកថា មហាចោរសូត្រទី ១១

## ចប់ចូឡវគ្គវណ្ណនា ទី ៥

ក្នុងវគ្គនេះ មាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១១ សូត្រ

## ចប់បឋមបណ្ណាសកៈ

# ទុតិយបណ្ណាសកៈ

## ព្រាហ្មណវគ្គទី ១

## អដ្ឋកថា បឋមជនសូត្រទី ១

*“ពោលដោយទីពឹងខាងមុខ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមជនសូត្រទី ១ ដូចតទៅនេះ ៖*

[៥៣] *បទថា **ជិណ្ណា** (គ្រាំគ្រា) បានដល់ គ្រាំគ្រាព្រោះជរា ។ បទថា **វុឌ្ឍា** (ចាស់) បានដល់ ចម្រើនវ័យ ។ បទថា **មហល្លកា** (ជាអ្នកធំ) បានដល់ ជាអ្នកធំព្រោះកើត (មកយូរ) ។ បទថា **អទ្ធគតា**[១] (កន្លងកាល) បានដល់ កន្លងពាក់កណ្ដាលវ័យទៅហើយ ។ បទថា **វយោអនុប្បត្តា** (កន្លងវ័យ) បានដល់ ចូលដល់បច្ឆិមវ័យ ។ បទថា **យេន ភគវា តេនុបសង្កមឹសុ** (ទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់) សេចក្ដីថា ព្រាហ្មណ៍ឃើញកូនប្រពន្ធមិនបដិបត្តិតាមពាក្យរបស់ខ្លួន គិតថា យើងនឹងទៅគាល់ព្រះសមណគោតម ស្វែងរកផ្លូវដែលនឹងនាំចេញចាកទុក្ខ ដូច្នេះហើយ ទើបចូលទៅគាល់ ។*

*បទថា **មយមស្សុ ភោ គោតម ព្រាហ្មណា** (បពិត្រព្រះគោតមដ៏ចម្រើន*

---

*(១) ក្នុងអដ្ឋកថា (អឌ្ឍគតា) ក្នុងបិដក (អទ្ធគតា) ។*

ពួកខ្ញុំព្រះអង្គជាព្រាហ្មណ៍) សេចក្ដីថា ព្រាហ្មណ៍ទាំងពីរនាក់ប្រកាសនូវខ្លួនជាព្រាហ្មណ៍ថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរជាព្រាហ្មណ៍ មិនមែនក្សត្រិយ៍ មិនមែនអាមាត្យ មិនមែនគហបតី ដូច្នេះហើយ ក្រាបទូលពាក្យជាដើមថា **គ្រាំគ្រា** ដូច្នេះ ។ ដោយបទថា **អកតកីរុត្តាណា** (មិនបានធ្វើកម្មដែលជាទីការពារភ័យ) ព្រាហ្មណ៍ទាំងពីរពោលថា ខ្ញុំព្រះអង្គទាំងពីរ មិនទាន់បានធ្វើកម្មជាគ្រឿងការពារភ័យ គឺ កម្មដែលជាទីពឹង ជាទីពំនាក់ ។ បទថា **តគ្ឃ** (ពិតហើយ) ជានិបាត ចុះក្នុងអត្ថថា ដោយចំណែកមួយ ឬចុះក្នុងអត្ថថាទទួល ។ ព្រះមានព្រះភាគទ្រង់សម្ដែងទុក ដោយទីបំផុតតែម្យ៉ាងថា អ្នកទាំងឡាយយ៉ាងនេះឯង សូម្បីតថាគតក៏ទទួលដូចគ្នា ។ បទថា **ឧបនីយតិ** (ត្រូវ... នាំចូលទៅ) បានដល់ ត្រូវជរានាំចូលទៅ អធិប្បាយថា សត្វលោកនេះ ត្រូវជាតិនាំទៅកាន់ជរា ត្រូវជរានាំទៅកាន់ព្យាធិ ត្រូវព្យាធិនាំទៅកាន់មរណៈ ត្រូវមរណៈនាំទៅកាន់ជាតិទៀត ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ឧបនីយតិ** ដូច្នេះ ។

## រឿងព្រាហ្មណ៍រក្សាសីល ៥

ឥឡូវនេះ ព្រោះហេតុដែលព្រាហ្មណ៍ទាំងនោះ សូម្បីបួសហើយ ក៏មិនអាចនឹងបំពេញវត្តឲ្យបរិបូរណ៍បាន ព្រោះជាមនុស្សចាស់ ដូច្នោះ ព្រះមាន-

ព្រះភាគ កាលនឹងឲ្យព្រាហ្មណ៍ទាំងពីរនោះ តាំងនៅក្នុងសីល ៥ ទើបត្រាស់ថា **សេចក្ដីសង្រួមផ្លូវកាយ...ក្នុងលោក** ។ បណ្ដាបទទាំងនោះ ការសង្រួមផ្លូវកាយទ្វារ ឈ្មោះថា **កាយសញ្ញមៈ** ។ សូម្បីបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ដោយបទថា **តំ តស្ស បេតស្ស** (នោះ... ដល់អ្នកដែលលះលោកនេះទៅហើយ) នេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា បុណ្យនោះ ឈ្មោះថា **ជាទីជ្រកកោន** ព្រោះអត្ថថា ជាទីជ្រកកោនរបស់អ្នកទៅកាន់បរលោក , ឈ្មោះថា **ជាទីពួន** ព្រោះអត្ថថា ជាទីពួនសម្ងំ , ឈ្មោះថា **ជាកោះ** ព្រោះអត្ថថា ជាទីពំនាក់ , ឈ្មោះថា **ជាទីពឹង** ព្រោះអត្ថថា ជាទីពឹងអាស្រ័យ និងឈ្មោះថា **ជាទីសង្ឃឹម** ព្រោះអាចឲ្យគតិខ្ពង់ខ្ពស់បាន ។ ព្រះគាថា មានអត្ថងាយទាំងអស់នោះឯង ។ ព្រាហ្មណ៍ទាំងនោះ ដែលព្រះតថាគតឲ្យសមាទានសីល ៥ យ៉ាងនេះហើយ រក្សាសីល ៥ រហូតអស់មួយជីវិត កើតហើយក្នុងសួគ៌ ។

ចប់អដ្ឋកថា បឋមជនសូត្រទី ១

# អដ្ឋកថា ទុតិយជនសូត្រទី ២

*"ពោលដោយទីពឹងក្នុងកពមុខ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយជនសូត្រទី ២ ដូចតទៅនេះ ៖-*

[៥៤] *បទថា* ***ភាជនំ*** *(ភាជនៈ) បានដល់ កណ្ឌៈណានីមួយ ។ បទដ៏សេស គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងសូត្រទី ១ ។*

ចប់អដ្ឋកថា ទុតិយជនសូត្រទី ២

# អដ្ឋកថា ព្រាហ្មណសូត្រទី ៣

## *“ពោលដោយធម្មគុណ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រាហ្មណសូត្រទី ៣ ដូចតទៅនេះ ៈ-*

*[៥៥] បទថា **សម្មោទនីយំ** (រាក់ទាក់) បានដល់ ឲ្យកើតការរីករាយចិត្ត ។ បទថា **សារណីយំ** បានដល់ ដែលសមគួរឲ្យរឭកដល់គ្នា ។ បទថា **វីតិសារេត្វា** ប្រែថា លុះឲ្យរឭកដល់គ្នាចប់ហើយ ។ បទថា **កិត្តាវតា** (ដោយហេតុត្រឹមណា) បានដល់ ដោយហេតុប៉ុន្មានយ៉ាង ។*

*បទថា **សន្ទិដ្ឋិកោ ធម្មោ ហោតិ** (ជាធម៌ដែលបុគ្គលបានសម្រេចគប្បីឃើញឯង) សេចក្តីថា ជាធម៌ដែលបុគ្គលគប្បីឃើញបានដោយខ្លួនឯង ។ បទថា **អកាលិកោ** (មិនប្រកបដោយកាល) សេចក្តីថា ឲ្យផលមិនរង់ចាំកាល ។ ដោយបទថា **ឯហិបស្សិកោ** (គួរហៅឲ្យមកមើល) នេះ ព្រាហ្មណ៍ទូលសួរដល់អាគមនីយប្បដិបទាថា ព្រះធម៌ដែលអ្នកបដិបត្តិអាច ដើម្បីនឹងបង្ហាញបានយ៉ាងនេះថា លោកចូរមកមើលចុះ ដូច្នេះ ។ បទថា **ឱបនយិកោ** (គួរបង្អោនចូលមក) សេចក្តីថា គប្បីបង្អោនចិត្តរបស់ខ្លួនចូលទៅរក ។ បទថា **បច្ចត្តំ វេទិតព្វោ** (ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួន) សេចក្តីថា គប្បីជ្រាបបានដោយខ្លួនឯង នុ៎ះឯង ។ បទថា **វិញ្ញូហិ** (វិញ្ញូ) បានដល់ បណ្ឌិតទាំងឡាយ ។ បទ*

ថា **បរិយាទិន្នចិត្តោ** (មានចិត្តត្រូវ...គ្របសង្កត់) បានដល់ ជាអ្នកមានចិត្តដែលរាគៈប្រកាន់ហើយ ចាប់ហើយ និងស្វាបអង្អែលហើយ ។ បទថា **ចេតេតិ** គឺ **ចិន្តេតិ** (រមែងគិត) ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងនោះឯង ។ តែក្នុងព្រះសូត្រនេះ ព្រាហ្មណ៍ទូលសួរដល់លោកុត្តរមគ្គ សូម្បីព្រះបរមសាស្តាក៏ទ្រង់ត្រាស់លោកុត្តរមគ្គនោះដូចគ្នា ព្រោះថា លោកុត្តរមគ្គនោះ ឈ្មោះថា **សន្ទិដ្ឋិកៈ** ព្រោះនឹងត្រូវឃើញដោយខ្លួនឯង ដូច្នេះ ។

ចប់អដ្ឋកថា ព្រាហ្មណសូត្រទី ៣

# អដ្ឋកថា បរិព្វាជកសូត្រទី ៤

*“ពោលដោយធម្មគុណ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិព្វាជកសូត្រទី ៤ ដូចតទៅនេះ ៖-*

[៥៦] *បទថា* ***ព្រាហ្មណបរិព្វាជកោ*** *បានដល់ បរិព្វាជកដែលមានជាតិជាព្រាហ្មណ៍ មិនមែនមានជាតិជាក្សត្រិយ៍ជាដើម ។ បទថា* ***អត្តត្ថម្បិ*** *(សូម្បីប្រយោជន៍របស់ខ្លួន) សេចក្តីថា ប្រយោជន៍របស់ខ្លួន ទាំងក្នុងបច្ចុប្បន្ន និងសម្បរាយភព ដែលលាយដោយលោកិយៈ និងលោកុត្តរៈ ។*

ចប់អដ្ឋកថា បរិព្វាជកសូត្រទី ៤

# អដ្ឋកថា និព្វុតសូត្រទី ៥

## “ពោលពីព្រះនិព្វាន”

*គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វុតសូត្រទី ៥ ដូចតទៅនេះ ៈ-*

[*៥៧*] *បទថា* ***អកាលិកំ*** *(មិនប្រកបដោយកាល) សេចក្តីថា មិនមែនគប្បីនឹងសម្រេចក្នុងវេលាដទៃ ។ បទថា* ***ឱបនយិកំ*** *(គួរបង្អោនចូលក្នុងខ្លួន) បានដល់ គួរចូលដល់ដោយការបដិបត្តិ ។*

ចប់អដ្ឋកថា និព្វុតសូត្រទី ៥

# អដ្ឋកថា បលោភសូត្រទី ៦

## *"ហេតុឲ្យមនុស្សមានចំនួនតិចចុះ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បលោភសូត្រទី ៦ ដូចតទៅនេះ ៖-*

*[៥៨] បទថា **អាចរិយបាចរិយានំ** (អ្នកជាអាចារ្យ និងអាចារ្យដែលបន្តគ្នាមក) សេចក្តីថា ទាំងអាចារ្យទាំងឡាយ ទាំងអាចារ្យរបស់អាចារ្យទាំងឡាយ ។ បទថា **អវីចិ មញ្ញេ ផុដ្ឋោ**[១] **ហោតិ** (លោកនេះ ពេញទៅដោយមនុស្ស ប្រហែលនឹងអវីចិមហានរក) សេចក្តីថា បរិបូរណ៍ទៅដោយមនុស្សទាំងឡាយ ដូចអវីចិមហានរកដែលសត្វសម្ផស្សហើយ គឺ ពេញប្រៀបទៅដោយពួកសត្វនរកជានិរន្តរ ។ បទថា **កុក្កុដសម្បាតិកា** (មួយរយៈនៃមាន់ហើរធ្លាក់) សេចក្តីថា ការហើរទៅរបស់មាន់ ពោលគឺ មាន់ហើរទៅពីដំបូលផ្ទះមួយកន្លែង ទៅធ្លាក់ចុះត្រង់ដំបូលផ្ទះមួយកន្លែងទៀត នៅក្នុងស្រុកទាំងនេះ ព្រោះហេតុនោះ ស្រុកទាំងនេះទើបឈ្មោះថា **កុក្កុដសម្បាតិកៈ** ។ បាឋៈថា **កុក្កុដសម្បាតិ** ក៏មាន ។ មានអធិប្បាយថា ការទៅធ្លាក់របស់មាន់ ពោលគឺ ការដើរទៅរបស់មាន់ពីលំនៅស្រុក កាន់លំនៅស្រុក មានហើយក្នុងស្រុកទាំងនេះ ។ សូម្បីទាំងពីរបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ការនៅរួម*

---

*(១) បិដក (ផុដោ) អដ្ឋកថា (ផុដ្ឋោ) ។*

គ្នាយ៉ាងកុះករនោះឯង ។

បទថា **អធម្មរាគរត្តា** (ត្រេកអរក្នុងរាគៈដែលជាអធម៌) សេចក្ដីថា រាគៈជាអធម៌តែម្យ៉ាងប៉ុណ្ណោះ តែរាគៈដែលកើតឡើងក្នុងបរិក្ខាររបស់ខ្លួន ទ្រង់មិនសំដៅយកថា ជាអធម្មរាគៈ រាគៈដែលកើតឡើងក្នុងបរិក្ខាររបស់អ្នកដទៃ ទើបទ្រង់បំណងយកថា ជាអធម្មរាគៈ ។

បទថា **វិសមលោភាភិភូតា** (ត្រូវសេចក្ដីលោភដែលជាសភាវៈអាក្រក់គ្របសង្កត់) សេចក្ដីថា ដែលឈ្មោះថា លោភៈ និងមានវេលាជាសភាវៈល្អមិនមាន ។ លោភៈនោះ ទើបជាសភាវៈអាក្រក់តែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែថា លោភៈកើតឡើងក្នុងវត្ថុដែលខ្លួនហួងហែង ឈ្មោះថា **សមលោភៈ** ដែលកើតឡើងក្នុងវត្ថុដែលអ្នកដទៃហួងហែងប៉ុណ្ណោះ ទ្រង់បំណងយកថាជា **វិសម-លោភៈ** ។ បទថា **មិច្ឆាធម្មបរេតា** (ត្រូវមិច្ឆាធម៌រួបរឹត) សេចក្ដីថា ប្រកបដោយធម៌ចំណែកខុស ពោលគឺ ការសេពវត្ថុដែលមិនមែនវត្ថុ ។

បទថា **ទេវោ ន សម្មា ធារំ អនុប្បវេច្ឆតិ** (ភ្លៀងទើបមិនធ្លាក់តាមរដូវកាល) សេចក្ដីថា ភ្លៀងមិនធ្លាក់ក្នុងវេលាដែលគួរធ្លាក់ ។ បទថា **ទុព្ភិក្ខំ** (ទុព្ភិក្ខភ័យ) បានដល់ ភិក្ខាដែលរកបានលំបាក ។ បទថា **ទុស្សស្សំ** (សំទូងមិនល្អ) សេចក្ដីថា ឈ្មោះថា សំទូងវិនាស ព្រោះសំទូងគ្រប់ប្រភេទមិនបញ្ចេញ

ផល ។ បទថា **សេតដ្ឋិកំ** (ក្រាស៊ី) សេចក្ដីថា កាលកំពុងធ្វើខ្នួន ពួកជន្ទូវ នឹងចុះស៊ី គួរស្រូវសាលីដែលចេញហើយ នឹងមានពណ៌ស មិនដាក់គ្រាប់ ព្រោះត្រូវជន្ទូវទាំងនោះជញ្ជក់ ។ ទ្រង់សំដៅយកស្រូវស្កកនោះ ត្រាស់ថា **ក្រាស៊ី** ដូច្នេះ ។ បទថា **សលាកាវុត្តំ** សេចក្ដីថា សន្ទូងដែលស្ងួងហើយ សម្រេចត្រឹមតែស្លឹកប៉ុណ្ណោះ អធិប្បាយថា មិនចេញផ្លែ ។ បទថា **យក្ខា** (យក្ខទាំងឡាយ) បានដល់ ពួកយក្ខដែលជាធំ ។ បទថា **វាឡេ អមនុស្សេ ឱស្សជ្ជន្តិ** (ព្រលែងពួកអមនុស្សកាចៗ) សេចក្ដីថា ព្រលែងពួកយក្ខកាចៗ ទៅក្នុងអាវាសមនុស្ស ។ យក្ខទាំងនោះបានឱកាស រមែងធ្វើឲ្យមហាជនដល់ ការអស់ជីវិត ។

ចប់អដ្ឋកថា បលោភសូត្រទី ៦

# អដ្ឋកថា វប្បសូត្រទី ៧[១]

## “បដិគ្គាហកៈធ្វើឲ្យទានមានផលច្រើន”

គប្បីជ្រាបវិនិច្ឆ័យក្នុង វប្បសូត្រទី ៧ ដូចតទៅនេះ ៖-

[៥៩] បទថា **មហប្ផលំ** (មានផលច្រើន) បានដល់ មានវិបាកច្រើន ។ ក្នុងបទថា **ធម្មស្ស ច អនុធម្មំ ព្យាករោន្តិ** (ពោលតាមធម៌នៃព្រះធម៌ឬ) នេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ពាក្យដែលព្រះមានព្រះភាគត្រាស់ហើយ ឈ្មោះថា **ព្រះធម៌** ។ ការពោលជំនួសប្រការដែលត្រាស់ហើយ ឈ្មោះថា **តាមធម្ម** ។

បទថា **សហធម្មិកោ** (ដែលត្រូវដល់ហេតុ) បានដល់ ព្រមដោយការណ៍ ព្រមដោយហេតុ ។ ការយល់តាម គឺ ការស្រេបតាម អធិប្បាយថា ការប្រព្រឹត្ត តាមពាក្យ ឈ្មោះថា **ការកាន់តាមពាក្យ** ។ បទថា **គារយ្ហំ ឋានំ** (ឋានៈដែលគួរតិះដៀល) បានដល់ ហេតុដែលគួរតិះដៀល ។ លោកអធិប្បាយទុកថា ការស្របតាមពាក្យដែលមានហេតុផល ដែលព្រះគោតមដ៏ចម្រើនត្រាស់ទុកហើយ មិនគួរនឹងដល់ហេតុដែលគប្បីតិះដៀលណាៗ ឡើយ ។ម្យ៉ាងទៀត ព្រាហ្មណ៍សួរថា ការស្របតាមវាទៈដែលមានហេតុ ដែលពួកមនុស្សដទៃនោះពោលហើយ នឹងដល់ហេតុដែលគួរតិះដៀលអ្វីៗ ទេ ។

---

(១) អដ្ឋកថា (វច្ឆគោត្តសូត្រ) ។

បទថា **អន្តរាយករោ ហោតិ** (ឈ្មោះថាធ្វើអន្តរាយ) សេចក្តីថា ធ្វើអន្តរាយ គឺ សេចក្តីវិនាស គឺ ឲ្យបានទទួលសេចក្តីលំបាក បានដល់ ឲ្យកើតសេចក្តីក្តៅក្រហាយ ។ បទថា **បារិបន្ថិកោ** (ប្រទូស្ត) បានដល់ ចោរដែលស្កាត់ប្លន់អ្នកធ្វើដំណើរ ។ បទថា **ខតោ ច ហោតិ** (គាស់រំលើង) បានដល់ ត្រូវជីកដោយជីកគាស់រំលើងគុណចោល ។ បទថា **ឧបហតោ** (ត្រូវកម្ចាត់) បានដល់ ត្រូវកម្ចាត់ ដោយការទម្លាយគុណចោលចេញ ។ បទថា **ចន្ទនិកាយ** (អណ្តូងទឹកស្អោកគ្រោក បានដល់ ក្នុងអណ្តូងទឹកកក់ដែលមិនស្អាត ។ បទថា **ឱឡិគ្គល្លេ** (រណ្តៅស្អោកគ្រោក) បានដល់ ទឹកជ្រាំដែលហូរទៅ ។ បទថា **សោ ច** (និងលោកដែលមានសីលនោះ) បានដល់ ព្រះខីណាស្រពដែលលោកពោលទុកថាលោកអ្នកមានសីលនោះ ។ បទថា **សីលក្ខន្ធេន** (ដោយសីលក្ខន្ធ) បានដល់ដោយកងសីល ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ក៏បច្ចវេក្ខណញាណ ព្រះមានព្រះភាគត្រាស់ហៅថា វិមុត្តិញាណទស្សនៈ ក្នុងបទថា **វិមុត្តិញាណទស្សនក្ខន្ធ** នេះ ។ បច្ចវេក្ខណញាណនោះ ព្រះមានព្រះភាគត្រាស់ថា អសេក្ខៈ ព្រោះប្រព្រឹត្តទៅហើយដល់ព្រះអសេក្ខៈ ។ ញាណក្រៅពីនេះ សូម្បីខ្លួនឯងក៏ជាអសេក្ខៈហើយ ព្រោះសម្រេចដល់ទីបំផុតនៃសិក្ខា ។ ញាណដទៃនោះក៏ជាលោកុត្តរៈ ។ បច្ចវេក្ខញាណជាលោកិយៈ ។

បទថា **រោហិណីសុ** (មានពណ៌ក្រហម) បានដល់ (មេគោ) មានពណ៌ក្រហម ។ បទថា **សុរូបាសុ** (ពណ៌ប្រក្រតី) បានដល់ មានពណ៌ធម្មតាដូចកូនគោរបស់ខ្លួន ។ បទថា **បារេវតាសុ** បានដល់ មានពណ៌ដូចសត្វព្រាប ។ បទថា **ទន្តោ** (ហ្វឹកហាត់ល្អហើយ) បានដល់ អស់មានះហើយ ។ គោនោះ ឈ្មោះថា **បុង្គវោ** ។ បទថា **ធោរយ្ហោ** បានដល់ គោសម្រាប់ប្រើការផារធ្ងន់ ។ បទថា **កល្យាណជវនិក្កមោ** (រហ័សរហួន) បានដល់ ប្រកបដោយសេចក្តីរហ័សរហួនស្មោះត្រង់ ។ បទថា **នាស្ស វណ្ណំ បរិក្ខរេ** (ពណ៌របស់វារកបរិសុទ្ធមិនបាន) សេចក្តីថា មិនចូលចិត្តដល់ពណ៌រាងកាយរបស់គោនោះ តែពេញចិត្តចំពោះការផារ គឺ ការប្រកបធុរៈរបស់វាប៉ុណ្ណោះ ។

បទថា **យស្មឹ កិស្មិញ្ចិ ជាតិយេ** (ក្នុងជនជាតិណាមួយ) សេចក្តីថា កើតហើយក្នុងត្រកូលណាៗ ។ បទថា **យាសុ កាសុចិ ឯត្ថាសុ** (ក្នុងជាតិទាំងនោះគ្រប់ជាតិ) បានដល់ ក្នុងកំណើតណាមួយ មានប្រភេទជាក្សត្រិយ៍ ជាដើមទាំងនេះ ។

បទថា **ព្រហ្មចរិយស្ស កេវលី** (ចប់ព្រហ្មចរិយៈ) សេចក្តីថា ប្រកបដោយការនៅចប់ព្រហ្មចរិយៈ អធិប្បាយថា ប្រកបដោយភាពជាអ្នកបរិបូរណ៍ដោយព្រហ្មចរិយៈ ព្រោះថា ព្រះខីណាស្រព ឈ្មោះថា ជាអ្នកប្រព្រឹត្តព្រហ្មច-

រិយៈទាំងអស់ ដោយហេតុនោះ លោកទើបពោលពាក្យនេះ ។

បទថា **បន្នភារោ** (ដាក់ភារៈហើយ) បានដល់ ដាក់ភារៈហើយ អធិប្បាយថា ដាក់ភារៈ គឺ ខន្ធភារៈ គឺ កិលេស និងភារៈ គឺ កាមគុណចុះហើយ ។ បទថា **កតកិច្ចោ** (សម្រេចកិច្ចហើយ) គឺ ធ្វើកិច្ចដោយមគ្គទាំង ៤ សម្រេចហើយ ។ បទថា **បារគូ សព្វធម្មានំ** (ដល់ត្រើយនៃធម៌ទាំងពួង) សេចក្ដីថា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ត្រាស់ហៅថា **ធម៌ទាំងពួង** ។ ឈ្មោះថា **ដល់ត្រើយ** ព្រោះដល់ត្រើយ ៦ យ៉ាង គឺ ត្រើយគឺ អភិញ្ញា ១ ត្រើយគឺ បហានៈ ១ ត្រើយគឺ ឈាន ១ ត្រើយគឺ ភាវនា ១ ត្រើយគឺ សច្ឆិកិរិយា ១ ត្រើយគឺ សមាបត្តិ ១ នៃធម៌ទាំងពួងនោះ ។ បទថា **អនុបាទាយ** បានដល់ ព្រោះមិនប្រកាន់មាំ ។ បទថា **និព្វុតោ** (រលត់ហើយ) បានដល់ វៀរចាកសេចក្ដីក្ដៅក្រហាយព្រោះកិលេស ។ បទថា **វិរជេ** (ដែលប្រាសចាកទោស) បានដល់ វៀរចាកធូលី គឺ រាគៈ ទោសៈ និងមោហៈ ។

បទថា **អវិជ្ជានន្តា** (មិនដឹង) បានដល់ មិនស្គាល់បុញ្ញខេត្ត ។ បទថា **ទុម្មេធា** បានដល់ មិនមានបញ្ញា ។ បទថា **អស្សុតាវិនោ** (មិនបានស្ដាប់) បានដល់ វៀរចាកការបានឮសេចក្ដីវិនិច្ឆ័យបុញ្ញខេត្ត ។ បទថា **ពហិទ្ធា** (ខាងក្រៅ) បានដល់ ខាងក្រៅពីព្រះសាសនានេះ ។ បទថា **ន ហិ សន្តេ ឧបាសរេ** (មិន

ចូលជិតសប្បុរសទាំងឡាយ) សេចក្តីថា មិនចូលទៅរកព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដែលជាបុរសខ្ពង់ខ្ពស់ ។ បទថា **ធីរសម្មតេ** (ដែលលោកដឹងទូទៅថាជាអ្នកប្រាជ្ញ) បានដល់ បណ្ឌិតដឹងហើយ សរសើរហើយ ។ ដោយបទថា **មូលជាតា បតិដ្ឋិតា** (មានឫសគល់តាំងស៊ប់) នេះ ទ្រង់សម្តែងដល់សទ្ធារបស់ព្រះសោតាបន្ន ។ បទថា **កុលេ វា ឥធ ជាយរេ** (ឬកើតក្នុងត្រកូលណាមួយក្នុងលោក) សេចក្តីថា ឬកើតក្នុងត្រកូលក្សត្រិយ៍ ត្រកូលព្រាហ្មណ៍ ត្រកូលវេស្សៈក្នុងមនុស្សលោកនេះ ។ បុគ្គលនេះឯង ឈ្មោះថា មានកុលសម្បត្តិ ៣ ប្រការ ។ បទថា **អនុបុព្វេន និព្វានំ អធិគច្ឆន្តិ** (សម្រេចព្រះនិព្វានដោយលំដាប់) សេចក្តីថា បំពេញគុណធម៌ទាំងនេះ គឺ សីល សមាធិ បញ្ញាឲ្យសម្បូរណ៍ ហើយសម្រេចព្រះនិព្វានតាមលំដាប់ ដូច្នេះឯង ។

ចប់អដ្ឋកថា ជប្បសូត្រទី ៧

# អដ្ឋកថា តិកណ្ណសូត្រទី ៨

## *“វិជ្ជា ៣ របស់ព្រាហ្មណ៍ និងរបស់ព្រះពុទ្ធ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តិកណ្ណសូត្រទី ៨ ដូចតទៅនេះ ៈ-*

[៦០] *បទថា* ***តិកណ្ណោ*** *ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ បទថា* ***ឧបសង្កមិ*** *(ចូលទៅគាល់) សេចក្ដីថា ព្រាហ្មណ៍គិតថា បានឮថា ព្រះសមណគោតមជាបណ្ឌិត យើងនឹងទៅកាន់សំណាក់របស់ព្រះអង្គ ដូច្នេះ បរិភោគអាហារព្រឹកហើយ មានមហាជនហែហម ចូលទៅគាល់ព្រះមានព្រះភាគ ។ បទថា* ***ភគវតោ សម្មុខា*** *(ចំពោះព្រះភក្ត្រព្រះមានព្រះភាគ) សេចក្ដីថា អង្គុយខាងមុខព្រះភក្ត្រព្រះទសពល ។*

*បទថា* ***វណ្ណំ ភាសតិ*** *(ពោលសរសើរ) សេចក្ដីថា សួរថា ព្រោះហេតុអ្វី ទើបពោលសរសើរ ។ ឆ្លើយថា បានជ្រាបថា មុនអំពីនេះ ព្រាហ្មណ៍នោះមិនធ្លាប់ទៅសំណាក់របស់ព្រះតថាគតឡើយ ព្រាហ្មណ៍ទើបមានសេចក្ដីគិតយ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ ចូលគាល់បានលំបាក យើងទូលមុនហើយ ព្រះអង្គត្រាស់ ឬមិនត្រាស់ក៏បាន បើព្រះអង្គមិនត្រាស់ ពេលនោះ មនុស្សទាំងឡាយនឹងពោលថា យើងដែលនិយាយក្នុងទីសមាគមយ៉ាងនេះថា ហេតុអ្វីលោកទើបនិយាយក្នុងទីនេះ ព្រោះថា លោកទៅកាន់សម្នាក់របស់ព្រះសមណគោតមហើយ*

ក៏មិនបានសួម្បីត្រឹមតែព្រះតម្រាស់ផង ។ ព្រោះហេតុនោះ កាលបើព្រាហ្មណ៍សម្គាល់ថា យើងនឹងផុតពីការរិះគន់ទៅបាន ដោយឧបាយយ៉ាងនេះ ទើបទូលឡើង ។ ព្រាហ្មណ៍និយាយសរសើរព្រាហ្មណ៍ទាំងឡាយក៏ពិត តែនិយាយដល់វិជ្ជា ៣ ដោយសេចក្ដីបំណងតែម្យ៉ាងថា យើងនឹងសាកល្បងព្រះញាណរបស់ព្រះតថាគត ។

បទថា **ឯវម្បិ តេវិជ្ជា ព្រាហ្មណា** (ព្រាហ្មណ៍អ្នកបានវិជ្ជា ៣ សូម្បីយ៉ាងនោះ) សេចក្ដីថា ព្រាហ្មណ៍អ្នកទ្រទ្រង់វិជ្ជា ៣ ជាបណ្ឌិតយ៉ាងនោះ ជាអ្នកប្រាជ្ញយ៉ាងនោះ ជាអ្នកឈ្លាសយ៉ាងនោះ ជាពហូសូតយ៉ាងនោះ ជាអ្នកមានប្រក្រតីពោលយ៉ាងនោះ អធិប្បាយថា ជាអ្នកបានទទួលការសរសើរយ៉ាងនេះ ។ ដោយបទថា **ឥតិបិ** (សូម្បីយ៉ាងនេះ) តិកណ្ណព្រាហ្មណ៍សម្ដែងការកំណត់អាការរបស់បណ្ឌិតជាដើម នៃព្រាហ្មណ៍ទាំងនោះ ។ ក៏ក្នុងសេចក្ដីនេះ មានអធិប្បាយយ៉ាងនេះថា ជាបណ្ឌិតដោយហេតុប៉ុណ្ណេះ ។ល។ ជាអ្នកបានទទួលការលើកសរសើរដោយហេតុប៉ុណ្ណេះ ។

បទថា **យថា** ក្នុងបទថា **យថា កថំ បន ព្រាហ្មណា** នេះ ជាបទសម្ដែងហេតុ ។ បទថា **កថំ បន** ជាពាក្យសួរ ។ សេចក្ដីនេះ សមពិតដូចដែលព្រះ-មានព្រះភាគត្រាស់ទុកថា ម្នាលព្រាហ្មណ៍ ព្រាហ្មណ៍ទាំងឡាយ បញ្ញត្តិព្រាហ្មណ៍

អ្នកបានវិជ្ជា ៣ ទុកដូចម្តេច ។ លោកចូរប្រាប់ហេតុដែលឲ្យស្គាល់ព្រាហ្មណ៍អ្នកបានវិជ្ជា ៣ នោះ ។ ព្រាហ្មណ៍ លុះបានស្តាប់ដូច្នោះហើយ សប្បាយចិត្តថា ព្រះសម្មាសម្ពុទ្ធត្រាស់សួរក្នុងធម៌ដែលមានឋានៈល្មមដឹងបាន មិនមែនមានឋានៈដែលដឹងមិនបាន ទើបទូលពាក្យជាដើមថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្នុងលោក ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឧភតោ** បានដល់ ទាំងពីរចំណែក ។ បទថា **មាតិតោ ច បីតិតោ ច** (ទាំងចំណែកមាតាទាំងចំណែកបិតា) សេចក្តីថា បុគ្គលណាមានមាតាជាព្រាហ្មណី មានយាយជាព្រាហ្មណី សូម្បីយាយទួតក៏ជាព្រាហ្មណី មានបិតាជាព្រាហ្មណ៍ មានតាជាព្រាហ្មណ៍ សូម្បីតាទួតក៏ជាព្រាហ្មណ៍ បុគ្គលនោះឯងឈ្មោះថា កើតល្អហើយទាំងពីរចំណែក គឺ ទាំងចំណែកមាតា និងចំណែកបិតា ។

បទថា **សំសុទ្ធគហណិកោ** (មានគភ៌ដែលបដិសន្ធិបរិសុទ្ធល្អ) សេចក្តីថា បុគ្គលណាមានកំណើត គឺ នៅក្នុងផ្ទៃរបស់មាតាបរិសុទ្ធិហើយ (បុគ្គលនោះឈ្មោះថា សំសុទ្ធគហណី) ។ តែក្នុងបទថា **សមវេបាកិនិយា គហណិយា** នេះ ព្រះមានព្រះភាគត្រាស់ហៅថា ការកាន់យកតេជោធាតុដែលកើតពីកម្ម ។

ក្នុងពាក្យថា **យាវ សត្តមា បិតាមហយុគា** (៧ សន្តាន) នេះ មានសេចក្តីថា បិតារបស់បិតាឈ្មោះថា **បិតាមហៈ** ។ យុគ (ជំនាន់) នៃជីតា ឈ្មោះ

ថា **បិតាមហយុគ** (ជំនាន់ជីតា) ។ ប្រមាណនៃអាយុ លោកហៅថា **យុគ** ។ ក៏ពាក្យថា **យុគ** នេះ ត្រឹមតែជាពាក្យដែលគេហៅប៉ុណ្ណោះ ។ តែដោយអត្ថហើយ បិតាមហៈ នុ៎ះឯង ឈ្មោះថា **បិតាមហយុគ** ។ បុព្វបុរសសូម្បីទាំងអស់ បន្ទាប់ពីបិតាមហយុគទៅ ក៏សំដៅយកដោយស័ព្ទថា បិតាមហៈនុ៎ះឯង ។ បើដូច្នេះ អ្នកដែលឈ្មោះថា សំសុទ្ធគហណិកៈ នឹងមានត្រឹមតែ ៧ ជួរមនុស្ស ។

ម្យ៉ាងទៀត ទ្រង់សម្តែងថា ព្រាហ្មណ៍ដែលជាឧភតោសុជាតនោះ នឹងមិនត្រូវទាស់ មិនត្រូវតិះដៀល ដោយការពោលអាងដល់ជាតិ ។ បទថា **អក្ខិត្តោ** (មិនត្រូវទាស់) សេចក្តីថា មិនត្រូវតាមជំទាស់យ៉ាងនេះថា លោកទាំងឡាយចូរនាំបុគ្គលនេះចេញទៅ បុគ្គលនេះនឹងមានប្រយោជន៍អ្វី ។ បទថា **អនុបក្កុដ្ឋោ** សេចក្តីថា នឹងមិនត្រូវតិះដៀល មិនធ្លាប់បានជេរ ឬមិនធ្លាប់ត្រូវនិន្ទា ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ដោយការពោលអាងដល់ជាតិ ។ អធិប្បាយថា ដោយការពោលបែបនេះថា បុគ្គលនេះជាតិថោកទាប សូម្បីដោយប្រការនេះ ។

បទថា **អជ្ឈាយកោ** នេះ គប្បីជ្រាបសេចក្តីដូចតទៅនេះ ពាក្យរិះគន់កើតឡើងដល់ព្រាហ្មណ៍អ្នកវៀរចាកឈាន ក្នុងកាលនៃបឋមកប្ប យ៉ាងនេះថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ឥឡូវនេះជនទាំងនេះមិនសម្ងំ ឥឡូវនេះ ពួកជនទាំងនេះ មិនសម្ងំយ៉ាងនេះឯង អក្ខរ[១]ថា **អជ្ឈាយកា អជ្ឈាយកា** (អ្នកមិន

សម្ព័ន្ធ សំដៅដល់ អ្នកតែង និងបង្រៀនគម្ពីរ) ទើបឧប្បត្តិឡើងជាលើកទី ៣[២] ។ តែក្នុងបច្ចុប្បន្ននេះ ព្រាហ្មណ៍ឈ្មោះថា អជ្ឈាយកោ ព្រោះសិក្សាព្រះវេទនោះ ។ មនុស្សទាំងឡាយពោលពាក្យសរសើរ ដោយអធិប្បាយនេះថា ព្រាហ្មណ៍រាយមន្ត (ព្រះវេទ) ។ ព្រាហ្មណ៍ឈ្មោះថា **មន្តធរោ** ព្រោះទ្រទ្រង់ចាំមន្ត (ព្រះវេទ) ទុកបាន ។

បទថា **តិណ្ណំ វេទានំ** (ត្រៃវេទ) បានដល់ ឥរុវេទ យជុវេទ និងសាម-វេទ ។ ព្រាហ្មណ៍ ឈ្មោះថា **បារគូ** ព្រោះដល់ត្រើយ ដោយអំណាចនៃការទន្ទេញ (គឺចងចាំបានហើយ) ។

(ត្រៃវេទ) ព្រមដោយ **និឃណ្ឌុសាស្ត្រ** និង **កេដុភសាស្ត្រ** ឈ្មោះថា **និឃណ្ឌុកេដុភៈ** ។ បទថា **និឃណ្ឌុ** (និឃណ្ឌុសាស្ត្រ) បានដល់ សាស្ត្រដែលចែកឈ្មោះ (វត្ថុផ្សេងៗ) គឺ សាស្ត្រដែលពោលអំពីឈ្មោះដើមឈើជាដើម ។ បទថា **កេដុភំ** (កេដុភសាស្ត្រ) បានដល់ សាស្ត្រដែលកំណត់អាកប្បកិរិយា គឺ សាស្ត្រដែលជាឧបការៈដល់កវី ។ ព្រះវេទ ព្រមដោយប្រភេទនៃអក្សរ ឈ្មោះថា **អក្ខរប្បភេទ** ។ សិក្ខា និងនិរុត្តិ ឈ្មោះថា **អក្ខរប្បភេទ** ។ បទថា **ឥតិហា-សបញ្ចមានំ** (មានគម្ពីរឥតិហាសៈជាទី ៥) សេចក្តីថា ព្រះវេទ ឈ្មោះថា មានឥតិហាសៈជាទី ៥ ព្រោះមានឥតិហាសៈដែលប្រកបដោយពាក្យដូច្នេះថា ឥតិ-

ហ-អាសៈ ។ ឥ-អតិ-អាសៈ ពោលគឺ គម្ពីរបុរាណ ឬពោលគឺ គម្ពីរពោល អំពីវិជ្ជារបស់ក្សត្រិយ៍ (អ្នកចម្បាំង) ជាទី ៥ ។ ដោយរាប់យកអាថព្វណវេទ ជាទី ៤ នៃព្រះវេទទាំងនោះ ដែលមានឥតិហាសជាទី ៥ ។

ឈ្មោះថា **ដឹងបទ ដឹងពាក្យដោះស្រាយ** (វេយ្យាករណ៍) ព្រោះចងចាំ គឺ ដឹងទាំងតួបទ ទាំងព្យាករណ៍ (ពាក្យអធិប្បាយ) តួបទដ៏សេសនោះ ។

វិតណ្ឌវាទសាស្ត្រ លោកហៅថា **លោកាយតៈ** ។ បទថា **មហាបុរិស-លក្ខណំ** (មហាបុរសលក្ខណសាស្ត្រ) បានដល់ សាស្ត្រដែលមានបទចងក្រង ប្រមាណ ១២.០០០ គម្ពីរ ដែលសម្ដែងលក្ខណៈរបស់មហាបុរស មានព្រះពុទ្ធ ជាដើម ឈ្មោះថា ពុទ្ធមន្តប្រមាណ ១៦.០០០ បទគាថា មានសេចក្ដីអាចជា ហេតុឲ្យដឹងសេចក្ដីផ្សេងគ្នា ដូច្នេះថា បុគ្គលប្រកបដោយលក្ខណៈនេះ ឈ្មោះថា ជាព្រះពុទ្ធ ដោយលក្ខណៈនេះឈ្មោះថា ជាព្រះបច្ចេកពុទ្ធ ដោយលក្ខណៈនេះ ឈ្មោះថា ជាព្រះអគ្គសាវកទាំងពីរ ដោយលក្ខណៈនេះឈ្មោះថា ជាព្រះអសីតិមហាសាវក ដោយលក្ខណៈនេះឈ្មោះថា ជាព្រះពុទ្ធមាតា ដោយលក្ខណៈនេះឈ្មោះថា ជាព្រះពុទ្ធបិតា ដោយលក្ខណៈនេះឈ្មោះថា ជាអគ្គឧបដ្ឋាក ដោយលក្ខណៈនេះឈ្មោះថា ជាអគ្គឧបដ្ឋាយិកា និងដោយលក្ខណៈនេះឈ្មោះថា ជាស្តេចចក្រពត្តិ ។

បទថា **អនវយោ** (វាងវៃ) បានដល់ ជាអ្នកមិនខ្វះខាត គឺ ជាអ្នកបរិបូរ ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈទាំងនេះ មានពាក្យអធិប្បាយថា មិនមែនជាអ្នកធូរថយ ។ បុគ្គលមិនអាចនឹងចងចាំសាស្ត្រទាំងនោះទុកបានទាំងដោយអត្ថាធិប្បាយ និងដោយគម្ពីរ បុគ្គលនោះឈ្មោះថា ធូរថយ ។ ម្យ៉ាងទៀត បទថា **អនវយោ** កាត់បទជា **អនុ អវយោ** ដោយអំណាចសន្ធិ លុប **ឧ** អក្សរចេញ (ដូច្នោះ) **អនុអវយោ** ទើបជា **អនវយោ** អធិប្បាយថា មានសិល្បៈបរិបូរណ៍ ។

ព្រះមានព្រះភាគ ទ្រង់ឃើញព្រាហ្មណ៍នោះទូលអារាធនាហើយ ទ្រង់ដឹងថា ឥឡូវនេះ ជាវេលាសមគួរដល់តថាគត នឹងពោលដោះស្រាយបញ្ហារបស់ព្រាហ្មណ៍នោះ ទើបត្រាស់ពាក្យនេះថា **បើដូច្នោះ** ដូច្នេះ ។ បទថា **តេនហិ** (បើដូច្នោះ) នោះ មានអត្ថថា ព្រោះហេតុដែលលោកសូមអង្វរតថាគត ដូច្នោះអ្នកចូរស្តាប់ ។ បទថា **វិវិច្ចេវ កាមេហិ** (ស្ងាត់ចាកកាម) ជាដើម បានអធិប្បាយទុកយ៉ាងពិស្តារក្នុងគម្ពីរវិសុទ្ធិមគ្គហើយ ។ តែក្នុងទីនេះ បទថា **ស្ងាត់ចាកកាម** ជាដើមនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកហើយ ដើម្បីទ្រង់សម្តែងដល់ការបដិបត្តិដែលជាបុព្វភាគរបស់វិជ្ជាទាំង ២ ។ បណ្តាវិជ្ជាទាំង ៣ នោះ ការពណ៌នាវិជ្ជាទាំង ២ ទៅតាមលំដាប់បទក្តី ន័យនៃការចម្រើនវិជ្ជាទាំង

២ ក្តី បានឲ្យពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គដូចគ្នា ។

### កថាពណ៌នាបុព្វេនិវាសានុស្សតិញ្ញាណ

បទថា **បឋមា វិជ្ជា** (វិជ្ជាទី ១) សេចក្តីថា វិជ្ជា ឈ្មោះថា ទី ១ ព្រោះកើតឡើងលើកដំបូង ។ ដែលឈ្មោះថា វិជ្ជា ព្រោះអត្ថថា ធ្វើឲ្យជាក់ច្បាស់ហើយ ។ សួរថា ធ្វើឲ្យជាក់ច្បាស់អ្វី ។ ឆ្លើយថា ឲ្យដឹងខន្ធដែលធ្លាប់អាស្រ័យក្នុងជាតិមុន ។ មោហៈដែលបិទបាំងបុព្វេនិវាសានុស្សតិញ្ញាណនោះ ព្រោះអត្ថថា ធ្វើបុព្វេនិវាសានុស្សតិញ្ញាណនោះឯងមិនឲ្យជាក់ច្បាស់ ត្រាស់ហៅថា **អវិជ្ជា** ។ បទថា **តមោ** (សេចក្តីងងឹត) សេចក្តីថា មោហៈនោះឯង ហៅថា សេចក្តីងងឹត ព្រោះអត្ថថា ជាហេតុបិទបាំង ។ បទថា **អាលោកោ** (ពន្លឺ) សេចក្តីថា វិជ្ជានុ៎ះឯង ត្រាស់ហៅថា **ពន្លឺ** ព្រោះអត្ថថា ធ្វើសេចក្តីស្វាងស្វៃ ។ ក៏ក្នុងព្រះសូត្រនេះ បំណងថា បានសម្រេចវិជ្ជា ៣ ហើយ ។ ពាក្យដ៏សេស ជាពាក្យពោលសរសើរ ។ ក៏ក្នុងសេចក្តីនេះ ប្រកបសេចក្តីថា អ្នកបានសម្រេចវិជ្ជានេះហើយ លំដាប់នោះ អវិជ្ជា ក៏អ្នកសម្រេចវិជ្ជាហើយកម្ចាត់ហើយ អធិប្បាយថា ឲ្យវិនាសហើយ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះវិជ្ជាកើតឡើងហើយ ។ ក្នុងបទទាំង ២ សូម្បីក្រៅពីនេះ ក៏មានន័យនេះឯង ។

បទថា **យថា** ក្នុងពាក្យថា **យថា តំ** នេះ ជាឧបមា ។ បទថា **តំ** ត្រឹម

តែជានិបាត ។ ឈ្មោះថា **មិនប្រមាទហើយ** ព្រោះមានសតិ ។ ឈ្មោះថា **មានសេចក្ដីព្យាយាម** ព្រោះមានសេចក្ដីព្យាយាមជាគ្រឿងដុតកិលេស ។ ឈ្មោះថា **មានខ្លួនដែលបញ្ជូនទៅ** ព្រោះមិនអាល័យ ក្រោកអរក្នុងរាងកាយ និងជីវិត ។ លោកអធិប្បាយទុកដូច្នេះ បុគ្គលមិនប្រមាទ មានសេចក្ដីព្យាយាម បញ្ជូនចិត្តទៅហើយ អវិជ្ជានឹងវិនាសទៅ វិជ្ជានឹងកើតឡើង សេចក្ដីងងឹតនឹងវិនាសទៅ ពន្លឺនឹងគប្បីកើតឡើង យ៉ាងណា អវិជ្ជា ដែលការព្រាហ្មណ៍នេះកម្ចាត់ហើយ វិជ្ជាក៏កើតឡើង សេចក្ដីងងឹតត្រូវកម្ចាត់ហើយ ពន្លឺក៏កើតឡើង ដូច្នោះដូចគ្នា ។ ព្រាហ្មណ៍នោះ ទើបបានទទួលផលដែលសមគួរដល់ការប្រកបសេចក្ដីព្យាយាមនោះ ដូច្នេះ ។

## កថាពណ៌នាចុតូបបាតញ្ញាណ

គប្បីជ្រាបវិនិច្ឆ័យក្នុងកថាពណ៌នាចុតូបបាតញ្ញាណ ដូចតទៅនេះ ។

វិជ្ជា គឺ ទិព្វចក្ខុញ្ញាណ ឈ្មោះថា **វិជ្ជា** ។ ការមិនដឹង ដែលបិទបាំងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ឈ្មោះថា **អវិជ្ជា** ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

## កថាពណ៌នាអាសវក្ខយញ្ញាណ

គប្បីជ្រាបវិនិច្ឆ័យក្នុងវិជ្ជាទី ៣ ដូចតទៅនេះ ។

ក្នុងបទថា ***សោ ឯវំ សមាហិតេ ចិត្តេ*** (ភិក្ខុនោះ លុះចិត្តជាសមាធិ... យ៉ាងនេះ) គប្បីជ្រាបថា បានដល់ ចតុត្ថជ្ឈានចិត្ត ដែលជាបាទនៃវិបស្សនា ។ បទថា ***អាសវានំ ខយញ្ញាណាយ*** (ដើម្បីអាសវក្ខយញ្ញាណ) សេចក្តីថា ដើម្បីប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ព្រោះអរហត្តមគ្គ ហៅថា ឈ្មោះថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ ព្រោះញ៉ាំងអាសវៈទាំងឡាយឲ្យវិនាស ។ ម្យ៉ាងទៀត អរហត្តមគ្គញ្ញាណ ក្នុងបទថា ***ដើម្បីអាសវក្ខយញ្ញាណ*** នោះ ហៅថា ឈ្មោះថា ញាណ ព្រោះរាប់បញ្ចូលក្នុងព្រះអរហត្តមគ្គនោះ ។ បទថា ***ចិត្តំ អភិនិន្នាមេតិ*** (បង្អោនចិត្ត) សេចក្តីថា បង្អោនចិត្តទៅក្នុងវិបស្សនា ។ ក្នុងបទមានជាអាទិ៍យ៉ាងនេះថា ***សោ ឥទំ ទុក្ខំ*** (បុគ្គលដឹងច្បាស់ថា នេះទុក្ខ) គប្បីជ្រាបសេចក្តីយ៉ាងនេះថា គេរមែងដឹង គឺ រមែងត្រាស់ដឹងទុក្ខសច្ចសូម្បីទាំងអស់ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមដោយកិច្ចថា ទុក្ខមានត្រឹមតែប៉ុណ្ណេះ មិនច្រើនជាងនេះ និងដឹង គឺ ចាក់ធ្លុះតណ្ហា ដែលឲ្យកើតទុក្ខនោះថា នេះជាហេតុឲ្យកើតទុក្ខ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងកិច្ច ដឹង គឺ ចាក់ធ្លុះឋានៈដែលទុក្ខ និងទុក្ខសមុទយៈសូម្បីទាំងពីរ (មក) ដល់ហើយរមែងរលត់ទៅ គឺ ឋានៈដែលប្រព្រឹត្តទៅមិនបាន ជាទីរលត់ទៅនៃទុក្ខ និងទុក្ខសមុទ័យទាំងពីរនោះ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំង

កិច្ចថា នេះជាទីរលត់ទុក្ខ និងដឹង គឺចាក់ធ្លុះអរិយមគ្គ ដែលឲ្យដល់និព្វាននោះ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈព្រមទាំងកិច្ចថា នេះជាវត្តបដិបត្តិឲ្យដល់ទីរលត់ទុក្ខ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងសច្ចៈទាំងឡាយដោយសរុបយ៉ាងនេះហើយ អំពីនេះ កាលទ្រង់សម្តែងសច្ចៈទាំងឡាយដោយអម ដោយអំណាចនៃកិលេស ទើបត្រាស់ពាក្យមានជាអាទិ៍ថា **អាសវៈទាំងនេះ** ដូច្នេះ ។

បទថា **តស្ស ឯវំ ជានតោ ឯវំ បស្សតោ** (កាលលោកដឹងយ៉ាងនេះ ឃើញយ៉ាងនេះ) សេចក្តីថា របស់ភិក្ខុនោះអ្នកដឹងហើយ ឃើញហើយយ៉ាងនេះ ។ ព្រះមានព្រះភាគត្រាស់មគ្គឲ្យដល់ទីបំផុត ព្រមទាំងវិបស្សនាទុក (ក្នុងទីនេះ) ។ បទថា **កាមាសវា** ប្រែថា ចេញចាកកាមាសវៈ ។ ដោយបទថា **ចិត្តំ វិមុច្ចតិ** (ចិត្តរួចផុត) ព្រះមានព្រះភាគ ទ្រង់សម្តែងដល់មគ្គខណៈ (ខណៈចិត្តដែលសម្បយុត្តដោយមគ្គ) អធិប្បាយថា ក្នុងខណៈនៃមគ្គចិត្ត ចិត្តកំពុងរួចផុត ។ ក្នុងខណៈនៃផលចិត្ត ចិត្តរួចផុតហើយ ។ ដោយបទថា **វិមុត្តស្មឹ វិមុត្តមិតិ ញាណំ** (កាលរួចផុតហើយ ក៏មានញាណថារួចផុតហើយ) នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងបច្ចវេក្ខណញ្ញាណ ។ ដោយពាក្យទាំងឡាយមានជាអាទិ៍ថា **ខីណា ជាតិ** (ជាតិអស់ហើយ) ទ្រង់សម្តែងភូមិរបស់ព្រះខីណាស្រពនោះ ព្រោះថា ព្រះខីណាស្រព

នោះ កាលពិចារណាដោយញាណនោះ រមែងជ្រាបសេចក្តីពិតថា ជាតិអស់ហើយ ដូច្នេះជាដើម ។

សួរថា ក៏ជាតិប្រភេទណារបស់ព្រះខីណាស្រពនោះអស់ទៅហើយ និង លោកនឹងដឹងថា ជាតិនោះអស់ទៅបានដូចម្តេច ។

ឆ្លើយថា មុនដំបូង អតីតជាតិរបស់លោកមិនបានអស់ទៅទេ ព្រោះអតីតជាតិនោះអស់ទៅហើយ ជាតិជាអនាគតក៏មិនអស់ ព្រោះមិនមានសេចក្តីព្យាយាមក្នុងអនាគត ជាតិបច្ចុប្បន្នក៏មិនទាន់អស់ ព្រោះជាតិបច្ចុប្បន្ននោះកំពុងមាន តែជាតិណាដែលចែកប្រភេទជា ខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ នឹងគប្បីកើតឡើង ក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព ព្រោះមិនបានចម្រើនមគ្គ ជាតិនោះឈ្មោះថា អស់ទៅហើយ ដោយការដល់ការមិនកើតឡើងជាធម្មតា ព្រោះបានចម្រើនមគ្គហើយ ។ លោក កាលពិចារណាកិលេសដែលលះបានហើយដោយមគ្គភាវនា កាលដឹងថា កម្មសូម្បីនឹងមាន ក៏មិនតាក់តែងបដិសន្ធិតទៅ ព្រោះមិនមានកិលេស ដូច្នេះ ឈ្មោះថា **ដឹងជាតិនោះ** ។

បទថា **វុសិតំ** (នៅចប់ហើយ) បានដល់ នៅហើយ គឺ នៅស្រេចអស់ហើយ អធិប្បាយថា ធ្វើសម្រេចអស់ហើយ ។ បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ ព្រះសេក្ខៈ ៧ ពួក ព្រមដោយកល្យាណបុថុជ្ជនទាំងឡាយ

ឈ្មោះថា នៅប្រព្រឹត្តព្រហ្មចរិយៈ (ចំណែក) ព្រះខីណាស្រព ឈ្មោះថា នៅចប់ព្រហ្មចរិយៈហើយ ព្រោះដូច្នោះ កាលលោកពិចារណាការនៅប្រព្រឹត្តព្រហ្មចរិយៈរបស់ខ្លួន រមែងដឹងច្បាស់ថា ព្រហ្មចរិយៈយើងនៅចប់ហើយ ។ បទថា **កតំ ករណីយំ** (កិច្ចដែលគួរធ្វើ បានធ្វើហើយ) មានអធិប្បាយថា កិច្ចទាំង ១៦ យ៉ាង ដោយអំណាចនៃការត្រាស់ដឹង ដោយបរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និងភាវនាកិច្ចដោយមគ្គទាំង ៤ ក្នុងសច្ចៈទាំង ៤ ដែលលោកឲ្យសម្រេចហើយ ។ ព្រោះថា កល្យាណបុថុជ្ជនជាដើម កំពុងធ្វើកិច្ចនោះឯង ។ ចំណែកព្រះខីណាស្រព ធ្វើកិច្ចស្រេចហើយ ព្រោះដូច្នោះ កាលលោកពិចារណាកិច្ចដែលខ្លួននឹងត្រូវធ្វើ រមែងដឹងច្បាស់ថា កិច្ចដែលគួរធ្វើយើងធ្វើស្រេចហើយ ។ បទថា **នាបរំ ឥត្ថត្តាយ** (កិច្ចដទៃដើម្បីជាយ៉ាងនេះ មិនមាន) សេចក្តីថា លោករមែងដឹងច្បាស់ថា កិច្ច គឺ ការបំពេញមគ្គ ដើម្បីភាពជាយ៉ាងនេះទៀត គឺ ដើម្បីជាកិច្ច ១៦ យ៉ាង ឬដើម្បីការអស់កិលេសយ៉ាងនេះ មិនមានដល់យើង ។

ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** (ដើម្បីជាយ៉ាងនេះ) សេចក្តីថា ដឹងច្បាស់ថា ការបន្តនៃខន្ធដទៃ អំពីសភាពជាយ៉ាងនេះ គឺ ការបន្តនៃខន្ធ ដែលមាននៅក្នុងបច្ចុប្បន្នមានប្រការយ៉ាងនេះ នេះមិនមានដល់យើង បញ្ចក្ខន្ធទាំងនេះ ដែលយើងកំណត់ដឹងហើយ តាំងនៅមែន (តែ) ដូចជាដើមឈើដែលមានឫសដាច់

ហើយ បញ្ចក្ខន្ធទាំងនោះនឹងរលត់ទៅ ព្រោះវិញ្ញាណដួងចុងក្រោយរលត់ ដូច អណ្តាតភ្លើងដែលអស់ឧសហើយ រមែងរលត់ទៅ ដូច្នោះ ។ វិជ្ជា គឺ **អរហត្ត-មគ្គញ្ញាណ** ឈ្មោះថា **វិជ្ជា** ក្នុងទីនេះ ។ អវិជ្ជា ដែលបិទបាំងអរិយសច្ច ៤ ឈ្មោះថា **អវិជ្ជា** ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ។

បទថា **អនុច្ចាវចសីលស្ស** (បុគ្គលមានសីលមិនខ្ពស់ទាប) សេចក្តីថា បុគ្គលមានសីល វេលាខ្លះសាបសូន្យ វេលាខ្លះចម្រើន ឈ្មោះថា មានសីលខ្ពស់ទាប ។ ចំណែកព្រះខីណាស្រព មានសីលចម្រើនតែម្យ៉ាងប៉ុណ្ណោះ ។ ព្រោះដូច្នោះ លោកទើបឈ្មោះថា មានសីលមិនខ្ពស់ទាប ។ បទថា **វសីភូតំ** (ជាវសី) បានដល់ ដល់នូវសេចក្តីជំនាញ ។ បទថា **សុសមាហិតំ** (តាំងមាំ) បានដល់ តាំងទុកដោយល្អ គឺ តាំងទុកល្អហើយក្នុងអារម្មណ៍ ។ បទថា **ធីរំ** (ជាអ្នកប្រាជ្ញ) បានដល់ អ្នកសម្បូរណ៍ដោយបញ្ញា ។ បទថា **មច្ចុហាយនំ** បានដល់ លះបង់មច្ចុរាជហើយតាំងនៅ ។ បទថា **សព្វប្បហាយិនំ** (លះបាបកម្មទាំងពួងចេញ) បានដល់ លះបាបធម៌ទាំងអស់ហើយតាំងនៅ ។ បទថា **ពុទ្ធំ** (ជាព្រះពុទ្ធ) បានដល់ ត្រាស់ដឹងសច្ចៈទាំង ៤ ។ បទថា **អន្តិមទេហធារំ** (មានព្រះសរីរៈជាគ្រាចុងក្រោយ) សេចក្តីថា ទ្រង់ទុកនូវរាងកាយជាលើកចុងក្រោយ ។ បទថា **តំ នមស្សន្តិ គោតមំ** (រមែងថ្វាយបង្គំព្រះគោតមអង្គនោះ) សេចក្តីថា សាវករបស់

ព្រះពុទ្ធទាំងឡាយ នមស្ការព្រះអង្គដែលជាគោតមគោត្រ ។ម្យ៉ាងទៀត មាន អធិប្បាយថា សូម្បីសាវករបស់ព្រះពុទ្ធ ទ្រង់ព្រះនាមថា គោតមៈ ក៏ឈ្មោះថា គោតមៈ ទេវតា និងមនុស្សទាំងឡាយ នមស្ការសាវកដែលឈ្មោះថា គោតមៈ នោះ ។

បទថា **បុព្វេនិវាសំ** (ជាតិមុន) បានដល់ ខន្ធដែលធ្លាប់អាស្រ័យនៅក្នុង ជាតិមុនបន្តគ្នាមក ។ បទថា **យោវេតិ** សេចក្តីថា បុគ្គលណាមិនសាបសូន្យ គឺ មិនធ្លាក់ចុះ ។ បាឋៈថា **យោ វេទិ** ដូច្នេះក៏មាន អធិប្បាយថា បុគ្គលណាបាន ដឹងហើយ គឺ ធ្វើវត្ថុដែលដឹងហើយឲ្យប្រាកដ ហើយតាំងនៅ ។ បទថា **សគ្គា-បាយញ្ច បស្សតិ** (ឃើញសួគ៌ និងអបាយ) សេចក្តីថា បុគ្គលនោះឃើញសួគ៌ ជាន់កាមាវចរៈ ៦ ជាន់ ព្រហ្មលោក ៩ ជាន់ និងអបាយទាំង ៤ ។ បទថា **ជាតិក្ខយំ បត្តោ** (ដល់ធម៌ដែលអស់ជាតិហើយ) សេចក្តីថា សម្រេចអរហត្តផល ។ បទថា **អភិញ្ញា វោសិតោ** (នៅចប់ហើយព្រោះដឹងដ៏ក្រៃលែង) សេចក្តីថា នៅ ដោយការបញ្ចប់កិច្ចព្រោះដឹង ។ មុនី គឺ ព្រះខីណាស្រព ដែលប្រកបដោយ ភាពជាអ្នកដឹង ឈ្មោះថា **មុនី** ។ បទថា **ឯតាហិ** (ទាំងនេះ) សេចក្តីថា ដោយ ញាណទាំងឡាយ មានបុព្វេនិវាសានុស្សតិញ្ញាណជាដើម ដែលទ្រង់សម្តែងទុក ហើយក្នុងខាងក្រោយ ។ បទថា **ន អញ្ញំ លបិតលាបនំ** (មិនហៅបុគ្គលដទៃ...

តាមពាក្យដែលបុគ្គលដទៃហៅ) សេចក្ដីថា តែតថាគតមិនហៅបុគ្គលដទៃនោះ ថា អ្នកបានវិជ្ជា ៣ ត្រឹមតែពាក្យដែលអ្នកដទៃហៅ ថា អ្នកបានវិជ្ជា ៣ ទេ ។ អធិប្បាយថា តថាគតហៅអ្នកដឹងដោយប្រចក្សចំពោះខ្លួន ហើយប្រាប់វិជ្ជា ៣ ដល់អ្នកដទៃផង ថាជាអ្នកមានវិជ្ជា ៣ ។ បទថា **កលំ** បានដល់ ចំណែក ។ បទថា **នាគ្ឃតិ** គឺ **ន បាបុណាតិ** (មិនដល់) ។ ឥឡូវនេះ ព្រាហ្មណ៍ជ្រះថ្លាក្នុងព្រះពុទ្ធវចនៈហើយ កាលនឹងសម្ដែងអាការរបស់អ្នកជ្រះថ្លា ទើបបានពោលពាក្យមានជាអាទិ៍ថា **ច្បាស់ណាស់** ដូច្នេះ ។

ចប់អដ្ឋកថា តិកណ្ណសូត្រទី ៨

# អដ្ឋកថា ជាណុស្សោណិសូត្រទី ៩

## “វិជ្ជា ៣ របស់ព្រាហ្មណ៍ និងរបស់ព្រះពុទ្ធ”

គប្បីជ្រាបវិនិច្ឆ័យក្នុង ជាណុស្សោណិសូត្រទី ៩ ដូចតទៅនេះ ៈ-

[៦១] បទថា **យស្សស្សុ** ស្មើនឹង **យស្ស ភវេយ្យុំ** (របស់បុគ្គលណា គប្បីមាន) ។ ក្នុងបទថា **យញ្ញោ** (យ័ញ្ញ) ជាដើម មានអធិប្បាយថា ទេយ្យធម៌ ឈ្មោះថា យ័ញ្ញ ព្រោះត្រូវបូជា ។ ពាក្យថា យ័ញ្ញនេះ ជាឈ្មោះនៃទេយ្យធម៌ ។ បទថា **សទ្ធំ** (វត្ថុដែលគប្បីឲ្យដោយសទ្ធា) បានដល់ កត្តាហារដែលឧទ្ទិសដើម្បីអ្នកស្លាប់ ។ បទថា **ថាលិបាកោ** (អាហារដែលគប្បីឲ្យ) បានដល់ កត្តាហារដែលគប្បីឲ្យដល់បរិស័ទដទៃ ។ ដែលឈ្មោះថា ទេយ្យធម៌គ្រប់យ៉ាងដ៏សេសអំពីដែលពោលហើយ ឈ្មោះថា **ទេយ្យធម៌** ។

បទថា **តេវិជ្ជេសុ ព្រាហ្មណេសុ ទានំ ទទេយ្យ** (គួរឲ្យទានក្នុងពួកព្រាហ្មណ៍អ្នកបានវិជ្ជា ៣) សេចក្តីថា ទានទាំងអស់នេះ គួរឲ្យក្នុងអ្នកមានវិជ្ជា ៣ ។ ជាណុស្សោណិព្រាហ្មណ៍ពោលថា ព្រាហ្មណ៍អ្នកមានវិជ្ជា ៣ ប៉ុណ្ណោះ គួរបានទទួល (ទាន) ។ បទដ៏សេសក្នុងព្រះសូត្រនេះ មានន័យដូចពោលហើយក្នុងខាងក្រោយនោះឯង ។

ចប់អដ្ឋកថា ជាណុស្សោណិសូត្រទី ៩

# អដ្ឋកថា សង្គារវសូត្រទី ១០

## "បុញ្ញប្បដិបទាដែលមានផលច្រើន"

គប្បីជ្រាបវិនិច្ឆ័យក្នុង សង្គារវសូត្រទី ១០ ដូចតទៅនេះ ៈ-

[៦២] បទថា **សង្គារវោ** (សគារវៈ) បានដល់ ព្រាហ្មណ៍អ្នកថែរក្សាអ្នកធ្វើការបដិសន្ធរណៈរបស់ចាស់ក្នុងក្រុងរាជគ្រឹះ មានឈ្មោះយ៉ាងនេះ ។ បទថា **ឧបសង្កមិ** (ចូលទៅគាល់) សេចក្តីថា ព្រាហ្មណ៍ទទួលទានអាហារព្រឹកហើយ មានមហាជនហែហម ចូលទៅគាល់ព្រះមានព្រះភាគ ។ បទថា **អស្សុ** ក្នុងបទថា **មយមស្សុ** នេះ ជានិបាត គឺ ជាបទសម្តែងសេចក្តីនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ឈ្មោះថា ជាព្រាហ្មណ៍ ។

បទថា **យញ្ញំ យជាម** (បូជាយ័ញ្ញ) សេចក្តីថា ដែលឈ្មោះថា យ័ញ្ញប្រកបទៅដោយការសម្លាប់សត្វយ៉ាងនេះ ចំណែកមួយ ៤ ក្បាល ចំណែកមួយ ៨ ក្បាល ចំណែកមួយ ១៦ ក្បាល ចំណែកមួយ ៣២ ក្បាល ចំណែកមួយ ៦៤ ក្បាល ចំណែកមួយ ១០០ ក្បាល និងចំណែកមួយ ៥០០ ក្បាល មាននៅក្នុងលទ្ធិខាងក្រៅ (ព្រះពុទ្ធសាសនា) ។ ព្រះមានព្រះភាគត្រាស់សំដៅយកយ័ញ្ញនោះឯង ។ បទថា **អនេកសារីរិកំ** បានដល់ ធ្វើឲ្យកើតផលដល់សរីរៈដ៏ច្រើន ។ បទថា **យទិទំ** ស្មើនឹង **យា ឯសា** (នេះណា) ។ បទថា **យញ្ញាធិ-**

*ករណំ (ដែលមានយញ្ញជាហេតុ) សេចក្តីថា មានការបូជាយញ្ញជាហេតុ និង មានការឲ្យអ្នកដទៃបូជាជាហេតុ ។ ពិតហើយ កាលបុគ្គលម្នាក់ ឲ្យដោយខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃឲ្យក្តី ដល់មនុស្សដ៏ច្រើន សូម្បីមនុស្សដ៏ច្រើន ឲ្យដោយខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃឲ្យក្តី ដល់មនុស្សដ៏ច្រើន បុញ្ញប្បដិបទា ឈ្មោះថា បដិបទាដែលធ្វើឲ្យកើតផលដល់សរីរៈច្រើន ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយកបដិបទានោះ ។ និងបុញ្ញប្បដិបទារបស់អ្នកពោលហើយថា យើងបូជាលោក យើងបូជាលោក ដូច្នេះក្តី អ្នកប្រើអ្នកដទៃថា លោកចូរបូជា លោកចូរបូជា ដូច្នេះក្តី ឈ្មោះថា ជាបដិបទាដែលធ្វើឲ្យកើតផលដល់សរីរៈដ៏ច្រើនដូចគ្នា ។ ពាក្យនេះ ព្រះមានព្រះភាគត្រាស់សំដៅយក បុញ្ញប្បដិបទានោះ ។*

*បទថា **យស្ស វា តស្ស វា** ស្មើនឹង **យស្មា វា តស្មា វា** (ចេញពីត្រកូលណាក៏ដោយ) ។ បទថា **ឯកមត្តានំ ទមេតិ** សេចក្តីថា ទូន្មានខ្លួនម្នាក់ឯង ដោយអំណាចនៃការទូន្មានឥន្ទ្រិយរបស់ខ្លួន ។ បទថា **ឯកមត្តានំ សមេតិ** សេចក្តីថា រម្ងាប់ខ្លួនម្នាក់ឯង ដោយការស្ងប់រាគៈជាដើមរបស់ខ្លួន ។ បទថា **បរិនិព្វាបេតិ** (ធ្វើខ្លួនឲ្យរលត់) សេចក្តីថា ធ្វើខ្លួនឲ្យរលត់ដោយការធ្វើរាគៈជាដើមមិនឲ្យកើតទៀតទុំះឯង ។ បទថា **ឯវមេស្សាយំ** ស្មើនឹង **ឯវំ សន្តេ អយំ** (សូម្បីដូច្នេះ បុគ្គលនេះ) ។*

ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍យ៉ាងនេះហើយ ទ្រង់ត្រិះរិះថា ព្រាហ្មណ៍នេះ ពោលដល់មហាយ័ញ្ញដែលប្រកបដោយការសម្លាប់សត្វថា ជាបុញ្ញប្បដិបទាដែលធ្វើឲ្យកើតផលដល់សរីរៈច្រើន តែពោលដល់បដិបទាដែលជាហេតុឲ្យកើតបុណ្យ មានបព្វជ្ជាជាឫសគល់ ថាជាបុញ្ញប្បដិបទាដែលធ្វើឲ្យកើតផលដល់សរីរៈតែមួយ ព្រាហ្មណ៍នេះមិនស្គាល់បដិបទា ដែលធ្វើឲ្យកើតផលដល់សរីរៈមួយផង មិនស្គាល់បដិបទាដែលធ្វើឲ្យកើតផលដល់សរីរៈច្រើនផង ណ្ហើយចុះ តថាគតនឹងសម្តែងបដិបទាដែលធ្វើឲ្យកើតផលដល់សរីរៈមួយ ទាំងធ្វើឲ្យកើតផលដល់សរីរៈច្រើនដល់គេ ដូច្នេះហើយ កាលនឹងទ្រង់អធិប្បាយព្រះធម៌ទេសនាតទៅទៀត ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ព្រាហ្មណ៍ បើដូច្នោះ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **យថា តេ ខមេយ្យ** (តាមដែលលោកគួរឃើញ) សេចក្តីថា លោកពេញចិត្តយ៉ាងណា ។ បទថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** (ព្រះតថាគតស្តេចឧប្បត្តិក្នុងលោក) បានឲ្យពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឯត្ថាយំ មគ្គោ** (មគ្គនេះ) សេចក្តីថា អ្នកទាំងឡាយមកចុះ តថាគតនឹងសម្តែងប្រាប់ នេះជាផ្លូវ ។ បទថា **អយំ បដិបទា** (បដិបទានេះ) នេះជាវេវចនៈនៃពាក្យ **មគ្គនេះ** នោះឯង ។ បទថា **យថា បដិបន្នោ** (ដំណើរទៅហើយតាម...) សេចក្តីថា ប្រព្រឹត្តទៅហើយ ដោយមគ្គណា ។ បទថា **អនុត្តរំ**

*ព្រហ្មចរិយោគធំ* (ធម៌ដ៏កំពូលដែលជាទីបំផុតនៃព្រហ្មចរិយៈ) សេចក្តីថា ធម៌ដ៏កំពូល គឺ ព្រះនិព្វាន ដែលជាទីពឹងដ៏កំពូល ជាទីបំផុតនៃព្រហ្មចរិយៈ ។ បទថា *ឥច្ចាយំ* កាត់បទជា *ឥតិ អយំ* ។

បទថា ***អប្បត្ថតរា*** (មានសេចក្តីត្រូវការតិចផង) សេចក្តីថា ជាបដិបទាដែលមិនត្រូវការសេចក្តីជួយ ឬមិនត្រូវការឧបករណ៍ច្រើន ។ បទថា ***អប្បសមារម្ភតរា*** (មានការរៀបចំតិចផង) សេចក្តីថា ជាបដិបទាដែលមិនមានការប្រណាំងប្រជែង ពោលគឺ សេចក្តីបៀតបៀនដោយអំណាចការកាត់នូវកម្ម (សេចក្តីល្អ) របស់បុគ្គលច្រើន ។

បទថា *សេយ្យថាបិ ភវំ គោតមោ ភវញ្ច អានន្ទោ ឯតេ មេ បុជ្ជា* (ព្រះគោតមយ៉ាងណា ព្រះអានន្ទក៏យ៉ាងនោះ លោកទាំងពីរនេះ ខ្ញុំគួរបូជា) សេចក្តីថា ព្រាហ្មណ៍ពោលពាក្យនោះ សំដៅដល់សេចក្តីនេះថា បុគ្គលដូចព្រះគោតមដ៏ចម្រើន និងព្រះអានន្ទដ៏ចម្រើន ជាអ្នកដែលខ្ញុំបូជាហើយ បានដល់ ពួកលោកនុ៎ះឯង គឺ ទាំងពីរនាក់ ជាបុគ្គលដែលខ្ញុំបូជា និងសរសើរ ។ បានឮថា ព្រាហ្មណ៍នោះ មានសេចក្តីគិតយ៉ាងនេះថា ព្រះអានន្ទត្ថេរត្រូវការឲ្យយើងប៉ុណ្ណោះ ឆ្លើយបញ្ហានេះ តែកាលយើងពោលសរសើរគុណរបស់ខ្លួន ឈ្មោះថា ជាអ្នកទឹងមិនគ្រេកអរមិនមាន ។ ព្រោះដូច្នោះ ព្រាហ្មណ៍កាលមិនបំណងឆ្លើយបញ្ហា ទើប

ពោលយ៉ាងនេះឲ្យឃ្លៀងឃ្លាតទៅ ដោយអំណាចនៃការពោលសរសើរ ។ បទថា **ន ខោ ត្យាហំ** កាត់បទជា **ន ខោ តេ អហំ** ។

បានឮថា សូម្បីព្រះថេរៈក៏គិតថា ព្រាហ្មណ៍នេះមិនបំណងនឹងឆ្លើយបញ្ហា ទើបនិយាយវាង យើងនឹងឲ្យព្រាហ្មណ៍នេះឆ្លើយបញ្ហានេះឲ្យបាន ព្រោះដូច្នោះ លោកទើបពោលយ៉ាងនេះ ចំពោះព្រាហ្មណ៍នោះ ។

បទថា **សហធម្មិកំ** (មានហេតុ) បានដល់ ប្រព្រឹត្តទៅជាមួយហេតុ ។ បទថា **សំសាទេតិ** (លះបង់) បានដល់ ទម្លាក់ចោល ។ បទថា **នោ វិស្សជ្ជេតិ** (មិនឆ្លើយ) បានដល់ មិនពោល ។

បទថា **យន្នូនាហំ បរិមោចេយ្យំ** (បើដូច្នោះ តថាគតនឹងជួយ) សេចក្តីថា កុំដូច្នោះឡើយ តថាគតនឹងជួយដោះស្រាយអ្នកទាំង ២ ឲ្យផុតពីសេចក្តីលំបាកចិត្ត ។ ព្រោះថា ព្រាហ្មណ៍កាលមិនឆ្លើយបញ្ហាដែលព្រះអានន្ទសួរ រមែងលំបាកចិត្ត ចំណែកព្រះអានន្ទ កាលឲ្យព្រាហ្មណ៍ដែលមិនព្រមឆ្លើយ ឆ្លើយឲ្យបាន ក៏លំបាកចិត្ត ដូច្នោះ ព្រះមានព្រះភាគទ្រង់ព្រះត្រិះរិះថា តថាគតនឹងជួយដោះស្រាយអ្នកទាំងពីរនេះ អំពីសេចក្តីលំបាកចិត្ត ទើបត្រាស់យ៉ាងនេះ ។ បទថា **កាន្វជ្ជ** កាត់បទជា **កា នុ អជ្ជ** (ថ្ងៃនេះ...យ៉ាងណាហ្ន៎) ។ បទថា **អន្តរាកថា ឧទបាទិ** (បានសន្ទនាគ្នាកើតឡើងក្នុងចន្លោះ) សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ក្នុង

ចន្លោះនៃការសន្ទនាគ្នាដល់រឿងដទៃ មានរឿងអ្វីកើតឡើងខ្លះ ។ ព្រះសាស្តាត្រាស់យ៉ាងនេះ ដោយមានពុទ្ធបំណងថា បានឮថា គ្រានោះ ក្នុងព្រះរាជវាំងមានកថាប្រារព្ធបាដិហារ្យ ៣ កើតឡើង តថាគតនឹងសួរសេចក្តីនោះ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា ឥឡូវនេះ យើងអាចនឹងនិយាយបានកាលនឹងក្រាបទូលសេចក្តីដែលកើតឡើងក្នុងព្រះរាជវាំង ទើបពោលពាក្យមានជាអាទិ៍ថា **អយំ ខ្វជ្ជ ភោ គោតម** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អយំ ខ្វជ្ជ** កាត់បទជា **អយំ ខោ អជ្ជ** ។ បទថា **សុទំ** ក្នុងបទថា **បុព្វេ សុទំ** (គេថាកាលមុន) ត្រឹមតែជានិបាត ។ បទថា **ឧត្តរិមនុស្សធម្មា** បានដល់ មនុស្សធម៌ដែលខ្ពង់ខ្ពស់ ពោលគឺ កុសលកម្មបថ ១០ ។ ដោយបទថា **ឥទ្ធិបាដិហារិយំ ទស្សេសុំ** (សម្តែងឥទ្ធិបាដិហារិយ៍) ព្រាហ្មណ៍ពោលសំដៅយកការហោះឡើងទៅលើអាកាស ដែលប្រព្រឹត្តទៅហើយក្នុងសម័យមុនយ៉ាងនេះ គឺ ភិក្ខុទាំងឡាយកាលទៅភិក្ខាចារ ទាំងទៅទាំងត្រឡប់ នឹងហោះទៅតាមផ្លូវអាកាសនោះឯង ។ ដោយបទថា **ឯតរហិ បន ពហុតរា ច ភិក្ខុ** (សព្វថ្ងៃនេះ ភិក្ខុធម្មតាមានច្រើនជាង) នេះ ព្រាហ្មណ៍ពោលយ៉ាងនេះតាមលទ្ធិថា កាលមុន ភិក្ខុទាំងឡាយប្រហែលជានឹងគិតថា ពួកយើងនឹងញ៉ាំងបច្ច័យ ៤ ឲ្យកើតឡើង ទើបធ្វើយ៉ាងនេះ តែឥឡូវនេះ ដឹងថា បច្ច័យកើតឡើងហើយ ទើបបណ្តោយវេលាឲ្យកន្លងទៅដោយ

មោហៈ និងសេចក្ដីប្រមាទ ។

បទថា **បាដិហារិយានិ** បានដល់ បាដិហារ្យ ដោយបំណងកម្ចាត់លទ្ធិដែលជាបដិបក្ខ ។ បទថា **ឥទ្ធិបាដិហារិយំ** សេចក្ដីថា បាដិហារ្យដោយអំណាចការសម្ដែងឫទ្ធិ ឈ្មោះថា ឥទ្ធិបាដិហារ្យ ។ សូម្បីក្នុងបាដិហារ្យក្រៅពីនេះ ក៏មានន័យនេះដូចគ្នា ។ អត្ថាធិប្បាយ វិជ្ជា ៨ ប្រការ មានឥទ្ធិវិធីផ្សេងៗ ក្ដី ន័យនៃការចម្រើន (វិជ្ជា ៨ ប្រការនោះ) ក្ដី បានឲ្យពិស្ដារក្នុងគម្ពីរវិសុទ្ធិមគ្គហើយនោះឯង ។

បទថា **និមិត្តេន អាទិសតិ** (និយាយទាយចិត្តតាមនិមិត្ត) សេចក្ដីថា ទាយថា ឈ្មោះថាវត្ថុនេះ នឹងមានដោយនិមិត្តដែលកន្លងមកហើយ ដោយនិមិត្តដែលកន្លងទៅហើយ ឬដោយនិមិត្តដែលតាំងនៅ ។ ក្នុងសេចក្ដីនេះ មានរឿងដូចតទៅនេះ (ជាឧទាហរណ៍) ។

ដំណាលមកថា ព្រះរាជាព្រះអង្គមួយ ទ្រង់ក្ដាប់កែវមុក្ដា ៣ គ្រាប់ ហើយត្រាស់សួរបុរោហិតថា លោកអាចារ្យអ្វីនៅក្នុងដៃរបស់យើង ។ បុរោហិតត្រួតមើលខាងនេះ ខាងនោះ និងវេលានោះ មានតុកែមួយក្បាលរត់ទៅដោយតាំងចិត្តថា នឹងចាប់រុយ ក្នុងវេលាចាប់ រុយក៏ហើរចេញទៅ ។ គេទើបក្រាបទូលថា បពិត្រមហារាជ កែវមុក្ដា ព្រះអង្គ ។ ព្រោះការ (កាន់យកនិមិត្ត) រុយដែលចេញ

ទៅបាន ។ ព្រះរាជាត្រាស់សួរតទៅទៀតថា ត្រូវហើយ កែវមុក្តា ប៉ុន្តែថា មាន ប៉ុន្មាន ។ បុរោហិតត្រួតមើលនិមិត្តទៀត វេលានោះមានរង្វាវឡើង ៣ ជង ក្នុង ទីមិនឆ្ងាយ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ មាន ៣ គ្រាប់ ព្រះអង្គ ។ បុគ្គលខ្លះទាយនិមិត្តដែលកន្លងមកហើយ ដូចពណ៌នាមកនេះ ។ សូម្បីដោយនិមិត្ត ដែលកន្លងទៅហើយ និងតាំងនៅ ក៏គប្បីជ្រាបការទាយដោយឧបាយនេះ ។

បទថា **ឯវម្បិ តេ មនោ** (ចិត្តរបស់លោកយ៉ាងនេះខ្លះ) សេចក្តីថា ចិត្ត របស់លោកយ៉ាងនេះ គឺ អាស្រ័យសោមនស្ស អាស្រ័យទោមនស្ស ឬប្រកប ដោយកាមវិតក្កៈជាដើម ។ បទទី ២ **ឥត្ថម្បិ តេ មនោ** (ចិត្តរបស់លោកយ៉ាង នេះខ្លះ) ជាវេវចនៈរបស់ពាក្យថា **ឯវម្បិ តេ នោ** នោះឯង ។ បទថា **ឥតិបិ តេ ចិត្តំ** (ចិត្តរបស់លោកមានដោយប្រការដូច្នេះខ្លះ) សេចក្តីថា ចិត្តរបស់លោក ប្រព្រឹត្តទៅដោយប្រការនេះ អធិប្បាយថា លោកកំពុងគិតដល់សេចក្តីនេះ និង ប្រការនេះ ហើយប្រព្រឹត្តទៅ ។ បទថា **ពហុញ្ចេបិ អាទិសតិ** (និយាយទាយ ចំពោះមនុស្សជាច្រើនក្តី) សេចក្តីថា ប្រសិនបើគេនឹងព្យាករណ៍ចំពោះមនុស្ស សូម្បីច្រើនសោត ។ បទថា **តថេវ តំ ហោតិ** (ពាក្យដែលលោកនិយាយនោះ ក៏ដូច្នោះ) សេចក្តីថា (វៀងផ្សេងៗ) នឹងដូចដែលទាយទុកនុ៎ះឯង ។

បទថា **អមនុស្សានំ** បានដល់ អមនុស្ស មានយក្ខ និងបិសាចជាដើម ។

បទថា **សទ្ទំ សុត្វា** (បានឮសំឡេង) សេចក្តីថា បានឮសំឡេងរបស់គេដែលកំពុងពោល ទើបទាយ ព្រោះដឹងចិត្តរបស់បុគ្គលដទៃ ។ បទថា **វិតក្កវិចារសទ្ទំ** (សំឡេងវិតក្កវិចារៈ) សេចក្តីថា សំឡេងមនុស្សដែលដេកលក់ និងប្រមាទជាដើម មមើមមាយដល់វត្ថុដែលកើតឡើងដោយអំណាចនៃវិតក្កៈ និងវិចារៈ ។ បទថា **សុត្វា** (បានឮ) បានដល់ បានឮសំឡេងនោះ ។ អធិប្បាយថា ទាយសំឡេងដែលកើតឡើងដោយអំណាចអារម្មណ៍ ដែលលោកកំពុងត្រិះរិះនោះថា ចិត្តរបស់លោកជាយ៉ាងនេះ ។ ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះ ។

បានឮមកថា បុរសម្នាក់គិតថា យើងនឹងទៅដោះស្រាយក្តី ចេញចាកផ្ទះទៅកាន់នគរ រាប់ពីថ្ងៃដែលចេញដំណើរទៅ ក៏គិតថា ក្នុងសាល យើងនឹងធ្វើវត្ថុនេះ នឹងនិយាយពាក្យនេះចំពោះព្រះរាជា និងរាជមហាមាត្យ បានដូចជាថាទៅកាន់រាជត្រកូលហើយ ដូចគ្នានឹងបានឈរចំពោះព្រះភ័ក្ត្ររបស់ព្រះរាជាហើយ និងដូចជាកំពុងឲ្យការនៅជាមួយអ្នកពិភាក្សា ។ បុរសម្នាក់បានឲ្យសំឡេងនោះរបស់គេដែលថ្ងៃងចេញទៅ ដោយអំណាចនៃវិតក្កៈ និងវិចារៈ ទើបសួរថា លោកនឹងទៅដោយរឿងអ្វី ។ គេឆ្លើយថា នឹងទៅដោះស្រាយក្តី ។ បុរសនោះទើបនិយាយថា ទៅចុះ លោកនឹងមានជ័យជំនះ ។ គេទៅដោះស្រាយក្តីហើយ ក៏ប្រសព្វនឹងជ័យជំនះ ។

សូម្បីព្រះថេរៈអ្នកស្រុកបោលិយគ្រាម មួយរូបទៀត បានចូលទៅបិណ្ឌ-បាតក្នុងស្រុក ។ ខណៈនោះ ក្មេងស្រីម្នាក់បញ្ចូនចិត្តទៅទីដទៃ ទើបមិនឃើញលោកដែលដើរចេញទៅ ។ លោកឈរត្រង់ទ្វារស្រុក ហើយត្រឡប់ចេញទៅសម្លឹងមើល ឃើញក្មេងស្រីនោះហើយ បានដើរត្រិះរិះទៅ និងកាលដើរទៅក៏បានពោលថា មេកណ្ដុរធ្វើអ្វី ទើបមិនឃើញយើង ។ បុរសម្នាក់ឈរជិតៗ នោះបានឮហើយ ក៏និយាយឡើងថា លោកម្ចាស់ដ៏ចម្រើន សូមលោកនិមន្តទៅស្រុកបោលិយគាមចុះ ។

បទថា **មនោសង្ខារា បណិហិតា** (លោកនេះ តាំងមនោសង្ខារ) សេចក្ដីថា ចិត្តសង្ខារដែលតាំងទុកល្អហើយ ។ បទថា **វិតក្កេស្សតិ** (នឹងត្រិះរិះ) សេចក្ដីថា ដឹងច្បាស់ថា នឹងត្រិះរិះ គឺ នឹងញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅ ។ ក៏កាលលោកដឹងច្បាស់ហើយ ឈ្មោះថា រមែងដឹងច្បាស់ ដោយនិមិត្តកន្លងមកនុ៎ះឯង ។ រមែងដឹងដោយនិមិត្តដែលជាចំណែកខាងដើម ។ ភិក្ខុពិចារណាចិត្តខាងក្នុងសមាបត្តិហើយ រមែងដឹង ។

ក្នុងវេលាបរិកម្មកសិណទាំងនោះឯង ភិក្ខុដឹងថា ព្រះយោគាវចរនេះប្រារព្ធការចម្រើនកសិណដោយអាការណា នឹងញ៉ាំងបឋមឈាន ។ល។ ចតុត្ថឈាន ឬសមាបត្តិ ៨ ឲ្យកើតឡើងដោយអាការនោះ ឈ្មោះថា **ដឹងដោយនិមិត្តកន្លងមក** ។

*កាលប្រារព្ធសមថវិបស្សនាហើយ ភិក្ខុដឹងហើយ គឺ ដឹងថា ព្រះយោគាវចរនេះ ប្រារព្ធវិបស្សនាហើយដោយអាការណា នឹងញុំាងសោតាបត្តិមគ្គឲ្យកើតឡើង ។ល។ ឬអរហត្តមគ្គឲ្យកើតឡើងដោយអាការនោះ ឈ្មោះថា* ***ដឹងនិមិត្តដោយចំណែកខាងដើម*** *។*

*ភិក្ខុដឹងថា មនោសង្ខាររបស់ព្រះយោគាវចរនេះ ដែលលោកតាំងទុកល្អហើយ លោកនឹងត្រិះរិះនូវវិតក្កៈឈ្មោះនេះ ក្នុងលំដាប់នៃចិត្តឈ្មោះនេះ ដោយអាការណា សមាធិរបស់ព្រះយោគាវចរនេះ ដែលចេញចាកសមាបត្តិនេះហើយ ដែលជាហានភាគិយៈ (នាំទៅកាន់ការលះបង់ នូវភាពវិបរិត និងអវិជ្ជា) ដែលជាឋិតិភាគិយៈ (ជាចំណែកនៃការតាំងនៅ) ដែលជាវិសេសភាគិយៈ (ដែលនាំទៅកាន់ការឈានមុខក្នុងផ្លូវចិត្ត) ឬជានិព្វេធភាគិយៈ (ជាចំណែកនៃការត្រាស់ដឹង) នឹងមាន ឬការធ្វើឲ្យច្បាស់ដោយអភិញ្ញា នឹងកើតឡើងដល់លោក ដោយអាការនោះ ឈ្មោះថា* ***ពិចារណាចិត្តខាងក្នុងសមាបត្តិហើយ រមែងដឹង*** *។*

*បណ្តាបុថុជ្ជនទាំងនោះ បុថុជ្ជនអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុថុជ្ជនផងគ្នា តែមិនដឹងចិត្តរបស់ព្រះអរិយៈ ។ សូម្បីក្នុងព្រះអរិយៈទាំងឡាយ ព្រះអរិយបុគ្គលថ្នាក់ក្រោម រមែងមិនដឹងចិត្តរបស់ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ តែព្រះអរិយបុគ្គលថ្នាក់ខ្ពស់ ដឹងចិត្តរបស់ព្រះអរិយបុគ្គលថ្នាក់ក្រោម ។*

មួយទៀត បណ្ដាព្រះអរិយៈទាំងនេះ ព្រះសោតាបន្ន ចូលសោតាបត្តិផលសមាបត្តិ ។ ព្រះសកទាគាមី... ព្រះអនាគាមី... ព្រះអរហន្ត ចូលអរហត្តផលសមាបត្តិ ។ ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ នឹងមិនចូលសមាបត្តិថ្នាក់ក្រោម ។ ព្រោះថាសមាបត្តិថ្នាក់ក្រោមៗ របស់ព្រះអរិយបុគ្គលថ្នាក់ក្រោមទាំងនោះ នឹងប្រព្រឹត្តទៅក្នុងព្រះអរិយបុគ្គលថ្នាក់ក្រោមប៉ុណ្ណោះ ។ បទថា **តថេវ តំ ហោតិ** (ពាក្យដែលលោកនិយាយនោះក៏ដូច្នោះ) សេចក្ដីថា ពាក្យនាយនោះ រមែងយ៉ាងនោះឯង ព្រោះពាក្យព្យាករណ៍ ដែលលោកដឹងដោយអំណាចនៃចេតោបរិយញ្ញាណឈ្មោះថា នឹងជាដទៃមិនមាន (គឺមិនខុស) ។

បទថា **ឯវំ វិតក្កេថ** (ចូរត្រិះរិះយ៉ាងនេះ) សេចក្ដីថា អ្នកទាំងឡាយចូរត្រិះរិះឲ្យនេក្ខម្មវិតក្កៈជាដើមប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **មា ឯវំ វិតក្កយិត្ថ** (កុំត្រិះរិះយ៉ាងនេះ) សេចក្ដីថា អ្នកទាំងឡាយកុំត្រិះរិះឲ្យកាមវិតក្កៈជាដើមប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **ឯវំ មនសិករោថ** (ចូរមនសិការយ៉ាងនេះ) សេចក្ដីថា អ្នកទាំងឡាយចូរមនសិការដល់អនិច្ចសញ្ញានុ៎ះឯង ឬសញ្ញាណាមួយ ក្នុងបណ្ដាទុក្ខសញ្ញាជាដើមយ៉ាងនេះ ។ បទថា **មា ឯវំ** (កុំមនសិការយ៉ាងនេះ) សេចក្ដីថា អ្នកទាំងឡាយកុំធ្វើទុកក្នុងចិត្ត ដោយន័យជាដើមថា ទៀង ដូច្នេះ ។ បទថា **ឥទំ** (នេះ) សេចក្ដីថា អ្នកទាំងឡាយចូរលះតម្រេកក្នុងបញ្ចកាមគុណនេះ ។ បទថា

ឥទំ បទ ឧបសម្បជ្ជ (ចូលដល់វត្ថុនេះ) សេចក្តីថា អ្នកទាំងឡាយចូរចូលដល់ គឺ សម្រេចលោកុត្តរធម៌ ចែកប្រភេទជាមគ្គ ៤ ផល ៤ នេះនុ៎ះឯង បានដល់ ឲ្យសម្រេចហើយ ។

បទថា មាយាសហធម្មរូបំ វិយ ខាយតិ (រមែងប្រាកដដល់ខ្ញុំព្រះអង្គ ដូចជារូបភាពប្រកបដោយកលមាយា) សេចក្តីថា រមែងប្រាកដដូចជារូបដែល កើតពីហេតុដែលស្មើដោយមាយា ។ ពិតហើយ អ្នកសម្តែងកល រមែងសម្តែង កលបានច្រើនបែបយ៉ាងនេះ គឺ ជប់ទឹកមកធ្វើជាប្រេងក៏បាន ជប់ប្រេងមកធ្វើជា ទឹកក៏បាន សូម្បីបាដិហារ្យនេះ ក៏បែបនោះដូចគ្នា ដូច្នេះ ។

ព្រាហ្មណ៍ពោលយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន សូម្បីបាដិហារ្យ នេះ ប្រាកដដល់ខ្ញុំព្រះអង្គដូចជារូបភាព សំដៅយកបាដិហារ្យស្រដៀងនឹងវិជ្ជា ចិន្តាមណីមន្ត ។ ព្រោះអ្នកដែលដឹងវិជ្ជាចិន្តាមណីមន្តនេះ ឃើញមនុស្សកំពុង ដើរមកនុ៎ះឯង រមែងដឹងថា បុគ្គលនេះដើរត្រិះរិះរឿងនេះ ។ មួយទៀត រមែង ដឹងថា បុគ្គលនេះឈរត្រិះរិះរឿងឈ្មោះនេះ អង្គុយត្រិះរិះរឿងឈ្មោះនេះ ដេក ត្រិះរិះរឿងឈ្មោះនេះ ដូច្នេះ ។

បទថា អភិក្កន្តតរំ (ល្អជាង) បានដល់ ជាទីពេញចិត្តជាង ។ បទថា បណីតតរំ (ប្រណីតជាង) បានដល់ ខ្ពង់ខ្ពស់ជាង ។ ក្នុងបទថា ភវញ្ហិ គោតមោ

***អវិតក្កំ អវិចារំ*** *(ព្រោះព្រះគោតមដ៏ចម្រើន...ដែលមិនមានវិតក្កវិចារៈ) នេះ ព្រាហ្មណ៍មិនបានកាន់យកទេសនាបាដិហារ្យដ៏សេសថា ជាលទ្ធិខាងក្រៅ (ព្រះពុទ្ធសាសនា) តែព្រាហ្មណ៍នោះ កាលនឹងពោលសរសើរព្រះតថាគត ទើបពោលសេចក្តីនេះទាំងអស់ ។ បទថា* ***អទ្ធា ខោ ត្យាហំ*** *(អ្នក...ដល់តថាគតដោយពិត) សេចក្តីថា វាចានេះ អ្នកពោលដល់តថាគតហើយតែម្យ៉ាងដោយពិត ។ បទថា* ***អាសជ្ជ ឧបនិយ្យ វាចា ភាសិតា*** *(ពោលវាចាដែលទាក់ទង) សេចក្តីថា វាចាអែបនែបដែលអ្នកពោលហើយ ប៉ះត្រូវដល់គុណរបស់តថាគតនោះឯង ។ បទថា* ***អបិច ត្យាហំ ព្យាករិស្សាមិ*** *(ណ្ហើយចុះ តថាគតនឹងព្យាករណ៍ដល់អ្នក) សេចក្តីថា ទាំងតថាគតនឹងព្យាករណ៍ដល់អ្នក ។ បទដ៏សេសមានអត្ថងាយទាំងនោះឯង ដូច្នេះ ។*

ចប់អដ្ឋកថា សង្គារវសូត្រទី ១០

## ចប់ព្រាហ្មណវគ្គវណ្ណនា ទី ១

ក្នុងវគ្គនេះ មាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# មហាវគ្គទី ២

## អដ្ឋកថា តិត្ថាយតនសូត្រទី ១[១]

*"លទ្ធិតិត្ថិយ ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តិត្ថាយតនសូត្រទី ១ ដូចតទៅនេះ ៈ-*

*[៦៣] ការកើតដែលជាទិដ្ឋិ ម្យ៉ាងទៀត ការកើតនៃតិត្ថិយ ឈ្មោះថា **តិត្ថាយតនៈ** ។*

*ក្នុងបទថា **តិត្ថាយតនៈ** នោះ អ្នកសិក្សាគប្បីដឹងតិត្ថៈ គប្បីដឹងតិត្ថករ (មេលទ្ធិ) គប្បីដឹងតិត្ថិយ (និង) គប្បីដឹងសាវករបស់តិត្ថិយ ។*

*ទិដ្ឋិ ៦២ ឈ្មោះថា តិត្ថៈ ។ បុគ្គលដែលធ្វើឲ្យកើតទិដ្ឋិ ៦២ ទាំងនោះ ឈ្មោះថា តិត្ថករ ។ បុគ្គលដែលពេញចិត្តក្នុងទិដ្ឋិ ៦២ ទាំងនោះ ឈ្មោះថា តិត្ថិយ ។ បុគ្គលដែលឲ្យបច្ច័យដល់តិត្ថិយទាំងនោះ ឈ្មោះថា សាវករបស់តិត្ថិយ ។*

### *អធិប្បាយស័ព្ទថា អាយតនៈ*

*បទថា **អាយតនំ** សេចក្តីថា ទីកើត ឈ្មោះថា **អាយតនៈ** (ដូច) ក្នុងប្រយោគនេះថា ដែនកម្ពោជៈ ជាទីកើតរបស់សេះទាំងឡាយ ទក្ខិណាបថជនបទជាទីកើតរបស់គោទាំងឡាយ ។*

ទីកន្លែងសមោសរ ឈ្មោះថា **អាយតនៈ** ដូចក្នុងប្រយោគនេះថា ក្នុងអាយតនៈ (សមោសរ) ដែលគួររីករាយ បក្សីទាំងឡាយ រមែងប្រើអាយតនៈនោះ ហ្វូងបក្សីដែលត្រូវការម្ហូប ក៏នាំគ្នាទៅ ហ្វូងបក្សីដែលត្រូវការផ្លែឈើ ក៏ស៊ីផ្លែឈើ ។

ហេតុ ឈ្មោះថា **អាយតនៈ** (ដូច) ក្នុងប្រយោគនេះថា ម្នាលភិក្ខុទាំងឡាយ **វិមុត្តាយតនៈ** (ហេតុនៃវិមុត្តិ) **៥ ប្រការនេះ** ។

អាយតនៈទាំងអស់នោះ (មានអត្ថ) ប្រើបានក្នុងទីនេះ ព្រោះថា មិច្ឆាទិដ្ឋិបុគ្គលទាំងអស់ កាលកើត ក៏កើតក្នុងឋានៈ ៣ នេះប៉ុណ្ណោះ សូម្បីកាលរួមចុះ រមែងរួមចុះ គឺ ប្រជុំចុះ ក្នុងឋានៈ ៣ នេះដូចគ្នា ។ ក៏កាលភាវៈនៃបុគ្គលទាំងនោះជាមិច្ឆាទិដ្ឋិ ហេតុទាំង ៣ នេះឯង ឈ្មោះថា អាយតនៈ ព្រោះន័យមានជាអាទិ៍ថា ជាទីកើតឡើង ការកើតទិដ្ឋិ សូម្បីព្រោះហេតុនោះ ទើបឈ្មោះថា **តិត្ថាយតនៈ** ។ មួយទៀត ឈ្មោះថា **តិត្ថាយតនៈ** ព្រោះអត្ថថា ជាអណ្ដូងកើតរបស់តិរ្ថិយទាំងឡាយ ដោយន័យនោះឯង ។

បទថា **សមនុយុញ្ជិមានានិ** (ត្រូវបណ្ឌិតសាកសួរ) បានដល់ ត្រូវបណ្ឌិតសួរយ៉ាងនេះថា ទិដ្ឋិទាំងនោះគឺអ្វី ។ បទថា **សមនុគ្គាហិយមានានិ** (ដេញដោល) សេចក្ដីថា ត្រូវសួរដោយល្អ យ៉ាងនេះថា ទិដ្ឋិទាំងនោះកើតឡើងព្រោះហេតុអ្វី ។

បទថា **សមនុភាសិយមានានិ** (ប្រដៅ) សេចក្ដីថា ត្រូវប្រដៅដោយល្អយ៉ាងនេះ ថា អ្នកទាំងឡាយចូរលះបង់ទិដ្ឋិដ៏លាមកទាំងនោះចេញ ។ មួយទៀត បទទាំង ៣ នេះ (**សមនុយុញ្ជិយមានានិ សមនុគ្គាហិយមានានិ សមនុភាសិយមានានិ**) ជាវេវចនៈនៃការសាកសួរ និងការដេញដោលនោះឯង ព្រោះហេតុនោះ លោកទើបពោលទុកក្នុងអដ្ឋកថាថា បទថា **សមនុយុញ្ជតិ** ក្ដី , បទថា **សមនុគ្គាហតិ** ក្ដី , បទថា **សមនុភាសតិ** ក្ដី នេះ ដូចគ្នា មានអត្ថតែម្យ៉ាង ស្មើគ្នា មានចំណែកស្មើគ្នា កើតពីវត្ថុនោះ (ដូចគ្នា) តែម្យ៉ាងដូចគ្នា ទុំះឯង ។

បទថា **បរម្បិ គន្ត្វា** (អាងដល់បរម្បរា) សេចក្ដីថា ដល់ការបន្តយ៉ាងណាមួយ ក្នុងបណ្ដាការបន្តទាំង ៣ នេះ គឺ **អាចរិយបរម្បរា** (ការបន្តពីអាចារ្យ) **លទ្ធិបរម្បរា** (ការបន្តពីលទ្ធិ) **អត្តភាវបរម្បរា** (ការបន្តពីអត្តភាព) ។

បទថា **អកិរិយាយ សណ្ឋហន្តិ** (ការឈរគ្រាញនៅក្នុងគោលអកិរិយា) គឺ តាំងនៅក្នុងឋានៈកំណត់ថា ជាអកិរិយទិដ្ឋិ ។

## បរម្បរា ៣ យ៉ាង

ក៏តិត្ថាយតនៈទាំងនេះ ដែលប្រព្រឹត្តទៅនៅយ៉ាងនេះ គឺ អាចារ្យរបស់យើងទាំងឡាយ ជាបុព្វេកតវាទី (ជាអ្នកមានវាទៈថា កម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុ) បាចារ្យ (អាចារ្យរបស់អាចារ្យ) របស់យើងទាំងឡាយ ជាបុព្វេ-

កតវាទី អាចរិយបាចារ្យ (បាចារ្យរបស់អាចារ្យ) របស់យើងទាំងឡាយ ជាបុព្វេ-កតវាទ ។ អាចារ្យរបស់យើងទាំងឡាយ ជាឥស្សរនិម្មានវាទី (ជាអ្នកមានវាទៈថា ការនិម្មិតរបស់ព្រះឥសូរជាហេតុ) បាចារ្យរបស់យើងទាំងឡាយ ជាឥស្សរ-និម្មានវាទី អាចរិយបាចារ្យរបស់យើងទាំងឡាយ ជាឥស្សរនិម្មានវាទី , អាចារ្យរបស់យើងទាំងឡាយ ជាអហេតុកបច្ចយវាទី (ជាអ្នកមានវាទៈថា មិនមានហេតុមិនមានបច្ច័យ) បាចារ្យរបស់យើងទាំងឡាយ ជាអហេតុកបច្ចយវាទី បាចារ្យនៃអាចារ្យរបស់យើងទាំងឡាយ ជាអហេតុកបច្ចយវាទី ឈ្មោះថា **ប្រព្រឹត្តទៅតាមការបន្តនៃអាចារ្យ** ។

តិត្ថាយតនៈដែលប្រព្រឹត្តទៅយ៉ាងនេះ គឺ អាចារ្យរបស់យើងទាំងឡាយជាបុព្វេកតលទ្ធិកបុគ្គល (បុគ្គលដែលមានលទ្ធិថា កម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុ) បាចារ្យរបស់យើងទាំងឡាយ ។ល។ បាចារ្យនៃអាចារ្យរបស់យើងទាំងឡាយ ជាអហេតុកបច្ចយលទ្ធិកបុគ្គល (បុគ្គលដែលមានលទ្ធិថា មិនមានហេតុមិនមានបច្ច័យ) ឈ្មោះថា **ប្រព្រឹត្តទៅតាមការបន្តនៃលទ្ធិ** ។

តិត្ថាយតនៈដែលប្រព្រឹត្តទៅយ៉ាងនេះ គឺ អត្តភាពរបស់អាចារ្យយើងទាំងឡាយ មានកម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុ អត្តភាពរបស់បាចារ្យយើងទាំងឡាយ ។ល។ អត្តភាពរបស់បាចារ្យនៃអាចារ្យរបស់យើងទាំងឡាយ មិនមាន

ហេតុ មិនមានបច្ច័យ ឈ្មោះថា **ប្រព្រឹត្តទៅតាមការបន្តនៃអត្តភាព** ។

ក៏តិត្ថាយតនៈទាំងនោះ រមែងដំណើរទៅសូម្បីទីបំផុតដ៏វែងឆ្ងាយយ៉ាងនេះ រមែងតាំងនៅក្នុងឋានៈកំណត់ថា ជាអកិរិយទិដ្ឋិទុំះឯង ។ អ្នកសាង ឬអ្នកឲ្យសាងរបស់មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ក៏មិនប្រាកដសូម្បីតែមួយនាក់ ។

## សត្វ-បុរស-បុគ្គល

បទថា **បុរិសបុគ្គលោ** (បុរសបុគ្គល) បានដល់ សត្វ ។ សេចក្ដីពិតកាលព្រះមានព្រះភាគត្រាស់ថា បុរសខ្លះ ត្រាស់ថា បុគ្គលខ្លះ ក៏ជាការត្រាស់ (សំដៅដល់) សត្វទុំះឯង ។ តែកថានេះចាត់ជាសម្មុតិកថា ។ បុគ្គលណាយល់បានយ៉ាងណា ក៏ត្រាស់ដល់បុគ្គលនោះយ៉ាងនោះ ។ បទថា **បដិសំវេទេតិ** (បានទទួល) សេចក្ដីថា រមែងទទួលសុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា ដែលកើតឡើងក្នុងសន្ដានរបស់ខ្លួន គឺ ធ្វើសុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនាដែលខ្លួនដឹងហើយ ឬរមែងសោយ ។

## អធិប្បាយ បុព្វេកតហេតុវាទៈ

បទថា **បុព្វេកតហេតុ** (ព្រោះកម្មធ្វើទុកក្នុងកាលមុនខ្លះជាហេតុ) បានដល់ ព្រោះកម្មដែលខ្លួនធ្វើទុកក្នុងជាតិមុនជាហេតុ អធិប្បាយថា បុគ្គលខ្លះបានទទួល (សុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា) ព្រោះកម្មដែលខ្លួនធ្វើទុក

ក្នុងជាតិមុនជាបច្ច័យប៉ុណ្ណោះ ។ ដោយបទថា **ព្រោះកម្មដែលធ្វើទុកក្នុងកាលមុនខ្លះជាហេតុ** នេះ មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយបដិសេធ កម្មវេទនា (វេទនាកើតពីកម្ម) និងកិរិយវេទនា (វេទនាកើតពីកិរិយា) ព្រមទទួលតែចំពោះវិបាកវេទនា (វេទនាដែលកើតពីវិបាក) តែម្យ៉ាងប៉ុណ្ណោះ ។

## ពោលអំពីរោគ ៨ យ៉ាងជាដើម

ព្រះមានព្រះភាគត្រាស់ រោគទុក ៨ យ៉ាងទាំងនេះ គឺ អាពាធមានប្រមាត់ (កម្រើក) ជាសមុដ្ឋាន ១ អាពាធមានស្លេស្មជាសមុដ្ឋាន ១ អាពាធមានខ្យល់ជាសមុដ្ឋាន ១ អាពាធដែលកើតចាកពីរោគប្រមាត់ រោគស្លេស្ម រោគខ្យល់មកប្រជុំគ្នា ១ អាពាធដែលកើតពីការផ្លាស់ប្តូររដូវ ១ អាពាធដែលកើតពីការរក្សា (រាងកាយ) មិនល្អ ១ អាពាធដែលកើតពីការព្យាយាម (ធ្វើឲ្យកើតឡើង) ១ អាពាធដែលកើតពីវិបាកកម្ម ១ ។ ក្នុងរោគទាំង ៨ យ៉ាងនោះ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធរោគ ៧ យ៉ាងខាងដើម ហើយព្រមទទួលចំពោះរោគប្រភេទទី ៨ ប៉ុណ្ណោះ ។

ក្នុងបណ្តាគំនរនៃកម្ម ៣ ប្រភេទ ដែលព្រះមានព្រះភាគត្រាស់ទុក គឺ ទិដ្ឋធម្មវេទនីយកម្ម (កម្មឲ្យផលក្នុងភពបច្ចុប្បន្ន) ១ ឧបបជ្ជវេទនីយកម្ម (កម្មឲ្យផលក្នុងភពបន្ទាប់) ១ អបរាបរិយាយវេទនីយកម្ម (កម្មឲ្យផលក្នុងភពតៗ ទៅ) ១

មិច្ឆាទិដ្ឋិកបុគ្គលបដិសេធកម្ម ២ ប្រភេទ (ខាងដើម) ព្រមទទួលតែចំពោះអបរាបរិយាយកម្មតែម្យ៉ាងប៉ុណ្ណោះ ។ សម្មាទិដ្ឋិក្នុងគំនរវិបាក ៣ ប្រភេទ ដែលព្រះមានព្រះភាគត្រាស់ទុក គឺ ទិដ្ឋធម្មវេទនីយវិបាក (វិបាករបស់កម្មដែលឲ្យផលក្នុងបច្ចុប្បន្ន) ១ ឧបបជ្ជវេទនីយវិបាក (វិបាករបស់កម្មដែលឲ្យផលក្នុងភពបន្ទាប់) ១ អបរាបរិយាយវេទនីយវិបាក (វិបាករបស់កម្មដែលឲ្យផលក្នុងភពតៗទៅ) ១ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធវិបាក ២ យ៉ាង (ខាងដើម) ព្រមទទួលចំពោះតែអបរាបរិយាយវិបាកតែម្យ៉ាងប៉ុណ្ណោះ ។

សម្មាទិដ្ឋិក្នុងកងចេតនា ៤ ប្រភេទ ដែលព្រះមានព្រះភាគត្រាស់ទុក គឺ កុសលចេតនា ១ អកុសលចេតនា ១ វិបាកចេតនា ១ កិរិយាចេតនា ១ មិច្ឆាទិដ្ឋិកបុគ្គលបដិសេធចេតនា ៣ ប្រភេទ ព្រមទទួលចំពោះវិបាកចេតនាតែម្យ៉ាងប៉ុណ្ណោះ ។

### អធិប្បាយឥស្សរនិម្មានហេតុ

បទថា **ឥស្សរនិម្មានហេតុ** (ព្រោះព្រះឥសូរសាងសួគ៌ជាហេតុ) បានដល់ព្រោះការនិម្មិតរបស់ព្រះឥសូរជាហេតុ ។ អធិប្បាយថា បុគ្គលខ្លះបានទទួលសុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា ក៏ព្រោះត្រូវព្រះឥសូរនិម្មិត ព្រោះថា មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ មានការត្រិះរិះដូច្នេះថា វេទនាទាំង ៣ នេះ បុគ្គល

ខ្លះ មិនអាចបានទទួល ព្រោះមានកម្មដែលខ្លួនធ្វើទុកក្នុងបច្ចុប្បន្នជាមូលខ្លះ ព្រោះការបង្គាប់ (របស់បុគ្គលដទៃ) ជាមូលខ្លះ ព្រោះកម្មដែលខ្លួនធ្វើទុកក្នុងជាតិមុនខ្លះ ព្រោះមិនមានហេតុមិនមានបច្ច័យ (គឺដោយចៃដន្យ) ខ្លះ តែបុគ្គលខ្លះបានទទួលវេទនាទាំងនេះបាន ព្រោះការនិម្មិតរបស់ព្រះឥស្សរជាហេតុតែម្យ៉ាង ។

ក៏មិច្ឆាទិដ្ឋិកបុគ្គលទាំងនេះ មានវាទៈយ៉ាងនេះ ទើបមិនព្រមទទួលភោគសម្បីប្រភេទណាមួយក្នុងបណ្តាភោគ ៨ យ៉ាង ដែលពោលទុកហើយក្នុងខាងដើម បដិសេធទាំងអស់ និងមិនព្រមទទួលកម្មប្រភេទណាមួយក្នុងបណ្តាកម្ម ៣ ប្រភេទ វិបាកប្រភេទណាមួយក្នុងបណ្តាវិបាក ៣ ប្រភេទ និងចេតនាប្រភេទណាមួយក្នុងបណ្តាចេតនា ៤ ប្រភេទ ដែលពោលទុកក្នុងផ្នែកខាងដើម គឺ បដិសេធទាំងអស់ ។

## អធិប្បាយ អហេតុអបច្ចយា

បទថា **អហេតុអបច្ចយា** (មិនមានហេតុមិនមានបច្ច័យ) បានដល់ វៀរចាកហេតុ និងបច្ច័យ ។ អធិប្បាយថា បុរសបុគ្គលខ្លះបានទទួលសុខវេទនា ទុក្ខវេទនា ឬអទុក្ខមសុខវេទនា ដោយមិនមានហេតុឡើយ ព្រោះថា មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ មានការត្រិះរិះដូច្នេះថា វេទនាទាំង ៣ នេះ នរណាៗ មិនអាចនឹងបានទទួលព្រោះកម្មដែលខ្លួនធ្វើទុកក្នុងបច្ចុប្បន្ន ជាមូលខ្លះ ព្រោះការបង្គាប់បញ្ជា (ពី

អ្នកដទៃ) ជាមូលខ្លះ ព្រោះកម្មដែលធ្វើទុកក្នុងជាតិមុនខ្លះ ព្រោះការនិម្មិតរបស់ព្រះឥសូរជាហេតុខ្លះ បុរសបុគ្គលសោយវេទនាទាំងនេះ ដោយមិនមានហេតុមិនមានបច្ច័យ ។ ក៏មិច្ឆាទិដ្ឋិកបុគ្គលទាំងនេះ មានវាទៈយ៉ាងនេះ ទើបមិនព្រមទទួលហេតុទាំងឡាយដែលពោលទុកហើយក្នុងខាងដើម មានរោគជាដើម សូម្បីត្រឹមតែម្យ៉ាង គឺ បដិសេធទាំងអស់ ។

## ព្រះសម្ពុទ្ធទ្រង់ឲ្យព្រាហ្មណ៍បញ្ឆោក់ពីលទ្ធិ

ព្រះសាស្ដា លុះទ្រង់តាំងមាតិកាទុកយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងចែកមាតិកានោះ ទើបត្រាស់បទថា **តត្រ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយក្នុងសមណព្រាហ្មណ៍ ៣ ពួកនោះ) ជាដើម ។ បណ្ដាបទទាំងនោះ ដោយបទថា **ឯវំ វទាមិ** (តថាគតចូលទៅសួរ...យ៉ាងនេះ) ព្រះមានព្រះភាគទ្រង់សម្ដែងថា តថាគតពោលយ៉ាងនេះ ដើម្បីឲ្យសមណព្រាហ្មណ៍ពួកនោះបញ្ឆោក់ពីលទ្ធិ ។ ក៏គេមិនបញ្ឆោក់ពីលទ្ធិបាន គេចកែលទ្ធិ ពីលទ្ធិដែលទ្រង់គ្របសង្កត់ ពោលពាក្យជាដើមថា ព្រះគោតមដ៏ចម្រើន ពួកខ្ញុំព្រះអង្គពោលវាទៈថាមាន ព្រោះកម្មដែលធ្វើទុកក្នុងកាលមុនឬ ។ តែកាលពួកគេបញ្ឆោក់ពីលទ្ធិហើយ មិនបានគេចកែ ក៏នឹងជាអ្នកគ្របសង្កត់បានងាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា តថាគតពោលយ៉ាងនេះ ដើម្បីឲ្យពួកគេបញ្ឆោក់ពីលទ្ធិរបស់ពួកគេ ដូច្នេះ ។

បទថា **តេនហាយស្មន្តោ** កាត់បទជា **តេនហិ អាយស្មន្តោ** ។ មានពាក្យអធិប្បាយយ៉ាងណា ។ មានពាក្យអធិប្បាយថា បើប្រការនោះពិត ដូច្នោះ តាមវាទៈរបស់អ្នកទាំងឡាយនោះ ។ បទថា **បាណាតិបាតិនោ ភវិស្សន្តិ បុព្វេកតហេតុ** (បុរសបុគ្គលជាអ្នកសម្លាប់សត្វ ក៏ព្រោះកម្មដែលធ្វើទុកក្នុងកាលមុន) សេចក្តីថា បុរសបុគ្គលពួកណាមួយសម្លាប់សត្វក្នុងលោក បុរសបុគ្គលទាំងនោះជាអ្នកសម្លាប់សត្វ ព្រោះកម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុ ។ ព្រោះហេតុអ្វី ។ ព្រោះអ្នកទាំងឡាយមានលទ្ធិដូច្នេះថា គេអាចបានទទួលកម្ម គឺ បាណាតិបាត ព្រោះកម្មដែលខ្លួនធ្វើទុកជាមូលក៏មិនមែន ព្រោះការបង្គាប់ (របស់អ្នកដទៃ) ជាមូលក៏មិនមែន ព្រោះការនិម្មិតរបស់ព្រះឥស្សរជាហេតុក៏មិនមែន ព្រោះមិនមានហេតុមិនមានបច្ច័យក៏មិនមែន គេបានទទួល ព្រោះកម្មដែលធ្វើទុកក្នុងភពមុនជាហេតុប៉ុណ្ណោះ ។ ក៏បុគ្គលជាអ្នកសម្លាប់សត្វ ដោយអាការណា សូម្បីកាលវៀរចាកបាណាតិបាត ក៏នឹងវៀរចាកដោយអាការនោះ គឺ ព្រោះកម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុដូចគ្នា ។ ព្រះមានព្រះភាគទ្រង់ចាប់លទ្ធិរបស់មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះឯងបានហើយ ទើបទ្រង់គ្របសង្កត់មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ដោយប្រការដូចពណ៌នាមក ដូច្នេះ ។ គប្បីជ្រាបពាក្យអធិប្បាយ សូម្បីក្នុងបទថា **លួចទ្រព្យ** ជាដើម ដោយន័យនេះ ។

បទថា **សារតោ បច្ចាគច្ឆតំ** (កាលកាន់យកបុព្វកម្មមកជាសារៈ) បាន ដល់ ប្រកាន់ថាជាសារៈ ។ បទថា **ឆន្ទោ** (ឆន្ទៈ) បានដល់ កត្តុកម្យតាឆន្ទៈ (សេចក្តីពេញចិត្ត គឺ ភាពជាអ្នកប្រាថ្នានឹងធ្វើ) ។ ក្នុងបទថា **ឥទំ វា ករណីយំ ឥទំ វា អករណីយំ** (វត្ថុនេះគួរធ្វើ ឬវត្ថុនេះមិនគួរធ្វើ) នេះ មានអធិប្បាយដូច្នេះ ថា មិនមានភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ឬសេចក្តីអត់ធន់របស់បុរសចំពោះខ្លួន ដើម្បីត្រូវការធ្វើវត្ថុដែលគួរធ្វើ ដោយគិតថា វត្ថុនេះគួរធ្វើ ឬដើម្បីមិនត្រូវការ ធ្វើវត្ថុដែលមិនគួរធ្វើ ដោយគិតថា វត្ថុនេះមិនគួរធ្វើ ។ ម្យ៉ាងទៀត កាលឆន្ទៈ និងវាយាមៈមិនមាន ក៏មិនមានសេចក្តីគិតថា វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ ។ បទថា **ឥតិ ករណីយាករណី ខោ បន សច្ចតោ ថេតតោ អនុបលព្ភិយមានេ** (កាលគេមិនបានវត្ថុដែលគួរធ្វើ និងវត្ថុដែលមិនគួរធ្វើ ដោយពិត ដោយមាំមួន ដូច្នេះ) សេចក្តីថា កាលវត្ថុដែលគួរធ្វើ និងមិនគួរធ្វើ មិនប្រាកដ គឺ មិនបាន ដោយពិត ជារបស់ប្រាកដយ៉ាងនេះ ។ ប្រសិនបើបុគ្គលនឹងគប្បីបានធ្វើវត្ថុដែល គួរធ្វើ នឹងគប្បីបានវៀរចាកវត្ថុដែលមិនគួរធ្វើសោត វត្ថុដែលគួរធ្វើ និងមិនគួរធ្វើ គេក៏នឹងគប្បីបានដោយពិត ដោយប្រាកដ តែព្រោះហេតុដែលមិនបានទាំង ២ យ៉ាង យ៉ាងនេះ ដូច្នោះ កិច្ចដែលគួរធ្វើ និងមិនគួរធ្វើនោះ គេទើបមិនបាន ដោយពិត ដោយប្រាកដ គឺថា មិនបានវត្ថុដែលគួរធ្វើ និងមិនគួរធ្វើនោះ ដោយ

អាការយ៉ាងនេះ ។

បទថា **មុដ្ឋស្សតីនំ** (ភាន់កាំងសតិ) បានដល់ បុគ្គលមិនមានសតិ គឺបណ្តោយសតិទៅ ។ បទថា **អនារក្ខានំ វិហរតំ** (មិនមានការរក្សា) បានដល់ប្រាសចាកការរក្សា (ក្នុងទ្វារទាំង ៦) ។ បទថា **ន ហោតិ បច្ចត្តំ សហធម្មិកោ សមណវាទោ** (សមណវាទដែលត្រូវតាមហេតុ ដែលជាវាទៈចំពោះខ្លួន) សេចក្តីថា សមណវាទដែលត្រូវតាមហេតុ ដែលជាវាទៈចំពោះខ្លួនថា យើងទាំងឡាយជាសមណៈ រមែងមិនមាន គឺ មិនសម្រេច ដល់លោកទាំងឡាយ ឬបុគ្គលពួកដទៃ ដែលមានសភាពយ៉ាងនេះ ព្រោះថា សូម្បីសមណៈទាំងឡាយ ក៏ជាបុគ្គលមានកម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុដូចគ្នា សូម្បីអ្នកមិនមែនសមណៈ ក៏ជាអ្នកមានកម្មដែលធ្វើទុកក្នុងជាតិមុនជាហេតុដូចគ្នានោះឯង ។ បទថា **សហធម្មិកោ** (ដែលត្រូវតាមហេតុ) បានដល់ ព្រមទាំងហេតុ ។ បទថា **និគ្គហោ ហោតិ** (ជាវាទៈសម្រាប់គ្របសង្កត់) បានដល់ ការគ្របសង្កត់របស់តថាគត មានហើយ ។ ក៏មិច្ឆាទិដ្ឋិកបុគ្គលទាំងនោះ ត្រូវគ្របសង្កត់ហើយនោះឯង ។ លុះទ្រង់គ្របសង្កត់បុព្វេកតវាទីបុគ្គលយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់គ្របសង្កត់ឥស្សរនិម្មានវាទីបុគ្គល ទើបត្រាស់បទថា **ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ** ជាដើម ។ អត្ថនៃបទនោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុង

បុព្វេកតវាទៈ ក្នុងអហេតុកវាទៈក៏ដូចគ្នា ។

## ទន្សាយផ្អើល

ព្រះមានព្រះភាគ លុះទ្រង់សម្តែងដល់លទ្ធិតិរ្ថិយទាំងនេះ ជាលទ្ធិសូន្យចាកប្រយោជន៍យ៉ាងនេះ ព្រោះសូម្បីមានការបន្តគ្នាមក តាំងនៅក្នុងឋានៈជាអកិរិយទិដ្ឋិក្តី ដែលលទ្ធិតិរ្ថិយទាំងនេះ មិនមានគុណធម៌ជាគ្រឿងនាំចេញចាកទុក្ខក្តី ដែលជាលទ្ធិតិរ្ថិយដូចជាបុកអង្កាម ព្រោះមិនមានខ្លឹមសារក្តី ដែលជាលទ្ធិតិរ្ថិយដូចជាអំពិលអំពែករបស់បុគ្គលដែលផ្ទុំដោយសម្គាល់ថាជាភ្លើង ព្រោះការប្រសព្វក្តី ដែលបុគ្គលជឿក្នុងលទ្ធិតិរ្ថិយនោះ មានឧបមាដូចជាឥតម្បាញខ្វាក់ភ្នែក ព្រោះមើលមិនឃើញសារៈរបស់លទ្ធិតិរ្ថិយ ទាំងខាងដើម ទាំងកណ្តាល ទាំងខាងចុងក្តី ដែលបុគ្គលអ្នកជឿលទ្ធិតិរ្ថិយទាំងនោះ ដោយហេតុត្រឹមតែសំឡេងប៉ុណ្ណោះ ហើយមានការឃើញថាជាសារៈ មានសភាពដូចជាទន្សាយដែលបានឮសំឡេងគួរខ្លាចរបស់ផ្លែត្នោតទុំ ដែលជ្រុះលើផែនដី ហើយរត់គេច ដោយសម្គាល់ថាផែនដីស្រុតក្តី ឥឡូវនេះ កាលទ្រង់នឹងសម្តែងសេចក្តីនៃធម៌ ដែលព្រះអង្គសម្តែងជាធម៌មានខ្លឹមសារ និងជាធម៌ជាគ្រឿងនាំចេញចាកទុក្ខ ទើបត្រាស់បទថា **ម្នាលភិក្ខុទាំងឡាយ ចំណែកធម៌ដែលតថាគតសម្តែងនេះ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អនិគ្គហិតោ** (នរណាៗ គ្របសង្កត់មិនបាន)

គឺ មិនត្រូវបុគ្គលដទៃគ្របសង្កត់ បានដល់ មិនមាននរណាអាចគ្របសង្កត់បាន ។ បទថា **អសង្កិលិដ្ឋោ** (ជាធម៌មិនសៅហ្មង) បានដល់ ជាធម៌មិនសៅហ្មងតែ គឺ បរិសុទ្ធិ ដែលបុគ្គលសូម្បីគិតថា នឹងធ្វើធម៌នោះឲ្យសៅហ្មង ហើយប្រព្រឹត្ត ក៏មិនអាចនឹងធ្វើឲ្យជាយ៉ាងនោះបាន ។ បទថា **អនូបវជ្ជោ** (អ្នកប្រាជ្ញតិះដៀលមិនបាន) បានដល់ ផុតចាកការត្រូវប្រទូស្ត ។ បទថា **អប្បដិកុដ្ឋោ** (អ្នកប្រាជ្ញស្អប់ខ្ពើមមិនបាន) សេចក្តីថា មិនត្រូវបដិសេធ ឬមិនត្រូវជំទាស់យ៉ាងនេះថា ប្រយោជន៍អ្វីដោយធម៌នេះ លោកទាំងឡាយចូរនាំធម៌នោះចេញទៅ ។ បទថា **វិញ្ញូហិ** (អ្នកប្រាជ្ញ) បានដល់ បណ្ឌិតទាំងឡាយ ។ ព្រោះពាក្យនិយាយរបស់បុគ្គលមិនមែនបណ្ឌិតមិនដឹងហើយនិយាយ មិនជាប្រមាណ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **អ្នកប្រាជ្ញ** ដូច្នេះ ។

ឥឡូវនេះ កាលទ្រង់សម្តែងធម៌នោះ ព្រះមានព្រះភាគទើបតាំងបញ្ហាសួរថា **ម្នាលភិក្ខុទាំងឡាយ ក៏...គឺអ្វី** ដូច្នេះ ហើយតាំងមាតិកាសង្ខេប ដោយន័យជាដើមថា **ធាតុទាំង ៦ នេះ** កាលទ្រង់សម្តែងចែកតាមលំដាប់ ទើបត្រាស់ពាក្យជាដើមថា **ធាតុទាំង ៦ នេះ** ទៀត ។

## អធិប្បាយធាតុ

បណ្តាបទទាំងនោះ បទថា **ធាតុយោ** (ធាតុ) បានដល់ សភាវៈទាំងឡាយ

មានន័យថា សភាវៈដែលប្រកាសដល់ភាពមិនមែនជីវៈ មិនមែនសត្វ ឈ្មោះថា អត្ថរបស់ធាតុ ។ បទថា **ផស្សាយតនានិ** (ផស្សាយតនៈ) បានដល់ ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាអណ្តូងកើតនៃវិបាកផស្សៈទាំងឡាយ ។ បទថា **មនោបវិចារា** (មនោបវិចារៈ) បានដល់ ការត្រាច់ទៅនៃចិត្ត ក្នុងឋានៈ ១៨ ដោយជើង គឺ វិតក្កៈ និងវិចារៈ ។

បទថា **បថវីធាតុ** បានដល់ ធាតុទីតាំងមាំ ។ បទថា **អាបោធាតុ** បានដល់ ធាតុធ្វើនាទីតភ្ជាប់ ។ បទថា **តេជោធាតុ** បានដល់ ធាតុធ្វើនាទីអប់កម្ដៅ ។ បទថា **វាយោធាតុ** បានដល់ ធាតុធ្វើនាទីឲ្យកម្រើកញ័រ ។ បទថា **អាកាសធាតុ** បានដល់ ធាតុដែលពាល់ត្រូវមិនបាន ។ បទថា **វិញ្ញាណធាតុ** បានដល់ ធាតុធ្វើនាទីដឹងច្បាស់ ។

## ធាតុកម្មដ្ឋាន

ធាតុកម្មដ្ឋាននេះ មកហើយយ៉ាងនេះ ។ ក៏កម្មដ្ឋាននេះ ក្នុងទីមកដោយសង្ខេប គួរពោលទាំងដោយសង្ខេប ទាំងដោយពិស្តារ តែក្នុងទីដែលមកដោយពិស្តារ នឹងពោលដោយសង្ខេបមិនគួរ គួរពោលដោយពិស្តារតែម្យ៉ាង ។ ចំណែកក្នុងតិត្ថាយតនសូត្រនេះ កម្មដ្ឋាននេះ មកហើយដោយអំណាចធាតុ ៦ ដោយសង្ខេប ។ នឹងពោលកម្មដ្ឋាននោះទាំងពីរយ៉ាង (ទាំងដោយសង្ខេប ទាំងដោយ

ពិស្តារ) ក៏គួរ ។

## កំណត់ដោយសង្ខេប

ព្រះយោគាវចរសូម្បីកាលកំណត់កម្មដ្ឋានដោយអំណាចធាតុ ៦ ដោយសង្ខេប ក៏រមែងកំណត់យ៉ាងនេះ ។ រូប ៤ ទាំងនេះ គឺ បថវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ចាត់ជាមហាភូតរូប អាកាសធាតុ ចាត់ជាឧបាទាយរូប ។ កាលឃើញឧបាទាយរូបប្រភេទមួយ ឧបាទាយរូប ២៣ ដ៏សេស គប្បីកំណត់ថាបាន ឃើញដូចគ្នា ។

បទថា **វិញ្ញាណធាតុ** បានដល់ ចិត្ត ។ ចិត្តនោះ បានដល់ វិញ្ញាណក្ខន្ធ វេទនាដែលកើតរួមជាមួយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា វេទនាខន្ធ សញ្ញាដែលកើតរួមជាមួយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា សញ្ញាខន្ធ ផស្សៈ និងចេតនាដែលកើតរួមជាមួយវិញ្ញាណក្ខន្ធនោះ ឈ្មោះថា សង្ខារក្ខន្ធ ខន្ធទាំង ៤ ដូចពោលមកនេះ ឈ្មោះថា អរូបក្ខន្ធ ។ មួយទៀត មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ឈ្មោះថា រូបក្ខន្ធ ។ បណ្តារូបក្ខន្ធ និងអរូបក្ខន្ធនោះ អរូបក្ខន្ធ ៤ ជានាម រូបក្ខន្ធ ជារូប ។ មានធម៌ ២ យ៉ាងប៉ុណ្ណោះ គឺ នាម ១ រូប ១ ។ មិនមែនសត្វ ឬជីវៈ ក្រៅពីធម៌ ២ យ៉ាងនោះ ។ គប្បីជ្រាបកម្មដ្ឋានដែលធ្វើឲ្យសម្រេចអរហត្តផលដោយអំណាចធាតុ ៦ ដោយសង្ខេបរបស់ភិក្ខុមួយរូប យ៉ាង

នេះ ។

## កំណត់ដោយពិស្តារ

ព្រះយោគាវចរ កាលនឹងកំណត់ដោយពិស្តារ កំណត់មហាភូតរូប ៤ ហើយ ទើបកំណត់ឧបាទាយរូប ២៣ តាមលំនាំនៃការកំណត់អាកាសធាតុ ។ ត មក កាលនឹងកំណត់បច្ច័យរបស់រូបទាំងនោះ ក៏ពិចារណាមើលមហាភូតរូប ៤ នុ៎ះឯងទៀត ហើយប្រមូលចុះជាកោដ្ឋាសៈ (ចំណែក) គឺ បណ្ដាមហាភូតរូប ៤ នោះ បឋវីធាតុមាន ២០ ចំណែក អាបោធាតុមាន ១២ ចំណែក តេជោធាតុ មាន ៤ ចំណែក វាយោធាតុមាន ៦ ចំណែក (រួមជា) កំណត់មហាភូតរូប ៤២ ចំណែក ។ បន្ថែមឧបាទាយរូប ២៣ (រួមជា) កំណត់រូប ៦៥ ព្រះយោគាវចរ ពិចារណាឃើញរូប ៦៥ ទាំងនោះ និងរួមវត្ថុរូបចូលផង ជារូប ៦៦ ។

ចំណែក វិញ្ញាណធាតុ បានដល់ ចិត្ត ៨១ ដោយជាលោកិយចិត្ត ចិត្ត ៨១ នោះ ឈ្មោះថា វិញ្ញាណក្ខន្ធ សូម្បីវេទនាជាដើមដែលកើតព្រមជាមួយចិត្ត ៨១ នោះ ក៏មានចំនួនប៉ុណ្ណោះដូចគ្នា រួមសេចក្ដីថា វេទនា ៨១ ឈ្មោះថា វេទនាខន្ធ សញ្ញា ៨១ ឈ្មោះថា សញ្ញាខន្ធ ចេតនា ៨១ ឈ្មោះថា សង្ខារខន្ធ រួមសេចក្ដីថា អរូបក្ខន្ធទាំង ៤ នេះ កាលកំណត់ដោយអំណាចធម៌ដែលប្រព្រឹត្ត ទៅក្នុងភូមិ ៣ ក៏បានដល់ ធម្មាយតនៈ ៣២៤ ។

## មិនមែនសត្វ ឬជីវៈ មានតែធម៌ ២

ធម៌ទាំងអស់ គឺ អរូបធម៌ទាំងនេះ និងរូបធម៌ ៦៦ ដូចពោលមកនេះ លុះប្រមូលមកហើយ ក៏មានធម៌ ២ យ៉ាង គឺ នាម ១ រូប ១ មិនមែនសត្វ ឬជីវៈ ក្រៅពីធម៌ ២ យ៉ាងនោះ ។

## កំណត់បច្ច័យរបស់នាម-រូប

ព្រះយោគាវចរគ្រាកំណត់បញ្ចក្ខន្ធ ជានាមរូប ដូចពោលមកនេះ កាលស្វែងរកបច្ច័យរបស់នាមរូបទាំងនោះ ក៏ឃើញបច្ច័យយ៉ាងនេះ គឺ ព្រោះមានអវិជ្ជាជាបច្ច័យ ព្រោះមានតណ្ហាជាបច្ច័យ ព្រោះមានកម្មជាបច្ច័យ ព្រោះមានអាហារជាបច្ច័យ ហើយធ្វើផុតសេចក្តីសង្ស័យក្នុងកាលទាំង ៣ បាន គឺ សូម្បីក្នុងអតីត នាមរូបនេះ ក៏ប្រព្រឹត្តទៅហើយដោយបច្ច័យទាំងនេះ សូម្បីក្នុងអនាគតក៏នឹងប្រព្រឹត្តទៅដោយបច្ច័យទាំងនេះ សូម្បីក្នុងបច្ចុប្បន្នក៏ប្រព្រឹត្តទៅហើយដោយបច្ច័យទាំងនេះដូចគ្នា កាលបដិបត្តិទៅតាមលំដាប់ រមែងសម្រេចអរហត្តផលបាន ។ គប្បីជ្រាបកម្មដ្ឋានដែលជាហេតុឲ្យសម្រេចអរហត្តផល ដោយអំណាចធាតុ ៦ សូម្បីដោយពិស្តារ ដូចពោលមកនេះ ។

## ផស្សាយតនៈ ៦

បទថា **ចក្ខុំ ផស្សាយតនំ** (ផស្សាយតនៈ គឺ ភ្នែក) សេចក្តីថា ចក្ខុ

ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាអណ្ដូងកើត ដោយអត្ថថា ជាសមុដ្ឋាន នៃផស្សៈ ៧ ដែលកើតព្រមជាមួយវិញ្ញាណ ៧ ទាំងនេះ គឺ ចក្ខុវិញ្ញាណ ២ សម្បដិច្ឆន្នវិញ្ញាណ ២ សន្តីរណវិញ្ញាណ ៣ ប្រៀបដូចមាសជាដើម ជាអណ្ដូងកើតរបស់មាសជាដើម ។ សូម្បីក្នុងបទថា **សោតំ ផស្សាយតនំ** (ផស្សាយតនៈ គឺ ត្រចៀក) ជាដើម ក៏មានន័យនេះឯង ។

ចំណែកក្នុងបទថា **មនោ ផស្សាយតនំ** (ផស្សាយតនៈ គឺ ចិត្ត) នេះ គប្បីជ្រាបថា បានដល់ វិបាកផស្សៈ ២២ កម្មដ្ឋាននេះ មកដោយអំណាចផស្សាយតនៈ ៦ ដូចពោលមកនេះ ។ កម្មដ្ឋាននោះ គួរពោលទាំងដោយសង្ខេបទាំងដោយពិស្ដារ ។ ពោលអំពីសង្ខេបមុន ក៏ក្នុងអាយតនៈ ៦ នេះ អាយតនៈ ៥ ប្រការដំបូង ឈ្មោះថា ឧបាទាយរូប កាលឃើញអាយតនៈ ៥ នោះហើយ ក៏ជាការឃើញឧបាទាយរូបដ៏សេសផង ។ អាយតនៈទី ៦ គឺ ចិត្ត ជាវិញ្ញាណក្ខន្ធ ។ ធម៌ ៣ ដ៏សេស មានវេទនាជាដើម ដែលកើតព្រមជាមួយវិញ្ញាណក្ខន្ធនោះ ជាអរូបក្ខន្ធ ។ គប្បីជ្រាបកម្មដ្ឋាន ដែលជាហេតុឲ្យសម្រេចអរហត្តផលទាំងដោយសង្ខេប ទាំងដោយពិស្ដារ តាមន័យដែលពោលហើយក្នុងខាងដើមនុ៎ះឯង ។

## មនោបវិចារ ១៨

បទថា **ចក្ខុនា រូបំ ទិស្វា** (ឃើញរូបដោយភ្នែក) សេចក្តីថា ឃើញរូបដោយចក្ខុវិញ្ញាណ ។ បទថា **សោមនស្សដ្ឋានិយំ** (ដែលជាទីតាំងនៃសោមនស្ស) បានដល់ ជាហេតុនៃសោមនស្ស ។ កិច្ចកាលញ៉ាំងចិត្តកម្រើក ឈ្មោះថា រមែងពិចារណា ក្នុងបទថា **ឧបវិចរតិ** នេះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ ក៏ក្នុងបទថា **ឃើញរូបដោយភ្នែក** នេះ គប្បីជ្រាបថា រូបដែលគួរប្រាថ្នា ឬមិនគួរប្រាថ្នាក៏ដោយ ឃើញរូបណាហើយ សោមនស្សកើតឡើង រូបនោះ ឈ្មោះថា ជាទីតាំងនៃសោមនស្ស ។ ឃើញរូបណាហើយ ទោមនស្សកើតឡើង រូបនោះ ឈ្មោះថា ជាទីតាំងនៃទោមនស្ស ។ ឃើញរូបណាហើយ ឧបេក្ខាកើតឡើង រូបនោះ ឈ្មោះថា ជាទីតាំងនៃឧបេក្ខា ។ សូម្បីក្នុងសំឡេងជាដើម ក៏មានន័យនេះឯង ។ កម្មដ្ឋាននេះមកហើយដោយសង្ខេប ដោយប្រការដូចពណ៌នាមកដូច្នេះ ។ ចំណែកកម្មដ្ឋាននោះ ក្នុងទីដែលមកហើយដោយសង្ខេប គួរពោលទាំងដោយសង្ខេប ទាំងដោយពិស្តារ ។ ក្នុងទីដែលមកហើយដោយពិស្តារ មិនគួរពោលដោយសង្ខេប ។ តែក្នុងតិត្ថាយសូត្រនេះ កម្មដ្ឋាននេះ មកហើយដោយអំណាចមនោបវិចារ ១៨ ដោយសង្ខេប ។ កម្មដ្ឋាននោះ គួរពោលទាំងដោយសង្ខេបទាំងដោយពិស្តារ ។

ក្នុងកម្មដ្ឋាននោះ ពោលអំពីសង្ខេបមុន រូប ៩ ទាំងនេះ គឺ ចក្ខុ សោតៈ

ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ជាឧបាទាយរូប កាលឃើញឧបាទាយរូបទាំង ៩ នោះហើយ ឧបាទាយរូបដ៏សេស ក៏ជាការឃើញដូចគ្នា ។ ផោដ្ឋព្វៈ គឺ មហាភូតរូប កាលឃើញមហាភូតរូបទាំង ៣ នោះហើយ មហាភូតរូបទី ៤ ក៏ជាការឃើញដូចគ្នា ។ មនោ ជាវិញ្ញាណក្ខន្ធ ។ ធម៌ទាំងឡាយមានវេទនាជាដើម ដែលកើតព្រមជាមួយវិញ្ញាណក្ខន្ធនោះ ជាអរូបក្ខន្ធ ។ គប្បីជ្រាបកម្មដ្ឋានដែលជាហេតុឲ្យសម្រេចអរហត្តផល ទាំងដោយសង្ខេប ទាំងដោយពិស្តារ តាមន័យដែលពោលហើយក្នុងខាងដើមទុំះឯង ។

បទថា **អរិយសច្ចានិ** (អរិយសច្ចៈ) បានដល់ សច្ចៈទាំងឡាយ ដែលធ្វើឲ្យជាអរិយៈ ឬដែលព្រះអរិយៈជាម្ចាស់ត្រាស់ដឹងហើយ ។ ក្នុងទីនេះមានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណេះ ។ តែកាលពោលដោយពិស្តារហើយ បទនេះបានប្រកាសទុកហើយក្នុងវិសុទ្ធិមគ្គ ។

## ធាតុ ៦

សួរថា បទថា **ឆន្នំ ភិក្ខវេ ធាតូនំ** (ម្នាលភិក្ខុទាំងឡាយ...ធាតុ ៦ នេះ) ព្រះមានព្រះភាគ ទ្រង់ប្រារព្ធដើម្បីអ្វី ។ ឆ្លើយថា ដើម្បីឲ្យអ្នកជទៃយល់បានងាយ ។ ពិតណាស់ ព្រះតថាគតបំណងនឹងត្រាស់បច្ចយវដ្តកៈ ១២ បទ ដល់បុគ្គលណា ក៏ទ្រង់សម្តែងវដ្តៈ គឺ ការឈានចុះកាន់គភ៌ដល់បុគ្គលនោះ ព្រោះថា

កាលទ្រង់សម្តែងវដ្តៈ គឺ ការឈានចុះកាន់គភ៌ហើយ ក៏ទ្រង់មានសេចក្តីងាយស្រួល ដែលនឹងត្រាស់ឯង ទាំងដែលនឹងទូន្មានអ្នកដទៃឲ្យដឹង ។ (ដូច្នោះ) ទើបគួរជ្រាបថា ព្រះមានព្រះភាគទ្រង់ផ្តើមបទនេះទុក ក៏ដើម្បីទូន្មានបុគ្គលដទៃឲ្យដឹងបានងាយ ។

បណ្តាបទទាំងនោះ បទថា **ឆន្នំ ធាតូនំ** (ធាតុ ៦) បានដល់ បឋវីធាតុជាដើម ដែលពោលហើយក្នុងខាងដើមនុ៎ះឯង ។ បទថា **ឧបាទាយ** គឺ **បដិច្ច** (អាស្រ័យ) ។ បទថា **អាស្រ័យ** នោះ ព្រះមានព្រះភាគទ្រង់សម្តែងត្រឹមតែបច្ច័យ ។ មានពាក្យអធិប្បាយដូច្នេះថា ការឈានចុះកាន់គភ៌មាតាមាន ព្រោះធាតុ ៦ ជាបច្ច័យ ។ ព្រោះធាតុ ៦ របស់សត្វអ្នកកើតក្នុងគភ៌នោះជាបច្ច័យ ។ សួរថា របស់មាតា ឬរបស់បិតា ។ ឆ្លើយថា មិនមែនរបស់មាតា មិនមែនរបស់បិតា ព្រោះធាតុ ៦ របស់សត្វដែលបដិសន្ធិនុ៎ះឯងជាបច្ច័យ ទើបមានការឈានចុះ (កាន់គភ៌មាតា) របស់សត្វអ្នកកើតក្នុងគភ៌ ។ ក៏ឈ្មោះថា គភ៌នេះ មានប្រការផ្សេងៗ គឺ គភ៌សត្វក្នុងនរក គភ៌ក្នុងសត្វតិរច្ឆាន គភ៌សត្វក្នុងបិត្តិវិស័យ គភ៌ក្នុងមនុស្ស គភ៌ក្នុងទេវតា ។ តែក្នុងទីនេះបំណងយកគភ៌ក្នុងមនុស្ស ។

បទថា **អវក្កន្តិ ហោតិ** (តាំងគភ៌) សេចក្តីថា មានការឈានចុះ គឺ ការកើត បានដល់ ការប្រាកដ ។ សួរថា មានដូចម្តេច ។ ឆ្លើយថា មានព្រោះការ

ប្រជុំព្រមនៃអង្គ ៣ ។ សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះការប្រជុំព្រមនៃអង្គ ៣ នេះឯង ទើបមានការតាំងគភ៌ ។

អង្គប្រកប ៣ ប្រការអ្វីខ្លះ ។

គឺ មាតាបិតាក្នុងលោកនេះនៅរួមគ្នា ១ មាតាមិនមែនស្ត្រីនៅក្នុងវ័យដែលមានរដូវ ១ គន្ធព្វសត្វមិនទាន់ប្រាកដ ១ ការតាំងគភ៌ក៏មិនមាន ។

មាតាបិតាក្នុងលោកនេះនៅរួមគ្នា និងមាតាជាស្ត្រីដែលនៅក្នុងវ័យមានមានរដូវ ប៉ុន្តែថា គន្ធព្វសត្វមិនទាន់ប្រាកដ (យ៉ាងនេះ) ការតាំងគភ៌ក៏មិនមាន ។

ម្នាលភិក្ខុទាំងឡាយ ក៏ប៉ុន្តែថា កាលណា មាតាបិតានៅរួមគ្នា ១ មាតាជាស្ត្រីដែលនៅក្នុងវ័យមានរដូវ ១ គន្ធព្វសត្វប្រាកដ ១ ព្រោះការប្រជុំព្រមនៃអង្គ ៣ ដូចពោលមកនេះ ការតាំងគភ៌ទើបមាន ។

បទថា **ឱក្កន្តិយា សតិ នាមរូបំ** (ការតាំងគភ៌មាន នាមរូបទើបមាន) សេចក្តីថា ក្នុងទីដែលត្រាស់ទុកថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ព្រះមានព្រះភាគទ្រង់បំណាងដល់ធម៌ ៣៣ ប្រការ គឺ វត្ថុទសកៈ កាយទសកៈ ភាវទកៈ (និង) អរូបក្ខន្ធ ៣ ។ តែក្នុងទីដែលត្រាស់ទុកថា កាលមានការឈានចុះ **នាមរូបទើបមាន** នេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សំដៅដល់ធម៌

៣៤ ប្រការ (ដែលកើត) ក្នុងខណៈបដិសន្ធិរបស់គព្ភសេយ្យកសត្វ ដោយទ្រង់បន្ថែមវិញ្ញាណក្ខន្ធចូលផង ។ សភាពនៃសឡាយតនៈប្រាកដ ក្នុងកាលមាននាមរូប , ផស្សៈប្រាកដ ក្នុងកាលមានសឡាយតនៈ , វេទនាប្រាកដ ក្នុងកាលមានផស្សៈ ព្រះមានព្រះភាគទ្រង់សម្ដែងទុកដោយបទទាំងឡាយមានជាអាទិ៍ថា **ព្រោះនាមរូបជាបច្ច័យ សឡាយតនៈទើបមាន** ដូចទ្រង់សម្ដែងសភាពនៃនាមរូបប្រាកដក្នុងកាលឈានចុះ (កាន់គភ៌មាតា) ដូច្នោះ ។

## សោយវេទនា

ក្នុងបទថា **វេទិយមានស្ស** (អ្នកសោយវេទនា) នេះ មានអធិប្បាយដូចតទៅនេះ ។ អ្នកសោយវេទនាក្តី អ្នកដឹងវេទនាក្តី ហៅថា អ្នកសោយ (នោះឯង) អធិប្បាយថា អ្នកកំពុងសោយ ឈ្មោះថា អ្នកសោយ (ដូច) ក្នុងប្រយោគនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំកំពុងសោយហើយ សូមសង្ឃចូរចាំខ្ញុំទុកថា កំពុងសោយហើយ ។ អ្នកដឹងខ្លួន ឈ្មោះថា អ្នកសោយ (ដូច) ក្នុងប្រយោគនេះថា បុគ្គលកាលសោយសុខវេទនា ក៏ដឹងច្បាស់ថា យើងកំពុងសោយសុខវេទនា ។ សូម្បីក្នុងទីនេះ ព្រះមានព្រះភាគក៏ទ្រង់បំណាងយកអ្នកដែលដឹងខ្លួននុ៎ះឯងថា អ្នកសោយ ។

បទថា **ឥទំ ទុក្ខន្តិ បញ្ញាបេមិ** (តថាគតប្រកាសថា នេះទុក្ខ) សេចក្តីថា

តថាគតសម្តែងថា នេះទុក្ខ ទុក្ខមានប៉ុណ្ណេះ មិនមានទុក្ខក្រៅអំពីនេះ ដល់សត្វអ្នកដឹងយ៉ាងនេះ គឺ ទូន្មានឲ្យគេដឹង បានដល់ ទូន្មានឲ្យគេបានជ្រាប ។ សូម្បីក្នុងបទថា **នេះទុក្ខសមុទយៈ** ជាដើម ក៏មានន័យនេះឯង ។ បណ្តាសច្ចៈ មានទុក្ខជាដើម ក្នុងសូត្រនោះ មានសន្និដ្ឋានកថាដូច្នេះ ក៏វៀរតណ្ហាចេញហើយ ខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **ទុក្ខ** ។ តណ្ហាក្នុងកាលមុន ដែលជាហេតុឲ្យកើតទុក្ខនោះឯង ឈ្មោះថា **ទុក្ខសមុទ័យ** ។ ការរលត់សច្ចៈទាំងពីរនោះដោយមិនកើតឡើងទៀត ឈ្មោះថា **ទុក្ខនិរោធ** ។ អរិយមគ្គមានអង្គ ៨ ឈ្មោះថា **ទុក្ខនិរោធគាមិនីបដិបទា** ។

## ត្រាស់បដិច្ចសមុប្បាទដល់នរណា

ព្រះមានព្រះភាគ សូម្បីកាលនឹងត្រាស់ថា កាលមានការឈានចុះ (កាន់គភ៌មាតា) នាមរូបទើបមាន ក៏ត្រាស់ដល់បុគ្គលអ្នកសោយហើយ អ្នកដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីនឹងត្រាស់ថា ព្រោះនាមរូបជាបច្ច័យ សឡាយតនៈទើបមាន ក៏ត្រាស់ដល់បុគ្គលអ្នកសោយហើយ អ្នកដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីកាលត្រាស់ថា ព្រោះសឡាយតនៈជាបច្ច័យ ផស្សៈទើបមាន ក៏ត្រាស់ដល់បុគ្គលអ្នកសោយហើយ បុគ្គលអ្នកដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីកាលនឹងត្រាស់ថា ព្រោះផស្សៈជាបច្ច័យ វេទនាទើបមាន ក៏ត្រាស់ដល់បុគ្គលដែលសោយហើយ

អ្នកដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីកាលទឹងត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏តថាគតសម្តែងថា នេះទុក្ខ ដល់បុគ្គលដែលសោយហើយ ក៏ត្រាស់ដល់បុគ្គលអ្នកសោយហើយ បុគ្គលដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីទឹងត្រាស់ថា តថាគតសម្តែងថា នេះទុក្ខសមុទ័យ ក៏ត្រាស់ដល់អ្នកសោយហើយ អ្នកដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីទឹងត្រាស់ថា យើងតថាគតសម្តែងថា នេះទុក្ខនិរោធ ក៏ត្រាស់ដល់អ្នកសោយហើយ អ្នកដឹងខ្លួនហើយប៉ុណ្ណោះ ។ សូម្បីទឹងត្រាស់ថា តថាគតសម្តែងថា នេះទុក្ខនិរោធគាមិនីបដិបទា ក៏ត្រាស់ដល់អ្នកសោយហើយ អ្នកដឹងខ្លួនហើយប៉ុណ្ណោះ ដោយប្រការដូចពណ៌នាមកនេះ ។

ឥឡូវនេះ កាលទឹងទ្រង់អធិប្បាយសច្ចៈទាំងនោះ ដែលត្រាស់តាមលំដាប់ឲ្យពិស្តារ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ច** ជាដើម ។ ទុក្ខទាំងអស់នោះ ក្នុងពាក្យនោះ ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) បានអធិប្បាយទុកយ៉ាងល្អិតល្អន់ហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ គប្បីជ្រាបតាមន័យដែលពោលទុកក្នុងវិសុទ្ធិមគ្គនោះចុះ ។ ចំណែកដែលប្លែកគ្នាមានដូចតទៅនេះ ។ បណ្តាអរិយសច្ចៈទាំងនោះ អរិយសច្ចៈ គឺ ទុក្ខសមុទ័យមកហើយយ៉ាងនេះ គឺ **យាយំ តណ្ហា បោនោព្ភវិកា** (សេចក្តីប្រាថ្នានេះ ធ្វើឲ្យមានកពទៀត) ក្នុងទីនេះ មកហើយដោយអំណាចបច្ចយាការថា **អវិជ្ជាបច្ចយា សង្ខារា**

(ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ) ជាដើម ។ ម្យ៉ាងទៀត បណ្តា អរិយ-សច្ចៈទាំងនោះ អរិយសច្ចៈ គឺ ទុក្ខនិរោធ មកហើយយ៉ាងនេះ គឺ **យោ តស្សា-យេវ តណ្ហាយ អសេសវិរាគនិរោធោ** (ការវិនាស រលត់ដោយមិនមានសេសសល់នៃតណ្ហានោះឯង) ក្នុងទីនេះ មកហើយដោយអំណាចការរលត់បច្ចយាការ គឺ **អវិជ្ជាយត្វេវ អសេសវិរាគនិរោធា** (ព្រោះអវិជ្ជាវិនាស រលត់មិនមានសេសសល់) ជាដើម ។ បណ្តាបទទាំងនោះ បទថា **អសេសវិរាគនិរោធា** (វិនាសរលត់មិនមានសេសសល់) សេចក្តីថា បទទាំង ២ នោះ (វិរាគៈ និងនិរោធៈ) ជាវេវចនៈគ្នានុ៎ះឯង ព្រោះវិនាសមិនមានសេសសល់ និងព្រោះរលត់មិនមានសេសសល់ (ដូចគ្នា) ។

បទថា **សង្ខារនិរោធោ** (សង្ខារទើបរលត់) បានដល់ សង្ខារទាំងឡាយរលត់ទៅ ដោយមិនកើតឡើងទៀត ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។ មួយទៀត កិលេសទាំងឡាយ មានអវិជ្ជាជាដើម មកដល់ឋានៈណា រមែងរលត់ទៅ ឋានៈនោះ កាលពោលដោយអត្ថ ក៏គឺ និព្វាន ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកហើយដោយបទទាំងនេះ ។ ពិតណាស់ និព្វាន ព្រះមានព្រះភាគត្រាស់ទុកដោយនាមថា ការរលត់ស្និទ្ធនៃធម៌ទាំងនោះ យ៉ាងនេះគឺ **អវិជ្ជានិរោធោ** (ការរលត់ស្និទ្ធនៃអវិជ្ជា) ខ្វះ **សង្ខារនិរោធោ** (ការរលត់ស្និទ្ធនៃសង្ខារ) ខ្វះ ។

បទថា **អសេសវិរាគនិរោធា** (ទាំងមូល) បានដល់ ទាំងអស់ ។ បទថា **ទុក្ខក្ខន្ធស្ស** គឺ គំនរនៃវដ្តទុក្ខ ។ បទថា **និរោធោ ហោតិ** (រលត់) គឺ មានការមិនប្រព្រឹត្តទៅ ។ ក្នុងបទថា **រលត់** នោះ គប្បីជ្រាបថា ព្រោះហេតុតែរលត់ស្និទ្ធនៃកិលេសទាំងឡាយ មានអវិជ្ជាជាដើម ហៅថា អាការដែលអស់ទៅនៃកិលេសទាំងឡាយ មានអវិជ្ជាជាដើមខ្លះថា អរហត្តផលខ្លះ និព្វានខ្លះ ដូច្នោះ ក្នុងទីនេះព្រះមានព្រះភាគទើបត្រាស់អរហត្តផលទុកក្នុងឋានៈ ១២ ដោយអំណាចការឃើញអាការដែលកិលេស មានអវិជ្ជាជាដើមអស់ទៅហើយ (និង) ត្រាស់និព្វានទុកក្នុងឋានៈ ១២ ដូចគ្នា ។

ក្នុងបទថា **ឥទំ វុច្ចតិ** (នេះ តថាគតហៅថា) នេះ មានអធិប្បាយថា បទថា **ឥទំ** (នេះ) ព្រះមានព្រះភាគត្រាស់សំដៅយកនិព្វានតែម្យ៉ាងក៏មិនមែន ។ បទថា **អដ្ឋង្គិកោ** (មានអង្គ ៨) សេចក្តីថា ឈ្មោះថា មគ្គដទៃផុតចាកអង្គ ៨ មិនមាន ។ ប្រៀបដូចជា កាលពោលថា តន្ត្រីប្រកបដោយអង្គ ៥ ក៏ជាការពោលថា តន្ត្រីមានត្រឹមតែអង្គ ៥ ប៉ុណ្ណោះ យ៉ាងណា សូម្បីក្នុងទីនេះ ក៏ដូច្នោះ គឺ កាលព្រះមានព្រះភាគត្រាស់ថា មគ្គប្រកបដោយអង្គ ៨ ក៏គប្បីជ្រាបថា គឺទ្រង់ត្រាស់ថា មគ្គមានអង្គ ៨ ប៉ុណ្ណោះ ។

បទថា **អនិគ្គហិតោ** (នរណាៗ គ្របសង្កត់មិនបាន) គឺ មិនត្រូវគ្រប

សង្កត់ ។ អធិប្បាយថា បុគ្គលកាលគ្របសង្កត់ធម៌ រមែងសម្តែងអរិយសច្ចៈ ចំនួនតិចខ្លះ ចំនួនច្រើនខ្លះ ផ្លាស់ប្តូរអរិយសច្ចៈនោះខ្លះ ។ ប្រការនោះៗ ដែលនរណាៗ មិនអាចនឹងសម្តែងអរិយសច្ចៈ ៤ ឲ្យតិចចុះយ៉ាងនេះ គឺ អរិយសច្ចៈទាំងនេះ មិនមែនមាន ៤ មានត្រឹមតែ ២ ឬ ៣ ប៉ុណ្ណោះខ្លះ មិនអាចនឹងសម្តែងបន្ថែមចំនួនឲ្យច្រើនឡើងយ៉ាងនេះ គឺ អរិយសច្ចៈមាន ៥ ឬអរិយសច្ចៈ ៦ ខ្លះ មិនអាចនឹងសម្តែងប្តូរថា ទាំងនេះមិនមែនអរិយសច្ចៈមិនមែន ៤ ផ្សេងអំពីនេះជាអរិយសច្ចៈ ៤ ។ ដូច្នោះ ធម៌នេះទើបឈ្មោះថា មិនត្រូវគ្របសង្កត់ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា តិត្ថាយតនសូត្រទី ១

# អដ្ឋកថា ភយសូត្រទី ២

## *“អមាតាបុត្តកភ័យ ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភយសូត្រទី ២ ដូចតទៅនេះ ៈ-*

[៦៤] *បទថា* **មាតាបុត្តិកានិ** *(អមាតាបុត្តិកៈ) សេចក្តីថា មាតា និងបុត្រ ឈ្មោះថា* **មាតាបុត្តៈ** *មាតា និងបុត្រ ឈ្មោះថា មិនមាន ព្រោះអាចដើម្បីការពារគ្នា (ជួយគ្នានឹងគ្នា) ក្នុងភ័យនោះ ហេតុនោះ ភ័យទាំងនេះ ទើបឈ្មោះថា មិនមានមាតា និងបុត្រ ។ បទថា* **យំ** *គឺ ក្នុងសម័យណា ។ បទថា* **តត្ថ មាតាបិ បុត្តំ ន បដិលភតិ** *(មាតារមែងព្រាត់ពីបុត្រខ្លះ ព្រោះអគ្គិភ័យនោះ) សេចក្តីថា កាលអគ្គិភ័យនោះកើតឡើងហើយ សូម្បីមាតាក៏មិនបានឃើញបុត្រ សូម្បីបុត្រក៏មិនបានឃើញមាតា ។*

*បទថា* **ភយំ ហោតិ** *(កើតភ័យ) សេចក្តីថា មានភ័យ គឺ សេចក្តីភ័យខ្លាចនៃចិត្ត ។ បទថា* **អដវីសង្កោបោ** *(ចោរព្រៃកម្រើក) បានដល់ ការកម្រើករបស់ចោរដែលលាក់ខ្លួននៅក្នុងព្រៃ ។ ក៏ក្នុងបទថា* **អដវី** *(ព្រៃ) នេះ គប្បីជ្រាបថា បានដល់ ចោរដែលលាក់ខ្លួននៅក្នុងព្រៃ ។ អធិប្បាយថា កាលណាចោរទាំងនោះ ចេញពីព្រៃចូលកាន់ជនបទ ដើរប្លន់ ទម្លាយគាម និគម និងរាជធានី កាលនោះ ឈ្មោះថា មានការកម្រើករបស់ចោរដែលនៅក្នុងព្រៃ ។ ព្រះមានព្រះភាគ*

ទ្រង់សំដៅដល់ការកម្រើករបស់ចោរដែលនៅក្នុងព្រៃនោះ ទើបត្រាស់ពាក្យនេះ ថា **ចោរកម្រើក** ។

## មនុស្សឡើងកាន់ចក្ររត់គេច

បទថា **ចក្កសមារុឡ្ហា** (ឡើងកាន់ចក្រ) នេះ មានអធិប្បាយថា ទាំងចក្រ គឺ ឥរិយាបថ ទាំងចក្រ គឺ យាន ។ ព្រោះថា កាលភ័យមកដល់ បុគ្គលពួកណាមានយាន បុគ្គលទាំងនោះ ក៏លើករបស់របរបស់ខ្លួនឡើងយានពាហនៈទាំងនោះ ហើយដេញគេចចេញទៅ បុគ្គលពួកណាមិនមាន បុគ្គលទាំងនោះក៏ប្រើអម្រែក ឬប្រើក្បាលទូលគេចចេញទៅដរាបបាន ។ បុគ្គលទាំងនោះ ឈ្មោះថា ឡើងកាន់ចក្រ (យានពាហនៈ) ។ បទថា **បរិយាយន្តិ** (ខ្ចាត់ខ្ចាយទៅ) បានដល់ ទៅខាងឯណេះ ខាងឯណោះ ។

បទថា **កទាចិ** គឺ ក្នុងកាលខ្លះនុ៎ះឯង ។ បទថា **ករហចិ** ជាវេវចនៈរបស់បទថា **កទាចិ** នុ៎ះឯង ។ បទថា **មាតាបិ បុត្តំ បដិលភតិ** (មាតាត្រឡប់មកបុត្រខ្លះ) សេចក្តីថា (សូម្បីមាតា) រមែងបានឃើញបុត្រដែលមកហើយ ដែលទៅហើយ ឬដែលពួនគេចហើយ ក្នុងទឹកទន្លេមួយ ។ បទថា **ឧទកវាហកោ** គឺ ពេញទន្លេ ។ បទថា **មាតាបិ បុត្តំ បដិលភតិ** (មាតាត្រឡប់មកជួបបុត្រខ្លះ) សេចក្តីថា បុត្រអណ្តែតតាមទឹកមកជាប់នៅលើពោង ឬផែ ឬក្នុងភាជនៈដី ឬលើ

កំណាត់ឈើ មាតាក៏បានឃើញ ។ ឬថា មាតាបានឃើញបុត្រហែលឆ្លងទៅ បាន រួចផុតភ័យហើយ ឈរក្នុងស្រុក ឬក្នុងព្រៃ ។

## ភ័យ ៣ យ៉ាង

ព្រះមានព្រះភាគលុះទ្រង់សម្ដែងភ័យដែលមាតា និងបុត្រមិនបានជួបគ្នា ដែលទ្រង់បំណាង មកដោយអមយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែង ភ័យដោយត្រង់ ទើបត្រាស់បទថា **៣ យ៉ាងនេះ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ជរាភយំ** (ជរាភ័យ) បានដល់ ភ័យដែលអាស្រ័យជរាកើតឡើង ។ សូម្បី ក្នុងភ័យ ២ យ៉ាងក្រៅពីនេះ ក៏មានន័យនេះឯង ។ សមដូចដែលព្រះមានព្រះ-ភាគត្រាស់ទុកដូច្នេះថា ភ័យ វត្ថុដែលគួរខ្លាច សេចក្ដីភ័យព្រួយ អាការព្រឺរោម សេចក្ដីតក់ស្លុតនៃចិត្ត រមែងកើតឡើងព្រោះអាស្រ័យជរា... ព្រោះអាស្រ័យ ព្យាធិ ។ ភ័យ វត្ថុដែលគួរខ្លាច សេចក្ដីភ័យព្រួយ ការព្រឺរោម សេចក្ដីតក់ស្លុត នៃចិត្ត រមែងកើតឡើងព្រោះអាស្រ័យមរណៈ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងនោះឯង ។

ចប់អដ្ឋកថា ភយសូត្រទី ២

# អដ្ឋកថា វេនាគសូត្រទី ៣

## *“ព្រះពុទ្ធបាននូវទីអង្គុយទីដេកដ៏ប្រសើរ ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វេនាគសូត្រទី ៣ ដូចតទៅនេះ ៈ-*

*ចារិកមាន ២ យ៉ាង*

[៦៥] *បទថា* ***កោសលេសុ*** *(កោសល) បានដល់ ក្នុងជនបទដែលមានឈ្មោះយ៉ាងនោះ ។ បទថា* ***ចារិកំ ចរមានោ*** *(ស្តេចចារិក) បានដល់ (ព្រះមានព្រះភាគ) ស្តេចពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយ ។ ធម្មតាថា ការចារិករបស់ព្រះមានព្រះភាគមាន ២ យ៉ាង គឺ* ***ស្តេចចារិកប្រញាប់*** *១* ***ស្តេចចារិកមិនប្រញាប់*** *១ ។ បណ្តាចារិក ២ យ៉ាងនោះ ការដែលព្រះមានព្រះភាគទ្រង់ឃើញបុគ្គលដែលគួរណែនាំឲ្យដឹងបាន សូម្បីនៅក្នុងទីឆ្ងាយ ស្តេចប្រញាប់ទៅដើម្បីប្រយោជន៍ក្នុងការទូន្មានបុគ្គលនោះឲ្យដឹង ឈ្មោះថា* ***ស្តេចចារិកប្រញាប់*** *។ ស្តេចចារិកប្រញាប់នោះ គប្បីឃើញក្នុងវេលាដែលស្តេចទៅទទួលព្រះមហាកស្សបៈ ជាដើម ។ ឯការដែលព្រះមានព្រះភាគ កាលនឹងទ្រង់អនុគ្រោះលោកដោយពុទ្ធកិច្ច មានការត្រាច់បិណ្ឌបាតជាដើម ស្តេចយាងទៅតាមលំដាប់ស្រុក មួយថ្ងៃ ១ យោជន៍ ២ យោជន៍ ឈ្មោះថា* ***ស្តេចចារិកមិនប្រញាប់*** *។ លោកសំដៅយក ស្តេចចារិកមិនប្រញាប់នេះ ទើបត្រាស់ពាក្យនេះថា* ***ស្តេចចារិក*** *។ ក៏កថាពោលដោយស្តេចចារិក*

បានពោលទុកហើយដោយពិស្តារ ក្នុងអម្ពដ្ឋសុត្តវណ្ណនាអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ។

## ស្រុកព្រាហ្មណ៍

បទថា **ព្រាហ្មណគាមោ** (ស្រុកព្រាហ្មណ៍) សេចក្តីថា ស្រុកព្រាហ្មណ៍ជាប្រជុំរបស់ព្រាហ្មណ៍ទាំងឡាយក្តី ស្រុកដែលព្រាហ្មណ៍ទាំងឡាយគ្រប់គ្រងក្តី ហៅថា ស្រុកដែលព្រាហ្មណ៍ (នោះឯង) ។ ក្នុងទីនេះ ស្រុកជាទីជុំនុំរបស់ពួកព្រាហ្មណ៍ លោកបំណងយកថា ជាស្រុកព្រាហ្មណ៍ ។ បទថា **តទវសរិ** (ស្តេចដល់ស្រុកព្រាហ្មណ៍...នោះ) គឺ ស្តេចទៅក្នុងស្រុកព្រាហ្មណ៍នោះ អធិប្បាយថា ស្តេចដល់ហើយ ។ ចំណែកការប្រថាប់នៅ មិនបានកំណត់ទុកក្នុងទីនេះ ។ ហេតុនោះទើបគួរជ្រាបថា ក្នុងទីមិនឆ្ងាយពីស្រុកព្រាហ្មណ៍នោះ មានព្រៃស្រោងមួយកន្លែងដែលសមគួរដល់ព្រះពុទ្ធទាំងឡាយ ព្រះសាស្តាស្តេចទៅកាន់ព្រៃស្រោងនោះ ។

បទថា **អស្សោសុំ** (បានស្តាប់) សេចក្តីថា (ព្រាហ្មណ៍គហបតីទាំងឡាយ) ស្តាប់ គឺ ចូលចិត្ត បានដល់ ជ្រាបតាមក្រសែសំឡេងដែលថ្លែងចេញជាពាក្យនិយាយដល់សោតទ្វារ ។ សព្ទថា **ខោ** ជានិបាត ប្រើក្នុងអត្ថនៃអវធារណៈ (ហាមសេចក្តីដទៃ) ឬក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ ។ បណ្តាអត្ថ ២ យ៉ាងនោះ ដោយអត្ថនៃអវធារណៈ គប្បីជ្រាបសេចក្តីដូច្នេះថា ព្រាហ្មណ៍គហបតីទាំងឡាយ

បានឮតែម្តង ព្រាហ្មណ៍គហបតីទាំងនោះ មិនមានអន្តរាយក្នុងការស្តាប់អ្វីឡើយ ។ និងក្នុងការធ្វើបទឲ្យពេញ (បទបូរណៈ) គប្បីជ្រាបថា ជាសេចក្តីស្អាតនៃព្យញ្ជនៈប៉ុណ្ណោះ ។

## អត្ថរបស់សមណៈ

ឥឡូវនេះ ដើម្បីនឹងប្រកាសសេចក្តីដែលព្រាហ្មណ៍គហបតីទាំងឡាយបានស្តាប់ហើយ ព្រះសង្គីតិកាចារ្យទើបពោលបទថា **សមណោ ខលុ ភោ គោតមោ** ជាដើម ។ ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្តីថា បុគ្គលឈ្មោះថា ជាសមណៈ ព្រោះមានបាបដែលស្ងប់ហើយ ។ ស័ព្ទថា **ខលុ** ជានិបាត ប្រើក្នុងអត្ថថា បានស្តាប់តៗ មក ។ បទថា **ភោ** ជាពាក្យដែលព្រាហ្មណ៍គហបតីទាំងនោះស្រែកហៅគ្នា ។ បទថា **គោតមោ** ជាបទសម្តែងដល់ព្រះមានព្រះភាគ ដោយអំណាចគោត្រ ។ ហេតុនោះក្នុងបទថា **សមណោ ខលុ ភោ គោតមោ** នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា លោកដ៏ចម្រើន បានឮថា ព្រះសមណៈ ជាគោតមគោត្រ ។ ចំណែកបទថា **សក្យបុត្តោ** (ជាសក្យឱរស) នេះ ជាបទសម្តែងដល់ត្រកូលដែលខ្ពង់ខ្ពស់របស់ព្រះមានព្រះភាគ ។ បទថា **សក្យកុលា បព្វជិតោ** (ទ្រង់បួសចេញចាកសក្យៈត្រកូល) ជាបទសម្តែងថា ព្រះមានព្រះភាគទ្រង់ព្រះផ្នួសដោយសទ្ធា ។ មានពាក្យអធិប្បាយថា ព្រះមានព្រះភាគមិនត្រូវសេចក្តីសាបសូន្យអ្វីឡើយគ្រប-

សន្តក ទ្រង់លះត្រកូលនោះដែលនៅមិនសាបសូន្យ ទ្រង់ព្រះផ្នួសដោយសទ្ធា ។

បទថា **តំ ខោ បន** ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថប្រាប់ថា ជាយ៉ាងនេះ ។ អធិប្បាយថា ក៏របស់ព្រះគោតមដ៏ចម្រើននោះឯង ។ បទថា **កល្យាណោ** (ល្អ) បានដល់ ប្រកបដោយគុណដែលល្អ មានពាក្យអធិប្បាយថា ប្រសើរបំផុត ។ បទថា **កិត្តិសទ្ទោ** (កិត្តិស័ព្ទ) បានដល់ កេរ្តិ៍ឈ្មោះនុ៎ះឯង ឬសំឡេងសរសើរ ។ បទថា **អព្ភុគ្គតោ** (ខ្ចរខ្ចាយសុះសាយ) បានដល់ ផ្សាយទៅដល់ទេវលោក ។ សួរថា កិត្តិស័ព្ទផ្សាយទៅដូចម្តេច ។ ឆ្លើយថា ផ្សាយទៅថា **ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវា** ។ ក្នុងព្រះបាលីនោះមានបទសម្ព័ន្ធដូច្នេះ ព្រះមានព្រះភាគនោះ ជាព្រះអរហន្តសូម្បីព្រោះហេតុនេះ ជាព្រះសម្មាសម្ពុទ្ធសូម្បីព្រោះហេតុនេះ ។ល។ ជាព្រះមានព្រះភាគសូម្បីព្រោះហេតុនេះ ។ មានពាក្យអធិប្បាយថា ព្រោះហេតុនេះផង ព្រោះហេតុនេះផង ។ ក្នុងព្រះពុទ្ធគុណនោះ លោកតាំងមាតិកាទុកដោយន័យជាដើមថា ព្រះមានព្រះភាគនោះ គប្បីជ្រាបថា ជាព្រះអរហន្ត ដោយហេតុទាំងនេះ គឺ ៖

១. ព្រោះជាអ្នកឆ្ងាយ (ចាកកិលេស)

២. ព្រោះទ្រង់កម្ចាត់សត្រូវទាំងឡាយ

៣. ព្រោះទ្រង់កាច់បំបាក់កាំទាំងឡាយ

៤. ព្រោះជាអ្នកគួរដល់បច្ច័យជាដើម

៥. ព្រោះមិនធ្វើបាបក្នុងទីកំបាំង

ដូច្នេះ ហើយអធិប្បាយបទទាំងនេះ គ្រប់បទនោះឯង ឲ្យពិស្តារក្នុងពុ-ទ្ធានុស្សតិនិទ្ទេស ក្នុងបករណ៍ពិសេសឈ្មោះវិសុទ្ធិមគ្គ ។ អ្នកសិក្សាគប្បីកាន់យកសេចក្តីពិស្តាររបស់បទទាំងនោះ ពីបករណ៍ពិសេសឈ្មោះវិសុទ្ធិមគ្គនោះចុះ ។

បទថា **សោ ឥមំ លោកំ** (ព្រះមានព្រះភាគអង្គនោះ...) សេចក្តីថា ព្រះគោតមដ៏ចម្រើននោះ... លោកនេះ ។ តទៅនេះ នឹងសម្តែងបទដែលនឹងគប្បីពោល ។ បទថា **សទេវកំ** (ព្រមទាំងទេវលោក) បានដល់ (សត្វលោក) ព្រមទាំងទេវតាទាំងឡាយ ឈ្មោះថា **សទេវកៈ** , (សត្វលោក) ព្រមទាំងមារយ៉ាងនេះ ឈ្មោះថា **សមារកៈ** , (សត្វលោក) ព្រមទាំងព្រហ្ម ឈ្មោះថា **សព្រហ្មកៈ** , ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ឈ្មោះថា **សស្សមណព្រាហ្មណី** , ពួកសត្វដែលឈ្មោះថា **បជា** ព្រោះមានខ្លួនកើតពីទឹក នូវបជានោះ បជាព្រមទាំងទេវតា និងមនុស្សទាំងឡាយឈ្មោះថា **សទេវមនុស្សៈ** ។ បណ្តាបទទាំងនោះដោយបទថា **សទេវកៈ** គប្បីជ្រាបថា បំណងយកទេវតាជាន់កាមាវចរ ៥ ជាន់ដោយបទថា **សមារកៈ** គប្បីជ្រាបថា បំណងយកទេវតាជាន់កាមាវចរជាន់ទី ៦ ។ ដោយបទថា **សព្រហ្មកៈ** គប្បីជ្រាបថា បំណងយកព្រហ្ម ។ ដោយបទថា **ស-**

**សស្សមណព្រាហ្មណី** គប្បីជ្រាបថា សំដៅដល់សមណព្រាហ្មណ៍ដែលជាសត្រូវចំពោះព្រះសាសនា និងសំដៅដល់សមណព្រាហ្មណ៍អ្នកមានបាបដែលស្ងប់ហើយ អ្នកអណ្តែតបាបហើយ ។ ដោយបទថា **បជា** គប្បីជ្រាបថា សំដៅដល់សត្វលោក ។ ដោយបទថា **សទេវមនុស្សា** គប្បីជ្រាបថា សំដៅដល់សម្មតិទេព និងមនុស្សដ៏សេស ។ ក្នុងទីនេះ សត្វលោកព្រមទាំងឱកាសលោក គប្បីជ្រាបថា លោកកាន់យកហើយដោយ ៣ បទ ។ សត្វលោក គឺ ពួកសត្វ គប្បីជ្រាបថា លោកកាន់យកហើយដោយ ២ បទ ដូចពណ៌នាមកដូច្នេះ ។

ន័យមួយទៀត លោកជាន់អរូបាវចរៈ លោកកាន់យកហើយដោយស័ព្ទថា **សទេវកៈ** , ទេវលោកជាន់កាមាវចរៈ ៦ ជាន់ លោកកាន់យកហើយដោយស័ព្ទថា **សមារកៈ** , លោករបស់រូបព្រហ្ម លោកកាន់យកហើយដោយស័ព្ទថា **សព្រហ្មកៈ** , មនុស្សលោកព្រមទាំងបរិស័ទ ៤ ឬសម្មតិទេព ឬសត្វលោកទាំងអស់ដ៏សេស លោកកាន់យកហើយដោយស័ព្ទថា **សស្សមណព្រាហ្មណៈ** ជាដើម ។ ចំណែកព្រះបុរាណាចារ្យទាំងឡាយពោលថា បទថា **សទេវកំ** (ព្រមទាំងទេវលោក) បានដល់ លោកដ៏សេសព្រមទាំងទេវតាទាំងឡាយ ។ បទថា **សមារកំ** (ព្រមទាំងមារលោក) បានដល់ លោកដ៏សេសព្រមទាំងមារ ។ បទថា **សព្រហ្មកំ** (ព្រមទាំងព្រហ្មលោក) បានដល់ លោកដ៏សេសព្រមទាំងព្រហ្ម ។

ដើម្បីនឹងប្រមូលសត្វដែលចូលដល់កព ៣ ទាំងអស់ទុកក្នុង ៣ បទ ដោយអាការ ៣ ហើយកំណត់កាន់យកដោយ ២ បទទៀត លោកទើបពោលថា **ប្រជាជន ព្រមទាំងសមណព្រាហ្មណ៍ ទាំងទេវតា និងមនុស្ស** ដូចពណ៌នាមកនេះ ។ លោកកំណត់កាន់យកធាតុ ៣ នុ៎ះឯង ដោយអាការនោះៗ ដោយបទ ៥ ដូច្នេះឯង ។

បទថា (សយំ) (ដោយព្រះអង្គ) ក្នុងបទថា **សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ** (ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយព្រះបញ្ញាដ៏ក្រៃលែងដោយព្រះអង្គឯង ហើយទ្រង់ញុំាង... ឲ្យដឹងផង) មានសេចក្តីថា ដោយព្រះអង្គឯង គឺ មិនមានអ្នកដទៃណែនាំ ។ បទថា **អភិញ្ញា** (ដោយព្រះបញ្ញាដ៏ក្រៃលែង) បានដល់ ដោយអភិញ្ញា អធិប្បាយថា ទ្រង់ដឹងដោយព្រះញាណដ៏ក្រៃលែង ។ បទថា **សច្ឆិកត្វា** (ទ្រង់ធ្វើឲ្យជាក់ច្បាស់) គឺ ទ្រង់ធ្វើឲ្យប្រចក្សច្បាស់ ។ លោកធ្វើការបដិសេធការប៉ាន់ស្មានជាដើម ដោយបទថា **សច្ឆិកត្វា** នោះ ។ បទថា **បវេទេតិ** (ទ្រង់...ឲ្យដឹង) គឺ ទ្រង់ញុំាងលោកនេះ...ឲ្យដឹង បានដល់ ទ្រង់ឲ្យជ្រាប គឺ ទ្រង់ប្រកាស ។

### បទដើម-បទកណ្តាល-បទចុង

បទថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិយោសានកល្យាណំ** (ព្រះមានព្រះភាគអង្គនោះទ្រង់សម្តែងធម៌ មានលម្អបទដើម ។ល។

លម្អបទចុង) សេចក្ដីថា ព្រះមានព្រះភាគនោះ ទ្រង់អាស្រ័យព្រះករុណាក្នុងសត្វទាំងឡាយ ទ្រង់លះបង់សេចក្ដីសុខដែលកើតពីវិវេកដ៏កំពូល ហើយទ្រង់សម្ដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌តិចខ្លះ ច្រើនខ្លះ ក៏ទ្រង់សម្ដែងធម៌មានប្រការផ្សេងៗ មានលម្អបទដើម ជាដើមនោះឯង ។ មានពាក្យអធិប្បាយថា ទ្រង់សម្ដែងធ្វើឲ្យស្អាត គឺ ខ្ពង់ខ្ពស់ បានដល់ មិនឲ្យមានទោសឡើយ ទាំងបទដើម ទ្រង់សម្ដែងធ្វើឲ្យស្អាត គឺ ខ្ពង់ខ្ពស់ មិនឲ្យមានទោសឡើយ ទាំងបទកណ្ដាល ទាំងបទចុង ។ ក្នុងប្រការនោះ មានអធិប្បាយថា បទដើម បទកណ្ដាល បទចុងនៃទេសនា មានហើយ បទដើម បទកណ្ដាល និងបទចុងនៃពាក្យទូន្មានក៏មានហើយ ។

ចំពោះទេសនា ក្នុងគាថា ៤ បាទ បាទទី ១ ឈ្មោះថា បទដើម ពីរបាទបន្ទាប់ពីនោះ ឈ្មោះថា បទកណ្ដាល បាទតែមួយខាងចុង ឈ្មោះថា បទចុង ។ ចំពោះព្រះសូត្រ ដែលមានអនុសន្ធិមួយ ពាក្យខាងដើម ជាបទដើម ពាក្យខាងចុងថា **ឥទមវោច** ជាបទចុង វាងពាក្យដើម និងពាក្យខាងចុងទាំងពីរ ជាបទកណ្ដាល ។ ឯព្រះសូត្រមានអនុសន្ធិច្រើន អនុសន្ធិដំបូង ជាបទដើម អនុ-សន្ធិខាងចុង ជាបទចុង អនុសន្ធិមួយខ្លះ អនុសន្ធិពីរខ្លះ អនុសន្ធិច្រើន (ជាង ១ ឬ ២) ខ្លះ ត្រង់កណ្ដាល ជាបទកណ្ដាល ។

ចំពោះពាក្យទូន្មាន សីល សមាធិ និងវិបស្សនា ឈ្មោះថា ជាបទដើម ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា ក៏អ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ សីលដែលបរិសុទ្ធិល្អ និងទិដ្ឋិដែលត្រង់ (សម្មាទិដ្ឋិ) ជាខាងដើមនៃកុសលធម៌ទាំងឡាយជាដើម ដូច្នេះ ។ ចំណែកអរិយមគ្គ ដែលត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទា ដែលតថាគតត្រាស់ដឹងហើយ មានហើយ ដូច្នេះ ឈ្មោះថា ជាបទកណ្តាល ផល និងនិព្វាន ឈ្មោះថា ជាបទចុង ។ ផល លោកពោលថា ជាបទចុង ក្នុងប្រយោគនេះថា ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះឯងលោកចូរប្រព្រឹត្តព្រហ្មចរិយៈ នោះជាត្រើយ នោះជាទីបំផុត ។ និព្វាន លោកពោលថា ជាបទចុង ក្នុងប្រយោគនេះថា ម្នាលវិសាខៈមានអាយុ លោកប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីចូលដល់និព្វាន មាននិព្វានជាទីទៅក្នុងខាងមុខ មាននិព្វានជាទីបំផុត ។

ក្នុងទីនេះ លោកបំណងយកបទដើម កណ្តាល និងបទចុងនៃទេសនា ។ ព្រោះថា ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងធម៌ ក៏ទ្រង់សម្តែងសីលក្នុងខាងដើម ទ្រង់សម្តែងមគ្គត្រង់កណ្តាល ហើយទ្រង់សម្តែងនិព្វានក្នុងទីបំផុត ។ ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ព្រះមានព្រះភាគនោះទ្រង់សម្តែងធម៌មានលម្អបទដើម លម្អបទកណ្តាល (និង) លម្អបទចុង ។ ព្រោះហេតុនោះ ព្រះ

ធម្មកថិកសូម្បីអង្គដទៃៗ កាលនឹងពោលធម៌

ក៏គប្បីសម្ដែងសីលក្នុងខាងដើម គប្បីសម្ដែងមគ្គត្រង់កណ្ដាល

គប្បីសម្ដែងនិព្វានក្នុងទីបំផុត នេះ ឈ្មោះថា ជាគោលដែលល្អ

របស់ព្រះធម្មកថិក ។

បទថា សាត្ថំ សព្យញ្ជនំ (ព្រមទាំងអត្ថទាំងព្យញ្ជនៈ) សេចក្ដីថា ក៏ទេសនារបស់ព្រះធម្មកថិកអង្គណា អាស្រ័យការពណ៌នាដល់បាយ បបរ ស្រីនិងប្រុសជាដើម (អាស្រ័យវត្ថុទាំងនេះជាហេតុចូលចិត្តទើបសម្ដែង) ព្រះធម្មកថិកនោះ មិនឈ្មោះថា សម្ដែងធម៌ដែលប្រកបព្រមដោយអត្ថ (ប្រយោជន៍) ។ តែព្រះមានព្រះភាគទ្រង់លះបង់ទេសនាបែបនោះចេញ ទ្រង់សម្ដែងទេសនា ដែលអាស្រ័យសតិប្បដ្ឋាន ៤ ជាដើម ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ទ្រង់សម្ដែងធម៌ដែលប្រកបព្រមដោយអត្ថ (ប្រយោជន៍) ។ ចំណែកទេសនារបស់ព្រះធម្មកថិករូបណា ប្រកបដោយព្យញ្ជនៈតែម្យ៉ាងជាដើមខ្លះ មានព្យញ្ជនៈខ្វះខ្លះ មានព្យញ្ជនៈដែលពោលចេញទាំងអស់ និងនិគហិតទៅទាំងអស់ខ្លះ ទេសនារបស់ព្រះធម្មកថិករូបនោះ ឈ្មោះថា មិនមានព្យញ្ជនៈ ព្រោះមានព្យញ្ជនៈមិនគ្រប់ ដូចភាសារបស់ពួកមនុស្សព្រៃ មានអ្នកស្រុកទមិឡ អ្នកស្រុកកិរាយតកៈ និងអ្នកស្រុកយោនកៈជាដើម ។ ប៉ុន្តែថា ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ ធ្វើ

ព្យញ្ជនៈឲ្យបរិបូរណ៍ ទ្រង់មិនលះបោលព្យញ្ជនៈទាំង ១០ ប្រភេទ ដែលពោលទុកយ៉ាងនេះថា ៖

សេចក្ដីដឹងរឿងព្យញ្ជនៈ មាន ១០ ប្រការ គឺ សិថិល ១ ធនិត ១ ទីឃៈ ១ រស្សៈ ១ លហុ ១ គរុ ១ និគហិត ១ សម្ពន្ធ ១ វវដ្ឋិតៈ ១ វិមុត្តៈ ១ ។

ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ទ្រង់សម្ដែងធម៌ព្រមទៅដោយព្យញ្ជនៈ ។

បទថា **កេវលំ** (អស់ជើង) ក្នុងបទថា **កេវលបរិបុណ្ណំ** (បរិបូរណ៍សព្វគ្រប់) នេះ ជាពាក្យប្រើជំនួសបទថា **សកល** សំដៅដល់ ទាំងអស់ ។ បទថា **បរិបុណ្ណំ** (បរិបូរណ៍) សំដៅដល់ មិនខ្វះមិនលើស ។ មានពាក្យអធិប្បាយដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្ដែងធម៌បរិបូរណ៍ទាំងអស់ សូម្បីទេសនារឿងតែមួយ ដែលមិនបរិបូរណ៍មិនមាន ។ បទថា **បរិសុទ្ធំ** (បរិសុទ្ធិ) បានដល់ មិនមានឧបក្កិលេស ។ អធិប្បាយថា ព្រះធម្មកថិករូបណា សម្ដែងធម៌ដោយប្រាថ្នាថា យើងនឹងបានលាភ ឬសក្ការៈព្រោះអាស្រ័យធម្មទេសនានេះ ទេសនារបស់ព្រះធម្មកថិករូបនោះ ឈ្មោះថា មិនបរិសុទ្ធិ ។ ប៉ុន្តែថា ព្រះមានព្រះភាគទ្រង់មិនប្រាថ្នាលោកាមិសៈ ទ្រង់មានព្រះទ័យទន់ភ្លន់ ដោយការផ្សាយប្រយោជន៍ដ៏ធំ

ដោយការចម្រើនមេត្តា ទ្រង់សម្តែងធម៌ដោយព្រះទ័យពេញទៅដោយសេចក្តីមេត្តា ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ទ្រង់សម្តែងធម៌បរិសុទ្ធិ ។ បទថា **ព្រហ្មចរិយំ** ក្នុងបទថា **ព្រហ្មចរិយំ បកាសេតិ** (ទ្រង់ប្រកាសព្រហ្មចរិយៈ) នេះ បានដល់ ពាក្យទូន្មានទាំងអស់ ដែលសង្គ្រោះចូលក្នុងត្រៃសិក្ខា ព្រោះហេតុនោះ ព្រះសង្គីតិកាចារ្យទើបពោលថា ទ្រង់ប្រកាសព្រហ្មចរិយៈ ។

គប្បីឃើញសេចក្តីក្នុងបទនេះ យ៉ាងនេះថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់សម្តែងធម៌មានលម្អបទដើម ។ល។ បរិសុទ្ធិ និងកាលទ្រង់សម្តែងយ៉ាងនេះ ឈ្មោះថា ទ្រង់ប្រកាសសាសនព្រហ្មចរិយៈទាំងអស់ ដែលសង្គ្រោះចូលក្នុងត្រៃសិក្ខា ។ បទថា **ព្រហ្មចរិយំ** សេចក្តីថា ចរិយា ដែលឈ្មោះថា ជាព្រហ្ម ព្រោះអត្ថថា ប្រសើរទីបំផុត ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ចរិយារបស់លោកដ៏ប្រសើរទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា **ព្រហ្មចរិយៈ** ។

បទថា **សាធុ ខោ បន** (ជាការល្អហើយ) សេចក្តីថា ក៏ (ការឃើញព្រះអរហន្តទាំងឡាយ) ជាការល្អ ។ មានពាក្យអធិប្បាយថា នាំប្រយោជន៍មកឲ្យ នាំសេចក្តីសុខមកឲ្យ ។ បទថា **តថារូបានំ អរហតំ** (ព្រះអរហន្តទាំងឡាយបែបនេះ) សេចក្តីថា ព្រះអរហន្តទាំងឡាយ ដូចជា ព្រះគោតមដ៏ចម្រើន ជាបុគ្គលដែលឃើញបានដោយលំបាក ដោយប្រើវេលាយូរអស់ច្រើនសែនកោដិកប្ប

(ទើបនឹងបានឃើញ) មានសរីរៈជាទីមនោរម្យ ដែលប្រដាប់ដោយមហាបុរិស-លក្ខណៈដ៏ប្រសើរ ៣២ ប្រការ ប្រដាប់ដោយរតនៈ គឺ អនុព្យញ្ជនៈ ៨០ ប្រការ ហែហមដោយព្រះរស្មីដែលផ្សាយចេញទៅប្រមាណមួយព្យាម គួរទស្សនា មានក្រសែសំឡេងសម្តែងធម៌ពីរោះក្រៃលែងណាស់ មានព្រះកិត្តិនាមថា ជាព្រះអរហន្តក្នុងលោក ព្រោះបានសម្រេចគុណតាមសេចក្តីពិត ។ បទថា ***ទស្សនំ ហោតិ*** (ការបានឃើញ) សេចក្តីថា សូម្បីត្រឹមតែបើកភ្នែក ដែលប្រកបដោយសេចក្តីជ្រះថ្លាជាដើមឡើងមើល ក៏ជាការល្អ ព្រោះធ្វើអធ្យាស្រ័យយ៉ាងនេះថា ប្រសិនបើ កាលព្រះពុទ្ធដូចជាព្រះគោតមដ៏ចម្រើនសម្តែងធម៌ហើយ ដោយព្រះសូរសៀងដូចសំឡេងព្រហ្ម ដែលប្រកបដោយអង្គ ៨ យើងទាំងឡាយនឹងបានស្តាប់ត្រឹមតែមួយបទសោត ក៏នឹងជាការប្រពៃក្រៃលែងណាស់នោះឯង ។

បទថា ***យេ ភគវា តេនុបសង្កមឹសុ*** (នាំគ្នាទៅគាល់ព្រះមានព្រះភាគ) សេចក្តីថា អ្នកស្រុកវេនាគបុរៈទាំងឡាយ លះចោលការងារគ្រប់យ៉ាង មានចិត្តត្រេកអរ បាននាំគ្នាមកហើយ ។ ក្នុងបទថា ***អញ្ជលិម្បណាមេត្វា*** (បង្អោនអញ្ជលី) នេះ មានអធិប្បាយថា ជនពួកណាចូលគ្នាបានទាំងពីរចំណែក គឺ ទាំងចំណែកសម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ ជនពួកនោះគិតយ៉ាងនេះថា បើពួកមិច្ឆាទិដ្ឋិនឹងជំទាស់ពួកយើងថា ព្រោះហេតុអ្វី លោកទាំងឡាយទើបសំពះព្រះសមណគោតម

យើងទាំងឡាយនឹងតបដល់ពួកមិច្ឆាទិដ្ឋិនោះថា សូម្បីដោយហេតុត្រឹមតែធ្វើអញ្ជលី ក៏ចាត់ថាជាការសំពះដែរឬ ។ បើពួកសម្មាទិដ្ឋិជំទាស់នឹងពួកយើងថា ព្រោះហេតុអ្វី លោកទាំងឡាយទើបមិនសំពះព្រះមានព្រះភាគ យើងទាំងឡាយនឹងឆ្លើយថា ទាល់តែសីសៈប៉ះខ្ទប់ផែនដីប៉ុណ្ណោះឬ ទើបចាត់ជាការសំពះ សូម្បីការអញ្ជលី ក៏រាប់ថា ជាការសំពះដូចគ្នាមិនមែនឬ ។

## ប្រកាសនាម និងគោត្រ

បទថា **នាមគោត្តំ** (ឈ្មោះ និងគោត្ត) សេចក្តីថា អ្នកស្រុកវេនាគបុរៈទាំងឡាយ កាលពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះទត្តៈ ជាបុត្ររបស់អ្នកឯណោះ ខ្ញុំព្រះអង្គឈ្មោះមិត្តៈ ជាបុត្រអ្នកឯណោះ មកក្នុងទីនេះ ដូច្នេះ ឈ្មោះថា ប្រកាសនាម ។ កាលពោលថា បពិត្រព្រះគោមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះវាសេដ្ឋៈ ខ្ញុំព្រះអង្គឈ្មោះកច្ចាយនៈ មកក្នុងទីនេះ ដូច្នេះ ឈ្មោះថា ប្រកាសគោត្រ ។

បានឮមកថា អ្នកស្រុកវេនាគបុរៈទាំងនោះក្រលំបាក ជាបុត្ររបស់ត្រកូលទាបថោក ធ្វើយ៉ាងនោះ ក៏ដោយសន្សំថា យើងទាំងឡាយនឹងប្រាកដដោយអំណាចនាម និងគោត្រត្រង់កណ្តាលបរិស័ទ ។ ក៏ឯអ្នកស្រុកវេនាគបុរៈពួកណាអង្គុយស្ងៀម អ្នកស្រុកវេនាគបុរៈទាំងនោះ ជាបុគ្គលកំណាញ់ ជាមនុស្សល្ងង់ ។

បណ្ដាជនទាំងនោះ ពួកដែលកំណាញ់គិតថា កាលយើងធ្វើការសន្ទនាប្រាស្រ័យមួយពាក្យ ពីរពាក្យ ព្រះសមណគោតមក៏នឹងរាប់អាន កាលមានការរាប់អាននឹងមិនឲ្យភិក្ខាមួយវែក ឬពីរវែក ក៏នឹងមិនសមគួរ ដូច្នេះ កាលនឹងដោះខ្លួនពីការរាប់អាននោះ ទើបអង្គុយស្ងៀម ។ ពួកបុគ្គលល្ងង់ អង្គុយស្ងៀមនៅក្នុងទីមួយកន្លែង ដូចដុំដីដែលត្រូវទុកចោល ព្រោះភាពនៃខ្លួនជាមនុស្សមិនដឹង ។

បទថា **វេនាគបុរិកោ** (អ្នកស្រុកវេនាគបុរៈ) បានដល់ អ្នកក្រុងវេនាគ-បុរី ។ បទថា **ឯតទវោច** (បានក្រាបទូល) សេចក្ដីថា អ្នកក្រុងវេនាគបុរីសម្លឹងមើលព្រះសរីរៈរបស់ព្រះតថាគត តាំងពីចុងព្រះបាទឡើងទៅដរាបដល់ចុងព្រះកេសា ក៏ឃើញព្រះសរីរៈរបស់ព្រះតថាគតប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដែលរុងរឿងដោយអនុព្យញ្ជនៈ ៨០ ហែហមដោយព្រះពុទ្ធរស្មី ៦ ពណ៌ដែលផ្សាយចេញពីព្រះសរីរៈទៅគ្រប់ដណ្ដប់ដោយជុំវិញប្រមាណ ៨០ ហត្ថ ទើបកើតសេចក្ដីភាំងស្មារតី កាលនឹងពោលសរសើរគុណ ទើបបានពោលយ៉ាងនេះគឺ បានពោលពាក្យមានជាអាទិ៍ថា **បពិត្រព្រះអង្គដ៏ចម្រើន គួរអស្ចារ្យ ។**

**ចិត្តផូរផង់ធ្វើឲ្យឥន្ទ្រិយ ៥ ផូរផង់**

បណ្ដាបទទាំងនោះ បទថា **យាវញ្ចិទំ** នេះ ជាពាក្យបង្ហាញដល់ការកំណត់មានប្រមាណក្រៃលែង ។ បទថា **យាវញ្ចិទំ** នោះ សម្ព័ន្ធចូលជាមួយបទ

ថា **វិប្បសន្នំ** ។ ម្យ៉ាងទៀត (ឥន្ទ្រិយទាំងឡាយ) ផូរផង់ត្រឹមណា ឈ្មោះថា ផូរផង់យ៉ាងក្រៃលែង អធិប្បាយថា ផូរផង់ក្រៃលែងណាស់ ។ បទថា **ឥន្ទ្រិយានិ** (ឥន្ទ្រិយ) បានដល់ ឥន្ទ្រិយ ៦ មានចក្ខុជាដើម ។ ក៏ឥន្ទ្រិយ ៦ នោះ ផូរផង់ បានប្រាកដហើយដល់ព្រាហ្មណ៍វច្ឆគោត្រ ព្រោះបានឃើញឱកាសដែលឥន្ទ្រិយ ៥ តាំងនៅក្នុងភាពផូរផង់ ។ ក៏ព្រោះឥន្ទ្រិយផូរផង់នោះ ជាការផូរផង់នៃចិត្ត នុ៎ះឯង ព្រោះសម្រាប់បុគ្គលដែលមានចិត្តមិនផូរផង់ ក៏នឹងមានឥន្ទ្រិយមិនផូរផង់ ដូច្នោះ សូម្បីសេចក្តីផូរផង់នៃមនិន្ទ្រិយ ក៏បានប្រាកដដល់ព្រាហ្មណ៍វច្ឆគោត្រនោះ ។ ព្រាហ្មណ៍វច្ឆគោត្រ សំដៅយកឥន្ទ្រិយ ៦ ផូរផង់ យ៉ាងនេះ ទើបពោលថា **ឥន្ទ្រិយផូរផង់... ក្រៃលែង** ។

បទថា **បរិសុទ្ធោ** (បរិសុទ្ធ) បានដល់ មិនមានមន្ទិល ។ បទថា **បរិយោទតោ** បានដល់ ផូរផង់ ។ បទថា **សារទំ ពទរបណ្ឌុំ** (ផ្លែពុទ្រាទុំដែលមានក្នុងសារទកាល) បានដល់ ផ្លែពុទ្រាទុំដែលកើតក្នុងសារទកាល ។ ពិតណាស់ ផលពុទ្រាទុំនោះ មានទាំងថ្លា ទាំងផូរផង់ ។ បទថា **តាលបក្កំ** បានដល់ ផ្លែត្នោតទុំ ។ បទថា **សម្បតិពន្ធនា បមុត្តំ** (ដែលជ្រុះចាកទង) បានដល់ ជ្រុះចាកទងក្នុងខណៈនោះឯង ។ អធិប្បាយថា សាច់ត្រឹមតែ ៤ អង្គុលី របស់ផ្លែត្នោតទុំនោះ ដែលបុគ្គលប្រឡេះចេញពីគ្រាប់ ហើយផ្ការឡើងដាក់លើបន្ទះក្តា រមែង

ប្រាកដជាពណ៌ស្រស់ថ្លា ផូរផង់ដល់បុគ្គលដែលក្រឡេកមើល ។ ព្រាហ្មណ៍-វច្ឆគោត្រ សំដៅយកផ្លែត្នោតទុំនោះឯង ទើបពោលយ៉ាងនេះ ។

បទថា **នេក្ខំ ជម្ពោនទំ** (មាសជម្ពុនុទ) បានដល់ ដុំមាសជម្ពូនុទដែលមានពណ៌ក្រហម ។ បទថា **ទក្ខកម្មារបុត្តសុបរិកម្មកតំ** (ដែលបុត្តជាងមាសដ៏ជំនាញតាក់តែងល្អហើយ) បានដល់ ដែលបុត្រជាងមាសដ៏ឈ្លាសតាក់តែងទុកល្អហើយ ។ បទថា **ឧក្កាមុខេ**[១] **សុកុសលសម្បហដ្ឋំ** (ដែលជាងមាសដ៏ឈ្លាសរំលាយល្អហើយ) សេចក្តីថា មាសជម្ពុនុទដែលជាងមាសអ្នកមានថ្វីដៃ រំលាយក្នុងចង្ក្រានរបស់ជាងមាសហើយ តាក់តែងយ៉ាងល្អ ដោយការជំ ការរឹត និងការហូត អធិប្បាយថា ខាស់ឲ្យល្អ ។ បទថា **បណ្ឌុកម្ពលេ និក្ខិត្តំ** (ទុកលើសំពត់កម្ពល) សេចក្តីថា ដែលជាងមាសអ្នកមានថ្វីដៃ ប្រើភ្លើង ដុសខាត់ដោយចង្កូមខ្លាដំបង តាក់តែងដោយពណ៌ក្រហម ហើយដាក់លើសំពត់កម្ពលពណ៌ក្រហម ។ បទថា **ភាសតេ** (បញ្ចេញពន្លឺ) បានដល់ បញ្ចេញពន្លឺ ព្រោះមានពន្លឺកើតឯង ។ បទថា **តបតេ** (ស្វាងស្វៃ) បានដល់ ភ្លឺស្វាងស្វៃ ព្រោះកម្ចាត់សេចក្តីងងឹត ។ បទថា **វិរោចតិ** (រុងរឿង) បានដល់ ផ្សាយពន្លឺដ៏រុងរោចន៍ អធិប្បាយថា ស្រស់ល្អ ។

---

(១) មិនប្រាកដក្នុងបិដក ។ ឯពាក្យថា សុកុសលសម្បហំដ្ឋំ បិដកជា កុសលសម្បហដ្ឋំ ។

ក្នុងបទថា **ឧច្ចាសយនមហាសយនានិ** នេះ មានអធិប្បាយដូចតទៅនេះ ទីដេក (ខ្ពស់) លើសខ្នាត ឈ្មោះថា ទីដេកដែលខ្ពស់ ។ ទីដេកដែលជាអកប្បិយភណ្ឌ: (របស់ដែលមិនគួរដល់សមណ:) ទាំងវែង និងធំ ឈ្មោះថា ទីដេកដែលធំ ។ ឥឡូវនេះ កាលនឹងសម្តែងទីដេកដែលខ្ពស់ និងទីដេកដែលធំនោះ ព្រាហ្មណ៍វច្ឆគោត្រ ទើបពោលបទថា **អាសន្ទិ** ជាដើម ។

## អធិប្បាយរឿងអាសនៈជាដើម

ក្នុងពាក្យថា **អាសន្ទិ** ជាដើមនោះ មានអធិប្បាយដូចតទៅនេះ ដែលឈ្មោះថា អាសន្ទិ បានដល់ អាសនៈ (ទីអង្គុយ) ហួសខ្នាត ដែលឈ្មោះថា **បល្ល័ង្ក** បានដល់ បល្ល័ង្ក (គ្រែ) ដែលគេធ្វើដោយប្រតិស្ឋានរូបសត្វកាចទុកត្រង់ជើង ។ ដែលឈ្មោះថា **គោណកៈ** បានដល់ សំពត់កោជាវផ្ទាំងធំ ដែលមានរោមវែង ។ បានឮមកថា រោមរបស់សំពត់កោជាវផ្ទាំងធំនោះ (វែង) ហួស ៤ ធ្នាប់ ។ ដែលឈ្មោះថា **ចិត្តិកា** បានដល់ គ្រឿងក្រាលរោមកែះ វិចិត្រដោយរតនៈ ។ ដែលឈ្មោះថា **បដិកា** បានដល់ កម្រាលពណ៌ស ធ្វើពីរោមកែះ ។ ដែលឈ្មោះថា **បដលិកា** បានដល់ កម្រាលរោមកែះមានផ្កាក្រាស់ ដែលហៅថា សំពត់ក្បាច់ស្ទឹកកន្ទួតព្រៃខ្ទះ ។ ដែលឈ្មោះថា **តូលិកា** បានដល់ កម្រាលធ្វើពីសំឡី ដែលញាត់ពេញដោយសំឡីប្រភេទណាមួយក្នុងសំឡី ៣ ប្រភេទ ។

ដែលឈ្មោះថា **វិកតិកា** បានដល់ កម្រាលរោមកែះដែលវិចិត្រដោយរូបរាជ-សីហ៍ និងខ្លាធំជាដើម ។ ដែលឈ្មោះថា **ឧទ្ធលោមី** បានដល់ កម្រាលរោមកែះដែលមានជាយទាំងពីរខាង ។ អាចារ្យពួកខ្លះពោលថា កម្រាលរោមកែះដែលមានផ្កាផុសឡើងតែម្ខាង ។ ដែលឈ្មោះថា **ឯកន្តលោមី** បានដល់ កម្រាលរោមកែះដែលមានជាយតែម្ខាង ។ អាចារ្យពួកខ្លះពោលថា កម្រាលរោមកែះដែលមានផ្កាផុសឡើងទាំងពីរខាង ។ ដែលឈ្មោះថា **កដ្ឋិស្សៈ** បានដល់ កម្រាលធ្វើដោយអំបោះលាយសូត្រ ដេរភ្ជាប់ដោយរតនៈ ។ ដែលឈ្មោះថា **កោសេយ្យៈ** បានដល់ កម្រាលធ្វើដោយសូត្រ ដេរភ្ជាប់ដោយរតនៈដូចគ្នា ។ ដែលឈ្មោះថា **កុត្តកៈ** បានដល់ កម្រាលរោមកែះល្មមពួកស្រីរបាំ ១៦ នាក់ ឈររាំបាន ។ ដែលឈ្មោះថា **កម្រាលសម្រាប់ក្រាលលើខ្នងដំរី** ជាដើម បានដល់ កម្រាលដែលក្រាលលើខ្នងដំរីជាដើម និងកម្រាលដែលធ្វើជារូបដំរីជាដើម ។ ដែលឈ្មោះថា **អជិនប្បវេណិ**[១] បានដល់ កម្រាលដែលយកស្បែកសត្វ (អជិនៈ) មកដេរធ្វើឲ្យល្មមប៉ុនគ្រែ ។ បទដ៏សេសមានអត្ថន័យដូចពោលហើយក្នុងខាងដើមនុ៎ះឯង ។

បទថា **និកាមលាភី** (បានតាមសេចក្តីប្រាថ្នា) បានដល់ (ព្រះសមណ-គោតមដ៏ចម្រើន) មានប្រក្រតីបានតាមប្រាថ្នា គឺ មានប្រក្រតីបានទីដេកដែល

---

(១) បិដក ជា អជិនប្បវេណិ ។

ខ្ពស់ និងធំតាមដែលទ្រទ្រង់បំណង ។ បទថា **អកិច្ឆលាភី** (បានដោយមិនលំបាក) ប្រែថា មានប្រក្រតីបានតាមសេចក្ដីប្រាថ្នា ។ បទថា **កសិរលាភី** (បានដោយងាយ) បានដល់ មានប្រក្រតីបានទីដេកដ៏សម្បូរ គឺ មានប្រក្រតីបានទីដេកធំ ព្រាហ្មណ៍វច្ឆគោត្រពោលសំដៅយកថា ព្រះសមណគោតមដ៏ចម្រើន នឹងបាននូវទីដេកដ៏ឱឡារិកតែម្យ៉ាង ។ បានឮថា ព្រាហ្មណ៍នេះសង្កេតឃើញក្នុងការដេក ។ គេឃើញថា ឥន្ទ្រិយរបស់ព្រះមានព្រះភាគថ្លាផូរផង់ជាដើម សម្គាល់ហើយថា ព្រះសមណ-គោតមនេះ អង្គុយ និងដេកលើទីដេកខ្ពស់ និងទីដេកធំបែបនេះដោយពិត ព្រោះហេតុនោះ ឥន្ទ្រិយទាំងឡាយរបស់លោកទើបផូរផង់ ពណ៌សម្បុរទើបបរិសុទ្ធផូរផង់ ទើបបានពោលសរសើរគុណរបស់សេនាសនៈនេះ ។

ក្នុងបទថា **លទ្ធា ច បន ន កប្បន្តិ** (និងបានមកហើយក៏មិនគួរ) នេះ មានអធិប្បាយថា ព្រោះព្រះបាលីថា កម្រាលខ្លះប្រើបាន អធិប្បាយថា កម្រាលធ្វើដោយសរសៃសូត្រសុទ្ធ នឹងក្រាលសូម្បីលើគ្រែ ក៏ប្រើបាន កម្រាលធ្វើដោយសំពត់រោមសត្វជាដើម នឹងក្រាល ដោយប្រើជាកម្រាលផែនដីក៏ប្រើបាន នឹងកាត់ជើងរបស់អាសន្ទិ (ហើយអង្គុយ) ក៏បាន នឹងទម្លាយរូបសត្វកាចរបស់គ្រែ (ហើយអង្គុយ) ក៏បាន នឹងហែកអាសនៈញាត់.គ យកមកធ្វើជាខ្នើយក៏បាន ដូច្នេះ កម្រាលសូម្បីទាំងនេះ ទើបគួរដោយវិធីដូចគ្នា តែព្រោះអាស្រ័យវត្ថុដែលជាអ-

កប្បិយៈ កម្រាលទាំងអស់នុ៎ះឯង ព្រះមានព្រះភាគត្រាស់ថា មិនគួរ ។

បទថា **វនន្តំយេវ បចារយាមិ** (ចូលទៅកាន់ជាយព្រៃ) សេចក្តីថា តថាគត ចូលទៅកាន់ព្រៃនោះឯង ។ បទថា **យទេវ** គឺ **យានិយេវ** (ពួកណា) ។ បទថា **បល្លង្កំ អាភុជិត្វា** (អង្គុយពត់ភ្នែន) គឺ អង្គុយពត់ភ្នែនលើអាសនៈ ។ បទថា **ឧជុំ កាយំ បណិធាយ** (តាំងកាយឲ្យត្រង់) គឺ តាំងកាយឲ្យត្រង់ ឲ្យឆ្អឹងខ្នង ១៨ កង់ ឲ្យមានចុងទល់នឹងចុងគ្នា ។ បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** (តាំងសតិឆ្ពោះមុខ) សេចក្តីថា តាំងសតិឆ្ពោះទៅកាន់ព្រះកម្មដ្ឋាន ឬធ្វើការកំណត់និងការនាំចេញ ។ សមដូចពាក្យដែលលោកពោលទុកដូច្នេះថា ស័ព្ទថា **បរិ** មានអត្ថថា កំណត់ ស័ព្ទថា **មុខំ** មានអត្ថថា នាំចេញ ស័ព្ទថា **សតិ** មានអត្ថថា តាំងមាំ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា តាំងសតិទុកចំពោះមុខ ។ បទថា **ឧបសម្បជ្ជ វិហរាមិ** (ត្រាស់ដឹង..ហើយ) សេចក្តីថា តថាគតបានចំពោះ គឺ ធ្វើឲ្យប្រចក្សហើយ ។

## ព្រះពុទ្ធចូលឈានស្តេចយាងចង្រ្កម

បទថា **ឯវម្ភូតោ** (បុគ្គលដូច្នេះ) សេចក្តីថា (តថាគត) ជាអ្នកព្រមព្រៀងដោយឈានណាមួយ ក្នុងបណ្តាឈាន មានបឋមឈានជាដើមយ៉ាងនេះ ។ បទថា **ទិព្វោ មេ ឯសោ តស្មឹ សមយេ ចង្កមោ ហោតិ** (ក្នុងសម័យនោះ ទីចង្រ្កម

របស់តថាគតនោះ ឈ្មោះថា ជារបស់ទិព្វ) សេចក្តីថា ក៏ទីចង្រ្កមរបស់តថាគត ដែលចូលរូបឈាន ៤ ដើរចង្រ្កមហើយ ឈ្មោះថា ជាទីចង្រ្កមទិព្វ សូម្បីកាល តថាគតចេញចាកសមាបត្តិដើរចង្រ្កម ទីចង្រ្កម (នោះ) ឈ្មោះថា ជាទីចង្រ្កមទិព្វ ដូចគ្នា ។ សូម្បីក្នុងឥរិយាបថទាំងឡាយ មានការឈរជាដើម ក៏មានន័យនេះ ឯង ។ ក្នុងការនៅ ២ យ៉ាង ក្រៅពីនេះក៏ដូចគ្នា ។ បទថា **សោ ឯវំ បជានាមិ រាគោ មេ បហីនោ** (តថាគតដឹងច្បាស់យ៉ាងនេះថា តថាគតលះរាគៈបានហើយ) សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងរាគៈដែលលះបានហើយ ដោយ អរហត្តមគ្គត្រង់មហាពោធិបល្ល័ង្កនុ៎ះឯង ទើបត្រាស់ថា **តថាគតដឹងច្បាស់យ៉ាង នេះថា តថាគតលះរាគៈបានហើយ** ដូច្នេះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យ នេះឯង ។ មួយទៀត សួរថា ដោយបទនេះទ្រង់ត្រាស់ដល់អ្វី (ឆ្លើយថា) ព្រះ មានព្រះភាគត្រាស់ដល់ការពិចារណា (បច្ចវេក្ខណញ្ញាណ) ។ ព្រះមានព្រះភាគ ត្រាស់ដល់ផលសមាបត្តិ ដោយការពិចារណា ។ ពិតណាស់ ទីកន្លែង មានទី ចង្រ្កមជាដើម របស់ព្រះមានព្រះភាគដែលចូលផលសមាបត្តិក្តី ដែលចេញចាក សមាបត្តិក្តី ឈ្មោះថា ជាចង្រ្កមរបស់ព្រះអរិយៈជាដើម ។ បទដ៏សេសក្នុងសូត្រ នេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា វេនាគសូត្រទី ៣

# អដ្ឋកថា សរភសូត្រទី ៤

## "អឋានៈ ៣ យ៉ាង"

គប្បីជ្រាបវិនិច្ឆ័យក្នុង សរភសូត្រទី ៤ ដូចតទៅនេះ ៈ-

[៦៦] បទថា *រាជគហេ* (ជិតក្រុងរាជគ្រឹះ) បានដល់ ជិតព្រះនគរដែលមានឈ្មោះយ៉ាងនេះ ។ បទថា **គិជ្ឈកូដេ បព្វតេ** (ត្រង់ភ្នំគិជ្ឈកូដ) សេចក្តីថា ភ្នំនោះមានកំពូលដូចសត្វត្មាត ។ ម្យ៉ាងទៀត ឈ្មោះថា គិជ្ឈកូដ ព្រោះសត្វត្មាតនៅលើកំពូលភ្នំនោះ ត្រង់ភ្នំគិជ្ឈកូដនោះ ។ ដោយបទថា **គិជ្ឈកូដ** នេះ លោកសម្តែងដល់ទីប្រថាប់របស់ព្រះមានព្រះភាគដែលទ្រង់ប្រថាប់ហើយ ដោយយកក្រុងរាជគ្រឹះជាគោចរគាម ។ អធិប្បាយថា គេសាងវិហារថ្វាយព្រះតថាគតលើភ្នំគិជ្ឈកូដ ។ ដូច្នោះ ពាក្យថា គិជ្ឈកូដវិហារ ទើបជាឈ្មោះរបស់វិហារនោះ ។ ក្នុងសម័យនោះ បរិព្វាជកឈ្មោះថា **សរភៈ** នៅក្នុងទីនោះ ដូច្នេះឯង ។

បទថា **សរភោ នាម បរិព្វាជកោ អចិរបក្កន្តោ ហោតិ** (បរិព្វាជកឈ្មោះសរភៈ ជាអ្នកទើបតែនឹងសឹក... មិនយូរ) សេចក្តីថា បរិព្វាជកអ្នកមានឈ្មោះយ៉ាងនេះថា សរភៈ បួសហើយក្នុងសាសនានេះ មិនយូរក៏សឹកទៅ ។ អធិប្បាយថា បួសមិនយូរ ក៏សឹក ។

ពិតហើយ កាលព្រះសម្មាសម្ពុទ្ធស្តេចឧប្បត្តិឡើងក្នុងលោក ពួកតិរ្ថិយ

ក៏សាបសូន្យលាភ និងសក្ការៈ ។ លាភសក្ការៈច្រើនណាស់ កើតឡើងដល់ព្រះរតនត្រ័យ ដូចដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា ក៏សម័យនោះឯងព្រះមានព្រះភាគដែលជនទាំងឡាយ សក្ការៈ គោរព រាប់អាន បូជា កោតក្រែងហើយ ព្រះអង្គបានទទួលបរិក្ខារ គឺ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជៈ ចំណែកអន្យតិរ្ថិយបរិព្វាជកទាំងឡាយ មិនមានអ្នកធ្វើសក្ការៈ គោរព រាប់អាន បូជា និងកោតក្រែង មិនបានទទួលបរិក្ខារ គឺ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជៈ ។

អន្យតិរ្ថិយប្រមាណទាំង ៥០០ នោះ ជាអ្នកសាបសូន្យលាភ និងសក្ការៈយ៉ាងនេះ បានប្រជុំក្នុងអារាមរបស់បរិព្វាជកមួយកន្លែង ជំនុំគ្នាថា លោកដ៏ចម្រើនទាំងឡាយ ផ្ដើមតាំងពីវេលាដែលព្រះសមណគោតមឧប្បត្តិឡើងហើយ ពួកយើងក្លាយជាអ្នកសាបសូន្យចាកលាភសក្ការៈ លោកទាំងឡាយចូរពិចារណារកទោសរបស់ព្រះសមណគោតម និងសាវករបស់ព្រះសមណគោតមត្រឹមតែមួយប្រការផ្សាយទោសចេញទៅ តិះដៀលពាក្យទូន្មានរបស់ព្រះសមណគោតមនោះ ហើយនឹងញុំាងលាភ និងសក្ការៈឲ្យកើតឡើងដល់ពួកយើងទាំងឡាយ អន្យតិរ្ថិយទាំងនោះ កាលពិចារណាមើលទោស បាននិយាយគ្នាថា ពួកយើងមិនអាចនឹងមើលឃើញទោសរបស់ព្រះសមណគោតមក្នុងទី ៤ ស្ថាន គឺ ក្នុងទ្វារ ៣ និងអាជីវៈ

១ បាន លោកទាំងឡាយចូរលះឋានៈទាំង ៤ ទុកសិន ហើយពិចារណាមើលក្នុងឋានៈដទៃ ។ លំដាប់នោះ ក្នុងរវាងពួកតិរ្ថិយទាំងនោះ តិរ្ថិយម្នាក់ពោលយ៉ាងនេះថា ខ្ញុំមិនឃើញឧបាយយ៉ាងដទៃ ក៏ប៉ុន្តែថា សមណៈទាំងនេះ ប្រជុំគ្នារាល់កន្លះខែ បិទទ្វារបន្ទប់ មិនឲ្យសូម្បីតែសាមណេរចូលទៅ សូម្បីឧបដ្ឋាកអ្នកជិតស្និទ្ធក៏មិនបានឃើញ សមណៈទាំងនេះ រាយមន្តមាយាដែលធ្វើឲ្យមនុស្សវង្វេងញុំាងមនុស្សឲ្យវង្វេងហើយទំពាស៊ី (បានបរិស័ទបរិវារ) បើយើងទាំងឡាយនឹងអាចនាំយកមន្តមាយាដែលធ្វើឲ្យមនុស្សវង្វេងនោះ មកបាន ដោយឧបាយនេះលាភសក្ការៈដ៏ឱឡារិក នឹងមានដល់ពួកយើង ។ តិរ្ថិយសូម្បីម្នាក់ទៀត ក៏បានក្រោកឡើងពោលយ៉ាងនោះដូចគ្នា ។ តិរ្ថិយទាំងអស់ បានមានវាទៈតែម្យ៉ាងដូចគ្នា ។ តអំពីនោះ តិរ្ថិយទាំងអស់និយាយថា អ្នកណានឹងអាចនាំមន្តមាយានោះមកបាន ពួកយើងនឹងតែងតាំងឲ្យជាប្រធានក្នុងលទ្ធិរបស់ពួកយើងទាំងឡាយ ។

លំដាប់នោះ ពួកតិរ្ថិយសួរគ្នាតាំងពីអ្នកនៅចុងក្រោយគេថា លោកអាចទេ ចំណែកច្រើនឆ្លើយថា ខ្ញុំមិនអាច ទើបនាំគ្នាសួរសរភៈបរិព្វាជកថា លោកអាចារ្យ លោកអាចារ្យអាចឬ , គេឆ្លើយថា ការនាំមន្តមាយានេះមក មិនមែនជារឿងធ្ងន់ទេ បើពួកលោកអះអាងតាមពាក្យរបស់ខ្លួន តែងតាំងយើងជាប្រធាន ។ ពួកតិរ្ថិយពោលថា កុំធ្ងន់ចិត្តឡើយលោកអាចារ្យ លោកចូរនាំមន្តមាយាមកចុះ

លោកធ្វើសម្រេចហើយ ពួកខ្ញុំតែងតាំងឲ្យជាប្រធានដោយពិត ។ គេនិយាយថា លោកនឹងនាំមន្តមាយានោះមកបាន មិនមែននឹងនាំមកបានដោយការលួច ឬប្លន់ទេ តែត្រូវធ្វើជាពួកតែមួយនឹងសាវករបស់ព្រះសមណគោតម ។ គឺ ត្រូវសុំព្រះសាវករបស់ព្រះសមណគោតម ធ្វើវត្តបដិបត្តិ ឆាន់អាហារក្នុងបាត្ររបស់សាវកនៃព្រះសមណគោតមទាំងនោះ ទើបនឹងអាចនាំមកបាន កិរិយាដូច្នេះនោះ ពួកលោកពេញចិត្តឬ ។ តិត្ថិយទាំងឡាយឆ្លើយថា លោកចូរធ្វើយ៉ាងណាមួយ នាំមកប្រគល់ឲ្យពួកយើង ។ សរភបរិព្វាជកបានឲ្យសញ្ញាដល់បរិព្វាជកទាំងឡាយថា បើដូច្នោះ លោកទាំងឡាយឃើញខ្ញុំហើយ ត្រូវធ្វើដូចជាមិនឃើញ ហើយក្នុងថ្ងៃទីពីរ ទើបក្រោកឡើងពីព្រឹក ចូលទៅកាន់មហាវិហារ ឈ្មោះថា គិជ្ឈកូដ ក្រាបទៀបជើងភិក្ខុទាំងឡាយ ដែលខ្លួនឃើញហើយ ដោយបញ្ចង្គប្រតិស្ឋាន ភិក្ខុទាំងឡាយនិយាយគ្នាថា បរិព្វាជកពួកដទៃ រឹងត្អឹង កាចសាហាវ តែបរិព្វាជកម្នាក់នេះ ជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា ។ គេពោលថា លោកម្ចាស់ លោកទាំងឡាយបួសហើយក្នុងសំណាក់ដែលសមគួរ ព្រោះដឹង (ល្អ) ហើយ ចំណែកខ្ញុំមិនបានពិចារណា កាលស្ទុះទៅខុសកំពង់ ទើបត្រាច់ទៅខុសក្នុងផ្លូវដែលមិនបាននាំសត្វចេញចាកទុក្ខ ។ ក៏គ្រាគេពោលយ៉ាងនេះហើយ ថ្វាយបង្គំភិក្ខុគ្រប់រូបដែលខ្លួនបានឃើញហើយ ត្រៀមទឹកសម្រាប់ផ្ទូតជាដើមទុក ធ្វើឈើ

ជម្រះធ្មេញឲ្យជាកប្បិយៈ លាងជើង លាបប្រេងឲ្យ បានកត្តដែលនៅសល់ហើយ បរិភោគ ។

ព្រះមហាថេរៈមួយរូប ឃើញគេដោយទំនងនេះ ទើបនិយាយថា បរិ-ញ្ញាជក លោកមានសទ្ធាជ្រះថ្លាហើយ ហេតុអ្វីមិនបួស ។ គេឆ្លើយថា លោកម្ចាស់ដ៏ចម្រើន នរណានឹងឲ្យខ្ញុំបួស ព្រោះពួកខ្ញុំប្រព្រឹត្តខ្លួនជាសត្រូវចំពោះលោកម្ចាស់ទាំងឡាយមកអស់កាលដ៏យូរ ។ ព្រះថេរៈពោលថា បើលោកប្រាថ្នានឹងបួស យើងក៏នឹងបំបួស ហើយបានឲ្យគេបព្វជ្ជា ។ ចាប់ពីវារៈដែលបួសហើយ គេបានធ្វើវត្តបដិបត្តិជានិច្ច ព្រះថេរៈពេញចិត្តក្នុងវត្តបដិបត្តិរបស់គេ មិនយូរក៏ឲ្យគេឧបសម្បទា ។ ក្នុងថ្ងៃឧបសម្បទា លោកចូលទៅក្នុងរោងឧបោសថ ព្រមជាមួយភិក្ខុទាំងឡាយ ឃើញភិក្ខុទាំងឡាយយកចិត្តទុកដាក់ក្នុងព្រះបាតិមោក្ខដោយឧស្សាហ៍ច្រើន ទើបគិតថា ភិក្ខុទាំងនេះ រាយមន្តមាយាដែលធ្វើឲ្យមនុស្សវង្វេងដោយទំនងនេះ ហើយបរិភោគលាភ (បានបច្ច័យពីអ្នកវង្វេងនោះ) ។ ២-៣ ថ្ងៃទៀតប៉ុណ្ណោះ យើងក៏នឹងនាំមកបាន ។ លោកទៅកាន់បរិវេណ ថ្វាយបង្គំព្រះឧបជ្ឈាយ៍ ហើយផ្តើមសួរថា លោកម្ចាស់ ធម៌នេះឈ្មោះអ្វី ។ ព្រះឧបជ្ឈាយ៍ឆ្លើយថា ឈ្មោះថា បាតិមោក្ខ ។ លោកម្ចាស់ បាតិមោក្ខនេះ ជាធម៌ដែលខ្ពង់ខ្ពស់ឬ ។ ត្រូវហើយអាវុសោ សិក្ខានេះនឹងទ្រទ្រង់ទុកបាននូវសាសនធម៌ទាំងអស់ ។

លោកម្ចាស់ បើធម្មសិក្ខានេះ ជាធម៌ដ៏ប្រសើរ ខ្ញុំនឹងរៀនយកធម្មសិក្ខានេះឯងជាមុន ។ ព្រះថេរៈទទួលថា រៀនចុះអាវុសោ លោកកំពុងរៀនហើយ ។ កាលជួបបរិព្វាជកទាំងឡាយ ត្រូវគេសួរថា យ៉ាងណាហើយអាចារ្យ ទើបប្រាប់ថា ពួកលោកកុំបារម្ភឡើយ ២-៣ ថ្ងៃទៀត ខ្ញុំនឹងនាំមកឲ្យ ។ មិនយូរប៉ុន្មានក៏រៀនជរាបចប់ ហើយនិយាយនឹងឧបជ្ឈាយ៍ថា មានត្រឹមតែប៉ុណ្ណោះទេឬ លោកម្ចាស់ ឬសូម្បីយ៉ាងដទៃក៏នៅមាន ។ ព្រះថេរៈឆ្លើយថា មានត្រឹមតែប៉ុណ្ណោះឯងអាវុសោ ។

ក្នុងថ្ងៃស្អែក លោកស្លៀកដណ្តប់តាមប្រក្រតី កាន់បាត្រតាមទំនងដែលធ្លាប់កាន់ ហើយចេញចាកអារាម ឈ្មោះថា គិជ្ឈកូដ ទៅកាន់អារាមរបស់បរិព្វាជក បរិព្វាជកទាំងឡាយឃើញលោកហើយ នាំគ្នាហែហមលោក សួរថា ជាយ៉ាងណាលោកអាចារ្យ ប្រហែលជានឹងមិនអាចនាំយកមាយាមន្ត ដែលធ្វើឲ្យមនុស្សវង្វេងបានទេដឹង ។ លោកឆ្លើយថា កុំបារម្ភឡើយអាវុសោទាំងឡាយ មន្តមាយាដែលធ្វើឲ្យមនុស្សវង្វេង យើងនាំមកបានហើយ តាំងពីនេះទៅ យើងទាំងឡាយនឹងបានលាភ និងសក្ការៈច្រើន លោកទាំងឡាយចូរសាមគ្គីគ្នា កុំឈ្លោះវិវាទគ្នា បរិព្វាជកទាំងឡាយពោលថា លោកអាចារ្យ បើលោករៀនបានមកហើយ ក៏ចូរប្រាប់មន្តមាយាដែលធ្វើឲ្យមនុស្សវង្វេងដល់ពួកខ្ញុំផង ។ លោកសុត្របាតិ-

មោក្ខតាំងពីដើម (រហូតចប់) ។ លំដាប់នោះ បរិព្វាជកទាំងអស់នោះ និយាយគ្នាថា មកចុះលោកដ៏ចម្រើនទាំងឡាយ ពួកយើងនឹងចូលទៅក្នុងព្រះនគរ ពោលទោសរបស់ព្រះសមណគោតម ។ កាលទ្វារក្រុងមិនទាន់បើក នាំគ្នាទៅជិតទ្វារចូលទៅមុននរណាៗ ទាំងអស់ កាលទ្វារបើកហើយ ។ បទថា **បរិព្វាជក ឈ្មោះថា សរភៈ ជាអ្នកសឹកហើយ** (ពីធម្មវិន័យ) **មិនយូរ** ដូច្នេះ លោកពោលសំដៅដល់បរិព្វាជកនោះ ដែលចេញទៅទាំងភេទរបស់ខ្លួន យ៉ាងនេះ ។

ក៏ក្នុងថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ត្រួតមើលសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់បានឃើញហេតុនេះថា ថ្ងៃនេះ សរភបរិព្វាជក នឹងត្រាច់ទៅក្នុងព្រះនគរ ហើយធ្វើបកាសនីយកម្ម កាលគេពោលពាក្យតិះដៀលព្រះរតនត្រ័យ ឈ្មោះថារោយថ្នាំពិសចុះ ហើយទៅកាន់អារាមរបស់បរិព្វាជក សូម្បីតថាគតក៏នឹងទៅក្នុងទីនោះដូចគ្នា បរិស័ទសូម្បីទាំង ៤ នឹងប្រជុំគ្នាក្នុងអារាមរបស់បរិព្វាជកនោះឯងក្នុងសមាគមនោះ នឹងមានមនុស្ស ៨៤.០០០ បានផឹកទឹកអម្រឹត ។ លំដាប់នោះព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា សរភបរិព្វាជកចូរមានឱកាស ចូរប្រកាសទោសតាមពេញចិត្ត ហើយត្រាស់ហៅព្រះអានន្ទត្ថេរមក ត្រាស់បង្គាប់ថា អានន្ទអ្នកចូរទៅប្រាប់ភិក្ខុសង្ឃក្នុងមហាវិហារ ១៨ កន្លែង ឲ្យទៅបិណ្ឌបាតព្រមជាមួយនឹងតថាគត ។ ព្រះថេរៈបានបដិបត្តិដូច្នោះហើយ ។ ភិក្ខុទាំងឡាយ កាន់បាត្រ

ចីវរ ហែហមព្រះតថាគត ។ ព្រះសាស្តាទ្រង់នាំភិក្ខុសង្ឃទៅបិណ្ឌបាត ទីស្រុក ជិតទ្វារព្រះនគរ ។ ចំណែកសរភបរិព្វាជក ក៏ចូលទៅកាន់ព្រះនគរ ព្រមទាំង បរិព្វាជកទាំងឡាយ លុះដល់កណ្តាលចំណោមបរិស័ទ ទ្វារព្រះរាជវាំង ទ្វារផ្ទះ អាមាត្រ និងផ្លូវបែកជា ៤ ជាដើម បានប្រកាសថា ធម៌របស់ពួកសមណ-សក្យបុត្រទាំងឡាយ យើងដឹងអស់ហើយ ដូច្នេះជាដើម ក្នុងទីនោះៗ ។ ពាក្យ មានជាអាទិ៍ថា សរភបរិព្វាជកនោះ ពោលវាចាយ៉ាងនេះ ក្នុងបរិស័ទក្នុងក្រុង រាជគ្រឹះ នេះ លោកពោលសំដៅដល់ការពោលទោសនោះ ។ បណ្តាបទទាំង នោះ ដោយបទថា **អញ្ញាតោ** (យើងដឹងទូទៅហើយ) សរភបរិព្វាជកសម្តែងថា (ធម៌របស់ពួកសមណសក្យបុត្រ) យើងដឹងហើយ គឺ យល់ហើយ បានដល់ រៀនបានជាក់ច្បាស់ហើយ ។ បទថា **អញ្ញាយ** បានដល់ ដឹងហើយ ។ បទថា **អបក្កន្តោ** (សឹក) បានដល់ គេចចេញទៅ ទាំងដែលនៅជាកេទទុំះឯង ។ សរភ-បរិព្វាជកនោះ កាលនឹងសម្តែងសេចក្តីនេះ ទើបពោលយ៉ាងនេះថា ប្រសិនបើ សាសនារបស់ព្រះសមណគោតម នឹងមានសារៈអ្វីខ្លះនោះ យើងក៏នឹងមិនសឹក ចេញដែរ តែសាសនារបស់ព្រះសមណគោតមនោះ គ្មានសារៈ មិនមានខ្លឹមសារ សមណៈទាំងឡាយរាយមាយាមន្ត ដែលធ្វើឲ្យមនុស្សវង្វេង ទំពាស៊ីលាភបច្ច័យ ។

បទថា **អថខោ សម្ពហុលា ភិក្ខូ** (គ្រានោះ ភិក្ខុច្រើនរូប) សេចក្តីថា

គ្រានោះកាលបរិព្វាជកនោះ ពោលយ៉ាងនេះហើយ ភិក្ខុចំណែកអរញ្ញវាសី ៥០០ រូប មិនដឹងថា ព្រះសាស្តាស្តេចទៅបិណ្ឌបាតក្នុងទីឈ្មោះឯណោះ ទើបចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ក្នុងវេលាភិក្ខាចារ ។ បទថា **គ្រានោះ ភិក្ខុច្រើនរូប** នេះ លោកពោលសំដៅដល់ភិក្ខុទាំងនោះ ។ បទថា **អស្សោសុំ** (បានឮ) បានដល់ បានឮហើយ ។ បទថា **យេន ភគវា តេនុបសង្កមឹសុ** (ចូលគាល់ព្រះមានព្រះភាគ) សេចក្ដីថា ចូលទៅដោយតាំងចិត្តថា ពួកយើងនឹងក្រាបទូលរឿងនេះចំពោះព្រះទសពល ។

បទថា **សិប្បិនិយា តីរំ** (ឆ្នេរស្ទឹងសិប្បិនី) បានដល់ ត្រើយស្ទឹងដែលមានឈ្មោះយ៉ាងនេះថា **សិប្បិនិកា** ។ បទថា **អធិវាសេសិ ភគវា តុណ្ហីភាវេន** (ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព) មានអត្ថាធិប្បាយថា ទ្រង់ឲ្យខន្តិប្រព្រឹត្តទៅក្នុងខាងក្នុង ទ្រង់ទទួលដោយចិត្តតែម្យ៉ាង ដោយទ្រង់មិនញាប់ញ័រអង្គ គឺ កាយ និងអង្គ គឺ វាចា ។ ព្រះមានព្រះភាគ លុះទ្រង់ទទួល (ដោយតុណ្ហីភាព) យ៉ាងនេះហើយ ទ្រង់ព្រះតម្រិះតទៅថា ថ្ងៃនេះ តថាគតកាលនឹងទៅកាច់បំបាក់វាទៈរបស់សរភបរិព្វាជក គួរនឹងទៅត្រឹមតែមួយអង្គឯង ឬមានភិក្ខុសង្ឃហែហមទៅផង ។ លំដាប់នោះ ព្រះអង្គទ្រង់សម្រេចព្រះទ័យដូច្នេះថា បើយើងមានភិក្ខុសង្ឃហែហមទៅ មហាជននឹងគិតយ៉ាងនេះថា ព្រះសមណគោ-

តម កាលនឹងចូលទៅកាន់ទីដោះវាទៈ ក៏ត្រូវនាំអ្នកដទៃទៅផង នឹងមិនមានដល់តថាគតឡើយ តថាគតតែម្នាក់ឯងនឹងកាច់បំបាក់វាទៈនោះ ។ម្យ៉ាងទៀត ដែលយើងជាព្រះពុទ្ធ កាច់បំបាក់វាទៈដែលកើតឡើងដល់ខ្លួនក្នុងបច្ចុប្បន្ននេះ មិនជាអស្ចារ្យ ព្រោះក្នុងពេលដែលតថាគតបំពេញពុទ្ធចរិយា បុគ្គលដទៃដែលអាចនាំធុរៈជំនួសតថាគត សូម្បីកើតក្នុងអហេតុកបដិសន្ធិ មិនធ្លាប់មានឡើយ ។ ដើម្បីនឹងញុំាងសេចក្ដីនេះឲ្យជាក់ច្បាស់ គប្បីនាំកណ្ហជាតក (មកសម្ដែងផង) ដូច្នេះ ។

កាលណា មានការងារធ្ងន់ កាលណា ការដើរផ្លូវលំបាក

កាលនោះ ម្ចាស់របស់ក៏នឹងទឹមគោឈ្មោះកណ្ហៈ គោកណ្ហៈ

នោះ នឹងត្រូវនាំធុរៈនោះទៅដោយពិត ។

## រឿងគោកាឡកៈ

ដំណាលមកថា ក្នុងអតីតសម័យ ឈ្មួញរទេះម្នាក់ អាស្រ័យនៅក្នុងផ្ទះរបស់ស្ត្រីជរាម្នាក់ ។ គ្រានោះ មេគោមួយក្បាលរបស់គេ បានកើតកូនក្នុងវេលាយប់ ។ វាកើតបានកូនគោឈ្មោលមួយ ។ ផ្ដើមតាំងពីស្ត្រីចាស់ឃើញកូនគោហើយ ក៏កើតសេចក្ដីស្រឡាញ់ដូចជាកូនរបស់ខ្លួន ។ លុះព្រឹកឡើង បុត្ររបស់ឈ្មួញរទេះពោលថា លោកយាយចូរទទួលតម្លៃឈ្នួលផ្ទះ ។ ស្ត្រីចាស់និយាយថា យើងមិនត្រូវការវត្ថុយ៉ាងដទៃទេ ឯងចូរឲ្យកូនគោមួយក្បាលនេះ ដល់យើង

ចុះ ។ បុត្រឈ្មួញរទេះពោលថា លោកយាយចូរយកវាចុះ ។ ស្ត្រីចាស់ទទួលកូនគោនោះទុកហើយ ឲ្យផឹកទឹកដោះ ឲ្យបបរ និងស្មៅជាដើម បានចិញ្ចឹមរក្សាហើយ ។ កូនគោនោះចម្រើនធំធាត់ឡើង មានរូបរាងធំជំបង សម្បូរណ៍ដោយកម្លាំង និងសេចក្តីព្យាយាម ដល់ព្រមដោយអាចារៈ មានឈ្មោះថា **កាឡកៈ** ។ គ្រាតមក កាលឈ្មួញរទេះម្នាក់ធ្វើដំណើរមកព្រមដោយរទេះ ៥០០ កង់រទេះជាប់នៅកក់ ក្នុងទីទឹកព្រោះ ។ គេព្យាយាមទឹមគោ ១០ ក្បាលខ្លះ ២០ ក្បាលខ្លះ ក៏មិនអាចនឹងអូសទាញរទេះឡើង (ពីកក់) បាន ទើបចូលទៅរកគោកាឡកៈ ពោលថា បាដ៏ចម្រើន យើងនឹងឲ្យរង្វាន់ដល់អ្នក សូមអ្នកឯងជួយទាញរទេះរបស់យើងឡើងផងចុះ ។ កាលពោលយ៉ាងនេះហើយ ក៏នាំគោកាឡកៈនោះទៅ គិតថា គោដទៃនឹងអាចទាញរទេះទៅព្រមជាមួយរទេះនេះ មិនមាន ទើបចងខ្សែភ្ជាប់ត្រង់នឹមរទេះ ហើយទឹមគោកាឡកៈនោះតែឯង គោកាឡកៈទាញរទេះនោះឡើងទៅឈប់នៅលើគោក ។ នាំរទេះទាំង ៥០០ ឡើងទៅបាន ដោយទំនងនេះឯង ។ កាឡកៈនាំរទេះចុងក្រោយឡើងបានហើយ (ពេលគេដោះចេញពីនឹម) ក៏លើកសីសៈឡើងសម្តែងអាការនឿយលំបាក ។ ឈ្មួញរទេះគិតថា គោកាឡកៈនេះកាលអូសរទេះមានប្រមាណប៉ុណ្ណោះ ឡើងមិនធ្លាប់ធ្វើយ៉ាងនេះ ប្រហែលជាវាទារតម្លៃឈ្នួល ដូច្នេះហើយ ទើបចាប់កហាបណៈពីចំនួនរទេះ ដាក់ក្នុងថង់ប្រាក់

៥០០ កហាបណៈ ចងទុកទ្រនំករបស់វា ។ វាមិនព្រមឲ្យអ្នកដទៃចូលជិតខ្លួន ដើរតម្រង់ទៅកាន់ផ្ទះតែម្តង ។ ស្ត្រីចាស់ឃើញហើយ ក៏ស្រាយចេញ ដឹងថា ជាកហាបណៈ ទើបនិយាយថា កូនអើយ ហេតុដូចម្តេចឯងទើបធ្វើយ៉ាងនេះ ឯង កុំយល់ថា ម៉ែនេះនឹងចិញ្ចឹមជីវិតដោយទ្រព្យដែលឯងធ្វើការងារ ហើយនាំមក ឲ្យ ដូច្នេះ ហើយឲ្យគោងូតទឹកដោយទឹកក្តៅ លាបខ្លួនដោយប្រេង ហើយពោល ទូន្មានថា អំពីនេះទៅ កូនកុំធ្វើយ៉ាងនេះទៀត ។

ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ព្រោះថា ក្នុងវេលាដែលយើងបំពេញ ពុទ្ធចរិយា បុគ្គលដទៃឈ្មោះថា អាចនាំធុរៈជំនួសយើង សូម្បីដែលកើតហើយ ក្នុងអហេតុកបដិសន្ធិ មិនធ្លាប់មានឡើយ ដូច្នេះ ទ្រង់សំដៅដល់រឿងដែលធ្លាប់ មានមកនេះឯង ទើបស្តេចទៅតែមួយព្រះអង្គឯង ។ ដើម្បីនឹងសម្តែងរឿងនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **លុះវេលាត្រជាក់ ស្តេចចេញចាកទីសម្ងំ ដូច្នេះ** ។

បណ្តាបទទាំងនោះ បទថា **បដិសល្លានា** (អំពីទីស្ងាត់) សេចក្តីថា ចាក ទីដែលទ្រង់សង្រួមចិត្តពីអារម្មណ៍ទាំងឡាយ ហើយចេញចាកទីសម្ងំ អធិប្បាយ ថា ចេញចាកផលសមាបត្តិ ។ បទថា **តេនុបសង្កមិ** (ស្តេចដល់) សេចក្តីថា កាលបរិព្វាជកទាំងឡាយ ធ្វើប្រកាសនីយកម្មទូទាំងព្រះនគរ ហើយចេញចាកព្រះ

នគរទៅប្រជុំគ្នានៅអារាមរបស់បរិព្វាជក អង្គុយសន្ទនាគ្នាដល់សីហនាទកថាយ៉ាង នេះថា បរិព្វាជកទាំងឡាយសួរថា សរភៈ បើព្រះសមណគោតមស្តេចនឹងមក លោកនឹងធ្វើដូចម្តេច សរភបរិព្វាជកឆ្លើយថា (ខ្ញុំនឹងធ្វើយ៉ាងនេះគឺ) ៖

កាលព្រះ សមណគោតមបន្លឺសីហនាទ ១ ដង ខ្ញុំនឹងបន្លឺ ២ ដង

កាលព្រះសមណគោតម បន្លឺ ២ ដង ខ្ញុំនឹងបន្លឺ ៤ ដង

កាលព្រះសមណគោតម បន្លឺ ៤ ដង ខ្ញុំនឹងបន្លឺ ៥ ដង

កាលព្រះសមណគោតម បន្លឺ ៥ ដង ខ្ញុំនឹងបន្លឺ ១០ ដង

កាលព្រះសមណគោតម បន្លឺ ១០ ដង ខ្ញុំនឹងបន្លឺ ២០ ដង

កាលព្រះសមណគោតម បន្លឺ ២០ ដង ខ្ញុំនឹងបន្លឺ ៣០ ដង

កាលព្រះសមណគោតម បន្លឺ ៣០ ដង ខ្ញុំនឹងបន្លឺ ៤០ ដង

កាលព្រះសមណគោតម បន្លឺ ៤០ ដង ខ្ញុំនឹងបន្លឺ ៥០ ដង

កាលព្រះសមណគោតម បន្លឺ ៥០ ដង ខ្ញុំនឹងបន្លឺ ១០០ ដង

កាលព្រះសមណគោតម បន្លឺ ១០០ ដង ខ្ញុំនឹងបន្លឺ ១.០០០ ដង ដូច្នេះ ព្រះមានព្រះភាគស្តេចចូលទៅហើយ ។

កាលព្រះមានព្រះភាគកាលស្តេចចូលទៅ ទ្រង់ស្លៀកសំពត់ពីរជាន់ដែល គេជ្រលក់ល្អហើយ ទ្រង់ដណ្តប់សុគតមហាចីវរ ស្តេចបានចូលទៅតែមួយព្រះអង្គ

ឯងត្រង់កណ្ដាលព្រះនគរ ដូចព្រះរាជាដែលប្រាសចាកពលនិករ ព្រោះផ្លូវទៅអារាមរបស់បរិព្វាជក នៅកណ្ដាលព្រះនគរ ។ មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយឃើញហើយ នាំគ្នាតាមទៅដោយគិតថា បរិព្វាជកទាំងឡាយ ធ្វើប្រកាសនីយកម្ម ប្រកាសទោសរបស់ព្រះសមណគោតម ប្រហែលជាព្រះអង្គស្ដេចទៅ ដើម្បីឲ្យបរិព្វាជកទាំងនោះ សុខចិត្តព្រមតាម ។ ចំណែកពួកសម្មាទិដ្ឋិកបុគ្គល ក៏នាំគ្នាជាប់តាមទៅ ដោយគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រដាប់បាត្រ និងចីវរ ស្ដេចទៅតែមួយព្រះអង្គឯងប៉ុណ្ណោះ (ប្រហែលជា) ថ្ងៃនេះនឹងមានមហាធម្មសង្គ្រាម ជាមួយសរភបរិព្វាជក សូម្បីពួកយើងទាំងឡាយ ក៏នឹងរួមគ្នាជាសាក្សីក្នុងសមាគមនោះ ។ កាលមហាជនកំពុងមើលទុំះឯង ព្រះបរមសាស្ដាស្ដេចចូលទៅកាន់អារាមរបស់បរិព្វាជកហើយ ។

បរិព្វាជកទាំងឡាយ ឃើញព្រះឆព្វណ្ណរង្សីរបស់ព្រះសម្មាសម្ពុទ្ធ ជាកញ្ចុំចេញពីព្រះវរកាយបាចសាចគ្របដណ្ដប់ ទាំងដើម ប្រគាប និងមែកនៃដើមឈើទាំងឡាយ ទើបនាំគ្នាងើយមើលដោយគិតថា ដែលឈ្មោះថា ឱភាសដទៃបែបនេះ មិនមាន តើនេះជាអ្វីហ្ន៎ ហើយពោលថា ព្រះសមណគោតមកំពុងមក ។ សរភបរិព្វាជកស្ដាប់ដូច្នោះហើយ ក៏អង្គុយឱនមុខ ក្បាលសំយុងចុះចន្លោះជង្គង់ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ គ្រាស្ដេចចូលទៅកាន់អារាមនោះ យ៉ាងនេះ

ហើយ ស្តេចប្រថាប់គង់លើអាសនៈដែលគេក្រាលទុក ។ ពិតហើយ ព្រះតថាគត ទ្រង់ជាបុគ្គលគួរដល់អាសនៈ ព្រោះស្តេចឧប្បត្តិក្នុងត្រកូលដ៏ប្រសើរ លើផែនដី ជម្ពូទ្វីប ។ ក្នុងទីគ្រប់កន្លែង គេនឹងចាត់អាសនៈទុកសម្រាប់ព្រះអង្គដោយចំពោះ ព្រះមានព្រះភាគប្រថាប់គង់លើពុទ្ធាសនៈ ដែលគេក្រាលហើយ យ៉ាងនេះ ។

បទថា **តេ បរិព្វាជកា សរកំ បរិព្វាជកំ ឯតទវោចុំ** (បរិព្វាជក ទាំងឡាយពោលនឹងសរកបរិព្វាជក) សេចក្តីថា បានឮថា កាលព្រះសម្មាសម្ពុទ្ធ ត្រាស់ពាក្យត្រឹមតែប៉ុណ្ណោះជាមួយបរិព្វាជកនោះឯង ភិក្ខុសង្ឃដែលតាមព្រះយុគ- លបាទរបស់ព្រះសាស្តា ក៏មកដល់អារាមរបស់បរិព្វាជក បរិស័ទសូម្បីទាំង ៤ ប្រជុំគ្នាហើយក្នុងបរិព្វាជការាមនុ៎ះឯង ។ លំដាប់នោះ បរិព្វាជកទាំងនោះគិតថា គួរអស្ចារ្យ ដែលព្រះសមណគោតមស្តេចបានមកកាន់សំណាក់របស់ពួកយើង ដែលជាគូពៀរវេរា ជាសត្រូវ ជាអ្នកធ្វើប្រកាសនីយកម្ម ប្រកាសទោស ទូទាំង ព្រះនគរមកហើយ មិនត្រាស់ពាក្យដែលបន្តឲ្យកើតការឈ្លោះវិវាទសូម្បីតែបន្តិច តែត្រឡប់ត្រាស់មធុរកថា ប្រៀបដូចជាស្រោលាបខ្លួនដោយប្រេងដែលស្ងួតទៅហើយ រំងាស់ ១០០ ដង ដូចជាឲ្យផឹកទឹកអម្រឹត ផ្តើមតាំងពីវេលាដែលបានស្តេចមក ហើយ ដូច្នេះ គ្រប់គ្នាទើបបានទូលពាក្យនេះ ស្របតាមព្រះសម្មាសម្ពុទ្ធ ។

បទថា **យាចេយ្យាសិ** (គប្បីសូម) សេចក្តីថា លោកគប្បីសូម គឺ គប្បី

ប្រាថ្នា បានដល់ គប្បីត្រូវការ ។ បទថា **តុណ្ហីភូតោ** (ជាអ្នកស្ងៀម) បានដល់ ដល់ភាពជាបុគ្គលស្ងៀម ។ បទថា **មង្កុភូតោ** (មានមុខសំយុងចុះ) បានដល់ ដល់ការអស់តេជៈ ។ បទថា **បត្តក្ខន្ធោ** (ដាក់.ក) បានដល់ មាន.កឱនចុះ ។ បទថា **អធោមុខោ** (មានមុខជ្រប់) បានដល់ (អង្គុយ) ឱនមុខ ។

បទថា **សម្មាសម្ពុទ្ធស្ស តេ បដិជានតោ** (លោកប្តេជ្ញាថាជាសម្មាសម្ពុទ្ធ) សេចក្តីថា លោកប្តេជ្ញាយ៉ាងនេះថា យើងជាព្រះសម្មាសម្ពុទ្ធ ធម៌ទាំងពួង យើងតថាគតត្រាស់ដឹងហើយ ។ បទថា **ឥមេ ធម្មា អនភិសម្ពុទ្ធា** (ធម៌ទាំងនេះលោកមិនបានត្រាស់ដឹងទេ) សេចក្តីថា ឈ្មោះថា ធម៌ទាំងនេះ ដែលលោកមិនបានត្រាស់ដឹងហើយ ។ បទថា **តត្ថ** (ក្នុងធម៌នោះ) បានដល់ ក្នុងធម៌ដែលសម្តែងទុកទាំងនោះ យ៉ាងនេះថា នៅមិនទាន់បានត្រាស់ដឹង ។

បទថា **អញ្ញេន វា អញ្ញំ បដិចរិស្សតិ** (នឹងត្រូវនិយាយបង្កប់សេចក្តី) សេចក្តីថា ឬនឹងបង្កប់ន័យដោយពាក្យណាមួយ ដោយពាក្យមួយទៀត អធិប្បាយថា ត្រូវសួរយ៉ាងណា នឹងឆ្លើយយ៉ាងដទៃ ។ បទថា **ពហិទ្ធា កថំ អបនាមេស្សតិ** (ចេញក្រៅរឿង) សេចក្តីថា នាំពាក្យក្រៅបញ្ហាមក នាំពាក្យដែលមានខាងដើមចេញ ។ បទថា **អប្បច្ចយំ** (ទាស់ចិត្ត) បានដល់ សេចក្តីមិនត្រេកអរ គឺ អាការមិនពេញចិត្ត ។ បទថា **បាតុករិស្សតិ** (សម្តែងឲ្យប្រាកដ) បានដល់

នឹងធ្វើឲ្យប្រាកដ ។ ក៏ក្នុងបណ្ដាឋានៈ ៣ យ៉ាងនោះ ត្រាស់ទោមនស្សដោយ **អបច្ចយ** ស័ព្ទ ត្រាស់សេចក្ដីក្រោធទុំះឯង បែកប្រភេទជាសេចក្ដីក្រោធខ្សោយ និងសេចក្ដីក្រោធមានកម្លាំង ដោយបទទាំងពីរខាងដើម ។

ព្រះមានព្រះភាគ គ្រាទ្រង់បន្លឺសីហនាទ ដោយវេសារជ្ជករណធម៌ ជាដំបូងយ៉ាងនេះហើយ កាលនឹងទ្រង់បន្លឺសីហនាទដោយវេសារជ្ជករណធម៌ ប្រការទី ២ ជាដើមតទៅទៀត ទើបត្រាស់ពាក្យមានជាអាទិ៍ថា **បរិព្វាជកទាំងឡាយ នរណានឹងគប្បីថាតថាគត** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ** (ទ្រង់សម្ដែងធម៌ដើម្បីប្រយោជន៍ណា) សេចក្ដីថា ចតុរារិយសច្ចធម៌ ដែលព្រះអង្គទ្រង់សម្ដែងហើយ ដើម្បីប្រយោជន៍ដល់មគ្គ ផលណា ។ បទថា **សោ ន និយ្យាតិ** (ប្រយោជន៍នោះមិននាំទៅ) សេចក្ដីថា ធម៌នោះមិននាំទៅ គឺ មិនចូលដល់ (ដើម្បីការរលត់ទុក្ខដោយប្រពៃ) លោកពោលអធិប្បាយថា មិនញុំាងប្រយោជន៍នោះឲ្យសម្រេច ។ បទថា **តក្ករស្ស** (របស់បុគ្គលដែលធ្វើតាម) មានអធិប្បាយថា នៃបុគ្គលដែលធ្វើតាម គឺ អ្នកបំពេញវត្តបដិបត្តិ ។ បទថា **សម្មាទុក្ខក្ខយាយ** (ដើម្បីការរលត់ទុក្ខដោយប្រពៃ) សេចក្ដីថា ដើម្បីការអស់ទៅនៃវដ្ដទុក្ខទាំងអស់ ដោយហេតុ ដោយន័យ ដោយការណៈ ។ម្យ៉ាងទៀត

បទថា **យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ** (លោកសម្ដែងធម៌ដើម្បីប្រយោជន៍ណា) សេចក្ដីថា ធម៌ដែលព្រះអង្គទ្រង់សម្ដែងដើម្បីប្រយោជន៍ណា គឺ ៖

**អសុភកម្មដ្ឋាន** ដើម្បីប្រយោជន៍ដល់ការកម្ចាត់រាគៈ

**មេត្តាភាវនា** ដើម្បីប្រយោជន៍ដល់ការកម្ចាត់ទោសៈ

**សច្ចធម៌ គឺ មរណៈ** ដើម្បីប្រយោជន៍ដល់ការកម្ចាត់មោហៈ

**អានាបានស្សតិ** ដើម្បីប្រយោជន៍ដល់ការកម្ចាត់វិតក្កៈ ។

ក្នុងបទថា **សោ ន និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយ** (ប្រយោជន៍នោះ មិននាំទៅដើម្បីការរលត់ទុក្ខដោយប្រពៃរបស់បុគ្គលដែលធ្វើតាម) មានអធិប្បាយដូច្នេះ ធម៌នោះមិននាំទៅ គឺ មិនចូលដល់ បានដល់ មិនញុំាងប្រយោជន៍ឲ្យសម្រេចដើម្បីការអស់ទៅនៃវដ្ដទុក្ខដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ដោយការណៈ ដល់អ្នកបដិបត្តិធម៌នោះ តាមដែលទ្រង់សម្ដែងទុក ។ បទថា **សេយ្យថាបិ សរភោ បរិព្វាជកោ** (ដូចជាសរភបរិព្វាជកខ្លះ) សេចក្ដីថា គេនឹងអង្គុយដូចសរភបរិព្វាជក ដែលអង្គុយសោកសៅ អស់បដិភាណ ដូច្នោះ ។

កាលព្រះតថាគត ទ្រង់បន្លឺសីហនាទដោយបទទាំង ៣ យ៉ាងនេះហើយ ទ្រង់ត្រឡប់សម្ដែងធម៌ បរិស័ទប្រមាណ ៨៤.០០០ ដែលប្រជុំគ្នាក្នុងទីនោះ បាន

ផឹកទឹកអម្រឹត ។ ព្រះសាស្ដាទ្រង់ជ្រាបថា បរិស័ទផឹកទឹកអម្រឹតហើយ ទើបហោះឡើងកាន់វេហាស៍ ស្ដេចត្រឡប់ទៅ ។ ដើម្បីសម្ដែងខ្លឹមសារនោះ លោកទើបពោលពាក្យមានជាអាទិ៍ថា **គ្រានោះ ព្រះមានព្រះភាគ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **សីហនាទំ** (ព្រះសីហនាទ) បានដល់ ការបន្លឺយ៉ាងប្រសើរ គឺការបន្លឺដែលមិនក្រែងរអែង បានដល់ ការបន្លឺរកអ្នកប្រៀបផ្ទឹមមិនបាន ។ បទថា **វេហាសំ បក្កាមិ** (ស្ដេចត្រឡប់ទៅផ្លូវអាកាស) សេចក្ដីថា ព្រះមានព្រះភាគទ្រង់ចូលចតុត្ថជ្ឈានមានអភិញ្ញាជាបាទ ចេញចាកឈានហើយ ទ្រង់អធិដ្ឋាន ហើយអណ្ដែតឡើងកាន់អាកាសព្រមទាំងភិក្ខុសង្ឃ ក៏គ្រាស្ដេចទៅយ៉ាងនេះហើយ ភ្លាមនោះ ស្ដេចក៏បានប្រថាប់នៅគិជ្ឈកូដមហាវិហារ ។

បទថា **វាចាយ សន្និតោទកេន** (បានយកជន្ទួញគឺវាចា) បានដល់ ជន្ទួញគឺ ពាក្យសម្ដី ។ បទថា **សញ្ឆម្ភរី អកំសុ** (ចាក់ដោត) សេចក្ដីថា បរិព្វាជកទាំងឡាយបានធ្វើការចាក់ដោត គឺ និយាយបន្ទុះបង្អាប់មិនឈប់ អធិប្បាយថា (និយាយ) ចាក់ដោតធ្ងន់ឡើង ។ បទថា **ព្រហារញ្ញេ** គឺ **មហារញ្ញេ** ប្រែថា ក្នុងព្រៃធំ ។ បទថា **សីហនាទំ នទិស្សាមិ** (នឹងបន្លឺសីហនាទ) សេចក្ដីថា ចចកចាស់ឃើញអាការរបស់រាជសីហ៍បន្លឺសីហនាទ ក៏គិតថា រាជសីហ៍នេះ ក៏ជាសត្វតិរច្ឆាន សូម្បីយើងក៏ជាសត្វតិរច្ឆាន រាជសីហ៍មានជើង ៤ សូម្បីយើងក៏

មានជើង ៤ យើងក៏នឹងបន្លឺសីហនាទបានដូចគ្នា ។ ចចកនោះ មិនអាចបន្លឺសីហនាទចំពោះមុខរាជសីហ៍បាន ពេលរាជសីហ៍ចេញទៅរកអាហារ ចចកនោះក៏ផ្ដើមបន្លឺសីហនាទ ។ គ្រានោះ វាក៏បន្លឺសំឡេងចចកទ៉ុះឯងចេញទៅ ។ ដោយហេតុនោះ បរិព្វាជកទើបពោលថា ក៏ស្រែកចេញមកជាសំឡេងចចកទ៉ុះឯង ។ បទថា **ភេរណ្ឌកំ** ជាវេវចនៈរបស់បទថា **សិង្គាលកំ** (ឆ្កែចចក) ទ៉ុះឯង ។ ម្យ៉ាងទៀត លោកអធិប្បាយថា ស្រែកសំឡេងបែក បានដល់ ស្រែកចេញមកជាសំឡេងមិនគួរពេញចិត្ត ។ ដោយការឧបមានេះថា **ឯវមេវ ខោ ត្វំ** (លោកក៏ដូច្នោះដូចគ្នា) បរិព្វាជកទាំងឡាយ ប្រៀបព្រះតថាគតចដូចជារាជសីហ៍ ប្រៀបសរភបរិព្វាជកដូចឆ្កែចចក ។

បទថា **អម្ពកបច្ចរី**[១] (មាន់ញី) បានដល់ កូនមាន់ញី ។ បទថា **បុស្សកររិកំ**[២] **វរិស្សាមិ** (នឹងសង្កត់ឲ្យដូចមាន់ឈ្មោល) សេចក្ដីថា វាឃើញមាន់ធំរងាវ ក៏គិតថា សូម្បីមាន់នេះ ក៏មានជើង ២ ស្លាប ២ សូម្បីយើងក៏មានដូចគ្នា សូម្បីយើងក៏នឹងរងាវយ៉ាងនោះខ្លះ ដូច្នេះ (តែ) វាមិនហ៊ានរងាវចំពោះមុខមាន់ធំ កាលមាន់ធំនោះចៀសចេញទៅហើយ ទើបរងាវ (តែ) ក៏ជាសំឡេងមាន់ញីទ៉ុះឯង ។ ព្រោះហេតុនោះ លោកទើបពោលថា **ស្រែកជាសំឡេងមាន់**

---

(១) បិដកជា អម្ពកមទ្ទី , (២) បុស្សកររិតំ ។

ញ្ញី ដូច្នេះ ។

*បទថា* ***ឧសភោ*** *គឺ* ***គោណោ*** *(គោបា) ។ បទថា* ***សុញ្ញាយ*** *(ទទេ) សេចក្តីថា សូន្យទទេ គឺ វៀរចាកគោបា សម្គាល់ថាខ្លួនចម្រើនបំផុត ។ បទថា* ***គម្ភីរំ នទិតព្វំ បញ្ញតិ*** *(រមែងសម្គាល់ថាស្រែកសំឡេងជ្រាលជ្រៅ) សេចក្តីថា រមែងសម្គាល់សំឡេងស្រែករបស់ខ្លួនថាជ្រាលជ្រៅ ដូចសំឡេងស្រែករបស់គោបា ថាខ្លួនប្រសើរបំផុត ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងនោះអស់ឯង ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថា កេសបុត្តិសូត្រទី ៥[១]

## “មិនឲ្យជឿដោយអាការ ១០ យ៉ាង”

*គប្បីជ្រាបវិនិច្ឆ័យក្នុង កេសបុត្តិសូត្រទី ៥ ដូចតទៅនេះ ៖*

*[៦៧] បទថា **កាលាមានំ និគមោ** (និគមនៃពួកអ្នកស្រុកកាលាមៈ) បានដល់ និគមរបស់ពួកក្សត្រិយ៍ ឈ្មោះថា កាលាមៈ ។ បទថា **កេសបុត្តិយា** (អ្នកនៅក្នុងកេសបុត្ត) បានដល់ អ្នកនៅក្នុងនិគម ឈ្មោះថា កេសបុត្តៈ ។ បទថា **ឧបសង្កមឹសុ** (ចូលគាល់) សេចក្តីថា ឲ្យកាន់យកកេសជ្ជៈមានទឹកដោះថ្លា ទឹកដោះខាប់ជាដើម និងទឹកបាន ៨ យ៉ាង ចូលទៅគាល់ ។*

*បទថា **សកំយេវ វាទំ ទីបេន្តិ** (សម្តែងតែពាក្យរបស់ខ្លួន) សេចក្តីថា ពោលតែលទ្ធិរបស់ខ្លួនទុំះឯង ។ បទថា **ជោតេន្តិ** បានដល់ ប្រកាស ។ បទថា **ខុំសេន្តិ** (ជំទាស់) បានដល់ និយាយបៀតបៀន ។ បទថា **វម្ភេន្តិ** (គ្របសង្កត់) បានដល់ និយាយមើលងាយ ។ បទថា **បរិភវន្តិ** (និយាយបន្អាប់បន្ថោក) បានដល់ ធ្វើឲ្យអាក្រក់ ។ បទថា **ឱបបក្ខឹ ករោន្តិ** (ពាក្យសំដីដែលជាបដិបក្ខ) បានដល់ ធ្វើការលប់លាង គឺ លើកចោល ។ បទថា **អបរេបិ ភន្តេ** សេចក្តីថា បានឮមកថា ស្រុកនោះតាំងនៅត្រង់មាត់ព្រៃ ព្រោះដូច្នោះ សមណព្រាហ្មណ៍ទាំង*

---

*(១) បិដក កាលាមសូត្រ ។*

ឡាយ ចូលព្រៃទៅក្តី មានបំណងនឹងត្រឡប់ទៅកាន់ព្រៃក្តី ត្រូវសម្រាកក្នុងស្រុក នោះ ។ សូម្បីបណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកដែលមកដល់មុន នឹងសម្តែង លទ្ធិសាសនារបស់ខ្លួន ហើយចៀសចេញទៅ ពួកដែលមកខាងក្រោយ ក៏សម្តែង លទ្ធិសាសនារបស់ខ្លួនថា សមណព្រាហ្មណ៍ទាំងនោះនឹងដឹងអ្វី គេទាំងនោះជា អន្តេវាសិករបស់ពួកយើង រៀនសូត្រសិល្បៈខ្លះក្នុងសំណាក់របស់យើង ដូច្នេះ ហើយក៏ចេញទៅ ។ អ្នកស្រុកកាលាមៈទាំងឡាយ មិនអាចនឹងកាន់យក សូម្បី ក្នុងលទ្ធិណាមួយបាន ។

អ្នកស្រុកកាលាមៈទាំងនោះ សម្តែងសេចក្តីនេះហើយ ទើបក្រាបទូល ព្រះមានព្រះភាគយ៉ាងនេះ ហើយពោលពាក្យជាដើមថា **តេសំ នោ ភន្តេ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ហោតេវ កង្ខា** (មានសេចក្តីសង្ស័យ) សេចក្តីថា (ខ្ញុំព្រះករុណាទាំងឡាយ) មានសេចក្តីងឿងឆ្ងល់ពិតៗ ។ បទថា **វិចិកិច្ឆា** ជា វេវចនៈរបស់ **កង្ខា** នុ៎ះឯង ។ បទថា **អលំ** បានដល់ គួរហើយ ។

បទថា **មា អនុស្សវេន** (កុំប្រកាន់ដោយគ្រាន់តែឮស្តាប់តាមគ្នា) បានដល់ កុំទាន់ជឿ សូម្បីដោយពាក្យតាមដែលបានស្តាប់មក ។ បទថា **មា បរម្បរាយ** (កុំប្រកាន់តាមពាក្យតៗ គ្នាមក) បានដល់ កុំទាន់ជឿសូម្បីដោយពាក្យដែលនាំ តៗ គ្នាមក ។ បទថា **មា ឥតិកិរិយា** (កុំប្រកាន់ដោយបានឮថាដូច្នេះ) បានដល់ កុំ

ប្រកាន់ជឿសេចក្ដីដំណាលមកថា បានឮថាសេចក្ដីនេះដូច្នេះ ។ បទថា **មា បិ-ដកសម្បទានេន** (កុំប្រកាន់ដោយអាងក្បួនតម្រា) បានដល់ កុំទាន់ជឿថា សេចក្ដីនេះ សមនឹងតម្រារបស់យើងខ្ញុំ ។ បទថា **មា តក្កហេតុ** (កុំប្រកាន់តាមហេតុដែលត្រិះរិះ) បានដល់ កុំទាន់ជឿស្ដីជោយការកាន់យកតាមដែលត្រិះរិះ ។ បទថា **មា នយហេតុ** (កុំប្រកាន់ដោយកាត់ជុំរួយផ្សេងៗ) បានដល់ កុំទាន់ជឿស្ដីដោយការកាន់យកតាមន័យ ។ បទថា **មា អាការបរិវិតក្កេន** (កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ) បានដល់ កុំទាន់ជឿស្ដីដោយការត្រិះរិះតាមហេតុការណ៍យ៉ាងនេះថា ហេតុនេះល្អ ។ បទថា **មា ទិដ្ឋិនិជ្ឈានក្ខន្តិយា** (កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យ សមនឹងសេចក្ដីយល់ឃើញ) បានដល់ កុំទាន់ជឿថាប្រការនេះសមជាមួយលទ្ធិ ដែលពួកយើងពិចារណាឃើញត្រូវហើយ ទើបកាន់យក ។ បទថា **មា ភព្វរូបតាយ** (កុំប្រកាន់ដោយយល់មានសភាពគួរ (ជឿ) បានដល់ កុំទាន់ជឿដោយគិតថា ភិក្ខុនេះសមរម្យ គួរជឿពាក្យរបស់ភិក្ខុនេះបាន ។ បទថា **មា សមណោ នោ គរុ** (កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង បានដល់ កុំទាន់ជឿថា សមណៈរូបនេះជាគ្រូរបស់យើង គួរជឿតាមពាក្យរបស់សមណៈរូបនេះបាន ។

បទថា **សមត្តា** (ពេញលេញ) បានដល់ បរិបូរ ។ បទថា **សមាទិន្នា**

(សមាទាន) បានដល់ ដែលកាន់យកហើយ គឺ ស្ទាបអង្អែលហើយ ។ បទថា **យំ តស្ស ហោតិ** (វត្ថុណាប្រព្រឹត្តទៅ...ដល់បុគ្គលដទៃនោះ) សេចក្តីថា ហេតុណាមានដល់បុគ្គលនោះ ។ កុសលមូលទាំងឡាយ មានអលោភៈជាដើម គប្បីជ្រាបដោយអំណាចនៃធម៌ដែលជាបដិបក្ខចំពោះលោភៈជាដើម ។ ព្រះមានព្រះភាគត្រាស់បុព្វភាគនៃមេត្តាដោយបទមានជាអាទិ៍ថា **ប្រាសចាកសេចក្តីលោភ** ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងត្រាស់កម្មដ្ឋាន មានមេត្តាជាដើម ទើបត្រាស់ពាក្យមានជាអាទិ៍ថា **ប្រកបដោយមេត្តា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទណាគប្បីពោលដោយន័យនៃកម្មដ្ឋានកថា និងភាវនាបធាន ឬដោយអដ្ឋកថានៃព្រះបាលី ពាក្យទាំងអស់នោះ ខ្ញុំបានពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គនោះហើយ ។

បទថា **ឯវំ អវេរចិត្តោ** (មានចិត្តរកពៀរមិនបានយ៉ាងនេះ) សេចក្តីថា ឈ្មោះថា មានចិត្តរកពៀរវេរាមិនបាន ព្រោះមិនមានទាំងពៀរដែលជាអកុសល ទាំងបុគ្គលជាគូនៃពៀរវេរា ។ បទថា **អព្យាបជ្ឈចិត្តោ** (មានចិត្តរកសេចក្តីបៀតបៀនមិនបាន) សេចក្តីថា ឈ្មោះថា មានចិត្តរកទុក្ខមិនបាន ព្រោះមិនមានចិត្តក្រោធខឹង ។ បទថា **អសង្កិលិដ្ឋចិត្តោ** (មានចិត្តមិនសៅហ្មង) សេចក្តីថា ឈ្មោះថា អ្នកមានចិត្តមិនសៅហ្មង ព្រោះមិនមានកិលេស ។ បទថា **វិសុទ្ធចិត្តោ** (មានចិត្តបរិសុទ្ធហើយ) មានអធិប្បាយថា ឈ្មោះថា មានចិត្តបរិសុទ្ធិ ព្រោះមិន

មានមន្ទិល គឺ កិលេស ។ បទថា **តស្ស** បានដល់ ព្រះអរិយសាវកនោះ គឺបែបនោះ ។ បទថា **អស្សាសា** (សេចក្តីធូរចិត្ត) បានដល់ ជាទីអាស្រ័យ គឺធម៌ជាទីពឹង ។

បទថា **សចេ ខោ បន អត្ថិ បរោ លោកោ** (បើលោកខាងមុខមាន) សេចក្តីថា ប្រសិនបើលោកដទៃ ក្រៅអំពីលោកនេះ មានដែរ ។ បទថា **ឋាន-មេតំ យេនាហំ កាយស្ស ភេទា ។បេ។ ឧបជ្ជិស្សាមិ** (សេចក្តីនេះ ជាឋានៈដែលប្រព្រឹត្តទៅបាន ។ល។ ព្រោះកាយបែកធ្លាយ យើងនឹងចូលដល់... សេចក្តីថា ការដែលយើងនឹងចូលដល់សុគតិលោកសួគ៌ ក្រោយពីស្លាប់ហើយ ព្រោះកាយបែកធ្លាយទៅ ជាហេតុដែលមានបាន ដូច្នោះ ។ ក្នុងគ្រប់ៗ បទ គប្បីជ្រាបន័យដូចដែលពណ៌នាមកនេះ ។ បទថា **អនីឃំ** (មិនមានទុក្ខ) បានដល់ មិនមានទុក្ខ (និទ្ទុក្ខំ) ។ បទថា **សុខី** (មានសុខ) បានដល់ ដល់ហើយនូវសេចក្តីសុខ ។ បទថា **ឧភយេនេវ វិសុទ្ធមត្តានំ សមនុបស្សាមិ** (យើងពិចារណាឃើញខ្លួនជាបុគ្គលបរិសុទ្ធិទាំងពីរចំណែក) សេចក្តីថា យើងនឹងពិចារណាឃើញខ្លួនឯងជាអ្នកបរិសុទ្ធិដោយហេតុទាំងពីរនេះ គឺ យើងមិនបានធ្វើបាប ១ សូម្បីកាលបុគ្គលធ្វើបាបមានហើយ , បាបមិនឈ្មោះថាយើងបានធ្វើ ១ ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយទាំងនោះឯង ។

ចប់អដ្ឋកថា កាលាមសូត្រទី ៥

# អដ្ឋកថា សាឡ្ហសូត្រទី ៦

## *“មិនឲ្យជឿដោយអាការ ១០ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាឡ្ហសូត្រទី ៦ ដូចតទៅនេះ ៖*

[៦៨] *បទថា* **មិគារនត្តា** *(ជាចៅរបស់មិគារសេដ្ឋី) បានដល់ (សាឡ្ហៈ) ជាចៅប្រុសរបស់មិគារសេដ្ឋី ។ បទថា* **ខេណិយនត្តា**[១] *(ជាចៅប្រុសរបស់ខេណិយសេដ្ឋី) ។ បទថា* **ឧបសង្កមឹសុ** *(ចូលទៅរក) សេចក្ដីថា ចៅទាំងពីរទទួលទានអាហារព្រឹកហើយ មានទាសៈ និងកម្មករហែហម ចូលទៅរកហើយ ។ បានឮថា វេលាព្រឹកមុនអាហារ នៅផ្ទះរបស់ចៅសេដ្ឋីទាំងពីរនោះ មានបញ្ហាមួយ តែមិនមានឱកាសនឹងដោះស្រាយបញ្ហានោះបាន ។ គេទាំងពីរគិតថា យើងនឹងស្ដាប់បញ្ហានោះ ទើបទៅកាន់សំណាក់របស់ព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយនៅស្ងៀម ។*

*ព្រះថេរៈដឹងចិត្តរបស់គេទាំងនោះថា គេមកដើម្បីស្ដាប់បញ្ហាដែលកើតឡើងក្នុងផ្ទះនោះ ដូច្នេះ កាលនឹងផ្ដើមនិយាយគ្នាដល់បញ្ហានោះឯង ទើបពោលពាក្យមានជាអាទិ៍ថា* **សាឡ្ហៈ និងរោហណៈ អ្នកទាំងឡាយមកចុះ** *ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា* **អត្ថិ លោភោ** *(សេចក្ដីលោភ មានឬ) សេចក្ដីថា*

---

*(១) បិដក : បេខុណិយនត្តា ។*

ព្រះនទ្ធកត្ថេរ សួរថា ឈ្មោះថា សេចក្តីលោភ មានការចង់បានជាលក្ខណៈ មានដែរឬ ។ បទថា **អភិជ្ឈាតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ** (សាឡ្ហៈ និងរោហណៈ សេចក្តីនេះយើងពោលថា) សេចក្តីថា ព្រះនទ្ធកត្ថេរ កាលនឹងសម្តែងសេចក្តីនៃបញ្ហាទីតាំងឡើង ទើបពោលថា យើងពោលសេចក្តីនេះ ពោលគឺសេចក្តីលោភ ថាជា **អភិជ្ឈា** ថាជា **តណ្ហា** ដូច្នេះ ។ គួរនាំន័យនេះទៅប្រើគ្រប់ៗ វារៈ យ៉ាងនេះ ។

បទថា **សោ ឯវំ បជានាតិ** (លោកដឹងច្បាស់យ៉ាងនេះ) សេចក្តីថា ព្រះអរិយសាវកនោះ ចម្រើនព្រហ្មវិហារ ៤ តាំងនៅហើយ ចេញចាកសមាបត្តិកាលផ្តើមវិបស្សនា រមែងដឹងច្បាស់យ៉ាងនេះ ។ បទថា **អត្ថិ ឥទំ** (ធម្មជាតិនេះ មានហើយ) សេចក្តីថា ទុក្ខសច្ចៈមានហើយ ព្រះអរិយសាវកនេះ កាលកំណត់ដឹងខន្ធបញ្ចកៈ ពោលគឺ ទុក្ខសច្ច ដោយអំណាចនៃនាមរូប ទើបដឹងច្បាស់យ៉ាងនេះ លោកហៅថា ធម្មជាតិនេះ មានហើយ ។ បទថា **ហីនំ** (ធម្មជាតិថោកទាប) បានដល់ សមុទយសច្ច ។ បទថា **បណីតំ** (ធម្មជាតិប្រណីត) បានដល់ មគ្គសច្ច ។ បទថា **ឥមស្ស សញ្ញាគតស្ស ឧត្តរឹ និស្សរណំ** (ធម្មជាតិជាទីរលាស់ចេញដ៏ក្រៃលែងនៃសញ្ញានេះ) សេចក្តីថា ព្រះនទ្ធកត្ថេរ សម្តែងនិរោធសច្ច ដោយពាក្យនេះថា ឈ្មោះថា ធម្មជាតិជាទីរលាស់ចេញដ៏ក្រៃលែងនៃ

សញ្ញា ពោលគឺ វិបស្សនាសញ្ញានេះ ឈ្មោះថា និព្វាន និព្វាននោះមានហើយ ។

បទថា **វិមុត្តស្មឹ វិមុត្តមិតិ ញាណំ** (កាលចិត្តរួចផុតហើយ ក៏មានញាណដឹងថា រួចផុតហើយ) សេចក្ដីថា បច្ចវេក្ខណញ្ញាណ ១៩ យ៉ាង លោកពោលទុកហើយ ។ បទថា **អហុ បុព្វេ លោភោ** (កាលអំពីមុន យើងមានលោភៈ) សេចក្ដីថា សេចក្ដីលោភរបស់យើងមានហើយក្នុងកាលមុន ។ បទថា **តទហុ អកុសលំ** (សេចក្ដីនោះជាការមិនល្អ) សេចក្ដីថា ធម្មជាតិនោះ បានឈ្មោះថា ជាអកុសល ។ម្យ៉ាងទៀត ឈ្មោះថា អកុសល មានហើយក្នុងកាលនោះ ។ បទថា **ឥច្ចេតំ កុសលំ** កាត់បទជា **ឥតិ ឯតំ កុសលំ** (យ៉ាងនេះជាកុសល) ។ ព្រះនន្ទកត្ថេរ ពោលសំដៅយកការមិនមាននៃអកុសលនុ៎ះឯង ថាជាកុសល គឺជាដែនក្សេម ។

បទថា **និច្ឆាតោ** (មិនមានសេចក្ដីស្រេកឃ្លាន) បានដល់ អស់តណ្ហា ។ បទថា **និព្វុតោ** (រលត់ស្ងប់) សេចក្ដីថា ឈ្មោះថា រលត់ស្ងប់ ព្រោះមិនមានកិលេសដែលធ្វើសេចក្ដីក្ដៅក្រហាយក្នុងខាងក្នុង ។ បទថា **សីតិភូតោ** (ត្រជាក់) បានដល់ ជាអ្នកមានសេចក្ដីត្រជាក់ជាប្រក្រតី ។ បទថា **សុខបដិសំវេទី** (សោយសុខ) បានដល់ ជាអ្នកសោយសុខផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ព្រហ្មភូតេន** គឺ **សេដ្ឋភូតេន** (ជាបុគ្គលប្រសើរបំផុត) ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយ

ទាំងអស់នោះឯង ។

ចប់អដ្ឋកថា សាឡ្ហសូត្រទី ៦

# អដ្ឋកថា កថាវត្ថុសូត្រទី ៧

## "ពាក្យដែលគួរពោល ៣ យ៉ាង"

*គប្បីជ្រាបវិនិច្ឆ័យក្នុង កថាវត្ថុសូត្រទី ៧ ដូចតទៅនេះ ៖*

*[៦៩] បទថា **កថាវត្ថូនិ** (កថាវត្ថុ) បានដល់ ហេតុដែលឲ្យកើតកថា អធិប្បាយថា ជាឫសគល់ គឺ ជាទីតាំងនៃកថា ។ បទថា **អតីតំ វា ភិក្ខវេ អទ្ធានំ** (ម្នាលភិក្ខុទាំងឡាយ... វេលាដែលជាអតីត) សេចក្ដីថា កាលក្ដី ខន្ធក្ដី ឈ្មោះថា អតីតទ្ធា (កាលដ៏វែងឆ្ងាយដែលកន្លងមកយូរហើយ) ក៏គួរ ។ សូម្បីក្នុងអនាគត និងបច្ចុប្បន្ន ក៏មានន័យតែម្យ៉ាងដូចគ្នា ។*

*ក្នុងបណ្ដាកាលទាំង ៣ នោះ បើនិយាយដោយន័យនេះថា ព្រះសម្មាសម្ពុទ្ធព្រះនាមថា កស្សបៈ មានហើយក្នុងអតីត ព្រះបាទក្រុងកាសីទ្រង់ព្រះនាមថា កិកិ្ក បានជាអគ្គឧបដ្ឋាករបស់ព្រះអង្គ ព្រះអង្គទ្រង់មានព្រះជន្មាយុវែង រហូតដល់ ២០.០០០ ឆ្នាំ ដូច្នេះ ឈ្មោះថា ពោលកថាប្រារព្ធអតីត ។*

*កាលពោលដោយន័យនេះថា ព្រះពុទ្ធព្រះនាមថា មេត្តេយ្យ នឹងមានក្នុងអនាគត ព្រះរាជាព្រះនាមថា សង្ខៈ នឹងជាអគ្គឧបដ្ឋាករបស់ព្រះអង្គ ព្រះអង្គនឹងមានព្រះជន្មាយុ ៨០.០០០ ឆ្នាំ ដូច្នេះ ឈ្មោះថា ពោលកថាប្រារព្ធអនាគត ។*

*កាលពោលដោយន័យមានជាអាទិ៍ថា ក្នុងបច្ចុប្បន្ននេះ ព្រះរាជាព្រះនាម*

ឯណោះ ជាធម្មិកកថា ព្រះអង្គឯណោះក៏ជាធម្មិកកថា ដូច្នេះ ឈ្មោះថា ពោលកថាប្រារព្ធបច្ចុប្បន្ន ។

បទថា **កថាសម្បយោគេន** (ដោយការប្រកបពាក្យសំដី) បានដល់ ដោយការប្រជុំពាក្យសំដី (ការសន្ទនាគ្នា) ។ បទថា **កច្ឆោ** (គួរសន្ទនា) បានដល់ គួរដើម្បីនឹងពោល ។ បទថា **អកច្ឆោ** (មិនគួរសន្ទនា) សេចក្តីថា មិនគួរដើម្បីនឹងពោល ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **ឯកំសព្យាករណីយំ បញ្ហំ** ដូចតទៅនេះ ៖

បុគ្គលត្រូវសួរថា ចក្ខុមិនទៀងឬ គួរឆ្លើយតែមួយចំណែកថា ត្រូវហើយ ចក្ខុ មិនទៀង ។ ក្នុងឥន្ទ្រិយទាំងឡាយ មានសោតៈជាដើម ក៏មានន័យនេះដូចគ្នា ។ នេះឈ្មោះថា **ឯកំសព្យាករណីយបញ្ហា** (បញ្ហាដែលគប្បីឆ្លើយត្រង់ៗ) ។

តែបើត្រូវសួរថា ចក្ខុ ឈ្មោះថា មិនទៀងឬ ក៏គួរចែកចម្លើយយ៉ាងនេះថា មិនមែនចក្ខុតែម្យ៉ាងដែលមិនទៀង សូម្បីសោតៈក៏មិនទៀង សូម្បីឃានៈក៏មិនទៀង នេះឈ្មោះថា **វិភជ្ជព្យាករណីយបញ្ហា** (ជាបញ្ហាដែលនឹងត្រូវចែកចម្លើយ) ។

បុគ្គលត្រូវសួរថា សោតៈដូចគ្នានឹងចក្ខុ ចក្ខុដូចគ្នានឹងសោតៈឬ គួរសួរ

ថា លោកសួរដោយន័យដូចម្ដេច ។ បើគេឆ្លើយថា យើងសួរសំដៅដល់ការឃើញ ត្រូវឆ្លើយថា មិនដូចគ្នា ។ តែបើគេឆ្លើយថា ខ្ញុំសួរសំដៅដល់សេចក្ដីមិនទៀង ក៏គួរឆ្លើយថា ដូចគ្នា នេះឈ្មោះថា **បដិបុច្ឆាព្យាករណីយបញ្ហា** (បញ្ហាដែលត្រូវសួរហើយ ទើបឆ្លើយ) ។

តែបើត្រូវសួរបញ្ហាជាដើមថា ជីវិតនោះ ក៏គឺសរីរៈនោះឬ ។ គួរឈប់ដោយនិយាយថា ប្រការនេះ ព្រះមានព្រះភាគទ្រង់មិនព្យាករណ៍ បញ្ហាបែបនេះ ជាបញ្ហាដែលមិនគួរឆ្លើយ នេះឈ្មោះថា **ឋបនីយបញ្ហា** (បញ្ហាដែលគួរឈប់) ។

បទថា **ឋានដ្ឋានេ ន សណ្ឋាតិ** (មិនតាំងនៅក្នុងឋានៈ និងអឋានៈ) សេចក្ដីថា មិនតាំងនៅក្នុងហេតុ ឬក្នុងវត្ថុដែលមិនមែនហេតុ ។ ក្នុងសេចក្ដីនោះ មានន័យដូចតទៅនេះ ក៏សស្សតវាទីបុគ្គល (អ្នកមានលទ្ធិថាទៀង) អាចនឹងគ្រប សង្កត់ឧច្ឆេទវាទីបុគ្គល (អ្នកមានលទ្ធិថាដាច់សូន្យ) ដោយហេតុដែលសមគួរបាន ឧច្ឆេទវាទីបុគ្គលកាលត្រូវគ្របសង្កត់ នឹងសម្ដែងភាពជាសស្សតវាទីបុគ្គល ចេញមកថា ក៏ខ្ញុំនិយាយសេចក្ដីដាច់សូន្យឬ គេឈ្មោះថា មិនអាចឈរនៅក្នុង វាទៈរបស់ខ្លួនបាន ។ កាលឧច្ឆេទវាទីបុគ្គលអាច (គ្របសង្កត់គេ) យ៉ាងនេះ សស្សតវាទីបុគ្គល... កាលបុគ្គលវាទីបុគ្គល (អ្នកមានលទ្ធិថាមានបុគ្គល) អាច (គ្របសង្កត់គេ) សុញ្ញតវាទីបុគ្គល (អ្នកមានលទ្ធិថាសូន្យ)... កាលសុញ្ញតវាទី-

បុគ្គលអាច (គ្របសង្កត់គេ) បុគ្គលវាទីបុគ្គល កាលត្រូវគ្របសង្កត់ នឹងសម្តែងភាពជាសុញ្ញតវាទីបុគ្គល ដោយប្រការដូចពោលមកនេះ រមែងឈ្មោះថា មិនឈរនៅ ទាំងក្នុងឋានៈ និងអឋានៈ ។

ពាក្យថា **បរិកប្បេ ន សណ្ឋាតិ** (មិនតាំងនៅក្នុងការកំណត់ទុក) នេះ បានទាំងក្នុងការសួរបញ្ហា និងការឆ្លើយបញ្ហា ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា ក៏បុគ្គលខ្លះ អួតអាងថានឹងសួរបញ្ហាថា យើងនឹងសួរបញ្ហា ។ គេត្រូវម្នាក់ទៀតនិយាយថា លោកនឹងសួរបញ្ហានេះឬ ដឹងថាគេដឹងហើយ ក៏និយាយថា មិនមែនប្រការនេះ ខ្ញុំនឹងសួរប្រការដទៃ ។ សូម្បីត្រូវសួរបញ្ហា ក៏ងើបឡើងបំណងនឹងឆ្លើយបញ្ហា ថាយើងនឹងឆ្លើយបញ្ហា ។ គេត្រូវបុគ្គលម្នាក់ទៀតនិយាយថា លោកនឹងឆ្លើយបញ្ហានេះឬ ដឹងថាគេដឹងហើយ ក៏និយាយថា មិនមែនប្រការនេះ យើងនឹងឆ្លើយប្រការដទៃ យ៉ាងនេះ ឈ្មោះថា មិនតាំងមាំនៅក្នុងប្រការដែលកំណត់ទុក ។

បទថា **អញ្ញវាទេ ន សណ្ឋាតិ** (មិនតាំងនៅក្នុងវាទៈរបស់អ្នកដទៃ) សេចក្តីថា មិនតាំងមាំក្នុងវាទៈដែលដឹងហើយ គឺ ក្នុងវាទៈដែលជ្រាបហើយ ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា បុគ្គលខ្លះសួរបញ្ហាហើយ បុគ្គលម្នាក់ទៀតនិយាយនឹងគេថា លោកសួរបញ្ហាត្រូវហើយ បញ្ហានេះលោករៀនមកពីណា

ចំណែកបុគ្គលម្នាក់ទៀតសួរបញ្ហា តាមលំនាំដែលនឹងត្រូវសួរទុំះឯង បន្តឲ្យកើតសង្ស័យក្នុងពាក្យសំដីដល់បុគ្គលនោះថា ដែលយើងសួរហើយមិនចំបញ្ហាឬយ៉ាងណា ។ ចំណែកម្នាក់ទៀតដែលត្រូវសួរបញ្ហាហើយ ឆ្លើយបញ្ហាហើយ បុគ្គលដទៃនិយាយចំពោះគេថា លោកឆ្លើយបញ្ហាល្អហើយ លោករៀនបញ្ហាមកអំពីណា ធម្មតាអ្នកដែលត្រូវឆ្លើយបញ្ហា ត្រូវឆ្លើយយ៉ាងនេះ ។ ចំណែកបុគ្គលផ្សេងទៀត សូម្បីដោះស្រាយបញ្ហាតាមលំនាំដែលនឹងត្រូវដោះស្រាយទុំះឯង តែបន្តឲ្យកើតសេចក្ដីសង្ស័យក្នុងពាក្យដល់បុគ្គលនោះថា ដែលយើងឆ្លើយទៅហើយមិនចំបញ្ហាឬយ៉ាងណា ។

បទថា **បដិបទាយ ន សណ្ឋាតិ** (មិនតាំងនៅក្នុងបដិបទា) សេចក្ដីថា មិនតាំងនៅក្នុងវត្តបដិបត្តិ អធិប្បាយថា សួរក្នុងវត្ថុដែលមិនគួរសួរ ដោយមិនដឹងធម្មទំនៀម ។ ក៏ធម្មតាបញ្ហានេះ អ្នកដែលត្រូវគេសួរត្រង់លានចេតិយ មិនគួរឆ្លើយ ។ ក្នុងផ្លូវភិក្ខាចារក្ដី ក្នុងវេលាត្រាច់ទៅបិណ្ឌបាតក្នុងស្រុកក្ដី ក្នុងវេលាអង្គុយលើអាសនៈសាលាក្ដី ក្នុងវេលាអង្គុយទទួលបាយយាគូ និងកត្តក្ដី ក្នុងវេលាអង្គុយឆាន់ក្ដី សូម្បីក្នុងវេលាធ្វើដំណើរទៅកាន់ទីពេលថ្ងៃក្ដី ក៏មិនគួរឆ្លើយដូចគ្នា តែក្នុងវេលាអង្គុយក្នុងទីសម្រាកពេលថ្ងៃ កាលគេសូមឱកាសមុនសួរក៏គួរឆ្លើយ កាលមិនសូមឱកាសហើយសួរ ក៏មិនគួរឆ្លើយ ។ អ្នកសួរដោយមិន

ដឹងធម្មទាំងនៀមនេះ ឈ្មោះថា មិនតាំងមាំនៅក្នុងបដិបទា ។ បទថា **ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ អកច្ឆោ ហោតិ** (ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ បុគ្គលនេះ ជាបុគ្គលមិនគួរសន្ទនា) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលហេតុនេះមានហើយ បុគ្គលនេះឈ្មោះថា មិនគួរនឹងពោល ។

បទថា **ឋានដ្ឋានេ សណ្ឋាតិ** (តាំងនៅក្នុងឋានៈ និងអឋានៈ) សេចក្តីថា សស្សតវាទីបុគ្គលអាចនឹងគ្របសង្កត់ឧច្ឆេទវាទីបុគ្គល ។ ឧច្ឆេទវាទីបុគ្គល សូម្បីត្រូវសស្សតវាទីបុគ្គលគ្របសង្កត់ហើយ ក៏ពោល (បញ្ជាក់) ថា យើងសូម្បីត្រូវលោកគ្របសង្កត់ហើយ ៧ ដង ក៏ស្ថិតនៅជាឧច្ឆេទវាទីទុំះឯង ។ សូម្បីក្នុងសស្សតវាទីបុគ្គល បុគ្គលវាទីបុគ្គល និងសុញ្ញតវាទីបុគ្គល ក៏គប្បីនាំន័យទៅដោយន័យនេះឯង យ៉ាងនេះ ឈ្មោះថា **តាំងនៅក្នុងឋានៈ និងអឋានៈ** ។

បទថា **បរិកប្បេ សណ្ឋាតិ** (តាំងនៅក្នុងប្រការដែលកំណត់ទុក) សេចក្តីថា បុគ្គលខ្លះអួតអាងក្នុងបញ្ហាថា យើងនឹងសួរបញ្ហា កាលត្រូវគេនិយាយថា លោកនឹងសួរបញ្ហាឈ្មោះនេះឬ ។ ក៏ឆ្លើយថា ត្រូវហើយ យើងនឹងសួរបញ្ហាប្រការនេះឯង (សូម្បីត្រូវគេសួរបញ្ហា) ក៏ងើបឡើងបំណងនឹងឆ្លើយបញ្ហាថា យើងនឹងឆ្លើយបញ្ហា កាលត្រូវសួរថា លោកនឹងឆ្លើយបញ្ហាប្រការនេះឬ ។ ក៏និយាយបញ្ជាក់ថា ត្រូវហើយ យើងនឹងឆ្លើយបញ្ហាប្រការនេះឯង យ៉ាងនេះឈ្មោះ

ថា តាំងនៅក្នុងប្រការដែលកំណត់ ។

បទថា **អញ្ញវាទេ សណ្ឋាតិ** (តាំងនៅក្នុងវាទៈអ្នកដទៃ) សេចក្តីថា បុគ្គលខ្លះសួរបញ្ហាហើយ បើមានអ្នកពោលថា លោកសួរបញ្ហាល្អហើយ ធម្មតាអ្នកសួរបញ្ហា គួរសួរយ៉ាងនេះ ដូច្នេះហើយ ក៏ព្រមទទួលមិនឲ្យកើតសេចក្តីសង្ស័យ (ដល់អ្នកដទៃ) ។ សូម្បីឆ្លើយបញ្ហាហើយ កាលបើមានអ្នកនិយាយថា លោកឆ្លើយបញ្ហាល្អហើយ ធម្មតាឆ្លើយបញ្ហា គួរឆ្លើយយ៉ាងនេះ ក៏ព្រមទទួលមិនឲ្យកើតសេចក្តីសង្ស័យឡើង (យ៉ាងនេះឈ្មោះថា តាំងនៅក្នុងវាទៈរបស់អ្នកដទៃ) ។

បទថា **បដិបទាយ សណ្ឋាតិ** (តាំងនៅក្នុងបដិបទា) សេចក្តីថា បុគ្គលខ្លះនិមន្តភិក្ខុឲ្យអង្គុយក្នុងផ្ទះ ថ្វាយបាយយាគូ និងរបស់គួរទំពារជាដើម អង្គុយនៅក្នុងរវាងនោះរហូតសម្រេចកិច្ចភត្ត ទើបនឹងសួរបញ្ហា កាន់យកភេសជ្ជៈ មានទឹកដោះថ្លាជាដើម ទឹកបានៈ ៨ យ៉ាង ឬសំពត់គ្រឿងបិទបាំង ផ្កាឈើ និងរបស់ក្រអូបជាដើម ដើរទៅវិហារ ឲ្យរបស់ទាំងនោះហើយ ចូលកាន់ទីសម្រាកពេលថ្ងៃ សូមឱកាសហើយ ទើបសួរបញ្ហា ។ ពិតហើយ អ្នកសួរបញ្ហាដោយដឹងធម្មទំនៀមយ៉ាងនេះ ឈ្មោះថា តាំងមាំនៅក្នុងបដិបទា លោកនឹងឆ្លើយបញ្ហារបស់គេក៏គួរ ។

បទថា **អញ្ញេនាញ្ញំ បដិចរតិ** (និយាយពាក្យផ្តេសផ្តាស) សេចក្តីថា បន្ទ-

បន្ទប់ពាក្យមួយ ដោយពាក្យមួយទៀត ឬត្រូវសួរបញ្ហាមួយ ក៏ឆ្លើយបញ្ហាមួយផ្សេងទៀត ។ បទថា **ពហិទ្ធា កថំ អបនាមេតិ** (និយាយក្រៅរឿង) សេចក្តីថា កាលយករឿងដទៃមកនិយាយ ឈ្មោះថា នាំរឿងដើមចេញទៅ ក្នុងសេចក្តីនោះមានរឿងដូចតទៅនេះ ។

## រឿងភិក្ខុនិយាយបន្ទៃបន្ទប់ក្រៅរឿង

បានឮមកថា ភិក្ខុទាំងឡាយប្រជុំគ្នា ហើយពោលនឹងភិក្ខុកំលោះមួយរូបថា អាវុសោ លោកត្រូវអាបត្តិឈ្មោះនេះ និងឈ្មោះនេះ ។ ភិក្ខុកំលោះឆ្លើយថា បពិត្រលោកដ៏ចម្រើន ខ្ញុំធ្វើដំណើរទៅនាគទ្វីប ។ ភិក្ខុទាំងឡាយបានពោលថា អាវុសោ ពួកយើងមិនសួរក្នុងរឿងដែលលោកទៅនាគទ្វីប តែពួកយើងសួរលោកថា លោកត្រូវអាបត្តិឬ ។

ភិក្ខុកំលោះ : លោកម្ចាស់ ខ្ញុំទៅនាគទ្វីប ហើយឆាន់ត្រី ។

ភិក្ខុទាំងឡាយ : អាវុសោ រឿងឆាន់ត្រីរបស់លោក ពួកយើងមិនសួរទេ តែគេថាលោកត្រូវអាបត្តិ ។

ភិក្ខុកំលោះ : ករុណាលោកម្ចាស់ ត្រីមិនឆ្អិនល្អ ធ្វើឲ្យខ្ញុំមិនសប្បាយ ។

ភិក្ខុទាំងឡាយ : អាវុសោ លោកសប្បាយ ឬមិនសប្បាយ ពួកយើងមិនទាក់ទងទេ (តែ) លោកត្រូវអាបត្តិ ។

ភិក្ខុកំលោះ : ករុណា ខ្ញុំមិនសប្បាយ រហូតក្នុងកាលនៅក្នុងនាគទ្វីបនោះ ។

ដោយរឿងតាមដែលពោលមកនេះ គប្បីជ្រាបថា ឈ្មោះថា រមែងនិយាយបន្ទែបន្ទប់ទៅក្រៅរឿង ដោយការយករឿងដទៃមកនិយាយជ្រែក ។

បទថា **អភិហរតិ** (និយាយប៉ប៉ាច់ប៉ប៉ោច) សេចក្តីថា និយាយបូរបាច់ដោយនាំយកព្រះសូត្រនេះខ្លះនោះខ្លះ ដូចព្រះតេបិដកតិស្សត្ថេរៈ ។ ដំណាលមកថា កាលមុនភិក្ខុទាំងឡាយប្រជុំគ្នាត្រង់លានមហាចេតិយ ធ្វើកិច្ចរបស់សង្ឃហើយឲ្យឱវាទដល់ភិក្ខុទាំងឡាយ និងសន្ទនាសួរបញ្ហាគ្នា ។ ក្នុងទីប្រជុំនោះព្រះថេរៈរូបនេះ នាំព្រះសូត្រមកពីគម្ពីរនោះៗ ពីព្រះត្រៃបិដក រហូតអស់មួយថ្ងៃ សូម្បីបញ្ហាតែមួយក៏ចប់មិនបាន ។

បទថា **អភិមទ្ទតិ** (សង្កត់សង្កិន) សេចក្តីថា នាំហេតុមកនិយាយសង្កត់សង្កិន ។ បទថា **អនុបជគ្ឃតិ** (និយាយសើចលេង) សេចក្តីថា កាលភិក្ខុរូបដទៃសួរបញ្ហាក្តី ឆ្លើយបញ្ហាក្តី ក៏ទះដៃសើច ដែលជាហេតុឲ្យកើតសេចក្តីសន្ទិះសង្ស័យថា យើងសួរបញ្ហាដែលអ្នកដទៃគេមិនសួរ ឬឆ្លើយបញ្ហាដែលគេមិនឆ្លើយ ។ បទថា **ខលិតំ គណ្ហាតិ** (តាមចាប់កំហុស) សេចក្តីថា ចាប់យកសេចក្តីដែលពោលខុសទៅបន្តិចបន្តួច គឺ លើកទោសថា សេចក្តីនេះ ត្រូវឆ្លើយ

យ៉ាងនេះ កាលនិយាយខុសក្នុង ១ អក្ខរៈ ១ បទ ឬ ១ ព្យញ្ជនៈ ។

បទថា **សឧបនិសោ** (ជាអ្នកមានឧបនិស្ស័យ) បានដល់ មានឧបនិស្ស័យ គឺ មានហេតុផល ។ បទថា **ឱហិតសោតោ** (តាំងចិត្តស្តាប់) បានដល់ ផ្ទៀងត្រចៀក ។ បទថា **អភិជានាតិ ឯកំ ធម្មំ** (រមែងដឹងច្បាស់នូវធម៌ណាមួយ) សេចក្តីថា ដឹងច្បាស់នូវកុសលធម៌ គឺ ដឹងអរិយមគ្គ ។ បទថា **បរិជានាតិ ឯកំ ធម្មំ** (រមែងកំណត់ដឹងនូវធម៌ណាមួយ) សេចក្តីថា កំណត់ដឹងទុក្ខសច្ចៈ ដោយតីរណបរិញ្ញា (ការកំណត់ដឹងដោយការពិចារណា) ។ បទថា **បជហតិ ឯកំ ធម្មំ** (រមែងលះនូវធម៌ណាមួយ) សេចក្តីថា លះធម៌ណាមួយ គឺ អកុសលធម៌ទាំងអស់ ។ បទថា **សច្ឆិករោតិ ឯកំ ធម្មំ** (រមែងធ្វើឲ្យជាក់ច្បាស់នូវធម៌មួយ) សេចក្តីថា ធ្វើធម៌ណាមួយ គឺ អរហត្តផល ឬនិរោធទុក្ខឲ្យប្រចក្ស ។ បទថា **សម្មា វិមុត្តិំ ផុសតិ** (រមែងពាល់ត្រូវវិមុត្តិដោយល្អ) សេចក្តីថា ពាល់ត្រូវវិមោក្ខ គឺ អរហត្តផល ដោយការពាល់ត្រូវដោយញាណ ដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ដោយការណៈ ។

បទថា **ឯតទត្ថា ភិក្ខវេ កថា** (ម្នាលភិក្ខុទាំងឡាយ ការនិយាយគ្នាមានប្រយោជន៍ ដូច្នេះ) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កថាដែលតថាគតសម្តែងទុកថា ដោយការប្រកបពាក្យសំដី (ការសន្ទនា) ដែលមានវិមុត្តិនេះជាប្រយោជន៍

បានដល់ មានការរួចផុតនៃចិត្ត ព្រោះមិនប្រកាន់មាំនេះ ជាឫសគល់ គឺ ជាទីតាំង ជាវត្ថុនៃកថានោះ គប្បីជ្រាបការប្រកបសេចក្តីក្នុងគ្រប់ៗ បទ ដូចពណ៌នាមកនេះ ។ បទថា **ឯតទត្ថា មន្តនា** (ការប្រឹក្សាគ្នាមានវត្ថុនេះជាប្រយោជន៍) សេចក្តីថា ក្នុងបណ្តាបុគ្គលដែលគួរសន្ទនាផង និងបុគ្គលដែលមិនគួរសន្ទនាផង ការប្រឹក្សាជាមួយបុគ្គលដែលគួរសន្ទនាផង សូម្បីនេះក៏មានវិមុត្តិជាប្រយោជន៍ដូចគ្នា ។ បទថា **ឯតទត្ថា ឧបនិសា** (ឧបនិស្ស័យមានវត្ថុនេះជាប្រយោជន៍) សេចក្តីថា សូម្បីការមានឧបនិស្ស័យដែលត្រាស់ទុកយ៉ាងនេះថា អ្នកតាំងចិត្តស្តាប់ ឈ្មោះថា អ្នកមានឧបនិស្ស័យ មានវិមុត្តិនេះជាប្រយោជន៍ដូចគ្នា ។ បទថា **ឯតទត្ថំ សោតាវធានំ** (ការតាំងចិត្តស្តាប់មានវត្ថុនេះជាប្រយាជន៍) សេចក្តីថា សូម្បីការតាំងចិត្តស្តាប់ ព្រមទាំងការមានឧបនិស្ស័យរបស់បុគ្គលនោះ មានវិមុត្តិនេះជាប្រយោជន៍ដូចគ្នា ។ បទថា **អនុបាទា** (ព្រោះមិនប្រកាន់) បានដល់ ព្រោះមិនប្រកាន់មាំដោយឧបាទានទាំង ៤ ។ សេចក្តីរួចផុត គឺ ព្រះអរហត្តផល ឈ្មោះថា ការរួចផុតនៃចិត្ត ។

ព្រោះថា ពាក្យទាំងអស់នេះ ត្រាស់ទុកដើម្បីប្រយោជន៍ដល់អរហត្តផល ព្រោះដូច្នោះ កាលព្រះអង្គទ្រង់សរុបព្រះសូត្រ រួមឲ្យដល់ទីបំផុតដោយព្រះគាថាតទៅ ទើបត្រាស់បទមានជាអាទិ៍ថា **ជនពួកណាក្រោធ** ដូច្នេះ ។ បណ្តាបទទាំង

*ទាំងនោះ បទថា **ក្រោធ** សេចក្ដីថា ទឹងព្រោះសេចក្ដីក្រោធ ពោលគឺ ទាស់ចិត្ត ។ បទថា **សល្លបន្តិ** បានដល់ ការចរចាប្រាស្រ័យគ្នា ។ បទថា **វិនិវិជ្ជា** (ប្រកាន់) បានដល់ ជាបុគ្គលប្រកាន់មាំ ។ បទថា **សមុស្សិតា** (ប្រកាន់ខ្លួន) សេចក្ដីថា លើកកម្ពស់ឡើងដោយការលើកដោយអំណាចមានះ ។ បទថា **អន-រិយគុណមាសជ្ជ** (ប៉ះខ្ទប់គុណឲ្យជាអនារយៈ) សេចក្ដីថា ពោលគុណឲ្យជាអនរិយៈ ។ ប៉ះខ្ទប់សេចក្ដីល្អ អធិប្បាយថា ពោលកថាប៉ះទង្គិចសេចក្ដីល្អ ដែលឈ្មោះថា អនរិយកថា មិនមែនអរិយកថា ។ បទថា **អញ្ញោញ្ញវិវរេសិនោ** (ស្វែងរកកំហុសគ្នាទៅវិញទៅមក) សេចក្ដីថា ស្វែងរកចន្លោះ គឺ កំហុសរបស់គ្នានឹងគ្នា ។ បទថា **ទុព្ភាសិតំ** (ពាក្យខុស) បានដល់ និយាយមិនល្អ ។ បទថា **វិក្ខលិតំ** (ពាក្យភ្លាំងភ្លាត់) បានដល់ និយាយភ្លាំងភ្លាត់បន្តិចបន្តួច ។ បទថា **សម្បមោហំ បរាជយំ** (ការភាន់ច្រឡំ ការបរាជ័យ) សេចក្ដីថា (ត្រេកអរ) ក្នុងការភាន់ច្រឡំ និងការផ្ចាញ់សំដីនៃគ្នានឹងគ្នា ព្រោះនិយាយឲ្យទាស់ចិត្តតិចតួច ។ បទថា **អភិនន្ទន្តិ** (រមែងត្រេកអរ) បានដល់ ពេញចិត្ត ។ បទថា **នាចរេ** សេចក្ដីថា មិនប្រព្រឹត្ត មិននិយាយ ។*

*បទថា **ធម្មដ្ឋប្បដិសំយុត្តា** (ដែលប្រកបដោយសេចក្ដីតាំងនៅក្នុងធម៌) សេចក្ដីថា កថាដែលបុគ្គលតាំងនៅក្នុងធម្មសន្ទនាគ្នា ឈ្មោះថា ធម្មដ្ឋប្បដិសំយុត្តា*

ព្រោះតាំងនៅក្នុងធម៌ផង ប្រកបដោយធម៌នោះផង ។ បទថា **អនុត្តិណ្ណេន មនសា** (មានចិត្តស្ងប់) បានដល់ មានចិត្តមិនរាយមាយ ។ បទថា **អបឡាសោ** (មិនវាយឫកស្មើ) សេចក្តីថា ជាបុគ្គលមិនលើកកម្ពស់ (ដោយការវាយឫកស្មើ ព្រោះប្រកាន់ជាគូប្រជែង) ។ បទថា **អសាហសោ** (មិនរួសរាន់) សេចក្តីថា មិនរួសរាន់ ដោយអំណាចនៃសេចក្តីរួសរាន់ គឺ រាគៈ ទោសៈ និងមោហៈ ។

បទថា **អនុស្សុយ្យាយមានោ** (ន ឧយ្យាយមានោ) (មិនឫស្យា) គឺ មិនឫស្យា ។ បទថា **ទព្ពជ្ជេ នាបសាទយេ** (កាលគេនិយាយខុសក៏មិនរុករាន) សេចក្តីថា មិនរុករាន ក្នុងពាក្យដែលនិយាយខ្លាំងក្លាត់ ។ បទថា **ឧបារម្ភំ ន សិក្ខេយ្យ** (មិននិយាយសង្កត់សង្កិន) សេចក្តីថា មិនសង្កត់សង្កិនតិះដៀលដែលមានលក្ខណៈហួសហេតុ ។ បទថា **ខលិតញ្ច ន គាហយេ** (គេនិយាយកាន់ប្រឡំខ្លះ ក៏មិនប្រកាន់) សេចក្តីថា ពាក្យនិយាយដែលខ្លាំងក្លាត់តិចតួច ក៏មិនប្រកាន់ថា នេះជាកំហុសរបស់គេ ។ បទថា **នាភិហារេ** (មិននិយាយប៉ប៉ាច់ប៉ប៉ោច) បានដល់ មិននិយាយច្រំដែល ។ បទថា **នាភិមទ្ទេ** បានដល់ មិននិយាយសង្កត់សង្កិន ។

ចប់អដ្ឋកថា កថាវត្ថុសូត្រទី ៧

# អដ្ឋកថា តិត្ថិយសូត្រទី ៨

## *“ការផ្សេងគ្នានៃអកុសលមូល ៣”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តិត្ថិយសូត្រទី ៨ ដូចតទៅនេះ ៖*

*[៧០] បទថា **ភគវំមូលកា** (មានព្រះមានព្រះភាគជាមូល) សេចក្តីថា ធម៌ទាំងឡាយ ឈ្មោះថា មានព្រះមានព្រះភាគជាមូល ព្រោះមានព្រះមាន-ព្រះភាគជាដើមហេតុ ។ លោកពោលពាក្យអធិប្បាយទុកដូចតទៅនេះ ថា ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់ពួកខ្ញុំព្រះអង្គទាំងនេះ ដែលព្រះកស្សបសម្មាសម្ពុទ្ធ ឲ្យកើតហើយក្នុងកាលមុន កាលព្រះអង្គបរិនិព្វានហើយ ដែលឈ្មោះថា សមណៈ ឬព្រាហ្មណ៍ដទៃៗ នឹងអាចញុំាងធម៌ទាំងនេះឲ្យកើតឡើង អស់មួយពុទ្ធន្តរមិនមានឡើយ តែធម៌ទាំងនេះរបស់ខ្ញុំព្រះអង្គទាំងឡាយ ដែលព្រះមានព្រះភាគឲ្យកើតឡើងហើយ ខ្ញុំព្រះអង្គទាំងឡាយនឹងដឹងទូទៅដល់ គឺ ត្រាស់ដឹងធម៌ទាំងនេះបាន ដោយអាស្រ័យព្រះមានព្រះភាគ ព្រោះដូច្នោះ បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់ខ្ញុំព្រះអង្គទាំងឡាយ ទើបឈ្មោះថា មានព្រះមានព្រះភាគជាមូល ដោយប្រការដូច្នេះ ។*

*បទថា **ភគវំនេត្តិកា** (មានព្រះមានព្រះភាគជាអ្នកណែនាំ) សេចក្តីថា ព្រះមានព្រះភាគទ្រង់ណែនាំ គឺ ទ្រង់នាំ គឺ តាមណែនាំនូវធម៌ទាំងឡាយ បានដល់*

ការតាំងឈ្មោះធម៌តែមួយយ៉ាងៗ ហើយទ្រង់សម្ដែងតាមសភាវៈ ព្រោះដូច្នោះ ធម៌ទាំងឡាយ ទើបឈ្មោះថា មានព្រះមានព្រះភាគជាអ្នកនាំ ។

បទថា **ភគវំបដិសរណា** (មានព្រះមានព្រះភាគជាទីអាស្រ័យ) សេចក្ដីថា ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ កាលមកកាន់គន្លងនៃព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា រមែងនៅក្នុងព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបឈ្មោះថា មានព្រះមានព្រះភាគជាទីអាស្រ័យ ។ បទថា **រមែងអាស្រ័យ** បានដល់ នៅរួម គឺ នៅប្រជុំ ។ ន័យមួយទៀត ព្រះមានព្រះភាគភាគ កាលទ្រង់តាំងឈ្មោះធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ តែមួយប្រការៗ តាមសេចក្ដីពិត ទើបទ្រង់វិលរឭកដល់ធម៌ទាំងឡាយ ដោយអំណាចនៃការត្រាស់ដឹងរបស់ព្រះអង្គ ដែលទ្រង់ប្រថាប់គង់ត្រង់គល់មហាពោធិ៍ យ៉ាងនេះថា ផស្សៈ (ដូច) មកទូលសួរថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គឈ្មោះអ្វី ។ ត្រាស់ឆ្លើយថា អ្នកឈ្មោះថា ផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ វេទនា... សញ្ញា ... សង្ខារ... វិញ្ញាណ (ដូច) មកទូលសួរថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមានឈ្មោះដូចម្ដេច ។ ត្រាស់ឆ្លើយថា អ្នកឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹងច្បាស់ ព្រោះដូច្នោះ ធម៌ទាំងឡាយទើបឈ្មោះថា **មានព្រះមានព្រះភាគជាទីអាស្រ័យ** ។ បទថា **ភគវន្តំយេវ បដិភាតុ** (សូមជាក់ច្បាស់ដល់ព្រះមានព្រះភាគចុះ) សេចក្ដីថា សេចក្ដីនៃភាសិតនេះ សូម

ប្រាកដដល់ព្រះមានព្រះភាគតែមួយព្រះអង្គចុះ អធិប្បាយថា សូមព្រះអង្គទ្រង់ឯង ចូរត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ ។

បទថា **រាគោ ខោ** (រាគៈ) បានដល់ រាគៈដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃសេចក្តីត្រេកអរ ។ បទថា **អប្បសាវជ្ជោ** (មានទោសតិច) សេចក្តីថា មានប្រការដែលគួរតិះដៀលតិច អធិប្បាយថា មានទោសតិច ដោយទោសទាំង ២ ស្ថាន គឺ ដោយអំណាចនៃទោសដែលជាលោកវជ្ជៈខ្លះ ដោយអំណាចនៃទោសដែលជាវិបាកវជ្ជៈខ្លះ ។ សេចក្តីនេះដូចម្តេច ។ គឺ មាតាបិតា ឲ្យបងនិងប្អូនជាដើម រៀបការនឹងគ្នា ១ ឲ្យពួកកូនទៅចាត់ចែងពិធីរៀបការឲ្យបងប្អូនរបស់កូនគេ ១ ។ រាគៈនេះ មានទោសតិច ព្រោះដែលជាលោកវជ្ជៈប៉ុណ្ណោះ ។ ចំណែករាគៈដែលមានទោសតិច ព្រោះជាវិបាកវជ្ជៈ យ៉ាងនេះគឺ ការបដិសន្ធិក្នុងអបាយ ដែលមានសទារសន្តោសជាមូល រមែងមិនមាន ។

បទថា **ទន្ធវិរាគី** (ក្រសាបរលាប) សេចក្តីថា ក៏រាគៈនេះ កាលនឹងសាបរលាប ក៏នឹងសន្សឹមៗ មិនរួចផុតដោយរហ័ស នឹងជាប់តាមយូរ ដូច (សំពត់) ដែលជ្រលក់ដោយលំអងលាយដោយប្រេង សូម្បីនឹងទៅកាន់កពជទៃ ២-៣ កព ក៏មិនទាន់រួចផុត ព្រោះដូច្នោះ ទើបឈ្មោះថា **ទន្ធវិរាគី** (ក្រសាបរលាប) ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះជាឧទាហរណ៍ ៖

## រឿងស្ត្រីសម្លាប់ប្តី

ដំណាលមកថា បុរសម្នាក់ប្រព្រឹត្តមិច្ឆាចារចំពោះភរិយារបស់បងប្រុស ។ គេបានជាទីស្រឡាញ់របស់ស្ត្រីនោះក្រៃលែងជាងស្វាមីរបស់ខ្លួន ។ នាងនិយាយនឹងគេថា កាលហេតុនេះប្រាកដហើយ ការរិះគន់យ៉ាងធំនឹងមាន អ្នកចូរសម្លាប់បងប្រុសរបស់អ្នកចេញ គេគម្រាមស្ត្រីនោះថា វិនាសហើយ ស្រីថោកទាប នាងកុំនិយាយយ៉ាងនេះទៀត ។ នាងក៏ស្ងៀម កន្លងទៅ ២-៣ ថ្ងៃ ក៏និយាយទៀត ចិត្តរបស់គេក៏ដល់នូវសេចក្តីវង្វេង ។ តពីនោះ ត្រូវនាងរំអុកដល់ ៣ ដង គេទើបនិយាយថា យើងនឹងធ្វើយ៉ាងណា ដើម្បីនឹងបានឱកាស ។ លំដាប់នោះ នាងបានប្រាប់ឧបាយដល់គេថា អ្នកចូរធ្វើតាមដែលខ្ញុំប្រាប់ប៉ុណ្ណោះ ជិតស្រុកមហាកកុធៈ ត្រង់ទីឯណោះមានកំពង់ទឹកមួយ អ្នកចូរកាន់យកកាំបិតដែលមុតទៅពួននៅទីត្រង់នោះ គេក៏បានធ្វើយ៉ាងនោះ ។ ចំណែកបងប្រុសរបស់គេធ្វើការងារក្នុងព្រៃស្រេចហើយ ត្រឡប់ផ្ទះ ។ នាងធ្វើដូចជាមានចិត្តទន់ភ្លន់ជាមួយគេ និយាយថា មកចុះនាយ ខ្ញុំនឹងមើលសីសៈឲ្យ ហើយមើលសីសៈឲ្យគេ និយាយថា សីសៈរបស់នាយស្មោកគ្រោកណាស់ ហើយឲ្យកាកកន្ទួតព្រៃឲ្យគេដោយប្រាប់ថា បងចូរទៅលាងសីសៈត្រង់កំពង់ឈ្មោះឯណោះ ហើយត្រឡប់មក ។ គេទៅកាន់កំពង់តាមដែលនាងប្រាប់ទុំះឯង កក់សក់ដោយកាកកន្ទួតព្រៃ

ហើយជ្រមុជក្នុងទឹក ។ គ្រានោះ ប្អូនប្រុសចេញមកពីចន្លោះដើមឈើ កាប់គេត្រង់.កឲ្យស្លាប់ ហើយត្រឡប់មកកាន់ផ្ទះ ។

បងប្រុស កាលមិនអាចលះបង់សេចក្តីស្នេហាក្នុងភរិយាបាន ទើបទៅកើតជាពស់ទៀវ ក្នុងផ្ទះនោះឯង ។ សូម្បីកាលនាង (ដែលជាភរិយាចាស់) ឈរក្តី អង្គុយក្តី វាក៏ទម្លាក់ខ្លួនចុះមកលើខ្លួន (របស់នាង) ។ តមក នាងទើបឲ្យសម្លាប់ពស់នោះ ដោយយល់ថា ពស់នេះប្រហែលជាប្តីយើង ។ ព្រោះសេចក្តីស្រឡាញ់នាងអ្នកជាភរិយា វាទើបទៅកើតជាកូនសុនខក្នុងផ្ទះនោះទៀត ។ តាំងពីវេលាដែលវាដើរបាន វាក៏រត់តាមក្រោយនាងទៅ សូម្បីនាងចូលព្រៃ វាក៏ជាប់តាមទៅផង មនុស្សទាំងឡាយឃើញនាងហើយ ក៏និយាយចំអកថា ព្រានសុនខចេញទៅហើយ នឹងទៅណា ។ នាងក៏បង្គាប់ឲ្យសម្លាប់វាទៀត ។

សូម្បីសុនខនោះ (ស្លាប់ហើយ) ក៏ទៅកើតជាកូនគោក្នុងផ្ទះនោះទៀត ហើយដើរតាមក្រោយនាងទៅ យ៉ាងនោះដូចគ្នា ។ សូម្បីក្នុងគ្រានោះ មនុស្សទាំងឡាយក៏នាំគ្នានិយាយចំអកថា គោបាលចេញហើយ គោទាំងឡាយនឹងទៅណា ។ នាងក៏បង្គាប់ឲ្យសម្លាប់គោនោះ ក្នុងទីត្រង់នោះ ។ សូម្បីគ្រានោះ គោនោះមិនអាចនឹងកាត់សេចក្តីស្នេហាចំពោះនាងបាន ក្នុងវារៈទី ៤ គេក៏កើតក្នុងផ្ទៃរបស់នាង ហើយរឭកជាតិបាន ។ គេឃើញថា ខ្លួនត្រូវនាងសម្លាប់មក ៤

អត្តភាព តាមលំដាប់ហើយ គិតថា យើងកើតក្នុងផ្ទៃរបស់ស្ត្រីដែលជាសត្រូវ បែបនេះ ។ ចាប់តាំងពីនោះមក ក៏មិនព្រមឲ្យនាងយកដៃប៉ះពាល់បាន ។ បើនាងប៉ះពាល់ខ្លួន គេនឹងស្រែកយំ ។ វេលានោះ មានតែតាគេប៉ុណ្ណោះនឹងលួងគេបាន ។ តមក គេចម្រើនធំធាត់ហើយ តាក៏និយាយថា ចៅអើយ ហេតុអ្វីបានជាឯងមិនព្រមឲ្យម្តាយយកដៃប៉ះពាល់ខ្លួន ពេលម្តាយពាល់ត្រូវខ្លួនចៅឯងឯងនឹងស្រែកយំដោយសំឡេងខ្លាំងៗ ។ គេបានប្រាប់ការប្រព្រឹត្តទៅទាំងអស់នោះ (ដល់ជីតាគេ) ថា លោកតា មនុស្សនេះមិនមែនម្តាយរបស់ខ្ញុំទេ តែជាសត្រូវ ។ ជីតាឱបក្រសោបគេ ហើយក៏យំ និយាយថា ណ្ហើយចុះចៅអើយ រឿងអ្វីពួកយើងនឹងត្រូវមកអាស្រ័យនៅក្នុងទីដូច្នេះ ហើយបាននាំគេចេញពីផ្ទះទៅកាន់វិហារមួយកន្លែង នាំគ្នាបួសនៅក្នុងវិហារនោះ សម្រេចព្រះអរហត្តទាំងពីរនាក់ ។

បទថា **មហាវជ្ជោ** (មានទោសច្រើន) សេចក្តីថា ឈ្មោះថា មានទោសច្រើន ដោយហេតុ ២ ស្ថាន គឺ ដោយអំណាចលោកវជ្ជៈ ១ ដោយអំណាចវិបាកវជ្ជៈ ១ ។ សេចក្តីនេះដូចម្តេច គឺ បុគ្គលដែលទោសៈប្រទូសរ៉ាយហើយ រមែងប្រព្រឹត្តខុសក្នុងមាតាក៏បាន ក្នុងបិតាក៏បាន ក្នុងបងប្អូនប្រុស បងប្អូនស្រីក៏បាន ក្នុងបព្វជិតក៏បាន ក្នុងទីគ្រប់កន្លែងដែលកន្លងទៅ គេនឹងបានពាក្យរិះគន់

យ៉ាងធំថា បុគ្គលនេះប្រព្រឹត្តខុស សូម្បីក្នុងមាតាបិតា សូម្បីក្នុងបងប្អូនប្រុស បងប្អូនស្រី សូម្បីក្នុងបព្វជិត ។ ទោសៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចនៃទោសដែលជាលោកវជ្ជៈ ដូចពណ៌នាមកនេះ ។ តែគេនឹងបានសោយផលក្នុងនរករហូតអស់កប្ប ព្រោះអនន្តរិយកម្មដែលខ្លួនធ្វើទុក ដោយអំណាចទោសៈ ។ ទោសៈ ឈ្មោះថា មានទោសច្រើន ដោយអំណាចនៃទោសដែលជាវិបាក ដូចពណ៌នាមកនេះឯង ។

បទថា **ខិប្បវិរាគី** (សាបរលាបរហ័ស) ប្រែថា អស់ទៅរហ័ស ។ អធិប្បាយថា បុគ្គលដែលត្រូវទោសៈប្រទូសរ៉ាយហើយ ប្រព្រឹត្តខុសក្នុងមាតាបិតាខ្លះ ក្នុងចេតិយខ្លះ ក្នុងពោធិព្រឹក្សខ្លះ ក្នុងបព្វជិតទាំងឡាយខ្លះ គេសូមទោសថា លោកទាំងឡាយចូរអត់ទោសដល់ខ្ញុំ ។ ព្រមដោយការសូមខមាទោសរបស់គេ កម្មនោះនឹងត្រឡប់ក្លាយជាប្រក្រតីភ្លាម ។

ចំណែកមោហៈ ឈ្មោះថាមានទោសច្រើន ព្រោះហេតុ ២ ស្ថាន ដូចគ្នា សេចក្តីនេះដូចម្តេច គឺ បុគ្គលដែលវង្វេងព្រោះមោហៈ នឹងប្រព្រឹត្តខុសក្នុងមាតាបិតាខ្លះ ក្នុងព្រះចេតិយខ្លះ ក្នុងពោធិព្រឹក្សខ្លះ ក្នុងបព្វជិតខ្លះ និងបានទទួលការតិះដៀលក្នុងទីដែលខ្លួនទៅហើយ ។ មោហៈ ឈ្មោះថា មានទោសច្រើនដោយអំណាចនៃទោសដែលជាលោកវជ្ជៈយ៉ាងនេះ ។ តែគេនឹងត្រូវសោយផលក្នុងនរក

*រហូតអស់កប្ប ព្រោះអនន្តរិកម្មដែលគេធ្វើទុកដោយអំណាចមោហៈ ដូច្នោះ មោហៈ ឈ្មោះថា មានទោសច្រើន សូម្បីដោយអំណាចនៃទោសដែលជាវិបាក ដូចពណ៌នាមកនេះឯង ។*

*បទថា* ***ទន្ធវិរាគី*** *(ក្រសាបរលាប) បានដល់ រឿយៗ ទើបអស់ទៅ ។ អធិប្បាយថា កម្មដែលបុគ្គលវង្វេងព្រោះមោហៈធ្វើទុក នឹងសន្សឹមៗ ទើបរួចផុតទៅ ។ ឧបមាដូចជាស្បែកខ្លាឃ្មុំដែលគេជម្រះអស់ ៧ ដង ក៏មិនស្អាតយ៉ាងណា កម្មដែលបុគ្គលវង្វេងហើយព្រោះមោហៈធ្វើ ក៏ដូច្នោះ នឹងមិនរួចផុតទៅរហ័ស គឺ នឹងសន្សឹមៗ ទើបរួចផុត ដូច្នេះឯង ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា តិត្ថិយសូត្រទី ៨

# អដ្ឋកថា មូលសូត្រទី ៩

## *“កុសលមូល និងអកុសលមូល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មូលសូត្រទី ៩ ដូចតទៅនេះ ៖*

*[៧១] មូលនៃអកុសល ឈ្មោះថា **អកុសលមូល** ។ម្យ៉ាងទៀត ធម្មជាតិនោះ ជាអកុសលផង ជាមូលផង ព្រោះដូច្នោះ ទើបឈ្មោះថា **អកុសលមូល** ។ បទថា **យទបិ ភិក្ខវេ លោភោ** ស្មើនឹង **យោបិ ភិក្ខវេ លោភោ** (ម្នាលភិក្ខុទាំងឡាយ សេចក្ដីលោភណានីមួយ) ។ បទថា **តទបិ អកុសលំ** (កម្ម... សូម្បីនោះក៏ជាអកុសល) សេចក្ដីថា កម្មសូម្បីនោះ ជាឫសគល់នៃអកុសល ឬជា (តួ) អកុសលក៏បាន ។ អធិប្បាយថា ក្នុងទីនេះ សូម្បីអកុសលនោះ សំដៅដល់អកុសលមូលនោះក៏គួរ ដូចគ្នា ។ ក្នុងបទទាំងពួង គប្បីនាំន័យនេះ មកដោយឧបាយនេះ ។*

*បទថា **អភិសង្ខរោតិ** (តាក់តែង) សេចក្ដីថា រមែងប្រមូល គឺ រួបរួមមក បានដល់ ធ្វើឲ្យជាគំនរ ។ បទថា **អសតា ទុក្ខំ ឧបទហតិ** (ធ្វើទុក្ខឲ្យកើតឡើង... ព្រោះរឿងដែលមិនពិត) សេចក្ដីថា ធ្វើទុក្ខ ដោយពោលទោសយ៉ាងណានីមួយដែលមិនពិតដល់គេ ដោយរឿងដែលមិនពិត គឺ មិនមាន ។ បទថា **វធេន វា** (ដោយការសម្លាប់) ជាដើម ព្រះមានព្រះភាគត្រាស់ទុក ដើម្បីទ្រង់*

សម្តែងអាការដែលគេបន្តុះបង្អាប់ឡើង ។

បណ្តាបទទាំងនោះ បទថា **ជានិយា** (ដោយការធ្វើឲ្យវិនាសទ្រព្យ) បានដល់ ដោយការធ្វើសេចក្តីសាបសូន្យទ្រព្យ ។ បទថា **បព្វាជនាយ** (ដោយការបំបរបង់) សេចក្តីថា បានដល់ ការបំបរបង់ចេញពីស្រុក ចេញពីព្រៃ ឬចេញពីរដ្ឋ ។ បទថា **ពលវម្ហិ** (អាងកម្លាំង) សេចក្តីថា យើងជាអ្នកមានកម្លាំង ។ បទថា **ពលត្ថោ ឥតិបិ** (ទ្រទ្រង់នូវកម្លាំងក្តី) សេចក្តីថា និយាយថា យើងចម្រើនដោយកម្លាំងខ្លះ យើងទ្រទ្រង់កម្លាំងខ្លះ ។

បទថា **អកាលវាទី** សេចក្តីថា មិននិយាយក្នុងវេលាដែលគួរនិយាយ ឈ្មោះថា និយាយក្នុងវេលាដែលមិនគួរ ។ បទថា **អភូតវាទី** សេចក្តីថា មិននិយាយរឿងពិត ឈ្មោះថា និយាយរឿងមិនពិត ។ បទថា **អនត្ថវាទី** សេចក្តីថា មិននិយាយរឿងដែលជាប្រយោជន៍ ឈ្មោះថា និយាយរឿងមិនជាប្រយោជន៍ ។ បទថា **អធម្មវាទី** សេចក្តីថា មិននិយាយវត្ថុដែលជាធម៌ ឈ្មោះថា និយាយវត្ថុដែលមិនមែនជាធម៌ ។ បទថា **អវិនយវាទី** សេចក្តីថា មិននិយាយវត្ថុដែលជាវិន័យ ឈ្មោះថា និយាយវត្ថុដែលមិនមែនវិន័យ ។

បទថា **តថាហាយំ** កាត់បទជា **តថា ហិ អយំ** ។ បទថា **ន អាតប្បំ ករោតិ តស្ស និព្វេឋនាយ** (មិនព្យាយាមដោះស្រាយសេចក្តីមិនពិតនោះ) សេចក្តី

ថា មិនធ្វើសេចក្តីព្យាយាម ដើម្បីប្រយោជន៍ដល់ការដោះស្រាយរឿងដែលមិនពិតនោះ ។ បទថា **ឥតិបេតំ អតច្ឆំ** សេចក្តីថា វត្ថុនេះមិនពិតដោយហេតុសូម្បីនេះ ។ បទក្រៅពីនេះ (មិនពិត) ជាវេវចនៈរបស់បទថា មិនពិតនោះនុ៎ះឯង ។

បទថា **ទុគ្គតិ បាដិកង្ខា** (មានទុគ្គតិជាទីប្រាកដ) សេចក្តីថា ទុគតិដែលចែកប្រភេទជានរកជាដើម គប្បីសង្ឃឹមបាន អធិប្បាយថា ទុគ្គតិនោះ នឹងត្រូវជាចំណែករបស់គេពិតប្រាកដ គឺ គេនឹងត្រូវកើតក្នុងទុគ្គតិនោះ ។ បទថា **ឧទ្ធ-សោតោ** (រួបរឹតពីខាងលើ) សេចក្តីថា ត្រូវព្ធរជ្រៃរួបរឹតពីខាងលើ ។ បទថា **បរិយោនទ្ធោ** (ព័ទ្ធព័ន្ធ) សេចក្តីថា ត្រូវព្ធរជ្រៃព័ទ្ធព័ន្ធដោយជុំវិញ ។

បទថា **អនយំ អាបជ្ជតិ** បានដល់ ដល់នូវសេចក្តីមិនចម្រើនជំធាត់ ។ បទថា **ព្យសនំ អាបជ្ជតិ** (រមែងដល់នូវសេចក្តីវិនាស) បានដល់ រមែងដល់នូវសេចក្តីវិនាស អធិប្បាយថា ក្នុងរដូវក្តៅ កាលផ្លៃជ្រៃទុំបែកចេញហើយ គ្រាប់ទាំងឡាយនឹងធ្លាក់ទៅត្រង់គល់ដើមជ្រៃជាដើម ក្នុងដើមឈើទាំងនោះ ត្រង់គល់ឈើដើមណាមានគ្រាប់ធ្លាក់ទៅ ៣ គ្រាប់ ក្នុងទិសទាំង ៣ កាលដើមឈើនោះត្រូវភ្លៀងក្នុងរដូវភ្លៀង ក៏ដុះពន្លក ៣ ពន្លក ពីគ្រាប់ទាំង ៣ នឹងដុះឡើងជាប់នឹងដើមឈើនោះ ។ តពីនោះ រុក្ខទេវតាជាដើម ក៏មិនអាចនឹងអាស្រ័យនៅតាម

ចិត្តរបស់ខ្លួនបាន ។ ពន្ធកសូម្បីទាំង ៣ នោះ ដុះលូតលាស់ឡើង ក្លាយជាពួររុំជាប់ដើមឈើនោះ ព័ទ្ធព័ន្ធប្រគាប មែកតូច មែកធំទាំងអស់ រួបរឹតដើមឈើនោះរហូតជិត ។ ដើមឈើនោះត្រូវពួរជ្រៃព័ទ្ធព័ន្ធ ដេរដាស់ទៅដោយពួរជ្រៃ កាលភ្លៀងធ្លាក់ចុះមក ឬខ្យល់បក់ ក៏នឹងបាក់ដួលចុះក្នុងទីនោះៗ នៅសល់តែជន្ទត់ប៉ុណ្ណោះ ។ បទថា ***រមែងដល់នូវសេចក្ដីវិនាស*** នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ដើមឈើនោះ ។

ក៏ក្នុងបទថា ***ឯវមេវ ខោ*** (ដូច្នោះនោះឯង) នេះ មានការប្រៀបធៀបដូចតទៅនេះ ។ ក៏សត្វលោក គប្បីឃើញដូចដើមឈើណានីមួយ អកុសលមូល ៣ គប្បីឃើញដូចពួរជ្រៃ ៣ ដើម ។ វេលាដែលសេចក្ដីលោភជាដើម មិនទាន់ប្រសព្វនឹងទ្វារ គប្បីឃើញដូចការដែលវល្លិ៍ទាំងនោះ រួបរឹតដើមឈើឡើងទៅត្រង់ៗ មិនទាន់ដល់មែកឈើ ។ វេលាដែលសេចក្ដីលោភជាដើម ប្រព្រឹត្តទៅដោយអំណាចនៃទ្វារ គប្បីឃើញដូចវេលាដែលវល្លិ៍វារទៅតាមមែកឈើ ។ វេលាដែលសេចក្ដីលោភជាដើម រួបរឹតចិត្ត គប្បីឃើញដូចវេលាដែលវល្លិ៍រុំព័ទ្ធដើមឈើ ។ វេលាដែលភិក្ខុត្រូវអាបត្តិតូចៗ ដោយអំណាចនៃកិលេសទាំងឡាយដែលមកប្រសព្វត្រង់ទ្វារ គប្បីឃើញដូចវេលាដែលមែកតូចៗ ស្វិតក្រៀមទៅ ។ វេលាដែលភិក្ខុត្រូវគរុកាបត្តិ គប្បីឃើញដូចជាវេលាមែកឈើធំស្វិតក្រៀមទៅ ។

វេលាដែលភិក្ខុត្រូវអាបត្តិបារាជិក ហើយធ្លាក់ចុះទៅក្នុងអបាយទាំង ៤ តាមលំដាប់ គប្បីឃើញដូចវេលាដែលដើមឈើ រលំដួលចុះត្រង់ផែនដី ក្នុងកាលដែលគល់ជោគទៅដោយទឹក ដែលហូរចុះមកតាមវល្លិ៍ ។

ចំណែកធម៌ស (កុសលធម៌) គប្បីជ្រាបដោយន័យផ្ទុយគ្នាដូចពោលមក ហើយចុះ ។ តែក្នុងបទថា **ឯវមេវ ខោ** (ព្រោះហេតុនោះ) នេះ គប្បីជ្រាបការប្រៀបធៀបដូចតទៅនេះ ។ សត្វលោកនេះ គប្បីឃើញដូចដើមឈើណានីមួយ ក្នុងបណ្តាដើមឈើទាំងនោះ ។ **អកុសលមូលទាំង ៣** គប្បីឃើញដូចជាពូរជ្រៃ ៣ ដើម ។ **ព្រះយោគាវចរ** គប្បីឃើញដូចបុរសអ្នកមកធ្វើវល្លិ៍ទាំងនោះឲ្យប្រព្រឹត្តទៅមិនបាន (ជីកវល្លិ៍ចោល) ។ **បញ្ញា** គប្បីឃើញដូចចប ។ បង្គី គឺ **សទ្ធា** គប្បីឃើញដូចជាចប និងបង្គី ។ **ការជីកដោយវិបស្សនា** គប្បីឃើញដូចការជីកដោយចប ។ វេលាដែលព្រះយោគាវចរ **ប្រើវិបស្សនាញាណ កាត់ឫសរបស់អវិជ្ជា** គប្បីឃើញដូចការកាត់ឫសរបស់វល្លិ៍ដោយការជីក ។ វេលាដែលព្រះយោគចឃើញ **(នាមរូប)** ដោយអំណាចនៃខន្ធ គប្បីឃើញដូចវេលាដែលកាត់វល្លិ៍ឲ្យជាកំណាត់តូចកំណាត់ធំ ។ វេលាដែលព្រះយោគាវចរដកកិលេសឡើងបាន **ដោយមគ្គញ្ញាណ** គប្បីឃើញដូចវេលាដែលពុះច្រៀកវល្លិ៍ ។ វេលាដែលបញ្ចក្ខន្ធតាំងនៅ គប្បីឃើញដូចវេលាធ្វើវល្លិ៍ឲ្យជាកម្ទេចផេះ ។ វេលាដែល

*ព្រះយោគាវចរ រំលត់ឧបាទិន្នកក្ខន្ធ ដោយការរំលត់មិនឲ្យមានបដិសន្ធិ ហើយមិនបដិសន្ធិក្នុងភពថ្មី គប្បីឃើញដូចវេលាដែលគេរោយកម្ទេចផេះទៅក្នុងព្យុះធំធ្វើមិនឲ្យកើតទៀត ដូច្នោះឯង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ។*

ចប់អដ្ឋកថា មូលសូត្រទី ៩

# អដ្ឋកថា ឧបោសថសូត្រទី ១០

## *"ឧបោសថ ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបោសថសូត្រទី ១០ ដូចតទៅនេះ ៖*

*[៧២] បទថា* ***តទហុបោសថេ*** *ស្មើនឹង* ***តស្មឹ អហុ ឧបោសថេ*** *គឺ* ***តំទិវសំ ឧបោសថេ*** *(បានដល់ ឧបោសថក្នុងថ្ងៃនោះ) ។ មានអធិប្បាយថា ក្នុងថ្ងៃនោះ ជាថ្ងៃបណ្ណរសីឧបោសថ ។ បទថា* ***ឧបសង្កមិ*** *(ចូលទៅគាល់) សេចក្តីថា នាងវិសាខាអធិដ្ឋានអង្គឧបោសថហើយ កាន់របស់ក្រអូប និងផ្កាឈើជាដើម ចូលទៅគាល់ ។ បទថា* ***ហន្ទ*** *ជានិបាតប្រើក្នុងអត្ថថា គោរពអញ្ជើញ ។ បទថា* ***ទិវា ទិវស្ស*** *(តែថ្ងៃ) សេចក្តីថា វេលាថ្ងៃត្រង់ ឈ្មោះថា ពេលថ្ងៃ បានដល់ក្នុងវេលាដែលព្រះអាទិត្យតាំងនៅត្រង់កណ្តាល ។ បទថា* ***កុតោ នុ ត្វំ អាគច្ឆសិ*** *(នាងមកពីណា) សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា នាងទៅធ្វើអ្វី ។*

*ឧបោសថដែលប្រៀបដូចអ្នកឃ្វាលគោ ព្រោះមានសេចក្តីត្រិះរិះដែលមិនបរិសុទ្ធិ៍ ឈ្មោះថា* ***គោបាលកុបោសថ*** *។ ឧបោសថ គឺ វត្តបដិបត្តិរបស់និគ្រណ្ឋទាំងឡាយ ឈ្មោះថា* ***និគណ្ឋុបោសថ*** *។ ឧបោសថ គឺ វត្តបដិបត្តិរបស់ព្រះអរិយៈទាំងឡាយ ឈ្មោះថា* ***អរិយុបោសថ*** *ដូច្នេះឯង ។*

*បទថា* ***សេយ្យថាបិ វិសាខេ*** *(វិសាខា ប្រៀបដូច) សេចក្តីថា ម្នាលនាង*

វិសាខា ប្រៀបផ្ទឹមដូច ។ បទថា **សាយណ្ហសមយេ សាមិកានំ គាវោ និយ្យា-ទេត្វា** (គង្វាលគោទាំងឡាយ ឲ្យពួកម្ចាស់គោ) សេចក្តីថា ពិតហើយ អ្នកគង្វាលគោ ទទួលគោមកឃ្វាល ព្រោះតម្លៃឈ្នួលប្រចាំថ្ងៃ ដោយកំណត់ថា ៥ ថ្ងៃ ១០ ថ្ងៃ កន្លះខែ មួយខែ ៦ ខែ ឬ ១ ឆ្នាំ (ទើបនឹងចាយវាយ) តែក្នុងព្រះសូត្រនេះ ត្រាស់ពាក្យថា **គោបាលកុបោសថោ** នេះ ទ្រង់សំដៅដល់ អ្នកឃ្វាលគោព្រោះតម្លៃឈ្នួលប្រចាំថ្ងៃ ។ បទថា **និយ្យាទេត្វា** (ប្រគល់ឲ្យ) សេចក្តីថា ប្រគល់ឲ្យម្ចាស់គោ គឺ និយាយថា គោរបស់លោកមានចំនួនប៉ុណ្ណេះ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** (នឹកយ៉ាងនេះថា) សេចក្តីថា ទៅដល់ផ្ទះរបស់ខ្លួន បរិភោគអាហារហើយ ដេកលើគ្រែ ពិចារណាយ៉ាងនេះ ។ បទថា **អភិជ្ឈាសហគតេន** (មានចិត្តទៅជាមួយសេចក្តីប្រាថ្នា) សេចក្តីថា សម្បយុត្តដោយតណ្ហា ។

បទថា **ឯវំ ខោ វិសាខេ គោបាលកុបោសថោ ហោតិ** (វិសាខា គោ-បាលកុបោសថ ដូច្នេះឯង) សេចក្តីថា ជាអរិយុបោសថដូចគ្នា តែព្រោះមានវិតក្កៈមិនបរិសុទ្ធិ៍ ទើបនៅក្នុងឋានៈនៃគោបាលកុបោសថប៉ុណ្ណោះ ។ បទថា **ន មហប្ផលោ** (មិនមានផលច្រើន) សេចក្តីថា មិនមានផលច្រើន ព្រោះផល គឺ វិបាក ។ បទថា **ន មហានិសំសោ** (មិនមានអានិសង្សច្រើន) សេចក្តីថា មិនមានអានិសង្សច្រើន ព្រោះអានិសង្ស គឺ វិបាក ។ បទថា **ន មហាជុតិកោ** (មិន

មានសេចក្តីរុងរឿងច្រើន) សេចក្តីថា មិនមានសេចក្តីរុងរឿងច្រើន ព្រោះសេចក្តីរុងរឿង គឺ វិបាក ។ បទថា **ន មហាវិប្ផរោ** (មិនមានការផ្សាយផលច្រើន) សេចក្តីថា ឈ្មោះថា មិនផ្សាយផលទៅច្រើន ព្រោះការផ្សាយទៅនៃវិបាកមិនមានច្រើន ។

បទថា **សមណជាតិកា** (ពួកអ្នកមានជាតិជាសមណៈ) បានដល់ ពួកសមណៈ ។ បទថា **បរំ យោជនសតំ** (ឯនាយ ១០០ យោជន៍) សេចក្តីថា ឆ្ងាយជាង ១០០ យោជន៍ គឺ ឯនាយនោះទៅ ។ បទថា **តេសុ ទណ្ឌំ និក្ខិបាហិ** (ដាក់ចុះអាជ្ញាក្នុងពពួកសត្វ) សេចក្តីថា ដាក់អាជ្ញា គឺ ជាអ្នកដាក់អាជ្ញាក្នុងសត្វទាំងឡាយនោះ ដែលនៅឯនាយ ១០០ យោជន៍ទៅ ។

បទថា **នាហំ ក្វចិនិ កស្សចិ កិញ្ចនំ តស្មឹ** (គេមិនកង្វល់ដល់នរណាៗ ក្នុងទីណាៗ) សេចក្តីថា យើងមិនមានសេចក្តីកង្វល់ដល់បុគ្គលដទៃ ក្នុងទីណាៗ បដិពោធ ព្រះអង្គត្រាស់ហៅថា សេចក្តីកង្វល់ ។ អធិប្បាយថា យើងជាអ្នកមិនមានសេចក្តីកង្វល់ ។ បទថា **ន ច មម ក្វចិនិ កិស្មិញ្ចិ កិញ្ចនំ នត្ថិ** (និងសេចក្តីកង្វល់ក្នុងវត្ថុអ្វីៗ ក្នុងទីណាៗ ក៏មិនមាន) សេចក្តីថា យើងមិនមានសេចក្តីកង្វល់ គឺ មិនមានបដិពោធក្នុងវត្ថុណាៗ គឺ សូម្បីក្នុងបរិក្ខារណាមួយក្នុងទីណាៗ គឺ ទាំងខាងក្នុង និងខាងក្រៅ ។ មានអធិប្បាយថា យើងកាត់សេចក្តី

កន្លល់បានហើយ ។ បទថា **ភោគេ** (ភោគៈ) បានដល់ គ្រឿងឧបភោគ និង បរិភោគ មានគ្រែ តាំង បាយ យាគូ និងកត្តជាដើម ។ បទថា **អទិន្នំយេវ បរិភុញ្ជតិ** (ដែលម្ចាស់ទ្រព្យមិនបានឲ្យនោះឯង) សេចក្ដីថា ក្នុងថ្ងៃស្អែក កាល គេដេកលើគ្រែក្ដី អង្គុយលើតាំងក្ដី ឆាន់បបរយាគូក្ដី ឆាន់អាហារក្ដី ឈ្មោះថា បរិភោគភោគៈនោះឯង ដែលគេមិនបានឲ្យឡើយ ។

បទថា **ន មហប្ផលោ** ប្រែថា គ្មានផល ។ ក៏ក្នុងបទថា **ន មហប្ផលោ** នេះ មានតែព្យញ្ជនៈប៉ុណ្ណោះដែលសល់នៅ ចំណែកសេចក្ដីមិនមានឡើយ ព្រោះ ថា ឧបោសថរបស់អ្នកបដិបត្តិយ៉ាងនេះ មិនមានផល គឺ វិបាកដែលគួរប្រាថ្នា គួររីករាយ គួរពេញចិត្ត សូម្បីត្រឹមតែបន្តិចបន្តួច ព្រោះដូច្នោះ និគណ្ឋុបោសថ គប្បីជ្រាបថា មិនមានផលឡើយ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់ពាក្យនេះទុកថា ចិត្ត ដែលសៅហ្មងហើយ ។

ឆ្លើយថា ព្រោះថា ឧបោសថដែលបុគ្គលមានចិត្តបរិសុទ្ធិ៍បដិបត្តិហើយ មានផលច្រើន គឺ ព្រះអង្គទ្រង់អនុញ្ញាតហើយ ព្រោះទ្រង់សម្ដែងទុកថា ឧបោសថ ដែលបុគ្គលមានចិត្តសៅហ្មងបដិបត្តិហើយ រមែងមិនមានផលច្រើន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះទុក ដើម្បីទ្រង់សម្ដែងកម្មដ្ឋានដែលជាហេតុ

ឲ្យចិត្តបរិសុទ្ធិ៍ គឺ កម្មដ្ឋានដែលជាហេតុជម្រះចិត្ត ។ បណ្តាបទទាំងនោះ បទថា **ឧបក្កមេន** (ដោយសេចក្តីព្យាយាម) សេចក្តីថា ដោយសេចក្តីព្យាយាមរបស់បុរសចំពោះខ្លួន ឬដោយឧបាយ ។

បទថា **តថាគតំ អនុស្សរតិ** (រឭកដល់តថាគត) សេចក្តីថា រឭកដល់ព្រះគុណរបស់ព្រះតថាគតដោយហេតុ ៨ ប្រការ ។ ក៏ក្នុងបទថា **រឭកដល់តថាគត** នេះ លោកសង្គ្រោះយកព្រះពុទ្ធគុណទាំងអស់ ទាំងដែលជាលោកិយៈនិងលោកុត្តរៈទុក ដោយបទថា **សូម្បីព្រោះហេតុនេះៗ ព្រះមានព្រះភាគព្រះអង្គនោះ** ដែលពង្រីកសេចក្តីចេញទៅថា ព្រោះសីលសូម្បីនេះ ព្រះមានព្រះភាគព្រះអង្គនោះ , ព្រោះសមាធិសូម្បីនេះ ព្រះមានព្រះភាគព្រះអង្គនោះ ។ ទ្រង់សម្តែងព្រះគុណដែលជាចំណែកព្រះអង្គប៉ុណ្ណោះ ដោយបទមានជាអាទិ៍ថា **ជាព្រះអរហន្ត** ដូច្នេះ ។ បទថា **តថាគតំ អនុស្សរតោ ចិត្តំ បសីទតិ** (កាលអ្នករឭកដល់តថាគតហើយ ចិត្តរមែងជូរថ្លា) សេចក្តីថា កាលគេរឭកដល់ព្រះគុណរបស់ព្រះតថាគតទាំងជាលោកិយៈ និងលោកុត្តរៈ ចិត្តប្បាទរមែងថ្លាផូរផង់ ។

នីវរណៈទាំង ៥ ឈ្មោះថា **ឧបក្កិលេសនៃចិត្ត** ។ ទឹកកន្ទួតព្រៃរំងាស់ឈ្មោះថា កាក ។ បទថា **តជ្ជំ វាយាមំ** (សេចក្តីព្យាយាមដែលសមគួរដល់កិច្ចនោះ) សេចក្តីថា សេចក្តីព្យាយាមដើម្បីលាបខ្លួន លាង និងដុសខាត់ដោយកាក

កន្ទួតព្រៃ ដែលកើតពីកិច្ចនោះ ដែលសមគួរជាមួយកិច្ចនោះ ។ បទថា **បរិយោ-ទបនា ហោតិ** (ការធ្វើ...ឲ្យស្អាតរមែងមាន) សេចក្តីថា រមែងធ្វើសេចក្តីស្អាត ។ ពិតណាស់ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយពុទ្ធបំណងថា បើបុគ្គលប្រដាប់គ្រឿងប្រដាប់ទុកលើសីសៈដែលស្មោកគ្រោក លេងនក្សត្រ ក៏មិនល្អ តែបើប្រដាប់គ្រឿងប្រដាប់លើសីសៈដែលស្អាត លេងនក្សត្រ រមែងស្រស់ល្អ (យ៉ាងណា) ក៏ឧបោសថដែលបុគ្គលមានចិត្តសៅហ្មងអធិដ្ឋានអដ្ឋឧបោសថហើយ សមាទាន នឹងមិនមានផលច្រើន តែឧបោសថដែលបុគ្គលមានចិត្តស្អាតអធិដ្ឋានអដ្ឋឧបោសថហើយ សមាទាន រមែងមានផលច្រើន ដូច្នោះដូចគ្នា ។

បទថា **ព្រហ្មុបោសថំ ឧបវសតិ** (ឈ្មោះថារក្សាព្រហ្មុបោសថ) សេចក្តីថា ព្រះសម្មាសម្ពុទ្ធ គេហៅថា ព្រះព្រហ្ម ឧបោសថនេះ ឈ្មោះថា ព្រហ្មុ-បោសថ ដោយអំណាចនៃការរលឹកដល់គុណរបស់ព្រះព្រហ្ម គឺ ព្រះសម្មាសម្ពុទ្ធនោះ ។ បទថា **ព្រហ្មុនា សទ្ធឹ សំវសតិ** (នៅរួមជាមួយព្រះព្រហ្ម) សេចក្តីថា សេពគប់ជាមួយព្រះសម្មាសម្ពុទ្ធ ។ បទថា **ព្រហ្មញ្ចស្ស អារព្ភ** (និងចិត្តរបស់អ្នកប្រារព្ធព្រះព្រហ្ម) សេចក្តីថា ប្រារព្ធព្រះសម្មាសម្ពុទ្ធ ។

បទថា **ធម្មំ អនុស្សរតិ** (រលឹកដល់ព្រះធម៌) សេចក្តីថា រលឹកដល់លោកុត្តរធម៌ ព្រមទាំងព្រះពុទ្ធវចនៈ ។ បទថា **សោត្តឹ** (គ្រាប់អង្កាំ) បានដល់

គ្រាប់អង្កាំកុរុវិន្ទក៍ ។ ក៏មនុស្សទាំងឡាយផ្សំជាមួយលម្អិតថ្មកុរុវិន្ទក៍ សូនជាកូនគ្រាប់អង្កាំ ចោះហើយយកអំបោះដោត ចាប់ចង្កោមខ្សែអង្កាំទាំងពីរខាងដុសខ្លួន ។ បទថា **សោត្តិញ្ច បដិច្ច** (ប្រើអង្កាំ) នេះ ព្រះមានព្រះភាគត្រាស់សំដៅយកខ្សែអង្កាំនោះ ។ បទថា **ចុណ្ណំ** បានដល់ លម្អិតដែលប្រើក្នុងវេលាងូតទឹក ។ បទថា **តជ្ជំ វាយាមំ** (ដែលសមគួរដល់កិច្ចនោះ) បានដល់ សេចក្តីព្យាយាមដែលសមគួរដល់កិច្ចនោះ មានការលាប ដុស និងលាងជម្រះជាដើម ។ បទថា **ធម្ម-បោសថំ** សេចក្តីថា ឧបោសថនេះ ព្រះមានព្រះភាគត្រាស់ហៅថា ធម្មុបោសថ ព្រោះប្រារព្ធនវលោកុត្តរធម៌ ព្រមទាំងព្រះពុទ្ធវចនៈ ហើយសមាទាន ។ អ្នកសិក្សាគប្បីដាក់បទថា **ធម្មំ (ចិត្តដែលសៅហ្មង) ឲ្យផូរផង់** នេះ ទុកជាគោល ហើយប្រកបសេចក្តីដោយន័យមុននុ៎ះឯង ។

បទថា **សង្ឃំ អនុស្សរតិ** (រឭកដល់ព្រះសង្ឃ) សេចក្តីថា រឭកដល់គុណរបស់ព្រះអរិយបុគ្គល ៨ ពួក ។ បទថា **ឧ,សញ្ច បដិច្ច** (ប្រើចំហាយ) សេចក្តីថា អាស្រ័យចំហាយទឹកក្តៅដែលគេដាំ ដោយអំណាចចំហាយដែលលើកឡើងពីចង្ក្រាន ២-៣ ដង ។ បាឋៈថា **ឧស្សំ** ដូច្នេះ ក៏មាន ។ អត្ថតែមួយ៉ាងដូចគ្នានេះឯង ។ បទថា **ខារំ** គឺ **ឆារិកំ** (កម្ទេចផេះ) ។ បទថា **គោមយំ** បានដល់ អាចម៍គោ ឬអាចម៍ពពែ ។ សូម្បីក្នុងបទថា **បរិយោទបនា** (ធ្វើ...ឲ្យផូរផង់) នេះ

ក៏គប្បីប្រកបសេចក្តីដូចន័យមុនទាំងឯង ។ បទថា **សង្ឃុបោសថំ** សេចក្តីថា ឧបោ-សថនេះ ត្រាស់ហៅថា សង្ឃុបោសថ ព្រោះប្រារព្ធគុណរបស់ព្រះអរិយបុគ្គល ៨ ពួកហើយ ទើបសមាទាន ។

បទថា **សីលានិ** (សីល) សេចក្តីថា ជាគ្រហស្ថក៏រឭកដល់សីលរបស់គ្រហស្ថ ជាបព្វជិតក៏រឭកដល់សីលរបស់បព្វជិត ។ អត្ថាធិប្បាយរបស់បទថា **អខណ្ឌានិ** (មិនដាច់) ជាដើម ខ្ញុំបានឲ្យពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **វាលណ្ឌុកំ** (ច្រាស) បានដល់ ច្រាសដែលគេធ្វើដោយរោមកន្ទុយសេះ ឬសំបកផ្ទៃជាដើម ។ បទថា **តជ្ជំ វាយាមំ** (សេចក្តីព្យាយាមដែលសមគួរដល់កិច្ចនោះ) បានដល់ ការដែលយកប្រេងលាប គិតថានឹងមានស្នឹមកើតឡើងចាក់កម្ទេចផេះចុះទៅ ហើយព្យាយាមយកច្រាសដុស ។ អ្នកសិក្សាគប្បីប្រកបសេចក្តីយ៉ាងនេះ ដោយកាន់យកបទថា **ធ្វើ (កញ្ចក់ស្រអាប់) ឲ្យស្អាត** នេះជាគោលដូចតទៅនេះ ។

ដូចជា រាងកាយ សូម្បីតាក់តែងដោយគ្រឿងប្រដាប់ហើយ (តែ) កាលកញ្ចក់ (សម្រាប់ឆ្លុះ) ស្មោកគ្រោក សម្លឹងមើលក៏មិនដឹងស្អាត កាលបើកញ្ចក់ស្អាត (សម្លឹងមើល) ទើបដឹងស្អាត យ៉ាងណា ឧបោសថដែលសមាទានហើយក៏ដូច្នោះ កាលចិត្តសៅហ្មង ក៏មិនមានផលច្រើន កាលចិត្តបរិសុទ្ធិ៍ ទើបមានផល

ច្រើន ដូច្នេះឯង ។ បទថា **សីលុបោសថំ** (សីលឧបោសថ) សេចក្តីថា ឧបោ-សថ ដែលសមាទានដោយការរឭកដល់សីលរបស់ខ្លួន ឈ្មោះថា សីលុបោ-សថ ។ បទថា **សីលេន សទ្ធឹ** (ជាមួយសីល) សេចក្តីថា ព្រមទាំងសីល ៥ សីល ១០ របស់ខ្លួន ។ បទថា **សីលំ អារព្ភ** (ប្រារព្ធសីល) សេចក្តីថា ប្រារព្ធ ទាំងសីល ៥ ទាំងសីល ១០ ។

បទថា **ទេវតា អនុស្សរតិ** (រឭកដល់ទេវតា) សេចក្តីថា រលឹកដល់គុណ មានសទ្ធាជាដើមរបស់ខ្លួន ដោយតាំងទេវតាទុកក្នុងឋានៈជាសាក្សី ។ បទថា **ឧក្កំ** គឺ **ឧទ្ធនំ** (ចង្ក្រាន) ។ បទថា **លោណំ** (អំបិល) បានដល់ ដីប្រៃ ។ បទថា **គេរុកំ** (ដីលឿង) បានដល់ លម្អិតដី.ស ។ បទថា **នឡិសណ្ឌាសំ** (ស្នប់ និង ដង្កាប់) បានដល់ ស្នប់សម្រាប់សប់ និងដង្កាប់សម្រាប់ចាប់[១] ។ បទថា **តជ្ជំ វាយាមំ** (សេចក្តីព្យាយាមសមគួរដល់កិច្ចនោះ) បានដល់ សេចក្តីព្យាយាមដែល សមគួរ មានការដាក់ចុះក្នុងចង្ក្រាន ការសប់ និងការប្រើដង្កាប់ចាប់ជាដើម ។ អ្នកសិក្សាគួរដាក់ បទថា **ធ្វើ (មាសដែលសៅហ្មង) ឲ្យផូរផង់** នេះ ទុកជា គោល ហើយប្រកបសេចក្តីដូចន័យមុនទុំះឯង ព្រោះថា អ្នកតុបតែងខ្លួនដោយ គ្រឿងប្រដាប់ដែលធ្វើដោយមាសដែលសៅហ្មង លេងនក្សត្រ រមែងមិនល្អ ដែល

---

(១) ក្នុងបិដក = ឧក្កញ្ច បាវមាស , លោណញ្ច ដីប្រៃ , គេរុញ្ច រង្គ , សណ្ឌាសញ្ច ស្នប់ និងដង្កាប់ ។

ធ្វើដោយមាសដែលមិនសៅហ្មង លេងនក្សត្រ ទើបនឹងស្អាតល្អ យ៉ាងណា បុគ្គលមានចិត្តសៅហ្មង ក៏ដូច្នោះ ឧបោសថ រមែងមិនមានផលច្រើន ។ ចំណែកបុគ្គលមានចិត្តបរិសុទ្ធិ៍ ទើបមានផលច្រើន ។ បទថា **ទេវតូបោសថំ** (ទេវតាឧបោសថ) សេចក្តីថា ឧបោសថដែលបុគ្គលរលឹកដល់គុណធម៌របស់ខ្លួន ដោយតាំងទេវតាទុកក្នុងឋានៈជាសាក្សី ហើយសមាទាន ឈ្មោះថា **ទេវតូបោសថ** ។ បទណាដ៏សេស ដែលគួរនឹងពោលដល់ក្នុងកម្មដ្ឋាន មានពុទ្ធានុស្សតិជាដើមនេះ ខ្ញុំបានពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គហើយនោះឯង ។

បទថា **បាណាតិបាតំ** បានដល់ ការសម្លាប់សត្វ ។ បទថា **បហាយ** (លះ) សេចក្តីថា លះការទ្រុស្តសីល ពោលគឺ ចេតនាជាហេតុសម្លាប់សត្វនោះ ។ បទថា **បដិវិរតា** (វៀរចាក) សេចក្តីថា វៀរ គឺ វៀរ ចាកភាពជាបុគ្គលទ្រុស្ត-សីលនោះ តាំងពីវេលាដែលលះបានហើយ ។

បទថា **និហិតទណ្ឌា និហិតសត្ថា** (ដាក់ចុះដំបង ដាក់ចុះសស្ត្រា) មានអធិប្បាយថា ឈ្មោះថា ទាំងលះបង់ដំបង ទាំងលះបង់សស្ត្រា ព្រោះមិនកាន់ដំបង ឬសស្ត្រា ប្រព្រឹត្តទៅដើម្បីសម្លាប់អ្នកដទៃ ។ វៀរដំបងចេញហើយ ឧបករណ៍ដ៏សេសទាំងអស់ គប្បីជ្រាបថា ឈ្មោះថា សស្ត្រា ក្នុងបទថា **ដាក់ចុះដំបង ដាក់ចុះសស្ត្រា** នេះ ព្រោះញ៉ាំងសត្វទាំងឡាយឲ្យវិនាស ។ ចំណែកភិក្ខុកាន់

ឈើប្រត់មនុស្សចាស់ កាំបិតកោរ ឈើស្ទន់ ឬកន្ត្រៃ ត្រាច់ទៅ មិនមែនដើម្បីត្រូវការសម្លាប់អ្នកដទៃ ព្រោះដូច្នោះ ភិក្ខុទាំងនោះចាត់ថា ដាក់ដំបងចុះហើយ ដាក់សស្ត្រាចុះហើយដូចគ្នា ។ បទថា **លជ្ជី** (មានការខ្មាសបាប) សេចក្តីថា ប្រកបដោយសេចក្តីខ្មាស មានការរង្កៀសក្នុងបាបជាលក្ខណៈ ។ បទថា **ទយាបន្នា** (មានសេចក្តីអាណិត) សេចក្តីថា ដល់នូវសេចក្តីអាណិត គឺ ជាអ្នកមានមេត្តាចិត្ត ។ បទថា **សព្វបាណភូតហិតានុកម្បី** (អនុគ្រោះប្រយោជន៍ដល់សព្វសត្វ) សេចក្តីថា អនុគ្រោះសត្វមានជីវិតទាំងពួង ដោយប្រយោជន៍ អធិប្បាយថា មានចិត្តជួយសង្គ្រោះពួកសត្វមានជីវិតទាំងពួង ព្រោះជាអ្នកមានមេត្តាចិត្តនុ៎ះឯង ។

បទថា **អហម្បជ្ជ** កាត់បទជា **អហំបិ អជ្ជ** (ក្នុងថ្ងៃនេះ សូម្បីយើង) ។ បទថា **ឥមិនាបិ អង្គេន** (ដោយអង្គសូម្បីនេះ) បានដល់ ដោយអង្គគុណសូម្បីនេះ ។ បទថា **អរហតំ អនុករោមិ** (យើងបានឈ្មោះថា ធ្វើតាមព្រះអរហន្ត) សេចក្តីថា កាលដើរតាមក្រោយអ្នកដែលដើរទៅខាងមុខ ឈ្មោះថា ដើរតាមយ៉ាងណា សូម្បីយើងក៏ដូច្នោះ កាលបំពេញគុណ គឺ សេចក្តីល្អនេះតាមក្រោយដែលព្រះអរហន្តទាំងឡាយបំពេញមកអំពីមុន ឈ្មោះថា ចម្រើនតាមស្នាមព្រះអរហន្តទាំងនោះ ។ បទថា **ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ** (និងឧបោ-

សថដែលយើងរក្សាហើយ) សេចក្តីថា ដែលយើងធ្វើយ៉ាងនេះ នឹងបានឈ្មោះថា ចម្រើនតាមស្នាមព្រះអរហន្តផង និងឈ្មោះថា សមាទានឧបោសថផង ។

ការកាន់យកវត្ថុដែលម្ចាស់របស់មិនបានឲ្យ គឺ ដែលអ្នកដទៃហួងហែង ឈ្មោះថា **អទិន្នាទាន** អធិប្បាយថា បានដល់ ការលួច គឺ ការធ្វើរបស់ចោរ ។ ឈ្មោះថា **កាន់យកតែរបស់ដែលគេឲ្យ** ព្រោះកាន់យកចំពោះតែរបស់ដែលគេឲ្យ ។ ឈ្មោះថា **ប្រាថ្នាតែរបស់ដែលគេឲ្យ** ព្រោះរមែងប្រាថ្នាសូម្បីដោយចិត្ត ចំពោះរបស់ដែលគេឲ្យ ។ ឈ្មោះថា **លួច** ព្រោះរមែងលួច ឈ្មោះថា **មិនលួច** ព្រោះមិនលួច ។ ឈ្មោះថា **ជាបុគ្គលស្អាត** ព្រោះមិនលួចនុ៎ះឯង ។ បទថា **អត្តនា** (មានខ្លួន) បានដល់ មានអត្តភាព លោកអធិប្បាយថា ធ្វើអត្តភាពមិនឲ្យលួច ឲ្យស្អាត ។

បទថា **អព្រហ្មចរិយំ** បានដល់ ការប្រព្រឹត្តដែលមិនប្រសើរ ។ ឈ្មោះថា **ព្រហ្មចារី** ព្រោះប្រព្រឹត្តអាចារៈដ៏ប្រសើរ គឺ ប្រសើរបំផុត ។ បទថា **អារាចារី** (ប្រព្រឹត្តឆ្ងាយ) សេចក្តីថា ប្រព្រឹត្តឆ្ងាយពីអព្រហ្មចរិយៈ ។ បទថា **មេថុនា** (មេថុន) បានដល់ អសទ្ធម្មដែលដល់ការរាប់ថា មេថុន ព្រោះមានសភាពដូចគ្នា ដែលជាកិលេសរួបរឹតចិត្ត គឺ រាគៈ ។ បទថា **គាមធម្មា** (ធម៌របស់អ្នកស្រុក) បានដល់ ធម៌របស់អ្នកគ្រប់គ្រងផ្ទះ ។

បទថា **មុសាវាទា** (ចាកពីមុសាវាទ) សេចក្តីថា ចាកការនិយាយបំភាន់ គឺ និយាយមិនពិត ។ ឈ្មោះថា **និយាយតែពាក្យពិត** ព្រោះនិយាយសេចក្តីពិត ឈ្មោះថា **និយាយពិតជានិច្ច** ព្រោះតសច្ចៈដោយសច្ចៈ អធិប្បាយថា មិននិយាយកុហកក្នុងចន្លោះៗ ។ ព្រោះថាបុគ្គលខ្លះ គ្រាខ្លះក៏និយាយកុហក គ្រាខ្លះក៏និយាយពិត បុគ្គលនោះឈ្មោះថា មិនតសច្ចៈដោយសច្ចៈ ព្រោះមានមុសាវាទមកកាត់ ព្រោះដូច្នោះ គេទើបមិនឈ្មោះថា មានសច្ចៈតភ្ជាប់ ។ តែលោកទាំងនេះមិនដូច្នោះ តពាក្យសច្ចៈដោយពាក្យសច្ចៈតែម្យ៉ាង មិនព្រមនិយាយកុហក សូម្បីព្រោះហេតុនៃជីវិត ព្រោះដូច្នោះ ទើបឈ្មោះថា មានសច្ចៈតជាប់ ។ បទថា **ថេតា** (ខ្ជាប់ខ្ជួន) បានដល់ ស្ថិតស្ថេរ អធិប្បាយថា មានពាក្យសំដីខ្ជាប់ខ្ជួន ។ បុគ្គលមួយរូបជាអ្នកមិនមានពាក្យសំដីខ្ជាប់ខ្ជួន ដូចការជ្រលក់សំពត់ដោយល្មៀត ដូចបង្គោលដែលបោះទុកលើគំនរអង្កាម និងដូចផ្លែត្រឡាចដែលដាក់លើខ្នងសេះ តែមួយរូបទៀត មានពាក្យសំដីខ្ជាប់ខ្ជួន ដូចគំនូសចារឹកលើផែនដី និងដូចសសរឥន្ទខីល សូម្បីយកកាំបិតកាត់សីសៈ ក៏មិនព្រមនិយាយពាក្យជាពីរ ។ បុគ្គលនេះ ហៅថា **ជាអ្នកមានពាក្យសំដីខ្ជាប់ខ្ជួន** ។ បទថា **បច្ចយិកា** (មានវាចាជឿបាន) បានដល់ មានវាចាគួរទុកចិត្តបាន អធិប្បាយថា គួរជឿ ។ ព្រោះបុគ្គលខ្លះជឿមិនបាន គឺ កាលត្រូវគេសួរថា ពាក្យនេះនរណានិយាយ ក៏ឆ្លើយថា បុគ្គល

ឯណោះនិយាយ រមែងជាអ្នកដែលគេគប្បីនិយាយថា កុំជឿពាក្យនិយាយរបស់គេ ។ តែមួយរូបទៀត និយាយជឿបាន គឺ កាលត្រូវសួរថា ពាក្យនេះនរណានិយាយ ក៏ឆ្លើយថា បុគ្គលឯណោះនិយាយ ក៏ទទួលថា បើអ្នកនោះនិយាយប្រការនេះក៏ជាការប្រមាណបាន ឥឡូវនេះមិនមានប្រការដែលនឹងត្រូវជំទាស់ថាពាក្យនេះជាយ៉ាងនេះៗ ។ បុគ្គលនេះ ហៅថា មានវាចាជឿបាន ។ បទថា **អវិសំវាទកោ លោកស្ស** (មិនពោលបង្កាច់សត្វលោក) មានអធិប្បាយថា មិននិយាយកុហកសត្វលោក ព្រោះនិយាយតែសេចក្តីពិតប៉ុណ្ណោះ ។

ហេតុនៃសេចក្តីប្រមាទ ពោលគឺ ចេតនា ដែលនឹងផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ ឈ្មោះថា **សុរាមេរយមជ្ជបមាទដ្ឋាន** ។

បទថា **ឯកភត្តិកា** (បរិភោគអាហារមួយពេល) សេចក្តីថា អាហារមាន ២ ពេល គឺ អាហារដែលត្រូវបរិភោគក្នុងពេលព្រឹក ១ អាហារដែលត្រូវបរិភោគក្នុងពេលល្ងាច ១ ។ បណ្តាអាហារទាំងពីរយ៉ាងនោះ អាហារដែលនឹងបរិភោគក្នុងពេលព្រឹក កំណត់ដោយវេលាខាងក្នុងថ្ងៃត្រង់ (ចំណែក) អាហារដែលនឹងបរិភោគក្នុងពេលល្ងាច កំណត់ដោយវេលាដែលកន្លងថ្ងៃត្រង់ទៅ រហូតដល់វេលាអរុណរះ ។ ព្រោះដូច្នោះ ក្នុងវេលាខាងក្នុងថ្ងៃត្រង់ សូម្បីនឹងបរិភោគ ១០ ដង ក៏ឈ្មោះថា ការបរិភោគអាហារមួយពេល ។ ព្រះមានព្រះភាគ

ត្រាស់ថា **បរិភោគអាហារមួយពេល** ទ្រង់សំដៅដល់ការបរិភោគអាហារក្នុងវេលាថ្ងៃត្រង់ ។ ការទទួលបរិភោគអាហារក្នុងវេលាពេលយប់ ឈ្មោះថា **រត្តិ** បុគ្គលវៀរចាកការបរិភោគអាហារក្នុងវេលាពេលយប់នោះ ព្រោះដូច្នោះ ទើបឈ្មោះថា **វៀរអាហារក្នុងវេលារាត្រី** ។ ការបរិភោគអាហារក្នុងវេលាកន្លងថ្ងៃត្រង់ទៅរហូតដល់វេលាព្រះអាទិត្យលិច ឈ្មោះថា ការបរិភោគអាហារក្នុងវេលាវិកាល បុគ្គលឈ្មោះថា វៀរចាកវិកាលភោជន ព្រោះវៀរចាកការបរិភោគអាហារក្នុងវេលាវិកាលនោះ ។

ការមើល ដែលឈ្មោះថា ជាសត្រូវ គឺ ជាសត្រូវ ព្រោះអនុលោមតាមពាក្យទូន្មានមិនបាន (ជំទាស់ដល់សាសនា) ព្រោះដូច្នោះ ទើបឈ្មោះថា **វិសូកទស្សនៈ** ការរាំ ការច្រៀង ការដេញ ដំ ផ្លុំ កូត សូម្បីដោយអំណាចនៃការរាំដោយខ្លួនឯង និងឲ្យអ្នកដទៃរាំជាដើម និងការមើលការច្រៀងរាំជាដើម ដែលប្រព្រឹត្តទៅហើយដោយទីបំផុត សូម្បីដោយអំណាចនៃការរាំរបស់សត្វក្ងោកជាដើម ដែលជាសត្រូវ ព្រោះដូច្នោះ ទើបឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនៈ** ។ ក៏ការប្រកបការរាំជាដើម ដោយខ្លួនឯងក្តី ឲ្យអ្នកដទៃប្រកបក្តី ការមើលរបាំជាដើម ដែលគេប្រកបហើយក្តី មិនគួរដល់ភិក្ខុ ភិក្ខុនីឡើយ ។

ក្នុងបណ្តាផ្កាឈើជាដើម ផ្កាឈើណាមួយ ឈ្មោះថា **មាលា** ។ គន្ធជាត

ណាមួយ ឈ្មោះថា **គន្ធៈ** ។ គ្រឿងចម្រើនសម្បុរ ឈ្មោះថា **វិលេបនៈ** ។ ក្នុងបណ្តាវត្ថុទាំងនោះ កាលបើប្រដាប់ ឈ្មោះថា ទ្រទ្រង់ ។ កាលបន្ថែមចំណែកដែលខ្វះខាត ឈ្មោះថា **តាក់តែង** ។ កាលត្រេកអរដោយរបស់ក្រអូបក្តី ដោយគ្រឿងចម្រើនសម្បុរក្តី ឈ្មោះថា ប្រដាប់ ។ ហេតុ ព្រះមានព្រះភាគត្រាស់ហៅថា **ឋានៈ** ។ អធិប្បាយថា ព្រោះដូច្នោះ មហាជនធ្វើការទ្រទ្រង់ផ្កាឈើជាដើមទាំងនោះ ដោយចេតនា គឺ ភាពជាអ្នកទ្រុស្តសីលណា ព្រះអរហន្តទាំងឡាយជាអ្នកវៀរចាកការទ្រុស្តសីលចេតនានោះ ។

ទីអង្គុយទីដេកហួសខ្នាត ត្រាស់ហៅថា **ឧច្ចាសយនៈ** ។ កម្រាលដែលជាអកប្បិយៈ (មិនសមគួរ) ឈ្មោះថា **មហាសយនៈ** ។ អធិប្បាយថា ព្រះអរហន្តទាំងឡាយជាអ្នកវៀរចាកទីអង្គុយទីដេកដែលខ្ពស់ និងទីអង្គុយទីដេកដែលធំនោះ ។

បទថា **កីវមហប្ផលោ** (មានផលច្រើនត្រឹមណា) សេចក្តីថា ផ្សាយផលច្រើនយ៉ាងណា ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **បហុ-តសត្តរតនានំ** (ដែលមានរតនៈ ៧ ប្រការដ៏ច្រើន) សេចក្តីថា ប្រកបដោយរតនៈពោលគឺ កែវដ៏ច្រើន អធិប្បាយថា ពង្រាបផែនដីជម្ពូទ្វីបទាំងអស់ឲ្យដូចជាផ្ទៃស្គរ ហើយចាក់រតនៈទាំង ៧ ចុះកម្ពស់ត្រឹមចង្កេះ ។ បទថា **ឥស្សរិយាធិបច្ចំ**

(ឥស្សរិយាធិបតី) សេចក្តីថា (សោយរាជសម្បត្តិ) ដែលជាធំ ឬជាអធិបតី ទាំងដោយភាពជាឥស្សរៈ ទាំងដោយសេចក្តីជាអធិបតី មិនមែនជាធំ ឬជាអធិបតីដោយភាពជាព្រះរាជាដែលធ្ងន់ព្រះទ័យ ។ ឈ្មោះថា សោយឥស្សរាធិបតី ព្រោះមិនមានអាជ្ញាកម្មដែលចាំបាច់ប្រើកម្លាំង ដូច្នេះខ្លះ ។ បទថា **រជ្ជំ ការេយ្យ** (គ្រប់គ្រងរាជ្យ) បានដល់ សោយចក្រពត្តិរាជសម្បត្តិឃើញបែបនេះ ។

បទថា **អង្គានំ** (អង្គៈ) ជាដើម ជាឈ្មោះរបស់ជនបទទាំងនោះ ។ បទថា **កលំ នាគ្ឃតិ សោឡសឹ** (មិនស្មើចំណែកទី ១៦) សេចក្តីថា បែងចែកបុណ្យក្នុងការសមាទានឧបោសថ អស់ថ្ងៃមួយ និងយប់មួយ ចេញជា ១៦ ចំណែក និងចក្រពត្តិរាជសម្បត្តិ មិនមានតម្លៃដល់ចំណែកមួយ អំពី ១៦ ចំណែកនោះ ។ អធិប្បាយថា ផលវិបាករបស់ចំណែកទី ១៦ នៃឧបោសថមួយយប់ ច្រើនជាងចក្រពត្តិរាជសម្បត្តិរបស់ស្តេចចក្រពត្តិនោះ ។ បទថា **កបណំ** (ជារបស់ស្តើងស្តួច) បានដល់ តិចតួច ។

បទថា **អព្រហ្មចរិយា** (មិនមែនជាការប្រព្រឹត្តប្រសើរ) បានដល់ ចាកការប្រព្រឹត្តដែលមិនប្រសើរ ។ បទថា **រត្តឹ ន ភុញ្ជេថ វិកាលភោជនំ** (មិនគួរបរិភោគអាហារក្នុងរាត្រី និងអាហារខុសកាល) សេចក្តីថា កាលសមាទានឧបោសថ មិនគប្បីបរិភោគអាហារក្នុងវេលាយប់ និងអាហារក្នុងវេលាពេលថ្ងៃ

ដែលជាវេលាវិកាល ។ បទថា **មញ្ចេ ឆមាយំវ សយេថ សន្ថតេ** (ដេកលើគ្រែ លើផែនដី ឬលើកម្រាល) មានអធិប្បាយថា គួរដេកលើគ្រែដែលជាកប្បិយៈ មានជើងកម្ពស់មួយហត្ថក្តាប់ ឬលើផ្ទៃដីដែលគេក្រាលទុកដោយកំបោរ.សជាដើម ឬលើសន្ថត់ដែលគេក្រាលដោយស្មៅ ស្លឹកឈើ ឬចំបើងជាដើម ។ បទថា **ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ** (បណ្ឌិតទាំងឡាយ ពោលឧបោសថនេះ... ថា ជាឧបោសថប្រកបដោយអង្គ ៨) សេចក្តីថា អ្នកប្រាជ្ញហៅឧបោសថដែលបុគ្គល មិនប្រព្រឹត្តបាណាតិបាតជាដើម សមាទានហើយយ៉ាងនេះថា ជាឧបោសថប្រកប ដោយអង្គ ៨ ព្រោះប្រកបដោយអង្គ ៨ ប្រការ ។

ចំណែកបុគ្គលសមាទានឧបោសថប្រកបដោយអង្គ ៨ នោះ គិតថា ស្អែក នេះ យើងនឹងរក្សាឧបោសថ ហើយគួរត្រួតពិនិត្យវត្ថុដែលត្រូវចាត់ចែង មាន អាហារជាដើមថា យើងត្រូវធ្វើយ៉ាងនេះ យ៉ាងនេះ ក្នុងថ្ងៃនេះឯង ។ ក្នុងថ្ងៃ ឧបោសថគួរបន្ទឺវាចាសមាទានអង្គឧបោសថ ក្នុងសម្នាក់របស់ភិក្ខុ ភិក្ខុនី ឧបាសក ឬឧបាសិកា អ្នកដឹងលក្ខណៈរបស់សីល ១០ ពីព្រឹក ។

ចំណែកបុគ្គលមិនដឹងបាលី គួរអធិដ្ឋានថា **ពុទ្ធប្បញ្ញត្តំ ឧបោសថំ អធិដ្ឋាមិ** (ខ្ញុំសូមអធិដ្ឋានអង្គឧបោសថ ដែលព្រះពុទ្ធទ្រង់បញ្ញត្តិទុកហើយ) ។ កាលរក អ្នកដទៃមិនបាន ក៏គួរអធិដ្ឋានដោយខ្លួនឯង ។ ចំណែកការបន្ទឺវាចា គួរធ្វើដោយ

ពិត ។

បុគ្គលបដិបត្តិឧបោសថ មិនគប្បីចាត់ចែងការងារ ដែលជាប់ដោយការបៀតបៀនអ្នកដទៃ ។ បុគ្គលរឭកដល់សេចក្តីចម្រើន និងសេចក្តីវិនាស មិនគួរបណ្តោយពេលវេលាឲ្យកន្លងទៅ ។ ចំណែកបុគ្គលបានអាហារអំពីក្នុងផ្ទះហើយ គួរបរិភោគដូចភិក្ខុដែលបានអាហារប្រចាំ ហើយទៅកាន់វិហារស្តាប់ធម៌ ឬមនសិការអារម្មណ៍ (កម្មដ្ឋាន) ៣៨ ប្រការណានីមួយ ។

បទថា **សុទស្សនា** (មើលច្បាស់) បានដល់ ឃើញបានច្បាស់ល្អ ។ បទថា **ឱភាសយំ** បានដល់ ភ្លឺហើយ ។ បទថា **អនុបរិយន្តិ** (គោចរ) បានដល់ គួរទៅ ។ បទថា **យាវតា** គឺ **យត្តកំ ឋានំ** (រហូតទីមានប្រមាណប៉ុនណា) ។ បទថា **អន្តលិក្ខគា** (ទៅក្នុងអាកាស) បានដល់ អណ្តែតទៅកាន់អាកាស ។ បទថា **បភាសន្តិ** ប្រែថា ភ្លឺស្វាង គឺ បញ្ចេញរស្មី ។ បទថា **ទិសា វិរោចនា** (រុងរឿងសព្វទិស) បានដល់ ភ្លឺទៅក្នុងទិសទាំងពួង ។ ន័យមួយទៀត ឈ្មោះថា ពន្លឺ ព្រោះភ្លឺទូទៅគ្រប់ទិស ។

បទថា **វេឡុរិយំ** (កែវពិទូរ្យ) សេចក្តីថា ព្រះមានព្រះភាគ សូម្បីនឹងត្រាស់បទថា មណីទុកហើយ (តែ) ក៏ទ្រង់សម្តែងដល់មណីដោយកំណើតទុកដោយបទថា **កែវពិទូរ្យ** នេះ ព្រោះថា ពិទូរ្យ ដែលមានពណ៌ដូចឫស្សី ដែលកើត

បាន ១ ឆ្នាំ ឈ្មោះថា មណីដោយកំណើត ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ទ្រង់សំដៅដល់កែវមណីដោយកំណើតនោះ ។

បទថា **ភទ្ទកំ** ស្មើនឹង **លទ្ធកំ** (ស្អាត) ។ បទថា **សិង្គិសុវណ្ណំ** (មាសសង្គី) បានដល់ មាសមានឈ្មោះយ៉ាងនេះ ព្រោះកើតឡើងមានសណ្ឋានដូចជើងគោ ។ បទថា **កាញ្ចនំ** បានដល់ មាស ដែលកើតពីភ្នំ គឺ មាសដែលកើតលើភ្នំ ។

បទថា **ជាតរូបំ** បានដល់ មាស ដែលមានពណ៌ដូចព្រះឆវីវណ្ណរបស់ព្រះសាស្តា ។ បទថា **ហដកំ** (មាសហដកៈ) បានដល់ មាសដែលស្រមោចក្រហមពាំមក ។ បទថា **នានុភវន្តិ** (មិនដល់) បានដល់ មិនទាន់ដល់ ។

បទថា **ចន្ទប្បភា** (ពន្លឺព្រះច័ន្ទ) ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ អធិប្បាយថា (មិនដល់ចំណែកទី ១៦) នៃពន្លឺច័ន្ទ ។ បទថា **ឧបវស្សុបោសថំ** (រក្សាឧបោសថ) បានដល់ សមាទានឧបោសថ ។ បទថា **សុខុទ្រយានិ** (ដែលមានសុខជាផល) បានដល់ មានសុខជាផល គឺ សោយសេចក្តីសុខ ។

បទថា **សគ្គមុបេន្តិ ឋានំ** (ចូលដល់ឋានៈ គឺ សួគ៌) បានដល់ ចូលដល់ឋានៈ ពោលគឺ សួគ៌ អធិប្បាយថា មិនមាននរណាតិះដៀល រមែងកើតក្នុងទេវលោក ។ ពាក្យដ៏សេសដែលមិនបានពោលទុកក្នុងចន្លោះៗ ក្នុងព្រះសូត្រនេះ

*គប្បីជ្រាបដោយទំនងដែលពោលហើយនុ៎ះឯង ។*

ចប់អដ្ឋកថា ឧទោសជសូត្រទី ១០

## ចប់មហាវគ្គវណ្ណនា ទី ២

ក្នុងវគ្គនេះ មាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# អានន្ទវគ្គទី ៣

## អដ្ឋកថា ឆន្នសូត្រទី ១

### *"ទោសនៃអកុសលមូល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឆន្នសូត្រទី ១ ដូចតទៅនេះ ៖*

[៧៣] *បទថា* ***ឆន្នោ*** *(ឆន្នៈ) បានដល់ បរិព្វាជកអ្នកមានសំពត់បិទបាំង (រាងកាយ) ដែលមានឈ្មោះយ៉ាងនេះ ។ បទថា* ***តុម្ហេបិ អាវុសោ*** *(អាវុសោ សូម្បីពួកលោក) សេចក្ដីថា ឆន្នបរិព្វាជកសួរថា ម្នាលអាវុសោ ពួកយើងបញ្ញត្តិការលះកិលេស មានរាគៈជាដើម យ៉ាងណា សូម្បីលោកទាំងឡាយក៏បញ្ញត្តិយ៉ាងនោះឬ ។ លំដាប់នោះ ព្រះថេរៈគិតថា បរិព្វាជកនេះ ពោលនឹងពួកយើងថា យើងទាំងឡាយបញ្ញត្តិការលះរាគៈជាដើម តែការបញ្ញត្តិការលះរាគៈជាដើមនេះ មិនមានក្នុងលទ្ធិខាងក្រៅ ដូច្នេះ កាលនឹងបដិសេធ ទើបពោលពាក្យមានជាអាទិ៍ថា* ***មយំ ខោ អាវុសោ*** *ដូច្នេះ ។ សព្ទថា* ***ខោ*** *ក្នុងបទថា* ***មយំ ខោ អាវុសោ*** *នោះ ជានិបាតប្រើក្នុងអត្ថថា ហាម អធិប្បាយថា ពួកយើងប៉ុណ្ណោះបញ្ញត្តិ ។ លំដាប់នោះ បរិព្វាជកគិតថា ព្រះថេរៈនេះ កាលនឹងរកកួនលទ្ធិខាងក្រៅ ទើបពោលថា ពួកយើងប៉ុណ្ណោះ សមណៈទាំងនេះឃើញទោសអ្វីហ្ន៎*

ទើបបញ្ញត្តិការលះរាគាជាដើមទាំងនេះ ។ លំដាប់នោះ ឆន្នបរិព្វាជក កាលនឹង ផ្តើមសួរព្រះថេរៈ ទើបពោលពាក្យមានជាអាទិ៍ថា **កឹ្ពពួកលោក ឃើញទោសក្នុង រាគៈដូចម្តេច** ដូច្នេះ ។

ព្រះថេរៈកាលនឹងឆ្លើយបញ្ហាគេ ទើបពោលពាក្យមានជាអាទិ៍ថា **អាវុសោ បុគ្គលដែលកើតរាគៈ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **អត្តត្ថំ** (ប្រយោជន៍ ខ្លួន) សេចក្តីថា ប្រយោជន៍របស់ខ្លួនទាំងក្នុងបច្ចុប្បន្ន និងសម្បរាយកព ទាំង ជាលោកិយៈ និងលោកុត្តរៈ ។ សូម្បីក្នុងប្រយោជន៍របស់បុគ្គលដទៃ និងប្រ- យោជន៍ទាំងពីរ ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អន្ធករណោ** (ធ្វើឲ្យងងឹត) ជាដើម ដូចតទៅនេះ ។ រាគៈ ឈ្មោះថា **ធ្វើឲ្យងងឹត** ព្រោះធ្វើ បុគ្គលដែលមានរាគៈកើតឡើងឲ្យងងឹត ដោយហាមការដឹង ការឃើញតាមសេចក្តី ពិត ។ ឈ្មោះថា **ធ្វើឲ្យខ្វាក់** ព្រោះមិនធ្វើឲ្យកើតបញ្ញាចក្ខុ ។ ឈ្មោះថា **ធ្វើ ឲ្យល្ងង់** ព្រោះមិនធ្វើឲ្យកើតញាណ ។ ឈ្មោះថា **បិទបាំងបញ្ញា** ព្រោះបញ្ញាទាំង ៣ យ៉ាងនេះ គឺ កម្មស្សកតាបញ្ញា (បញ្ញាដែលដឹងថាសត្វមានកម្មជារបស់ខ្លួន) ឈានបញ្ញា (បញ្ញាកើតពីការសម្ងំ) និងវិបស្សនាបញ្ញា (បញ្ញាពិចារណាឃើញ ច្បាស់) រលត់ទៅ ដោយមិនធ្វើឲ្យប្រព្រឹត្តទៅ ។ ឈ្មោះថា **ចាត់ជាចំណែក បៀតបៀន** ព្រោះប្រព្រឹត្តទៅក្នុងបក្ខពួកនៃសេចក្តីក្តៅក្រហាយ ពោលគឺ ទុក្ខ ព្រោះ

ឲ្យផលដែលមិនគួរប្រាថ្នាប៉ុណ្ណោះ ។ ឈ្មោះថា **មិនប្រព្រឹត្តទៅដើម្បីនិព្វាន** ព្រោះមិនញ៉ាំងការរលត់កិលេសឲ្យប្រព្រឹត្តទៅ ។ បទថា **អលញ្ច បនាវុសោ អានន្ទ អប្បមាទាយ** (ម្នាលអាវុសោ អានន្ទ ហេតុនោះ គួរតែកុំធ្វេសប្រហែសឡើយ) សេចក្ដីថា ឆន្នបរិព្វាជក អនុមោទនាពាក្យរបស់ព្រះថេរៈថា អាវុសោអានន្ទ ប្រសិនបើបដិបទាបែបនេះមានសោត ក៏សមគួរ ដល់លោកទាំងឡាយមិនប្រមាទ លោកទាំងឡាយចូរបំពេញសេចក្ដីមិនប្រមាទចុះ ដូច្នេះហើយ ក៏គេចចេញទៅ ។ ក្នុងព្រះសូត្រនេះ ព្រះអានន្ទត្ថេរពោលដល់អរិយមគ្គ ដែលលាយដោយលោកុត្តរៈទុកហើយ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ មានអត្ថងាយទាំងនោះឯង ។

ចប់អដ្ឋកថា ឆន្នសូត្រទី ១

# អដ្ឋកថា អាជីវកសូត្រទី ២

## *“ទោសនៃអកុសលមូល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាជីវកសូត្រទី ២ ដូចតទៅនេះ ៖*

*[៧៤] បទថា **តេនហិ គហបតិ** (គហបតី ប្រសិនបើដូច្នោះ) សេចក្តីថា បានឮថា ព្រះថេរៈគិតថា អាជីវកនេះកាលមកក្នុងទីនេះ ក៏មិនបានបំណងនឹងមកដើម្បីចង់ដឹង តែមកដើម្បីនឹងពិសោធ យើងនឹងឆ្លើយបញ្ហាដែលព្រាហ្មណ៍នេះសួរហើយ ដោយការសួរនេះឯង ព្រះថេរៈបំណងនឹងឲ្យព្រាហ្មណ៍នោះ ឆ្លើយបញ្ហានោះដោយខ្លួនឯង ដោយឧបាយនេះ ទើបពោលពាក្យមានជាអាទិ៍ថា **ប្រសិនបើដូច្នោះ** ដូច្នេះ ។*

*ក្នុងពាក្យថា **ប្រសិនបើដូច្នោះ** ជាដើមនោះ ពាក្យថា **ប្រសិនបើដូច្នោះ** ជាការអាងដល់ហេតុ អធិប្បាយថា ព្រោះហេតុដែលលោកសួរយ៉ាងនេះ ខ្ញុំទើបសូមសួរលោកក្នុងសេចក្តីនេះ ។ បទថា **កេសន្នោ** គឺ **កតមេសំ នុ** (របស់ពួកណាហ្ន៎) ។ បទថា **សន្ទិដ្ឋុក្កំសនា** (លើកធម៌របស់ខ្លួន) សេចក្តីថា លើកលទ្ធិរបស់ខ្លួនឡើងតាំងទុក ។ បទថា **បរធម្មាបសាទនា** (រុករានធម៌របស់អ្នកដទៃ) សេចក្តីថា បៀតបៀន ញាំញី កម្ចាត់ នូវលទ្ធិរបស់អ្នកដទៃ ។ បទថា **អាយតនេវ ធម្មទេសនា** (សម្តែងធម៌ចំពោះហេតុ) សេចក្តីថា សម្តែងធម៌ក្នុងហេតុនោះ*

ឯង ។ បទថា **អត្ថោ ច វុត្តោ** (ពោលនូវអត្ថ) សេចក្ដីថា នឹងចង្អុលបង្ហាញអត្ថនៃបញ្ហាដែលយើងសួរហើយ ។ បទថា **អត្ថា ច អនុបនីតោ** (ទាំងមិនអួតអាងខ្លួន) សេចក្ដីថា និងមិនអួតអាងខ្លួនយ៉ាងនេះថា ពួកយើងជាយ៉ាងនេះ បាឋៈថា **នុបនីតោ** ដូច្នេះ ក៏មាន ។

ចប់អដ្ឋកថា អាជីវកសូត្រទី ២

# អដ្ឋកថា សក្កសូត្រទី ៣

## "ត្រៃសិក្ខារបស់ព្រះសេក្ខៈ និងព្រះអសេក្ខៈ"

គប្បីជ្រាបវិនិច្ឆ័យក្នុង សក្កសូត្រទី ៣ ដូចតទៅនេះ ៖

[៧៥] បទថា **គិលានា វុដ្ឋិតោ** (ទ្រង់ស្បើយអំពីជំងឺ) សេចក្ដីថា ព្រះមានព្រះភាគទ្រង់បានស្បើយអំពីប្រឈួន ។ បទថា **គេលញ្ញា** គឺ **គិលានភាវតោ** (ស្បើយអំពីជំងឺ) ។ បទថា **ឧបសង្កមិ** (ចូលទៅគាល់) សេចក្ដីថា មហានាមសក្កៈ(១) សម្រេចសោយព្រះក្រយាហារព្រឹកហើយ ទ្រង់កាន់យកផ្កាឈើ និងរបស់ក្រអូបជាដើម មានបរិវារជាច្រើនហែហមហើយ ចូលទៅគាល់ (ព្រះមានព្រះភាគ) ។

ដោយបទថា **ពាហាយំ គហេត្វា** (ចាប់ព្រះពាហា)(២) គប្បីជ្រាបសេចក្ដីថា ព្រះអានន្ទត្ថេរៈ មិនបានចាប់ព្រះពាហា (របស់មហានាមសក្កៈ) ទាញមក (តែ) ក្រោកឡើងចាកអាសនៈដែលអង្គុយហើយ ទៅកាន់មហានាមសក្កៈ ប្រើម្រាមដៃកេះត្រង់ព្រះពាហាខាងស្ដាំ ហើយនាំចេញទៅក្នុងទីម្ខាង ។ ព្រះអានន្ទត្ថេរៈ លុះប្រាប់សីល សមាធិ និងបញ្ញា ដែលជារបស់ព្រះសេក្ខៈទាំង ៧ ពួក ដោយន័យមានជាអាទិ៍ថា មហានាម ព្រះមានព្រះភាគត្រាស់សីលដែលជាសេក្ខៈទុក

---

(១) ក្នុងអដ្ឋកថា ជា សក្យមហានាម , បិដក មហានាមសក្កៈ ។ (២) កំភួនដៃ ។

ក៏មាន ដូច្នេះ ហើយកាលនឹងប្រាប់សីល សមាធិ បញ្ញា របស់ព្រះអសេក្ខៈ ដោយអំណាចនៃអរហត្តផល ទើបសម្តែងថា វិបស្សនាញាណដែលជាសេក្ខៈ និងផលញាណដែលជាអសេក្ខៈ កើតឡើងខាងក្រោយសមាធិដែលជាសេក្ខៈ និងផលសមាធិដែលជាអសេក្ខៈ កើតឡើងខាងក្រោយវិបស្សនាដែលជាសេក្ខៈ ដូច្នេះ ។ ចំណែកសមាធិ និងញាណ ដែលជាសម្បយុត្តធម៌ គប្បីជ្រាបថា កើតឡើងមិនមុនមិនក្រោយគ្នា ។

ចប់អដ្ឋកថា សក្កសូត្រទី ៣

# អដ្ឋកថា និគណ្ឋសូត្រទី ៤

## *“សេចក្តីបរិសុទ្ធ ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និគណ្ឋសូត្រទី ៤ ដូចតទៅនេះ ៖*

*[៧៦] បទថា **កូដាគារសាលាយំ** (កូដាគារសាលា) បានដល់ ព្រះគន្ធកុដិដែលគេភ្ជាប់ជហ្វា ២ ខាង មានដំបូលចោទរាងមូល ។ បទថា **អបរិសេសំ ញាណទស្សនំ បដិជានាតិ** (ជាសព្វញ្ញូឃើញសព្វ តែងប្តេជ្ញានូវញាណទស្សនៈមិនមានសេសសល់) សេចក្តីថា ដឹងច្បាស់ញាណទស្សនៈគ្រប់យ៉ាង មិនមានសេសសល់ ។ បទថា **សតតំ សមិតំ** (គ្រប់កាលជានិច្ច) សេចក្តីថា រហូតគ្រប់កាល គឺ ជានិរន្តរ ។ ដោយបទថា **ញាណទស្សនំ បច្ចុបដ្ឋិតំ** (ញាណទស្សនៈប្រាកដ) នេះ និគណ្ឋនាដបុត្រសម្តែងថា សព្វញ្ញុតញ្ញាណប្រាកដហើយដល់យើង ។ បទថា **បុរាណានំ កម្មានំ** (កម្មចាស់) បានដល់ កម្មដែលសន្សំមក ។ បទថា **តបសា ព្យន្តីការំ** (ធ្វើឲ្យអស់... ដោយតបៈ) បានដល់ ធ្វើឲ្យកិលេសអស់ទៅដោយតបៈ ដែលធ្វើបានដោយលំបាក ។ បទថា **នវានំ កម្មានំ** (កម្មថ្មី) បានដល់ កម្មដែលគប្បីសន្សំក្នុងបច្ចុប្បន្ន ។ បទថា **អករណា** (ដោយការមិនធ្វើ) សេចក្តីថា ដោយការមិនសន្សំ ។ ដោយបទថា **សេតុឃាតំ** (ការកាត់ផ្តាច់) និគណ្ឋនាដបុត្រពោលដល់ការកាត់ផ្លូវដើរ គឺ កម្មាត់បច្ច័យ ។ បទថា*

**កម្មក្ខយា ទុក្ខក្ខយោ** (ព្រោះអស់កម្ម ទុក្ខក៏អស់) បានដល់ ព្រោះកម្មវដ្តៈអស់ ទុក្ខវដ្តៈក៏អស់ ។ បទថា **ទុក្ខក្ខយា វេទនាក្ខយោ** (ព្រោះអស់ទុក្ខ វេទនាក៏អស់) បានដល់ ព្រោះទុក្ខវដ្តៈអស់ វេទនាក៏អស់ អធិប្បាយថា កាលទុក្ខវដ្តៈអស់ទៅ សូម្បីការវិលទៅនៃវេទនា ក៏អស់ទៅដូចគ្នា ។ បទថា **វេទនាក្ខយា សព្វំ ទុក្ខំ និជ្ជិណ្ណំ ភវិស្សតិ** (ព្រោះវេទនាអស់ ទុក្ខទាំងពួងក៏វិនាសទៅ) សេចក្តីថា ក៏វដ្តទុក្ខទាំងអស់ទីងវិនាសទៅមិនមានសល់ ព្រោះវេទនាអស់ទៅ ។ បទថា **សន្ទិដ្ឋិ-កាយ** (ជាសន្ទិដ្ឋិកៈ) សេចក្តីថា ដែលទីងគប្បីឃើញ គឺ ប្រចក្សផង ។ បទថា **និជ្ជរាយ វិសុទ្ធិយា** សេចក្តីថា ឈ្មោះថា និជ្ជរាយៈ ព្រោះជាបដិបទាដែលធ្វើកិលេសឲ្យវិនាស ឬព្រោះកិលេសទាំងឡាយវិនាសទៅមិនមានសេសសល់ ឈ្មោះថា បរិសុទ្ធិ ព្រោះញុំាងសត្វទាំងឡាយឲ្យដល់សេចក្តីបរិសុទ្ធិ ព្រោះដូច្នោះទើបឈ្មោះថា និជ្ជរាយវិសុទ្ធិ ។ បទថា **សមតិក្កមោ ហោតិ** (ការកន្លងផុត) សេចក្តីថា មានការកន្លងផុតវដ្តទុក្ខទាំងអស់ ។ បទថា **ឥធ ភន្តេ ភគវា កិមាហ** (លោកដ៏ចម្រើន ក្នុងធម្មវិន័យនេះ ព្រះមានព្រះភាគត្រាស់ដូចម្តេច) សេចក្តីថា និគណ្ឋនាដបុត្រសួរថា បពិត្រលោកដ៏ចម្រើន សម្រាប់វត្តបដិបត្តិនេះ ព្រះមានព្រះភាគត្រាស់ទុកដូចម្តេច គឺ ទ្រង់បញ្ញត្តិបដិបទានៃការអស់ទៅរបស់កិលេសនេះទុកដូចម្តេច ឬទ្រង់បញ្ញត្តិទុកជាយ៉ាងដទៃ ។

បទថា **ជានតា** (ទ្រង់ដឹង) សេចក្តីថា ទ្រង់ដឹងដោយអនាវរណញ្ញាណ ។ បទថា **បស្សតា** (ទ្រង់ឃើញ) សេចក្តីថា ទ្រង់ឃើញដោយសមន្តចក្ខុ ។ បទថា **វិសុទ្ធិយា** (ដើម្បីសេចក្តីបរិសុទ្ធិ) សេចក្តីថា ដើម្បីប្រយោជន៍ក្នុងការឲ្យដល់សេចក្តីបរិសុទ្ធិ ។ បទថា **សមតិក្កមាយ** (ដើម្បីឈានកន្លង) សេចក្តីថា ដើម្បីប្រយោជន៍ឲ្យដល់ការរួចផុត ។ បទថា **អត្ថង្គមាយ** (ដើម្បីរួចផុត) សេចក្តីថា ដើម្បីប្រយោជន៍ដល់ការរលត់ ។ បទថា **ញាយស្ស អធិគមាយ** (ដើម្បីសម្រេចធម៌ដ៏ត្រឹមត្រូវ) សេចក្តីថា ដើម្បីប្រយោជន៍ដល់ការសម្រេចមគ្គព្រមដោយវិបស្សនា ។ បទថា **និព្វានស្ស សច្ឆិកិរិយាយ** (ដើម្បីធ្វើឲ្យជាក់ច្បាស់ព្រះនិព្វាន) សេចក្តីថា ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលរកបច្ច័យមិនបាន ។

បទថា **នវញ្ច កម្មំ ន ករោតិ** (បុគ្គលមិនធ្វើកម្មថ្មី) សេចក្តីថា មិនសន្សំកម្មថ្មី ។ បទថា **បុរាណញ្ច កម្មំ** (កម្មចាស់) បានដល់ កម្មដែលសន្សំមកហើយក្នុងកាលមុន ។ បទថា **ផុស្ស ផុស្ស ព្យន្តីករោតិ** (ប៉ះខ្ទប់...ហើយក៏ធ្វើអស់ទៅ) សេចក្តីថា ប្រឈម (កម្មចាស់ចូលមកហើយ) ក៏ធ្វើឲ្យអស់ទៅ អធិប្បាយថា ពាល់ត្រូវផស្សៈដែលជាវិបាកហើយ ធ្វើកម្មនោះឲ្យអស់ទៅ ។

បទថា **សន្ទិដ្ឋិកា** (គប្បីឃើញឯង) សេចក្តីថា ដែលបុគ្គលគប្បីឃើញ

ឯង ។ បទថា **អកាលិកា** (មិនប្រកបដោយកាល) សេចក្តីថា ធ្វើនាទីមិនរង់ចាំកាល ។ បទថា **ឯហិបស្សិកា** (គួរហៅឲ្យមកមើល) សេចក្តីថា គួរដើម្បីបង្ហាញឲ្យឃើញយ៉ាងនេះថា លោកចូរមកមើលចុះ ។ បទថា **ឱបនយិកា** (គួរបង្អោនចូលមក) សេចក្តីថា គួរក្នុងការបង្អោនចូលមក គឺ សមគួរដល់ធម៌ដែលខ្លួនគួរជាប់ជំពាក់ ។ បទថា **បច្ចត្តំ វេទិតព្វា វិញ្ញូហិ** (ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួន) សេចក្តីថា ដែលបណ្ឌិតទាំងឡាយ គប្បីដឹងបានក្នុងសន្តានរៀងៗ ខ្លួនរបស់ឯង តែពាលជនទាំងឡាយដឹងបានលំបាក ដូចនោះ មគ្គ ២ ផល ២ ព្រះមានព្រះភាគត្រាស់ទុកហើយ ដោយអំណាចនៃសីល ព្រោះថា ព្រះសោតាបន្នព្រះសកទាគាមីជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីល ។ ចំណែកមគ្គ ៣ ផល ៣ ត្រាស់ទុកហើយដោយសមាធិសម្បត្តិ មានជាអាទិថា ស្ងាត់ចាកកាមទាំងឡាយ ព្រោះព្រះអរិយសាវកថ្នាក់ព្រះអនាគាមិបុគ្គល ព្រះមានព្រះភាគត្រាស់ថា ជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសមាធិ ។

ដោយពាក្យមានជាអាទិ៍ថា **អាសវានំ ខយា** (ព្រោះអស់អាសវៈទាំងឡាយ) ព្រះអង្គត្រាស់ (សំដៅដល់) ព្រះអរហត្តផល ។ ក៏សីល និងសមាធិប្រភេទខ្លះដែលសម្បយុត្តដោយព្រះអរហត្តផល ទ្រង់បំណាងយកហើយក្នុងសូត្រនេះ តែដើម្បីសម្តែងដល់វត្តបដិបត្តិដោយអំណាចនៃសីល និងសមាធិ តែមួយ

ប្រភេទ ទើបទ្រង់លើកឡើងទុកជាផ្នែកៗ ដូច្នេះឯង ។

ចប់អដ្ឋកថា និគណ្ឋសូត្រទី ៤

# អដ្ឋកថា និវេសកសូត្រទី ៥[(១)]

## "ពោលដោយឋានៈ ៣ យ៉ាង"

គប្បីជ្រាបវិនិច្ឆ័យក្នុង សមាទបកសូត្រទី ៥ ដូចតទៅនេះ ៖

[៧៧] បទថា **អមច្ចា** (អាមាត្យ) បានដល់ មិត្តដែលមានចិត្តល្អ ។ បទថា **ញាតិ** (ញាតិ) បានដល់ ញាតិចំណែកស្វាមី និងចំណែកភរិយា ។ បទថា **សាលោហិតា** បានដល់ ញាតិអ្នករួមខ្សែលោហិត មានបងប្អូនប្រុស បងស្រីប្អូនស្រីជាដើម ។ បទថា **អវេច្ចប្បសាទេ** (ក្នុងសេចក្ដីជ្រះថ្លាមិនកម្រើក) សេចក្ដីថា មានសេចក្ដីជ្រះថ្លាដែលមិនញាប់ញ័រ ដែលកើតឡើងដោយយល់ដឹងដល់គុណទាំងឡាយ ។

បទថា **អញ្ញថត្តំ** (ភាពជាដទៃ) បានដល់ សភាពជាយ៉ាងដទៃដោយភាវៈ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បឋវីធាតុ** ជាដើមដូចតទៅនេះ ។ បឋវីធាតុដែលជាធាតុមានអាការរឹង ក្នុងកោដ្ឋាសៈ ២០ យ៉ាង (គប្បីមានសេចក្ដីដទៃទៅបាន) អាបោធាតុដែលជាទឹក ជាធាតុកកផ្ដុំ ក្នុងកោដ្ឋាសៈ ១២ យ៉ាង (គប្បីមានសេចក្ដីដទៃទៅបាន) តេជោធាតុ ដែលជាធាតុក្ដៅ ក្នុងកោដ្ឋាសៈ ៤ យ៉ាង (គប្បីមានសេចក្ដីដទៃទៅបាន) វាយោធាតុ ដែលជាធាតុខ្យល់ ក្នុងកោដ្ឋាសៈ ៦

---

(១) បិដក ជាសមាទបកសូត្រ ។

យ៉ាង (គប្បីមានសេចក្ដីដទៃទៅបាន) ។

ដោយបទថា **សិយា អញ្ញថត្តំ ន ត្វេវ** (សេចក្ដីដទៃ... គប្បីមានបាន ចំណែក...មិនគប្បីមានឡើយ) ព្រះមានព្រះភាគទ្រង់សម្ដែងថា ពិតហើយ មហាភូតរូបទាំង ៤ នេះ គប្បីមានសេចក្ដីជាដទៃទៅបាន ព្រោះចូលដល់សភាវៈជាដទៃៗ តែសម្រាប់ព្រះអរិយសាវក មិនមានសេចក្ដីជាដទៃទៅបានឡើយ ។

ក៏ក្នុងព្រះសូត្រនេះ បទថា **អញ្ញថត្តំ** (ភាពជាដទៃ) បានដល់ សភាពដទៃដោយសេចក្ដីជ្រះថ្លា និងសភាពដទៃដោយគតិ ព្រោះថា ទាំង ២ យ៉ាងនោះមិនមានដល់ព្រះអរិយសាវកនោះ មានតែសភាពជាដទៃដោយភាវៈ អធិប្បាយថា ព្រះអរិយសាវកដែលជាមនុស្ស ទៅជាទេវតាក៏មាន ទៅជាព្រហ្មក៏មាន តែសេចក្ដីជ្រះថ្លារបស់ព្រះអរិយសាវកនោះ នឹងមិនដាច់ (ប្រែប្រួល) ក្នុងរវាងភពទាំងនឹងមិនដល់សភាពជាដទៃដោយគតិ ពោលគឺ អបាយគតិ ។ សូម្បីព្រះ-បរមសាស្ដា កាលនឹងទ្រង់សម្ដែងសេចក្ដីនោះឯង ទើបត្រាស់ពាក្យមានជាអាទិ៍ថា **នេះគឺសភាពជាដទៃក្នុងប្រការនោះ** ដូច្នេះ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា និវេសកសូត្រទី ៥

# អដ្ឋកថា បឋមភវសូត្រទី ៦[១]

## *“ហេតុកើតនៃភពទាំង ៣”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមភវសូត្រទី ៦ ដូចតទៅនេះ ៖*

*[៧៨] បទថា **កាមធាតុវេបក្កំ** (ដែលអំណោយផលក្នុងកាមធាតុ) បាន ដល់ កម្មដែលឲ្យផលក្នុងកាមធាតុ ។ បទថា **កាមភវោ** (កាមភព) បានដល់ ភពដែលឧប្បត្តិក្នុងកាមធាតុ ។ បទថា **កម្មំ ខេត្តំ** (កម្មឈ្មោះថាជាស្រែ) សេចក្តីថា កុសលកម្ម និងអកុសលកម្ម ឈ្មោះថា ជាស្រែ ព្រោះអត្ថថា ជាទីដុះឡើង (នៃវិបាកខន្ធ) ។ បទថា **វិញ្ញាណំ ពីជំ** (វិញ្ញាណឈ្មោះថាជាពូជ) សេចក្តីថា វិញ្ញាណដែលមានអភិសង្ខារជាបច្ច័យ ដែលកើតព្រមគ្នា ឈ្មោះថា ជាពូជ ព្រោះអត្ថថា ជាហេតុដុះឡើង ។ បទថា **តណ្ហាស្នេហោ** (តណ្ហាឈ្មោះថាជាទឹក) សេចក្តីថា តណ្ហា ឈ្មោះថា ទឹក ព្រោះដោយអំណាចនៃការឧបត្ថម្ភ និងកពូន ។*

*បទថា **អវិជ្ជានីវរណានំ** (មានអវិជ្ជាជាទំនប់) សេចក្តីថា បុគ្គលដែលអវិជ្ជាភាំងហើយ ។ បទថា **តណ្ហាសញ្ញោជនានំ** (មានតណ្ហាជាគ្រឿងចង) សេចក្តីថា បុគ្គលត្រូវគ្រឿងចង គឺ តណ្ហាចងទុក ។ បទថា **ហីនាយ ធាតុយា***

---

*(១) បិដកជា នវសូត្រ ។*

(ព្រោះហីនធាតុ) បានដល់ ព្រោះកាមធាតុ ។ បទថា **វិញ្ញាណំ បតិដ្ឋិតំ** (វិញ្ញាណតាំងមាំហើយ) សេចក្តីថា វិញ្ញាណដែលមានអភិសង្ខារជាបច្ច័យ តាំងមាំហើយ ។ បទថា **មជ្ឈិមាយ ធាតុយា** (ព្រោះធាតុជាកណ្តាល) បានដល់ ព្រោះរូបធាតុ ។ បទថា **បណីតាយ ធាតុយា** (ព្រោះធាតុដ៏ប្រណីត) បានដល់ ព្រោះអរូបធាតុ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា បឋមភវសូត្រទី ៦

# អដ្ឋកថា ទុតិយភវសូត្រទី ៧

*"ហេតុកើតនៃភពទាំង ៣"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយភវសូត្រទី ៧ ដូចតទៅនេះ ៖*

*[៧៩] ចេតនាជាហេតុធ្វើកម្ម ឈ្មោះថា **ចេតនា** ។ សេចក្តីប្រាថ្នាដែលធ្វើកម្ម ឈ្មោះថា **សេចក្តីប្រាថ្នា** ។ ពាក្យដ៏សេស មានសេចក្តីដូចគ្នានឹងសូត្រមុនទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ទុតិយភវសូត្រទី ៧

# អដ្ឋកថា សីលព្វតសូត្រទី ៨

## “ផលនៃសីលព្វត”

គប្បីជ្រាបវិនិច្ឆ័យក្នុង សីលព្វតសូត្រទី ៨ ដូចតទៅនេះ ៖

[៨០] បទថា **សីលព្វតំ** បានដល់ សីល និងវត្ត ។ បទថា **ជីវិតំ** បានដល់ សេចក្តីព្យាយាមរបស់អ្នកធ្វើកម្ម ដែលធ្វើបានដោយលំបាក ។ បទថា **ព្រហ្មចរិយំ** បានដល់ ការប្រព្រឹត្តព្រហ្មចរិយៈ ។ បទថា **ឧបដ្ឋានសារំ** (ដែលមានសារៈដោយសេចក្តីប្រាកដ) សេចក្តីថា សីលជាដើមនេះមានសារៈ ព្រោះជាធម៌គ្រឿងប្រាកដ អធិប្បាយថា ប្រាកដយ៉ាងនេះថា សីលជាដើមនេះជាខ្លឹមសារ សីលជាដើមនេះជារបស់ប្រសើរ សីលជាដើមនេះជាហេតុឲ្យសម្រេច ។ ព្រះមានព្រះភាគត្រាស់សួរថា សីលជាដើមនេះ មានផល គឺ មានសេចក្តីចម្រើនដោយបទថា **មានផល** ដូច្នេះ ។ បទថា **ន ខ្វេត្ថ ភន្តេ ឯកំសេន** (ប្រការនេះនឹងព្យាករណ៍តែម្យ៉ាងមិនបានឬ ព្រះអង្គ) សេចក្តីថា (ព្រះអានន្ទឆ្លើយថា) បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសេចក្តីនេះ មិនគួរព្យាករណ៍ដោយចំណែកមួយឡើយ ។ បទថា **ឧបដ្ឋានសារំ សេវតោ** (កាលប្រព្រឹត្ត... ដែលមានសារៈដោយសេចក្តីប្រាកដ) សេចក្តីថា កាលបដិបត្តិសីលជាដើមដែលជាសារៈ គឺ ជាគ្រឿងប្រាកដយ៉ាងនេះថា សីលជាដើមនេះ ជាសារៈ ជាវត្ថុប្រសើរ ជាហេតុឲ្យសម្រេច ។

បទថា ***អផលំ*** សេចក្ដីថា មិនមានផល ដោយផលដែលត្រូវការ ។ ដោយពាក្យឆ្លើយឆ្លងត្រឹមតែប៉ុណ្ណេះ ។ ជាការកាន់យកលទ្ធិខាងក្រៅសូម្បីទាំងអស់ដ៏សេស វៀរការបព្វជ្ជារបស់កម្មវាទីបុគ្គល និងកិរិយវាទីបុគ្គល ។ បទថា ***សផលំ*** បានដល់ មានផល គឺ មានផល ដោយផលដែលបានសមតាមបំណង ដោយពាក្យត្រឹមប៉ុណ្ណេះ ជាការកាន់យកបព្វជ្ជារបស់កម្មវាទីបុគ្គល និងកិរិយ-វាទីបុគ្គលសូម្បីទាំងអស់ ផ្ដើមតាំងពី (ពុទ្ធ) សាសនានេះ ។ ដោយបទថា ***ន ច បនស្ស សុលភរូបោ សមសមោ បញ្ញាយ*** (តែបុគ្គលស្មើនឹងព្រះអានន្ទផ្នែកបញ្ញា មិនមែនរកបានងាយ) នេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា បុគ្គលដែលតាំងនៅក្នុងសេក្ខភូមិ ឆ្លើយបញ្ហាបានយ៉ាងនេះ ដែលស្មើដោយបញ្ញារបស់ព្រះអានន្ទនោះ រកមិនបានងាយ ។ ធម៌ ឈ្មោះថា សេក្ខភូមិ ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងព្រះសូត្រនេះ ។

ចប់អដ្ឋកថា សីលព្វតសូត្រទី ៨

# អដ្ឋកថា គន្ធសូត្រទី ៩

## “ក្លិនរបស់ក្រអូប ៣ យ៉ាង”

គប្បីជ្រាបវិនិច្ឆ័យក្នុង គន្ធសូត្រទី ៩ ដូចតទៅនេះ ៖

[៨១] បទថា **ឯតទវោច** (បានក្រាបទូលសួរសេចក្តីនេះ) សេចក្តីថា ក្នុងវេលាក្រោយភត្តាហារ ព្រះអានន្ទត្ថេរត្រឡប់ពីបិណ្ឌបាត សម្តែងវត្តចំពោះព្រះទសពលហើយ ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន ហើយគិតថា ក្នុងលោកនេះ ដែលឈ្មោះថា ក្លិនកើតពីឫសក៏មាន ក្លិនកើតពីខ្លឹមក៏មាន ក្លិនកើតពីផ្កាក៏មាននៅ តែក្លិនទាំង ៣ យ៉ាងនេះ រមែងផ្សាយទៅតាមខ្យល់ប៉ុណ្ណោះ មិនផ្សាយទៅច្រាស់ខ្យល់ឡើយ មានគន្ធជាតអ្វី ដែលផ្សាយទៅច្រាស់ខ្យល់បានហ្ន៎ ដូច្នេះ ព្រោះហេតុដែលលោកទទួលពរ គឺ ការចូលទៅគាល់ក្នុងវេលាដែលកើតសេចក្តីសង្ស័យ ក្នុងកាលដែលទទួលពរ ៨ ប្រការទុំះឯង ក្លាមនោះ ទើបចេញចាកទីសម្រាកពេលថ្ងៃទៅកាន់សំណាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ដើម្បីនឹងបន្ទោបង់សេចក្តីសង្ស័យដែលកើតឡើង ទើបបានក្រាបទូលពាក្យនេះ គឺ ពាក្យមានជាអាទិ៍ថា **បពិត្រព្រះអង្គដ៏ចម្រើន...៣ យ៉ាងនេះ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **គន្ធជាតានិ** (គន្ធជាតិ) បានដល់របស់ក្រអូបដោយកំណើតទាំងឡាយ ។ បទថា **មូលគន្ធោ** (ក្លិនដែលកើតពីឫស)

បានដល់ ក្លិនដែលតាំងនៅក្នុងឫស ឬឫសដែលសម្បូរណ៍ដោយក្លិនទុំះឯង ទើបឈ្មោះថា **ក្លិនកើតពីឫស** ព្រោះថា ក្លិនរបស់ឫសនោះ រមែងផ្សាយទៅតាមខ្យល់ ។ តែក្លិនរបស់ក្លិន (នោះ) មិនមាន ។ សូម្បីក្នុងក្លិនដែលកើតពីខ្លឹម និងក្លិនដែលកើតពីផ្កា ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អត្ថានន្ទ គន្ធជាតំ** (អានន្ទ មាន...គន្ធជាតិ) នេះ ដូចតទៅនេះ ការដល់សរណៈជាដើម ឈ្មោះថា ជាក្លិន ព្រោះស្រដៀងក្លិនដោយផ្សាយទៅគ្រប់ទិស ដោយអំណាចនៃការពោលសរសើរគុណ គឺ សេចក្តីល្អ ក្លិនទាំងនោះ មានបុគ្គលជាទីតាំង ទើបឈ្មោះថា គន្ធជាត ។ បទថា **គន្ធោ គច្ឆតិ** (ក្លិនផ្សាយទៅ) សេចក្តីថា ផ្សាយទៅដោយអំណាចនៃការពោលសរសើរ ។ បទថា **សីលវា** (មានសីល) បានដល់ មានសីល ដោយសីល ៥ ឬសីល ១០ ។ បទថា **កល្យាណធម្មោ** (មានកល្យាណធម៌) សេចក្តីថា មានកល្យាណធម៌ គឺ មានធម៌ដែលល្អស្អាត ដោយសីលធម៌ទុំះឯង ។ អធិប្បាយរបស់បទមានជាអាទិ៍ថា **វិគតមលមច្ឆេរេន** (ប្រាសចាសសេចក្តីកំណាញ់ដែលជាសេចក្តីសៅហ្មង) ជាដើម បានឲ្យពិស្តារទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ បទថា **ទិសាសុ** (ក្នុងទិសទាំងឡាយ) បានដល់ ក្នុងទិសធំ ៤ ក្នុងទិសតូច ៤ ។

បទថា **សមណព្រាហ្មណា** បានដល់ សមណព្រាហ្មណ៍អ្នកស្ងប់បាប

និងបណ្តែតបាបហើយ ។

បទថា **ន បុប្ផគន្ធោ បដិវាតមេតិ** (ក្លិនផ្កាផ្សាយទៅបញ្ច្រាសខ្យល់មិនបាន) សេចក្តីថា ក្លិនរបស់ផ្កាម្លិះជាដើម នឹងមិនផ្សាយទៅបញ្ច្រាសខ្យល់ ។ បទថា **ន ចន្ទនំ តគរមល្លិកា វា** (ក្លិនចន្ទន៍ ក្រឹស្នា ឬលំពាន់ ក៏ផ្សាយទៅបញ្ច្រាសខ្យល់មិនបាន) មានអត្ថាធិប្បាយថា សូម្បីក្លិនរបស់ចន្ទន៍ ក្រឹស្នា ឬលំពាន់ ក៏ផ្សាយបញ្ច្រាសខ្យល់មិនបាន ។ ពិតហើយ អ្នកប្រាជ្ញទាំងឡាយពោលថា សូម្បីក្នុងទេវលោក ក៏មានផ្កាម្លិះដែលរីកហើយដូចគ្នា ក្នុងថ្ងៃដែលផ្កាម្លិះនោះរីកហើយ ក្លិនក៏នឹងផ្សាយទៅបាន ១០០ យោជន៍ តែក្លិននោះ ក៏មិនអាចផ្សាយទៅច្រាសខ្យល់បាន សូម្បីត្រឹមតែមួយចំអាម ឬត្រឹមតែមួយហត្ថ ។ បទថា **សតញ្ច គន្ធោ បដិវាតមេតិ** (ចំណែកក្លិនសប្បុរសផ្សាយទៅបញ្ច្រាសខ្យល់បាន) សេចក្តីថា ចំណែកក្លិន គឺ គុណ មានសីលជាដើមរបស់សប្បុរសទាំងឡាយ គឺបណ្ឌិតទាំងឡាយ បានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវកទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ។ បទថា **សព្វា ទិសា សប្បុរិសោ បវាយតិ** (សប្បុរសរមែងផ្សាយទៅគ្រប់ទិស) សេចក្តីថា សប្បុរស គឺ បណ្ឌិត រមែងផ្សាយទៅគ្រប់ទិស ដោយក្លិន គឺ គុណសេចក្តីល្អ មានសីលជាដើម ។ អធិប្បាយថា មានក្លិនផ្សាយទៅទូទាំងទិស ។

ចប់អដ្ឋកថា គន្ធសូត្រទី ៩

# អដ្ឋកថា ចូឡនីសូត្រទី ១០

## *“ពោលដោយសែនកោដិចក្រវាល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចូឡនីសូត្រទី ១០ ដូចតទៅនេះ ៖*

*[៨២] ក្នុងសូត្រទី ១០ មានប្រការដែលលើកឡើងទុក ២ យ៉ាង គឺ ការលើកប្រការដែលទាក់ទងនឹងហេតុកើតនៃរឿង ១ ដែលទាក់ទងនឹងការសួរ ១ ។ ប្រសិនបើមានពាក្យសួរថា ក្នុងការកើតឡើងនៃសេចក្ដីដូចម្ដេច ព្រះមានព្រះភាគត្រាស់ឆ្លើយពាក្យសួររបស់នរណា ។ ឆ្លើយថា ក្នុងការកើតឡើងនៃរឿងរបស់អរុណវតីសូត្រ ព្រះមានព្រះភាគត្រាស់តបពាក្យសួររបស់ព្រះអានន្ទត្ថេរ ។ សួរថា អរុណវតីសូត្រ នរណាពោលទុក ។ ឆ្លើយថា ព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សិខី** និងព្រះសាស្ដារបស់យើងត្រាស់ទុក ។*

## *ការឧប្បត្តិនៃអរុណវតីសូត្រសម័យព្រះសិខីសម្ពុទ្ធ*

*អធិប្បាយសេចក្ដីថា រាប់ពីកប្បនេះថយក្រោយទៅ ក្នុងកប្បទី ៣១ ក្នុងអរុណវតីនគរ ព្រះមានព្រះភាគព្រះនាមថា **សិខី** ទ្រង់បដិសន្ធិក្នុងគភ៌របស់ព្រះមហេសីព្រះនាមថា **បភាវតី** របស់ព្រះបាទអរុណវតី កាលព្រះញាណចាស់ក្លាហើយ ស្ដេចចេញមហាភិនេសក្រមណ៍ ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណត្រង់គល់ដើមមហាពោធិ៍ ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ទ្រង់អាស្រ័យអរុណវតីនគរប្រថាប់*

នៅ ។ ថ្ងៃមួយវេលាព្រឹកព្រលឹម ទ្រង់បដិបត្តិសរីរកិច្ចហើយ មានភិក្ខុសង្ឃចំនួនច្រើនជាបរិវារ ទ្រង់ព្រះតម្រិះថា តថាគតនឹងទៅកាន់អរុណវតីនគរ ដើម្បីបិណ្ឌបាត ហើយស្តេចចេញ ទៅប្រថាប់ឈរជិតខ្លោងទ្វារព្រះវិហារ ទ្រង់ត្រាស់ហៅព្រះអគ្គសាវកនាមថា **អភិភូ** មក ត្រាស់ថា ម្នាលភិក្ខុ វេលានៅព្រឹកណាស់ ដែលនឹងទៅកាន់អរុណវតីដើម្បីបិណ្ឌបាត យើងទាំងឡាយនឹងទៅកាន់ព្រហ្មលោកជាន់ណាមួយសិន ដូច្នេះ ។

សមដូចព្រះអង្គត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះមានព្រះភាគព្រះនាមថា សិខីអរហន្តសម្មាសម្ពុទ្ធ ត្រាស់ហៅអភិភូភិក្ខុមក ទ្រង់ត្រាស់ថា មកចុះព្រាហ្មណ៍ យើងទាំងពីរនឹងទៅកាន់ព្រហ្មលោកជាន់ណាមួយ វេលាភត្តាហារនឹងមិនទាន់ដល់ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួលព្រះពុទ្ធតម្រាស់របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា សិខី ហើយគ្រានោះឯង ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះនាមថា សិខី និងព្រះអភិភូភិក្ខុ បានចូលទៅកាន់ព្រហ្មលោកជាន់ណាមួយហើយ ។

មហាព្រហ្មក្នុងព្រហ្មលោកនោះ បានឃើញព្រះសម្មាសម្ពុទ្ធហើយ ត្រេកអរធ្វើការក្រោកទទួល បានក្រាលអាសនៈព្រហ្មថ្វាយ ។ ចំណែកព្រះថេរៈ ព្រហ្មទាំងឡាយក៏នាំគ្នាក្រាលអាសនៈដែលសមគួរប្រគេន ។ ព្រះមានព្រះភាគប្រថាប់

គង់លើអាសនៈដែលគេក្រាលថ្វាយហើយ សូម្បីព្រះថេរៈក៏គង់លើអាសនៈដែលគេក្រាលប្រគេនខ្លួន ។ ចំណែកស្តេចមហាព្រហ្មក៏ថ្វាយបង្គំព្រះទសពល ហើយប្រថាប់អង្គុយក្នុងចំណែកម្ខាង ។

គ្រានោះឯង ព្រះមានព្រះភាគព្រះនាម សិខី បានត្រាស់ហៅភិក្ខុឈ្មោះថា អភិភូ ទ្រង់ត្រាស់ថា ព្រាហ្មណ៍ អ្នកចូរសម្តែងធម្មីកថាដល់ព្រហ្ម បរិស័ទរបស់ព្រហ្ម និងព្រហ្មជាន់បារិសជ្ជា ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួលព្រះពុទ្ធតម្រាស់របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះនាមថា សិខី ហើយសម្តែងធម្មីកថាដល់ព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មជាន់បារិសជ្ជា កាលព្រះថេរៈសម្តែងធម៌ហើយ ព្រហ្មទាំងឡាយលើកទោសថា យូរណាស់ហើយ ពួកយើងទើបនឹងបានឃើញព្រះបរមសាស្តាស្តេចមកកាន់ព្រហ្មលោក តែភិក្ខុនេះខារខាំងព្រះសាស្តា ហើយសម្តែងធម្មកថាដោយខ្លួនឯង ។

ព្រះសាស្តាទ្រង់ជ្រាបថា ពួកព្រហ្មទាំងនោះមិនពេញចិត្ត ទើបបានត្រាស់ចំពោះអភិភូភិក្ខុ ដូច្នេះថា ព្រាហ្មណ៍ ព្រហ្ម ព្រហ្មបរិស័ទ និងព្រហ្មជាន់បារិសជ្ជា នាំគ្នាលើកទោសអ្នក បើដូច្នោះ អ្នកចូរធ្វើឲ្យព្រហ្មទាំងនោះតក់ស្លុតឲ្យក្រៃលែងចុះ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ហើយ ធ្វើការប្លែងឫទ្ធិច្រើនយ៉ាង ច្រើនប្រការ កាលនឹងញ៉ាំងលោកធាតុមួយពាន់ឲ្យដឹងច្បាស់ដោយសំឡេង ទើបបាន

ពោល ២ គាថាថា **អារម្ភថ និក្កមថ** (អ្នកទាំងឡាយចូរចាប់ផ្តើម ចូរឈានកន្លង) ដូច្នេះ ជាដើម ។

សួរថា ក៏ព្រះថេរៈធ្វើដូចម្តេច ទើបឲ្យលោកធាតុទាំងមួយពាន់ដឹងច្បាស់បាន ។

ឆ្លើយថា ព្រះថេរៈចូលនីលកសិណជាមុន ហើយផ្សាយភាពងងឹតទៅទូទាំងទិសទាំងពួង តពីនោះ កាលសត្វទាំងឡាយកើតសេចក្តីរពឹងឡើងថា នេះជាសេចក្តីងងឹតអន្ធការអ្វីហ្ន៎ ទើបសម្តែងជាពន្លឺ ។ កាលពួកគេគិតថា នេះពន្លឺអ្វី ទើបសម្តែងខ្លួនឲ្យឃើញ ទេវតា និងមនុស្សទាំងឡាយក្នុងមួយពាន់ចក្រវាឡទើបបាននាំគ្នាឈរផ្គងអញ្ជលី នមស្ការព្រះថេរៈនោះឯង ។ ព្រះថេរៈអធិដ្ឋានថា សូមមហាជន ចូរបានឮសំឡេងរបស់យើងអ្នកសម្តែងធម៌ ដូច្នេះ ហើយបានភាសិតគាថាទាំងនេះ ។ ទេវតា និងមនុស្សទាំងឡាយទាំងពួង បានឮសំឡេងរបស់ព្រះថេរៈ ដូចជាអង្គុយសម្តែងធម៌នៅត្រង់កណ្តាលបរិស័ទ ដែលព្រមព្រៀងហើយ សូម្បីសេចក្តីក៏ប្រាកដច្បាស់ដល់ទេវតា និងមនុស្សទាំងនោះ ។

គ្រានោះឯង ព្រះមានព្រះភាគ ស្តេចបានត្រឡប់មកកាន់អរុណវតីនគរព្រមជាមួយព្រះថេរៈ ស្តេចបិណ្ឌបាត ស្តេចត្រឡប់ពីបិណ្ឌបាត ខាងក្រោយភត្តបានត្រាស់សួរភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានឮសំឡេងរបស់

អភិភូភិក្ខុ ដែលឈរពោលគាថានៅឯព្រហ្មលោកឬទេ ។ ភិក្ខុទាំងនោះទូលថា បានឮព្រះអង្គ ។ កាលនឹងប្រកាសសេចក្តីដែលខ្លួនបានឮ ទើបបានលើកយកគាថាទាំងពីរឡើងមកអាង ។ ព្រះសាស្តាទ្រង់ប្រទានសាធុការថា សាធុ សាធុ ហើយផ្តើមសម្តែងព្រះធម៌ទេសនា ។ ព្រះសូត្រនេះ ដែលព្រះមានព្រះភាគព្រះនាមថា សិខី បានត្រាស់ទុកក្នុងកប្បទី ៣១ រាប់អំពីកប្បនេះថយក្រោយទៅ ដោយប្រការដូចពណ៌នាមកនេះ ។

## ការឧប្បត្តិនៃអរុណវតីសូត្រនៃព្រះពុទ្ធរបស់យើង

ចំណែកព្រះមានព្រះភាគរបស់យើងទាំងឡាយ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ចូលទៅអាស្រ័យព្រះនគរសាវត្ថី ហើយប្រថាប់នៅក្នុងព្រះជេតវនមហាវិហារ ក្នុងថ្ងៃពេញបូរមី ខែជេស្ឋមូល[១] បានត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់ផ្តើមសម្តែងព្រះសូត្រឈ្មោះថា អរុណវតីនេះ ។ ព្រះអានន្ទត្ថេរបានឈរថ្វាយផ្ចិតទុំឯង រៀនព្រះសូត្រទាំងអស់ តាំងពីដើមដរាបចប់ មិនឲ្យជ្រុះសូម្បីតែព្យញ្ជនៈមួយ ។ ក្នុងថ្ងៃស្អែក លោកត្រឡប់ពីបិណ្ឌបាត សម្តែងវត្តចំពោះព្រះទសពលហើយ ត្រឡប់ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលសទ្ធិវិហារិក និងអន្តេវាសិកទាំងឡាយ សម្តែងវត្តហើយចៀស

---

(១) ខែ ៧ ពេលដែលព្រះច័ន្ទគោចរតាមផ្លូវពពួកផ្កាយមូលា ។

ចេញទៅ ក៏អន្តរធានលើកដល់អរុណវតីសូត្រ ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងថ្ងៃម្សិលមិញ ។ គ្រានោះ ព្រះសូត្រទាំងអស់ បានប្រាកដច្បាស់ដល់ (ព្រះអានន្ទ) ។ ព្រះអានន្ទត្ថេរគិតថា អគ្គសាវករបស់ព្រះមានព្រះភាគព្រះនាមថាសិខី ឈរលើព្រហ្មលោក បញ្ចេញរស្មីចាករាងកាយ កម្ចាត់សេចក្តីងងឹតអន្ធការក្នុងចក្រវាឡមួយពាន់ ហើយសម្តែងធម្មកថាឲ្យទេវតា និងមនុស្សបានឮសំឡេងរបស់ខ្លួន ពាក្យដូចដែលពោលមកនេះ ព្រះបរមសាស្តាត្រាស់ទុកហើយកាលពីថ្ងៃម្សិលមិញ វិស័យរបស់ព្រះសាវក (មានអានុភាព) ដូច្នេះហ្ន៎ ចំណែកព្រះសម្មាសម្ពុទ្ធដែលទ្រង់បំពេញបារមី ១០ ទស ហើយសម្រេចព្រះសព្វញ្ញុតញ្ញាណនឹងបន្លឺព្រះសូរសៀងទៅចម្ងាយណាហ្ន៎ ។ ដើម្បីបន្ទោបង់សេចក្តីសង្ស័យដែលកើតហើយយ៉ាងនេះ ក្នុងកាលនោះឯង លោកទើបចូលទៅគាល់ព្រះមានព្រះភាគទូលសួរសេចក្តីនោះ ។ ដើម្បីនឹងសម្តែងសេចក្តីនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលពាក្យថា **គ្រានោះឯង ព្រះអានន្ទ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សម្មុខា** (ចំពោះព្រះភក្ត្រ) សេចក្តីថា ព្រះសូត្រនេះ ខ្ញុំ (ព្រះអានន្ទ) ឈរចំពោះព្រះភក្ត្រស្តាប់ហើយ មិនមែនស្តាប់ដោយបានឮតាមគ្នាមក គឺ មិនបានស្តាប់ដោយតពីអ្នកដែលស្តាប់មកហើយ ព្រះអានន្ទត្ថេរពោលយ៉ាងនេះ ដោយមានន័យដូចអធិប្បាយមកនេះឯង ។

បទថា **កីវតកំ បហោតិ សរេន វិញ្ញាបេតុំ** (ទ្រង់អាចនឹងញុំាងព្រះសូរសៀងឲ្យលោកធាតុមានប្រមាណត្រឹមណាជ្រាបច្បាស់បាន) សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់កម្ចាត់សេចក្ដីងងឹតអន្ធការ ដោយព្រះរស្មីដែលបញ្ចេញចាកព្រះវរកាយ ហើយបន្លឺព្រះសូរសៀងទៅបានឆ្ងាយប៉ុនណា ។

ព្រះមានព្រះភាគត្រាស់ពាក្យនេះថា **អានន្ទ អភិភូនោះជាសាវក ព្រះតថាគតទាំងឡាយ នរណាៗ នឹងប្រមាណមិនបាន** ដោយមានព្រះពុទ្ធបំណងដូច្នេះថា ម្នាលអានន្ទ អ្នកនិយាយអ្វី (យ៉ាងនេះ) ព្រះសាវកតាំងនៅក្នុងញាណដោយចំពោះ តែព្រះតថាគតទ្រង់បំពេញបារមី ១០ ទស ហើយសម្រេចព្រះសព្វញ្ញុតញ្ញាណ នរណាៗ នឹងប្រមាណមិនបាន ។ អ្នក និយាយអ្វីយ៉ាងនេះ ដូចយកចុងក្រចកចូកធូលីឡើងមក ប្រៀបជាមួយគំនរដីនៃមហាប្រថពី ព្រោះវិស័យរបស់ព្រះសាវកទាំងឡាយក៏ជាចំណែកមួយ ឯរបស់ព្រះពុទ្ធទាំងឡាយក៏ជាចំណែកមួយ ធម៌ជាគោចររបស់ព្រះសាវកទាំងឡាយក៏ជាចំណែកមួយ របស់ព្រះពុទ្ធទាំងឡាយក៏ជាចំណែកមួយ កម្លាំងរបស់ព្រះសាវកទាំងឡាយក៏ជាចំណែកមួយ របស់ព្រះពុទ្ធទាំងឡាយក៏ជាចំណែកមួយ ។ ព្រះមានព្រះភាគ លុះត្រាស់សេចក្ដីដែលព្រះពុទ្ធទាំងឡាយ មានអានុភាពរកប្រមាណមិនបាន ដោយមានព្រះពុទ្ធបំណងដូចពណ៌នាមកនេះហើយ ទ្រង់ក៏តុណ្ហីភាព ។

សូម្បីព្រះថេរៈក៏ទូលសួរជាលើកទី ២ ។ ព្រះបរមសាស្តាកាលទ្រង់នឹងសម្តែងថា អានន្ទ អ្នកនិយាយអ្វីយ៉ាងនេះ ដូចជាយកប្រហោងដើមត្នោត ទៅប្រៀបនឹងអាកាសល្ហល្ហេវ ដូចជាយកសត្វត្រចៀកកាំទៅប្រៀបជាមួយស្តេចគ្រុឌ ដែលហើរបានមួយថ្ងៃ ១៥០ យោជន៍ ដូចជាយកទឹកក្នុងប្រមោយជីរទៅប្រៀបនឹងទឹកក្នុងមហាទន្លេគង្គា ដូចជាយកទឹកក្នុងរណ្តៅទទឹងប្រវែង ៤ ហត្ថ ទៅប្រៀបនឹងស្រះទាំង ៧ ដូចជាយកអ្នកដែលមានតម្លៃបានត្រឹមតែបាយ ១ នាឡិទៅប្រៀបនឹងស្តេចចក្រពត្តិ ដូចជាយកបិសាចធូលី ទៅប្រៀបនឹងស្តេចសក្កទេវរាជ និងដូចជាយកពន្លឺរបស់អំពិលអំពែក ទៅប្រៀបនឹងពន្លឺព្រះអាទិត្យ ដូច្នេះ ហើយត្រាស់សេចក្តីដែលព្រះពុទ្ធទាំងឡាយ មានអានុភាពរកប្រមាណមិនបាន ជាលើកទី ២ ហើយទ្រង់តុណ្ហីភាព ។ លំដាប់នោះ ព្រះថេរៈគិតថា ព្រះសាស្តាដែលយើងទូលសួរហើយ មិនត្រាស់តបឡើយ យើងនឹងទូលសូម (ឱកាសទូលសួរ) លើកទី ៣ ហើយនឹងឲ្យព្រះសាស្តាបន្លឺពុទ្ធសីហនាទ ដូច្នេះ ទើបទូលសូមជាលើកទី ៣ ។ ដើម្បីសម្តែងដល់ការទូលសូមជាគ្រាទី ៣ នោះ លោកទើបពោលពាក្យមានអាទិថា **សូម្បីលើកទី ៣** ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់នឹងឆ្លើយបញ្ហារបស់ព្រះអានន្ទ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **អានន្ទ អ្នកបានស្តាប់** ដូច្នេះ ។ ព្រះថេរៈគិតថា

ព្រះបរមសាស្ដាត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះ ដល់យើងថា អានន្ទ ១.០០០ លោកធាតុតិចតួច អ្នកបានស្ដាប់ហើយ (មិនមែនឬ) ហើយទ្រង់តុណ្ហីភាព តទៅនេះ ព្រះពុទ្ធនឹងទ្រង់បន្លឺពុទ្ធសីហនាទ ដូច្នេះ ។ កាលលោកទូលសូមព្រះបរមសាស្ដា ទើបបានក្រាបទូលពាក្យមានជាអាទិ៍ថា **បពិត្រព្រះមានព្រះភាគ ឥឡូវនេះ ជាកាលគួរ** ដូច្នេះ ។

ចំណែកព្រះមានព្រះភាគត្រាស់ពាក្យមានជាអាទិ៍ថា **អានន្ទ បើដូច្នោះ** ដូច្នេះ ដើម្បីនឹងត្រាស់កថាយ៉ាងពិស្ដារ ដល់ព្រះអានន្ទ ។ បណ្ដាបទទាំងនោះ បទថា **យាវតា** (មានប្រមាណប៉ុនណា) បានដល់ រហូតទីមានប្រមាណប៉ុនណា ។ ទាំងព្រះច័ន្ទ ទាំងព្រះអាទិត្យ ឈ្មោះថា **ព្រះច័ន្ទ និងព្រះអាទិត្យ** ។ បទថា **បរិហរន្តិ** (គោចរ) ប្រែថា គោចរទៅ ។ បទថា **ទិសា ភន្តិ** (បញ្ចេញពន្លឺទូទាំងទិស) បានដល់ បំភ្លឺទូទាំងទិស ។ បទថា **វិរោចនា** (ភ្លឺស្វាង) ប្រែថា រុងរោចន៍ហើយ ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ គឺ ទ្រង់កំណត់ចក្រវាឡមួយហើយសម្ដែង ។ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងចក្រវាឡមួយនោះគុណនឹងមួយពាន់ ទើបត្រាស់ថា **លោកមួយក៏មានត្រឹមណា លោកមួយពាន់ក៏ដូច្នោះ** ដូច្នេះ ។ បទថា **តស្មឹ សហស្សធា លោកេ** (ក្នុងលោកចំនួនមួយពាន់នោះ) សេចក្ដីថា ក្នុងមួយពាន់នៃចក្រវាឡនោះ ។ បទថា **សហស្សំ ចាតុម្មហារាជិកានំ** (មានទេវលោកជាន់ចាតុ-

មហារាជ ១.០០០) បានដល់ ទេវលោកជាន់ចាតុម្មហារាជិកាមួយពាន់ ក៏ព្រោះហេតុតែក្នុងមួយចក្រវាឡ មានស្តេចមហារាជប្រចាំនៅចក្រវាឡមួយ ៤ៗ ដូច្នោះទើបត្រាស់ថា **មានមហារាជ ៤.០០០** ដូច្នេះ ។ ក្នុងគ្រប់ៗ បទ គប្បីជ្រាបសេចក្តីដោយឧបាយនេះ ។ បទថា **ចូឡនិកា** (យ៉ាងតូច) បានដល់ លោកធាតុខ្នាតតូច ។ នេះជាវិស័យរបស់ព្រះសាវកទាំងឡាយ ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់នាំលោកធាតុខ្នាតតូចនេះមក (សម្តែង) ។ ឆ្លើយថា ដើម្បីទ្រង់សម្តែងដល់ការកំណត់លោកធាតុខ្នាតកណ្តាល ។

បទថា **យាវតា** គឺ **យត្តកា** (មានប្រមាណប៉ុនណា) ។ បទថា **តាវសហស្សធា** (មានទីប្រមាណប៉ុណ្ណោះ មានដោយចំនួន ១.០០០) សេចក្តីថា លោក (ចក្រវាឡ) មានទីប៉ុណ្ណោះ ដោយចំនួន ១.០០០ ។ ដោយបទថា **ទ្វិសហស្សី មជ្ឈិមិកា លោកធាតុ** នេះ ទ្រង់សម្តែងថា លោកធាតុនេះមានចំនួនមួយពាន់ពីរដង មានចក្រវាឡមួយលានជាប្រមាណ ដោយយកមួយពាន់គុណនឹងចក្រវាឡមួយពាន់ ឈ្មោះថា **លោកធាតុខ្នាតកណ្តាល** ។ នេះមិនមែនវិស័យនៃព្រះសាវកទាំងឡាយ ជាវិស័យរបស់ព្រះពុទ្ធប៉ុណ្ណោះ ។ ព្រោះថា ក្នុងទីប៉ុណ្ណោះ ព្រះតថាគតទាំងឡាយ អាចនឹងទ្រង់បញ្ចេញព្រះរស្មីពីព្រះពុទ្ធសរីរៈ កម្ចាត់សេចក្តីងងឹតអន្ធការ ហើយឲ្យទេវតា និងមនុស្សទាំងឡាយ បានឮព្រះសូរសៀងបាន ។ ដែល

ឈ្មោះថា **ជាតិខេត្ត** របស់ព្រះពុទ្ធទាំងឡាយ ទ្រង់សម្ដែងទុកហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ អធិប្បាយថា ក្នុងភពចុងក្រោយរបស់ព្រះពោធិសត្វទាំងឡាយ ក្នុងថ្ងៃដែលព្រះអង្គស្ដេចចុតិចាកទេវលោក មកបដិសន្ធិក្នុងគភ៌របស់ព្រះពុទ្ធមាតា ១ ក្នុងថ្ងៃប្រសូតិចាកព្រះគភ៌ ១ ក្នុងថ្ងៃស្ដេចចេញព្រះផ្នួស ១ ក្នុងថ្ងៃត្រាស់ដឹង ១ ក្នុងថ្ងៃទ្រង់សម្ដែងធម្មចក្ក ១ ក្នុងថ្ងៃទ្រង់ដាក់អាយុសង្ខារ ១ និងក្នុងថ្ងៃបរិនិព្វាន ១ ស្ថានទីមានប្រមាណប៉ុណ្ណេះ (លោកធាតុខ្នាតកណ្ដាល) រមែងញាប់ញ័រ ។

បទថា **តិសហស្សី មហាសហស្សី** សេចក្ដីថា ឈ្មោះថា **តិសហស្សី** ព្រោះតាំងពីចំនួនមួយពាន់ យកមួយពាន់គុណ ៣ ដង ។ លោកធាតុដែលគុណដោយច្រើនៗ ពាន់ ព្រោះតាំងមួយពាន់ទុក យកមួយពាន់គុណ តាំងជាលោកធាតុខ្នាតកណ្ដាលទុក យកមួយពាន់គុណ ព្រោះដូច្នោះ ទើបឈ្មោះថា **មហាសហស្សី** ។ ដោយពាក្យត្រឹមប៉ុណ្ណេះ គឺ ទ្រង់សម្ដែងលោក មានសែនកោដិចក្រវាឡជាប្រមាណ ។ ព្រះមានព្រះភាគ កាលមានពុទ្ធបំណងនឹងទ្រង់បញ្ចេញព្រះរស្មីចេញពីព្រះពុទ្ធសរីរៈ កម្ចាត់សេចក្ដីងងឹតអន្ធការ ឲ្យទេវតា និងមនុស្សទាំងឡាយបានឮព្រះសូរសៀង ក្នុងស្ថានទីប៉ុណ្ណេះ ។ ចំណែកព្រះគណកបុត្តតិស្សត្ថេរៈពោលទុកយ៉ាងនេះថា **តិសហស្សីលោកធាតុ** និង **មហាសហ-**

សហស្សីលោកធាតុ មានប្រមាណយ៉ាងនេះ ព្រោះបរិមាណនេះ ជាទីតាំងនៃការរក្សា ដោយវាចា (និយាយគ្នាដោយមាត់) ជាមូលនៃការស្វាធ្យាយរបស់អាចារ្យទាំងឡាយ តែស្ថានទីដែលឈ្មោះថា **តិសហស្សីលោកធាតុ** និង **មហាសហស្សីលោកធាតុ** មានប្រមាណមួយលានកោដិចក្រវាឡ ។ ក៏ដោយពាក្យមានប្រមាណប៉ុណ្ណេះ គឺ ព្រះមានព្រះភាគទ្រង់សម្តែងខេត្ត ដែលឈ្មោះថា **អាណាខេត្ត** ព្រោះក្នុងវាងនេះ អាណា (អំណាច) នៃ **អាដានាដិយបរិត្ត ឥសិគិលិបរិត្ត ធជគ្គបរិត្ត ពោជ្ឈង្គបរិត្ត ខន្ធបរិត្ត មោរបរិត្ត មេត្តាបរិត្ត** និង **រតនបរិត្ត** រមែងផ្សាយទៅដល់ ។

បទថា **យាវតា បន អាកង្ខេយ្យ** (គប្បីប្រាថ្នា) សេចក្តីថា ទ្រង់ប្រាថ្នាស្ថានទីមានប្រមាណប៉ុនណា ។ ដោយពាក្យនេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ **វិសយខេត្ត** ព្រោះតាមធម្មតា វិសយខេត្តរបស់ព្រះពុទ្ធទាំងឡាយ មិនមានកំណត់ប្រមាណ ។ ក្នុងវិសយខេត្តរបស់ព្រះពុទ្ធទាំងឡាយ មិនមានកំណត់ប្រមាណនុ៎ះឯង ព្រះបុរាណាចារ្យទាំងឡាយ នាំប្រការឧបមាមកអាងទុក ដូចតទៅនេះ ។ ប្រសិនបើមាននរណាៗ យកគ្រាប់ស្ពៃទៅគរឲ្យពេញសែនកោដិចក្រវាឡ ដរាបដល់ព្រហ្មលោក ដាក់គ្រាប់ស្ពៃចុះទៅក្នុងចក្រវាឡ ចក្រវាឡមួយ ១ គ្រាប់ ទិសបូព៌ាសោត គ្រាប់ស្ពៃសូម្បីទាំងអស់នោះ គប្បីដល់ការអស់ទៅ

មុន តែចក្រវាឡក្នុងផ្នែកទិសបូព៌ា នឹងមិនទាន់ដល់នូវការអស់ ។ សូម្បីចក្រវាឡក្នុងទិសទក្សិណជាដើម ក៏មានន័យនេះដូចគ្នា ។ ក្នុងវិសយខេត្តនោះ ដែលឈ្មោះថា មិនមែនវត្ថុជាវិស័យរបស់ព្រះពុទ្ធទាំងឡាយ មិនមានឡើយ ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះថេរៈគិតថា ព្រះសាស្តាត្រាស់ទុកយ៉ាងនេះថា ម្នាលអានន្ទ តថាគតកាលបើបំណងហើយ ក៏គប្បីញ៉ាំងលោកធាតុឈ្មោះថា តិសហស្សី (និង) មហាសហស្សី បានឮសូរសៀងតាមចំណង់ ដូច្នេះ ។ ក៏ឯលោកនេះមិនស្មើគ្នា ចក្រវាឡមិនមានទីបំផុត ព្រះអាទិត្យរះឡើងម្តង ត្រង់ម្តង លិចទៅម្តង បឋមយាមមានម្តង មជ្ឈិមយាមមានម្តង បច្ឆិមយាមក៏មានម្តង ។ សូម្បីសត្វទាំងឡាយ ខ្វល់ខ្វាយក្នុងការងារ ពេញចិត្តក្នុងការលេង ស្វែងរកអាហារ ព្រោះដូច្នោះ សត្វទាំងឡាយ រមែងរវើរវាយនិងប្រមាទដោយហេតុនោះៗ យ៉ាងនេះ ព្រះបរមសាស្តានឹងញ៉ាំងសត្វទាំងឡាយនោះ ឲ្យបានឮព្រះសូរសៀងបានយ៉ាងណាហ្ន៎ ដូច្នេះ ។ ព្រះអានន្ទត្ថេរ លុះគិតយ៉ាងនេះហើយ កាលនឹងទូលសួរព្រះតថាគត ដើម្បីបន្ទោបង់សេចក្តីសង្ស័យ ទើបក្រាបទូលពាក្យជាដើមថា **យាវ កថំ បន** ដូច្នេះ ។

លំដាប់នោះ ព្រះបរមសាស្តាកាលនឹងទ្រង់ព្យាករណ៍ដល់ព្រះអានន្ទត្ថេរ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **អានន្ទ តថាគតនៅក្នុងទីនេះ** ដូច្នេះ ។ បណ្តាបទ

ទាំងនោះ បទថា **ឱភាសេន ផរេយ្យ** (ផ្សាយរស្មី) សេចក្តីថា ផ្សាយទៅដោយរស្មីនៃព្រះសរីរៈ ។ សួរថា ឱភាសនោះ កាលផ្សាយទៅ គប្បីធ្វើអាការយ៉ាងណា ។ ឆ្លើយថា ទីណាមានព្រះអាទិត្យប្រាកដ ទីនោះព្រះអង្គក៏ធ្វើឲ្យព្រះអាទិត្យលិចដោយអានុភាពរបស់ព្រះអង្គ តែក្នុងទីណាព្រះអាទិត្យមិនប្រាកដ ទីនោះព្រះអង្គនឹងធ្វើឲ្យព្រះអាទិត្យប្រាកដ ស្ថិតនៅកណ្តាល (ផ្ទៃអាកាស) តពីនោះ ក្នុងទីណាព្រះអាទិត្យប្រាកដ ក្នុងទីនោះមនុស្សទាំងឡាយ ក៏គប្បីកើតវិតក្កៈថា ព្រះអាទិត្យ (ទើបតែ) ប្រាកដក្នុងកាលមិនយូរនេះឯង តែព្រះអាទិត្យនោះក៏លិចទៅឥឡូវនេះឯង ប្រការនេះគង់នឹងជាការបណ្តាលរបស់នាគ ឬការបណ្តាលរបស់ភូត ការបណ្តាលរបស់យក្ខ ឬការបណ្តាលរបស់ទេវតាណានីមួយ តែក្នុងទីណាព្រះអាទិត្យមិនប្រាកដ ក្នុងទីនោះ មនុស្សទាំងឡាយនឹងកើតវិតក្កៈថា ព្រះអាទិត្យទើបតែលិចទៅឥឡូវនេះឯង ព្រះអាទិត្យមួយដួងដូចគ្នានេះ ក៏ត្រឡប់រះឡើងឥឡូវនេះទៀត នេះនឹងជាការបណ្តាលរបស់នាគ ការបណ្តាលរបស់ភូត ការបណ្តាលរបស់យក្ខ និងការបណ្តាលរបស់ទេវតាណានីមួយ ឬយ៉ាងណាហ្ន៎ តពីនោះ កាលមនុស្សទាំងឡាយនោះរំពឹងដល់សេចក្តីភ្លឺ និងសេចក្តីងងឹត ហើយនាំគ្នាស្វែងរក (ហេតុផល) ដោយគិតថា នេះមានអ្វីជាបច្ច័យហ្ន៎ ព្រះបរមសាស្តាទ្រង់ចូលនីលកសិណ ហើយផ្សាយភាពងងឹតទៅ ។

សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះទ្រង់ផ្សាយទៅដើម្បីឲ្យសត្វទាំងឡាយដែលខ្វល់ខ្វាយការងារជាដើមទាំងនោះ កើតសេចក្ដីតក់ស្លុត ។ លំដាប់នោះ ព្រះបរមសាស្ដាទ្រង់ជ្រាបថា សត្វទាំងនោះដល់នូវសេចក្ដីតក់ស្លុតហើយ ទ្រង់ក៏ចូលឱកាសកសិណសមាបត្តិ ទ្រង់បញ្ចេញព្រះពុទ្ធរស្មីឡើង ទ្រង់បណ្ដាលឲ្យទីគ្រប់កន្លែងមានពន្លឺដូចគ្នា ដោយការបញ្ចេញព្រះរស្មីតែម្ដងប៉ុណ្ណោះ ដូចវេលាដែលព្រះច័ន្ទ និងព្រះអាទិត្យរះឡើងព្រមៗ គ្នា មួយពាន់ដួង និងទ្រង់បញ្ចេញព្រះឱភាសនោះ ដោយចំណែកនៃព្រះវរកាយមានប្រមាណប៉ុនគ្រាប់ល្ង ។ ក៏បើបុគ្គលណាបណ្ដាលផែនដីទូទាំងចក្រវាឡ ឲ្យដូចជាចង្កៀង បណ្ដាលទឹកក្នុងមហាសមុទ្រឲ្យជាប្រេង បណ្ដាលភ្នំសិនេរុឲ្យជាប្រឆេះចង្កៀង ដុតដាក់លើកំពូលភ្នំសិនេរុដទៃបាន បុគ្គលនោះគង់នឹងធ្វើឲ្យភ្លឺក្នុងចក្រវាឡតែមួយប៉ុណ្ណោះ មិនអាចនឹងធ្វើផ្ទៃដីសូម្បីត្រឹមតែមួយចំអាម ខាងក្រៅពីនោះឲ្យភ្លឺបាន ។ ចំណែកព្រះតថាគតទ្រង់បញ្ចេញព្រះឱភាស ដោយចំណែកនៃព្រះសរីរៈប្រមាណប៉ុនគ្រាប់ល្ង គប្បីធ្វើឲ្យតិសហស្សីលោកធាតុ និងមហាសហស្សី ឬក្រៃលែងជាងនោះឲ្យមានពន្លឺតែមួយដូចគ្នាបាន ព្រោះថា គុណរបស់ព្រះពុទ្ធមាន (អានុភាព) ច្រើនយ៉ាងនេះ ដូច្នេះឯង ។

បទថា តំ អាលោកំ សញ្ជានេយ្យុំ (ដឹងច្បាស់ពន្លឺនោះ) សេចក្ដីថា

មនុស្សទាំងឡាយឃើញពន្លឺនោះហើយ គិតថា ព្រះអាទិត្យលិចផង រះឡើងផង សេចក្ដីងងឹតក៏វិនាសទៅផង ព្រោះនរណា ឥឡូវនេះ បុគ្គលនេះឈរបណ្ដាល ឲ្យកើតពន្លឺឡើងហើយ ឱ! អស្ចារ្យណាស់ហ្ន៎ អច្ឆរិយបុរស ដូច្នេះ ហើយឈរ ផ្គងអញ្ជលីនមស្ការ ។

បទថា *សទ្ទមនុស្សាវេយ្យ* (ឲ្យបានឮសំឡេង) សេចក្ដីថា ព្រះតថាគត ញុំាងទេវតា និងមនុស្សទាំងឡាយ ឲ្យពេញចិត្តស្ដាប់ព្រះធម្មកថា ។ ពិតហើយ បុគ្គលណាបណ្ដាលក្នុំចក្រវាឡបព្វតមួយឲ្យជាស្គរ បណ្ដាលមហាប្រថពីឲ្យជា ស្បែកស្គរ បណ្ដាលក្នុំសិនេរុឲ្យជាអន្ទង់វាយស្គរ ហើយដាក់លើកំពូលភ្នំសិនេរុ ដរទៃ ហើយវាយ បុគ្គលនោះ នឹងឲ្យមនុស្សទាំងឡាយបានឮសំឡេងនោះ ចំពោះ ក្នុងចក្រវាឡមួយប៉ុណ្ណោះ មិនអាចនឹងឲ្យសំឡេងនោះឮទៅខាងក្រៅត្រឹមតែមួយ ចំអាមបាន ។ ចំណែកព្រះតថាគត ប្រថាប់គង់លើបល្ល័ង្ក ឬតាំង ទ្រង់ញុំាង សហស្សីលោកធាតុ និងមហាសហស្សី ឬក្រៃលែងទៅជាងនោះ ឲ្យបានឮព្រះ សូរសៀងបាន ព្រះតថាគត ទ្រង់មានអានុភាពច្រើនយ៉ាងនេះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់សម្ដែងវិសយខេត្តនុ៎ះឯង ដោយទីមានប្រមាណប៉ុណ្ណោះ ដោយប្រការដូចពោលមកនេះ ។

ក៏ព្រោះបានស្ដាប់ពុទ្ធសីហនាទនេះ ព្រះថេរៈ បានកើតបីតិដ៏មានកម្លាំង

ឡើងក្នុងខាងក្នុង លោកកាលនឹងថ្លែងឧទានដោយអំណាចនៃបីតិ ទើបបានពោលពាក្យមានជាអាទិ៍ថា ជាលាភរបស់យើងហ្ន៎ ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **យស្ស មេ សត្ថា ឯវំមហិទ្ធិកោ** (ដែលយើងបានព្រះសាស្ដាមានឫទ្ធិច្រើនយ៉ាងនេះ) សេចក្ដីថា ការដែលយើងបានព្រះសាស្ដាអ្នកមានឫទ្ធិច្រើនយ៉ាងនេះ រាប់ថាជាលាភ និងជាវត្ថុដែលបានមកដោយល្អ ។ ម្យ៉ាងទៀត ព្រះអានន្ទត្ថេរពោលយ៉ាងនេះ មានន័យថា ការដែលយើងមានឱកាសកាន់បាត្រ និងចីវររបស់ព្រះសាស្ដាបែបនេះ ហើយត្រាច់ទៅ (ក្ដី) មានឱកាសគក់ប្រេបាច់ព្រះបាទ (ក្ដី) មានឱកាសថ្វាយទឹកលុបព្រះភក្ត្រ និងទឹកស្រង់ (ក្ដី) មានឱកាសបោសសំអាតបរិវេណព្រះគន្ធកុដិ (ក្ដី) មានឱកាសទូលសួរបញ្ហាតាមប្រការសង្ស័យដែលកើតឡើងហើយ (ក្ដី) បានស្ដាប់ធម្មកថាដ៏ពីរោះ (ក្ដី) ទាំងនេះ សូម្បីទាំងអស់ចាត់ជាលាភរបស់យើងដោយពិត និងជាវត្ថុដែលបានមកដោយល្អដោយពិត ដូច្នេះខ្ញុះ ។ ក៏ក្នុងព្រះសូត្រនេះ អ្នកសិក្សាគប្បីជ្រាបសេចក្ដីនូវព្រះមានព្រះភាគទ្រង់មានឫទ្ធិច្រើន ព្រោះទ្រង់មានឫទ្ធិ ពោលគឺ ការធ្វើសេចក្ដីងងឹតឲ្យភ្លឺ ធ្វើទេវតា និងមនុស្សឲ្យបានឮព្រះសូរសៀង ដ៏ច្រើន (និងគប្បីជ្រាប) ដល់ព្រះមានព្រះភាគមានអានុភាពច្រើន ព្រោះឫទ្ធិនោះៗ ឯង ផ្សាយទៅរឿយៗ ។

បទថា **ឧទាយិ** (ព្រះឧទាយី) បានដល់ ព្រះលោឡុទាយិត្ថេរ ។ បានឮ

មកថា ព្រះលោឡុទាយិត្ថេរនោះ ត្រាច់ព្យាបាទក្នុងព្រះថេរៈ ដោយសេចក្ដីប្រាថ្នា ដែលតាំងទុកក្នុងកាលមុន ព្រោះដូច្នោះ ឥឡូវនេះ ពេលបានឱកាសទើបធ្វើការ កាច់បំបាក់សេចក្ដីជ្រះថ្លារបស់ព្រះថេរៈ ហើយពោលយ៉ាងនេះ ដូចរំលត់អណ្ដាត ប្រទីបដែលឆេះហើយ ក្នុងវេលាចប់ពុទ្ធសីហនាទនេះ ដូចយករំពាត់វាយគោដែល កំពុងដើរទៅ (និងដូចផ្ដាប់ថាសដែលមានអាហារពេញ)[១] ដូច្នោះ ។

បទថា **ឯវំ វុត្តេ ភគវា** (កាលព្រះឧទាយីពោលយ៉ាងនេះ ព្រះមានព្រះ-ភាគ) សេចក្ដីថា កាលព្រះឧទាយិត្ថេរពោលយ៉ាងនេះហើយ ព្រះមានព្រះភាគ កាលនឹងទ្រង់ហាមព្រះឧទាយិត្ថេរអំពីពាក្យនោះ ទើបត្រាស់ពាក្យថា **កុំពោលយ៉ាង នោះ ឧទាយិ** ដូច្នេះ ។ ដូចបុរសអ្នកប្រាថ្នាប្រយោជន៍ ឈរក្នុងចំណែកមួយ គប្បីនិយាយជាមួយបុរសអ្នកឈរនៅទ្រង់មាត់ជ្រោះថា ចូរមកផ្លូវនេះ ចូរមកផ្លូវ នេះ ដូច្នោះ ។ បណ្ដាបទទាំងនោះ បទថា **ហិ** ជានិបាត អធិប្បាយថា លោក កុំពោលយ៉ាងនោះ ។ បទថា **មហារជ្ជំ** (មហារាជសម្បត្តិ) បានដល់ ចក្រពត្តិ-រាជសម្បត្តិ ។ សួរថា ក៏ព្រះសាស្ដាទ្រង់បានធ្វើអានិសង្សនៃសេចក្ដីជ្រះថ្លាដែល កើតឡើង ព្រោះការសម្ដែងធម៌ដល់សាវកមួយរូប មិនមានកំណត់ មិនមែនឬ ហេតុដូចម្ដេច ព្រះអង្គទើបទ្រង់កំណត់អានិសង្សនៃសេចក្ដីជ្រះថ្លា ដែលកើតឡើង

---

(១) មានក្នុងបាឋៈដទៃ ។

ដល់ព្រះអានន្ទនេះ ព្រោះប្រារព្ធពុទ្ធសីហនាទ ។ ឆ្លើយថា ព្រោះព្រះអរិយសាវក មានអត្តភាពត្រឹមប៉ុណ្ណេះជាប្រមាណ ។ ព្រោះថា ព្រះសោតាបន្ន សូម្បីមានបញ្ញាខ្សិលប្រអូស នឹងមានអត្តភាពក្នុងទេវតា និងមនុស្សទាំងឡាយ ៧ ដង (ប៉ុណ្ណោះ) ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់កំណត់គតិរបស់ព្រះអានន្ទនោះ ទើបបានត្រាស់យ៉ាងនេះ ។ បទថា **ទិដ្ឋេវ ធម្មេ** (ក្នុងជាតិបច្ចុប្បន្ននេះ) សេចក្តីថា តាំងនៅក្នុងអត្តភាពនេះប៉ុណ្ណោះ ។ បទថា **បរិនិព្វាយិស្សតិ** (នឹងបរិនិព្វាន) សេចក្តីថា នឹងបរិនិព្វាន ដោយបរិនិព្វានដែលរកបច្ច័យមិនបាន ។

ព្រះមានព្រះភាគទ្រង់កាន់យកទីបំផុត ដោយព្រះនិព្វាន ហើយទ្រង់ញ៉ាំងសីហនាទសូត្រនេះឲ្យចប់ស្រេច ដោយប្រការដូចពណ៌នាមកដូច្នេះឯង ។

ចប់អដ្ឋកថា ចូឡនីសូត្រទី ១០

## ចប់អានន្ទវគ្គវណ្ណនា ទី ៣

ក្នុងវគ្គនេះ មាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សមណវគ្គទី ៤

## អដ្ឋកថា សមណសូត្រទី ១

### *“កិច្ចរបស់សមណៈ ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមណសូត្រទី ១ ដូចតទៅនេះ ៖*

*[៨៣] បទថា* ***សមណស្ស*** *ប្រែថា ដែលជារបស់សមណៈ ។ បទថា* ***សមណករណីយានិ*** *ប្រែថា កិច្ចដែលសមណៈគប្បីធ្វើ ។ ក្នុងបទថា* ***អធិសីលសិក្ខាសមាទានំ*** *(សមាទានអធិសីលសិក្ខា) ជាដើម មានអធិប្បាយថា ការកាន់យក ហៅថា សមាទាន ។ ការសមាទាន ការកាន់យក ការបំពេញអធិសីលសិក្ខា ឈ្មោះថា* ***សមាទានអធិសីលសិក្ខា*** *។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។*

*ម្យ៉ាងទៀត គប្បីជ្រាបការចែកដូច្នេះ* ***សីល អធិសីល , ចិត្ត អធិចិត្ត , បញ្ញា អធិប្បញ្ញា*** *ក្នុងការចែកនោះ សីល ៥ ឈ្មោះថា សីល សីល ១០ ឈ្មោះថា អធិសីល ព្រោះប្រៀបធៀបនឹងសីល ៥ នោះ ។ បារិសុទ្ធិសីល ៤ ឈ្មោះថា អធិសីល ព្រោះប្រៀបផ្ទឹមនឹងសីល ១០ នោះ ។ ម្យ៉ាងទៀត លោកិយសីលទាំងអស់ ចាត់ជាសីល លោកុត្តរសីលចាត់ជា អធិសីល ។ អធិសីល*

នោះឯងហៅថា សិក្ខា ព្រោះត្រូវសិក្សា ។ ចំណែកកាមាវចរចិត្ត ឈ្មោះថា ចិត្ត រូបាវចរចិត្ត ឈ្មោះថា អធិចិត្ត ព្រោះប្រៀបផ្ទឹមនឹងកាមាវចរចិត្តនោះ ។ អរូបាវចរចិត្ត ឈ្មោះថា អធិចិត្ត ព្រោះប្រៀបផ្ទឹមនឹងរូបាវចរចិត្តនោះ ។ មួយទៀត លោកិយចិត្តទាំងអស់ចាត់ជាចិត្ត លោកុត្តរចិត្តចាត់ជាអធិចិត្ត ។ សូម្បីក្នុងបញ្ញា ក៏មានន័យនេះដូចគ្នា ។ បទថា **តស្មា** (ព្រោះហេតុនោះ) សេចក្តីថា ព្រោះហេតុនៃកិច្ចដែលសមណៈគប្បីធ្វើទាំង ៣ នេះ ។ បទថា **តិព្វោ** (ដ៏ក្រៃលែង) បានដល់ ដ៏ច្រើន ។ បទថា **ឆន្ទោ** (ការពេញចិត្ត) បានដល់ សេចក្តីពេញចិត្តក្នុងកុសល គឺ ភាពជាអ្នកត្រូវការនឹងធ្វើ ។

សិក្ខា ៣ ទាំងដែលជាលោកិយៈ និងលោកុត្តរៈ ព្រះមានព្រះភាគត្រាស់ទុកក្នុងសូត្រនេះ ដោយប្រការដូចពណ៌នាមកដូច្នេះឯង ។

ចប់អដ្ឋកថា សមណសូត្រទី ១

# អដ្ឋកថា គទ្រភសូត្រទី ២

## "ភិក្ខុមិនមានត្រៃសិក្ខា ប្រៀបដូចសត្វលាក្នុងហ្វូងគោ"

គប្បីជ្រាបវិនិច្ឆ័យក្នុង គទ្រភសូត្រទី ២ ដូចតទៅនេះ ៖

[៨៤] បទថា **បិដ្ឋិតោ បិដ្ឋិតោ** គឺ **បច្ឆតោ បច្ឆតោ** (ខាងក្រោយៗ) ។ បទថា **អហម្បិ អម្ហា អហម្បិ អម្ហា** (សូម្បីអញក៏ជាគោ សូម្បីអញក៏ជាគោ) សេចក្ដីថា គោស្រែកថា សូម្បីយើងជាគោ (យ៉ាងណា) (លាក៏ស្រែកថា) សូម្បីយើងក៏ជាគោ (ដូច្នោះ) ។ បទថា **សេយ្យថាបិ គុន្នំ** (ដូចជាគោ) សេចក្ដីថា សម្បុរមេគោទាំងឡាយមានយ៉ាងណា ពិតហើយ គោទាំងឡាយមានសម្បុរខ្មៅខ្លះ មានសម្បុរក្រហមខ្លះ មានសម្បុរសជាដើមខ្លះ ប៉ុន្តែថា លាមិនមានសម្បុរដូច្នោះ និងសម្បុរមានយ៉ាងណា សំឡេងក្ដី ស្នាមជើងក្ដី ក៏ដូចគ្នាទុំះឯង ។

បទដ៏សេសមានអត្ថងាយទាំងអស់នោះឯង សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ ទុកលាយគ្នានោះឯង ។

ចប់អដ្ឋកថា គទ្រភសូត្រទី ២

# អដ្ឋកថា ខេត្តសូត្រទី ៣

## *"កិច្ចខាងដើមរបស់អ្នកស្រែ និងរបស់ភិក្ខុ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខេត្តសូត្រទី ៣ ដូចតទៅនេះ ៖*

*[៨៥] បទថា **បដិកច្ចេវ** (មុននោះឯង) បានដល់ មុនដំបូង ។ បទថា **សុកដ្ឋំ ករោតិ** (ធ្វើការភ្ជួរឲ្យល្អ) សេចក្តីថា អ្នកស្រែភ្ជួរស្រែល្អហើយដោយនង្គ័ល ។ បទថា **សុមតិកតំ** (រាស់ឲ្យល្អ) សេចក្តីថា យករនាស់រាស់ឲ្យមានផ្ទៃដីរាបល្អ ។ បទថា **កាលេន** (តាមកាល) បានដល់ តាមកាលដែលគួរសាបព្រោះ ។*

*បទដ៏សេសងាយទាំងអស់នោះឯង សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ លាយគ្នានោះឯង ។*

ចប់អដ្ឋកថា ខេត្តសូត្រទី ៣

# អដ្ឋកថា វជ្ជីបុត្តសូត្រទី ៤

## “ការបម្រើនត្រៃសិក្ខា ដើម្បីលះអកុសល”

គប្បីជ្រាបវិនិច្ឆ័យក្នុង វជ្ជីបុត្តសូត្រទី ៤ ដូចតទៅនេះ ៖

[៨៦] បទថា **វជ្ជីបុត្តកោ** បានដល់ បុត្ររបស់រាជត្រកូលវជ្ជី ។ បទថា **ទិយឌ្ឍសិក្ខាបទសតំ** គឺ **បណ្ណាសាធិកំ សិក្ខាបទសតំ** (សិក្ខាបទ ១៥០) ។ ភិក្ខុវជ្ជីបុត្រសំដៅយកសិក្ខាបទដែលទ្រង់បញ្ញត្តិទុកក្នុងសម័យនោះ ទើបពោលពាក្យនេះថា **សិក្ខាបទ ១៥០** ។ បានឮថា ភិក្ខុនោះដល់ព្រមដោយអាជ្ជវធម៌ ជាអ្នកមាននិស្ស័យស្មោះត្រង់ មិនកោងកាច សច្ចៈ ដូច្នោះ លោកទើបគិតថា យើងអាចរក្សាសិក្ខាបទចំនួនប៉ុណ្ណោះបានឬទេ ដូច្នេះ ហើយក្រាបទូលឲ្យព្រះសាស្តាទ្រង់ជ្រាប ។ បទថា **សក្កោមហំ** កាត់បទជា **សក្កោមិ អហំ** (ខ្ញុំព្រះអង្គអាច) ។ បានឮថា ភិក្ខុនោះសម្គាល់ថា កាលយើងសិក្សានៅក្នុងសិក្ខាបទចំនួនប៉ុណ្ណោះបានក៏មិនលំបាក ទើបក្រាបទូលយ៉ាងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់លើកសិក្ខា ២ ទៀត ឡើងមកក្នុងលំដាប់ដែលខ្ពស់តទៅ ដល់ភិក្ខុដែលមិនអាចនឹងសិក្សាក្នុងសិក្ខាប្រការមួយ ទើបត្រាស់ពាក្យថា **ភិក្ខុ ព្រោះហេតុនោះឯងអ្នក** ជាដើម ប្រៀបដូចបុគ្គលចងបាច់ស្មៅ ៥០០ បាច់ (រួមគ្នា) ដាក់លើសីសៈរបស់បុគ្គលដែលមិនអាចនឹងលើកបាច់ស្មៅ ៥០ បាច់ឡើងបាន ដូច្នោះ ។

## សេចក្តីឧបមា

បានឮថា ក្នុងរោហណជនបទ អ្នកជនបទម្នាក់ឈ្មោះឧត្តរៈ នៅក្នុងគេរបាសាណវិហារ ។ ថ្ងៃមួយ ភិក្ខុកំលោះទាំងឡាយបាននិយាយនឹងគេថា ឧត្តរៈ រោងភ្លើងត្រូវភ្លៀងលិច សូមអ្នកចូរធ្វើស្មៅឲ្យគួរហើយឲ្យចុះ ដូច្នេះ ហើយនាំគេចូលទៅព្រៃកាត់ស្មៅ ដែលឧត្តរៈនោះប្រូតហើយធ្វើបាច់ៗ ហើយពោលថា ឧត្តរៈ អ្នកអាចលីស្មៅ ៥០ បាច់ ទៅបានទេ ។ ឧត្តរៈនោះពោលថា មិនអាចទេលោកម្ចាស់ ។ តែ (បើ) ៨០ បាច់ អ្នកអាចទេ ។ មិនអាចទេលោកម្ចាស់ ។ ១០០ បាច់ (រួមជាដុំតែមួយ) អ្នកអាចទេ ។ (បើយ៉ាងនោះ) បាន លោកម្ចាស់ ខ្ញុំលីទៅបាន ។ ភិក្ខុកម្លោះទាំងឡាយទើបចងស្មៅ ១០០ បាច់រួមគ្នា ហើយដាក់លើសីសៈគេ ។ នាយឧត្តរៈនោះ លើកឡើងហើយអត់ដង្ហើមទូលទៅ បោះទុកជិតរោងភ្លើង ។ លំដាប់នោះ ភិក្ខុទាំងឡាយទើបពោលថា ហត់ទេឧត្តរៈ ។ នាយឧត្តរៈឆ្លើយថា ហត់ លោកម្ចាស់ ពួកភិក្ខុកំលោះលួងខ្ញុំ (តាមពិត) ខ្ញុំមិនអាចលីបាច់ស្មៅ ១០០ បាច់នេះបានទេ (តែ) លោកប្រាប់ថា អ្នកចូរលី ៥០ បាច់ដូច្នេះជាដើម ។ ភិក្ខុទាំងឡាយពោលថា មែនហើយឧត្តរៈ ពួកភិក្ខុកំលោះលួងលោមអ្នក ។ គប្បីជ្រាបសេចក្តីឧបមេយ្យនេះ ដូច្នេះ ។

សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ ទុកលាយគ្នាដែរ ។

ចប់អដ្ឋកថា វជ្ជិបុត្តសូត្រទី ៤

# អដ្ឋកថា បឋមសេក្ខសូត្រទី ៥

## *"ពោលដោយសេក្ខបុគ្គល"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសេក្ខសូត្រទី ៥ ដូចតទៅនេះ ៖*

*[៨៧] បទថា **ឧជុមគ្គានុសារិនោ** (អ្នកបដិបត្តិតាមផ្លូវត្រង់) សេចក្តីថា អរិយមគ្គ ហៅថា ផ្លូវត្រង់ សេក្ខបុគ្គលដែលរឭកដល់ គឺ អ្នកបដិបត្តិផ្លូវត្រង់នោះ ។ បទថា **ខយស្មឹ បឋមំ ញាណំ** (ញាណក្នុងការអស់កិលេស...ដំបូង) សេចក្តីថា មគ្គញ្ញាណនោះឯង កើតឡើងមុន ។ ពិតហើយ មគ្គ ឈ្មោះថា ជាហេតុអស់ទៅនៃកិលេសទាំងឡាយ ព្រោះរួចផុតចាកកិលេស ញាណដែលសម្បយុត្តដោយមគ្គនោះ ឈ្មោះថា ខយញ្ញាណ ។ បទថា **តតោ អញ្ញា អនន្តរា** (អរហត្តផលរមែងកើតឡើងក្នុងលំដាប់ពីញាណនោះ) សេចក្តីថា ការដឹងច្បាស់ឃើញច្បាស់ រមែងកើតឡើងតពីមគ្គញ្ញាណទី ៤ នោះ អធិប្បាយថា អរហត្តផលរមែងកើតឡើង ។ បទថា **អញ្ញាវិមុត្តស្ស** (ដល់លោកដែលរួចផុតដោយអរហត្តផល) បានដល់ អ្នករួចផុតហើយដោយវិមុត្តិ គឺ អរហត្តផល ។ បទថា **ញាណំ វេ ហោតិ** (ញាណ... រមែងមាន) បានដល់ បច្ចវេក្ខណញ្ញាណនោះឯង ។*

*ព្រះមានព្រះភាគត្រាស់សេក្ខបុគ្គល ៧ ពួក ទុកទាំងក្នុងព្រះសូត្រ ទាំងក្នុងគាថាទាំងឡាយ តែទ្រង់សម្តែងព្រះខីណាស្រពទុកផ្នែកខាងចុង ។*

ចប់អដ្ឋកថា បឋមសេក្ខសូត្រទី ៥

# អដ្ឋកថា បឋមសិក្ខាសូត្រទី ៦[១]

## *“ពោលដោយសេក្ខបុគ្គល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសិក្ខាសូត្រទី ៦ ដូចតទៅនេះ ៖*

*[៨៨] បទថា **អត្ថកាមា** (អ្នកប្រាថ្នាប្រយោជន៍) បានដល់ កុលបុត្រទាំងឡាយដែលប្រាថ្នាប្រយោជន៍ចំពោះខ្លួន ។ បទថា **យត្ថេតំ សព្វំ សមោធានំ គច្ឆតិ** (សិក្ខាបទ ១៥០ ទាំងអស់នេះ សូមប្បីរួមចុះក្នុង... ណា) សេចក្តីថា សិក្ខាបទ ១៥០ ទាំងអស់នេះ ដល់ការសង្គ្រោះចូលក្នុងសិក្ខាពួកណា ។ បទថា **បរិបូរការី ហោតិ** (ជាអ្នកធ្វើឲ្យបរិបូរ) សេចក្តីថា ភិក្ខុជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូរណ៍ ។ បទថា **មត្តសោការី** (ធ្វើឲ្យល្មមប្រមាណ) សេចក្តីថា ជាអ្នកមានប្រក្រតីធ្វើល្មមប្រមាណ អធិប្បាយថា មិនអាចធ្វើបានទាំងអស់ ។ បទថា **ខុទ្ទានុខុទ្ទកានិ** (តិចតួច) បានដល់ សិក្ខាបទដ៏សេសវៀរបារាជិក ៤ ។ មួយទៀត ក្នុងបទថា **ខុទ្ទានុខុទ្ទកានិ** នោះ មានអធិប្បាយថា សង្ឃាទិសេស ឈ្មោះថា **ខុទ្ទកសិក្ខាបទ** ថុល្លច្ច័យ ឈ្មោះថា **អនុខុទ្ទកសិក្ខាបទ** ។ មួយទៀត ថុល្លច្ច័យ ឈ្មោះថា **ខុទ្ទកសិក្ខាបទ** បាចិត្តិយ ឈ្មោះថា **អនុខុទ្ទកសិក្ខាបទ** ។ មួយទៀត បាចិត្តិយ ឈ្មោះថា **ខុទ្ទកសិក្ខាបទ** បាដិទេសនីយៈ ទុក្កដ និងទុព្ភាសិត ឈ្មោះ*

---

*(១) បិដក = ទុតិយសេក្ខសូត្រ*

ថា **អនុខុទ្ទកសិក្ខាបទ** ។ តែអាចារ្យអ្នកប្រើអង្គុត្តរមហានិកាយនេះ ពោលថា សិក្ខាបទដ៏សេសទាំងអស់ វៀរលែងតែបារាជិក ៤ ឈ្មោះថា **ខុទ្ទានុខុទ្ទកសិក្ខាបទ** ។

## ព្រះខីណាស្រពត្រូវអាបត្តិ

ក៏ក្នុងបទថា **តានិ អាបជ្ជតិបិ វុដ្ឋាតិបិ** (រមែងកន្លងសិក្ខាបទតូចខ្លះ រមែងចេញចាកអាបត្តិខ្លះ) នេះ មានអធិប្បាយថា ព្រះខីណាស្រពមិនត្រូវអាបត្តិ ដែលជាលោកវជ្ជៈឡើយ នឹងត្រូវ ក៏ត្រូវតែអាបត្តិដែលជាបណ្ណត្តិវជ្ជៈប៉ុណ្ណោះ និងកាលត្រូវ ក៏ត្រូវតាមផ្លូវកាយខ្លះ តាមផ្លូវវាចាខ្លះ តាមផ្លូវចិត្តខ្លះ គឺ កាលត្រូវតាមផ្លូវកាយ ក៏ត្រូវកុដិការសិក្ខាបទ និងសហសិក្ខាបទជាដើម , កាលត្រូវតាមផ្លូវវាចា ក៏ត្រូវសញ្ចរិត្តសិក្ខាបទ និងបទសោធម្មសិក្ខាបទជាដើម , កាលត្រូវតាមផ្លូវចិត្ត ក៏ត្រូវ (ព្រោះ) ទទួលរូបិយៈ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ បទថា **ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា** (ព្រោះក្នុងការត្រូវអាបត្តិ និងការចេញចាកអាបត្តិតូចៗ នេះ តថាគតមិនពោលការប្រព្រឹត្តទៅមិនបាន) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងទីនេះ តថាគតមិនបានពោលថា ព្រះអរិយបុគ្គលមិនគួរ (ប្រព្រឹត្តទៅមិនបាន) ទាំងក្នុងការត្រូវ និងការចេញចាកអាបត្តិបែបនេះ ។

បទថា **អាទិព្រហ្មចរិយកានិ** (ជាខាងដើមនៃព្រហ្មចរិយៈ) សេចក្តីថា សិក្ខាបទដែលជាមហាសីល ៤ ដែលជាខាងដើមរបស់មគ្គព្រហ្មចរិយៈ ។ បទថា **ព្រហ្មចរិយសារុប្បានិ** (សមគួរដល់ព្រហ្មចរិយៈ) សេចក្តីថា សិក្ខាបទដែលជាមហាសីលទាំងនោះឯង សមគួរ គឺ សមគួរដល់មគ្គព្រហ្មចរិយៈទី ៤ ។ បទថា **តត្ថ** បានដល់ ក្នុងសិក្ខាបទទាំងនោះ ។

## លក្ខណៈព្រះសោតាបន្ន

បទថា **ធុវសីលោ** (មានសីលជាប់មិនដាច់) បានដល់ អ្នកមានសីលប្រចាំ ។ បទថា **ឋិតិសីលោ** បានដល់ អ្នកមានសីលតាំងមាំ ។ បទថា **សោតាបន្នោ** (ព្រះសោតាបន្ន) បានដល់ អ្នកចូលដល់ផល ដោយមគ្គ ពោលគឺសោតៈ ។ បទថា **អវិនិបាតធម្មោ** (មានការមិនធ្លាក់ចុះជាធម្មតា) បានដល់ មានការមិនធ្លាក់ទៅក្នុងអបាយ ៤ ជាសភាវៈ ។ បទថា **និយតោ** (ជាបុគ្គលទៀង) បានដល់ បុគ្គលទៀងដោយគុណធម៌ជាគ្រឿងកំណត់ គឺ សោតាបត្តិមគ្គ ។ បទថា **សម្ពោធិបរាយនោ** (មានការត្រាស់ដឹងក្នុងខាងមុខ) បានដល់ មានបញ្ញាជាគ្រឿងត្រាស់ដឹងព្រម គឺ មគ្គ ៣ ខាងលើ ដែលប្រព្រឹត្តទៅក្នុងខាងមុខ ។

## លក្ខណៈព្រះសកទាគាមី

បទថា **តនុត្តា** (ព្រោះ... ស្រាលស្តើង) បានដល់ ព្រោះកិលេសទាំងឡាយ

ស្រាលស្តើង ។ អធិប្បាយថា កិលេសទាំងឡាយមានរាគៈជាដើម របស់ព្រះសកទាគាមីស្រាលស្តើង មិនក្រាស់ ប្រៀបដូចជាជាន់ផ្ទៃមេឃ និងប្រៀបដូចជាស្លាបរុយ ។

## លក្ខណៈព្រះអនាគាមី

បទថា **ឱរម្ភាគិយានំ** គឺ **ហេដ្ឋាភាគិយានំ** (ប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម) ។ បទថា **សំយោជនានំ** (សំយោជនៈ) បានដល់ គ្រឿងចងទាំងឡាយ ។ បទថា **បរិក្ខយា** គឺ **បរិក្ខយេន** (ព្រោះការអស់ទៅ) ។ បទថា **ឱបបាតិកោ ហោតិ** (ជាឱបបាតិកៈ) បានដល់ ជាអ្នកឧប្បត្តិឡើង ។ បទថា **តត្ថ បរិនិព្វាយី** (បរិនិព្វានក្នុងលោកនោះ) បានដល់ មានការមិនចុះមកកើតក្នុងភពជាន់ក្រោមៗ នឹងបរិនិព្វានក្នុងភពជាន់ខ្ពស់នោះឯងជាធម្មតា ។ បទថា **អនាវត្តិធម្មោ** (មានការមិនត្រឡប់មកជាធម្មតា) បានដល់ មានការមិនវិលត្រឡប់មកទៀតជាធម្មតាដោយអំណាចកំណើត និងគតិ ។

## អ្នកធ្វើបានចំណែកខ្លះ - អ្នកធ្វើបានបរិបូរណ៍

ក្នុងបទថា **បទេសំ បទេសការី** (បុគ្គលធ្វើបានចំណែកខ្លះ រមែងឲ្យបានសម្រេចចំណែកខ្លះ) ជាដើម មានអធិប្បាយថា ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី ឈ្មោះថា ជាបុគ្គលដែលមានប្រក្រតីធ្វើបានចំណែកខ្លះ គឺ ព្រះ

សោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីនោះ ធ្វើត្រៃសិក្ខាឲ្យបរិបូរណ៍បាន ចំណែកខ្លះប៉ុណ្ណោះ (ចំណែក) ព្រះអរហន្ត ឈ្មោះថា ជាអ្នកមានប្រក្រតីធ្វើឲ្យ បរិបូរណ៍ គឺ ព្រះអរហន្តនោះ ធ្វើត្រៃសិក្ខាឲ្យបរិបូរណ៍បានតែម្យ៉ាង ។ បទថា *អវញ្ឈានិ* គឺ មិនទទេ អធិប្បាយថា មានផល មានកម្រៃ ។ សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ លាយគ្នានោះឯង ។

ចប់អដ្ឋកថា បឋមសិក្ខាសូត្រទី ៦

# អដ្ឋកថា ទុតិយសិក្ខាសូត្រទី ៧

*“ពោលដោយសេក្ខបុគ្គល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសិក្ខាសូត្រទី ៧ ដូចតទៅនេះ ៖*

*[៨៩] បទថា **កោលំកោលោ** (កោលំកោលៈ) បានដល់ (ព្រះសោតាបន្ន) ទៅពីត្រកូលកាន់ត្រកូល ។ ក៏ក្នុងបទថា **ត្រកូល** នេះ លោកបំណងយក កព ព្រោះហេតុនោះ សូម្បីក្នុងបទថា ២ ឬ ៣ ត្រកូលនេះ គប្បីជ្រាបន័យថា ២ ឬ ៣ កព ។ ពិតហើយ ព្រះសោតាបន្ននេះ រមែងអន្ទោលទៅ ២ កពខ្លះ ៣ កពខ្លះ ឬយ៉ាងច្រើនបំផុតក៏ ៦ កព ព្រោះហេតុនោះ គប្បីឃើញវិកប្ប (ការកំណត់) ក្នុងបទនេះយ៉ាងនេះថា ២ កពខ្លះ ៣ កពខ្លះ ៤ កពខ្លះ ៥ កពខ្លះ ៦ កពខ្លះ ។*

*បទថា **ឯកពីជី** មានរូបវិគ្រោះថា ពូជរបស់កពមួយប៉ុណ្ណោះ របស់ព្រះអរិយៈនេះមានហើយ ហេតុនោះ ព្រះអរិយៈនេះទើបឈ្មោះថា ឯកពីជី (អ្នកមានពូជតែមួង) ។*

*បទថា **ឧទ្ធំសោតោ** ជាដើម អធិប្បាយថា ព្រះអនាគាមី ប្រភេទឧទ្ធំសោតោអកនិដ្ឋគាមី ១ , ប្រភេទឧទ្ធំសោតោ ន អកនិដ្ឋគាមី ១ , ប្រភេទ ន ឧទ្ធំសោតោអកនិដ្ឋគាមី ១ , ប្រភេទ ន ឧទ្ធំសោតោ ន អកនិដ្ឋគាមី ១ ។*

បណ្ដាព្រះអនាគាមី ៤ ជំពូកនោះ ព្រះអនាគាមីណា សម្រេចអនាគាមិផលក្នុងលោកនេះហើយ កើតក្នុងជាន់សុទ្ធាវាស មានជាន់អវិហាជាដើម ស្ថិតនៅក្នុងជាន់អវិហានោះ រហូតដល់អស់អាយុ ហើយក៏កើតក្នុងជាន់សុទ្ធាវាសជាន់លើៗ រហូតដល់សុទ្ធាវាសជាន់អកនិដ្ឋៈ ព្រះអនាគាមីនេះ មានឈ្មោះថា **ឧទ្ធំសោតោ អកនិដ្ឋគាមី** ។

ចំណែកព្រះអនាគាមីណា កើតក្នុងសុទ្ធាវាសជាន់អវិហាជាដើម (តែ) មិនបរិនិព្វានក្នុងសុទ្ធាវាសជាន់នោះ ទៅបរិនិព្វានក្នុងព្រហ្មលោកជាន់លើៗ តែមិនដល់សុទ្ធាវាសជាន់អកនិដ្ឋៈ ព្រះអនាគាមីនេះ ឈ្មោះថា **ឧទ្ធំសោតោ ន អកនិដ្ឋគាមី** ។

ព្រះអនាគាមីណា ចុតិចាកលោកនេះហើយ ទៅកើតក្នុងសុទ្ធាវាសជាន់អកនិដ្ឋៈតែម្ដង ព្រះអនាគាមីនេះ ឈ្មោះថា **ន ឧទ្ធំសោតោអកនិដ្ឋគាមី** ។

ចំណែកព្រះអនាគាមីណាឧប្បត្តិក្នុងសុទ្ធាវាសជាន់ណាមួយ ក្នុងបណ្ដាសុទ្ធាវាស ៤ មានអវិហាជាដើម និងបរិនិព្វានក្នុងសុទ្ធាវាសជាន់នោះឯង ព្រះអនាគាមីនេះ ឈ្មោះថា **ន ឧទ្ធំសោតោ ន អកនិដ្ឋគាមី** ។

ចំណែកព្រះអនាគាមីឧប្បត្តិក្នុងព្រហ្មលោកជាន់ណាមួយហើយ សម្រេចអរហត្តផលដោយចិត្តដែលជាសសង្ខារ និងជាសប្បយោគៈ ព្រះអនាគាមីនេះ

ឈ្មោះថា **សសង្ខារបរិនិព្វាយី** ។

ព្រះអនាគាមីដែលសម្រេចព្រះអរហត្តផល ដោយចិត្តដែលជាអសង្ខារ ជាអសប្បយោគ ព្រះអនាគាមីនេះឈ្មោះថា **អសង្ខារបរិនិព្វាយី** ។

ព្រះអនាគាមីណា កើតក្នុងសុទ្ធាវាសជាន់អវិហា ដែលមានអាយុ ១.០០០ កប្ប កន្លងផុតទៅបាន ១០០[១] កប្បដំបូង ក៏សម្រេចអរហត្តផល ព្រះអនាគាមីនេះឈ្មោះថា **ឧបហច្ចបរិនិព្វាយី** ។

សូម្បីក្នុងសុទ្ធាវាសជាន់អតប្បាជាដើម ក៏មានន័យនេះឯង ។

បទថា **អន្តរាបរិនិព្វាយី** សេចក្តីថា ព្រះអនាគាមីណា អាយុមិនទាន់បានពាក់កណ្តាល ក៏បរិនិព្វាន ព្រះអនាគាមីនោះមាន ៣ ប្រភេទ គឺ ជាដំបូង ព្រះអនាគាមីមួយអង្គ កើតក្នុងសុទ្ធាវាសជាន់អវិហាដែលមានអាយុ ១.០០០ កប្ប ហើយក៏សម្រេចអរហត្តផលក្នុងថ្ងៃដែលកើតនោះឯង តែថា បានសម្រេចក្នុងទីបំផុត ១០០ កប្បដំបូង ព្រះអនាគាមីនេះ ឈ្មោះថា **អន្តរាបរិនិព្វាយី** ប្រភេទទី ១ ។ ព្រះអនាគាមីមួយអង្គទៀត មិនអាចសម្រេចអរហត្តផលបានយ៉ាងនោះ (ប៉ុន្តែថា) បានសម្រេចក្នុងទីបំផុត ២០០ កប្ប ព្រះអនាគាមីនេះ ឈ្មោះថា **អន្តរាបរិនិព្វាយី** ប្រភេទទី ២ ។

---

(១) បាឋៈដទៃៗ ថា កន្លង ៥០០ កប្ប ។

ព្រះអនាគាមីមួយអង្គទៀត សូម្បីក្នុងទីបំផុត ២០០ កប្បនោះ ក៏មិនអាច (សម្រេចអរហត្តផល) បាន (ប៉ុន្តែថា) បានសម្រេចក្នុងទីបំផុត ៤០០ កប្ប ព្រះអនាគាមីនេះ ឈ្មោះថា **អន្តរាបរិនិព្វាយី** ប្រភេទទី ៣ ។ បទដ៏សេសមាន ន័យដូចពោលហើយនោះឯង ។

## ព្រះសោតាបន្ន ២៤ ជាដើម

ម្យ៉ាងទៀត អ្នកសិក្សាគប្បីតាំងនៅក្នុងឋានៈនេះ ហើយពោលដល់ព្រះសោតាបន្ន ២៤ ពួក ព្រះសកទាគាមី ១២ ពួក ព្រះអនាគាមី ៤៨ ពួក និងព្រះអរហន្ត ១២ ពួក ។ អធិប្បាយថា ក្នុងសាសនានេះ មានធុរៈ ២ គឺ សទ្ធាធុរៈ ១ បញ្ញាធុរៈ ១ មានបដិបទា ៤ មានទុក្ខាបដិបទាទន្ធាភិញ្ញាជាដើម ។

ក្នុងសទ្ធាធុរៈ និងបញ្ញាធុរៈនោះ ព្រះសោតាបន្នបុគ្គលមួយរូប មុតមាំដោយសទ្ធាធុរៈដរាបបានសម្រេចសោតាបត្តិផល កើតក្នុងភពមួយ ហើយធ្វើទីបំផុតទុក្ខបាន ព្រះសោតាបន្នបុគ្គលរូបនេះ ចាត់ជា **ឯកពីជី** ប្រភេទមួយ ។ ព្រះសោតាបន្នបុគ្គលប្រភេទឯកពីជីនោះ មាន ៤ ប្រភេទ ដោយអំណាចបដិបទា ។ ព្រះសោតាបន្នបុគ្គលប្រភេទឯកពីជី ដែលមុតមាំដោយសទ្ធាធុរៈនេះ យ៉ាងណា សូម្បីលោកមុតមាំដោយបញ្ញាធុរៈក៏យ៉ាងនោះ រួមជាព្រះសោតាបន្នបុគ្គលប្រភេទឯកពីជី មាន ៨ ប្រភេទ ។ ព្រះសោតាបន្នប្រភេទ កោលំកោលៈ និងព្រះសោតា-

បន្ន ប្រភេទសត្តក្ខត្តុបរមៈ ក៏ដូចគ្នា គឺ ប្រភេទមួយៗ មាន ៨ រួមជា ព្រះសោតាបន្នទាំងនេះមាន ២៤ ប្រភេទ ។

ក្នុងវិមោក្ខទាំង ៣ ព្រះសកទាគាមីបុគ្គល ដែលសម្រេចភូមិរបស់ព្រះសកទាគាមី ដោយសុញ្ញតវិមោក្ខ ក៏មាន ៤ ដោយអំណាចបដិបទា ៤ ។ មួយទៀត ព្រះសកទាគាមីបុគ្គលដែលសម្រេចភូមិរបស់ព្រះសកទាគាមី ដោយអនិមិត្តវិមោក្ខ ក៏មាន ៤ ។ អ្នកសម្រេចភូមិព្រះសកទាគាមី ដោយអប្បណិហិតវិមោក្ខ ក៏មាន ៤ រួមជា ព្រះសកទាគាមីទាំងនេះ មាន ១២ ប្រភេទ ។

ចំណែកក្នុងព្រហ្មលោកជាន់អវិហា ព្រះអនាគាមី មាន ៥ គឺ ព្រះអនាគាមីប្រភេទ **អន្តរាបរិនិព្វាយី** មាន ៣ , ព្រះអនាគាមីប្រភេទ **ឧបហច្ចបរិនិព្វាយី** មាន ១ , ព្រះអនាគាមីប្រភេទ **ឧទ្ធំសោតោអកនិដ្ឋគាមី** មាន ១ ។ ព្រះអនាគាមីទាំងនោះ បែកជា ១០ គឺ ព្រះអនាគាមីប្រភេទ **អសង្ខារបរិនិព្វាយី** មាន ៥ ព្រះអនាគាមីប្រភេទ **សសង្ខារបរិនិព្វាយី** មាន ៥ ។ ក្នុងសុទ្ធាវាសជាន់អតប្បាជាដើម ក៏មានចំនួនដូចគ្នា ។ តែសុទ្ធាវាសជាន់អកនិដ្ឋៈ ព្រះអនាគាមីប្រភេទឧទ្ធំសោតោ មិនមាន ។ ព្រោះដូច្នោះ ក្នុងសុទ្ធាវាសជាន់អកនិដ្ឋៈនោះ ទើបមានព្រះអនាគាមី ៨ គឺ ព្រះអនាគាមីប្រភេទ **សសង្ខារបរិនិព្វាយី** មាន ៤ ព្រះអនាគាមីប្រភេទ **អសង្ខារបរិនិព្វាយី** មាន ៤ (ដូចគ្នា) រួមជា ព្រះអនាគាមី

មានទាំងអស់ ៤៨ ។ សូម្បីព្រះអរហន្ត ក៏គប្បីជ្រាបថា មាន ១២ ដូចព្រះសកទាគាមី ។ សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ លាយគ្នានោះឯង ។

ចប់អដ្ឋកថា តតិយសេក្ខសូត្រទី ៧

# អដ្ឋកថា តតិយសិក្ខាសូត្រទី ៨

*“ពោលដោយសេក្ខបុគ្គល”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយសិក្ខាសូត្រទី ៨ ដូចតទៅនេះ ៖*

[៩០] *បទថា* ***តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ*** *(កាលមិនទាន់សម្រេច មិនទាន់ដឹងច្បាស់អរហត្តនោះ) សេចក្តីថា ព្រះអនាគាមីនៅមិនទាន់សម្រេច នៅមិនទាន់ត្រាស់ដឹងអរហត្តផលនោះ ។ អ្នកសិក្សាគប្បីជ្រាបន័យក្នុងទីគ្រប់កន្លែង (ដែលមានបទថា កាលមិនទាន់សម្រេច មិនទាន់ដឹងច្បាស់នូវអរហត្តនោះ) ដោយន័យនេះ ។ សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគក៏ត្រាស់សិក្ខា ៣ យ៉ាងទុកលាយគ្នានោះឯង ។*

ចប់អដ្ឋកថា ចតុត្ថសេក្ខសូត្រទី ៨

# អដ្ឋកថា បឋមសិក្ខត្តយសូត្រទី ៩

## "ពោលដោយត្រៃសិក្ខា"

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសិក្ខត្តយសូត្រទី ៩ ដូចតទៅនេះ ៖

[៩១] ក្នុងសូត្រទី ៩ មានអត្ថងាយទាំងអស់នោះឯង ។ សូម្បីក្នុងសូត្រនេះ ព្រះមានព្រះភាគ ក៏ត្រាស់សិក្ខា ៣ ទុកលាយគ្នានោះឯង ។

ចប់អដ្ឋកថា បឋមសិក្ខាសូត្រទី ៩

# អដ្ឋកថា ទុតិយសិក្ខត្តយសូត្រទី ១០

## *“ពោលដោយត្រៃសិក្ខា”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសិក្ខត្តយសូត្រទី ១០ ដូចតទៅនេះ ៖*

*[៩២] ក្នុងបទថា **អាសវានំ ខយា** (ព្រោះអស់អាសវៈទាំងឡាយ) នេះ មានអធិប្បាយថា អរហត្តមគ្គ ឈ្មោះថា **អធិប្បញ្ញាសិក្ខា** ។ ចំណែកផល មិនគួរពោលថា សិក្ខា ព្រោះកើតឡើងដល់បុគ្គលដែលបានសិក្សាសិក្ខាហើយ ។*

*បទថា **យថា បុរេ តថា បច្ឆា** (មុនយ៉ាងណា ក្រោយក៏យ៉ាងនោះ) សេចក្ដីថា ក្នុងផ្នែកខាងដើម សិក្សាក្នុងសិក្ខា ៣ យ៉ាង ខាងក្រោយក៏សិក្សាយ៉ាងនោះដូចគ្នា ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះឯង ។ បទថា **យថា អធោ តថា ឧទ្ធំ** (ខាងក្រោមយ៉ាងណា ខាងលើក៏យ៉ាងនោះ) សេចក្ដីថា អ្នកពិចារណាឃើញកាយខាងក្រោម ដោយអំណាចនៃអសុភៈយ៉ាងណា ក៏ពិចារណាឃើញកាយខាងលើយ៉ាងនោះដូចគ្នា ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **យថា ទិវា តថា រត្តិំ** (ពេលថ្ងៃយ៉ាងណា ពេលយប់ក៏យ៉ាងនោះ) សេចក្ដីថា ក្នុងវេលាថ្ងៃ អ្នកសិក្សាសិក្ខា ៣ យ៉ាង សូម្បីក្នុងវេលាយប់ក៏សិក្សាយ៉ាងនោះដូចគ្នា ។ បទថា **អភិភុយ្យ ទិសា សព្វា** (គ្របសង្កត់ទិសទាំង*

ពួន) សេចក្តីថា គ្របសង្កត់ទិសទាំងពួង គឺ អារម្មណ៍ទាំងឡាយ ។ បទថា **អប្បមាណសមាធិ** (ដោយសមាធិដែលរកប្រមាណមិនបាន) គឺ ដោយសមាធិដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា **សេក្ខំ** (អ្នកសិក្សា) បានដល់ អ្នកនៅសិក្សា គឺ អ្នកនៅមានកិច្ចដែលត្រូវធ្វើ ។ បទថា **បដិបទំ** (បដិបទា) បានដល់ វត្តបដិបត្តិ ។ បទថា **សំសុទ្ធចារិនំ** (មានការប្រព្រឹត្តបរិសុទ្ធិល្អ) បានដល់ អ្នកមានចរណៈបរិសុទ្ធិល្អ គឺ អ្នកមានសីលបរិសុទ្ធិ ។ បទថា **សមុទំ** (អ្នកត្រាស់ដឹង) បានដល់ អ្នកត្រាស់ដឹងសច្ចៈ ៤ ។ បទថា **ធីរំ**[១] **បដិបទន្តគុំ** (ជាអ្នកប្រាជ្ញ ដល់នូវទីបំផុតនៃបដិបទា) ។ សេចក្តីថា ជាអ្នកប្រាជ្ញ គឺ អ្នកដល់ព្រមដោយបញ្ញា ដោយអំណាចនៃបញ្ញាក្នុងខន្ធ ធាតុ និងអាយតនៈ ជាអ្នកដល់ទីបំផុតនៃវត្តបដិបត្តិ ។

បទថា **វិញ្ញាណស្ស** (នៃវិញ្ញាណ) បានដល់ នៃចរិមកវិញ្ញាណ (ចិត្តដួងចុងក្រោយ) ។ បទថា **តណ្ហក្ខយវិមុត្តិនោ** (របស់អ្នករួចផុតព្រោះអស់តណ្ហា) បានដល់ របស់បុគ្គលប្រកបដោយអរហត្តផលវិមុត្តិ ពោលគឺ សេចក្តីរួចផុតព្រោះអស់តណ្ហា ។ បទថា **បជ្ជោតស្សេវ និព្វានំ** (ដូចការរលត់នៃដួងប្រទីប) មានន័យថា ប្រៀបដូចការរលត់ទៅរបស់ដួងប្រទីប ។ បទថា **វិមោក្ខោ ហោតិ**

---

(១) បិដក = ធីរំ បដិបទន្តគុំ ។

*ចេតសោ* (ការរួចផុតនៃចិត្តរមែងមាន) សេចក្តីថា ការរួច គឺ ការផុត បានដល់ភាវៈ គឺ ការមិនប្រព្រឹត្តទៅនៃចិត្ត រមែងមាន ។ អធិប្បាយថា ក៏ការរួចផុតទៅនៃចិត្ត ដែលប្រៀបដូចការរលត់ទៅនៃប្រទីប រមែងមានដល់ព្រះខីណាស្រពអ្នករួចផុត ព្រោះអស់តណ្ហា ព្រោះចរិមកវិញ្ញាណរលត់ទៅ ស្ថានទីដែលព្រះខីណាស្រពទៅក៏មិនប្រាកដ លោកជាអ្នកចូលដល់ភាពដែលបញ្ញត្តិមិនបាន ។

ចប់អដ្ឋកថា ទុតិយសិក្ខត្តយសូត្រទី ១០

# អដ្ឋកថា បង្កធាសូត្រទី ១១

## "អ្នកគួរសរសើរ និងមិនគួរសរសើរ"

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសិក្ខត្តយសូត្រទី ១០ ដូចតទៅនេះ ៖

[៩៣] បទថា **បង្កធា នាម កោសលានំ និគមោ** (តំបន់បង្កធានៃកោសលរដ្ឋនោះ) សេចក្ដីថា និគមក្នុងកោសលរដ្ឋដែលមានឈ្មោះយ៉ាងនេះថា **បង្កធា** ។ បទថា **អាវាសិកោ** (ជាចៅអាវាស) សេចក្ដីថា ភិក្ខុដែលជាចៅអាវាសសាងទីនៅថ្មីៗ ឡើង រក្សាទីនៅចាស់ៗ ។ បទថា **សិក្ខាបទបដិសំយុត្តាយ** (ប្រកបដោយសិក្ខាបទ) បានដល់ បដិសំយុត្តដោយបទ ពោលគឺ សិក្ខា អធិប្បាយថា ប្រកបដោយសិក្ខា ៣ ។ បទថា **សន្ទស្សេតិ** (ទ្រង់ឲ្យឃើញច្បាស់) បានដល់ ទ្រង់ឲ្យភិក្ខុទាំងឡាយឃើញដូចនៅចំពោះមុខ ។ បទថា **សមាទបេតិ** (ឲ្យសមាទាន) បានដល់ ឲ្យភិក្ខុទាំងឡាយបដិបត្តិ ។ បទថា **សមុត្តេជេតិ** (ឲ្យអាចហ៊ាន) គឺ ឲ្យភិក្ខុទាំងឡាយឧស្សាហៈ ។ បទថា **សម្បហំសេតិ** (ឲ្យរីករាយ) គឺ ត្រាស់សរសើរធ្វើភិក្ខុទាំងឡាយឲ្យជ្រះថ្លាក្នុងគុណ ដែលខ្លួនបានហើយ ។ បទថា **អធិសល្លេខតេ** (ជុសខាត់ដ៏ក្រៃលែង) បានដល់ សមណៈនេះរមែងជុសខាត់ជ្រុលពេក អធិប្បាយថា សមណៈនេះ រមែងពោលធម៌ដែលល្អិត ធ្វើឲ្យជាការជុសខាត់ហួសប្រមាណ ។

បទថា **អច្ចយោ** (ទោស) គឺ កំហុស ។ បទថា **មំ អច្ចគ្គមា**[១] (បាន គ្របសង្កត់ខ្ញុំព្រះអង្គ) បានដល់ គ្របសង្កត់ញាំញីខ្ញុំព្រះអង្គ ប្រព្រឹត្តទៅ ។ បទ ថា **អហុទេវ អក្ខន្តិ** (មានសេចក្តីមិនពេញចិត្ត) សេចក្តីថា ការមិនអាចអត់ទ្រាំ មានហើយនោះឯង ។ បទថា **អហុ អប្បច្ចយោ** (មានសេចក្តីទាស់ចិត្ត) សេចក្តី ថា អាការមិនត្រេកអរមានហើយ ។ បទថា **បដិគ្គណ្ហាតុ** (សូមទ្រង់ទទួល) សេចក្តីថា សូមព្រះមានព្រះភាគបូរអត់នូវទោស ។ បទថា **អាយតឹ សំវរាយ** (ដើម្បីសេចក្តីសង្រួមតទៅ) គឺ ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួមក្នុងអនាគត អធិប្បាយថា ដើម្បីត្រូវការនឹងមិនធ្វើកំហុស គឺ ទោស បានដល់ សេចក្តីក្លាំង ក្លាត់ បែបនេះទៀត ។ បទថា **តគ្ឃ** ជានិបាតតែម្យ៉ាង ។

បទថា **យថាធម្មំ បដិករោសិ** (ធ្វើតាមធម៌) គឺ ធម៌តាំងនៅដោយប្រការ ណា អ្នកក៏ធ្វើដោយប្រការនោះ មានពាក្យអធិប្បាយថា ឲ្យអត់ទោស ។ បទថា **តំ តេ មយំ បដិគ្គណ្ហាម**[២] (តថាគតទទួលអត់ទោសនោះដល់អ្នក) សេចក្តីថា តថាគតព្រមលើកទោសនោះឲ្យអ្នក ។ បទថា **វុឌ្ឍិ ហេសា កស្សប អរិយស្ស វិនយេ** (កស្សបៈ នុ៎ះជាសេចក្តីចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ) សេចក្តីថា ម្នាលកស្សបៈ នេះឈ្មោះថា ជាសេចក្តីចម្រើនក្នុងសាសនារបស់ព្រះមានព្រះ-

---

(១) បិដក = មំ ភន្តេ អច្ចគមោ , (២) តន្តេ មយំ បដិគ្គណ្ហាម ។

ភាគ ។ សួរថា សេចក្ដីចម្រើនដូចម្ដេច ។ ឆ្លើយថា ការឃើញទោសថាជាទោស ហើយ ធ្វើតាមធម៌ ដល់នូវសេចក្ដីសង្រួមតទៅ ។ ក៏ព្រះមានព្រះភាគ កាលទ្រង់ធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋាន ទើបត្រាស់ថា **បុគ្គលណាឃើញទោសថាជាទោស ធ្វើតាមធម៌ ដល់នូវសេចក្ដីសង្រួមតទៅ** ដូច្នេះ ។

បទថា **ន សិក្ខាកាមោ** (មិនប្រាថ្នាសិក្សា) សេចក្ដីថា ភិក្ខុមិនត្រូវការ គឺ មិនប្រាថ្នា បានដល់ មិនធ្វើសេចក្ដីប្រាថ្នាដល់សិក្ខា ៣ ។ បទថា **សិក្ខាសមាទានស្ស** (នៃកិរិយាសមាទានសិក្ខា) គឺ នៃការបំពេញសិក្ខាឲ្យបរិបូរណ៌ ។ បទថា **ន វណ្ណវាទី** (មិនសរសើរគុណ) គឺ មិននិយាយដល់គុណ ។ បទថា **កាលេន** (តាមវេលា) គឺ ដោយកាលដែលសមគួរ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា បង្កធាសូត្រទី ១១

**ចប់សមណវគ្គវណ្ណនា ទី ៤**

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១១ សូត្រ

# លោណផលវគ្គទី ៥

## អដ្ឋកថា អច្ចាយិកសូត្រទី ១

### “កិច្ចប្រញាប់របស់អ្នកស្រែ និងរបស់ភិក្ខុ”

គប្បីជ្រាបវិនិច្ឆ័យក្នុង អច្ចាយិកសូត្រទី ១ ដូចតទៅនេះ ៖

[៩៤] បទថា **អច្ចាយិកានិ** បានដល់ ប្រញាប់ ។ បទថា **ករណីយានិ** (កិច្ចដែលត្រូវធ្វើ) ប្រែថា កិច្ចដែលត្រូវធ្វើដោយពិត ក៏ធុរៈណាមិនត្រូវធ្វើ មានប្រាកដ ធុរៈនោះហៅថា កិច្ច (ការងារអតិរេក) ធុរៈដែលត្រូវធ្វើក៏មានប្រាកដ ឈ្មោះថា ករណីយៈ (ការងារប្រចាំ) ។ បទថា **សីឃសីឃំ** (ប្រញាប់ៗ) បានដល់ ដោយរួសរាន់ ។ បទថា **តំ** ក្នុងបទថា **តស្ស ខោ តំ** នេះ ត្រឹមតែនិបាត ។ បទថា **នត្ថិ សា ឥទ្ធិ វា អានុភាវោ វា** (មិនមានឫទ្ធិ ឬអានុភាព) សេចក្ដីថា ឫទ្ធិនោះ ឬអានុភាពនោះ មិនមាន ។

បទថា **ឧត្តរស្វេ** (ខានស្អែក) បានដល់ ក្នុងថ្ងៃទី ៣ ។ បទថា **ឧតុបរិណាមិនី** (មានរដូវប្រែប្រួល) បានដល់ ធញ្ញជាតិទាំងឡាយ បានការផ្លាស់ប្ដូររដូវ ។ បទថា **ជាយន្តិបិ** (រមែងដុះ) បានដល់ មានពន្លកពណ៌សដុះចេញក្នុងថ្ងៃទី ៣ កាលគ្រប់ ៧ ថ្ងៃ ពន្លកក៏ក្លាយជាពណ៌ខៀវ ។ បទថា **គព្ភិនីបិ ហោន្តិ**

សេចក្តីថា ដល់វេលាកន្លះខែក៏មូលដើម ។ បទថា **បចន្តិបិ** (ទុំខ្លះ) សេចក្តីថា ដល់វេលា ៣ ខែក៏ទុំ ។

ឥឡូវនេះ ព្រោះហេតុដែលព្រះសម្ពុទ្ធទាំងឡាយមិនមានសេចក្តីត្រូវការដោយគហបតី ឬដោយស្រូវអង្ករ តែដែលទ្រង់នាំឧបមានោះមក ក៏ដើម្បីទ្រង់សម្តែងបុគ្គល ឬអត្ថដែលសមគួរជាមួយទេសនានោះក្នុងសាសនា ដូច្នោះ កាលទ្រង់សម្តែងអត្ថដែលព្រះអង្គទ្រង់បំណងនឹងសម្តែង (ដែលជាហេតុ) ទ្រង់ប្រារព្ធឧបមានោះ ទើបត្រាស់ពាក្យថា **ដូច្នោះនោះឯង** ជាដើម ។ សូត្រនេះ កាលពោលអំពីអត្ថ ឆាយទាំងអស់នោះឯង ។ ក៏សិក្ខា ព្រះមានព្រះភាគក៏ត្រាស់ទុកលាយគ្នា សូម្បីក្នុងសូត្រនេះ ។

ចប់អដ្ឋកថា អច្ចាយិកសូត្រទី ១

# អដ្ឋកថា វិវិត្តសូត្រទី ២

## *“ការស្ងាត់ចាកកិលេស ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិវិត្តសូត្រទី ២ ដូចតទៅនេះ ៖*

[៩៥] *បទថា* ***ចីវរបវិវេកំ*** *(ចីវរបវិវេក) បានដល់ ការស្ងាត់ចាកកិលេស ដែលកើតឡើងព្រោះអាស្រ័យចីវរ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យតែម្យ៉ាងដូចគ្នា ។ បទថា* ***សាណានិ*** *បានដល់ សំពត់ដែលត្បាញដោយសំបកធ្មៃ ។ បទថា* ***មសាណានិ*** *បានដល់ សំពត់ដែលមានសាច់លាយគ្នា ។ បទថា* ***ឆវទុស្សានិ*** *(សំពត់រុំសាកសព) បានដល់ សំពត់ដែលចោលពីកាយរបស់មនុស្សស្លាប់ ឬសំពត់ស្លៀកដែលក្រងដោយស្មៅជាដើម ។ បទថា* ***បំសុកូលានិ*** *(សំពត់ដែលគេចោល) បានដល់ សំពត់មិនមានជាយ ដែលទុកចោលលើផែនដី ។ បទថា* ***តិរីដកានិ*** *(សំពត់សំបកឈើ) បានដល់ សំពត់ដែលធ្វើពីសំបកឈើ ។ បទថា* ***អជិនានិ*** *(ស្បែកសត្វ) បានដល់ ស្បែករបស់សត្វឈ្មោះអជិនៈ (ខ្លាឃ្មុំ) ។ បទថា* ***អជិនក្ខិបំ*** *(ស្បែកសត្វទាំងក្រចក) បានដល់ ស្បែកខ្លានោះឯងដែលវះត្រង់កណ្តាល អាចារ្យពួកខ្លះពោលថា ស្បែកខ្លាដែលមានទាំងក្រចក ដូច្នេះខ្លះ ។*

*បទថា* ***កុសចីរំ*** *បានដល់ ចីវរដែលក្រងដោយស្បូវ ។ សូម្បីក្នុងសំពត់ក្រងដោយសំបកឈើ និងចំរៀកក្តារ ក៏មានន័យនេះឯង ។ បទថា* ***កេសកម្ពលំ***

(សំពត់កម្ពលសក់មនុស្ស) បានដល់ សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស ។ បទថា **វាលកម្ពលំ** (សំពត់កម្ពលកន្ទុយសត្វ) បានដល់ សំពត់កម្ពលដែលធ្វើដោយកន្ទុយសេះជាដើម ។ បទថា **ឧលូកបក្ខិកំ** (សំពត់ស្លាបសត្វ) បានដល់ សំពត់ស្បៀកដែលក្រងដោយស្លាបមៀម ។

បទថា **សាកភក្ខា** (ស៊ីបន្លែ) បានដល់ មានបន្លែស្រស់ជាអាហារ ។ បទថា **សាមាកភក្ខា** បានដល់ មានអង្ករស្រងែជាអាហារ ។ ក្នុងបទថា **និវារ** (ស្រូវព្រៃ) ជាដើម ស្កួយដែលដុះឡើងឯងក្នុងព្រៃ ឈ្មោះថា ស្រូវព្រៃ ។ បទថា **ទទ្ទុលំ** (កំទេចស្បែក) បានដល់ កំទេចសាច់សត្វ[១] ដែលពួកជាងស្បែកកោសស្បែកហើយចោល ។ ស្លែក្តី សារាយក្តី ជ័រឈើមានដើមកណ្ណិការជាដើមក្តី ហៅថា **ហដៈ** ។ បទថា **កណំ** បានដល់ កន្ទក់ ។ បទថា **អាចាមោ** (បាយក្តាំង) បានដល់ បាយក្រៀមដែលជាប់ឆ្នាំងបាយ តិរ្ថិយទាំងឡាយប្រមូលយកបាយក្តាំងនោះក្នុងទីដែលគេទុកចោល ហើយទំពាស៊ី ។ អាចារ្យពួកខ្លះពោលថា **ទឹកបាយ** ដូច្នេះខ្លះ ។ ល្វបុកជាដើម ក៏ប្រាកដច្បាស់ហើយ ។ បទថា **បវត្ត-ផលភោជី** (ស៊ីផ្លែឈើដែលជ្រុះឯង) បានដល់ មានប្រក្រតី បរិភោគផ្លែឈើដែលជ្រុះស្រាប់ ។ បទថា **កុសាគារំ** បានដល់ រោងដាក់អន្ទាម ។

---

(១) បិដក = ចម្បៀវស្បែក ។

បទថា **សីលវា** (អ្នកមានសីល) បានដល់ ប្រកបដោយបារិសុទ្ធិសីល ៤ ។ បទថា **ទុស្សីលញ្ចស្ស បហីនំ ហោតិ** (លះបង់ការទ្រុស្តសីល) សេចក្តីថា ទ្រុស្តសីល ៥ ដែលភិក្ខុនោះលះបានហើយ ។ បទថា **សម្មាទិដ្ឋិកោ** បានដល់ ជាអ្នកមានទិដ្ឋិ (ការឃើញ) តាមសេចក្តីពិត ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ ជាអ្នកមានទិដ្ឋិមិនប្រព្រឹត្តទៅតាមសេចក្តីពិត ។ បទថា **អាសវា** បានដល់ អាសវៈ ៤ ។ បទថា **អគ្គប្បត្តោ** បានដល់ អ្នកដល់កំពូលដោយសីល ។ បទថា **សារប្បត្តោ** បានដល់ សម្រេចសារៈ គឺ សីល ។ បទថា **សុទ្ធោ** បានដល់ បរិសុទ្ធិ ។ បទថា **សារេ បតិដ្ឋិតោ** បានដល់ តាំងមាំនៅក្នុងសារៈ គឺ សីល សមាធិ និង បញ្ញា ។

បទថា **សេយ្យថាបិ** ស្មើនឹង **យថា នាម** (ឈ្មោះយ៉ាងណា) ។ បទថា **សម្បន្នំ** (សម្បូរ) គឺ បរិបូរណ៍ បានដល់ ពេញដោយស្រូវសាលីទុំ ។ បទថា **សង្ឃរាបេយ្យ** (ឲ្យជញ្ជូន) បានដល់ អ្នកស្រែគប្បីឲ្យជញ្ជូនមក ។ បទថា **ឧព្ពហាបេយ្យ** (ឲ្យនាំឡើង) បានដល់ គប្បីឲ្យនាំមកកាន់លាន ។ បទថា **កុសិកំ** សំបកស្រូវ) បានដល់ អង្កាម ។ បទថា **កោដ្ដាបេយ្យ** (ឲ្យបុក) បានដល់ គប្បីឲ្យចាក់ទៅក្នុងត្បាល់ ហើយយកអង្រែបុក ។ បទថា **អគ្គប្បត្តានិ** (ដល់នូវភាពប្រសើរ) បានដល់ (ធញ្ញជាតិទាំងឡាយ) ដល់នូវភាពជាបាយដ៏ប្រសើរ ។

*សូម្បីក្នុងបទថា* ***សារប្បត្តានិ*** *(ដល់នូវសារៈ) ជាដើម ក៏មានន័យនេះឯង ។ ចំណែកបទដ៏សេស មានអត្ថងាយទាំងអស់ ។*

*ចំណែកពាក្យណាដែលត្រាស់ទុកក្នុងសូត្រនេះថា ភាពទ្រុស្តសីលនោះ ភិក្ខុលះបានហើយ និងមិច្ឆាទិដ្ឋិ ភិក្ខុនោះក៏លះបានហើយ ដូច្នេះ ពាក្យនោះគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅយកការទ្រុស្តសីល និងមិច្ឆាទិដ្ឋិ ដែលភិក្ខុលះបានហើយ ដោយសោតាបត្តិមគ្គ ។*

ចប់អដ្ឋកថា វិវិត្តសូត្រទី ២

# អដ្ឋកថា សរទសូត្រទី ៣

## *“ការលះសំយោជនៈ ៣ ដោយធម្មចក្ខុ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សរទសូត្រទី ៣ ដូចតទៅនេះ ៖*

[៩៦] *បទថា* ***វិទ្ធេ*** *(ស្វាងស្រឡះ) គឺ ស្វាងស្រឡះព្រោះប្រាសចាកពពក ។ បទថា* ***ទេវេ*** *(ផ្ទៃមេឃ) គឺ អាកាស ។ បទថា* ***អភិវិហច្ច*** *គឺ កម្ចាត់ ។ បទថា* ***យតោ*** *គឺ ក្នុងកាលណា ។ បទថា* ***វិរជំ*** *គឺ ប្រាសចាកធូលី មានធូលី គឺ រាគៈជាដើម ។ ដែលឈ្មោះថា ប្រាសចាកមន្ទិល ព្រោះមន្ទិលទាំងនោះឯងប្រាសចាកហើយ ។ បទថា* ***ធម្មចក្ខុំ*** *បានដល់ ចក្ខុ គឺ សោតាបត្តិមគ្គ ដែលកំណត់ធម៌ គឺ សច្ចៈ ៤ ។ បទថា* ***នត្ថិ តំ សំយោជនំ*** *(សំយោជនៈនោះ...រមែងមិនមាន) សេចក្តីថា ព្រះអរិយសាវកនោះមិនមានសំយោជនៈ ២ យ៉ាង (អភិជ្ឈា និងព្យាបាទ) ។ មួយទៀត ក្នុងសូត្រក្រៅពីនេះ លោកពោលថា មិនមាន ក៏ព្រោះមិនអាចនឹងនាំមកកាន់លោកនេះបានទៀត ។ ពិតណាស់ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ព្រះអនាគាមី ។*

ចប់អដ្ឋកថា សរទសូត្រទី ៣

# អដ្ឋកថា បរិសាសូត្រទី ៤

## "បរិស័ទ ៣ ពួក"

គប្បីជ្រាបវិនិច្ឆ័យក្នុង បរិសាសូត្រទី ៤ ដូចតទៅនេះ ៖

[៩៧] បទថា **ន ពាហុល្លិកា ហោន្តិ** (មិនជាអ្នកប្រាថ្នាច្រើន) សេចក្តីថា មិនជាអ្នកប្រាថ្នាច្រើនដោយបច្ច័យ ។ បទថា **ន សាថលិកា** (មិនបន្ធូរបន្ថយ) គឺ មិនបន្ធូរបន្ថយក្នុងសិក្ខា ៣ ។ បទថា **ឱក្កមនេ**(១) **និក្ខិត្តធុរា** (ដាក់ចុះធុរៈក្នុងទីទាប) សេចក្តីថា នីវរណៈ ៥ ហៅថា **ឱក្កមនៈ** ព្រោះមានន័យថា ធ្វើឲ្យធ្លាក់ចុះ (ភិក្ខុជាថេរៈ) ជាអ្នកដាក់ធុរៈក្នុងនីវរណៈ ៥ ដែលធ្វើឲ្យធ្លាក់ចុះក្នុងទីទាបទាំងនោះ ។ បទថា **បវិវេកេ បុព្វង្គមា** (មានការស្ទុះទៅក្នុងសេចក្តីស្ងប់) សេចក្តីថា ស្ទុះទៅក្នុងវិវេក ៣ យ៉ាង ពោលគឺ កាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ បទថា **វីរិយំ អារភន្តិ** (ប្រារព្ធសេចក្តីព្យាយាម) បានដល់ ផ្គងសេចក្តីព្យាយាមទាំង ២ យ៉ាង ។ បទថា **អប្បត្តស្ស** (ធម៌ដែលមិនទាន់សម្រេច) បានដល់ មិនសម្រេចគុណវិសេស ពោលគឺ ឈាន វិបស្សនា មគ្គ និងផល ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះឯង ។

បទថា **បច្ឆិមា ជនតា** (ប្រជុំជនដែលកើតខាងក្រោយ) បានដល់ ប្រជុំជន

(១) បិដក = វោក្កមនេ និក្ខិត្តធុរា ។

ខាងក្រោយ មានសទ្ធិវិហារិក និងអន្តេវាសិកជាដើម ។ បទថា **ទិដ្ឋានុគតឹ អាបជ្ជតិ** (ដល់នូវទិដ្ឋានុគតិ) សេចក្តីថា ធ្វើតាមវត្តដែលឧបជ្ឈាយ៍ និងអាចារ្យបានធ្វើមកហើយ ។ ប្រជុំជនខាងក្រោយនេះ ឈ្មោះថា ដល់ការប្រព្រឹត្តតាមវត្តដែលប្រជុំជននោះបានឃើញមកហើយ ក្នុងឧបជ្ឈាយាចារ្យ ។ បទថា **អយំវុច្ចតិ ភិក្ខវេ អគ្គវតី បរិសា** (ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទដែលមានបុគ្គលជាអ្នកប្រសើរ) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទដែលមានបុគ្គលជាអ្នកកំពូល ។

បទថា **ភណ្ឌនជាតា** (កើតសេចក្តីប្រេះឆា) បានដល់ បង្កហេតុ បង្កជម្លោះនឹងគ្នា ។ បទថា **កលហជាត** (កើតការវិវាទ) ប្រែថា កើតការឈ្លោះគ្នា ក៏ចំណែកខាងដើមនៃការឈ្លោះគ្នា ឈ្មោះថា ការប្រេះឆា ក្នុងសូត្រនេះ ។ ការប្រព្រឹត្តកន្លងគ្នាដោយអំណាច (ដល់ថ្នាក់) ដាក់ឈើច្រត់ចុះជាដើម ឈ្មោះថា ការឈ្លោះគ្នា ។ បទថា **វិវាទាបន្នា** (ដល់នូវការវិវាទ) បានដល់ ដល់នូវការឈ្លោះប្រកែកគ្នា ។ បទថា **មុខសត្តីហិ** (ដោយលំពែង គឺ មាត់) សេចក្តីថា វាចាដែលគ្រោតគ្រាត ហៅថា លំពែង គឺ មាត់ ព្រោះមានន័យថា ចាក់ដោតគ្នាដោយលំពែង គឺ មាត់នោះឯង ។ បទថា **វិតុទន្តា វិហរន្តិ** (ចាក់ដោត...ហើយ) គឺ ដើរ (និយាយ) ចាក់រុកគ្នា ។

បទថា **សមគ្គា** បានដល់ ព្រមព្រៀងគ្នា ។ បទថា **សម្មោទមានា** (រីករាយ) បានដល់ មានសេចក្ដីរីករាយប្រព្រឹត្តទៅព្រម ។ បទថា **ខីរោទកីភូតា** (ប្រៀបដូចទឹកដោះលាយនឹងទឹក) បានដល់ (លាយគ្នាបាន) ដូចជាទឹក និងទឹកដោះ ។ បទថា **បិយចក្ខូហិ** បានដល់ ដោយចក្ខុដែលប្រកបដោយមេត្តា ដែលស្ងប់ ។

បទថា **បីតិ ជាយតិ** (បីតិរមែងកើត) បានដល់ បីតិ ៥ ប្រភេទ កើតឡើង ។ បទថា **កាយោ បស្សម្ភតិ** (កាយ... រមែងស្ងប់) សេចក្ដីថា ទាំងនាមកាយ ទាំងរូបកាយ ជាការប្រាសចាកសេចក្ដីក្រវល់ក្រវាយ ។ បទថា **បស្សទ្ធកាយោ** (មានកាយស្ងប់) បានដល់ មានកាយមិនរសាប់រសល់ ។ បទថា **សុខំ វេទិយតិ** (រមែងហសោយសុខ) បានដល់ សោយសុខទាំងកាយ និងផ្លូវចិត្ត ។ បទថា **សមាធិយតិ** (រមែងតម្កល់មាំ) សេចក្ដីថា ក៏ចិត្ត (របស់ភិក្ខុដែលមានសេចក្ដីសុខ) រមែងតម្កល់មាំនៅក្នុងអារម្មណ៍ ។

បទថា **ថុល្លផុសិតកេ** (គ្រាប់ថ្លោស) បានដល់ ភ្លៀងគ្រាប់ធំ ។ ក្នុងបទថា **បព្វតកន្ទរបទរសាខា** (ញកភ្នំ ក្រហែង និងជ្រោះ ) នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ដែលឈ្មោះថា ញកភ្នំ បានដល់ ចំណែកនៃភ្នំដែលត្រូវទឹកហូរបាន នាមថា កំ ព្រោះហើយ គឺ ទម្លាយហើយ ដែលមនុស្សលោកហៅថា ច្រក

ភ្នំខ្លះ ជ្រលងមេទឹកខ្លះ ។ ដែលឈ្មោះថា ក្រហែង បានដល់ ភូមិប្រទេសដែលបែកក្រហែង ក្នុងកាលមិនមានភ្លៀងធ្លាក់អស់វេលាកន្លះខែ ។ ដែលឈ្មោះថា ជ្រោះ បានដល់ ប្រឡាយតូចជាផ្លូវសម្រាប់ទឹកហូរទៅកាន់ត្រពាំង ។ ដែលឈ្មោះថា ត្រពាំង បានដល់ ថ្លុកទឹកតូច ។ ដែលឈ្មោះថា បឹង បានដល់ ថ្លុកទឹកធំ ។ ដែលឈ្មោះថា ស្ទឹងតូច បានដល់ ស្ទឹងខ្នាតតូច ។ ដែលឈ្មោះថា ស្ទឹងធំ បានដល់ ស្ទឹងខ្នាតធំ មានស្ទឹងគង្គា និងយមុនាជាដើម ។

ចប់អដ្ឋកថា បរិសាសូត្រទី ៤

# អដ្ឋកថា បឋមអាជានីយសូត្រទី ៥

## *"អង្គ ៣ របស់សេះអាជានេយ្យ និងរបស់ភិក្ខុ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអាជានីយសូត្រទី ៥ ដូចតទៅនេះ ៖*

[៩៨] *បទថា* ***អង្គេហិ*** *(អង្គ) គឺ ដោយអង្គគុណទាំងឡាយ ។ បទថា* ***រាជារហោ*** *(គួរដល់ព្រះរាជា) គឺ (សេះអាជានេយ្យ) សមគួរ គឺ សមគួរដល់ព្រះរាជា ។ បទថា* ***រាជភោគ្គោ*** *(ជាសត្វសម្រាប់ប្រើរបស់ព្រះរាជា) គឺ ជាសេះព្រះរាជទ្រព្យ ។ បទថា* ***រញ្ញោ អង្គំ*** *(ជាអង្គរបស់ព្រះរាជា) បានដល់ ដល់នូវការរាប់ថាជាអង្គាវយវៈរបស់ព្រះរាជា ព្រោះជាសត្វស្មើដោយអង្គាវយវៈ មានព្រះហស្ត និងព្រះបាទជាដើម (ត្រាស់បង្គាប់បានស្មើដោយដៃ និងជើង) ។ បទថា* ***វណ្ណសម្បន្នោ*** *បានដល់ ដល់ព្រមដោយសម្បុរកាយ ។ បទថា* ***ពលសម្បន្នោ*** *បានដល់ សម្បូរណ៍ដោយកម្លាំងកាយ ។ បទថា* ***ជវសម្បន្នោ*** *បានដល់ ដល់ព្រមដោយសន្ទុះ ។*

*បទថា* ***អាហុនេយ្យោ*** *បានដល់ ជាអ្នកសមគួរទទួលបិណ្ឌបាត ពោលគឺ របស់ដែលគេនាំមកបូជា ។ បទថា* ***បាហុនេយ្យោ*** *បានដល់ ជាអ្នកសមគួរនឹងទទួលភត្តដែលគេបម្រុងទទួលភ្ញៀវ ។ បទថា* ***ទក្ខិណេយ្យោ*** *បានដល់ ជាអ្នកសមគួរដល់ទក្ខិណា ពោលគឺ របស់ដែលគេថ្វាយដោយសទ្ធា ដោយអំណាចលះ*

បង់ទានវត្ថុ ១០ យ៉ាង ។ បទថា **អញ្ជលិករណីយោ** បានដល់ ជាអ្នកសមគួរដល់ការផ្គងអញ្ជលី ។ បទថា **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** បានដល់ ជាទីដុះឡើងនៃបុណ្យរបស់មនុស្សលោកទាំងអស់ មិនមានទីណាស្មើដូច ។

បទថា **វណ្ណសម្បន្នោ** (សម្បូរណ៍ដោយវណ្ណៈ) បានដល់ ដល់ព្រមដោយវណ្ណៈ គឺ គុណ ។ បទថា **ពលសម្បន្នោ** (សម្បូរណ៍ដោយកម្លាំង) បានដល់ សម្បូរណ៍ដោយវិរិយពលៈ ។ បទថា **ជវសម្បន្នោ** (សម្បូរណ៍ដោយសន្ទុះ) បានដល់ ប្រកបព្រមដោយសន្ទុះ គឺ ញាណ ។ បទថា **ថាមវា** (រឹងមាំ) បានដល់ ដល់ព្រមដោយកម្លាំងនៃញាណ ។ បទថា **ទឡ្ហបរក្កមោ** (មានសេចក្តីសង្វាតយ៉ាងមាំ) បានដល់ មានសេចក្តីព្យាយាមមុតមាំ ។ បទថា **អនិក្ខិត្តធុរោ** (មិនដាក់ធុរៈ) បានដល់ មិនដាក់ធុរៈ គឺ បដិបត្តិដោយគិតយ៉ាងនេះថា យើងមិនទាន់សម្រេចអរហត្តផល ដែលជាផលដ៏ប្រសើរហើយ នឹងមិនលះបង់ចោលធុរៈ គឺ សេចក្តីព្យាយាម ។

ក្នុងសូត្រនេះ សោតាបត្តិមគ្គ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចសច្ចៈ ៤ និងភាពជាអ្នកដល់ព្រមដោយសន្ទុះនៃញាណ ត្រាស់ទុកហើយដោយសោតាបត្តិមគ្គនោះឯង ។

ចប់អដ្ឋកថា បឋមអាជានីយសូត្រទី ៥

# អដ្ឋកថា ទុតិយអាជានីយសូត្រទី ៦

## “អង្គ ៣ របស់សេះអាជានេយ្យ និងរបស់ភិក្ខុ”

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអាជានីយសូត្រទី ៦ ដូចតទៅនេះ ៖*

*[៩៩] ក្នុងសូត្រទី ៦ មគ្គ ៣ ផល ៣ ព្រះមានព្រះភាគត្រាស់ទុកហើយ និងភាពជាអ្នកដល់ព្រមដោយសន្ទុះនៃញាណ ព្រះមានព្រះភាគក៏ត្រាស់ទុកហើយ ដោយមគ្គ ៣ ផល ៣ ។*

ចប់អដ្ឋកថា ទុតិយអាជានីយសូត្រទី ៦

# អដ្ឋកថា តតិយអាជានីយសូត្រទី ៧

*"អង្គ ៣ របស់សេះអាជានេយ្យ និងរបស់ភិក្ខុ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអាជានីយសូត្រទី ៧ ដូចតទៅនេះ ៖*

*[១០០] ក្នុងសូត្រទី ៧ អរហត្តផល ព្រះមានព្រះភាគត្រាស់ទុកហើយ មគ្គកិច្ច ព្រះមានព្រះភាគត្រាស់ទុកហើយដោយអរហត្តផលទុំះឯង ។ ចំណែកផល (គឺអរហត្តផល) មិនគួរហៅថា សន្ទុះ ព្រោះកើតឡើងបានដោយសន្ទុះ (គឺញាណ) ដែលស្ទុះទៅហើយ ។*

ចប់អដ្ឋកថា តតិយអាជានីយសូត្រទី ៧

# អដ្ឋកថា ចោត្តកសូត្រទី ៨[១]

## "បុគ្គលប្រៀបដូចសំពត់សំបកឈើ ៣ ប្រភេទ"

*គប្បីជ្រាបវិនិច្ឆ័យក្នុង បោត្ថកសូត្រទី ៨ ដូចតទៅនេះ ៖*

[១០១] *សំពត់ដែលត្រាស់ថា ថ្មី ព្រោះអាស្រ័យការធ្វើ ។ សំពត់ដែលធ្វើចាកពីធ្មៃ ឈ្មោះថា* ***សំពត់សំបកឈើ*** *។ សំពត់ដែលឈ្មោះថា* ***ពាក់កណ្ដាលចាស់ពាក់កណ្ដាលថ្មី*** *បានដល់ សំពត់ពាក់កណ្ដាលចាស់ពាក់កណ្ដាលថ្មី ព្រោះប្រើប្រាស់ ។ សំពត់ដែលឈ្មោះថា* ***ចាស់*** *បានដល់ សំពត់ចាស់ព្រោះប្រើប្រាស់ ។ បទថា* ***ឧក្ខលិ បរិមជ្ជនំ*** *(សំពត់សម្រាប់ជូតឆ្នាំង) បានដល់ ជាសំពត់ជូតឆ្នាំងបាយ ។ បទថា* ***ទុស្សីលោ*** *(ទុស្ដសីល) បានដល់ មិនមានសីល ។ បទថា* ***ទុព្វណ្ណតាយ*** *(ដោយមានពណ៌អាក្រក់) បានដល់ ព្រោះជាអ្នកមានសម្បុរអាក្រក់ ទាក់ទងនឹងការមិនមានសម្បុរ គឺ គុណ ។ បទថា* ***ទិដ្ឋានុគតឹ អាបជ្ជន្តិ*** *(ដល់នូវទិដ្ឋានុគតិ) បានដល់ ភិក្ខុទាំងឡាយនាំគ្នាធ្វើតាមភិក្ខុនោះ ដែលធ្វើទុកហើយ ។ បទថា* ***ន មហប្ផលំ ហោតិ*** *(រមែងមិនមានផលច្រើន) សេចក្ដីថា មិនមានផលច្រើន ដោយផល គឺ វិបាក ។ បទថា* ***ន មហានិសំសំ*** *(មិនមានអានិសង្សច្រើន) សេចក្ដីថា មិនមានអានិសង្សច្រើន ដោយអានិសង្ស គឺ វិបាក ។*

---

*(១) បិដក = នវសូត្រ ។*

បទថា **អប្បគ្ឃតាយ** (ព្រោះមានតម្លៃតិច) បានដល់ ព្រោះការទទួលនោះ មានតម្លៃតិច ដោយតម្លៃ គឺ វិបាក ។ បទថា **កាសិកំ វត្ថំ** (សំពត់កាសី) បានដល់ សំពត់ដែលត្បាញដោយអំបោះពីកប្បាស ។ ក៏សំពត់ប្រភេទនោះ កើតឡើងតែក្នុងដែនកាសី ។

បទដ៏សេសងាយទាំងអស់នោះឯង ។ ចំណែកសីលក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុកលាយគ្នានោះឯង ។

ចប់អដ្ឋកថា ទោត្តកសូត្រទី ៨

# អដ្ឋកថា លោណផលសូត្រទី ៩

## *“ការឲ្យផលរបស់កម្ម”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង លោណផលសូត្រទី ៩ ដូចតទៅនេះ ៖*

[១០២] *បទថា* **យថា យថាយំ** *កាត់បទជា* **យថា យថា អយំ** ។ *បទថា* **តថា តថា តំ** *បានដល់* **តថា តថា តំ កម្មំ** ។ *មានពាក្យអធិប្បាយដូច្នេះថា បុគ្គលណាគប្បីពោលទុកយ៉ាងនេះថា បុគ្គលធ្វើកម្មទុកដោយប្រការណាៗ ក៏នឹងសោយវិបាក (ផល) របស់កម្មនោះ ដោយប្រការនោះៗ ព្រោះថានរណាៗ មិនអាចដែលនឹងមិនសោយវិបាករបស់កម្មដែលធ្វើទុកហើយបាន ព្រោះដូច្នោះ បុគ្គលធ្វើកម្មទុកប៉ុនណា ក៏នឹងសោយវិបាករបស់កម្មប៉ុណ្ណោះឯង ។ បទថា* **ឯវំ សន្តំ** *គឺ* **ឯវំ សន្តេ** *(បើដូច្នេះ) ។ បទថា* **ព្រហ្មចរិយវាសោ ន ហោតិ** *(ការនៅប្រព្រឹត្តព្រហ្មចរិយៈក៏មិនមានឱកាស) សេចក្តីថា ឧបបជ្ជវេទនីយកម្មណាដែលធ្វើទុកមុនការធ្វើមគ្គឲ្យកើតមាន ព្រោះឧបបជ្ជវេទនីយកម្មនោះ ដែលខ្លួននឹងត្រូវសោយដោយពិត ព្រហ្មចរិយៈសូម្បីនៅហើយ ក៏មិនជាការនៅឡើយ ។ បទថា* **ឱកាសោ ន បញ្ញាយតិ សម្មាទុក្ខស្ស អន្តកិរិយា** *(ដើម្បីធ្វើឲ្យផុតទុក្ខដោយប្រពៃក៏មិនប្រាកដ) សេចក្តីថា ក៏ព្រោះមានហេតុដូច្នេះ ការសន្សំកម្ម និងការសោយផលរបស់កម្ម ក៏គង់មានហើយ ដូច្នោះ ឱកាសនៃការធ្វើទីបំផុតនៃ*

វដ្តទុក្ខ ដោយហេតុ ដោយន័យ ឈ្មោះថា មិនប្រាកដ ។ បទថា **យថា យថា វេទិយំ** (ដែលគប្បីឲ្យផលយ៉ាងណាៗ) បានដល់ ដែលខ្លួនគប្បីសោយដោយអាការណាៗ ។ បទថា **តថា តថាស្ស វិបាកំ បដិសំវេទិយតិ** (រមែងសោយផលកម្មនោះយ៉ាងនោះៗ) សេចក្តីថា សោយវិបាករបស់កម្មនោះ ដោយអាការនោះៗ ។

មានពាក្យអធិប្បាយដូច្នេះថា ក្នុងជវនចិត្តទាំង ៧ កម្មក្នុងជវនចិត្តទី ១ កាលមានបច្ច័យ ក៏បានវារៈនឹងឲ្យផលក្នុង កម្មនោះចាត់ជា ទិដ្ឋធម្មវេទនីយកម្ម កាលមិនមានបច្ច័យ ក៏នឹងឈ្មោះថា ជាអហោសិកម្ម ។ ចំណែកកម្មក្នុងជវនចិត្តទី ៧ កាលមានបច្ច័យ ក៏នឹងជាឧបបជ្ជវេទនីយកម្ម កាលមិនមានបច្ច័យ ក៏ឈ្មោះថា ជាអហោសិកម្ម និងកម្មក្នុងជវនចិត្តទាំង ៥ ត្រង់កណ្តាល កម្មនោះឈ្មោះថា អបរាបរិយវេទនីយកម្ម រមែងអន្ទោលតាមទៅក្នុងសង្សារវដ្ត បុរស (បុគ្គល) នេះ ធ្វើកម្មនោះទុក នឹងគប្បីសោយបានដោយអាការណាៗ ក្នុងបណ្តាអាការទាំងនេះ ក៏នឹងសោយវិបាករបស់កម្មនោះ ដោយអាការនោះៗ ឯង ។ ពិតហើយ លោកពោលទុកក្នុងអដ្ឋកថាថា កម្មដែលបានវារៈឲ្យផលហើយប៉ុណ្ណោះ ឈ្មោះថា **យថាវេទនីយកម្ម** ។ បទថា **ឯវំ សន្តំ ភិក្ខវេ ព្រហ្មចរិយវាសោ ហោតិ** (បើដូច្នេះ ការប្រព្រឹត្តព្រហ្មចរិយៈរមែងមានបាន) សេចក្តីថា ពាក្យដែល

ពោលទុកថា ឈ្មោះថា មានការនៅព្រហ្មចរិយៈដែលធ្វើកម្មឲ្យអស់ទៅ ព្រោះកម្មដែលនឹងត្រូវធ្វើឲ្យអស់ទៅ នៅមាន ដូច្នេះ ជាការពោលទុកល្អហើយ ។

បទថា **ឱកាសោ បញ្ញាយតិ សម្មា ទុក្ខស្ស អន្តកិរិយាយ** (ឱកាសនឹងធ្វើទីបំផុតទុក្ខដោយប្រពៃ ក៏រមែងប្រាកដ) សេចក្តីថា ព្រោះកាលមានហេតុដូច្នេះ ក៏នឹងមិនកើតវដ្តទុក្ខតទៅក្នុងភពនោះៗ ព្រោះអភិសង្ខារវិញ្ញាណរលត់ទៅដោយមគ្គនោះៗ ដូច្នោះ ឱកាសនៃការធ្វើទីបំផុតនៃទុក្ខដោយល្អទើបប្រាកដ ។

## យថាវេទនីយកម្ម

ឥឡូវនេះ កាលនឹងទ្រង់សម្តែងសភាពយថាវេទនីយកម្មនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យជាដើមថា **ម្នាលភិក្ខុទាំងឡាយ... បុគ្គលខ្លះក្នុងលោកនេះ** ។ បណ្តាបទទាំងនោះ បទថា **អប្បមត្តកំ** (ប្រមាណតិច) បានដល់ កម្មតិចតួច គឺ កម្មបន្តិចបន្តួច បានដល់ កម្មស្រាល កម្មលាមក ។ បទថា **តាទិសំយេវ** (តែម្យ៉ាងដូចគ្នា) បានដល់ វិបាកដែលឃើញសមដោយកម្មនោះឯង ។ បទថា **ទិដ្ឋធម្មវេទនិយំ** សេចក្តីថា ក្នុងកម្មនោះឯង មានអធិប្បាយថា កម្មដែលនឹងគប្បីឲ្យផល កាលបានវារៈដែលនឹងឲ្យផលក្នុងបច្ចុប្បន្ន ក៏នឹងជាទិដ្ឋធម្មវេទនិយកម្ម ។ បទថា **នាណុបិ ខាយតិ** (នឹងមិនប្រាកដផលសូម្បីតិច) សេចក្តីថា មិនប្រាកដ (ត្រឹមតែ) តិចតួចក្នុងអត្តភាពទី ២ អធិប្បាយថា មិនឲ្យផលសូម្បីត្រឹមតែតិចតួច

ក្នុងអត្តភាពទី ២ ។ បទថា **ពហុទេវ** (ច្រើន) សេចក្តីថា នឹងឲ្យផលច្រើនបានយ៉ាងណា ។

បុថុជ្ជនដែលវៀរចាកភាវនា (ចម្រើនសតិប្បដ្ឋាន) ក្នុងកាយ ជាអ្នកមានប្រក្រតីទៅកាន់វដ្តៈ ព្រះមានព្រះភាគទ្រង់សម្តែងដោយបទថា **មានកាយមិនបានអប់រំ** ជាដើម ។ បទថា **បរិត្តោ** (មានគុណតិច) បានដល់ មានគុណបន្តិចបន្តួច ។ បទថា **អប្បាតុមោ** (មានអត្តភាពតិច) សេចក្តីថា អត្តភាពហៅថា **អាតុមៈ** បុថុជ្ជនឈ្មោះថា មានអត្តភាពតិចតួចដោយពិត ព្រោះសូម្បីកាលអត្តភាពនោះធំ តែក៏មានគុណតិចតួច ។ បទថា **អប្បទុក្ខវិហារី** (មានប្រក្រតីនៅជាទុក្ខដោយផលតិចតួច) សេចក្តីថា មានប្រក្រតីនៅជាទុក្ខដោយវិបាកតិចតួច ។ ព្រះខីណាស្រព ព្រះមានព្រះភាគទ្រង់សម្តែងដោយបទថា **មានកាយដែលអប់រំហើយ** ជាដើម ។ អធិប្បាយថា ព្រះខីណាស្រពនោះ ឈ្មោះថា មានកាយអប់រំហើយ ដោយភាវនាពោលគឺ កាយានុបស្សនា ឬឈ្មោះថា មានកាយអប់រំហើយ ព្រោះចម្រើនកាយានុបស្សនា ។ បទថា **ភាវិតសីលោ** (មានសីលដែលអប់រំហើយ) បានដល់ចម្រើនសីល ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះឯង ។

ម្យ៉ាងទៀត ព្រះខីណាស្រព ឈ្មោះថា មានកាយអប់រំហើយ ដោយអប់រំបញ្ចទ្វារ ។ ព្រះមានព្រះភាគត្រាស់ឥន្ទ្រិយសំវរៈសីល ដោយបទថា **មានកាយ**

**អប់រំហើយ** នេះ ។ ត្រាស់សីល ៣ ដ៏សេស ដោយបទថា **មានសីលដែលអប់រំហើយ** ។ បទថា **អបរិត្តោ** (មានគុណមិនតិច) គឺ មានគុណមិនមែនតិច ។ បទថា **មហត្តា** (មានអត្តភាពធំ) គឺ ព្រះខីណាស្រព ឈ្មោះថា មានអត្តភាពធំ ព្រោះសូម្បីនឹងមានអត្តភាពតូច តែក៏មានគុណច្រើន ។ ក៏បទថា **អប្បមាណវិហារី** (មានប្រក្រតីនៅដោយធម៌ដែលរកប្រមាណមិនបាន) នេះ ជាឈ្មោះរបស់ព្រះខីណាស្រពដោយពិត អធិប្បាយថា ព្រះខីណាស្រពនោះ ឈ្មោះថា មានប្រក្រតីនៅដោយធម៌ដែលរកប្រមាណមិនបាន ព្រោះមិនមានកិលេស មានរាគៈជាដើម ដែលធ្វើឲ្យមានប្រមាណ ។ បទថា **បរិត្តេ** គឺ តូច (ខុទ្ទកេ) ។ បទថា **ឧទកមល្លកេ** គឺ ផ្តិលទឹក (ឧទកសរាវកេ) ។

បទថា **ឱរព្ភិកោ** គឺ ម្ចាស់របស់ចៀម (ឧរព្ភសាមិកោ) ។ បទថា **ឱរព្ភឃាតកោ** គឺ អ្នកសម្លាប់ចៀម (សូនការោ) ។ បទថា **ជាបេតុំ វា**[១] (ដើម្បីធ្វើឲ្យវិនាស) បានដល់ ដើម្បីធ្វើឲ្យវិនាស ដោយការវិនាសទ្រព្យ ។ បាឋៈថា **ឈាបេតុំ** ដូច្នេះក៏មាន ន័យតែមួយដូចគ្នានោះឯង ។ បទថា **យថាបច្ចយំ វា កាតុំ** (ឬដើម្បីធ្វើតាមបំណង) សេចក្តីថា ដើម្បីធ្វើបានតាមប្រាថ្នា ។ បទថា **ឧរព្ភធនំ** (តម្លៃចៀម) បានដល់ តម្លៃខ្លួនចៀម ។ អ្នកលួចចៀមនោះ បើប្រាថ្នា

(១) បិដក = ឈាបេតុំ ។

ក៏នឹងឲ្យតម្លៃចៀមនោះ បើមិនប្រាថ្នាក៏នឹងឲ្យចាប់កអូសចេញទៅ ។

បទដ៏សេសគប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។ តែព្រះមាន-ព្រះភាគត្រាស់វដ្តៈ និងវិវដ្តៈ (និព្វាន) ទុកក្នុងសូត្រនេះឯង ។

ចប់អដ្ឋកថា លោណផលសូត្រទី ៩

# អដ្ឋកថា សង្ឃសូត្រទី ១០

## "ឧបក្កិលេស ៣ យ៉ាង"

គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ឃសូត្រទី ១០ ដូចតទៅនេះ ៖

[១០៣] បទថា **ធោវតិ** (លាង) បានដល់ ជម្រះ ។ បទថា **សន្ធោវតិ** (លាងជម្រះ) ប្រែថា លាងដោយល្អ គឺ លាងហើយលាងទៀត ។ បទថា **និទ្ធោវតិ** (លាងឲ្យចេញ) បានដល់ លាងយកវត្ថុសៅហ្មងចេញ ។ បទថា **អនិទ្ធន្តំ** (មិនបានផ្លុំជេញមន្ទិល) គឺ មិនទាន់បានជេញយកវត្ថុសៅហ្មងចេញ ។ បទថា **អនិន្នីតកាសាវំ** (មិនទាន់កម្ចាត់មន្ទិល) គឺ នៅមិនទាន់កម្ចាត់វត្ថុសៅហ្មង ។ បទថា **បភង្គុ** (បែក) បានដល់ មានការបែកធ្លាយទៅជាសភាព ។ រៀរមាសដែលរំលាយហើយ (ដ៏សេស) ត្រឹមតែយកអង្គុញដៃជំ ក៏បែក ។ បទថា **បដ្ឋ-កាយ** (ផែនមាស) បានដល់ ដើម្បីត្រូវការឲ្យជាផែនមាស ។ បទថា **គីវេយ្យកេ** (ខ្សែក) បានដល់ គ្រឿងប្រដាប់ក ។ បទថា **អធិចិត្តំ** បានដល់ ចិត្តដែលអប់រំដោយសមថៈ និងវិបស្សនា ។ បទថា **អនុយុត្តស្ស** (ប្រកបរឿយៗ) បានដល់ ចម្រើនចិត្ត ។ បទថា **ចេតសោ** (មានចិត្ត) បានដល់ សម្បូរណ៍ដោយចិត្ត ។

បទថា **ទព្វជាតិកោ** (ជាតិបណ្ឌិត) បានដល់ ជាបណ្ឌិតដោយកំណើត ។ ក្នុងវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើម មានអធិប្បាយថា វិតក្កៈដែលប្រារព្ធ

កាមកើតឡើង ឈ្មោះថា កាមវិតក្កៈ ។ វិតក្កៈដែលសម្បយុត្តដោយព្យាបាទ ឈ្មោះថា ព្យាបាទវិតក្កៈ ដែលសម្បយុត្តដោយវិហិង្សា ឈ្មោះថា វិហិង្សាវិតក្កៈ ។

ក្នុងវិតក្កៈទាំងឡាយ មានញាតិវិតក្កៈជាដើម មានអធិប្បាយថា វិតក្កៈដែលប្រារព្ធញាតិកើតឡើង ដោយន័យជាដើមថា ញាតិរបស់យើងទាំងឡាយចំនួនច្រើនមានបុណ្យ ឈ្មោះថា ញាតិវិតក្កៈ ។ វិតក្កៈដែលអាស្រ័យផ្ទះ ដែលប្រារព្ធជនបទកើតឡើង ដោយន័យជាដើមថា ជនបទឯណោះរួចផុតភ័យ រកកិក្ខាបានងាយ ឈ្មោះថា ជនបទវិតក្កៈ ។ បទថា **ន បណីតោ** គឺ មិនប្រណីត ។ បទថា **ន បដិប្បស្សទ្ធលទ្ធោ** (មិនបានស្ងប់រម្ងាប់) គឺ មិនបានសេចក្តីស្ងប់រម្ងាប់កិលេស ។ បទថា **ន ឯកោទិភាវាធិគតោ** (មិនដល់នូវភាពជាធម៌ប្រសើរឯក) គឺ មិនដល់នូវភាពជាសមាធិ ។ បទថា **សសង្ខារនិគ្គយ្ហវារិតវតោ** (ត្រូវប្រើសេចក្តីព្យាយាមគ្រប់សង្កត់) បានដល់ គ្រប់សង្កត់ រារាំង ហាមកិលេសទាំងឡាយទុក ដោយសសង្ខារដែលជាសប្បយោគៈ មិនមែនកើតឡើងក្នុងទីបំផុត ដែលកិលេសទាំងឡាយត្រូវកាត់ផ្តាច់ទៅ តែកើតឡើងហាមកិលេសទាំងឡាយ ។

ក្នុងបទថា **ហោតិ សោ ភិក្ខវេ សមយោ** (ម្នាលភិក្ខុទាំងឡាយ មានហើយ សម័យដែល) នេះ មានអធិប្បាយថា ដែលឈ្មោះថា សម័យ បានដល់វេលាដែលបានសប្បាយ ៥ ទាំងនេះ គឺ រដូវសប្បាយ អាហារសប្បាយ សេនា-

សទៈសប្បាយ បុគ្គលសប្បាយ ធម្មស្សវនសប្បាយ ។ បទថា **យន្តំ ចិត្តំ** (ក្នុងសម័យដែលចិត្ត) បានដល់ ក្នុងសម័យណា វិបស្សនាចិត្តនោះ ។ បទថា **អជ្ឈត្តំយេវ សន្តិដ្ឋតិ** (តាំងនៅក្នុងខាងក្នុងនោះឯង) បានដល់ តាំងនៅក្នុងខ្លួនទុះឯង ។ ក៏ក្នុងទីនេះ វិស័យនៃអារម្មណ៍ដែលទៀង ឈ្មោះថា អជ្ឈត្តៈ ក្នុងទីនេះ សូម្បីអារម្មណ៍ខាងក្នុងក៏គួរ ។ មានពាក្យអធិប្បាយថា វិបស្សនាចិត្ត លះអារម្មណ៍ចំនួនច្រើន ហើយតាំងមាំនៅក្នុងអារម្មណ៍តែមួយ គឺ ក្នុងអារម្មណ៍ គឺព្រះនិព្វានប៉ុណ្ណោះ ។ បទថា **សន្និសីទតិ** (ស្ងប់) បានដល់ ស្ងប់ដោយល្អ ។ បទថា **ឯកោទិភាវោ ហោតិ** (ដែនតែមួយ) បានដល់ ជាចិត្តមានអារម្មណ៍តែមួយដ៏ប្រសើរ ។ បទថា **សមាធិតិ** (តាំងមាំ) បានដល់ តាំងមាំដោយល្អ ។

ក្នុងបទថា **សន្តោ** (ស្ងប់) ជាដើម មានអធិប្បាយថា សមាធិ ឈ្មោះថា ស្ងប់ ព្រោះចូលទៅរម្ងាប់កិលេសដែលជាសត្រូវ ។ សមាធិ ឈ្មោះថា ប្រណីត ព្រោះមានន័យថា ឆ្អែតស្កប់ស្កល់ ។ សមាធិ ឈ្មោះថា បានសេចក្តី ស្ងប់រម្ងាប់ ព្រោះបានការស្ងប់រម្ងាប់កិលេស ។ សមាធិ ឈ្មោះថា ដល់នូវភាពជាធម៌ប្រសើរឯក ព្រោះដល់នូវភាពជាធម្មជាតិមានអារម្មណ៍តែមួយដ៏ប្រសើរ ។ សមាធិ ដែលឈ្មោះថា មិនត្រូវគ្របសង្កត់ ហាម រារាំង កិលេសទាំងឡាយទុកដោយសប្បយោគៈ ព្រោះកើតឡើងក្នុងទីបំផុតដែលកិលេសទាំងឡាយត្រូវកាត់ផ្តាច់ ព្រោះ

ហេតុនោះទើបឈ្មោះថា មិនត្រូវសស្នាគ្រេបសង្កត់ រារាំង ហាមទុក ។ ភិក្ខុនេះឈ្មោះថា ធ្វើចិត្តឲ្យវិលត្រឡប់ ហើយសម្រេចព្រះអរហត្តផល ដោយហេតុដែលប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ កាលនឹងទ្រង់សម្ដែងការត្រាស់ដឹងដោយអភិញ្ញារបស់ភិក្ខុនោះ ដែលជាព្រះខីណាស្រព ព្រះមានព្រះភាគទើបត្រាស់បទថា **ក៏...ណាៗ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អភិញ្ញាសច្ចិករណីយស្ស** (នូវអភិញ្ញាសច្ចិករណីយធម៌) បានដល់ ដែលគប្បីធ្វើឲ្យប្រច័ក្សព្រោះដឹងក្រៃលែង ។ បទថា **សតិ សតិ អាយតនេ** (កាលបើហេតុមានហើយ មានហើយ) សេចក្ដីថា កាលហេតុពោលគឺ បុព្វហេតុ និងប្រភេទនៃឈានជាដើម ដែលនឹងគប្បីបានក្នុងឥឡូវនេះ មានហើយ មានហើយ ។ ក៏កថាពណ៌នារឿងអភិញ្ញានេះ របស់ព្រះខីណាស្រពនោះ គប្បីជ្រាបដោយពិស្ដារ តាមន័យដែលពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គនុ៎ះឯង ។ ចំណែកបទថា **អាសវានំ ខយា** (ព្រោះអាសវៈទាំងឡាយអស់ទៅ) ជាដើម ក្នុងសូត្រនេះ គប្បីជ្រាបថា ត្រាស់ទុកហើយដោយអំណាចផលសមាបត្តិ ។

ចប់អដ្ឋកថា សង្ខ្យសូត្រទី ១០

# អដ្ឋកថា និមិត្តសូត្រទី ១១

## *“និមិត្ត ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និមិត្តសូត្រទី ១១ ដូចតទៅនេះ ៖*

*[១០៤] **អធិចិត្ត** បានដល់ ចិត្តក្នុងសមថៈ និងវិបស្សនាទាំងឯង ។ បទថា **តីណិ និមិត្តានិ** (និមិត្ត ៣) បានដល់ ហេតុ ៣ ។ បទថា **កាលេន កាលំ** (តាមកាលដ៏សមគួរ) បានដល់ ក្នុងកាល ក្នុងកាល អធិប្បាយថា រហូតកាលដ៏សមគួរ ។ ក្នុងបទថា **កាលេន កាលំ សមាធិនិមិត្តំ មនសិកាតព្វំ** (គប្បីមនសិការសមាធិនិមិត្តតាមកាលដ៏គួរ) ជាដើម មានអធិប្បាយថា ភិក្ខុគប្បីកំណត់កាលនោះៗ ហើយ មនសិការដល់ឯកគ្គតា (ភាពនៃចិត្តមានអារម្មណ៍តែមួយដ៏ប្រសើរ) ក្នុងវេលាដែលចិត្តប្រកបដោយឯកគ្គតា ។*

*ព្រោះថា ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ឯកគ្គតាថាជា **សមាធិនិមិត្ត** ។ ក្នុងបទថា **សមាធិនិមិត្ត** នោះ មានន័យរបស់ពាក្យដូច្នេះ និមិត្ត គឺសមាធិ ឈ្មោះថា សមាធិនិមិត្ត ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះឯង ។ បទថា **បគ្គាហោ** ជាឈ្មោះរបស់វីរិយៈ ។ បទថា **ឧបេក្ខា** ជាឈ្មោះរបស់មជ្ឈត្តភាវៈ (ភាពនៃចិត្តជាកណ្តាល) ។ ព្រោះដូច្នោះ ភិក្ខុគប្បីមនសិការដល់វីរិយៈក្នុងវេលាដែលសមគួរដល់វីរិយៈ ។ គប្បីតាំងនៅក្នុងមជ្ឈត្តភាវៈ ក្នុងវេលា*

ដែលសមគួរដល់មជ្ឈត្តការៈនោះឯង ។ បទថា **ឋានន្តំ ចិត្តំ កោសជ្ជាយ សំវត្តេយ្យ** (គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស) សេចក្តីថា ហេតុដែលធ្វើឲ្យចិត្តនោះតាំងនៅក្នុងការៈ គឺ សេចក្តីខ្ជិលច្រអូសមានហើយ ។ សូម្បីក្នុងហេតុពីក្រោនេះ ក៏មានន័យនេះឯង ។ មួយទៀត ក្នុងបទថា **ឧបេក្ខានិមិត្តំ យោនិសោ មនសិករេយ្យ** (មនសិការឧបេក្ខានិមិត្ត) មានអត្ថដូច្នេះថា ភិក្ខុគប្បីសម្លឹងមើលនូវភាពវាងវៃនៃញាណព្រងើយៗ ។ បទថា **អាសវានំ ខយាយ** (ដើម្បីការអស់អាសវៈទាំងឡាយ) បានដល់ ដើម្បីប្រយោជន៍ដល់អរហត្តផល ។

បទថា **ឧក្កំ ពន្ធេយ្យ**[១] (ចាត់ចែងបាវ) បានដល់ គប្បីត្រៀមក្បៀង (ឡ) ដាក់ធ្យូង ។ បទថា **អាលិម្បេយ្យ**[២] (ដុតមាត់បាវ) សេចក្តីថា គប្បីដាក់ធ្យូងទៅក្នុងក្បៀងនោះ ហើយដុតភ្លើង ហើយសប់ឲ្យភ្លើងឆេះជាប់ ។ បទថា **ឧក្កាមុខេ បក្ខិបេយ្យ**[៣] (ដាក់ត្រង់មាត់បាវ) សេចក្តីថា គប្បីកកាយរងើកភ្លើង ហើយដាក់លើរងើកភ្លើង ឬដាក់ទុកក្នុងបាវ ។ បទថា **អជ្ឈុបេក្ខតិ** (គប្បីសម្លឹងមើល) បានដល់ ពិចារណាមើលថា ក្តៅល្មមហើយឬនៅ ។

បទថា **សម្មា សមាធិយតិ អាសវានំ ខយាយ** (តាំងមាំដោយល្អ ដើម្បីការអស់អាសវៈ) បានដល់ (ចិត្ត) តម្កល់មាំដោយល្អ ដើម្បីប្រយោជន៍ដល់ព្រះ

---

(១-២-៣) បិដក = ឧក្កំ ពន្ធតិ , អាលិម្បេតិ , ឧក្កាមុខេ បក្ខិបិត្វា ។

*អរហត្តផល ។ ភិក្ខុដែលចម្រើនវិបស្សនាហើយ សម្រេចអរហត្តផល ព្រះ-មានព្រះភាគទ្រង់សម្តែងទុកហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។*

*ឥឡូវនេះ កាលនឹងទ្រង់សម្តែងបដិបទាជាហេតុឲ្យសម្រេចអភិញ្ញារបស់ព្រះខីណាស្រពនោះ ទើបត្រាស់ពាក្យថា ក៏... ណា ជាដើម ។ បទនោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងខាងដើមនុ៎ះឯង ។*

ចប់អដ្ឋកថា និមិត្តសូត្រទី ១១

ចប់លោណផលវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១១ សូត្រ

# ចប់ទុតិយបណ្ណាសកៈ

# តតិយបណ្ណាសកៈ

## សម្ពោធិវគ្គទី ១

## អដ្ឋកថា បុព្វេសម្ពោធសុត្រទី ១

*“ហេតុឲ្យប្រាថ្នាថា ជាអ្នកត្រាស់ដឹង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុព្វេសម្ពោធសូត្រទី ១ ដូចតទៅនេះ ៖*

[១០៥] *បទថា* ***បុព្វេ វសម្ពោធា*** *(មុនត្រាស់ដឹង) បានដល់ កាលមុននឹងត្រាស់ដឹង លោកអធិប្បាយទុកថា ក្នុងវេលាដទៃ (មុន) ព្រះអរិយមគ្គកើតឡើងនុ៎ះឯង ។ បទថា* ***អនភិសម្ពុទ្ធស្ស*** *(មិនទាន់បានអភិសម្ពុទ្ធៈ) បានដល់មិនទាន់ត្រាស់ដឹងអរិយសច្ច ៤ ។ បទថា* ***ពោធិសត្តស្សេវ សតោ*** *(ជាពោធិសត្វ) សេចក្ដីថា កាល (យើង) សត្វដែលនឹងត្រាស់ដឹងនុ៎ះឯង គឺ អ្នកផ្ដើមដើម្បីនឹងត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ឬថា កាល (យើង) ជាអ្នកនៅជាប់ជំពាក់ក្នុងព្រះពោធិញ្ញាណ ។ ពិតហើយ ព្រះតថាគត សម្រេចអភិនិហារដោយការប្រមូលធម៌ ៨ ប្រការ ទៀបបាទមូលរបស់ព្រះមានព្រះភាគព្រះនាមថា* ***ទីបង្ករ*** *ជាអ្នកជាប់ គឺ ជាប់ជំពាក់នៅក្នុងពោធិញ្ញាណ ទ្រង់ត្រិះរិះថា យើងត្រូវសម្រេចព្រះពោធិញ្ញាណនេះ ហើយទ្រង់មិនលះសេចក្ដីព្យាយាមដើម្បីសម្រេចព្រះពោ-*

ពិញ្ញាណទាំងឯង ស្ដេចមកហើយ ព្រោះដូច្នោះ ទើបហៅថា ព្រះពោធិសត្វ ។

បទថា **កោ នុ ខោ** គឺ **កតមោ នុ ខោ** (អ្វីហ្ន៎) ។ សង្ខារលោក ឈ្មោះថា **លោក** ។ បទថា **អស្សាទោ** បានដល់ អាការរីករាយ ។ បទថា **អាទីនវោ** បានដល់ អាការមិនគួររីករាយ ។ បទថា **តស្ស មយ្ហំ** (តថាគតនោះ) សេចក្ដីថា កាលតថាគតនោះ គឺ ជាអ្នកជាប់ជំពាក់នៅក្នុងព្រះពោធិញ្ញាណយ៉ាងនេះ នោះឯង ។ បទថា **ឆន្ទរាគបដិវិនយោ ឆន្ទរាគប្បហានំ** (ការកម្ចាត់ឆន្ទរាគៈចេញបាន ការលះឆន្ទរាគៈចេញបាន) សេចក្ដីថា ព្រោះថា ឆន្ទរាគៈដល់នូវការប្រាសទៅ គឺ លះបាន ព្រោះប្រារព្ធ គឺ អាស្រ័យព្រះនិព្វាន ព្រោះដូច្នោះ ព្រះនិព្វាន លោកទើបហៅថា **ការកម្ចាត់ឆន្ទរាគៈចេញបាន ការលះឆន្ទរាគៈចេញបាន** ។ បទថា **ឥទំ លោកនិស្សរណំ** (នេះជានិស្សរណៈក្នុងលោក) សេចក្ដីថា ព្រះនិព្វាននេះ លោកហៅថា **លោកនិស្សរណំ** (ជាដែនស្ទុះចេញចាកលោក) ព្រោះរលាស់ចេញចាកលោកហើយ ។ បទថា **យាវកីវំ** (ដ៏រាបណា) សេចក្ដីថា អស់កាលមានប្រមាណប៉ុនណា ។ បទថា **អព្ភញ្ញាសឹ** (បានដឹងច្បាស់) សេចក្ដីថា បានដឹងហើយ ដោយអរិយមគ្គញាណដ៏ប្រសើរក្រៃលែង ។ សូម្បីដោយបទទាំងពីរនេះថា **ញាណញ្ច បន មេ ទស្សនំ** ព្រះមានព្រះភាគត្រាស់សំដៅដល់បច្ចវេក្ខ-ណញ្ញាណ ។ បទដ៏សេសក្នុងព្រះសូត្រនេះងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា បុព្វេវសម្ពោធសូត្រទី ១

# អដ្ឋកថា មនុស្សសូត្រទី ២[១]

## *“ហេតុឲ្យប្បជ្ជាថា ជាអ្នកត្រាស់ដឹង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មនុស្សសូត្រទី ២ ដូចតទៅនេះ ៖*

[១០៦] *បទថា* ***អស្សាទបរិយេសនំ អាចរឹ*** *(បានស្វែងរកអានិសង្ស) សេចក្ដីថា បានត្រាច់ទៅ ដើម្បីប្រយោជន៍ដល់ការស្វែងរកអស្សាទៈ ។ សួរថា បានត្រាច់ទៅ ចាប់ផ្ដើមពីពេលណា ។ ឆ្លើយថា បានត្រាច់ទៅ តាំងពីជាសុមេធតាបស ។ បទថា* ***បញ្ញាយ*** *(ដោយបញ្ញា) បានដល់ មគ្គប្បញ្ញាព្រមទាំងវិបស្សនា ។ បទថា* ***សុទិដ្ឋោ*** *(បានឃើញយ៉ាងល្អ) បានដល់ ត្រាស់ដឹងហើយដោយល្អ ។ គប្បីជ្រាបសេចក្ដីក្នុងគ្រប់ៗ បទ ដោយឧបាយនេះ ។*

ចប់អដ្ឋកថា មនុស្សសូត្រទី ២

---

*(១) អដ្ឋកថា = បឋមអស្សាទសូត្រ ។*

# អដ្ឋកថា អស្សាទសូត្រទី ៣

*"ហេតុឲ្យរួចផុតចាកលោក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អស្សាទសូត្រទី ៣ ដូចតទៅនេះ ៖*

[១០៧] *សេចក្តីក្នុងបទទាំងពួង ក្នុងសូត្រទី ៣ ងាយទាំងអស់ ។*

ចប់អដ្ឋកថា អស្សាទសូត្រទី ៣

# អដ្ឋកថា សមណសូត្រទី ៤

*“បុគ្គលគួរសរសើរជាសមណៈ និងព្រាហ្មណ៍”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមណសូត្រទី ៤ ដូចតទៅនេះ ៖*

[១០៨] *បទថា* ***សាមញ្ញត្ថំ*** *(ប្រយោជន៍នៃភាពជាសមណៈ) បានដល់ អរិយផលទាំង ៤ យ៉ាង ។ បទក្រៅពីនេះ (ប្រយោជន៍នៃភាពជាព្រាហ្មណ៍) ជាវេវចនៈរបស់បទថា ប្រយោជន៍នៃភាពជាសមណៈ នោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា មគ្គ ៤ ព្រោះអត្ថថា ភាពជាសមណៈ , ឈ្មោះថា ផល ៤ ព្រោះអត្ថថា ភាពជាព្រាហ្មណ៍ ។ ក៏ក្នុងព្រះសូត្រទាំង ៤ នេះ ព្រះមានព្រះភាគត្រាស់ដល់ខន្ធលោកតែម្យ៉ាង ។*

ចប់អដ្ឋកថា សមណសូត្រទី ៤

# អដ្ឋកថា រោណសូត្រទី ៥(១)

## *"ការរីករាយ និងការសើចក្នុងធម៌"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មនុស្សសូត្រទី ២ ដូចតទៅនេះ ៖*

[១០៩] *សូត្រទី ៥ ខ្ញុំនឹងលើករឿងឡើងសម្តែងតាមអត្ថុប្បត្តិ (រឿងដែលកើតឡើង) ។ សួរថា រឿងកើតឡើងដូចម្តេច ។ ឆ្លើយថា រឿងកើតឡើងព្រោះអនាចារ (ការប្រព្រឹត្តក្រៅប្រពៃណី ក្រៅគំនូស) របស់ភិក្ខុឆព្វគ្គិយទាំងឡាយ ។ ដំណាលមកថា ភិក្ខុឆព្វគ្គិយទាំងនោះ ច្រៀង រាំ សើច គ្រាប់ទៅ ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលព្រះទសពល ព្រះបរមសាស្តាត្រាស់ហៅភិក្ខុឆព្វគ្គិយទាំងនោះមក ហើយទ្រង់ប្រារព្ធព្រះសូត្រនេះ ពុទ្ធបំណងនឹងទ្រង់ប្រៀនប្រដៅភិក្ខុទាំងនោះ ។*

*បណ្តាបទទាំងនោះ បទថា* ***រុណ្ណំ*** *បានដល់ ការយំ (រោហិតំ) ។ បទថា* ***ឧម្មត្តកំ*** *បានដល់ កិរិយារបស់អ្នកឆ្កួត ។ បទថា* ***កោមារិកំ*** *(ភាពនៅក្មេង) បានដល់ រឿងដែលក្មេងៗ នឹងត្រូវធ្វើ ។ បទថា* ***ទន្តវិទំសកហសិតំ*** *(ការសើចរហូតឃើញធ្មេញ) បានដល់ ការសើចដោយសំឡេងក្អាកក្អាយ ទះដៃ ។ ដោយបទថា* ***សេតុឃាតោ គីតេ*** *(កាត់បច្ច័យក្នុងការច្រៀង) ព្រះមានព្រះភាគទ្រង់*

---

*(១) អដ្ឋកថា = រុណសូត្រ ។*

សម្តែងថា អ្នកទាំងឡាយចូរកាត់បច្ច័យក្នុងការច្រៀង ចូរលះបង់ការច្រៀង ព្រមទាំងហេតុ ។ សូម្បីក្នុងការរាំ ក៏មានន័យនេះដូចគ្នា ។

បទថា **អលំ** បានដល់ គួរហើយ ។ ហេតុ ត្រាស់ហៅថា ធម៌ ក្នុងបទនេះថា **ធម្មប្បមោទិតានំ សតំ** (កាលអ្នកទាំងឡាយមានហេតុដែលឲ្យកើតសេចក្តីរីករាយ) កាលអ្នកទាំងឡាយរីករាយហើយ ដោយហេតុណាមួយ ។ បទថា **សិតំ សិតមត្តាយ** (ត្រឹមតែញញឹម) មានពាក្យអធិប្បាយថា កាលមានហេតុដែលត្រូវសើច ការសើចដែលពួកអ្នកនឹងធ្វើបាននោះ សម្រាប់ពួកអ្នក គួរត្រឹមតែញញឹម គឺ ដើម្បីសម្តែងត្រឹមតែអាការញញឹមឲ្យឃើញធ្មេញប៉ុណ្ណោះ ។

ចប់អដ្ឋកថា ភោណាសូត្រទី ៥

# អដ្ឋកថា អត្ថិតសូត្រទី ៦

## *"វត្ថុដែលសេពមិនចេះឆ្អែត ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អត្ថិតសូត្រទី ៦ ដូចតទៅនេះ ៖*

[១១០] *បទថា **សុប្បស្ស** (ការដេក) បានដល់ ការលក់ (និទ្រា) ។ បទថា **បដិសេវនាយ នត្ថិ តិត្តិ** (ការឆ្អែតក្នុងការសេព... មិនមាន) សេចក្តីថា នឹងសេពទៅប៉ុនណាៗ ក៏នៅពេញចិត្តប៉ុណ្ណោះៗ ព្រោះដូច្នោះ ដែលឈ្មោះថា ការឆ្អែត ទើបមិនទាន់មាន ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។ ក៏ប្រសិនបើទឹកក្នុងមហាសមុទ្រនឹងក្លាយជាសុរា និងអ្នកលេងសុរានឹងកើតជាត្រី កាលគេស្រេកឃ្លានហើយក្តី ដេកហើយក្តី ក្នុងទឹកនោះ ឈ្មោះថា ការឆ្អែតក៏មិនគប្បីមាន ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់វដ្តៈតែម្យ៉ាង ។*

ចប់អដ្ឋកថា អត្ថិតសូត្រទី ៦

# អដ្ឋកថា បឋមកូដសូត្រទី ៧

*"កម្មដែលកើតពីការរក្សា និងមិនរក្សាចិត្ត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកូដសូត្រទី ៧ ដូចតទៅនេះ ៖*

[១១១] *បទថា* ***អវស្សុតំ ហោតិ*** *បានដល់ ជោក (តិន្តំ ហោតិ) ។ បទថា* ***ន ភទ្ទកំ មរណំ ហោតិ*** *(រមែងមិនមានការស្លាប់ដោយល្អ) សេចក្តីថា ការស្លាប់ដោយល្អ អ្នកក៏មិនបាន ព្រោះកម្មទាំង ៣ ជាបច្ច័យនៃបដិសន្ធិក្នុងអបាយ ។ បទថា* ***កាលកិរិយា*** *ជាវេវចនៈរបស់បទថា* ***មរណំ*** *នុ៎ះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ចំណែកកុសលបក្ខ (ធម៌ចំណែកស) ដូចតទៅនេះ ។ ការស្លាប់ដោយល្អអ្នកបានហើយ ព្រោះកម្មទាំង ៣ ជាបច្ច័យនៃបដិសន្ធិក្នុងសួគ៌ តែការស្លាប់នោះ បានចំពោះព្រះអរិយសាវកទាំងឡាយ ៣ ពួក មានព្រះសោតាបន្នជាដើម តែម្យ៉ាងប៉ុណ្ណោះ ។ បទដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា បឋមកូដសូត្រទី ៧

---

*(១) អដ្ឋកថា = អរក្ខិតសូត្រ ។*

# អដ្ឋកថា ទុតិយកូដសូត្រទី ៨[(១)]

## *“កម្មវិនាស និងមិនវិនាសព្រោះចិត្ត”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយកូដសូត្រទី ៨ ដូចតទៅនេះ ៖*

[១១២] *បទថា* ***ព្យាបន្នំ*** *(វិនាស) បានដល់ ចិត្តដែលលះប្រក្រតីភាព ហើយតាំងនៅ ។ បទដ៏សេសមានន័យដូចពោលហើយក្នុងសូត្រមុនន៉ុះឯង ។*

ចប់អដ្ឋកថា ទុតិយកូដសូត្រទី ៨

*(១) អដ្ឋកថា = ព្យាបន្នសូត្រ ។*

# អដ្ឋកថា បឋមនិទានសូត្រទី ៩

## *“ហេតុឲ្យកើតកម្ម”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមនិទានសូត្រទី ៩ ដូចតទៅនេះ ៖*

*[១១៣] បទថា **និទានានិ** បានដល់ ហេតុ (ការណានិ) ។ បទថា **កម្មានំ សមុទយាយ** (ដើម្បីការកើតឡើងនៃកម្មទាំងឡាយ) សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការប្រមូលមកនូវកម្មដែលជាវដ្ដគាមិនី (កម្មដែលធ្វើឲ្យសត្វវិលវល់ស្លាប់កើត) ។ បទថា **លោភបកតំ** (ត្រូវលោភៈបង្គាប់) សេចក្ដីថា ធ្វើដោយសេចក្ដីលោភ ។ បទថា **សាវជ្ជំ** (មានទោស) បានដល់ ប្រព្រឹត្តទៅជាមួយទោស ។ បទថា **តំ កម្មំ កម្មសមុទយាយ សំវត្តតិ** (កម្មនោះប្រព្រឹត្តទៅដើម្បីការកើតនៃកម្ម) សេចក្ដីថា កម្មនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការប្រមូលនូវកម្មសមុទ័យ (ហេតុដែលឲ្យកើតកម្ម) សូម្បីពួកដទៃដែលជាវដ្ដគាមិនី ។ បទថា **ន តំ កម្មំ កម្មនិរោធាយ** (កម្មនោះប្រព្រឹត្តទៅដើម្បីការរលត់នៃកម្ម) សេចក្ដីថា តែកម្មនោះមិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការរលត់វដ្ដគាមិនីកម្ម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មចំណែកសដូចតទៅនេះ ។ បទថា **កម្មានំ សមុទយាយ** (ដើម្បីការកើតឡើងនៃកម្ម) សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការកើតឡើងនៃវដ្ដគាមិនីកម្ម ។ បទទាំងពួងគប្បីជ្រាបសេចក្ដីដោយន័យនេះ ។*

ចប់អដ្ឋកថា បឋមនិទានសូត្រទី ៩

# អដ្ឋកថា ទុតិយនិទានសូត្រទី ១០

## *"ហេតុឲ្យកើតកម្ម"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយនិទានសូត្រទី ១០ ដូចតទៅនេះ ៖*

[១១៤] *បទថា* **កម្មានំ** *(នៃកម្មទាំងឡាយ) បានដល់ កម្មដែលជាហេតុនាំទៅកាន់វដ្តៈទុំ:ឯង ។ បទថា* **ឆន្ទរាគដ្ឋានិយេ** *(ដែលជាឋានៈនៃឆន្ទរាគៈ) សេចក្តីថា ជាហេតុនៃឆន្ទរាគៈ ។ បទថា* **អារព្ភ** *(ប្រារព្ធ) បានដល់ អាស្រ័យ គឺ សំដៅយក បានដល់ ចោះចំពោះ ។ បទថា* **ឆន្ទោ** *(សេចក្តីពេញចិត្ត) បានដល់ សេចក្តីពេញចិត្តដោយអំណាចតណ្ហា ។ បទថា* **យោ ចេតសោ សារាគោ** *(តម្រេកនៃចិត្ត) សេចក្តីថា តម្រេក សេចក្តីត្រេកអរនៃចិត្ត សេចក្តីដែលចិត្តត្រេកត្រអាលហើយ យ៉ាងណា សេចក្តីតម្រេកនៃចិត្តនេះ តថាគតពោលថា ជាសញ្ញោជនៈ គឺ ជាគ្រឿងចង ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មចំណែកស ដូចតទៅនេះ បទថា* **កម្មានំ** *(នៃកម្មទាំងឡាយ) បានដល់ កម្មដែលជាហេតុនាំទៅកាន់វិវដ្តៈ ។ បទថា* **តទភិនិវជ្ជេតិ** *(ត្រឡប់ធម៌នោះចេញ) សេចក្តីថា ឲ្យធម៌ដែលជាទីតាំងនៃរាគៈជាដើម និងវិបាករបស់ធម៌នោះវិលត្រឡប់ គឺថា កាលណាគេដឹង គឺ យល់វិបាក ដែលជាទីតាំង (នៃឆន្ទរាគៈជាដើម) កាលនោះ គេនឹងញុំាងធម៌ទាំងនោះផង វិបាកនោះផង ឲ្យ*

*វិលត្រឡប់ ។ មួយទៀត ដោយបទនេះ ព្រះអង្គត្រាស់វិបស្សនាទុកហើយ ។ ដោយបទថា* ***តទភិនិវជ្ជេត្វា*** *(លុះត្រឡប់ចមិនោះបានហើយ) នេះ ទ្រង់ត្រាស់ដល់មគ្គទុក ។ តែដោយបទថា* ***ចេតសា អភិវិវាជេត្វា*** *(ប្រាសចេញអំពីចិត្ត) នេះ ទ្រង់ត្រាស់ដល់មគ្គតែម្យ៉ាង ។ បទថា* ***បញ្ញាយ អតិវិជ្ឈ បស្សតិ*** *(ឃើញច្បាស់ចាក់ធ្លុះដោយបញ្ញា) សេចក្តីថា ឃើញច្បាស់ ចាក់ធ្លុះដោយមគ្គប្បញ្ញា ព្រមទាំងវិបស្សនា ។ ក្នុងគ្រប់ៗ បទ គប្បីជ្រាបសេចក្តីយ៉ាងនេះ ។ ក៏ក្នុងព្រះសូត្រនេះ ត្រាស់ទុកទាំងវដ្តៈ និងវិវដ្តៈដូច្នេះឯង ។*

ចប់ទុតិយនិទាន សូត្រទី ១០

**ចប់សម្ពោធិវគ្គទី ១**

ក្នុងវគ្គនេះ មាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# អាបាយិកវគ្គទី ២

## អដ្ឋកថា អាបាយិកសូត្រទី ១

*"បុគ្គល ៣ ពួក ដែលត្រូវទៅអបាយភូមិ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាបាយិកសូត្រទី ១ ដូចតទៅនេះ ៖*

[១១៥] *សត្វទាំងឡាយ ឈ្មោះថា* ***អាបាយិកា*** *ព្រោះនឹងត្រូវទៅកាន់អបាយ ។ សត្វទាំងឡាយ ឈ្មោះថា* ***នេរយិកា*** *ព្រោះនឹងត្រូវទៅកាន់នរក ។ បទថា* ***ឥទមប្បហាយ*** *(មិនលះកម្មអាក្រក់ទាំង ៣) នេះ សេចក្តីថា មិនលះកម្មអាក្រក់ទាំង ៣ មានការប្តេជ្ញាខ្លួនថា ជាព្រហ្មចារី ជាដើម ។ បទថា* ***ព្រហ្មចារិប្បដិញ្ញោ*** *(ប្តេជ្ញាខ្លួនថាជាព្រហ្មចារី) បានដល់ អ្នកប្រព្រឹត្តព្រហ្មចារីក្លែងក្លាយ ។ម្យ៉ាងទៀត បានដល់ អ្នកប្តេជ្ញាយ៉ាងនេះថា សូម្បីយើងក៏ជាព្រហ្មចារីដោយមិនលះអាកប្បកិរិយារបស់ពួកគេ ។ បទថា* ***អនុទ្ធំសេតិ*** *(កម្ចាត់) សេចក្តីថា ជេរ គឺ បរិភាស បានដល់ តិះដៀល ។ បទថា* ***នត្ថិ កាមេសុ ទោសោ*** *(ទោសក្នុងកាមទាំងឡាយ មិនមាន) សេចក្តីថា បុគ្គលសេពកិលេសកាម និងវត្ថុកាម មិនមានទោស ។ បទថា* ***បាតព្យតំ*** *(ស្រេកឃ្លានក្នុងកាម) សេចក្តីថា ដល់នូវភាពជាបុគ្គលនឹងត្រូវផឹក គឺ ភាពជាបុគ្គលនឹងត្រូវបរិភោគ បានដល់ ភាព*

ជាបុគ្គលទីងត្រូវផឹកស៊ី ដូចការផឹកទឹករបស់អ្នកស្រេកទឹក ដោយចិត្តប្រាសចាកសេចក្តីរង្កៀស ។ ក្នុងព្រះសូត្រនេះ ត្រាស់វដ្តៈទុកតែម្យ៉ាង ។

ចប់អដ្ឋកថា អាចាយិសូត្រទី ១

# អដ្ឋកថា ទុល្លភសូត្រទី ២

## *“បុគ្គលក្រ ៣ ពួក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុល្លភសូត្រទី ២ ដូចតទៅនេះ ៖*

[១១៦] *បទថា* ***កតញ្ញូ កតវេទី*** *(បុគ្គលកតញ្ញូកតវេទី) បានដល់ បុគ្គលដឹងកម្មដែលគេធ្វើហើយ (ដល់ខ្លួន) ថា បុគ្គលនេះធ្វើគុណដល់យើង ដូច្នេះ ហើយធ្វើការតបឲ្យបុគ្គលដទៃដឹង គឺ ឲ្យប្រាកដ ។*

ចប់អដ្ឋកថា ទុល្លភសូត្រទី ២

# អដ្ឋកថា អប្បមេយ្យសូត្រទី ៣

## *"បុគ្គល ៣ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បមេយ្យសូត្រទី ៣ ដូចតទៅនេះ ៖*

[១១៧] *បុគ្គល ឈ្មោះថា* ***ប្រមាណបានងាយ*** *ព្រោះត្រូវប្រមាណបានដោយងាយ ។ ឈ្មោះថា* ***ប្រមាណបានលំបាក*** *ព្រោះត្រូវប្រមាណបានដោយលំបាក ។ ឈ្មោះថា* ***ប្រមាណមិនបាន*** *ព្រោះមិនអាចប្រមាណបាន ។ បទថា* ***ឧន្នឡា*** *(ធ្មើងធ្មៃ) បានដល់ បុគ្គលដូចជាឈើបបុសដែលបះឡើង អធិប្បាយថា លើកមានះដែលទទេឡើងតាំងទុក ។ បទថា* ***ចបលា*** *(រពើតរពើង) បានដល់ បុគ្គលប្រកបដោយសេចក្ដីវង្វេង មានការតាក់តែងបាត្រជាដើម ។ បទថា* ***មុខរា*** *(មាត់រឹង) បានដល់ បុគ្គលមាត់រឹង ។ បទថា* ***វិកិណ្ណវាចា*** *(និយាយប៉ប៉ាច់ប៉ប៉ោច) បានដល់ អ្នកមិនសង្រួមពាក្យសំដី ។ បទថា* ***អសមាហិតា*** *(ភ្លេចស្មារតី) បានដល់ អ្នកមិនមានចិត្តជាសមាធិ ។ បទថា* ***វិព្ភន្តចិត្តា*** *(មានចិត្តមិននឹងធឹង) បានដល់ បុគ្គលមានចិត្តឆ្វេងឆ្វាប្រៀបដូចម្រឹគផ្អើលព្រៃ ។ បទថា* ***បាកតិន្ទ្រិយា*** *(មិនសង្រួមឥន្ទ្រិយ៍) បានដល់ មិនរក្សាឥន្ទ្រិយ៍ ។ បទដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា អប្បមេយ្យសូត្រទី ៣

# អដ្ឋកថា អានេញ្ជសូត្រទី ៤

## "បុគ្គលចម្រើនអរូបជ្ឈាន ៣ ពួក"

*គប្បីជ្រាបវិនិច្ឆ័យក្នុង អានេញ្ជសូត្រទី ៤ ដូចតទៅនេះ ៖*

*[១១៨] បទថា **តទស្សាទេតិ** (ត្រេកអរក្នុងឈាននោះ) បានដល់ ពេញចិត្តឈាននោះ ។ បទថា **តំ និកាមេតិ** (ជាប់ចិត្តក្នុងឈាននោះ) បានដល់ ប្រាថ្នាឈាននោះឯង ។ បទថា **តេន ច វិត្តឹ អាបជ្ជតិ** (ដល់ការឆ្អែតដោយឈាននោះ) បានដល់ ដល់សេចក្ដីត្រេកអរដោយឈាននោះ ។ បទថា **តត្ថ ឋិតោ** (ស្ថិតនៅក្នុងឈាននោះ) បានដល់ តាំងនៅក្នុងឈាននោះ ។ បទថា **តទធិមុត្តោ** (បង្អោនទៅក្នុងឈាន) បានដល់ បង្អោនចិត្តទៅក្នុងឈាននោះឯង ។ បទថា **តព្ពហុលវិហារី** (ច្រើនដោយឈាននោះឯង) បានដល់ នៅជាមួយឈាននោះដោយចំណែកច្រើន ។ បទថា **សហព្យតំ ឧបបជ្ជតិ** (រមែងចូលដល់ភាពជាសំឡាញ់) បានដល់ ចូលដល់ភាពជាសំឡាញ់ អធិប្បាយថា រមែងកើតក្នុងទេវលោកនោះ ។*

*ពាក្យមានជាអាទិ៍ថា **និរយម្បិ គច្ឆតិ** (ទៅនរកក៏បាន) ព្រះមានព្រះភាគត្រាស់សំដៅដល់ការទៅនរកនោះ ដោយអំណាចនៃបរិយាយដទៃ ព្រោះមិនផុតពីនរកជាដើមទៅបាន ។ ព្រោះថា គេមិនមានអកុសលកម្មដែលមានកម្លាំងច្រើនជាងឧបចារឈាន ដែលជាហេតុឲ្យកើតក្នុងអបាយជាប់តគ្នា ។ បទថា **ភគវតោ***

បទ *សាវកោ* (សាវករបស់ព្រះមានព្រះភាគ) បានដល់ ព្រះសាវកអង្គណាមួយ បណ្ដាព្រះសាវកដែលជាព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីទាំងឡាយ ។ បទថា **តស្មឹយេវ ភវេ** (ក្នុងភពនោះៗ ឯង) បានដល់ ក្នុងអរូបភពនុ៎ះឯង ។ បទថា **បរិនិព្វាយតិ** (រមែងបរិនិព្វាន) សេចក្ដីថា រមែងបរិនិព្វាន ដោយបរិនិព្វានដែលរកបច្ច័យមិនបាន ។ សេចក្ដីព្យាយាមជាគ្រឿងប្រកបយ៉ាងក្រៃលែង ឈ្មោះថា **សេចក្ដីប្រែកគ្នា** ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ គប្បីជ្រាបតាមន័យដែលពោលមកហើយនុ៎ះឯង ។ មួយទៀត ក្នុងព្រះសូត្រនេះ ឈានដែលនឹងជាហេតុឲ្យឧប្បត្តិ ព្រះមានព្រះភាគត្រាស់ទុកសម្រាប់បុថុជ្ជន សម្រាប់ព្រះអរិយសាវក ត្រាស់ទាំងឈានដែលជាហេតុឲ្យឧប្បត្តិនុ៎ះឯង ទាំងឈានដែលជាបាទនៃវិបស្សនាផង ។

ចប់អដ្ឋកថា អានេញ្ជសូត្រទី ៤

# អដ្ឋកថា អយសូត្រទី ៥

## *“វិបត្តិ ៣ និងសម្បទា ៣”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អយសូត្រទី ៥ ដូចតទៅនេះ ៖*

[១១៩] *បទថា* ***សីលវិបត្តិ*** *បានដល់ អាការដែលសីលវិនាស ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។ ដោយបទថា* ***នត្ថិ ទិន្នំ*** *(ទានដែលឲ្យហើយមិនមានផល) ព្រះមានព្រះភាគត្រាស់សំដៅយកទានដែលឲ្យហើយមិនមានផល ។ ការបូជាធំ ហៅថា* ***យិដ្ឋះ*** *។ លាភសក្ការៈដែលល្មមប្រមាណ ទ្រង់បំណងយកថា* ***ហុតះ*** *។ មិច្ឆាទិដ្ឋិកបុគ្គល ហាម* ***យិដ្ឋះ*** *និង* ***ហុតះ*** *ទាំងពីរនោះថា មិនមានផលឡើយ ។ បទថា* ***សុកដទុក្កដានំ*** *(ដែលធ្វើល្អ និងធ្វើអាក្រក់) បានដល់ (ផលវិបាករបស់កម្ម) ដែលធ្វើល្អ និងធ្វើអាក្រក់ អធិប្បាយថា របស់កុសលកម្ម និងអកុសលកម្ម ។ ដោយបទថា* ***ផលវិបាកោ*** *(ផលវិបាក) មិច្ឆាទិដ្ឋិកបុគ្គល ពោលវត្ថុដែលហៅថា ផល ឬវិបាក ថាមិនមាន ។*

*បទថា* ***នត្ថិ អយំ លោកោ*** *(លោកនេះមិនមាន) សេចក្តីថា លោកនេះមិនមានសម្រាប់អ្នកដែលតាំងនៅក្នុងលោកខាងមុខ ។ បទថា* ***នត្ថិ បរោ លោកោ*** *(លោកដទៃមិនមាន) សេចក្តីថា លោកខាងមុខមិនមាន សូម្បីសម្រាប់អ្នកតាំងនៅក្នុងលោកនេះ ។ មិច្ឆាទិដ្ឋិកបុគ្គល សម្តែងថា សត្វទាំងអស់ (ស្លាប់ហើយ) រមែង*

ដាច់សូន្យក្នុងលោកនោះៗ ទុំះឯង ។ ដោយបទថា **នត្ថិ មាតា នត្ថិ បិតា** (មាតាមិនមាន បិតាមិនមាន) មិច្ឆាទិដ្ឋិកបុគ្គល ពោលដោយអំណាចនៃការបដិបត្តិត្រូវនិងការបដិបត្តិខុសក្នុងមាតា បិតា ទាំងនោះថា មិនមានផល ។ បទថា **នត្ថិ សត្តា ឱបបាតិកា** (សត្វជាឱបបាតិកៈមិនមាន) សេចក្តីថា ដែលឈ្មោះថា សត្វដែលចុតិហើយកើតមិនមាន ។ សេចក្តីបរិបូរណ៍ ឈ្មោះថា **សម្បទា** ។ សីលបរិបូរណ៍មិនខ្វះខាត ឈ្មោះថា **សីលសម្បទា** ។ សូម្បីក្នុងបទទាំងពីរដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **អត្ថិ ទិន្នំ** (ទានឲ្យហើយមានផល) ជាដើមអ្នកសិក្សាគប្បីកាន់យកដោយន័យដែលផ្ទុយនឹងដែលពោលមកហើយចុះ ។

ចប់អដ្ឋកថា អយសូត្រទី ៥

# អដ្ឋកថា អបណ្ណកសូត្រទី ៦

## *"វិបត្តិ ៣ និងសម្បទា ៣"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អបណ្ណកសូត្រទី ៦ ដូចតទៅនេះ ៖*

[១២០] *បទថា **អបណ្ណកោ មណិ** (កូនបាសកា) បានដល់ កូនបាសកាដែលប្រកបហើយដោយជ្រុង ៦ ។ បទថា **សុគតី សគ្គំ** (សុគតិ សួគ៌) បានដល់លោកសួគ៌ ក្នុងបណ្តាសួគ៌ ៦ ជាន់ មានជាន់ចាតុម្មហារាជិកាជាដើមណាមួយ ។*

*ក្នុងព្រះសូត្រនេះ ត្រាស់ធម៌ទាំងពីរប្រការ គឺ សីល និងសម្មាទិដ្ឋិលាយគ្នា ។*

ចប់អដ្ឋកថា អបណ្ណកសូត្រទី ៦

# អដ្ឋកថា កម្មន្តសូត្រទី ៧

## *“វិបត្តិ ៣ និងសម្បទា ៣”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កម្មន្តសូត្រទី ៧ ដូចតទៅនេះ ៖*

[១២១] *សូត្រទី ៧ មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា កម្មន្តសូត្រទី ៧

# អដ្ឋកថា បឋមសោចេយ្យសូត្រទី ៨

## “សេចក្តីស្អាត ៣ យ៉ាង”

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសោចេយ្យសូត្រទី ៨ ដូចតទៅនេះ ៖

[១២២] សេចក្តីស្អាត ឈ្មោះថា **សោចេយ្យ** ។ សេចក្តីស្អាតក្នុងកាយទ្វារ ឈ្មោះថា **កាយសោចេយ្យ** ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះឯង ។ ក៏ក្នុងព្រះសូត្រ ៤ សូត្រនេះ តាមលំដាប់ ព្រះមានព្រះភាគត្រាស់វត្តបដិបត្តិសម្រាប់អ្នកគ្រប់គ្រងផ្ទះ ។ សូម្បីព្រះអរិយបុគ្គលដែលជាសោតាបន្ន និងព្រះសកទាគាមី ក៏ប្រើបាន ។

ចប់អដ្ឋកថា បឋមសោចេយ្យសូត្រទី ៨

# អដ្ឋកថា ទុតិយសោចេយ្យសូត្រទី ៩

## "សេចក្តីស្អាត ៣ យ៉ាង"

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសោចេយ្យសូត្រទី ៩ ដូចតទៅនេះ ៖

[១២៣] បទថា **អជ្ឈត្តំ** (ខាងក្នុង) បានដល់ ដែលប្រព្រឹត្តទៅក្នុងខ្លួនឯង ។ នីវរណៈ គឺ កាមច្ឆន្ទៈ ឈ្មោះថា **កាមច្ឆន្ទៈ** ។ សូម្បីក្នុងនីវរណៈ មានព្យាបាទៈជាដើម ក៏មានន័យនេះដូចគ្នា ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ មានន័យដូចពោលហើយក្នុងកាលមុននុ៎ះឯង ។ ចំណែកក្នុងគាថា បទថា **កាយសុចឹ** (អ្នកស្អាតផ្លូវកាយ) បានដល់ អ្នកស្អាតក្នុងកាយទ្វារ ឬអ្នកស្អាតផ្លូវកាយ ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **និន្ហាតបាបកំ** (អ្នកលាងបាបហើយ) សេចក្តីថា អ្នកលាង គឺ ជម្រះបាបទាំងអស់ហើយតាំងនៅ ។ ទាំងព្រះសូត្រនេះ ទាំងព្រះគាថា ព្រះមានព្រះភាគត្រាស់ដល់ព្រះទីណាស្រេចតែម្យ៉ាង ដូច្នេះឯង ។

ចប់អដ្ឋកថា សោចេយ្យសូត្រទី ៩

# អដ្ឋកថា មោនេយ្យសូត្រទី ១០

## *"ភាពជាមុនី ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មោនេយ្យសូត្រទី ១០ ដូចតទៅនេះ ៖*

[១២៤] *ភាពជាមុនី ឈ្មោះថា* ***មោនេយ្យៈ*** *។ ភាពជាមុនី គឺ ភាពជាបុគ្គលល្អ បានដល់ ភាពជាបណ្ឌិត ក្នុងកាយទ្វារ ឈ្មោះថា* ***កាយមោនេយ្យៈ*** *។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា* ***ឥទំ វុច្ចតិ ភិក្ខវេ កាយមោនេយ្យំ*** *(ម្នាលភិក្ខុទាំងឡាយ នេះហៅថា កាយមោនេយ្យ) សេចក្តីថា ពិតហើយ ការលះកាយទុច្ចរិត ៣ យ៉ាងនេះ ឈ្មោះថា កាយមោនេយ្យៈ ។ មួយទៀត សូម្បីកាយសុចរិត ៣ យ៉ាង ក៏ឈ្មោះថា កាយមោនេយ្យៈ ។ ញាណដែលមានកាយជាអារម្មណ៍ ក៏ឈ្មោះថា កាយមោនេយ្យៈដូចគ្នា ។ ការកំណត់ដឹងកាយ ក៏ឈ្មោះថា កាយមោនេយ្យៈ ។ មគ្គដែលសហគតដោយបរិញ្ញា ក៏ឈ្មោះថា កាយមោនេយ្យៈ ។ ការលះឆន្ទរាគៈផ្ទៃកាយ ក៏ឈ្មោះថា កាយមោនេយ្យៈ ។ ការរលត់កាយសង្ខារ និងការចូលចតុត្ថជ្ឈាន ក៏ឈ្មោះថា កាយមោនេយ្យៈ ។ សូម្បីក្នុងវចីមោនេយ្យៈ ក៏មានន័យនេះដូចគ្នា ។*

*ចំណែកក្នុងវចីមោនេយ្យៈ និងមនោមោនេយ្យៈនេះ មានសេចក្តីផ្សេងគ្នាដូចតទៅនេះ ។ ក្នុងទីនោះ គប្បីជ្រាបការចូលទុតិយជ្ឈាន គឺ ការរលត់វចីសង្ខារ*

*ឈ្មោះថា វចីមោនេយ្យៈ ដូចការចូលចតុត្ថជ្ឈានក្នុងទីនេះ ។ លុះជ្រាបសេចក្តីក្នុងមនោមោនេយ្យៈ ដោយន័យសូម្បីនេះហើយ ក៏គួរជ្រាបការចូលសញ្ញាវេទយិតនិរោធ គឺ ការរលត់ចិត្តសង្ខារ ឈ្មោះថា មនោមោនេយ្យៈ ។*

*បទថា **កាយមុនឹ** (បុគ្គលមុនីផ្លូវកាយ) បានដល់ បណ្ឌិត គឺ បុគ្គលប្រសើរបំផុត បានដល់ បុគ្គលបរិសុទ្ធក្នុងកាយទ្វារ ឬបុគ្គលជាមុនីផ្លូវកាយ ។ សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សព្វប្បហាយិនំ** (បុគ្គលលះអាសវៈបានទាំងអស់) បានដល់ ព្រះខីណាស្រព ។ ព្រោះថា ព្រះខីណាស្រព ឈ្មោះថា បុគ្គលលះអាសវៈបានទាំងអស់ ដូច្នេះឯង ។*

ចប់អដ្ឋកថា មោនេយ្យសូត្រទី ១០

## ចប់អាចាយិកវគ្គទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# កុសិនារវគ្គទី ៣

## អដ្ឋកថា កុសិនារសូត្រទី ១

### *"បិណ្ឌបាត្រដែលមានផលច្រើន"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុសិនារសូត្រទី ១ ដូចតទៅនេះ ៖*

[១២៥] *បទថា* ***កុសិនារាយំ*** *(ជិតនគរកុសិនារា) បានដល់ ជិតព្រះនគរដែលមានឈ្មោះយ៉ាងនេះ ។ បទថា* ***ពលិហរណេ វនសណ្ឌេ*** *(ត្រង់ដងព្រៃឈ្មោះពលិហរណៈ) បានដល់ ក្នុងដងព្រៃដែលមានឈ្មោះយ៉ាងនេះ ។ បានឮថា មនុស្សទាំងឡាយនាំពលីកម្មទៅ ដើម្បីធ្វើពលីកម្មដល់ភូត ឯដងព្រៃនោះ ព្រោះដូច្នោះ ដងព្រៃនោះ ជនទាំងឡាយទើបហៅថា* ***ពលិហរណៈ*** *។ បទថា* ***អាកង្ខមានោ*** *(អ្នកចង់ទៅ) បានដល់ អ្នកប្រាថ្នាទៅ ។ បទថា* ***សហត្ថា*** *(ដោយដៃខ្លួន) បានដល់ ដោយដៃរបស់ខ្លួន (សហត្ថេន) ។ បទថា* ***សម្បវារេតិ*** *(ប្រពៃហើយ) សេចក្ដីថា ហាមដោយវាចាថា ល្មមហើយ ល្មមហើយ និងដោយការរាដៃ ។*

*បទថា* ***សាធុ វត មាយំ*** *(ល្អណាស់... នេះ (ចិញ្ចឹម) យើង សេចក្ដីថា ល្អណាស់ហ្ន៎ (គហបតី ឬបុត្រនៃគហបតី) នេះ ចិញ្ចឹមយើងឲ្យឆ្អែតស្កប់ស្កល់ ។ បទថា* ***គធិតោ*** *(ជាប់ចិត្ត) សេចក្ដីថា ជាប់ចិត្តដោយសេចក្ដីត្រេកអរ ព្រោះតណ្ហា ។*

បទថា **មុច្ឆិតោ** (វង្វេង) បានដល់ វង្វេងហើយដោយសេចក្ដីវង្វេង ព្រោះតណ្ហានុ៎ះឯង ។ បទថា **អជ្ឈោបន្នោ** (ជំពាក់ចិត្ត) សេចក្ដីថា លេបចូលទៅហើយដោយអំណាចនៃតណ្ហា ។ បទថា **អនិស្សរណបញ្ញោ** (មិនមានបញ្ញាជាគ្រឿងរលាស់ចេញ) សេចក្ដីថា ភិក្ខុដែលលះឆន្ទរាគៈហើយ ទើបឈ្មោះថា អ្នកមានបញ្ញាជាគ្រឿងរលាស់ចេញ ភិក្ខុនេះមិនដូច្នោះ គេនៅមានឆន្ទរាគៈឆាន់អាហារ ព្រោះដូច្នោះ ទើបឈ្មោះថា អ្នកមិនមានបញ្ញាជាគ្រឿងរលាស់ចេញ ។ ធម៌ចំណែកស បណ្ឌិតគប្បីជ្រាបដោយខុសពីបរិយាយដូចពោលហើយ ។ មួយទៀត ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះអង្គត្រាស់នេក្ខម្មវិតក្កៈជាដើមលាយគ្នា ដូច្នេះឯង ។

ចប់អដ្ឋកថា កុសិនារសូត្រទី ១

## អដ្ឋកថា ភណ្ឌនសូត្រទី ២

*"ហេតុនៃសេចក្តីប្រេះឆា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភណ្ឌនសូត្រទី ២ ដូចតទៅនេះ ៖*

[១២៦] *បទថា* ***បជហឹសុ*** *(លះ) ប្រែថា រមែងលះបង់ ។ បទថា* ***ពហុលមកំសុ*** *(ធ្វើឲ្យច្រើន) បានដល់ ធ្វើរឿយៗ។ សូម្បីក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់វិតក្កៈទាំង ៣ នេះ លាយគ្នា ។*

ចប់អដ្ឋកថា ភណ្ឌនសូត្រទី ២

# អដ្ឋកថា គោតមសូត្រទី ៣

## *“អាការដែលព្រះពុទ្ធទ្រង់សម្តែងធម៌”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង គោតមសូត្រទី ៣ ដូចតទៅនេះ ៖*

[**១២៧**] *បទថា* ***គោតមកេ*** *(គោតមចេតិយ៍) បានដល់ ក្នុងទីអាស្រ័យ (ទេវស្ថាន) របស់គោតមកយក្ខ ។ អធិប្បាយថា ក្នុងបឋមពោធិកាល ដោយច្រើន ព្រះតថាគតប្រថាប់នៅទេវាល័យប៉ុណ្ណោះ អស់វេលា ២០ វស្សាយ៉ាងនេះ គឺ គ្រាខ្លះនៅឯបាវាលចេតិយ គ្រាខ្លះនៅឯសារន្ទចេតិយ គ្រាខ្លះនៅឯពហុបុត្តចេតិយ គ្រាខ្លះនៅឯសត្តម្ពចេតិយ ។ តែក្នុងវេលានេះ ព្រះអង្គទ្រង់អាស្រ័យក្រុងវេសាលី ប្រថាប់នៅហើយក្នុងទេវស្ថានរបស់គោតមកយក្ខ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទើបពោលថា* ***គោតមកចេតិយ*** *ដូច្នេះ ។*

*បទថា* ***ឯតទវោច*** *(បានត្រាស់ព្រះធម៌ទេសនានេះ) នេះ សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ គឺ ព្រះសូត្រមានជាអាទិ៍ថា* ***តថាគតដឹងច្បាស់ហើយ*** *ដូច្នេះ ។*

*ក៏ក្នុងការកើតឡើងនៃសេចក្តី ព្រះសូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកហើយ ។ សួរថា ក្នុងការកើតឡើងនៃសេចក្តីដូចម្តេច ។ ឆ្លើយថា ក្នុងការកើតឡើងនៃសេចក្តីក្នុងមូលបរិយាយសូត្រ ។*

បានជ្រាបថា ព្រាហ្មណ៍បព្វជិតចំនួនច្រើន កើតសេចក្តីស្រវឹង ព្រោះអាស្រ័យព្រះពុទ្ធវចនៈដែលខ្លួនធ្លាប់រៀនហើយ មិនព្រមទៅកាន់សាលាស្តាប់ធម៌ ដោយគិតថា ព្រះសម្មាសម្ពុទ្ធកាលនឹងត្រាស់ ក៏ត្រាស់ពាក្យដែលពួកយើងដឹងហើយប៉ុណ្ណោះ មិនត្រាស់ពាក្យដែលពួកយើងមិនទាន់ដឹង ដូច្នេះ ។ ភិក្ខុទាំងឡាយក្រាបទូល (សេចក្តីនោះ) ដល់ព្រះតថាគត ។ ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុទាំងនោះមក ទ្រង់កាន់យកមុខប្បញ្ហា (ការទទួលពាក្យរបស់ភិក្ខុទាំងនោះ) ហើយទ្រង់សម្តែងមូលបរិយាយសូត្រ ភិក្ខុទាំងនោះមិនបានឃើញទីមកទីទៅ របស់ព្រះធម៌-ទេសនាឡើយ កាលមិនឃើញ ក៏នាំគ្នាគិតថា ព្រះសម្មាសម្ពុទ្ធគង់យល់ព្រះទ័យថាធម្មកថារបស់តថាគត រមែងនាំសត្វចេញទៅចាកទុក្ខ ទើបត្រាស់ព្រះធម៌ទេសនាដែលជំនាញពីព្រះឱសប៉ុណ្ណោះ ។ ព្រះសាស្តាទ្រង់ដឹងចិត្តរបស់ភិក្ខុទាំងនោះហើយ ទើបទ្រង់ផ្តើមព្រះសូត្រនេះ ។

បណ្តាបទទាំងនោះ បទថា **អភិញ្ញាយ** (ដឹងក្រៃលែង) សេចក្តីថា ដឹងគឺ ត្រាស់ដឹង បានដល់ ធ្វើឲ្យប្រចក្សថា ធម៌ទាំងនេះ គឺ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ អរិយសច្ច ៤ ហេតុ ៩ ផស្សៈ ៧ វេទនា ៧ ចេតនា ៧ សញ្ញា ៧ ចិត្ត ៧ ។ មួយទៀត អធិប្បាយថា ដឹង គឺ ត្រាស់ដឹង បានដល់ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះៗ ដោយន័យមានជាអាទិ៍ថា សតិប្បដ្ឋាន

៤ នេះ ដូច្នេះ ។ បទថា **សនិទានំ** (មានហេតុ) សេចក្តីថា តថាគតពោលធម៌ព្រមទាំងបច្ច័យនុ៎ះឯង មិនមែនមិនមានបច្ច័យ ។ បទថា **សប្បាដិហារិយំ** (មានបាដិហារ្យ) សេចក្តីថា តថាគតពោលធម៌មានបាដិហារ្យនុ៎ះឯង ព្រោះកម្ចាត់សត្រូវបាន មិនមែនមិនមានបាដិហារ្យ ។ បទថា **អលញ្ច បន វោ** (ក៏អ្នកទាំងឡាយ... គួរ) សេចក្តីថា ក៏អ្នកទាំងឡាយកាលរឭករឿយៗ... គួរនឹងត្រេកអរ ។ បទថា **តុដ្ឋិយា** (សេចក្តីត្រេកអរ) មានអធិប្បាយថា អ្នកទាំងឡាយគួររឭកដល់រឿយៗនូវរតនៈទាំង ៣ ដោយព្រះគុណថា ព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ គប្បីធ្វើសេចក្តីត្រេកអរ ដូច្នេះ សូម្បីក្នុងបទទាំងពីរដ៏សេសក៏មានន័យនេះឯង ។

បទថា **អកម្បិត្ថ** (បានញាប់ញ័រ) បានដល់ បានញាប់ញ័រហើយដោយអាការ ៦ យ៉ាង អធិប្បាយថា សេចក្តីញាប់ញ័រនៃប្រឹថពីបែបនេះ បានមានហើយត្រង់ពោធិមណ្ឌល បានឮថា កាលព្រះពោធិសត្វ ស្តេចឡើងកាន់ពោធិ-មណ្ឌលទិសខាងត្បូង ផ្នែកទិសខាងត្បូងខាងក្រោម ក៏ដូចជាចុះទៅដល់អវិចី-មហានរក , ទិសខាងជើង ក៏ដូចជានឹងលើកឡើងរហូតដល់ភវគ្គព្រហ្ម , ទិសខាងលិចខាងក្រោម ដូចជាចុះទៅដល់អវិចីមហានរក , ទិសខាងកើត ក៏ដូចជា

នឹងលើកឡើងរហូតដល់ភវគ្គព្រហ្ម , ទិសខាងជើងផ្នែកខាងក្រោម ក៏ដូចជាចុះទៅដល់អវិចីមហានរក , ទិសខាងត្បូង ក៏ដូចជានឹងលើកឡើងដល់ភវគ្គព្រហ្ម , ទិសខាងកើតខាងក្រោម ដូចជាចុះទៅដល់អវិចីមហានរក , ទិសខាងលិច ដូចជានឹងលើកឡើងដល់ភវគ្គព្រហ្ម ។ សូម្បីពោធិព្រឹក្សខាងក្រោម ក៏ដូចជាលិចចុះទៅដល់អវិចីមហានរកគ្រាតែមួយ (ផ្នែកខាងលើ) ដូចជាផ្សាយឡើងទៅរហូតដល់ភវគ្គព្រហ្មគ្រាតែមួយ ។ សូម្បីក្នុងថ្ងៃនោះ មហាប្រឹថពី ១.០០០ ចក្រវាឡ បានញាប់ញ័រហើយ ដោយអាការ ៦ យ៉ាង ដូចពណ៌នាមកដូច្នេះ ។

ចប់អដ្ឋកថា គោតមសូត្រទី ៣

# អដ្ឋកថា ករណ្ឌុសូត្រទី ៤

## *"សាស្តា ៣ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ករណ្ឌុសូត្រទី ៤ ដូចតទៅនេះ ៖*

[១២៨] *បទថា **កេវលកប្បំ** (គ្រប់ចំណែក) បានដល់ ជុំវិញទាំងអស់ ។ បទថា **អហិណ្ឌន្តោ** (យាង) បានដល់ ស្តេចយាងទៅ ។ បទថា **ន អទ្ទសា** (ទ្រង់មិនឃើញ) សេចក្តីថា ព្រោះហេតុអ្វី សក្យមហានាម ទើបទ្រង់មិនឃើញ ។ បានឮថា ករណ្ឌុកាលាមតាបសនេះ ត្រាច់ទៅសូមចង្ហាន់បិណ្ឌបាតដ៏ប្រសើររបស់សក្យរាជទាំងឡាយ ព្រះមានព្រះភាគទ្រង់ជ្រាបថា ក្នុងវេលាដែលព្រះអង្គស្តេចយាងដល់ទីនៅរបស់តាបសនោះ ព្រះធម្មទេសនាកណ្ឌមួយនឹងកើតឡើង ទើបទ្រង់បានអធិដ្ឋានទុក ដោយមិនឲ្យទឹកខ្វែងដទៃប្រាកដ ព្រោះដូច្នោះ សក្យមហានាម ទើបទ្រង់មិនឃើញ ។*

*បទថា **បុរាណសព្រហ្មចារី** (ជាសព្រហ្មចារីបុគ្គលជាន់ចាស់) បានដល់ ធ្លាប់ជាអ្នករួមប្រព្រឹត្តព្រហ្មចារ្យជាមួយគ្នាមកពីមុន ។ បានឮថា ករណ្ឌុកាលាមតាបសនោះ បាននៅក្នុងអាស្រមនោះ ក្នុងសម័យអាឡារតាបសកាលាមគោត្រ ។ ព្រះធម្មសង្គាហកាចារ្យពោលសំដៅដល់តាបសនោះឯង ។ បទថា **សន្ថរំ បញ្ញាបេហិ** (ចូរក្រាលកម្រាល) មានអធិប្បាយថា អ្នកចូរក្រាលអាសនៈក្នុងទីដែល*

ត្រូវក្រាល ។ បទថា **សន្ថរំ បញ្ញាបេត្វា** (ក្រាលកម្រាល) សេចក្តីថា ក្រាលសំពត់សម្រាប់ក្រាលដេកលើគ្រែដែលជាកប្បិយៈ ។ ការកន្លងផុត ឈ្មោះថា បរិញ្ញា ក្នុងបទថា **បញ្ញត្តិកាមបរិញ្ញា (កាមានំ បរិញ្ញំ បញ្ញាបេតិ)** នេះ ព្រោះដូច្នោះ សាស្តាពួកខ្លះ ទើបបញ្ញត្តិការឈានកន្លងកាមទាំងឡាយថា ជាបឋម-ឈាន ។ បទថា **ន រូបានំ បរិញ្ញំ** (មិនបញ្ញត្តិរូបបរិញ្ញា) សេចក្តីថា មិនបញ្ញត្តិធម៌ដែលជាហេតុឈានកន្លងរូបថា ជាអរូបាវចរសមាបត្តិ ។ បទថា **ន វេទនានំ បរិញ្ញំ** (មិនបញ្ញត្តិវេទនាបរិញ្ញា) សេចក្តីថា មិនបញ្ញត្តិការឈានកន្លងវេទនាថា ជានិព្វាន ។ គតិ គឺ សេចក្តីសម្រេច ឈ្មោះថា **សេចក្តីសម្រេច** ។ បទថា **ឧទាហុ បុថុ** គឺ **ឧទាហុ នានា** (ឬផ្សេងគ្នា) ។

ចប់អដ្ឋកថា ភរណ្ឌុសូត្រទី ៤

# អដ្ឋកថា ហត្ថកសូត្រទី ៥

## *"ហត្ថកទេវបុត្តមិនឆ្អែតក្នុងធម៌ ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ករណ្ឌសូត្រទី ៤ ដូចតទៅនេះ ៖*

[១២៩] ***អភិក្កន្ត*** *ស័ព្ទ ក្នុងបទថា* ***អភិក្កន្តាយ រត្តិយា*** *នេះ ប្រាកដក្នុងអត្ថថា* ***អស់ទៅ*** *(ខយៈ)* ***ល្អ*** *(សុន្ទរៈ)* ***ស្អាតក្រៃលែង*** *(អភិរូបៈ)* ***គួរអនុមោទនាក្រៃលែង*** *(អព្ភនុមោទនា) ជាដើម ។ ក្នុងអត្ថ ៤ យ៉ាងនោះ* ***អភិក្កន្ត*** *ស័ព្ទប្រាកដក្នុងការ* ***អស់ទៅ*** *ដូចក្នុងប្រយោគទាំងឡាយមានជាអាទិ៍យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីអស់ទៅហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយនៅយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយចុះ ព្រះអង្គ ។ ប្រាកដក្នុងសេចក្តីថា* ***ល្អ*** *ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា បុគ្គលនេះទាំងល្អ ទាំងប្រណីតជាងបុគ្គល ៤ ពួកនេះ ។*

*ប្រាកដ ក្នុងសេចក្តីថា* ***ស្អាតក្រៃលែង*** *ដូចក្នុងប្រយោគទាំងឡាយមានជាអាទិ៍យ៉ាងនេះថា*

*នរណារុងរឿងហើយដោយឫទ្ធិ ដោយយស មានពណ៌សម្បុរ*
*ដ៏ក្រៃលែង ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង ថ្វាយបង្គំជើងទាំងពីរ*
*របស់យើង ។*

ប្រាកដក្នុងសេចក្ដីថា **គួរអនុមោទនាយ៉ាងក្រៃលែង** ដូចក្នុងប្រយោគទាំងឡាយមានជាអាទិ៍យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន គួរអនុមោទនាដ៏ក្រៃ-លែង ។ តែក្នុងបទថា **អភិក្កន្តាយ រត្តិយា** នេះ **អភិក្កន្ត** ស័ព្ទ ប្រាកដក្នុងសេចក្ដីល្អ ។ ព្រោះហេតុនោះ លោកទើបពង្រីកសេចក្ដីទុកថា បទថា **អភិក្កន្តាយ រត្តិយា** សេចក្ដីថា ក្នុងរាត្រីដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ **អភិ-ក្កន្ត** ស័ព្ទ ក្នុងបទថា **អភិក្កន្តវណ្ណា** នេះ ប្រាកដក្នុងសេចក្ដីថា ស្អាតក្រៃលែង ។

ចំណែក **វណ្ណ** ស័ព្ទ ប្រាកដក្នុងអត្ថថា សម្បុរ (ឆវិ) **សរសើរ** (ថុតិ) **វណ្ណៈ** (កុលវគ្គ) **ហេតុ** (ការណៈ) **រូបរាង** (សណ្ឋាន) **ខ្នាត** (បមាណៈ) និង **រូបាយតនៈ** ជាដើម ។ ក្នុងបណ្ដាអត្ថ ៦ យ៉ាងនោះ **វណ្ណ** ស័ព្ទ ប្រាកដក្នុងសេចក្ដីថា **សម្បុរ** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា ព្រះមានព្រះភាគទ្រង់មានព្រះឆវីដូចវណ្ណៈនៃមាស ។ ប្រាកដក្នុងសេចក្ដី **សរសើរ** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា ម្នាលគហបតី ក៏ការសរសើរគុណរបស់ព្រះសមណ-គោតម លោកបានចងទុកអំពីកាលណា ។ ប្រាកដក្នុង **វណ្ណៈ** (ខ្ពស់ទាប) ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន វណ្ណៈរបស់ខ្ញុំព្រះអង្គមាន ៤ យ៉ាង ។ ប្រាកដក្នុងសេចក្ដីថា **ហេតុ** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា មួយទៀត ដោយហេតុត្រឹមប៉ុនណាហ្ន៎ គេហៅថា **គន្ធត្ថេនោ**

(លួចកិន) ។ ប្រាកដក្នុងសេចក្ដីថា **រូបរាង** ក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា និម្មិតរូបរាងជាស្ដេចដ៏វិជំ ។ ប្រាកដក្នុងសេចក្ដីថា **ខ្នាត** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា ខ្នាតរបស់បាត្រមាន ៣ យ៉ាង ។ ប្រាកដក្នុងសេចក្ដីថា **រូបាយតនៈ** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា រូប (វណ្ណៈ) គន្ធៈ រសៈ ឱជា ។ **វណ្ណ** សព្ទនោះ ក្នុងទីនេះ គប្បីជ្រាបថា បានដល់ **ពណ៌សម្បុរ** ។ ព្រោះហេតុនោះ លោកទើបអធិប្បាយសេចក្ដីទុកថា បទថា **អភិក្កន្តវណ្ណា** (មានវណ្ណៈស្អាតក្រៃលែង) សេចក្ដីថា មានពណ៌សម្បុរស្អាតក្រៃលែង គឺ មានពណ៌សម្បុរគួរប្រាថ្នា មានពណ៌សម្បុរគួរពេញចិត្ត ។

**កេវល** សព្ទ ក្នុងបទថា **កេវលកប្បំ** នេះ មានអត្ថមិនមែនតិច ដូចជា **អនវសេស** (មិនមានចំណែកនៅសល់) **យេភុយ្យ** (ដោយច្រើន) **អព្យាមិស្ស** (មិនលាយគ្នា) **អនតិរេក** (មិនច្រើន) **ទឡ្ហត្ថ** (ប្រាថ្នាមាំ) **វិសំយោគ** (ប្រាសចាកគ្នា) ។ ពិតណាស់ **កេវល** សព្ទនោះ មានអត្ថថា **មិនមានចំណែកនៅសល់** ក្នុងប្រយោគមានជាអាទិ៍ថា ព្រហ្មចរិយបរិសុទ្ធិ បរិបូរណ៍អស់ជើង ។ សេចក្ដីដែល **កេវល** សព្ទ ប្រើក្នុងអត្ថថា **ដោយច្រើន** ដូចក្នុងប្រយោគមានជាអាទិ៍ថា ក៏អ្នកស្រុកអង្គៈ និងមគធៈដោយច្រើន នឹងនាំគ្នាកាន់យកខាទនីយៈ និងភោជនីយហារ ចូលទៅគាល់ ។ **កេវល** សព្ទ ក្នុងអត្ថថា **មិនលាយគ្នា** ដូចក្នុងប្រយោគ

មានជាអាទិ៍យ៉ាងនេះថា ការកើតឡើងនៃកងទុក្ខសុទ្ធៗ (មិនលាយគ្នា) រមែងមាន ។ **កេវល** ស័ព្ទ ក្នុងអត្ថ **មិនច្រើន** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា លោកដ៏មានអាយុនេះ អាស្រ័យគុណត្រឹមសទ្ធាតែម្យ៉ាង (មិនច្រើន) ទេ ។ **កេវល** ស័ព្ទក្នុងអត្ថថា **ប្រាថ្នាមាំ** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា បពិត្រលោកដ៏ចម្រើន សទ្ធិវិហារិករបស់ព្រះអនុរុទ្ធៈ ឈ្មោះថា ពាហិកៈ តាំងមាំនៅក្នុងសង្ឃភេទ ។ **កេវល** ស័ព្ទ ក្នុងសេចក្ដីថា **ប្រាសចាកគ្នា** ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា អ្នកបែកគ្នាហើយ លោកហៅថា ឧត្តមបុរស ។ តែក្នុងទីនេះ ទ្រង់បំណងយកសេចក្ដីថា **មិនមានចំណែកនៅសល់** ថាជាអត្ថរបស់ **កេវល** ស័ព្ទនោះ ។

ចំណែក **កប្ប** ស័ព្ទ មានអត្ថច្រើនយ៉ាង ជាដើមថា **អភិសទ្ទហ** (ការដាក់ចិត្តជឿ) **វោហារ** (ការហៅ) **កាល** (កាល) **បញ្ញត្តិ** (បញ្ញត្តិ) **ឆេទ** (ការកាត់) **វិកប្ប** (កំណត់) **លេស** (ការអាង) **សមន្តភាវ** (ការៈជុំវិញ) ។ ពិតហើយ **កប្ប** សព្ទនោះ មាន **ការដាក់ចិត្តជឿ** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា ព្រះតម្រាស់នេះ របស់ព្រះគោតមដ៏ចម្រើន ទ្រង់ជាព្រះអរហន្តសម្មាសម្ពុទ្ធ គួរដាក់ចិត្តជឿ ។ **កប្ប** សព្ទ មាន **ការហៅ** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឆាន់ផ្លែឈើ តាមសមណ-

វោហារ ៥ យ៉ាង ។ **កប្ប** ស័ព្ទ មាន **កាល** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា តថាគតនឹងនៅរហូតអស់កាលជានិច្ច ដោយអាការណា ។ **កប្ប** ស័ព្ទ មាន **បញ្ញត្តិ** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា លោកដ៏មានអាយុឈ្មោះថា កប្បៈ ទូលសួរថា... ដូច្នេះ ។ **កប្ប** ស័ព្ទ មាន **ការកាត់** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា អ្នកប្រដាប់ហើយ កោរសក់ និងពុកមាត់ហើយ ។ **កប្ប** ស័ព្ទ មាន **ការកំណត់** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា កំណត់ ២ អង្គុលី រមែងគួរ ។ **កប្ប** ស័ព្ទ មាន **លេស** ជាអត្ថ ដូចក្នុងប្រយោគមានជាអាទិ៍ថា លេសដើម្បីនឹងដេក មានហើយ ។ **កប្ប** ស័ព្ទ មាន **ភាវៈជុំវិញ** ជាអត្ថ ក្នុងប្រយោគមានជាអាទិ៍យ៉ាងនេះថា ឲ្យភ្លឺទូទៅទាំងព្រះជេតវ័ន ។ តែក្នុងទីនេះ ទ្រង់បំណងយក **សេចក្តីជុំវិញ** ជាអត្ថរបស់ **កប្ប** ស័ព្ទនោះ ។ ព្រោះដូច្នោះ ក្នុងបទថា **កេវលកប្បំ ជេតវនំ** នេះ ទើបមានអត្ថថា ញុំាងព្រះជេតវ័នឲ្យភ្លឺដោយជុំវិញ មិនមានសល់ ។

បទថា **ឱភាសេត្វា** (ធ្វើឲ្យភ្លឺ) បានដល់ ផ្សាយស្មើទៅ ។ បទថា **វាលិកាយ** (ខ្សាច់) បានដល់ ខ្សាច់ដ៏ល្អិត ។ បទថា **ន សណ្ឋាតិ** (មិនដក់នៅ) សេចក្តីថា មិនស្ថិតនៅ ។ បទថា **ឱឡារិកំ** (ឲ្យធំ) សេចក្តីថា ព្រោះថា ក្នុងវេលាដែលព្រះព្រហ្ម និងទេពដទៃឈរលើផែនដី គួរនឹងនិម្មិតអត្តភាពឲ្យធំ ឬនិម្មិត

ផែនដី ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។ ដោយបទថា **ធម្មា** (ធម៌) នេះ ទ្រង់សម្តែងដល់ព្រះពុទ្ធវចនៈ ដែលហត្ថកទេវបុត្រ ធ្លាប់ហៅមកក្នុងកាលមុន ។ បទថា **នាទប្បត្តិនោ អហេសុំ** (មិនបានឲ្យប្រព្រឹត្តទៅ) សេចក្តីថា ធម៌ទាំងឡាយបានវិនាសទៅ ពីការពោលរបស់អ្នកដែលភ្លេចស្វាធ្យាយ ។ បទថា **អប្បដិវាណោ** (មិនធុញ) សេចក្តីថា មិនត្រឡប់ គឺ មិនណាយ ។ បទថា **ទស្សនស្ស** (ការឃើញ) សេចក្តីថា សូម្បីការឃើញដោយចក្ខុវិញ្ញាណ ។ បទថា **ឧបដ្ឋានស្ស** (ការឧបដ្ឋាក) សេចក្តីថា ដល់ការទំនុកបម្រុងដោយបច្ច័យ ៤ ។ បទថា **អធិសីលំ** (អធិសីល) បានដល់ សីល ១០ យ៉ាង ។ ព្រោះថា សីល ១០ នោះ ព្រះមានព្រះភាគត្រាស់ហៅថា អធិសីល ព្រោះប្រៀបជាមួយបញ្ចសីល ។ ដោយបទថា **អវិហំ គតោ** (ទៅអវិហា) ហត្ថកទេវបុត្រសម្តែងថា ខ្ញុំព្រះអង្គកើតហើយក្នុងព្រហ្មលោកជាន់ អវិហា ។

ចប់អដ្ឋកថា ហត្ថកសូត្រទី ៥

# អដ្ឋកថា កដុរិយសូត្រទី ៦

*“ភិក្ខុធ្វើខ្លួនឲ្យជារបស់ស្អុយ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កដុរិយសូត្រទី ៦ ដូចតទៅនេះ ៖*

[១៣០] *បទថា* ***គោយោគមិលក្ខស្មឹ*** *(ក្នុងសម្នាក់របស់ពួកមិលក្ខៈដែលជាឈ្មួញគោ) សេចក្តីថា ក្នុងសម្នាក់របស់ពួកមិលក្ខៈ ដែលប្រជុំគ្នាក្នុងកន្លែងទិញលក់គោ ។ បទថា* ***រិត្តស្សាទំ*** *(មិនមានការរីករាយ) សេចក្តីថា គ្មានសេចក្តីរីករាយ ព្រោះមិនមានសេចក្តីសុខកើតពីឈាន ។ បទថា* ***ពាហិរស្សាទំ*** *(មានការរីករាយខាងក្រៅ) សេចក្តីថា មានសេចក្តីត្រេកអរក្នុងសេចក្តីសុខខាងក្រៅ ដោយអំណាចនៃសេចក្តីសុខដែលកើតពីកាមគុណ ។ បទថា* ***កដុវិយំ*** *(របស់ស្អុយ) បានដល់ របស់ដែលគេចោលហើយ ។ បទថា* ***អាមគន្ធេ*** *(វត្ថុមានក្លិនឆ្អេះឆ្អាប) សេចក្តីថា វត្ថុដែលមានក្លិនឆ្អាប ពោលគឺ សេចក្តីក្រោធ ។ បទថា* ***វស្សុតំ*** *(ប្រឡាក់) សេចក្តីថា សើមជោកហើយ ។ បទថា* ***មក្ខិកា*** *(រុយ) ពោលគឺ កិលេស ។ បទថា* ***នានុបតិស្សន្តិ*** *(នឹងមិនហោមរោម) សេចក្តីថា នឹងមិនហើរតាមហោមរោម ។ បទថា* ***នានាស្សវិស្សន្តិ*** *(ទើបមិនរំា) សេចក្តីថា ទើបមិនជាប់តាមស៊ី ។ បទថា* ***សំវេគមាបាទិ*** *(កើតសេចក្តីសង្វេគ) បានដល់ បានជាព្រះសោតាបន្ន ។*

បទថា **កដុវិយកតោ** (ត្រូវធ្វើឲ្យជារបស់ស្អុយ) សេចក្តីថា ត្រូវធ្វើឲ្យជារបស់ដែលបោះចោលហើយ ។ បទថា **អារកា ហោតិ** (រមែងជាអ្នកឃ្លាតឆ្ងាយ) សេចក្តីថា មានក្នុងទីឆ្ងាយ ។ បទថា **វិឃាតសេវ្យ ភាគវា** (មានតែសេចក្តីចង្អៀតចង្អល់) សេចក្តីថា មានចំណែកនៃទុក្ខទុំនុះឯង ។ បទថា **ចរេ** (ត្រាច់) បានដល់ រមែងត្រាច់ គឺ រមែងទៅ ។ បទថា **ទុម្មេធោ** (មានបញ្ញាអាក្រក់) បានដល់ ជាអ្នកមិនមានបញ្ញា ។ ក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់វដ្តៈទុកតែម្យ៉ាងប៉ុណ្ណោះ ។ តែក្នុងគាថាទាំងឡាយ ត្រាស់ទុកទាំងវដ្តៈ និងវិវដ្តៈ ។

ចប់អដ្ឋកថា កដុវិយសូត្រទី ៦

# អដ្ឋកថា បឋមអនុរុទ្ធសូត្រទី ៧

*“ធម៌ ៣ យ៉ាង ដែលនាំស្ត្រីទៅអបាយភូមិ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអនុរុទ្ធសូត្រទី ៧ ដូចតទៅនេះ ៖*

[១៣១] *ក្នុងព្រះសូត្រទី ៧ ទ្រង់ត្រាស់វដ្ដៈទុកតែម្យ៉ាង ។*

ចប់អដ្ឋកថា បឋមអនុរុទ្ធសូត្រទី ៧

# អដ្ឋកថា ទុតិយអនុរុទ្ធសូត្រទី ៨

*"ព្រះអនុរុទ្ធសន្ទនាជាមួយព្រះសារីបុត្ត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអនុរុទ្ធសូត្រទី ៨ ដូចតទៅនេះ ៖*

[១៣២] *បទថា* **ឥទន្តេ មានស្មឹ** *(នេះព្រោះមានះរបស់លោក) សេចក្តីថា នេះជាមានះដែលចម្រើនហើយដោយចំណែក ៩ របស់លោក ។ បទថា* **ឥទន្តេ ឧទ្ធច្ចស្មឹ** *(នេះជាឧទ្ធច្ចៈរបស់លោក) សេចក្តីថា នេះជាសេចក្តីរាយមាយរបស់លោក គឺ ភាពនៃចិត្តរបស់លោករាយមាយ ។ បទថា* **ឥទន្តេ កុក្កុច្ចស្មឹ** *(នេះជាកុក្កុច្ចៈរបស់លោក) សេចក្តីថា នេះជាការរំខានរបស់លោក ។*

ចប់អដ្ឋកថា ទុតិយអនុរុទ្ធសូត្រទី ៨

# អដ្ឋកថា បដិច្ឆន្នសូត្រទី ៩

## *“វត្ថុដែលបិទ និងវត្ថុដែលបើក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិច្ឆន្នសូត្រទី ៩ ដូចតទៅនេះ ៖*

[១៣៣] *បទថា **វហន្តិ** (ប្រសើរ) ប្រែថា ដំណើរទៅបាន ។ បទថា **បដិច្ឆន្នោ វហតិ** (បិទបាំងហើយទើបប្រសើរ) សេចក្តីថា បិទបាំងហើយ ទើបដំណើរទៅបាន ។ ក្នុងបទថា **វិវដ្ដោ វិរោចតិ** (បើកហើយទើបរុងរឿង) គប្បីជ្រាបប្រការដែលនឹងត្រូវបើក ៤ យ៉ាងគឺ បើកដោយចំណែកតែមួយ ១ បើកដោយចំណែកពីរ ១ បើកដោយខ្លួន ១ បើកដោយទូទៅ ១ ។ ក្នុងបណ្តាវត្ថុដែលនឹងត្រូវបើក ៤ យ៉ាងនោះ សិក្ខាបទដែលមិនទូទៅ (ដល់ភិក្ខុ និងភិក្ខុនី) ឈ្មោះថា បើកដោយចំណែកតែមួយ ។ សិក្ខាបទដែលទូទៅ (ដល់ឧភតោសង្ឃ) ឈ្មោះថា បើកដោយចំណែកពីរ ។ គុណធម៌ដែលបានសម្រេចហើយ ឈ្មោះថា បើកចំពោះខ្លួន ។ (ចំណែក) ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ឈ្មោះថា វត្ថុដែលបើកដោយទូទៅ ។*

ចប់អដ្ឋកថា បដិច្ឆន្នសូត្រទី ៩

# អដ្ឋកថា លេខសូត្រទី ១០

## *"បុគ្គល ៣ ពួក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង លេខសូត្រទី ១០ ដូចតទៅនេះ ៖*

[១៣៤] *បទថា* ***អភិណ្ហំ*** *(រឿយៗ) សេចក្តីថា ជានិច្ច គឺ និរន្តរ ។ បទថា* ***អគាឡ្ហេន*** *(ដោយពាក្យអាក្រក់) សេចក្តីថា ដោយពាក្យធ្ងន់ គឺ ពាក្យកក្ខឡៈ ។ បទថា* ***ផរុសេន*** *សេចក្តីថា ដោយពាក្យគ្រោតគ្រាត អធិប្បាយថា សូម្បីត្រូវតបតថាយ៉ាងធ្ងន់ៗ យ៉ាងគ្រោតគ្រាត ដូច្នេះ ។ បទថា* ***អមនាបេន*** *(ដោយពាក្យមិនគួរពេញចិត្ត) សេចក្តីថា ដោយពាក្យដែលមិនរីករាយ គឺ មិនចម្រើនចិត្ត ។ បទថា* ***សន្ធិយតិយេវ*** *(ផ្សះផ្សាបាន) សេចក្តីថា នៅជាប់តគ្នាបាន ។ បទថា* ***សំសន្ទតិយេវ*** *(ទំនាក់ទំនងបាន) សេចក្តីថា មិនឆ្ងាយពីគ្នា ។ បទថា* ***សម្មោទតិយេវ*** *(រមែងរីករាយនឹងគ្នា) សេចក្តីថា មិនឃ្លាតពីគ្នា ដល់ភាពតែមួយជាមួយគ្នាទុំះឯង ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា លេខសូត្រទី ១០

**ចប់កុសិនារវគ្គទី ៣**

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# យោធាជីវវគ្គទី ៤

## អដ្ឋកថា យោធាសូត្រទី ១

*"អ្នកច្បាំងដែលគួរដល់ព្រះរាជា"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យោធាសូត្រទី ១ ដូចតទៅនេះ ៖*

[១៣៥] *អ្នកដែលចូលទៅអាស្រ័យការច្បាំងចិញ្ចឹមជីវិត ឈ្មោះថា* ***អ្នកច្បាំង*** *។ បទថា* ***រាជារហោ*** *(ជាគួគួរដល់ព្រះរាជា) សេចក្តីថា សមគួរដល់ព្រះរាជា ។ បទថា* ***រាជាភោគ្គោ*** *(រាជសេវកៈ) សេចក្តីថា ជាអ្នកដែលព្រះរាជាគប្បីប្រើប្រាស់ ។ បទថា* ***អង្គន្តេវ សង្ខ្យំ គច្ឆតិ*** *(ដល់នូវការរាប់ថាជាអង្គាវយវៈតែម្យ៉ាង) សេចក្តីថា រមែងរាប់ថាជាអង្គប្រកប ព្រោះចាំត្រូវប្រាថ្នាដោយពិត ដូចដៃ និងជើង ។ បទថា* ***ទូរេបាតី ហោតិ*** *(បាញ់ឆ្ងាយ) សេចក្តីថា បាញ់កូនសរទៅបានឆ្ងាយយ៉ាងនេះ គឺ ក្នុងទីកចម្ងាយប្រមាណ ១ ឧសភៈ លើគោកចម្ងាយប្រមាណ ៨ ឧសភៈ ឬឆ្ងាយជាងនោះ ។ ពិតណាស់ ទាហានរបស់ព្រះបាទទុដ្ឋគាមិនីអភ័យ បាញ់កៅទណ្ឌ (ធ្នូ) បានចម្ងាយប្រមាណ ៩ ឧសភៈ ។*

*ក្នុងភពចុងក្រោយ ព្រះពោធិសត្វ ព្រះអង្គទ្រង់បាញ់បានចម្ងាយប្រមាណ ១ យោជន៍ ។ បទថា* ***អក្ខណវេធី*** *(បាញ់មិនខុស) បានដល់ បាញ់បានដោយមិន*

ខុសម្យ៉ាងទៀត អធិប្បាយថា អាចបាញ់បានរហ័សទាន់ផ្លេកបន្ទោរ ។ បទថា **មហតោ កាយស្ស បទាលេតា** (បាញ់ទម្លាយគំនរធំបាន) មានអធិប្បាយថា អាចបាញ់ទម្លុះផែនក្តារ ១០០ បន្ទះ ដែលចងរួមគ្នាខ្លះ ផ្ទាំងស្បែកក្របី ១០០ ផ្ទាំង ដែលចងរួមគ្នាខ្លះ ផែនលោហៈកម្រាស់ប្រមាណប៉ុនមេដៃខ្លះ ផែនក្តាររាបដែលធ្វើដោយឈើធ្នង់កម្រាស់ ៤ ធ្នាប់ខ្លះ ។ ផែនក្តាររាបដែលធ្វើដោយឈើល្វាមង់ កម្រាស់ ១ ចំអាមខ្លះ រទេះបន្ទុកខ្សាច់តាមបណ្តោយខ្លះ ។ បទថា **យំកិញ្ចិ រូបំ** (រូបណានីមួយ) ជាដើម បានឲ្យពិស្តារហើយក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គនោះឯង ។ បទ **នេតំ មម** (នុ៎ះមិនមែនរបស់យើង) ជាដើម ព្រះមានព្រះភាគ ត្រាស់ទុកដោយអំណាចនៃការហាមតណ្ហា មានះ និងទិដ្ឋិ ។ បទថា **សម្មប្បញ្ញាយ បស្សតិ** (ឃើញដោយបញ្ញាដ៏ប្រពៃ) សេចក្តីថា ពិចារណាឃើញដោយមគ្គប្បញ្ញាព្រមទាំងវិបស្សនាដោយប្រពៃ គឺ ដោយហេតុ បានដល់ ដោយការណ៍ ។ បទថា **បទាលេតិ** (ទម្លាយ) សេចក្តីថា រមែងទម្លាយដោយព្រះអរហត្តមគ្គ ។

ចប់អដ្ឋកថា យោធាសូត្រទី ១

# អដ្ឋកថា បរិសាសូត្រទី ២

## *“បរិស័ទ ៣ ពួក”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិសាសូត្រទី ២ ដូចតទៅនេះ ៖*

[១៣៦] *បទថា* ***ឧក្កាចិតវិនីតា*** *(មិនត្រូវសួរ ហើយណែនាំ) បានដល់ បរិស័ទដែលត្រូវណែនាំដោយមិនបានសាកសួរ គឺ បរិស័ទដែលទូន្មានលំបាក ។ បទថា* ***បដិបុច្ឆាវិនីតា*** *(ត្រូវសួរ ហើយណែនាំ) បានដល់ បរិស័ទដែលត្រូវណែនាំដោយសាកសួរ គឺ បរិស័ទដែលទូន្មានបានងាយ ។ បទថា* ***យាវតា ច វិនីតា*** *(ត្រូវណែនាំពេលដល់អធ្យាស្រ័យ) បានដល់ បរិស័ទដែលត្រូវណែនាំដោយប្រការណែនាំល្មមប្រមាណ អធិប្បាយថា បានដល់ បរិស័ទដែលត្រូវណែនាំដោយដឹងប្រមាណ ។ ក៏សេចក្ដីនៃព្រះបាលីដែលថា* ***យាវតជ្ឈា*** *ស្មើនឹង* ***យាវ បយោគអជ្ឈាសយេន*** *(ល្មមដល់អធ្យាស្រ័យ) អធិប្បាយថា បរិស័ទដែលបានទទួលការណែនាំ ដោយដឹងអធ្យាស្រ័យ ។*

ចប់អដ្ឋកថា បរិសាសូត្រទី ២

# អដ្ឋកថា មិត្តសូត្រទី ៣

## *"អង្គ ៣ របស់មិត្តពិត"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មិត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[១៣៧] *មានអត្ថងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា មិត្តសូត្រទី ៣

# អដ្ឋកថា ឧប្បាទសូត្រទី ៤

## “ធម្មនិយាម”

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧប្បាទសូត្រទី ៤ ដូចតទៅនេះ ៖*

[១៣៨] *បទថា* ***ធម្មដ្ឋិតតា*** *(ការតាំងនៅដោយធម៌) បានដល់ ការៈដែលទ្រទ្រង់ខ្លួនឯងតាមសភាវៈ ។ បទថា* ***ធម្មនិយាមតា*** *(សេចក្តីពិតដោយធម៌) បានដល់ សេចក្តីពិតដោយសភាវៈ ។ បទថា* ***សព្វេ សង្ខារា*** *(សង្ខារទាំងពួង) បានដល់ សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា* ***អនិច្ចា*** *(មិនទៀង) សេចក្តីថា (សង្ខារទាំងពួង) មិនទៀង ដោយអត្ថថា មានហើយត្រឡប់ជាមិនមាន ។ បទថា* ***ទុក្ខា*** *(ជាទុក្ខ) សេចក្តីថា (សង្ខារទាំងពួង) ជាទុក្ខ ដោយអត្ថថា បៀតបៀនជានិច្ច ។ បទថា* ***អនត្តា*** *(ជាអនត្តា) សេចក្តីថា (ធម៌ទាំងពួង) ជាអនត្តា ព្រោះអត្ថថា មិនប្រព្រឹត្តទៅតាមអំណាច ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់លក្ខណៈទាំង ៣ យ៉ាងទុកលាយគ្នា ដូចពណ៌នាមក ដូច្នេះ ។*

ចប់អដ្ឋកថា ឧប្បាទសូត្រទី ៤

# អដ្ឋកថា កេសកម្ពលសូត្រទី ៥

## *"មោឃបុរសជាលបជាក់មនុស្ស"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កេសកម្ពលសូត្រទី ៥ ដូចតទៅនេះ ៖*

[១៣៩] *បទថា* ***តន្តាវុតានំ វត្ថានំ*** *ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃបឋមាវិភត្តិ ។ អធិប្បាយថា បានដល់ សំពត់ដែលត្បាញដោយសរសៃអំបោះ ។ សំពត់កម្ពលដែលត្បាញដោយសក់មនុស្ស ឈ្មោះថា* ***កេសកម្ពល*** *។ សូម្បីបទថា* ***បវាទានំ*** *(លទ្ធិខាងក្រៅ) នេះ ក៏ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃបឋមាវិភត្តិ ។ បទថា* ***បដិកិដ្ឋោ*** *(អាក្រក់) សេចក្តីថា លទ្ធិថយក្រោយ គឺ ទាប ។ បទថា* ***មោឃបុរិសោ*** *(មោឃបុរស) បានដល់ បុរសទទេ គឺ បុរសវង្វេងវង្វាន់ ។ បទថា* ***បដិពាហតិ*** *(ជំទាស់) បានដល់ បដិសេធ ។ បទថា* ***ខិបំ ឧឌ្ឌេយ្យ*** *បានដល់ ដាក់លប ។*

ចប់អដ្ឋកថា កេសកម្ពលសូត្រទី ៥

# អដ្ឋកថា សម្បទាសូត្រទី ៦

## *“សម្បទា ៣ យ៉ាង”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សម្បទាសូត្រទី ៦ ដូចតទៅនេះ ៖*

[១៤០] *មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា សម្បទាសូត្រទី ៦

# អដ្ឋកថា វុឌ្ឍិសូត្រទី ៧

*"វុឌ្ឍិ ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វុឌ្ឍិសូត្រទី ៧ ដូចតទៅនេះ ៖*

[១៤១] *មានអត្ថងាយហើយនោះឯង ។*

ចប់អដ្ឋកថា វុឌ្ឍិសូត្រទី ៧

# អដ្ឋកថា បឋមអស្សសូត្រទី ៨

*"សេះខ្ចក និងមនុស្សខ្ចក"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអស្សសូត្រទី ៨ ដូចតទៅនេះ ៖*

*[១៤២] បទថា **អស្សខលុង្កេ** (សេះខ្ចក) បានដល់ ពូជសេះ ។ បទថា **ឥទមស្ស ជវស្មឹ វទាមិ** (តថាគតពោលការដឹង... នេះ ក្នុងការមានបញ្ញាឆ្លាតវៃរបស់អ្នក)[១] សេចក្តីថា តថាគតពោលថា នេះជាបញ្ញា គឺ ញាណរបស់ភិក្ខុនោះ ។ បទថា **ឥទមស្ស វណ្ណស្មឹ វទាមិ** (តថាគតពោលការដែល... មានក្នុងការមានសម្បុរល្អរបស់អ្នក)[២] សេចក្តីថា តថាគតពោលថា នេះជាសម្បុរ គឺ គុណល្អរបស់ភិក្ខុនោះ ។ បទថា **ឥទមស្ស អារោហបរិណាហស្មឹ**[៣] (នេះក្នុងការមានទ្រង់ទ្រាយល្អរបស់អ្នក) សេចក្តីថា តថាគតពោលថា នេះជាសេចក្តីខ្ពង់ខ្ពស់ សេចក្តីស្អាត របស់ភិក្ខុនោះ ដូច្នេះឯង ។*

ចប់អដ្ឋកថា បឋមអស្សសូត្រទី ៨

---

*បិដក (១) = នេះជាល្បឿនរបស់ភិក្ខុនោះ ។ (២) = នេះជាសម្បុររបស់ភិក្ខុនោះ ។*
*(៣) = ឥទមស្ស អារោហបរិណាហស្មឹ វទាមិ នេះជាកំពស់ និងមាឌរបស់ភិក្ខុនោះ ។*

# អដ្ឋកថា ទុតិយអស្សសូត្រទី ៩

## *"សេះល្អ និងបុរសល្អ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអស្សសូត្រទី ៩ ដូចតទៅនេះ ៖*

[១៤៣] *បទថា **អស្សសទស្សេ** (សេះល្អ) សេចក្ដីថា សេះល្អ ក្នុងចំនួនសេះទាំងឡាយ ។ បទថា **បុរិសសទស្សេ** (មនុស្សល្អ) សេចក្ដីថា បុរសល្អដែលដូចសេះល្អ ក្នុងបុរសទាំងឡាយ អធិប្បាយថា បានដល់ សុភាពបុរស ។ ក្នុងព្រះសូត្រនេះ ត្រាស់មគ្គផលទុក ៣ យ៉ាង ។ ក្នុងបណ្ដាបុគ្គល ៣ ប្រភេទនោះ បុគ្គលល្អនេះ គប្បីជ្រាបថា ដល់ព្រមដោយបញ្ញាធ្លាតវៃ គឺ ញាណ ដោយមគ្គ ៣ ។*

ចប់អដ្ឋកថា ទុតិយអស្សសូត្រទី ៩

# អដ្ឋកថា តតិយអស្សសូត្រទី ១០

## *"សេះអាជានេយ្យ និងបុរសអាជានេយ្យ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអស្សសូត្រទី ១០ ដូចតទៅនេះ ៖*

[១៤៤] *បទថា **ភទ្រេ** (ប្រសើរ) បានដល់ សេះអាជានេយ្យដ៏ចម្រើន ។ សេះដែលដឹងហេតុដែលគួរ និងមិនគួរ ឈ្មោះថា **សេះអាជានេយ្យ** ។ សូម្បីក្នុងបុរសអាជានេយ្យ ក៏មានន័យនេះដូចគ្នា ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់អរហត្តផលទុក ។ បណ្ដាបុគ្គល ៣ ប្រភេទនោះ បុរសអាជានេយ្យនេះ គប្បីជ្រាបថា ជាអ្នកបរិបូរណ៍ដោយបញ្ញាធ្លាតវៃ គឺ ញាណ ព្រោះព្រះអរហត្តមគ្គ ។*

ចប់អដ្ឋកថា តតិយអស្សសូត្រទី ១០

# អដ្ឋកថា បឋមមោរនិវាបសូត្រទី ១១

*"ពោលដោយខន្ធ ៣"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមមោរនិវាបសូត្រទី ១១ ដូចតទៅនេះ ៖*

[១៤៥] *បទថា* ***អច្ចន្តនិដ្ឋោ*** *(ជាអ្នកសម្រេចដល់ទីបំផុត) សេចក្តីថា សម្រេចដោយឈានកន្លងទីបំផុត (នៃទុក្ខ) អធិប្បាយថា សម្រេចអកុប្បធម៌ ។ ពាក្យដ៏សេស ដូចគ្នា (នឹងពាក្យដែលពោលហើយ) នោះឯង ។*

ចប់អដ្ឋកថា បឋមមោរនិវាបសូត្រទី ១១

# អដ្ឋកថា ទុតិយមោរនិវាបសូត្រទី ១២

## *“ពោលដោយបាដិហារ្យ ៣”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយមោរនិវាបសូត្រទី ១២ ដូចតទៅនេះ ៖*

[១៤៦] *បទថា* ***ឥទ្ធិបាដិហារិយេន*** *(ឥទ្ធិបាដិហារ្យ) បានដល់ ដោយការសម្តែងឫទ្ធិជាអស្ចារ្យ ។ បទថា* ***អាទេសនាបាដិហារិយេន*** *(អាទេសនាបាដិហារ្យ) បានដល់ ដោយការពោលចង្អុល អានដល់ (ដាក់ចិត្ត) ជាអស្ចារ្យ ។*

ចប់អដ្ឋកថា ទុតិយមោរនិវាបសូត្រទី ១២

# អដ្ឋកថា តតិយមោរនិវាបសូត្រទី ១៣

*"បុគ្គលប្រសើរព្រោះមានធម៌ ៣"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយមោរនិវាបសូត្រទី ១៣ ដូចតទៅនេះ ៖*

*[១៤៧] បទថា **សម្មាទិដ្ឋិយា** (សម្មាទិដ្ឋិ) បានដល់ ដោយសម្មាទិដ្ឋិ ដែលកើតពីវិបស្សនា ដើម្បីប្រយោជន៍ដល់ផលសមាបត្តិ ។ បទថា **សម្មាញាណេន** (សម្មាញាណ) បានដល់ ដោយផលញ្ញាណ ។ បទថា **សម្មាវិមុត្តិយា** (សម្មាវិមុត្តិ) បានដល់ ធម៌ គឺ ផលសមាបត្តិដ៏សេស ។ ក្នុងសូត្រសូម្បីទាំង ៣ នេះ ព្រះមានព្រះភាគត្រាស់សំដៅដល់ ព្រះខីណាស្រពតែម្យ៉ាង ដូច្នេះឯង ។*

ចប់អដ្ឋកថា តតិយមោរនិវាបសូត្រទី ១៣

ចប់យោធាជីវវគ្គទី ៤

ក្នុងវគ្គនេះ មាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# មង្គលវគ្គទី ៥

## អដ្ឋកថា អកុសលសូត្រទី ១

*"ហេតុឲ្យធ្លាក់នរក និងឡើងសួគ៌"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អកុសលសូត្រទី ១ ដូចតទៅនេះ ៖*

[១៤៨] *បទថា* ***យថាភតំ និក្ខិត្តោ*** *(ដូចត្រូវនាំមកតម្កល់ទុក) សេចក្តីថា តាមដែលនាំមករក្សាទុក ។*

ចប់អដ្ឋកថា អកុសលសូត្រទី ១

# អដ្ឋកថា សាវជ្ជសូត្រទី ២

*"ហេតុឲ្យធ្លាក់នរក និងឡើងសួគ៌"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាវជ្ជសូត្រទី ២ ដូចតទៅនេះ ៖*

[១៤៩] *បទថា **សាវជ្ជេន** (មានទោស) បានដល់ កម្មដែលមានទោស ។*

ចប់អដ្ឋកថា សាវជ្ជសូត្រទី ២

# អដ្ឋកថា វិសមសូត្រទី ៣

*“ហេតុឲ្យធ្លាក់នរក និងឡើងសួគ៌”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិសមសូត្រទី ៣ ដូចតទៅនេះ ៖*

[១៥០] *បទថា* ***វិសមេន*** *(ខុស) បានដល់ ដោយកម្មដែលមានសេចក្តីភ្លាំងភ្លាត់ ។ បទថា* ***សមេន*** *(ត្រូវ) បានដល់ ដោយកម្មដែលប្រាសចាកសេចក្តីភ្លាំងភ្លាត់ ។*

ចប់អដ្ឋកថា វិសមសូត្រទី ៣

# អដ្ឋកថា អសុចិសូត្រទី ៤

*"ហេតុឲ្យធ្លាក់នរក និងឡើងសួគ៌"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អសុចិសូត្រទី ៤ ដូចតទៅនេះ ៖*

[១៥១] *បទថា* ***អសុចិនា*** *(មិនស្អាត) បានដល់ ដោយកម្មដែលមិនស្អាត ដូចជាលាមក ។ បទថា* ***សុចិនា*** *(ស្អាត) បានដល់ ដោយកម្មដែលស្អាត ។*

ចប់អដ្ឋកថា អសុចិសូត្រទី ៤

# អដ្ឋកថា បឋមខតសូត្រទី ៥

*“ហេតុដែលខ្លួនត្រូវទម្លាយ និងមិនត្រូវទម្លាយ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមខតសូត្រទី ៥ ដូចតទៅនេះ ៖*

[១៥២] *មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា បឋមខតសូត្រទី ៥

# អដ្ឋកថា ទុតិយខតសូត្រទី ៦

*“ហេតុដែលខ្លួនត្រូវទម្លាយ និងមិនត្រូវទម្លាយ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយខតសូត្រទី ៦ ដូចតទៅនេះ ៖*

[១៥៣] *មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ទុតិយខតសូត្រទី ៦

# អដ្ឋកថា តតិយខតសូត្រទី ៧

*“ហេតុដែលខ្លួនត្រូវទម្លាយ និងមិនត្រូវទម្លាយ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយខតសូត្រទី ៧ ដូចតទៅនេះ ៖*

[១៥៤] *មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា តតិយខតសូត្រទី ៧

# អដ្ឋកថា ចតុត្ថខតសូត្រទី ៨

*“ហេតុដែលខ្លួនត្រូវទម្លាយ និងមិនត្រូវទម្លាយ”*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចតុត្ថខតសូត្រទី ៨ ដូចតទៅនេះ ៖*

[១៥៥] *មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ចតុត្ថខតសូត្រទី ៨

# អដ្ឋកថា វន្ទនាសូត្រទី ៩

## *"ការសំពះ ៣ យ៉ាង"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វន្ទនាសូត្រទី ៩ ដូចតទៅនេះ ៖*

[១៥៦] *មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា វន្ទនាសូត្រទី ៩

# អដ្ឋកថា សុបុព្វណ្ហសូត្រទី ១០

## *"វេលាដែលជាឫក្សល្អ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុបុព្វណ្ហសូត្រទី ១០ ដូចតទៅនេះ ៖*

[១៥៧] *ក្នុងបទជាដើមថា* **សុនក្ខត្តំ** *(ឫក្សល្អ) មានអធិប្បាយថា ថ្ងៃដែលមនុស្សទាំងឡាយបំពេញសុចរិតធម៌ ៣ ឲ្យបរិបូរណ៍ ឈ្មោះថា ជាថ្ងៃដែលបានការប្រកបឫក្ស ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ថ្ងៃនោះជាឫក្សល្អគ្រប់កាល ។ ថ្ងៃនោះឯង ឈ្មោះថា ជាថ្ងៃធ្វើមង្គលហើយ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ថ្ងៃនោះជាមង្គលល្អគ្រប់កាល ។ សូម្បីថ្ងៃដែលមានសេចក្ដីភ្លឺស្វាងនោះ ក៏ឈ្មោះថា មានសេចក្ដីភ្លឺស្វាងល្អជាប្រចាំនោះឯង ។ សូម្បីការក្រោកឡើងពីដំណេក ក៏ឈ្មោះថា ក្រោកឡើងដោយល្អ ។ សូម្បីខណៈ ក៏ឈ្មោះថា ជាខណៈល្អ ។ សូម្បីយាម ក៏ឈ្មោះថា ជាយាមល្អ ។*

*ក៏ក្នុងបទថា* **សុមុហុត្តោ** *(យាមល្អ) នេះ គប្បីជ្រាបការបែងចែកវេលាដូច្នេះ វេលាប្រមាណ ១០ ផ្ទាប់ ឈ្មោះ ខណៈ ។ វេលា ១០ ខណៈ ដោយខណៈនោះ ឈ្មោះថា លយៈ ។ វេលា ១០ លយៈ ដោយលយៈនោះ ឈ្មោះថា ខណលយៈ ។ វេលា ១០ នោះ ដោយខណលយៈនោះ ឈ្មោះថា មុហុត្តៈ ។ វេលា ១០ នោះ ដោយមុហុត្តៈនោះ ឈ្មោះថា ខណមុហុត្តៈ ។*

បទថា ***សុយិដ្ឋំ ព្រហ្មចារិសុ*** *(ឈ្មោះថាបូជាល្អក្នុងព្រហ្មចារីបុគ្គលទាំងឡាយ) សេចក្តីថា ទានដែលគេឲ្យក្នុងអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ក្នុងថ្ងៃដែលបំពេញសុចរិត ៣ ឲ្យបរិបូរណ៍ហើយ ឈ្មោះថា បូជាល្អហើយ ។ បទថា* ***បទក្ខិណំ កាយកម្មំ*** *(កាយកម្មជាជោគល្អ) សេចក្តីថា កាយកម្មដែលគេធ្វើហើយក្នុងថ្ងៃនោះ ឈ្មោះថា ជាកាយកម្មប្រកបដោយសេចក្តីចម្រើន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា* ***បទក្ខិណានិ កត្វាន*** *(ធ្វើកម្មទាំងឡាយដែលជាកម្មល្អ) សេចក្តីថា លុះធ្វើកាយកម្មជាដើម ដែលប្រកបដោយសេចក្តីចម្រើនហើយ ។ បទថា* ***លភន្តត្ថេ បទក្ខិណេ*** *(រមែងបានទទួលវត្ថុទាំងឡាយដែលល្អមានប្រយោជន៍) សេចក្តីថា រមែងបានវត្ថុដែលល្អ គឺ ប្រយោជន៍ដែលប្រកបដោយសេចក្តីចម្រើនទាំងឡាយ ។ អត្ថដ៏សេសក្នុងព្រះសូត្រនេះ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សុបុព្វណ្ហសូត្រទី ១០

ចប់មង្គលវគ្គទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៥ សូត្រ

# ចប់តតិយបណ្ណាសកៈ

# អ ដ្ឋ ក ថា

## សូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសកៈ

### “ពោលដោយបដិបទា ៣”

[១៥៨] *បទថា* ***អាគាឡ្ហា បដិបទា*** *បានដល់ បដិបទាដែលធ្ងន់ គឺគ្រោតគ្រាត បានដល់ ប្រកាន់ទុកដ៏មាំ ដោយអំណាចលោភៈ ។ បទថា* ***និជ្ឈាមា*** *បានដល់ បដិបទាដែលដុតកំដៅ គឺ ធ្វើខ្លួនឲ្យក្តៅ ដោយអំណាចនៃអត្តកិលមថានុយោគ ។ បទថា* ***មជ្ឈិមា*** *បានដល់ បដិបទាដែលមិនគ្រោតគ្រាត មិនដុតកំដៅ គឺ កណ្តាល ។*

*បទថា* ***អចេលកោ*** *គឺ អ្នកមិនមានសំពត់ បានដល់ ជាអ្នកអាក្រាត ។ បទថា* ***មុត្តាចារោ*** *(គ្មានមារយាទ) បានដល់ លះបង់នូវអាចារៈ ។ គេជាអ្នកវៀរចាកអាចារៈរបស់កុលបុត្រ ក្នុងផ្លូវលោកិយៈ ក្នុងកិច្ចនៃខ្លួនទាំងឡាយ មានការបន្ទោបង់ឧច្ចារៈជាដើម ឈរបន្ទោបង់ឧច្ចារៈ ឈរបន្ទោបង់បស្សាវៈ ឈរទំពារ ឈរស៊ី ។ បទថា* ***ហត្ថាវលេខនោ*** *(លិទ្ធដៃ) សេចក្តីថា កាលដុំបាយក្នុងដៃអស់ហើយ (អ្នកបួសស្រាតមានបដិបទាតឹងនោះ) ក៏ប្រើអណ្តាតលិទ្ធដៃ ឬកាលបន្ទោបង់ឧច្ចារៈហើយ ជាអ្នកមានសេចក្តីសម្គាល់ក្នុងដៃនោះឯង ថាជាទឹក យកដៃជូត (ធ្វើឲ្យស្អាត) ។ អ្នកបួសស្រាត កាលប្រជាជនពោលថា លោកដ៏*

ចម្រើន សូមលោកមេត្តាមកទទួលភិក្ខាចុះ ដូច្នេះ ក៏មិនមក ដូច្នោះទើបឈ្មោះថា គេអញ្ជើញឲ្យមកទទួលភិក្ខា ក៏មិនមក ។ អ្នកបួសស្រោត សូម្បីកាលប្រជាជនពោលថា បើដូច្នោះ និមន្តឈប់សិនលោកដ៏ចម្រើន ក៏មិនព្រមឈប់ ដូច្នោះទើបឈ្មោះថា គេអញ្ជើញឲ្យឈប់ ក៏មិនឈប់ ។ បានឮមកថា អ្នកបួសស្រោតនោះ មិនព្រមធ្វើទាំងការមក និងការឈប់ទាំងពីរនោះ ក៏ព្រោះខ្លាចថា ជាការធ្វើតាមពាក្យនិយាយរបស់អ្នកនិមន្តនោះ ។ បទថា **អភិហដំ** (ដែលគេបែងទុកមុន) បានដល់ ភិក្ខាដែលគេកាន់យកមុន (បែងទុក) ទើបនាំមក ។ បទថា **ឧទ្ទិស្សកតំ** (ដែលគេធ្វើចំពោះ) បានដល់ ភិក្ខាដែលគេប្រាប់ថា មនុស្សទាំងនេះធ្វើចំពោះ (ថ្វាយ) ពួកលោក ។ បទថា **និមន្តនំ** (ការអញ្ជើញ) សេចក្តីថា អ្នកបួសស្រោតត្រូវគេនិមន្តយ៉ាងនេះថា សូមចូលទៅ (ទទួលភិក្ខា) ញាំងត្រកូលផ្លូវ ឬស្រុក ឈ្មោះឯណោះ ក៏មិនត្រេកអរ គឺ មិនទទួលសូម្បីភិក្ខា ។ បទថា **ន កុម្ភិមុខា** (មិនទទួលភិក្ខាពីមាត់ឆ្នាំង) បានដល់ មិនទទួលភិក្ខាដែលគេចាកពីឆ្នាំងមកឲ្យ ។ បទថា **កឡោបិ** ក្នុងបទថា **ន កឡោបិមុខា** បានដល់ ឆ្នាំងបាយ ឬកញ្ជើ ។ អ្នកបួសស្រោតនឹងមិនទទួលភិក្ខាពីឆ្នាំងបាយ ឬពីកញ្ជើនោះ ។ សួរថា ព្រោះហេតុអ្វីទើបមិនទទួល ។ ឆ្លើយថា ព្រោះគិតថា ឆ្នាំង និងកញ្ជើ អាស្រ័យយើង ទើបបានប៉ះជាមួយវែក ។ បទថា **ន ឯលកមន្តរំ** (មិនទទួលភិក្ខាកន្លង

ធរណីទ្វារ) សេចក្តីថា មិនទទួលភិក្ខាដែលគេឈរកន្ទងធរណីទ្វារប្រគេន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះគិតថា បុគ្គលនេះអាស្រ័យយើងហើយទើបបានធ្វើទានមានធរណីទ្វារនៅចន្លោះកណ្តាល ។ សូម្បីក្នុងកំណាត់ឈើ និងអង្រែក៏មាននន័យនេះឯង ។

បទថា **ទ្វិន្នំ** (២) សេចក្តីថា កាលមនុស្សពីរនាក់កំពុងបរិភោគជាមួយគ្នា កាលមនុស្សម្នាក់ក្រោកឡើងឲ្យក៏មិនទទួល ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះគិតថា មានអន្តរាយដល់ការស៊ីដុំបាយ (អាក់ខានការស៊ី) ។ ចំណែកក្នុងបទថា **ន គព្ភិនិយា** (មិនទទួលភិក្ខារបស់ស្ត្រីមានគភ៌) ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ចំពោះស្ត្រីមានគភ៌ ទារកដែលនៅក្នុងផ្ទៃ នឹងបានទទួលការប៉ះទង្គិច ។ ឯស្ត្រីដែលកំពុងឲ្យកូនបៅដោះ នឹងអន្តរាយដល់ការបំបៅដោះដល់ទារក ។ ចំណែកស្ត្រីដែលនៅជាមួយបុរស (ស្វាមី) នឹងអន្តរាយដល់សេចក្តីរីករាយ ព្រោះហេតុដូចពោលមកនេះ អ្នកបួសអាក្រាត ទើបមិនទទួលភិក្ខា (ពីស្ត្រីទាំងនេះ) ។ បទថា **ន សង្កិត្តីសុ** (មិនទទួលភត្តដែលពួកគ្នាឯងណែនាំ) បានដល់ ក្នុងភត្តដែលគេបង្គាប់ឲ្យធ្វើ ។

បានឮមកថា ក្នុងសម័យរកបាយបានលំបាក សាវករបស់អចេលក៏ប្រមូលយកអង្ករជាដើមពីទីនោះៗ មកដាំជាបាយ ដើម្បីប្រយោជន៍ដល់អចេលទាំងឡាយ

អចេលអ្នករង្កៀស ក៏មិនព្រមទទួលពីកត្តទីនោះ ។ បទថា **ន យត្ថ សា** (មិនទទួលភត្តក្នុងទីដែលមានឆ្កែនៅចាំ) សេចក្តីថា ក្នុងទីណា ឆ្កែនៅចាំ ដោយបំណងថា នឹងបានដុំបាយ ក្នុងទីនោះ អចេល នឹងមិនទទួលភត្តដែលនៅមិនទាន់បានឲ្យដល់ឆ្កែនោះ ហើយនាំមកឲ្យខ្លួន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះគិតថា អន្តរាយនៃដុំបាយនឹងមានដល់ឆ្កែនោះ ។ បទថា **សណ្ឌសណ្ឌចារិណី** (រុយរោមជាក្រុម) បានដល់ រុយរោមជាក្រុមៗ ។ អធិប្បាយថា បើមនុស្សទាំងឡាយឃើញអចេលហើយ ចូលទៅកាន់រោងបាយដោយគិតថា នឹងប្រគេនភត្តដល់អចេលនេះ និងកាលមនុស្សទាំងនោះចូលទៅ រុយដែលទំនៅតាមមាត់កញ្ជើជាដើម ក៏នឹងហើរឡើងទៅជាក្រុមៗ អចេលនឹងមិនទទួលភត្តដែលនាំមកពីទីដែលរុយហើរឡើងទៅនោះឡើយ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះគិតថា នឹងអន្តរាយក្នុងទីរកស៊ីរបស់រុយ ព្រោះអាស្រ័យយើង ។

បទថា **ន ថុសោទកំ** (មិនផឹកទឹកត្រាំថ្នាំ) បានដល់ ទឹកផឹកដែលធ្វើដោយគ្រឿងផ្សំ គឺ ស្រូវគ្រប់ប្រភេទ ។ ក៏ក្នុងទីនេះ ការផឹកសុរាប៉ុណ្ណោះ មានទោស ។ តែអចេលនេះ មានសេចក្តីសម្គាល់ក្នុងទឹកផឹកគ្រប់ប្រភេទថា មានទោស ។ អចេលណាទទួលភត្តក្នុងផ្ទះមួយខ្នងហើយត្រឡប់ អចេលនោះឈ្មោះថា **ទទួលភត្តក្នុងផ្ទះមួយខ្នង** អចេលណាចិញ្ចឹមអត្តភាពដោយបាយមួយដុំប៉ុណ្ណោះ

អចេលនោះឈ្មោះថា **ញុាំងអត្តភាពដោយបាយមួយដុំ** ។ សូម្បីក្នុងអចេលប្រភេទ **ទទួលភត្តក្នុងផ្ទះ ២ ខ្នង** ជាដើម ក៏មានន័យនេះឯង ។

បទថា **ឯកិស្សាបិ ទត្តិយា** បានដល់ ក្នុងភាជន៍តូចតែមួយ (ឯកាយ ទត្តិយា) ។ ដែលឈ្មោះថា **ទត្តិ** (ភាជន៍តូច) បានដល់ ភាជន៍តូចៗ ដែលគេដាក់ភត្តដ៏ច្រើន ។ បទថា **ឯកាហិតំ** (រំលងមួយថ្ងៃ) បានដល់ ស៊ីអាហារដែលរំលងមួយថ្ងៃ ។ បទថា **អឌ្ឍមាសិកំ** (រំលងកន្លះខែ) បានដល់ ស៊ីអាហារដែលរំលងកន្លះខែ ។ បទថា **បរិយាយភត្តភោជនំ** (ផ្លាស់ប្តូរនូវការបរិភោគភត្ត) បានដល់ ការបរិភោគភត្តដែលគេប្រគេនតាមវារៈ គឺ ការបរិភោគភត្តដែលគេនាំមកឲ្យតាមវារៈគ្នាយ៉ាងនេះ គឺ តាមវារៈ ១ ថ្ងៃ តាមវារៈ ២ ថ្ងៃ តាមវារៈ ៧ ថ្ងៃ តាមវារៈកន្លះខែ ។ បទថា **សាកភក្ខោ** (មានបន្លែស្រស់ជាអាហារ) ជាដើម មានន័យដូចពោលហើយនោះឯង ។ បទថា **ឧព្ភដ្ឋកោ** (ជាអ្នកឈរតែម្យ៉ាង) បានដល់ ជាអ្នកឈរសម្រឹង (ឈរត្រង់ក្ដឹង) ។ បទថា **ឧក្កុដិកប្បធានមនុយុត្តោ** (ប្រកបសេចក្តីព្យាយាមក្នុងការអង្គុយច្រហោង) បានដល់ ជាអ្នកប្រកបសេចក្តីព្យាយាមក្នុងឥរិយាបថច្រហោង សូម្បីដើរ ក៏ដើរច្រហោង គឺ លោតៗ ទៅ ។ បទថា **កណ្ដកាបស្សយិកោ** (ជាអ្នកប្រើគ្រឿងទ្រនាប់មានបន្លា) សេចក្តីថា បោះបន្លាដែក ឬបន្លាធម្មតាទុកត្រង់ផែនដី ហើយក្រាលកំណាត់ស្បែកលើបន្លានោះ

ធ្វើឥរិយាបថ មានការឈរ និងការចង្ក្រមជាដើម ។ បទថា **សេយ្យំ** (ការដេក) បានដល់ សូម្បីកាលដេក ក៏សម្រេចការដេកដូចគ្នានោះឯង ។ (ការងូតទឹក) ក្នុងវេលាល្ងាចជាលើកទី ៣ ។ គេប្រកបការព្យាយាមចុះងូតទឹកមួយថ្ងៃ ៣ ដង គឺ ព្រឹក ពេលថ្ងៃ និងល្ងាច ដោយគិតថា យើងនឹងបណ្តែតបាប ។

បទថា **កាយេ កាយានុបស្សី** (ពិចារណាឃើញកាយក្នុងកាយ) ជាដើម គប្បីជ្រាបតាមន័យដែលពោលហើយក្នុងអដ្ឋកថាឯកនិបាត ក្នុងខាងក្រោយចុះ ។ បទថា **អយំ វុច្ចតិ ភិក្ខវេ មជ្ឈិមា បដិបទា** (ម្នាលភិក្ខុទាំងឡាយ នេះហៅថា មជ្ឈិមាបដិបទា) សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បដិបទានេះមិនចូលទៅជិតទីបំផុត ២ យ៉ាង គឺ កាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ។ ម្យ៉ាងទៀត បដិបទាដែលផុតចាកទីបំផុត គឺ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ គប្បីជ្រាបថា ជាមជ្ឈិមាបដិបទា ។

## ពណ៌នាកម្មបថបេយ្យាល

[១៥៩] បទថា **សមនុញ្ញោ** (ពេញចិត្ត) បានដល់ មានអធ្យាស្រ័យស្មើគ្នា ។ បទថា **រាគស្ស** (រាគៈ) បានដល់ រាគៈជាប់ក្នុងបញ្ចកាមគុណ ។ បទថា **អភិញ្ញាយ** (ដើម្បីដឹងក្រៃលែង) បានដល់ ដើម្បីដឹងដ៏ក្រៃលែង (អភិជានទត្ថំ) ។ វិបស្សនានោះឯង ព្រះមានព្រះភាគត្រាស់ទុកដោយសមាធិទាំង ៣ មានបទថា

*សុញ្ញតសមាធិ ជាដើម ។ ពិតណាស់ វិបស្សនាបានឈ្មោះទាំងនេះ ក៏ព្រោះ មិនមានការប្រកាន់ ថាទៀង និមិត្តថាទៀង និងសេចក្តីប្រាថ្នាថាទៀង ។ បទថា* ***បរិញ្ញាយ*** *(ដើម្បីកំណត់ដឹង) បានដល់ ដើម្បីកំណត់ដឹង (បរិជាននត្ថំ) សូម្បីក្នុង បទដ៏សេស ក៏មានន័យនេះឯង ។*

## ចប់តិកនិបាតវណ្ណនា

## ក្នុងអដ្ឋកថាអង្គុត្តរនិកាយ

## ឈ្មោះ មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសកសោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |